# ហិរញ្ញវត្ថុសាធារណៈ



បណ្ឌិត ហង់ ជួន ណារ៉ុន ២០០៩

ច៉ាទ្រឹក ហ្សឺលបែ - ដឺវ៉ាល់ឡុង

បោះពុម្ព ដោយមានការឧបត្ថម្ភគាំទ្រពីសំណាក់

**ធនាគារអភិវឌ្ឍន៍អាស៊ី**

មតិយោបល់ និង សេចក្តីសន្និដ្ឋានទាំងឡាយ
គឺជាមតិផ្ទាល់របស់អ្នកនិពន្ធ ដោយមិនឆ្លុះបញ្ចាំងនូវជំហរផ្លូវការ
របស់ **ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ** ឬ **ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ** ឡើយ
**(ហង់ជួន ណារ៉ុន)**

រូបនៅលើទំព័រទី១ គឺ រូបបដិមាករ «**ព្រះព្រហ្ម**» ដែលជាព្រះអាទិទេពមួយនៃអាទិទេពទាំងបីនៃលទ្ធិ **ព្រាហ្មណ៍** ។ «**ព្រះព្រហ្ម**» ជាអាទិទេពតុបតែងបង្កើតលោក និង មានឋានៈខ្ពង់ខ្ពស់ ។ «**ព្រះព្រហ្ម**» មាន៖

- មានព្រះភក្រ្ត ៤ និង មានដៃ ៤ ដែលកាន់កេតនភណ្ឌ ៤៖ ស្លាបព្រា ខ្យងស័ង្ខ ខ្សែផ្កាំ និង គម្ពីរវេទ ។
- បែងភាគពី **ឥស្វរៈ** ឬ មានកំណើតពីស៊ុតមាសធំអស្ចារ្យមួយ ។
- មានយានជំនិះ ជាសត្វ **ហង្ស** មានមហេសីឈ្មោះ **សរស្វតី** អាទិទេពនៃការសិក្សា និង មានបុត្របីព្រះអង្គ (ទក្សៈ ភិគុ សំឆ្យា) ។

(រូបចម្លាក់ដែលមានប្រភពពី **កម្ពុជា** ថតដោយ **ហង់ ជួន ណារ៉ុន** នៅសារមន្ទីរ **ហ្គីមេ** ទីក្រុងប៉ារីស)

# ហិរញ្ញវត្ថុសាធារណៈ


**បណ្ឌិត ហង់ ជួន ណារ៉ុន**

**ប៉ាទ្រិក ហ្ស៊ីលបែ - ជីវ៉ាល់ឡុង**






**ភ្នំពេញ ២០០៩**



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

បោះពុម្ពលើកទី ១

© រក្សាសិទ្ធិ គ.ស. ២០០៩

ដោយគ្រឹះស្ថានបោះពុម្ពផ្សាយ **ព្រះវិហារ**

បោះពុម្ពនៅភ្នំពេញ  ព្រះរាជាណាចក្រកម្ពុជា

លសខអ ១៣: ៩៧៨-៩៩៩៦៣-៥០៥-០-៤

ISBN-13: 978-99963-505-0-4

Copyright © 2009

All rights reserved

# មាតិកា

# ហិរញ្ញវត្ថុសាធារណៈ

## ផ្នែកទី ១

## ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈនៃព្រះរាជាណាចក្រកម្ពុជា


**ជំពូកទី ១- ក្របខ័ណ្ឌគតិយុត្តិ និងស្ថាប័ននៃចំណាយសាធារណៈ** ១

១- រដ្ឋធម្មនុញ្ញ ២

២- ក្រុមប្រឹក្សាធម្មនុញ្ញ ៨

៣- ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ៩

៤- តុលាការកំពូល និង យុត្តាធិការផ្សេងៗទៀត ៩

៥- គណៈរដ្ឋមន្ត្រី ១០

៦- រចនាសម្ព័ន្ធនៃរាជរដ្ឋាភិបាល ១២

៧- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ១២

៨- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ១៥

៩- ការរៀបចំដែនដី ១៦

១០- ធនាគារជាតិនៃកម្ពុជា ១៦

**ជំពូកទី ២- ចំណូលថវិកា: ប្រព័ន្ធសារពើពន្ធនៃព្រះរាជាណាចក្រកម្ពុជា** ២១

១- របបស្វ័យប្រកាស ២២

២- របបម៉ៅការ ២២

៣- ប្រភេទពន្ធ និង អាករ ២២

៤- ការពិពណ៌នាអំពីប្រភេទពន្ធនៅកម្ពុជា ២៥

៥- សមិទ្ធិកម្មសារពើពន្ធនៅកម្ពុជា ៣៦

**ជំពូកទី៣- ថវិកា: គោលការណ៍គន្លឹះ** ៤១

១- គោលការណ៍ជាសារវ័ន្ត ៤១

២- ការលើកលែងមិនអនុវត្តគោលការណ៍ជាសារវ័ន្ត ៤៩

**ជំពូកទី៤ - កម្មវិធីនីយកម្មនៃចំណាយថវិកា ៥៥**

១- ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ៥៥

២- គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ៥៦

៣- ការសម្របសម្រួលហិរញ្ញប្បទានដើម្បីអភិវឌ្ឍន៍ ៦៦

៤- ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម ៦៧

៥- ការព្យាករណ៍ម៉ាក្រូសេដ្ឋកិច្ច ៧២

៦- កម្មវិធីវិនិយោគសាធារណៈ ៨០

**ជំពូកទី៥ - ការរៀបចំថវិកា ៨៥**

១- ប្រតិទិនថវិកា ៨៥

២- ចំណាត់ថ្នាក់មុខងារនៃរដ្ឋបាលសាធារណៈ ៨៦

៣- ការរៀបចំថវិកាតាមកម្មវិធី និង តាមផ្នែក ៩៤

**ជំពូកទី៦ - ការអនុវត្តថវិកា ១១៣**

១- ការបែងចែកឥណទានថវិកា ១១៣

២- ការធ្វើវិសោធនកម្មថវិកា ១១៦

៣- កម្មវិធីសកម្មភាពជាអាទិភាព ១១៦

**ជំពូកទី៧ - ការគ្រប់គ្រងក្របខ័ណ្ឌមន្ត្រីរាជការ និង បញ្ជីបើកប្រាក់បៀវត្សរ៍ ១១៩**

១- ការគ្រប់គ្រងក្របខ័ណ្ឌមន្ត្រីរាជការ ១១៩

២- ការគណនាបន្ទុកបុគ្គលិកនៅក្នុងថវិកាជាតិ ១២៣

**ជំពូកទី៨ - ការត្រួតពិនិត្យការអនុវត្តថវិកា ១២៧**

១- តារាងប្រតិបត្តិការហិរញ្ញវត្ថុសាធារណៈ (TOFE) ១២៧

២- ការធ្វើហិរញ្ញប្បទានឱនភាពថវិកា ១៤០

**ជំពូកទី៩ - ទិដ្ឋភាពម៉ាក្រូសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ១៤៩**

១- ជញ្ជីងពាណិជ្ជកម្ម ១៤៩

២- ជញ្ជីងទូទាត់ចរន្ត ១៥១

៣- គណនីមូលធន ១៥៤

៤- គណនីហិរញ្ញវត្ថុ ១៥៤

៥- គោលនយោបាយសេដ្ឋកិច្ច ១៥៦

៦- គោលនយោបាយរូបិយវត្ថុ ១៥៦

៧- គោលនយោបាយថវិកា ១៥៦

៨- ការតាមដានត្រួតពិនិត្យសេដ្ឋកិច្ច ១៥៧

**ជំពូកទី១០- ការត្រួតពិនិត្យថវិកាក្រោយចំណាយ ១៦១**

១- អគ្គាធិការដ្ឋាននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ១៦១

២- អគ្គាធិការបច្ចេកទេសតាមវិស័យ ១៦៣

៣- នាយកដ្ឋានសវនកម្មផ្ទៃក្នុងរបស់ក្រសួង- ស្ថាប័ន ១៦៣

៤- សវនកម្មផ្ទៃក្រៅ និង អាជ្ញាធរសវនកម្មជាតិ ១៦៦

៥- រដ្ឋសភា ១៦៩

**ជំពូកទី១១- ការគ្រប់គ្រងបំណុល ១៧១**

១- និយមន័យ ១៧១

២- ការគ្រប់គ្រងបំណុលក្រៅប្រទេស ១៧៤

៣- ក្លឹបទីក្រុងប៉ារីស និង ការចរចាបំណុលឡើងវិញ ១៨១

៤- បំណុលក្រៅប្រទេសរបស់កម្ពុជា ១៨២

៥- ការពិពណ៌នាពីបំណុលក្រៅប្រទេសរបស់កម្ពុជា ១៨៥

៦- សមត្ថភាពសងបំណុលរបស់កម្ពុជា ១៩៧

**ជំពូកទី១២- ការវិនិយោគសាធារណ: ២០១**

១- ហិរញ្ញប្បទានក្រៅប្រទេសដោយផ្ទាល់ ២០១

២-វិនិយោគដោយហិរញ្ញប្បទានក្នុងស្រុក ២០៣

៣- ការទ្រទ្រង់ថវិកា ២០៥

**ជំពូកទី១៣- លទ្ធកម្មសាធារណ: ២០៧**

១- ក្របខ័ណ្ឌគតិយុត្តិ ២០៧

២- ក្របខ័ណ្ឌនៃកិច្ចព្រមព្រៀងម៉ារ៉ាកិច ២០៩
៣- ក្របខ័ណ្ឌគតិយុត្តិនៃព្រះរាជាណាចក្រកម្ពុជា ២១៤
៤- នីតិវិធីដោយឡែកក្នុងកិច្ចលទ្ធកម្មសេវាទីប្រឹក្សា ២៣៥
៥- ស្ថាប័នគ្រប់គ្រងលទ្ធកម្មសាធារណៈ ២៣៧
**ជំពូកទី១៤- ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ២៤៣**
**ជំពូកទី១៥- វិមជ្ឈការ វិសហមជ្ឈការ និង ឯកជនភាវូបនីយកម្ម ២៤៧**
១- និយមន័យរបស់រដ្ឋ ២៤៧
២-វិមជ្ឈការបច្ចេកទេស និង គ្រឹះស្ថានសាធារណៈ ២៤៩
៣-វិមជ្ឈការដែនដី និង រដ្ឋបាលថ្នាក់ក្រោមជាតិ ២៥៧
៤-វិស័យឯកជនរបស់រដ្ឋៈ ក្រុមហ៊ុនរដ្ឋ និង ក្រុមហ៊ុនចម្រុះ ២៦២
៥- ឯកជនភាវូបនីយកម្ម ២៦៤

## ផ្នែកទី ២

## គណនេយ្យសាធារណៈ

**ជំពូកទី១- អាណាប័ក និង គណនេយ្យករ ២៧៥**
១-វិសមិតភាពរវាងអាណាប័ក និង គណនេយ្យករ ២៧៥
២- ការអនុវត្តផ្ទុយនឹងគោលការណ៍វិសមិតភាពរវាងអាណាប័ក និង គណនេយ្យករ ២៨៩
**ជំពូកទី២- ការត្រួតពិនិត្យហិរញ្ញវត្ថុ ២៩៥**
១- តួនាទីរបស់មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ២៩៥
**ជំពូកទី៣- ប្រតិបត្តិការរតនាគារ ៣០១**
១- រតនាគារ ៣០១
២- ប្រតិបត្តិការរតនាគារ ៣០២
៣- និក្ខិត្តកររតនាគារ ៣០៣
**ជំពូកទី៤- ការទទួលខុសត្រូវរបស់តួអង្គផ្សេងៗ ៣០៥**
១- ការទទួលខុសត្រូវរបស់អាណាប័ក ៣០៥

២- ការទទួលខុសត្រូវរបស់មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ៣០៦
៣- ការទទួលខុសត្រូវរបសគណនេយ្យករ (និង រជ្ជទេយ្យករ) ៣០៦
៤- ការទទួលខុសត្រូវរបស់តួអង្គផ្សេងៗទៀត ៣០៦
**ជំពូកទី៥ - គណនេយ្យសាធារណៈ ៣០៧**
១- គណនេយ្យរដ្ឋបាលអាណាប័ក ៣០៧
២- គណនេយ្យរបស់មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ៣០៧
៣- គណនេយ្យរជ្ជទេយ្យ ៣០៧
៤- គណនេយ្យរបស់រដ្ឋ ៣០៨
៥- គណនេយ្យពិសេស ៣១០
៦- លទ្ធផលប្រចាំឆ្នាំ និង គណនីនៅចុងឆ្នាំ ៣១១

## ផ្នែកទី ៣

## ការគ្រប់គ្រងហិរញ្ញវត្ថុតាមប្រព័ន្ធព័ត៌មានវិទ្យា

១- ដែនអនុវត្ត ៣១៣
២- ទម្រង់នៃប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យាលើវិស័យហិរញ្ញវត្ថុសាធារណៈ ៣១៥
៣- ម៉ូឌុលផ្សេងៗទៀត ៣១៧

## ផ្នែកទី ៤

## កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

១- ចក្ខុវិស័យនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ៣២៥
២- កម្មវិធីសកម្មភាពកំណែទម្រង់ ៣៣០
៣- យុទ្ធសាស្ត្រៈ ការអនុវត្តជាដំណាក់កាល ដើម្បីកសាងម្តងមួយជំហានម្តងៗ ៣៣២
៤- កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទីមួយ ៣៣៤
៥- ផែនការសកម្មភាពសម្រាប់ដំណាក់កាលទីមួយ ៣៣៥

៦- ក្របខ័ណ្ឌនៃការគ្រប់គ្រងការអនុវត្ត ៣៣៧

៧- ការអភិវឌ្ឍស្ថាប័ន និង រចនាសម្ព័ន្ធ ៣៣៨

៨- ការសម្របសម្រួលរបស់ដៃគូអភិវឌ្ឍន៍ និងការប្រមូលជំនួយ ៣៣៩

**ឧបសម្ព័ន្ធទី១ - ឯកសារស្រាវជ្រាវ ៣៤១**

**ឧបសម្ព័ន្ធទី២ - មាតិកាថវិកា និង មាតិកាគណនេយ្យឆ្នាំ ២០០៧ ៣៤៣**

**ឧបសម្ព័ន្ធទី៣ - ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ៣៧៥**

**អ្នកនិពន្ធ ៤១៥**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

**ហិរញ្ញវត្ថុសាធារណៈ** ដើរតួនាទីយ៉ាងសំខាន់នៅក្នុងគោលនយោបាយអភិវឌ្ឍន៍ជាតិ និងជាឧបករណ៍ដ៏ស័ក្តិសិទ្ធិក្នុងការអនុវត្តនូវកម្មវិធីនយោបាយរបស់ **រាជរដ្ឋាភិបាលកម្ពុជា** ដូចជា «**យុទ្ធសាស្ត្រចតុកោណ**» និង «**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ**» ដោយប្រើប្រាស់ **ថវិកាជាតិ** ជាឧបករណ៍គោលនយោបាយ ។ ម៉្យាងវិញទៀត **ហិរញ្ញវត្ថុសាធារណៈ** គឺជាមូលដ្ឋានសម្រាប់ការរៀបចំ និង ការអនុវត្តនូវ **គោលនយោបាយហិរញ្ញវត្ថុសាធារណៈ** ដែលជាចំណែកមួយយ៉ាងសំខាន់នៃគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច នៅក្នុងបរិការណ៍នៃដុល្លារភាវូបនីយកម្មកម្រិតខ្ពស់ដូចនៅកម្ពុជា ដែល **គោលនយោបាយរូបិយវត្ថុ** គឺជាឧបករណ៍បន្ទាប់បន្សំប៉ុណ្ណោះក្នុងការដោះស្រាយវិបត្តិសេដ្ឋកិច្ច ។

**រាជរដ្ឋាភិបាលកម្ពុជា** បានអនុវត្តជាច្រើនដំណាក់កាលរួមមកហើយ នូវកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ ដែលចាប់ផ្តើមចាប់តាំងពីនីតិកាលទីមួយនៃរដ្ឋសភា គឺនៅក្នុងឆ្នាំ ១៩៩៣ ។ ទំនើបភាវូបនីយកម្មនៃថវិកាជាតិ គឺជាតម្រូវការដ៏ចាំបាច់ និងជាចំណែកមួយយ៉ាងសំខាន់នៃទំនើបភាវូបនីយកម្មនៃការគ្រប់គ្រងរដ្ឋ ។ ក្នុងន័យនេះ ខ្ញុំបានដាក់ចេញនៅក្នុងនីតិកាលទីបីកន្លងទៅនេះ នូវ **កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ** ហើយដំណាក់កាលទីមួយត្រូវបានអនុវត្តប្រកបដោយជោគជ័យ ។ នៅក្នុងខែ ធ្នូ ឆ្នាំ ២០០៨ កន្លងទៅនេះ រាជរដ្ឋាភិបាលកម្ពុជាបានចាប់ផ្តើមអនុវត្ត **កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ** ដំណាក់កាលទីពីរទៀត ។

ក្នុងន័យនេះ ខ្ញុំសូមអបអរសាទរចំពោះ បណ្ឌិត **ហង់ ជួន ណារ៉ុន** និង លោក **ប៉ាទ្រិក ហ្ស៊ីលបែ-ជីទ៉ាល់ឡុង** ដែលបាននិពន្ធចងក្រងសៀវភៅ «**ហិរញ្ញវត្ថុសាធារណៈ**» នេះឡើង ដើម្បីចែករំលែកនូវប្រាជ្ញាញាណក្នុងគោលដៅផ្សព្វផ្សាយអោយបានទូលំទូលាយទាំងក្នុងកម្រិតជាតិ និងអន្តរជាតិ នូវបទពិសោធន៍ល្អៗរបស់កម្ពុជាក្នុងការអនុវត្តយ៉ាងស៊ីជម្រៅនូវកម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ ដើម្បីឈានទៅសម្រេចឱ្យបាននូវនិយាមអន្តរជាតិ ។

ខ្ញុំសង្ឃឹមថាសៀវភៅ «**ហិរញ្ញវត្ថុសាធារណៈ**» នេះនឹងចូលរួមវិភាគទានក្នុងការស្រាវជ្រាវ និងពិភាក្សាដើម្បីពង្រីក និងចែករំលែកនូវ **ពុទ្ធិ** សំខាន់ៗពាក់ព័ន្ធនឹងវិស័យហិរញ្ញវត្ថុសាធារណៈ ជាពិសេសក្នុងការអនុវត្តនូវកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈដំណាក់កាលទីពីរនេះ ។

**ហ៊ុន សែន**

# ហិរញ្ញវត្ថុសាធារណៈ

## ផ្នែកទី ១

## ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈនៃព្រះរាជាណាចក្រកម្ពុជា

## ជំពូកទី ១

## ក្របខ័ណ្ឌគតិយុត្តិ និងស្ថាប័ននៃចំណាយសាធារណៈ

នាពេលបច្ចុប្បន្ននេះ គេតែងតែបែងចែកប្រព័ន្ធគតិយុត្តិ ជាបួនក្រុមធំៗ គឺ ÷

- **ប្រព័ន្ធ រ៉ូម៉ាំង-អាឡឺម៉ង់** ឬហៅម្យ៉ាងទៀតថា នីតិសរសេរ ឬ **ប្រព័ន្ធ ច្បាប់រដ្ឋប្បវេណី** ។
- **ប្រព័ន្ធច្បាប់ កុំម៉ុនវែល** ដែលគេតែងតែនិយាយថាជាប្រព័ន្ធ **អង់គ្លោ-សាក់សុង** ឬហៅម្យ៉ាងទៀតថា *ប្រព័ន្ធនៃយុត្តាធិការ* ។
- **ប្រព័ន្ធ ច្បាប់សាសនា** និង
- **ប្រព័ន្ធ ច្បាប់ទំនៀមទម្លាប់**

បណ្ដាប្រទេសមួយចំនួន ប្រើប្រាស់ប្រព័ន្ធនីតិចម្រុះរវាងប្រព័ន្ធ **ច្បាប់រដ្ឋប្បវេណី** និងប្រព័ន្ធ*ទំនៀមទម្លាប់* ឬ *ប្រព័ន្ធច្បាប់រដ្ឋប្បវេណី* និង **កុំម៉ុនវែល** ដូចជានៅកេបិក និងអាហ្សង់ទីន ។ល។

លក្ខណៈពិសេសនៃប្រព័ន្ធ **រ៉ូម៉ាំង-អាឡឺម៉ង់** ដែលកម្ពុជាប្រើប្រាស់ មានដូចខាងក្រោម÷

- ការប្រើប្រាស់សញ្ញាណអរូបី
- ការបង្កើតវិធានទូទៅ
- ការបែងចែកចែករវាងវិធានជាសារវ័ន្ត និង នីតិវិធីច្បាប់

លក្ខណៈពិសេសនៃប្រព័ន្ធ **កុំម៉ុនវែល** គឺ÷

- ឧត្តមភាពនៃយុត្តាធិការ

- ការជាន់គ្នារវាងវិធានជាសារវ័ន្ត និង នីតិវិធីច្បាប់ ។

យោងតាមការសិក្សាស្រាវជ្រាវនៃសាកលវិទ្យាល័យ **អូតាវ៉ា** (wwww.uottawa.ca/world-legal-systems) នៅឆ្នាំ១៩៩៨ មានប្រជាជនលើពិភពលោកប្រហែលមួយភាគបីប្រើប្រាស់ប្រព័ន្ធកុំម៉ុនវែល ដូចជាសហរដ្ឋអាមេរិក និងបណ្តាប្រទេសកុំម៉ុនវែលជាដើម ។ យោងតាមការស្រាវជ្រាវដដែលនេះដែរ ប្រព័ន្ធ *ច្បាប់រដ្ឋប្បវេណី* មានប្រហែល ៦០%នៃចំនួនប្រជាជនពិភពលោក ហើយពេលខ្លះនៅមានលាយឡំនឹងប្រព័ន្ធច្បាប់ទំនៀមទំលាប់ផងដែរ ដូចជានៅទ្វីបអ៊ឺរ៉ុប ទ្វីបអាហ្វ្រិក លើកលែងបណ្តាប្រទេសដែលប្រកាន់នូវប្រព័ន្ធច្បាប់សាសនា និងប្រព័ន្ធច្បាប់រដ្ឋប្បវេណី ដូចជាប្រទេស អាមេរិកឡាទីន និងអាស៊ី និងបណ្តាប្រទេសដែលប្រកាន់ប្រព័ន្ធច្បាប់សាសនា ឬ ប្រព័ន្ធច្បាប់រដ្ឋប្បវេណី ។

នាកំឡុងសហស្សវត្សទីមួយ ប្រព័ន្ធច្បាប់កម្ពុជាបានទទួលឥទ្ធិពលខ្លាំងពីប្រទេសឥណ្ឌា ជាពិសេសផ្នែកសាសនា ។ ការរៀបចំចងក្រងក្រមច្បាប់នៅប្រទេសកម្ពុជា មានតាំងពីយូរយារណាស់មកហើយ ៖ គឺតាំងពីរជ្ជកាលព្រះបាទជ័យជេដ្ឋា (សូមមើលអត្ថបទយោង: **សេចក្តីផ្តើមនៃនីតិខ្មែរ)** និងត្រូវបានកែសំរួលដោយព្រះរាជានៅសម័យកាលក្រោយៗ និង លេចជារូបរាងកម្រងច្បាប់នារជ្ជកាលព្រះបាទអង្គឌួង នៅឆ្នាំ ១៨៦០ ។ ក្រមទាំងនេះរៀបរាប់ពីកម្រងយុត្តិសាស្ត្រ ដែលអាចនិយាយបានថាជាប្រព័ន្ធ **កុំម៉ុនវែល** រួមបញ្ចូលនឹងច្បាប់សាសនា ។

ការបោះពុម្ពផ្សាយក្រមទាំងនោះ គឺនៅមុនអាណាព្យាបាលបារាំងបន្តិច (១៨៨៤) ពី ១៨៨១ ក្នុងរជ្ជកាលព្រះបាទនរោត្តម ។ ការប្តូរមកជាប្រព័ន្ធរ៉ូម៉ាំង-អាល្លឺម៉ង់ គឺចាប់ផ្តើមពីឆ្នាំ ១៩១១ ដោយមានការដាក់ឱ្យប្រើប្រាស់នូវក្រមរដ្ឋប្បវេណី ក្រមនីតិវិធីរដ្ឋប្បវេណី និងស្ថាប័នយុត្តាធិការ ។ ចាប់ពីឯករាជ្យ ឆ្នាំ ១៩៥៣ មក នីតិកម្ពុជាបានវិវត្តដោយស្វ័យភាព ព្រមទាំងមានដំណាក់កាល ដែលបញ្ជាក់អំពីព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រ ៖ របបខ្មែរក្រហម និងរបបសាធារណៈរដ្ឋប្រជាមានិតកម្ពុជា ។ បច្ចុប្បន្ននេះ នីតិកម្ពុជា មានស្នេហភាពក្នុងប្រព័ន្ធរ៉ូម៉ាំង-អាល្លឺម៉ង់ ។

### ១- រដ្ឋធម្មនុញ្ញ

រដ្ឋធម្មនុញ្ញចែងពីហិរញ្ញវត្ថុសាធារណៈ ក្នុងកម្រិតណាមួយដែលពាក់ព័ន្ធនឹងបទប្បញ្ញត្តិស្តីពីហិរញ្ញវត្ថុសាធារណៈ ជាពិសេសក្នុងឋានានុក្រមនៃច្បាប់ ពន្ធ និងថវិការដ្ឋ ការដាក់អោយចូលជាធរមាន និងការបោះពុម្ពផ្សព្វផ្សាយច្បាប់ (ជាពិសេសច្បាប់ពាក់ព័ន្ធនឹងវិស័យហិរញ្ញវត្ថុ) ដើម្បីអោយច្បាប់ទាំងនេះអាចអនុវត្តនិងតវ៉ាបាន រួមទាំងច្បាប់ទូទាត់ថវិការរដ្ឋ និង ថវិការបស់ស្ថាប័នជាដើម ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ១.១. ច្បាប់អង្គការ

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣ បានចែងអំពីច្បាប់អង្គការចំនួនបី គឺ ÷ ច្បាប់ស្តីពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម (មាត្រា ១៣៤ថ្មី), ច្បាប់ស្តីពីក្រុមប្រឹក្សាធម្មនុញ្ញ (មាត្រា១៤៤ថ្មី) និង ច្បាប់ស្តីពីការរៀបចំរដ្ឋបាលដែនដី (មាត្រា ១៤៧ថ្មី) ។

ភាពខុសគ្នារវាងច្បាប់អង្គការ និងច្បាប់ធម្មតា គឺ ច្បាប់អង្គការត្រូវតែបញ្ជូនទៅក្រុមប្រឹក្សាធម្មនុញ្ញ ពិនិត្យសិន មុននឹងប្រកាសឱ្យប្រើប្រាស់ (មាត្រា ១៤០ថ្មី) ដូចជាបទបញ្ញត្តិក្នុងរដ្ឋសភាជាតិ និងព្រឹទ្ធសភា ។ ក្រោយពីប្រកាសឱ្យប្រើប្រាស់ រាល់ច្បាប់ទាំងអស់អាចត្រូវបានពិនិត្យពីធម្មនុញ្ញភាព ដោយក្រុមប្រឹក្សាធម្មនុញ្ញ តាមសំណើរបស់ព្រះមហាក្សត្រ ប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា សមាជិកព្រឹទ្ធសភាចំនួន ១/៤ តំណាងរាស្ត្រ ចំនួន ១/១០ ឬ តុលាការ (មាត្រា១៤១ថ្មី) ។

ឧត្តមភាពនៃច្បាប់អង្គការលើច្បាប់ធម្មតា គឺស្តែងឡើងដោយឯកឯង ពោលគឺតាមរយៈទ្រឹស្តី ដែលជាប្រភពមួយនៃច្បាប់ដូចរដ្ឋធម្មនុញ្ញដែរ ច្បាប់ យុត្តាធិការ និងទំនៀមទម្លាប់ ។

រដ្ឋធម្មនុញ្ញ ហាក់ពុំសូវមានចែងច្បាស់លើផ្នែកហិរញ្ញវត្ថុសាធារណៈឡើយ ។

## ១.២. ពន្ធ និង ថវិការដ្ឋ

«ការយកពន្ធដារនឹងអាចធ្វើទៅបាន លុះត្រាតែមានចែងក្នុងច្បាប់ ។ ថវិការដ្ឋត្រូវបានអនុវត្តដោយ អនុលោមទៅតាមច្បាប់ ។ ការគ្រប់គ្រងរូបិយប័ណ្ណបរទេស និង ការគ្រប់គ្រងប្រព័ន្ធហិរញ្ញវត្ថុត្រូវកំណត់ក្នុងច្បាប់» (មាត្រា ៥៧ នៃរដ្ឋធម្មនុញ្ញ) ។

«...រដ្ឋសភាអនុម័តថវិការដ្ឋ ផែនការរដ្ឋ ការផ្តល់កម្ចី ការសុំខ្ចី ការធានាផ្នែកហិរញ្ញវត្ថុ និងការបង្កើត ឬ កែប្រែ ឬលើកលែងពន្ធ» (មាត្រា ៩០ថ្មី នៃរដ្ឋធម្មនុញ្ញ) ។

បទប្បញ្ញត្តិទាំងនេះមានវិសាលភាពគ្រប់ដណ្តប់លើការរៀបចំរដ្ឋបាលដែនដី និងវិមជ្ឈការ ដែលយើងនឹង ឃើញនៅក្នុងផ្នែកខាងក្រោយនៃសៀវភៅនេះ ។

## ១.៣. ច្បាប់ស្តីពីការទូទាត់ថវិការដ្ឋ

«រដ្ឋសភាផ្តល់សេចក្តីយល់ព្រមលើគណនីរដ្ឋបាល...» (មាត្រា ៩០ថ្មី នៃរដ្ឋធម្មនុញ្ញ)។

**សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ :**

«សមាជិកព្រឹទ្ធសភា សមាជិករដ្ឋសភា និង នាយករដ្ឋមន្ត្រី មានសិទ្ធិផ្តួចផ្តើមគំនិតធ្វើច្បាប់» (មាត្រា ៩១ ថ្មីនៃរដ្ឋធម្មនុញ្ញ) ។

នាយករដ្ឋមន្ត្រីរៀបចំសេចក្តីព្រាងច្បាប់ ។

រដ្ឋសភា ឬ ព្រឹទ្ធសភារៀបចំសេចក្តីស្នើច្បាប់ ។

## ១.៤. ការអនុម័តលើសេចក្តីព្រាងច្បាប់ និង សេចក្តីស្នើច្បាប់ (ហិរញ្ញវត្ថុ)

«ព្រឹទ្ធសភាពិនិត្យហើយឱ្យយោបល់ក្នុងរយៈពេលមួយខែយ៉ាងយូរ លើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ដែលរដ្ឋសភាបានអនុម័តយល់ព្រមលើកដំបូង...។ បើជាការប្រញាប់ រយៈពេល នោះត្រូវបន្ថយមកនៅត្រឹមតែប្រាំថ្ងៃ» (មាត្រា ១១៣ ថ្មី នៃរដ្ឋធម្មនុញ្ញ) ។

«បើព្រឹទ្ធសភាសុំឱ្យកែសម្រួលសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់នោះរដ្ឋសភាត្រូវយកមកពិចារណាភ្លាមជាលើកទីពីរ ។ រដ្ឋសភាត្រូវពិនិត្យ និងសម្រេចតែត្រង់បទប្បញ្ញត្តិ ឬចំណុចណាដែលព្រឹទ្ធសភាសុំឱ្យកែសម្រួល ដោយបដិសេធចោលទាំងមូល ឬទុកជាបានការខ្លះ ។ ការបង្វិលទៅបង្វិលមករវាងព្រឹទ្ធសភា និងរដ្ឋសភា ត្រូវធ្វើតែក្នុងរយៈពេលមួយខែ ។ រយៈពេលនេះត្រូវបន្ថយមកត្រឹមដប់ថ្ងៃ បើត្រូវពិនិត្យសម្រេច ពីថវិកាជាតិ និងហិរញ្ញវត្ថុ ហើយមកត្រឹមតែពីរថ្ងៃបើជាការប្រញាប់ ។

បើរដ្ឋសភាទុកឱ្យហួសរយៈពេលកំណត់ ឬពន្យារពេលដែលកំណត់ទុកសម្រាប់ពិនិត្យនោះ រយៈពេលជាគោលការណ៍សម្រាប់រដ្ឋសភា និង ព្រឹទ្ធសភាត្រូវបន្ថែមឱ្យស្មើគ្នាដែរ ។

បើព្រឹទ្ធសភាបដិសេធសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់នោះជាអសារបង់ រដ្ឋសភាមិនអាចនឹងយកមកពិចារណាជាលើកទីពីរបានមុនរយៈពេលមួយខែទេ ។ រយៈពេលនេះ ត្រូវបន្ថយមកត្រឹមដប់ប្រាំថ្ងៃ បើពិនិត្យថវិកាជាតិ និងហិរញ្ញវត្ថុ ហើយមកត្រឹមតែបួនថ្ងៃ បើជាការប្រញាប់ ។

**សម្លេងភាគច្រើនដាច់ខាត សម្លេងភាគច្រើនធម្មតា និង សម្លេងភាគច្រើនលើសលប់**

- សម្លេងភាគច្រើនដាក់ខាត: សម្លេងច្រើនជាងពាក់កណ្តាល ។
- សម្លេងភាគច្រើនធម្មតា (ឬប្រៀបធៀប): ដែលមានសម្លេងច្រើនជាង (មានបេក្ខជនលើសពី ២ នាក់) ។
- សម្លេងភាគច្រើនលើសលប់: សម្លេងភាគច្រើនដែលមានលក្ខណៈស្មុគ្រស្មាញជាងសម្លេងភាគច្រើនដាច់ខាត ។ ឧទាហរណ៍ សម្លេង ២/៣ ករណីការផ្តើមគំនិតសើរើ ឬ វិសោធនកម្មរដ្ឋធម្មនុញ្ញ (មាត្រា ១៥១ ថ្មី នៃរដ្ឋធម្មនុញ្ញ) ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

***ការគណនារយៈពេលអនុម័តលិខិតបទដ្ឋានថវិកា និង ច្បាប់ស្តីពីហិរញ្ញវត្ថុ***

**ករណីទី ១ : ការប្រកាសប្រញាប់ និងករណីព្រឹទ្ធសភាមិនស្នើឱ្យកែសម្រួល**

ព្រឹទ្ធសភាមានរយៈពេលប្រាំថ្ងៃសម្រាប់ពិចារណាសេចក្តីព្រាងច្បាប់ ដែលបញ្ជូនដោយរដ្ឋសភា ។ យើងអាចសន្មតថា រដ្ឋសភាមានរយៈពេលដូចគ្នាសម្រាប់ពិចារណាលើសេចក្តីព្រាងច្បាប់ដែលបញ្ជូនដោយនាយករដ្ឋមន្ត្រី ។

- នាយករដ្ឋមន្ត្រីបញ្ជូនអត្ថបទសេចក្តីព្រាងច្បាប់ : ថ្ងៃទី J
- ចាប់ផ្តើមរាប់ថិរវេលាសម្រាប់ពិចារណាដោយរដ្ឋសភា: J (គិតទាំងថ្ងៃធ្វើការ និង ថ្ងៃឈប់)
- បន្ទាប់ចប់ថិរវេលាដែលពិចារណាដោយរដ្ឋសភា: J + ៥
- ពិចារណាដោយព្រឹទ្ធសភា: J + ៥ + ៥ = J +១០ ថ្ងៃ

**ករណីទី ២ : ការប្រកាសប្រញាប់ និងករណីព្រឹទ្ធសភាស្នើឱ្យកែសម្រួល**

- នាយករដ្ឋមន្ត្រីបញ្ជូនអត្ថបទសេចក្តីព្រាងច្បាប់: ថ្ងៃទី J
- ចប់ថិរវេលាពិចារណា ដោយរដ្ឋសភា: J + ៥
- រដ្ឋសភា ពិនិត្យលើកទីពីរលើអត្ថបទកែសម្រួល: J + ៥ +៥ + ២ = ១២ ថ្ងៃ ប្រសិនបើយល់ព្រម
- ព្រឹទ្ធសភា ពិនិត្យលើកទីពីរលើអត្ថបទកែសម្រួល: J + ៥ + ៥ + ៤ = ១៤ ថ្ងៃ ប្រសិនបើបដិសេធ

**ករណីទី ៣ : ករណីធម្មតា និងករណីព្រឹទ្ធសភាមិនស្នើឱ្យកែសម្រួល**

- នាយករដ្ឋមន្ត្រី បញ្ជូនអត្ថបទសេចក្តីព្រាងច្បាប់: J
- ចាប់ផ្តើមគិតថិរវេលាពិចារណា ដោយរដ្ឋសភា: J (ពុំមែនជាថ្ងៃកាលបរិច្ឆេទ)
- ចប់ថិរវេលាពិចារណា ដោយរដ្ឋសភា: J + ១ខែ
- ពិចារណាដោយព្រឹទ្ធសភា: J + ១ខែ + ១ខែ = J + ២ ខែ

**ករណីទី ៤ : ករណីធម្មតា និងករណីព្រឹទ្ធសភាស្នើឱ្យកែសម្រួល**

- នាយករដ្ឋមន្ត្រី បញ្ជូនអត្ថបទសេចក្តីព្រាងច្បាប់: J
- ចប់ថិរវេលាពិចារណា ដោយរដ្ឋសភា: J + ១ខែ
- ចាប់ផ្តើមគិតថិរវេលាពិចារណា ដោយរដ្ឋសភា: J + ១ខែ + ១ខែ

ក្នុងការពិនិត្យសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ជាលើកទី២នេះ រដ្ឋសភាត្រូវអនុម័តដោយវិធីបោះឆ្នោតចំហ និងយកតាមមតិភាគច្រើនដាច់ខាត» (មាត្រា ១១៣ថ្មី នៃរដ្ឋធម្មនុញ្ញ)។

ថិរវេលាតិចបំផុតក្នុងការទទួលបានការយល់ព្រមលើច្បាប់ហិរញ្ញវត្ថុដោយសភា (រដ្ឋសភា និងព្រឹទ្ធសភា) គឺ ១០ ថ្ងៃ (សម្រាប់ការប្រកាសជាការប្រញាប់) និង យ៉ាងយូរបំផុត ២ ខែ កន្លះ ។

## ១.៥. ការប្រកាសអោយប្រើច្បាប់

«ព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខាលើព្រះរាជក្រមប្រកាសឱ្យប្រើរដ្ឋធម្មនុញ្ញ ច្បាប់ដែលរដ្ឋសភា


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

***ការប្រកាសអោយប្រើប្រាស់ច្បាប់***

ព្រះមហាក្សត្រឡាយព្រះហត្ថលេខាលើរាជក្រម ដើម្បីអោយច្បាប់ចូលជាធរមាន និង ប្រកាសដាក់អោយប្រើប្រាស់ជាផ្លូវការនូវច្បាប់ទាំងឡាយ ។

បានអនុម័ត និង ព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់រួចហើយ...» (មាត្រា ២៨ ថ្មី នៃរដ្ឋធម្មនុញ្ញ) ។

ថិរវេលាខ្លីបំផុតសម្រាប់អនុម័តយល់ព្រមច្បាប់ហិរញ្ញវត្ថុ ដោយសភា (រដ្ឋសភា និងព្រឹទ្ធសភា) គឺ ១០ថ្ងៃ (ប្រកាស់ប្រញាប់) និងយូរបំផុត គឺ ២ខែ ១៥ថ្ងៃ ។

## ១.៦. ការចូលជាធរមាននៃច្បាប់

***អានុភាពតតាំងនៃច្បាប់ និង វិធានផ្សព្វផ្សាយ***

យើងអាចនិយាយបានថា តាមន័យនៃមាត្រា ៩៣ ថ្មី រដ្ឋធម្មនុញ្ញ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ច្បាប់ដែលមានអានុភាពតតាំងជាមួយតតីយជនបាន លុះត្រាណាច្បាប់នោះត្រូវបានប្រកាសអោយប្រើប្រាស់ និង ផ្សព្វផ្សាយ នៅក្នុងរាជកិច្ច ហើយរាជកិច្ចនេះត្រូវតែត្រូវបានចែកផ្សាយទូទាំងប្រទេសនៃព្រះរាជាណាចក្រកម្ពុជា ។

ថេរវេលានៃការផ្សព្វផ្សាយ គឺ នៅរាជធានីភ្នំពេញ មានរយៈពេលដប់ថ្ងៃគត់ក្រោយពីថ្ងៃប្រកាសអោយប្រើ និង នៅទូទាំងប្រទេស មានរយៈពេលម្ភៃថ្ងៃគត់ ក្រោយពីថ្ងៃប្រកាសអោយប្រើ ។ ក្នុងករណីដែលប្រកាសអោយប្រើជាប្រញាប់ ត្រូវផ្សព្វផ្សាយភ្លាមនៅថ្ងៃប្រកាសអោយប្រើ ។

«ច្បាប់ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់រួចហើយ ហើយត្រូវបានព្រះមហាក្សត្រទ្រង់ឡាយព្រះហស្ថលេខាប្រកាសឱ្យប្រើ ត្រូវចូលជាធរមាននៅរាជធានីភ្នំពេញ ក្នុងរយៈពេលដប់ថ្ងៃគត់ក្រោយពីថ្ងៃប្រកាសឱ្យប្រើ និងនៅទូទាំងប្រទេសរយៈពេលម្ភៃថ្ងៃគត់ក្រោយពីថ្ងៃប្រកាសឱ្យប្រើ ។ ប៉ុន្តែបើច្បាប់នេះបានចែងថាជាការប្រញាប់ ច្បាប់នេះត្រូវចូលជាធរមានភ្លាមនៅទូទាំងប្រទេសក្រោយពីថ្ងៃប្រកាសឱ្យប្រើ ។

***លិខិតបទដ្ឋានជាលក្ខណៈបុគ្គល លិខិតបទដ្ឋានមានលក្ខណៈជាបទបញ្ជា***

***លិខិតបទដ្ឋានមានលក្ខណៈជាបុគ្គលៈ*** មានគោលដៅបង្កើតអានុភាពជាប្រយោជន៍ចំពោះបុគ្គលម្នាក់ជាក់លាក់ ឬ ចំពោះបុគ្គលច្រើនគ្នា ដូចជាលិខិតបទដ្ឋានតែងតាំង ឬ តម្លើងឋានន្តរសក្តិ ។ លិខិតនេះមានទំនាក់ទំនងផ្ទាល់នឹងម្ចាស់ខ្លួន និង មានអានុភាពតតាំង ហើយពុំតម្រូវអោយចុះផ្សាយនៅក្នុងរាជកិច្ចទេ ។

***លិខិតបទដ្ឋានមានលក្ខណៈជាបទបញ្ជាៈ*** មានអានុភាពទូទៅ និង មិនចំពោះ ហើយត្រូវចុះផ្សាយនៅក្នុងរាជកិច្ចសម្រាប់បញ្ជាក់អំពីអានុភាពតតាំង ។



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

***វិធានចូលជាធរមាន និង ចុះផ្សាយអត្ថបទច្បាប់ និងបទបញ្ជា និង ការផ្សព្វផ្សាយនៅបណ្តាប្រទេសផ្សេងៗ***

ប្រទេសបារាំងបង្កើតលក្ខណៈទំនើបកម្មនៃនីតិវិធានច្បាប់របស់ខ្លួន យោងតាមសេចក្តីសម្រេចលេខ ២០០៤-១៦៤ ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០០៤ «ស្តីពីបែបបទ និងអានុភាពនៃការចុះផ្សាយច្បាប់ និង លិខិតបទដ្ឋានរដ្ឋបាលមួយចំនួន»។

សេចក្តីសម្រេចអាចជំនួយច្បាប់បាន ដោយសារសភាបានផ្តល់នូវនីតិសម្បទាអោយរដ្ឋាភិបាល ដើម្បីបង្ករលក្ខណៈងាយស្រួលអនុវត្តច្បាប់ ជាពិសេសច្បាប់នៅសតវត្សទី ១៩ និង មានវិធានមួយចំនួននៅសម័យកាលប្រហែលគ្នា គឺបដិវត្ត (ឆ្នាំទី ១៤) ។ អត្ថបទច្បាប់ និង បទបញ្ជាដែលមានអត្ថន័យទូទៅ ចូលជាធរមាននៅថ្ងៃដែលកំណត់ ឬ មួយថ្ងៃក្រោយពីការចុះផ្សាយនៃច្បាប់នោះ ។ ការចូលជាធរមាន គឺនៅថ្ងៃដដែលនោះ ប្រសិនបើអាច ។ ការចុះផ្សាយដោយប្រព័ន្ធអេឡិចត្រូនិចមានអនុភាពដូចការចុះផ្សាយ «លើក្រដាសសៀវភៅដែរ»។

នៅបណ្តាប្រទេសអាហ្វ្រិកមួយចំនួនធំ ដែលប្រើប្រាស់ភាសាបារាំង មានវិធានចុះផ្សាយនៅក្នុងរាជកិច្ច ហើយថែមវិធានទីពីរ ហៅថា «ការប្រកាសអោយប្រើជាប្រញាប់» ដើម្បីកែក្លែងនូវភាពមិនប្រក្រតីនៃការចុះផ្សាយក្នុងរាជកិច្ច ។ ការប្រកាសអោយប្រើជាប្រញាប់ ប្រែប្រួលតាមពេលវេលា និង តាមប្រទេសនីមួយៗ ។ កាលពីអតីតកាល គឺការបិទផ្សាយនៅសាលាខេត្ត-ក្រុង ដែលមានអគ្គលេខាធិការនៃសាលាខេត្ត-ក្រុង មានតួនាទីចុះផ្សាយក្នុងព្រឹត្តិប័ត្រពិសេស ។ នាពេលថ្មីៗនេះ គឺជារបៀបនៃការចេញផ្សាយម្តង ឬ ច្រើនដងក្នុងសារព័ត៌មាន ដែលចែកផ្សាយទូលំទូលាយ និង/ឬ តាមរយៈវិទ្យុ និង/ឬ តាមរយៈទូរទស្សន៍ ។ ការចុះផ្សាយតាមប្រព័ន្ធអេឡិចត្រូនិចមាននៅប្រទេសមួយចំនួន ប៉ុន្តែហាក់ពុំទាន់មានអានុភាពតតាំង ដូចមធ្យោបាយចុះផ្សាយផ្សេងៗទៀតនៅឡើយ ដោយហេតុថា គ្មានអត្ថបទពេញលេញល្អ ។

ច្បាប់ដែលព្រះមហាក្សត្រទ្រង់បានឡាយព្រះហស្ថលេខា ប្រកាសឱ្យប្រើត្រូវចុះក្នុងរាជកិច្ច និងផ្សព្វផ្សាយទូទាំងប្រទេសឱ្យទាន់តាមពេលកំណត់ខាងលើ»។ (មាត្រា៩៣ នៃរដ្ឋធម្មនុញ្ញ)

យើងអាចសន្មតថា វិធានផ្សព្វផ្សាយ គឺដូចគ្នាដែរសម្រាប់បទដ្ឋានគតិយុត្តិមានលក្ខណៈជាបទបញ្ជា (មានអត្ថន័យទូទៅ) ៖ ច្បាប់ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីអំពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រីបានចែងក្នុងមាត្រា ១៣ ថា «លិខិតបទដ្ឋាននានាដែលមានអត្ថន័យទូទៅរបស់រាជរដ្ឋាភិបាល ត្រូវតែបានចុះផ្សាយក្នុងរាជកិច្ច »។

## ១.៧. ថវិកានៃរដ្ឋសភាព និង ព្រឹទ្ធសភា

មាត្រា ៨១ ថ្មី សម្រាប់រដ្ឋសភា និង ១០៥ថ្មី សម្រាប់ព្រឹទ្ធសភាបានចែងថា «ថវិកាស្វយ័តសម្រាប់ដំណើរការស្ថាប័នរបស់ខ្លួន »។

ផ្ទុយទៅវិញ រដ្ឋធម្មនុញ្ញពុំបានចែងទាល់តែសោះអំពីថវិការបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម (ជំពូកទី១១ ថ្មី) និងក្រុមប្រឹក្សាធម្មនុញ្ញ (ជំពូកទី ១២ ថ្មី) (សូមមើលខាងក្រោម) ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

### ១.៨. គណៈកម្មការជំនាញនៃរដ្ឋសភា

រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជាមានគណៈកម្មការជំនាញចំនួន ៩÷

- គណៈកម្មការសិទ្ធិមនុស្ស បណ្តឹង អង្កេត និងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា
- គណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម
- គណៈកម្មការផែនការ វិនិយោគ កសិកម្ម អភិវឌ្ឍន៍ជនបទ បរិស្ថាន និងធនធានទឹក
- គណៈកម្មការមហាផ្ទៃ ការពារជាតិ អង្កេត បោសសំអាត និងមុខងារសាធារណៈ
- គណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាន
- គណៈកម្មការ នីតិកម្ម និងយុត្តិធម៌
- គណៈកម្មការ អប់រំ យុវជន និង កីឡា កិច្ចការសាសនា វប្បធម៌ និងទេសចរណ៍
- គណៈកម្មការ សុខាភិបាល សង្គមកិច្ច អតីតយុវជន យុវនីតិសម្បទា ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងកិច្ចការនារី
- គណៈកម្មការ សាធារណការ ដឹកជញ្ជូន ទូរគមនាគមន៍ ប្រៃសណីយ៍ ឧស្សាហកម្ម រ៉ែ ពាណិជ្ជកម្ម រៀបចំដែនដី នគរូបនីយកម្ម និង សំណង់

គណៈកម្មការប្រហាក់ប្រហែលនេះ ក៏មាននៅព្រឹទ្ធសភាដែរ ។

## ២. ក្រុមប្រឹក្សាធម្មនុញ្ញ

ក្រុមប្រឹក្សាធម្មនុញ្ញបង្កើតឡើងដោយរដ្ឋធម្មនុញ្ញ ក្នុងជំពូកទី ៧ ថ្មី ។

«ក្រុមប្រឹក្សាធម្មនុញ្ញមានសមត្ថកិច្ចធានាការពារការគោរពរដ្ឋធម្មនុញ្ញ ការបកស្រាយរដ្ឋធម្មនុញ្ញ និងច្បាប់ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ហើយ» ។(មាត្រា ១៣៦ថ្មី រដ្ឋធម្មនុញ្ញ)

វិធានរៀបចំ និងប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញកំណត់ដោយច្បាប់អង្គការលេខ ៦ ចុះថ្ងៃទី ៨ ខែ មេសា ឆ្នាំ ១៩៩៨ ដោយយោងតាមមាត្រា ១៤៤ ថ្មី រដ្ឋធម្មនុញ្ញ ដែលបញ្ជាក់ថា «ក្រុមប្រឹក្សាធម្មនុញ្ញមានថវិកាផ្ទាល់ខ្លួន ដែលផ្គត់ផ្គង់ដោយថវិកាជាតិ» និងចែងថា «ប្រធាននៃក្រុមប្រឹក្សាធម្មនុញ្ញ ជាអាណាប័កដើមខ្សែ (នៃថវិការនេះ)»


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

(មាត្រា ១៣) ។

## ៣. ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមមានចែងក្នុងរដ្ឋធម្មនុញ្ញ (មាត្រា ១៣៤ថ្មី ) ដែលកំណត់ថានឹងត្រូវបង្កើតឡើងដោយច្បាប់អង្គការដែល «កំណត់អំពីសមាសភាព និងសមត្ថកិច្ចរបស់ខ្លួន»។

សមាសភាព និងសមត្ថកិច្ចរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម កំណត់ដោយច្បាប់លេខ ៩ ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ១៩៩៤ ដែលចែងថា «ចំណាយសម្រាប់ដំណើរការរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវគ្រោងថវិការបស់ក្រសួងយុត្តិធម៌» (មាត្រា ១៩ ច្បាប់ ៩៤-៩) ។

«ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមសម្រេច និងលើកសេចក្ដីស្នើថ្វាយព្រះមហាក្សត្រអំពីការតែងតាំង ការផ្លាស់ប្ដូរ ការផ្ដាច់ពីមុខងារ ការដាក់ឱ្យនៅទំនេរ ការដាក់ឱ្យនៅក្រៅក្របខណ្ឌ ការហូតងារចៅក្រម និងព្រះរាជអាជ្ញាទាំងអស់ ។

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ឱ្យយោបល់ចំពោះការតម្លើងថ្នាក់ និងការតម្លើងថានន្តរសក្តិឱ្យទៅចៅក្រម និងព្រះរាជអាជ្ញាទាំងអស់» ។ (មាត្រា ១១ ច្បាប់លេខ ៩ ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ១៩៩៤ ស្ដីពីការរៀបចំនិងប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម) ។ គួរកត់សម្គាល់ដែរថា ដោយសារភាពរលូននៃខ្សែសង្វាក់ការងារដែលអាចបញ្ជាក់អំពីសារសំខាន់នៃតួនាទីរបស់ក្រសួងយុត្តិធម៌ ក្នុងដំណើរការរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដែលមានចែងក្នុងមាត្រា ១៧ ថា ការតែងតាំងចៅក្រម និង ព្រះរាជអាជ្ញាទាំងអស់ គឺ ធ្វើឡើងដោយព្រះរាជក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងពុំមែនតាមសំណើរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមឡើយ ។

## ៤. តុលាការកំពូល និង យុត្តាធិការផ្សេងៗទៀត

តុលាការកំពូល និងយុត្តាធិការប្រភេទផ្សេងៗទៀត ត្រូវបានបង្កើតឡើងដោយមាត្រា ១២៨ថ្មី នៃរដ្ឋធម្មនុញ្ញ ។ រដ្ឋធម្មនុញ្ញចែងថា «គ្មានអង្គការណាមួយនៃអំណាចនីតិបញ្ញត្តិ ឬនីតិប្រតិបត្តិអាចទទួលអំណាចតុលាការបានឡើយ» (មាត្រា ១៣០ថ្មី) និងមានចែងថា «មានតែអង្គការអយ្យការទេ ដែលមានសិទ្ធិធ្វើបណ្ដឹងអាជ្ញា » (មាត្រា ១៣១ ថ្មី) ។

ចាប់ពីពេលនោះមក រដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ ត្រូវបានធ្វើវិសោធនកម្ម មានតែយុត្តាធិការតែមួយប្រភេទប៉ុណ្ណោះ : យុត្តាធិការរដ្ឋបាល និងគណនេយ្យពុំមានចែងទាល់តែសោះ ។

*ស្ថានភាពគតិយុត្តិរបស់អនុរដ្ឋលេខាធិការ*

ស្ថានភាពគតិយុត្តិរបស់អនុរដ្ឋលេខាធិការ ប្រហាក់ប្រហែលនឹងលក្ខន្តិកៈនៃសមាជិកខុទ្ទកាល័យរដ្ឋមន្ត្រីនៅប្រទេសបារាំងដែរ ។

## ៥. គណៈរដ្ឋមន្ត្រី

«គណៈរដ្ឋមន្ត្រីគឺជារាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ។

គណៈរដ្ឋមន្ត្រីត្រូវបានដឹកនាំដោយនាយករដ្ឋមន្ត្រី អមដោយឧបនាយករដ្ឋមន្ត្រី ព្រមទាំងមានទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការជាសមាជិក» (មាត្រា ១១៨ ថ្មី នៃរដ្ឋធម្មនុញ្ញ)។

នាយករដ្ឋមន្ត្រីត្រូវបានតែងតាំងដោយព្រះមហាក្សត្រ «តាមសេចក្តីស្នើពីប្រធាន ដោយមានមតិឯកភាពពីអនុប្រធានទាំងពីរនៃរដ្ឋសភា... ក្នុងចំណោមសមាជិកសភានៃគណបក្សនយោបាយដែលឈ្នះឆ្នោត...» (មាត្រា ១១៩ ថ្មី នៃរដ្ឋធម្មនុញ្ញ)។

រដ្ឋមន្ត្រីជាសមាជិកសភា ឬជាសមាជិកនៃគណបក្សដែលត្រូវមានតំណាងនៅរដ្ឋសភា (មាត្រាដដែល) ។ រាជរដ្ឋាភិបាល មុននឹងត្រូវចាត់តាំងដោយព្រះរាជក្រឹត្យ ត្រូវទទួលការបោះឆ្នោតទុកចិត្តពីរដ្ឋសភា (មាត្រាដដែល និងមាត្រា ៥ នៃច្បាប់ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤) ។

រដ្ឋសភាអាចបញ្ឈប់សមាជិកគណៈរដ្ឋមន្ត្រី ឬ ទម្លាក់រាជរដ្ឋាភិបាលបាន តាមការបោះឆ្នោតដកការទុកចិត្តដោយសម្លេងភាគច្រើន (ព្រះរាជក្រមលេខ ០៣០៦/០០៦ បានលុបសម្លេង២/៣) នៃសមាជិករដ្ឋសភា (មាត្រា ៩៩ នៃរដ្ឋធម្មនុញ្ញ) ។ គណៈរដ្ឋមន្ត្រីប្រជុំរៀងរាល់សប្តាហ៍ (មាត្រា ១២៣ នៃរដ្ឋធម្មនុញ្ញ) ។

«ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រីនឹងត្រូវកំណត់ក្នុងច្បាប់មួយ» (មាត្រា ១២៧ នៃរដ្ឋធម្មនុញ្ញ គឺច្បាប់ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ប្រកាសឱ្យប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដាស្តីអំពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី) ។ រដ្ឋមន្ត្រីអាចបន្តឋានៈជាសមាជិកសភាបាន។ (មាត្រា ៧៨ នៃរដ្ឋធម្មនុញ្ញ) ។

«សមាសភាពនៃរាជរដ្ឋាភិបាល មាននាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការ» (មាត្រា ៤ នៃច្បាប់ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤) ។

«អនុរដ្ឋលេខាធិការ ត្រូវតែងតាំងដោយព្រះរាជក្រឹត្យតាមសំណើររបស់នាយករដ្ឋមន្ត្រី ។ អនុរដ្ឋលេខា-



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ធិការមិនមែនជាសមាជិករាជរដ្ឋាភិបាលទេ ហើយក៏មិនមែនជាភ្នាក់ងាររដ្ឋបាលអចិន្ត្រៃយ៍ដែរ ។ នៅពេលណាដែលរាជរដ្ឋាភិបាលត្រូវបានលាលែង ឬ រំលាយអនុរដ្ឋលេខាធិការក៏ត្រូវអស់តំណែងដែរ» (មាត្រា៦នៃច្បាប់ឆ្នាំ១៩៩៤)។

ក្រសួងអាចត្រូវដឹកនាំ និងគ្រប់គ្រងដោយសហរដ្ឋមន្ត្រី ។ «រដ្ឋមន្ត្រីទាំងពីររូបមានសិទ្ធិ និងអំណាចស្មើគ្នា។ ការគ្រប់គ្រង និងដឹកនាំក្រសួងត្រូវឈរលើគោលការណ៍សហព័ទ្ធសម្រេច» (មាត្រា ២៣ នៃច្បាប់ ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤) ។

«ក្នុងករណីដែលក្រសួងត្រូវបានដឹកនាំ និងគ្រប់គ្រងដោយរដ្ឋមន្ត្រី និងរដ្ឋលេខាធិការ រដ្ឋមន្ត្រីជាប្រធានស្ថាប័ន រដ្ឋលេខាធិការជាអនុប្រធានស្ថាប័ន ។ រដ្ឋលេខាធិការអនុវត្តតាមភារកិច្ចដែលរដ្ឋមន្ត្រីប្រគល់ជូន ។ រាល់បញ្ហាធំៗ រដ្ឋមន្ត្រីត្រូវពិគ្រោះជាមួយរដ្ឋលេខាធិការ មុននឹងធ្វើសេចក្តីសម្រេចជាស្ថាពរ» (មាត្រា២៤ នៃច្បាប់ឆ្នាំ ១៩៩៤) ។

«រដ្ឋលេខាធិការដ្ឋានស្វយ័ត ដែលដឹកនាំដោយរដ្ឋលេខាធិការ រដ្ឋលេខាធិការជាប្រធានស្ថាប័ននោះ» ។ (មាត្រា២៤ នៃច្បាប់ឆ្នាំ ១៩៩៤)។ ទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រី ដែលមិនដឹកនាំក្រសួងអាចទទួលភារកិច្ចតាមការកំណត់របស់នាយករដ្ឋមន្ត្រី (មាត្រា២០ នៃច្បាប់ឆ្នាំ ១៩៩៤) ។

ទាក់ទងនឹងផ្នែកហិរញ្ញវត្ថុសាធារណៈ ព្រះមហាក្សត្រតែងតាំងមន្ត្រីជាន់ខ្ពស់ តាមសេចក្តីស្នើរបស់គណៈរដ្ឋមន្ត្រី (មាត្រា ២១ នៃរដ្ឋធម្មនុញ្ញ) ។ ព្រះមហាក្សត្រទ្រង់ឡាយព្រះហស្ថលេខាលើព្រះរាជក្រមប្រកាសឱ្យប្រើច្បាប់តាមសេចក្តីស្នើសុំរបស់គណៈរដ្ឋមន្ត្រី (មាត្រា ២៨ នៃរដ្ឋធម្មនុញ្ញ) ។

នាយករដ្ឋមន្ត្រីលើកសំណើរតែងតាំង ផ្លាស់ប្តូរ បញ្ចប់ភារកិច្ចមន្ត្រីជាន់ខ្ពស់ស៊ីវិលដូចតទៅ : ទេសាភិបាល ទេសាភិបាលរងធនាគារជាតិនៃកម្ពុជា ទីប្រឹក្សារាជរដ្ឋាភិបាល ទីប្រឹក្សារដ្ឋមន្ត្រី អគ្គលេខាធិការរាជរដ្ឋាភិបាល ប្រតិភូរាជរដ្ឋាភិបាល អភិបាលខេត្ត- ក្រុង ឯកអគ្គរាជទូត ប្រេសិតវិសាមញ្ញ និងពេញសមត្ថភាព នាយអគ្គសេនាធិការ និង នាយអគ្គសេនាធិការរង ឧត្តមសេនីយ៍ឡើងទៅ (មាត្រា១៤ នៃច្បាប់ឆ្នាំ ១៩៩៤) ។

«នាយករដ្ឋមន្ត្រី តែងតាំង ផ្លាស់ប្តូរ បញ្ចប់ភារកិច្ចដោយអនុក្រឹត្យនូវមន្ត្រីជាន់ខ្ពស់ស៊ីវិល យោធា មន្ត្រីការទូត និងអភិបាលរងខេត្ត-ក្រុង អភិបាលស្រុក-ខណ្ឌ...» (មាត្រា១៥ នៃច្បាប់ឆ្នាំ ១៩៩៤) ។

«ក្នុងករណីពិសេស ឬប្រធានសក្តិ នាយករដ្ឋមន្ត្រីមានសិទ្ធិបញ្ជាចំណាយក្រៅពីការកំណត់ក្នុងថវិកាជាតិ ដើម្បីដោះស្រាយកិច្ចការចាំបាច់ និងបន្ទាន់រួចរាយការណ៍ជូនរដ្ឋសភាភ្លាម» (មាត្រា១៦ នៃច្បាប់ឆ្នាំ ១៩៩៤) ។

ប្រធានស្ថាប័នមានសិទ្ធិលើកសំណើរ តែងតាំង ផ្លាស់ប្តូរ បញ្ចប់ភារកិច្ចមន្ត្រីរាជការក្រោមឱវាទ តាមបែប



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

បទនីតិវិធីជាធរមាន ចាប់ពីថ្នាក់ប្រធាននាយកដ្ឋាន វរៈសេនីយ៍ឯក និងថ្នាក់ប្រហាក់ប្រហែលឡើងទៅ ។ ប្រធានស្ថាប័នមានសិទ្ធិ តែងតាំង ផ្លាស់ប្តូរ បញ្ចប់ភារកិច្ចមន្ត្រីរាជការក្រោមឱវាទ តាមបែបបទនីតិវិធីជាធរមាន ដោយប្រកាស ចាប់ពីថ្នាក់ក្រោមប្រធាននាយកដ្ឋាន និងថ្នាក់ប្រហាក់ប្រហែលឡើងទៅ» (មាត្រា ២៨ នៃច្បាប់ឆ្នាំ ១៩៩៤)។

«ប្រធានស្ថាប័នមានសិទ្ធិចេញប្រកាស និងសារាចរ ។ សារាចរ ជាអត្ថបទសម្រាប់បំភ្លឺកិច្ចការ និងធ្វើការណែនាំ ។ ប្រកាស ឬសារាចររបស់ស្ថាប័នមិនអាចចែងអំពីកិច្ចការអ្វី ដែលមិនចូលក្នុងរង្វង់ក្របខ័ណ្ឌសមត្ថកិច្ចស្ថាប័នឡើយ ហើយក៏ពុំអាចមានទំនាស់ជាមួយលិខិតបទដ្ឋាននានា ដូចជាអនុក្រឹត្យ ឬសារាចររបស់រាជរដ្ឋាភិបាលដែរ» (មាត្រា ២៩ នៃច្បាប់ឆ្នាំ ១៩៩៤) ។

## ៦. រចនាសម្ព័ន្ធនៃរាជរដ្ឋាភិបាល

រាជរដ្ឋាភិបាលនៅថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០០៦ មានសមាសភាពដូចតទៅ៖

- នាយករដ្ឋមន្ត្រីមួយរូប
- ឧបនាយករដ្ឋមន្ត្រី ៦ រូប
- ទេសរដ្ឋមន្ត្រី ១៦ រូប
- រដ្ឋមន្ត្រី ១៣ រូប និង
- រដ្ឋលេខាធិការ ១៣៥ រូប

គិតមកដល់ ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០០៤ (ក្នុងនោះមានតែក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មានចំនួន ៦ រូប) នៅកាលបរិច្ឆេទដូចគ្នានេះ អនុរដ្ឋលេខាធិការមាន ១៤៦ រូប ។

## ៧. ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ដោយអនុលោមតាមអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុមានមុខងារ និង ភារកិច្ចដូចតទៅ៖

- រួមចំណែករៀបចំ អនុវត្ត និង តាមដានការអនុវត្តគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាល



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

- គ្រប់គ្រង និង សម្របសម្រួលកិច្ចការកែទម្រង់រចនាសម្ព័ន្ធសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ពង្រឹងអភិបាលកិច្ចល្អ ទៅលើអ្វីដែលជាប់ពាក់ព័ន្ធ និង ការគ្រប់គ្រងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសាធារណៈ
- ធ្វើការបែងចែក និង បែងចែកឡើងវិញនូវផលទុនជាតិ តាមរយៈការប្រមូលចំណូល និង កម្មវិធីនីយកម្ម និង ថវិកានីយកម្មនៃចំណាយសាធារណៈ
- កសាងប្រព័ន្ធហិរញ្ញវត្ថុឱ្យឯកភាពទូទាំងប្រទេស ហើយធានាឱ្យអនុវត្តប្រព័ន្ធនេះឱ្យបានត្រឹមត្រូវ តាមច្បាប់ស្តីពីហិរញ្ញវត្ថុ និង ច្បាប់ហិរញ្ញវត្ថុសម្រាប់គ្រប់គ្រងឆ្នាំនីមួយៗ ព្រមទាំងច្បាប់ពាក់ព័ន្ធ និង បទបញ្ញាដទៃទៀត
- រៀបចំកសាងសេចក្តីព្រាងច្បាប់ និងបទបញ្ញាផ្សេងៗសំរាប់ការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាលក្ខណៈប្រចាំឆ្នាំនីមួយៗ ឬ ជាលក្ខណៈអចិន្ត្រៃយ
- រៀបចំ និង គ្រប់គ្រងថវិការដ្ឋ
- រៀបចំ និង អនុវត្តគោលនយោបាយចំណូលថវិកាជាតិ
- ប្រមូលចំណូលសារពើពន្ធ និង មិនមែនសារពើពន្ធ បង់ចូលបេឡាថវិការដ្ឋ ធ្វើតារាងតុល្យភាព និង វិភាគគណនីនៃប្រតិបត្តិការហិរញ្ញវត្ថុរដ្ឋ
- ពិនិត្យ និង ចុះទិដ្ឋាការ លើចំណាយរបស់ក្រសួង និង ស្ថាប័ននានា
- គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ
- វិភាគតាមដាន និងព្យាករណ៍ស្ថានភាពសេដ្ឋកិច្ចក្នុងរយៈពេលខ្លី មធ្យម និងរយៈពេលវែង និងដាក់ចេញនូវវិធានការ ដើម្បីតម្រង់ទិស និង កែលម្អការគ្រប់គ្រងសេដ្ឋកិច្ច
- ចូលរួមចំណែកអភិវឌ្ឍ គ្រប់គ្រង និង ត្រួតពិនិត្យកិច្ចការឧស្សាហកម្មហិរញ្ញវត្ថុ រួមមានកិច្ចការធានារ៉ាប់រង ទីផ្សារមូលបត្រ ឡូត្តូ កាស៊ីណូ បេឡាសោធននិវត្តន៍ និង សេវាហិរញ្ញវត្ថុផ្សេងៗទៀត
- សហការជាមួយក្រសួង និង ស្ថាប័នពាក់ព័ន្ធ ដើម្បីដឹកនាំ និង ចូលរួមក្នុងការរៀបចំអនុវត្តគោលនយោបាយយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល លើកិច្ចសហប្រតិបត្តិការអន្តរជាតិក្នុងវិស័យសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង កិច្ចការសមាហរណកម្មសេដ្ឋកិច្ចកម្ពុជា ទៅក្នុងសេដ្ឋកិច្ចពិភពលោក ពិសេសកិច្ចការសមាហរណកម្មសេដ្ឋកិច្ចក្នុងក្របខ័ណ្ឌអាស៊ាន
- ចូលរួមក្នុងការងារកៀងគរជំនួយ ព្រមទាំងរៀបចំផែនការខ្ចី និង សងបំណុលបរទេស ហើយតាមដាន និង ត្រួតពិនិត្យលើការអនុវត្តផែនការទាំងនោះ

- គ្រប់គ្រង និង ត្រួតពិនិត្យកិច្ចការលទ្ធកម្មសាធារណៈនៃបណ្តាក្រសួង- ស្ថាប័ន និង ខេត្ត-ក្រុង ព្រមទាំងស្ថាប័នរដ្ឋកាន់កាប់ ឬ ស្វ័យគ្រប់គ្រង
- ចូលរួមរៀបចំគោលនយោបាយ និង គ្រប់គ្រងកិច្ចការវិនិយោគ
- បំពេញមុខងារអធិការកិច្ច លើផ្នែកហិរញ្ញវត្ថុសាធារណៈ
- បណ្តុះបណ្តាល និង ធ្វើវិក្រឹតការជាប្រចាំនូវមុខជំនាញសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋដល់មន្ត្រីក្រសួង ស្ថាប័នពាក់ព័ន្ធ ។

ក្នុងន័យនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបានរៀបចំឡើងតាមរចនាសម្ព័ន្ធដូចតទៅ៖

### ៧.១. ថ្នាក់កណ្តាល

ក• អគ្គលេខាធិការដ្ឋាន

ខ• ខុទ្ទកាល័យរដ្ឋមន្ត្រី

គ• អគ្គាធិការដ្ឋាន

ឃ• អគ្គនាយកដ្ឋានពន្ធដារ

ង• អគ្គនាយកដ្ឋានគយ និង រដ្ឋាករ

ច• អគ្គនាយកដ្ឋានរតនាគារជាតិ

ឆ• នាយកដ្ឋានថវិកា

ជ• នាយកដ្ឋានហិរញ្ញកិច្ច

ឈ• នាយកដ្ឋានលទ្ធកម្មសាធារណៈ

ញ• នាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ

ដ• នាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសាធារណៈ

ឋ• នាយកដ្ឋានវិនិយោគ និង សហប្រតិបត្តិការ

ឌ• នាយកដ្ឋានសមាហរណកម្មសេដ្ឋកិច្ច និង អាស៊ាន

ឍ• នាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ណ. នាយកដ្ឋានបុគ្គលិក

ត. នាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ

ថ. នាយកដ្ឋាននីតិកម្ម

ទ. នាយកដ្ឋានដោះស្រាយផលប៉ះពាល់គម្រោងអភិវឌ្ឍន៍

ធ. នាយកដ្ឋានសវនកម្មផ្ទៃក្នុង

ន. វិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

### ៧.២. អង្គភាពមូលដ្ឋាន

- មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ខេត្ត ក្រុង
- រតនាគារខេត្ត ក្រុង «ថ្នាក់ស្មើការិយាល័យថ្នាក់កណ្តាល»
- សាខាពន្ធដារខេត្ត ក្រុង «ថ្នាក់ស្មើការិយាល័យថ្នាក់កណ្តាល» និង ស្នាក់ការពន្ធដារខណ្ឌ ស្រុក «ថ្នាក់ស្មើការិយាល័យនៅខេត្ត- ក្រុង»
- សាខាគយ និង រដ្ឋាករ ខេត្ត ក្រុង «ថ្នាក់ស្មើការិយាល័យនៅថ្នាក់កណ្តាល» និង ស្នាក់ការគយ និង រដ្ឋាករ តាមមាត់ច្រកព្រំដែន «ថ្នាក់ស្មើការិយាល័យខេត្ត- ក្រុង» ។

៣. ក្រុមត្រួតពិនិត្យហិរញ្ញវត្ថុ

## ៨. ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវបានរៀបចំឡើងវិញដោយអនុក្រឹត្យលេខ ១៤៩ អនក្រ.បក ចុះថ្ងៃទី ៣ ខែតុលា ឆ្នាំ ២០០៨ ដែលជាស្ថាប័នប្រតិបត្តិរបស់រាជរដ្ឋាភិបាល ។ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាដឹកនាំដោយ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា មានអនុប្រធាន ៤ រូប និង មានសមាជិកចំនួន ១៧ រូប និង អគ្គលេខាធិការមួយរូប ។

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាមានរចនាសម្ព័ន្ធដូចតទៅ ÷

- **គណៈកម្មាធិការនីតិសម្បទា និង អភិវឌ្ឍន៍កម្ពុជា** ដែលស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់អគ្គលេខាធិការមួយរូប



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

- **គណៈកម្មាធិការវិនិយោគកម្ពុជា** ដែលស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់អគ្គលេខាធិការមួយរូប

- **គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេស** ដែលស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់អគ្គលេខាមួយរូប

- **អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា** ដែលស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់អគ្គលេខាធិការ «ក.អ.ក.» ។

**ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា** គឺ ជាស្ថាប័នប្រតិបត្តិរបស់រដ្ឋាភិបាល ហើយមានភារកិច្ចដូចតទៅ ÷

- ជាសេនាធិការ និង ជា «ច្រកចេញចូលតែមួយ» របស់រាជរដ្ឋាភិបាល ក្នុងកិច្ចការនីតិសម្បទា និងអភិវឌ្ឍន៍ និងវិនិយោគសាធារណៈ ការវិនិយោគឯកជន និងការបង្កើត និង ការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស ។

- ដឹកនាំការងាររៀបចំទស្សនទាន និង យុទ្ធសាស្ត្រអភិវឌ្ឍន៍ សម្រាប់ប្រទេសកម្ពុជា ដោយសហការជាមួយបណ្តាស្ថាប័នពាក់ព័ន្ធ ។

- ទាក់ទងជាមួយប្រទេស អង្គការអន្តរជាតិពហុភាគី/ទ្វេភាគី និងអង្គការមិនមែនរដ្ឋាភិបាលទាំងអស់ ក្នុងគោលបំណងធ្វើអោយគេយល់ជ្រួតជ្រាបអំពីទស្សនទានយុទ្ធសាស្ត្រសេដ្ឋកិច្ច និងបណ្តាអាទិភាពនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ដើម្បីសម្របសម្រួលការទទួល និង ការប្រើប្រាស់ហិរញ្ញប្បទានសហប្រតិបត្តិការការអោយមានប្រសិទ្ធភាព ស្របតាមសេចក្តីត្រូវការ និងអាទិភាពរបស់ប្រទេសជាតិ ដោយប្រកាន់តួនាទីជាម្ចាស់ សម្រាប់សម្រេចលទ្ធផលជូនប្រទេសជាតិ ។

- សម្របសម្រួលការងាររវាងក្រសួង និង ស្ថាប័ននានា ដែលមានការពាក់ព័ន្ធជាមួយនឹងប្រទេស និង អង្គការអន្តរជាតិអ្នកផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការ ព្រមទាំងជាមួយអ្នកវិនិយោគ ។

- តម្រង់ទិសក្នុងការបែងចែក និង ក្នុងការប្រើប្រាស់ធនធានសាធារណៈ និងធនធានឯកជន ក្នុងកិច្ចការអភិវឌ្ឍន៍កម្ពុជា ។

- បង្កលក្ខណៈងាយស្រួល និង សម្រួលកិច្ចការដល់ដៃគូអភិវឌ្ឍន៍ និងដល់អ្នកវិនិយោគ ។

- ពិនិត្យ និងសម្រេចរាល់កិច្ចការនីតិសម្បទា និងអភិវឌ្ឍន៍ និងការវិនិយោគសាធារណៈ ការវិនិយោគឯកជន និងការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

***វិសហមជ្ឈការ វិមជ្ឈការ ការផ្លាស់ទីតាំង ឯកជនភាវូបនីយកម្ម***

**វិសហមជ្ឈការ**- វិសហមជ្ឈការ គឺជាដំណើរការផ្ទេរអំណាច (និងសមត្ថកិច្ច) ពីរដ្ឋបាលកណ្តាល ទៅរដ្ឋបាលថ្នាក់ក្រោម ក្នុងវិស័យដូចតទៅ៖ ការអនុវត្តនីតិវិធីលទ្ធកម្មអាចផ្ទេរទៅអោយប្រធានមន្ទីរ ។ រដ្ឋមន្ត្រីអាចធ្វើវិសហមជ្ឈការអំណាចក្នុងការគ្រប់គ្រងថវិកាទៅអោយមន្ទីរខេត្ត- ក្រុង អភិបាលខេត្ត ឬ ប្រធានមន្ទីរខេត្ត- ក្រុង។

**វិមជ្ឈការ**- វិមជ្ឈការ គឺជាការផ្ទេរអំណាច និង សមត្ថកិច្ចមួយចំនួនពីនីតិបុគ្គលសាធារណៈ ទៅនីតិបុគ្គលសាធារណៈមួយទៀត ដែលត្រូវបានបង្កើតឡើងតាមការចាំបាច់ ដោយផ្តល់នូវធនធានផ្ទាល់ (ពន្ធ អាករ និង ការឧបត្ថម្ភកធន) ដើម្បីបំពេញនូវតួនាទី និងភារៈកិច្ចដែលបានទទួល ។

វិមជ្ឈការអាចមានលក្ខណៈ «ដែនដី» នៅពេលដែលអំណាចត្រូវបានផ្ទេរទៅអោយនីតិបុគ្គលនៃនីតិសាធារណៈដែលជា សហគមន៍មួយដែលត្រូវបានបោះឆ្នោតជ្រើសរើស ដឹកនាំអោយប្រធានប្រតិបត្តិដែលត្រូវ បានជ្រើសរើសតាមរយៈការបោះឆ្នោតផងដែរ ដូចជាក្រុមប្រឹក្សាឃុំ- សង្កាត់ជាដើម ។

វិមជ្ឈការអាចមានលក្ខណៈ «បច្ចេកទេស» នៅពេលដែលអំណាចត្រូវបានផ្ទេរទៅអោយអង្គភាពជានីតិបុគ្គល (នៃនីតិ សាធារណៈ) និង មានស្វ័យភាពហិរញ្ញវត្ថុ ដូចជាគ្រឹះស្ថានសាធារណៈ ។ វិមជ្ឈការដែលផ្តល់អោយខេត្ត មានថវិកាស្វយ័ត អាចចាត់ទុកថាជាវិមជ្ឈការបច្ចេកទេសបាន ។

**ការផ្លាស់ទីតាំង**- ការផ្លាស់ប្តូរទីតាំង គឺជាការដូរទីតាំងនៃអាជីវកម្ម ដើម្បីទៅបង្កើតអាជីវកម្មនៅបរទេស ដូចជាការប្តូរទីតាំងនៃរោងចក្រកាត់ដេរពីប្រទេសចិន មកកាន់ប្រទេសកម្ពុជា ដោយឈរលើមូលដ្ឋាននៃថ្លៃដើមកត្តាផលិតកម្មទាប (ប្រាក់បៀវត្ស ទឹក ភ្លើង ទូរស័ព្ទ ការដឹកជញ្ជូន ពន្ធដារ ជាដើម) ។

**ឯកជនភាវូបនីយកម្ម**- ឯកជនភាវូបនីយកម្ម គឺជាការផ្ទេរពីវិស័យសាធារណៈ មកវិស័យឯកជននូវសកម្មភាពដែលវិស័យឯកជនអាចគ្រប់គ្រង ដោយផ្តល់នូវទិន្នផលសេដ្ឋកិច្ច និង ហិរញ្ញវត្ថុខ្ពស់ ។ សកម្មភាពដែលអាចធ្វើឯកជន- ភាវូបនីយកម្ម មានវិស័យកសិកម្ម (កសិដ្ឋានរដ្ឋ អាជីវកម្មកសិ- ឧស្សាហកម្មរបស់រដ្ឋ) វិស័យឧស្សាហកម្ម (សាធារណៈការ ការថែទាំផ្លូវ រោងចក្ររដ្ឋ) ឬ វិស័យសេវាកម្ម (សកម្មភាពគ្រប់គ្រងដោយរដ្ឋ ដូចជាវិស័យសុខាភិបាល អប់រំ ឬ គយ ជាដើម)។

ឯកជនភាវូបនីយកម្មអាចពាក់ព័ន្ធនឹងលក្ខន្តិកៈ ÷ ការកែប្រែសេវាសាធារណៈអោយក្លាយជាសហគ្រាសឯកជន ដូចជា ករណីការថែទាំផ្លូវនៅក្នុងប្រទេសមួយចំនួន តាមរយៈនីតិវិធីលទ្ធកម្មសាធារណៈ ការប្រែក្លាយគ្រឹះស្ថានសាធារណៈអោយទៅជាសហគ្រាសនៃនីតិឯកជន តែរដ្ឋអាចគ្រប់គ្រងទាំងស្រុងនូវមូលធនរបស់ក្រុមហ៊ុន ។ ឯកជនភាវូបនីយកម្មនៃលក្ខន្តិកៈពាក់ព័ន្ធទៅនឹងមូលធន និង ស្ថានភាពនៃបុគ្គលិក (លើកលែងតែថ្នាក់ដឹកនាំក្រុមហ៊ុន)។

ឯកជនភាវូបនីយកម្ម អាចជាការផ្ទេរនូវមូលធនទាំងស្រុង ឬ មួយចំណែកនៃមូលធនរបស់រដ្ឋ ទៅអោយផ្នែកឯកជន ។ ការមិនអាចរឹបអូសយកមូលធនរបស់រដ្ឋនឹងត្រូវផ្លាស់ប្តូរតាមរយៈការធ្វើឯកជនភាវូបនីយកម្ម ។

នៅកម្ពុជា ឯកជនភាវូបនីយកម្មត្រូវបានរៀបចំឡើងដោយអនុក្រឹត្យលេខ ៣៨ ចុះថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ១៩៩៥

## ៩. ការរៀបចំដែនដី

ព្រះរាជាណាចក្រកម្ពុជាចែកចេញជា ក្រុង និង ទីជនបទ ។ ការរៀបចំរដ្ឋបាលបែងចែកដែនដីជា ÷

- ខេត្ត ដែលចែកចេញជាស្រុក និង ឃុំ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

- ក្រុង ដែលចែកចេញជាខ័ណ្ឌ និង សង្កាត់ (មាត្រា ១៤៥ ថ្មីនៃរដ្ឋធម្មនុញ្ញ) ។

ការរៀបចំដែលដីត្រូវគ្រប់គ្រងដោយច្បាប់អង្គការ (មាត្រា ១២៧ ថ្មីនៃរដ្ឋធម្មនុញ្ញ) ។ ក៏ប៉ុន្តែ ចាប់តាំងពីឆ្នាំ ១៩៩៦ មក «ដោយរង់ចាំការអនុម័តនូវច្បាប់អង្គការ ... ការងារនៅថ្នាក់មូលដ្ឋានត្រូវបានបញ្ចូលទៅក្នុងថវិកាទូទៅរបស់រដ្ឋ...» (ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ១៩៩៦) ។

ច្បាប់ចុះថ្ងៃទី ១០ កុម្ភៈ ឆ្នាំ ១៩៩៨ ស្តីពីរបបហិរញ្ញវត្ថុ និង ការគ្រប់គ្រងទ្រព្យសម្បត្តិខេត្ត- ក្រុងបានកំណត់ខេត្ត និង ក្រុងជានីតិបុគ្គលនៃនីតិសាធារណៈ ដែលគ្រប់គ្រងដោយអភិបាលខេត្ត- ក្រុង ដែលជាអាណាប័កដើមខ្សែនៃថវិការបស់ខ្លួន ។ នីតិបុគ្គលទាំងនេះ មាននូវរូបភាពជាគ្រឹះស្ថានសាធារណៈដែលមិនទាន់គ្រប់លក្ខណៈ ដោយសារអវត្តមាននូវក្រុមប្រឹក្សាភិបាល ការតែងតាំងនូវប្រធានប្រតិបត្តិ ស្វ័យភាពហិរញ្ញវត្ថុ ទ្រព្យសម្បត្តិផ្ទាល់ និងធនធានផ្ទាល់ខ្លួន ។ អភិបាលខេត្ត- ក្រុង គឺជាអាណាប័កដើមខ្សែនៃថវិកាខេត្ត- ក្រុង និង ជាអាណាប័កផ្ទេរសិទ្ធិនៃថវិកានៃមន្ទីរដែលស្ថិតនៅក្រោមឱវាទរបស់ខ្លួន ។

## ១០. ធនាគារជាតិនៃកម្ពុជា

ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ១៩៩៦ ប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា ដែលអាចហៅបានថា «ធនាគារកណ្តាល» ។ ធនាគារជាតិនៃកម្ពុជា គឺជាស្ថាប័នស្វយ័តសាធារណៈមានលក្ខណៈជាពាណិជ្ជកម្ម និង ឧស្សាហកម្ម (មាត្រា ១) ។

### ១០.១. សមត្ថភាពគតិយុត្តិ

«ធនាគារកណ្តាលជានីតិបុគ្គលមានសត្ថភាពគតិយុត្តិពេញលេញ» (មាត្រា ២) ។ «បេសកកម្មចម្បងរបស់ធនាគារកណ្តាល គឺ កំណត់និងដឹកនាំគោលនយោបាយរូបិយវត្ថុ ក្នុងក្របខ័ណ្ឌនគោលយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា ក្នុងគោលដៅរក្សាថ្លៃអោយមានស្ថិរភាព សំដៅបង្កលក្ខណៈងាយស្រួលដើម្បីធ្វើអោយសេដ្ឋកិច្ចរីចចម្រើន» (មាត្រា ៣) ។

***ធនាគារនៃប្រទេសបារាំង***

ចាប់តាំងពីចូលក្នុងសហគមន៍រូបិយវត្ថុ និងសេដ្ឋកិច្ចរបស់អ៊ឺរ៉ុបចាប់តាំងពីឆ្នាំ ១៩៩៧ មក **ធនាគារបារាំង** ដែលត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ ១៨០០ ដោយ **ណាប៉ូឡេអុង** គឺជាស្ថាប័នរដ្ឋបាលសាធារណៈ ដែលស្ថិតក្រោមការទទួលខុសត្រូវរបស់នាយករដ្ឋមន្ត្រីចាប់តាំងពីឆ្នាំ ១៩៥៨ មកម្ល៉េះ ។ ធនាគារបារាំងស្ថិតក្រោមរបបលទ្ធកម្មសាធារណៈ ។



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

## ១០.២. របបហិរញ្ញវត្ថុ

«ធនាគារកណ្តាលត្រូវកាន់កាប់បញ្ជីគណនេយ្យ និងបញ្ជីផ្សេងៗទៀត ហើយត្រូវកត់ត្រាគ្រប់ប្រតិបត្តិការហិរញ្ញវត្ថុ...ស្របទៅតាមគោលការណ៍ និងបែបបទគណនេយ្យដែលត្រូវបានទទួលស្គាល់ជាទូទៅសម្រាប់ធនាគារកណ្តាល» (មាត្រា ៥៦) ។ «ការពិនិត្យបញ្ជីហិរញ្ញវត្ថុរបស់ធនាគារកណ្តាលត្រូវធ្វើឡើងដោយគណៈកម្មការពិសេសមួយដែលតែងតាំងដោយរាជរដ្ឋាភិបាល» (មាត្រា ៥៧) ។ ដូច្នេះ យើងអាចសន្និដ្ឋានថា ធនាគារជាតិកម្ពុជាជានីតិបុគ្គលដែលមានលក្ខណៈជាស្ថាប័នសាធារណៈ ដែលមិនឋិតក្រោមរបបគណនេយ្យសាធារណៈឡើយ ។

## ១០.៣. អំណាចនៃការគ្រប់គ្រង

«ធនាគារកណ្តាលមានសិទ្ធិចេញប្រកាស បទបញ្ជា សារាចរ និងសេចក្តីណែនាំផ្សេងៗទៀត ដើម្បីបំពេញបេសកកម្មរបស់ខ្លួន និងដើម្បីអនុវត្តខ្លឹមសារនៃច្បាប់នេះ» (មាត្រា ៤) ។

## ១០.៤. សម្ព័ន្ធការផ្នែកហិរញ្ញវត្ថុជាមួយអង្គភាពសាធារណៈ

«ធនាគារកណ្តាលអាចបើកគណនីអោយ÷

- ស្ថាប័នរដ្ឋ ឬ អង្គការរដ្ឋបាលកណ្តាលជា ដូចជារតនាគារជាតិជាដើម ។
- គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុដែលមានការអនុញ្ញាតពីធនាគារកណ្តាលអោយធ្វើអាជីវកម្ម ។
- ធនាគារកណ្តាលបរទេស និងស្ថាប័នហិរញ្ញវត្ថុសាធារណៈអន្តរជាតិ ។

ធនាគារជាតិមិនអាចបើកគណនីអោយសហគ្រាសឧស្សាហកម្ម ឬពាណិជ្ជកម្មបានទេ ទោះជារបស់រដ្ឋក៏ដោយ» (មាត្រា ៨) ។

«ធនាគារកណ្តាលទទួលប្រាក់បញ្ញើផ្ទាល់មុខជារូបិយវត្ថុពីរតនាគារជាតិ ។ ធនាគារកណ្តាលទទួលប្រាក់ពីរតនាគារជាតិ ហើយចេញជួសនូវទឹកប្រាក់ដែលរតនាគារជាតិត្រូវចំណាយ ។ ចំណូលជារូបិយប័ណ្ណរបស់រតនាគារជាតិត្រូវលក់អោយធនាគារកណ្តាល ហើយធនាគារកណ្តាលត្រូវបញ្ចូលទឹកប្រាក់ជារៀលក្នុងគណនីទោលរបស់រតនាគារ ដោយគិតតាមអត្រាប្តូរប្រាក់ប្រចាំថ្ងៃ» (មាត្រា ២១) ។

«ធនាគារកណ្តាលជាទីប្រឹក្សារបស់រាជរដ្ឋាភិបាលក្នុងវិស័យរូបិយវត្ថុ និង ហិរញ្ញវត្ថុ ។ ធនាគារកណ្តាលមានភារកិច្ចក្នុងការផ្តល់ព័ត៌មាន និងយោបល់ជូនរាជរដ្ឋាភិបាលអំពីបញ្ហាទាំងឡាយដែលមានអានុភាពក្នុងការធ្វើអោយសម្រេចគោលនយោបាយហិរញ្ញវត្ថុ» (មាត្រា ២២) ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

«ធនាគារកណ្តាលអាចទទួលធ្វើជាអាណត្តិគាហកៈរបស់រាជរដ្ឋាភិបាល ឬរបស់អង្គភាពសាធារណៈចំពោះប្រតិបត្តិការៈ (១) ការទិញ លក់មូលបត្រដែលបោះផ្សាយដោយរាជរដ្ឋាភិបាល ឬអង្គភាពសាធារណៈព្រមទាំងកិច្ចការជាភ្នាក់ងារគណនេយ្យដើម្បីចុះបញ្ជី និង ផ្ទេរនូវមូលបត្រនោះ (២) ការទូទាត់សងដើម និងការប្រាក់ព្រមទាំងកម្រៃផ្សេងៗលើមូលបត្រទាំងនោះ» (មាត្រា ២៣) ។

«ធនាគារកណ្តាលមិនត្រូវផ្តល់ឥណទានដោយផ្ទាល់ ឬដោយប្រយោលដល់រាជរដ្ឋាភិបាលឡើយ ជាពិសេសដោយទិញយកមូលបត្រដែលបោះផ្សាយដំបូង ឬ មូលបត្រដែលធានាអោយរាជរដ្ឋាភិបាល ឬ ដោយអង្គភាពសាធារណៈ លើកលែងតែករណីស្របទៅនឹងបទបញ្ញត្តិនានាក្នុងជំពូកនេះ » (មាត្រា ២៤) ។

«ធនាគារកណ្តាលអាចផ្តល់ឥណទានដែលមានកាលវសានមិនហួសពី ៣ ខែ ជូនទៅរតនាគារជាតិដោយគិតការប្រាក់តាមអត្រាបុនហិរញ្ញប្បទានៈ (១) រាល់ប្រតិបត្តិការឥណទានត្រូវមានកិច្ចព្រមព្រៀងរវាងធនាគារកណ្តាល និង អ្នកខ្ចីដែលត្រូវមានបញ្ជាក់ទឹកប្រាក់ឥណទាន កាលវសាននិងអត្រាការប្រាក់ (២) ប្រតិបត្តិការឥណទានត្រូវធ្វើអោយមានយថាភាពដោយប្រគល់ជូនធនាគារកណ្តាលនូវមូលបត្ររដ្ឋ ដែលអាចធ្វើអន្តរការបាន (៣) ចំនួនទឹកប្រាក់សរុបនៃឥណទាននិងមូលបត្រដែលមានស្របតាមមាត្រា ២៤ នៃច្បាប់នេះក្នុងការិយបរិច្ឆេទនីមួយៗមិនត្រូវអោយលើសពី ១០%នៃចំណូលចរន្តនៃថវិកាជាតិ ក្នុងការិយបរិច្ឆេទនាឆ្នាំមុនឡើយដោយមិនគិតជំនួយ និងចំណូលពីការលក់ទ្រព្យសម្បត្តិ ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ជំពូកទី ២

## ចំណូលថវិកា

## ប្រព័ន្ធសារពើពន្ធនៃព្រះរាជាណាចក្រកម្ពុជា

***ពន្ធ ពន្ធផ្ទាល់ ពន្ធប្រយោល អាករ និង តម្លៃផ្សេងៗ***

***ពន្ធ-*** គឺជាវិភាគទានហិរញ្ញវត្ថុជាកាតព្វកិច្ច ដែលរដ្ឋ ឬ ស្ថាប័នរដ្ឋ (អាជ្ញាធរដែនដី ឬ គ្រឹះស្ថានសាធារណៈ) ត្រូវប្រមូល ដោយមានការកំណត់ដាច់ខាត និងដោយគ្មានបដិភាគអ្វីទាំងអស់ ដើម្បីយកមកបំពេញ ចំណាយសាធារណៈ។

***ពន្ធផ្ទាល់-*** គឺជាបន្ទុកផ្ទាល់នៃអ្នកជាប់ពន្ធ មានដូចជា៖ ពន្ធលើប្រាក់បៀវត្សរ៍ ពន្ធលើប្រាក់ចំណេញ ។

***ពន្ធប្រយោល-*** ពន្ធនេះបង់ដោយអ្នកជាប់ពន្ធជំនួសតតិយជន ដែលជាអ្នកជាប់ពន្ធពិតប្រាកដ ÷ ដូចជា អាករលើតម្លៃបន្ថែម និង ពន្ធគយ ។

***អាករ-*** ប្រមូលដោយស្ថាប័នរដ្ឋ ឬ ស្ថាប័នរដ្ឋ ចំពោះការប្រើប្រាស់សេវា ដែលមានបដិភាគជាក់ស្តែង៖ ដូចជា អាករលើការប្រមូលសម្រាម ឬ លើលូទឹកស្អុយ ។

***ថ្លៃសេវា-*** គឺជាថ្លៃសេវារបស់រដ្ឋ ផ្គត់ផ្គង់អគ្គិសនី សេវាកម្មសុខភាព សាធារណៈ ការបង់ពន្ធផ្លូវ ។ល។

យើងបានឃើញពីខាងដើមស្រាប់ គេអាចប្រមូលពន្ធបាន ទាល់តែមានចែងក្នុងច្បាប់ (មាត្រា ៥៧ និង ៩០ ថ្មីនៃរដ្ឋធម្មនុញ្ញ) ។

«ពន្ធ អាករ និងចំណូលសារពើពន្ធផ្សេងៗ ត្រូវកំណត់ដោយច្បាប់ និង ត្រូវប្រមូល និង ត្រួតពិនិត្យដោយរដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ អត្រាពន្ធ អាករ មូលដ្ឋានជាប់ពន្ធ ការលើកលែងពន្ធ និង វិវាទដែលទាក់ទងនឹងការកំណត់ការប្រមូល និង ការត្រួតពិនិត្យពន្ធ ត្រូវកំណត់នៅក្នុងក្របខ័ណ្ឌ និងតាមបែបបទដែលមានចែងនៅក្នុងច្បាប់ដែលទាក់ទងដល់ប្រភេទពន្ធ និង អាករនីមួយៗ» (មាត្រា ១៦ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ)។

អ្នកជាប់ពន្ធទាំងឡាយត្រូវមានកាតព្វកិច្ចចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធក្នុងអំឡុងពេល ១៥ ថ្ងៃ ក្រោយមានសកម្មភាពសេដ្ឋកិច្ច ។ ជាការអនុវត្ត អ្នកជាប់ពន្ធនៅព្រះរាជាណាចក្រកម្ពុជាមានពីរប្រភេទគឺ អ្នកជាប់ពន្ធតាម **របបស្វ័យប្រកាស** និង អ្នកជាប់ពន្ធតាម **របបម៉ៅការ** ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ១. របបស្វ័យប្រកាស

អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស គឺជានីតិបុគ្គលទាំងឡាយដែលបានចុះបញ្ជីពាណិជ្ជកម្មនៅកម្ពុជា និង បុគ្គលទាំងឡាយ ដែលប្រកបធុរកិច្ចដែលមានផលរបរប្រចាំឆ្នាំចាប់ពី ៥០០ លានរៀល ឡើងទៅសម្រាប់ការផ្គត់ផ្គង់ទំនិញ ចាប់ពី ២៥០ លានរៀលឡើងទៅសម្រាប់ការផ្គត់ផ្គង់សេវា និងចាប់ពី ១២៥ លានរៀលឡើងទៅសម្រាប់ការធ្វើកិច្ចសន្យាជាមួយរដ្ឋ ។ អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសមានកាតព្វកិច្ចដាក់លិខិតប្រកាស និងបង់ប្រាក់ពន្ធដោយខ្លួនឯង ។ ក្នុងអំឡុងពេលមួយមានកំណត់ អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសនឹងត្រូវបានទទួលការធ្វើសវនកម្មពីមន្ត្រីសវនកម្មពន្ធដារដើម្បីធានាភាពត្រឹមត្រូវនៃការប្រកាសរបស់ខ្លួន ។

នៅចុងឆ្នាំ ២០០៨ មានអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសមានចំនួន ១២.០៨៩ សហគ្រាស ក្នុងនោះមានសហគ្រាសជាអ្នកជាប់ពន្ធធំចំនួន ១.១៧១ សហគ្រាសនៅទូទាំងប្រទេស និងអ្នកជាប់ពន្ធមធ្យមចំនួន ៩.១៤៤ សហគ្រាស នៅភ្នំពេញ ១.៧៧៤ នៅតាមខេត្ត-ក្រុងទាំង ២៤ ។ ចំណូលដែលទទួលបានពីអ្នកជាប់ពន្ធទាំងនេះមានចំនួនប្រមាណ ៨៥% នៃចំណូលពន្ធដារសរុបដែលអគ្គនាយកដ្ឋានពន្ធដារប្រមូលបាន ។

## ២. របបម៉ៅការ

អ្នកជាប់ពន្ធតាមរបបម៉ៅការ គឺជាអ្នកជាប់ពន្ធតូចៗ ដែលស្ថិតក្រោមកម្រិតអប្បបរមា ដែលត្រូវចុះបញ្ជីជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស និងត្រូវបានកំណត់ឱ្យបង់ប្រាក់ពន្ធជាស្ថេរវគ្គ ក្នុងរយៈពេលកំណត់ណាមួយ (៣ ខែ ឬ ៦ ខែ) នៃឆ្នាំប្រតិទិន ។ នៅក្នុងរបបនេះ មានសហគ្រាសចំនួន ៤៨.៥១០ ។ ចំណូលពន្ធដែលប្រមូលបានពីសហគ្រាសតាមរបបម៉ៅការមានប្រមាណ ១៥% នៃចំណូលពន្ធ ដែលអគ្គនាយកដ្ឋានពន្ធដារប្រមូលបាន ។ នៅក្នុងប្រព័ន្ធនេះ អគ្គនាយកដ្ឋានពន្ធដារផ្ទាល់បានរៀបចំមូលដ្ឋានត្រូវបង់ពន្ធ ស្របតាមបញ្ជីទាំងឡាយដែលប្រគល់មកដោយការប៉ាន់ប្រមាណ ។ ជាក់ស្តែងណាស់ដែលថាប្រព័ន្ធនេះនឹងត្រូវចំណាយច្រើន ដើម្បីគ្រប់គ្រងអោយបានប្រសើរឡើង ។

## ៣. ប្រភេទពន្ធ និង អាករ

យើងអាចធ្វើចំណាត់ថ្នាក់ពន្ធ ទៅតាមភ្នាក់ងារសេដ្ឋកិច្ច ដែលត្រូវបង់ពន្ធទាំងនោះដូចខាងក្រោម ÷

- ភ្នាក់ងារទាំងឡាយ ដែលយកពន្ធនៅលើទីផ្សារកត្តា ឬ ទីផ្សារផលិតកម្ម
- ភ្នាក់ងារទាំងឡាយ ដែលយកពន្ធលើអ្នកទិញ និង អ្នកលក់នៅទីផ្សារ
- ភ្នាក់ងារទាំងឡាយ ដែលយកពន្ធលើគ្រួសារ ឬ សហគ្រាស

យើងអាចធ្វើចំណាត់ថ្នាក់ពន្ធ ទៅតាមការគិតគូរលើប្រភេទពន្ធសំខាន់ៗ ដូចខាងក្រោម ÷


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

- ពន្ធលើបុគ្គល ដែលអាស្រ័យលើលទ្ធភាពរបស់អ្នកបង់ពន្ធអាចបង់បាន និង តាមឯកតាពន្ធ ឬ ពន្ធលើប្រតិបត្តិការ និង សកម្មភាពនានា ដូចជា ការទិញ លក់ ឬ ការកាន់កាប់ទ្រព្យសម្បត្តិ ។
- ពន្ធផ្ទាល់ និង ពន្ធប្រយោល
- ពន្ធវិជ្ជមាន និង ពន្ធអវិជ្ជមាន

**ពន្ធផ្ទាល់** នៅកម្ពុជារួមមាន ÷

- ពន្ធលើប្រាក់ចំណេញ
- ពន្ធលើប្រាក់បៀវត្ស និង
- ពន្ធលើការជួលទ្រព្យសម្បត្តិ
- ពន្ធលើជំនិះយានយន្ត
- ពន្ធប្រថាប់ត្រា

នៅកម្ពុជាមាន **ពន្ធប្រយោល** ដូចខាងក្រោម ÷

- ពន្ធលើផលរបរ
- អាករលើតម្លៃបន្ថែម
- អាករពិសេសលើផលិតផលមួយចំនួន
- ពន្ធគយលើការនាំចូល

ការបង្វែរ ឬ ការទូទាត់ជំនួយដោយរដ្ឋាភិបាលអាចចាត់ទុកជាពន្ធអវិជ្ជមាន ដោយសារការបង្វែរផ្តល់ត្រលប់មកវិញជាចំណូលទៅកាន់អង្គភាពនានា ខណៈដែលពន្ធដកយកចំណូលពីអង្គភាពទាំងនោះវិញ ។ ឧទាហរណ៍ វិភាគទានសន្តិសុខសង្គម ត្រូវបានគិតជាពន្ធលើប្រាក់ចំណូលអវិជ្ជមាន ហើយឧបត្ថម្ភកធនដល់អាជីវកម្មអាចគិតថាជាពន្ធលើអាជីវកម្មអវិជ្ជមាន ។

បណ្តា **ពន្ធដែលត្រូវបង់ចូលថវិការដ្ឋ** មានដូចតទៅ÷

- ពន្ធលើប្រាក់ចំណេញ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

- ពន្ធកាត់ទុក
- ពន្ធអប្បបរមា
- ពន្ធលើប្រាក់បៀវត្ស
- អាករលើតម្លៃបន្ថែម
- អាករពិសេសលើទំនិញនិងសេវាមួយចំនួន

បណ្ដា **ពន្ធដែលត្រូវបង់ចូលថវិកាខេត្ត - ក្រុង** មានដូចតទៅ៖

- អាករសម្រាប់បំភ្លឺសាធារណៈ
- អាករលើការស្នាក់នៅ
- ពន្ធប៉ាតង់
- ពន្ធលើដីទំនេរ
- ពន្ធប្រថាប់ត្រា
- ពន្ធសត្តឃាត
- ពន្ធតែមប្រិ៍
- ពន្ធលើមធ្យោបាយដឹកជញ្ជូន ។ល។

លក្ខណៈសំខាន់ៗនៃរចនាសម្ព័ន្ធសារពើពន្ធល្អ មានដូចខាងក្រោម លក្ខណៈសំខាន់ៗនៃរចនាសម្ព័ន្ធសារពើពន្ធល្អ មានដូចខាងក្រោម (Musgrave, 2004) ÷

- ចំណូលដែលប្រមូលបានត្រូវតែគ្រប់គ្រាន់
- ការបែងចែកបន្ទុកពន្ធត្រូវតែប្រកបដោយសមធម៌
- អ្វីដែលសំខាន់នោះមិនមែនស្ថិតនៅលើមុខសញ្ញាយកពន្ធទេ តែអ្នកណាដែលត្រូវរងបន្ទុកពន្ធ
- ត្រូវជ្រើសរើសពន្ធណា ដែលកាត់បន្ថយអោយដល់កម្រិតអប្បបរមា នូវអន្តរាគមន៍ជាមួយនឹងការសម្រេចចិត្ត


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ខាងផ្នែកសេដ្ឋកិច្ច នៅក្នុងបរិការណ៍ទីផ្សារមានប្រសិទ្ធភាព ។ ត្រូវកាត់បន្ថយ ជាអតិបរិមានូវ «បន្ទុកបន្ថែម» ។

- រចនាសម្ព័ន្ធពន្ធត្រូវជួយសម្រួលដល់ការអនុវត្តគោលនយោបាយសារពើពន្ធ ដើម្បីឱ្យមានស្ថិរភាព និង កំណើន
- ប្រព័ន្ធសារពើពន្ធត្រូវមានរដ្ឋបាលប្រកបដោយភាពយុត្តិធម៌ ឥតលំអៀង ហើយងាយយល់ សម្រាប់អ្នកបង់ពន្ធ
- តម្លៃរដ្ឋបាល និង តម្លៃអនុវត្តច្បាប់ត្រូវតែមានកម្រិតទាបសមស្រប ។

## ៤. ការពិពណ៌នាអំពីប្រភេទពន្ធនៅកម្ពុជា

### ៤.១. ពន្ធដែលត្រូវបង់ចូលថវិការដ្ឋ

#### ក. ពន្ធលើប្រាក់ចំណូល ពន្ធលើប្រាក់ចំណេញ និង ផលចំណេញមូលធន

**១.១. ពន្ធលើប្រាក់បៀវត្ស:** ពន្ធលើប្រាក់បៀវត្ស គឺជាពន្ធប្រចាំខែ កំណត់លើប្រាក់បៀវត្សដែលរូបវន្តបុគ្គលបានទទួល ក្នុងក្របខ័ណ្ឌនៃការបំពេញសកម្មភាពបម្រើការងារ ។ រូបវន្តបុគ្គលនិវាសនជននៅក្នុងព្រះរាជាណាចក្រកម្ពុជាត្រូវជាប់ពន្ធលើប្រាក់បៀវត្សចំពោះប្រាក់បៀវត្សប្រភពកម្ពុជា និងប្រាក់បៀវត្សប្រភពបរទេស ។ រូបវន្តបុគ្គលអនិវាសនជនត្រូវជាប់ពន្ធលើប្រាក់បៀវត្ស ចំពោះប្រាក់បៀវត្សប្រភពកម្ពុជា ។ សហគ្រាសដែលជានិយោជកត្រូវមានកាតព្វកិច្ចកាត់ទុកពន្ធលើប្រាក់បៀវត្ស នៅមុនពេលបើកប្រាក់បៀវត្សឱ្យដល់និយោជិត និងបង់ប្រាក់ពន្ធនេះជូនរដ្ឋបាលសារពើពន្ធ យ៉ាងយឺតបំផុតនៅថ្ងៃទី ១៥ នៃខែបន្ទាប់ពីខែដែលប្រាក់បៀវត្សត្រូវបានបើក ។

សម្រាប់និយោជិតនិវាសនជន ប្រាក់ពន្ធត្រូវបង់ត្រូវកំណត់លើប្រាក់បៀវត្សជាប់ពន្ធប្រចាំខែ និងត្រូវកាត់ទុក តាមអត្រាកំណើនតាមថ្នាក់ដូចតទៅ ÷

| តារាង ១៧.៥ អត្រាពន្ធលើប្រាក់បៀវត្ស | | | | |
|---|---|---|---|---|
| **គោលបៀវត្សប្រចាំខែត្រូវជាប់ពន្ធ** | | | | **អត្រាពន្ធ** |
| ពី | ០ ៛ | ដល់ | ៥០០.០០០ ៛ | ០% |
| ពី | ៥០០.០០១ ៛ | ដល់ | ១.២៥០.០០០ ៛ | ៥% |
| ពី | ១.២៥០.០០១ ៛ | ដល់ | ៨.៥០០.០០០ ៛ | ១០% |
| ពី | ៨.៥០០.០០១ ៛ | ដល់ | ១២.៥០០.០០០ ៛ | ១៥% |
| | | លើសពី | ១២.៥០០.០០០ ៛ | ២០% |

សម្រាប់និយោជិតអនិវាសនជន ពន្ធលើប្រាក់បៀវត្សត្រូវបានកាត់ទុកតាមអត្រា ២០% នៃទឹកប្រាក់ត្រូវបើកឱ្យមុនការកាត់ទុក ។ ពន្ធកាត់ទុកនេះគឺជាពន្ធចុងក្រោយនៃប្រាក់បៀវត្សសម្រាប់អនិវាសនជនជាអ្នកទទួល


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ប្រាក់បៀវត្ស ។

ចំពោះអត្ថប្រយោជន៍បន្ថែម ជារៀងរាល់ខែ សហគ្រាស ក្រុមហ៊ុន ត្រូវកាត់ទុកនិងបង់ប្រាក់ពន្ធតាមអត្រា ២០% នៃតម្លៃសរុបរបស់អត្ថប្រយោជន៍បន្ថែមដែលបានផ្តល់ឱ្យនិយោជិតទាំងអស់ ។ តម្លៃនៃអត្ថប្រយោជន៍បន្ថែម គឺជាតម្លៃទីផ្សារ រួមទាំងពន្ធអាករទាំងអស់ ។

**១.២. ពន្ធលើប្រាក់ចំណេញ:** ពន្ធលើប្រាក់ចំណេញត្រូវបានកំណត់លើអ្នកជាប់ពន្ធនិវាសនជន ចំពោះប្រាក់ចំណូលប្រភពកម្ពុជា និងប្រាក់ចំណូលប្រភពបរទេស ។ សំរាប់អ្នកជាប់ពន្ធអនិវាសនជនពន្ធលើប្រាក់ចំណេញកំណត់តែលើប្រាក់ចំណូលប្រភពកម្ពុជាប៉ុណ្ណោះ ។

**ប្រាក់ចំណេញជាប់ពន្ធ**- ប្រាក់ចំណេញជាប់ពន្ធ គឺជាប្រាក់ចំណេញសុទ្ធបានមកពីលទ្ធផលទាំងអស់នៃប្រតិបត្តិការអាជីវកម្មគ្រប់ប្រភេទ រួមបញ្ចូលទាំងចំណេញមូលធនដែលសម្រេចបានក្នុងពេលកំពុងប្រកបអាជីវកម្ម ឬនៅពេលបញ្ចប់អាជីវកម្ម ព្រមទាំងប្រាក់ចំណូលពីទ្រព្យសកម្មហិរញ្ញវត្ថុ ឬទ្រព្យសកម្មវិនិយោគ ការប្រាក់ ថ្លៃឈ្នួល និងសួយសារផង ។ ប្រាក់ចំណេញជាប់ពន្ធក៏រួមបញ្ចូលផងដែរនូវចំណេញមូលធនទាំងអស់ពីអចលនទ្រព្យ ទ្រព្យហិរញ្ញវត្ថុ ឬទ្រព្យវិនិយោគ ដែលសម្រេចបានមកពីប្រតិបត្តិការនានា ក្រៅពីប្រតិបត្តិការអាជីវកម្ម ។

**អត្រាពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ**- អត្រាពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ មានដូចតទៅ៖

១- ២០ ភាគរយ ចំពោះប្រាក់ចំណេញដែលសម្រេចបានដោយនីតិបុគ្គល ។

២- ៣០ ភាគរយ ចំពោះប្រាក់ចំណេញដែលសម្រេចបានក្រោមកិច្ចសន្យាបែងចែកផលិតផលប្រេងកាត និងឧស្ម័នធម្មជាតិ ឬសម្រេចបានពីការធ្វើអាជីវកម្មលើធនធានធម្មជាតិ រួមទាំងព្រៃឈើ រ៉ែ មាស ឬ ត្បូងថ្មមានតម្លៃនានា ។

៣- ៩ ភាគរយ ចំពោះប្រាក់ចំណេញរបស់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលទទួលស្គាល់ដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សម្រាប់រយៈពេលអន្តរកាល ៥ ឆ្នាំ ដោយគិតចាប់ផ្តើមពីថ្ងៃប្រកាសឱ្យប្រើ **ច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគ**នៃព្រះរាជាណាចក្រកម្ពុជា ។

៤- ០ ភាគរយ ចំពោះប្រាក់ចំណេញរបស់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលស្ថិតនៅក្នុងរយៈពេលលើកលែងពន្ធ ដែលកំណត់ដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។

៥- តាមតារាងអត្រាពន្ធកំណើនតាមថ្នាក់ខាងក្រោម ចំពោះប្រាក់ចំណេញដែលសម្រេចបានដោយរូបវន្តបុគ្គលនិង ចំណែកដែលត្រូវបែងចែកឱ្យសមាជិកម្នាក់ៗរបស់ក្រុមអាជីវកម្មដែលមិនត្រូវបានចាត់ទុកជានីតិបុគ្គល ÷

៦- ចំពោះសហគ្រាសដែលមានសកម្មភាពជាសំខាន់ ក្នុងការធានារ៉ាប់រង ឬធានារ៉ាប់រងបន្តលើជីវិត ទ្រព្យសម្បត្តិ ឬហានិភ័យផ្សេងៗ ពន្ធលើប្រាក់ចំណេញត្រូវបានកំណត់ខាងក្រោម ÷



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

| តារាង ១៧.៦. អត្រាពន្ធសម្រាប់ក្រុមហ៊ុននៅក្រោមរបបពិត | | | | |
|---|---|---|---|---|
| ភាគនៃប្រាក់ចំណេញប្រចាំឆ្នាំដែលត្រូវបង់ | | | | អត្រាពន្ធ |
| ពី | ០ ៛ | ដល់ | ៦.០០០.០០០ ៛ | ០% |
| ពី | ៦.០០០.០០១ ៛ | ដល់ | ១៥.០០០.០០០ ៛ | ៥% |
| ពី | ១៥.០០០.០០១ ៛ | ដល់ | ១០២.០០០.០០០ ៛ | ១០% |
| ពី | ១០២.០០០.០០១ ៛ | ដល់ | ១៥០.០០០.០០០ ៛ | ១៥% |
| | | លើសពី | ១៥០.០០០.០០០ ៛ | ២០% |

ក. ៥% នៃបុព្វលាភធានារ៉ាប់រងដុលដែលទទួលបាននៅក្នុងឆ្នាំជាប់ពន្ធ ចំពោះការធានារ៉ាប់រង ឬធានារ៉ាប់រងបន្តនូវហានិភ័យនៅព្រះរាជាណាចក្រកម្ពុជា

ខ. តាមអត្រាទាំងឡាយដូចមានចែងក្នុងចំណុច ១-២-៣-៤ និង ៥ ខាងលើ ចំពោះសកម្មភាពដទៃទៀត ដែលមិនមែនជាការធានារ៉ាប់រងឬធានារ៉ាប់រងបន្ត ។

**ប្រាក់រំដោះពន្ធលើប្រាក់ចំណេញ**- អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស រួមទាំងគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលជាប់ពន្ធលើប្រាក់ចំណេញតាមអត្រា ៩% ត្រូវមានកាតព្វកិច្ចបង់ប្រាក់រំដោះពន្ធលើប្រាក់ចំណេញប្រចាំខែ តាមអត្រា ១% នៃផលរបរ គិតរួមបញ្ចូលទាំងពន្ធអាករទាំងអស់ វៀរលែងតែអាករលើតម្លៃបន្ថែមដែលសម្រេចបានក្នុងខែមុន យ៉ាងយឺតបំផុតត្រឹមថ្ងៃទី ១៥ នៃខែបន្ទាប់ ។ ផលរបរនៃគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលស្ថិតក្នុងរយៈពេលលើកលែងពន្ធត្រូវបាន លើកលែងពីការបង់ប្រាក់រំដោះនេះ ។ ប្រាក់រំដោះពន្ធលើប្រាក់ចំណេញនឹងត្រូវបានយកទៅកាត់កងពីពន្ធលើប្រាក់ចំណេញ នៅពេលធ្វើការទូទាត់ប្រចាំឆ្នាំ។

**ពន្ធលើប្រាក់ចំណេញបន្ថែមលើការបែងចែកភាគលាភ**- នៅពេលបែងចែកភាគលាភ អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ត្រូវបង់ពន្ធលើប្រាក់ចំណេញបន្ថែមលើការបែងចែកភាគលាភ ដូចតទៅ÷

១- ពន្ធលើប្រាក់ចំណេញបន្ថែមត្រូវបង់ក្នុងចំនួនស្មើនឹង ២០ ភាគរយ នៃទឹកប្រាក់ត្រូវបែងចែក ចំពោះ÷

ក. ការបែងចែកប្រាក់ចំណេញរក្សាទុក ឬប្រាក់ចំណេញប្រចាំឆ្នាំក្រោយការបង់ពន្ធលើប្រាក់ចំណេញ ប្រសិនបើអ្នកជាប់ពន្ធធ្វើការបែងចែកប្រាក់ចំណេញរក្សាទុក ឬប្រាក់ចំណេញប្រចាំឆ្នាំ ដែលបានបង់ពន្ធលើប្រាក់ចំណេញ តាមអត្រា ០ ភាគរយ ។

ខ. ការបែងចែកដទៃទៀត វៀរលែងតែការបែងចែកដែលបានកំណត់ក្នុងចំណុច ២ និង ចំណុច ៣ ខាងក្រោមនេះ និងការបង់សងវិញនូវមូលធន ។

២- ពន្ធលើប្រាក់ចំណេញបន្ថែមត្រូវបង់ក្នុងចំនួនស្មើនឹង ១១ ភាគ ៨១ នៃទឹកប្រាក់ត្រូវបែងចែកចំពោះការបែងចែកប្រាក់ចំណេញរក្សាទុក ឬប្រាក់ចំណេញប្រចាំឆ្នាំក្រោយការបង់ពន្ធលើប្រាក់ចំណេញ ប្រសិនបើអ្នកជាប់ពន្ធធ្វើការបែងចែកប្រាក់ចំណេញរក្សាទុក ឬ ប្រាក់ចំណេញប្រចាំឆ្នាំ ដែលបានបង់ពន្ធលើប្រាក់ចំណេញតាមអត្រា ៩ ភាគរយ ។

៣- ពន្ធលើប្រាក់ចំណេញបន្ថែមមិនត្រូវអនុវត្តទេ ចំពោះការបែងចែកប្រាក់ចំណេញរក្សាទុក ឬ ប្រាក់ចំណេញប្រចាំឆ្នាំ ក្រោយការបង់ពន្ធលើប្រាក់ចំណេញ ប្រសិនបើអ្នកជាប់ពន្ធធ្វើការបែងចែកប្រាក់ចំណេញរក្សាទុក ឬប្រាក់ចំណេញប្រចាំឆ្នាំ ដែលបានបង់ពន្ធលើប្រាក់ចំណេញតាមអត្រា ២០ ភាគរយ ឬអត្រា ៣០ ភាគរយ ។

### ១.៣. ពន្ធកាត់ទុក

**ពន្ធកាត់ទុកលើនិវាសនជន**- អ្នកជាប់ពន្ធនិវាសនជនដែលប្រកបអាជីវកម្ម ដែលបានធ្វើការទូទាត់ជាសាច់ប្រាក់ ឬជាវត្ថុឱ្យដល់អ្នកជាប់ពន្ធនិវាសនជនត្រូវកាត់ទុកនិង បង់ប្រាក់ពន្ធទៅតាមអត្រាដូចខាងក្រោមលើចំនួនទូទាត់មុនការកាត់ទុកប្រាក់ពន្ធ ÷

ក. អត្រា ១៥% ចំពោះ ÷

- ប្រាក់ចំណូល ដែលរូបវន្តបុគ្គលបានទទួលពីការបំពេញសេវានានា រួមទាំងការគ្រប់គ្រង ឬការពិគ្រោះយោបល់ ឬ សេវាប្រហាក់ប្រហែល
- សួយសារចំពោះទ្រព្យអរូបីនិងភាគកម្មក្នុងធនធានរ៉ែ ហើយនិងការប្រាក់ដែលអ្នកជាប់ពន្ធនិវាសនជន ដែលប្រកបអាជីវកម្មដែលមិនមែនជាធនាគារ ឬស្ថាប័នសញ្ជ័យធនក្នុងស្រុកបង់ឱ្យទៅអ្នកជាប់ពន្ធនិវាសនជន

ខ. អត្រា ១០% ចំពោះប្រាក់ចំណូលពីការឱ្យជួលចលនឬ អចលនទ្រព្យ

គ. អត្រា ៦% ចំពោះការប្រាក់ដែលធនាគារ ឬស្ថាប័នសញ្ជ័យធនក្នុងស្រុកបង់ឱ្យទៅអ្នកជាប់ពន្ធនិវាសនជន ដែលមានគណនីបញ្ញើមានកាលកំណត់

ឃ. អត្រា ៤% ចំពោះការប្រាក់ដែលធនាគារ ឬស្ថាប័នសញ្ជ័យធនក្នុងស្រុកបង់ឱ្យទៅអ្នកជាប់ពន្ធនិវាសនជន ដែលមានគណនីសន្សំគ្មានកាលកំណត់ ។

ការកាត់ទុកខាងលើនេះមិនត្រូវអនុវត្តទេចំពោះការប្រាក់ដែលបង់ទៅឱ្យធនាគារ និងស្ថាប័នសញ្ជ័យក្នុងស្រុក និង ការទូទាត់ចំពោះប្រាក់ចំណូលលើកលែងពន្ធដូចមានចែងក្នុងមាត្រា ៩ ថ្មី នៃច្បាប់ស្តីពីសារពើពន្ធ ។

**ពន្ធកាត់ទុកលើអនិវាសនជន**- អ្នកជាប់ពន្ធនិវាសនជន ដែលប្រកបអាជីវកម្មដែលធ្វើការទូទាត់ប្រាក់ចំណូលដូចខាងក្រោមនេះឱ្យទៅអ្នកជាប់ពន្ធអនិវាសនជនត្រូវកាត់ទុក និងបង់នូវប្រាក់ពន្ធតាមអត្រា ១៤% នៃទឹកប្រាក់ត្រូវបើក ÷



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ក- ការប្រាក់

ខ- សួយសារ ថ្លៃឈ្នួល និងប្រាក់ចំណូលផ្សេងៗ ទាក់ទិននឹងការប្រើប្រាស់ទ្រព្យសម្បត្តិ

គ- ការទូទាត់ចំពោះសេវាគ្រប់គ្រង និងសេវាបច្ចេកទេសនានា

ឃ- ភាគលាភ ។

សហគ្រាសក្រុមហ៊ុន ត្រូវដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធដែលបានកាត់ទុកក្នុងរយៈពេល ១៥ ថ្ងៃក្រោយដំណាច់ខែដែលមានការកាត់ទុក ។ ពេលកាត់ទុក គឺជាពេលដែលចំណាយត្រូវបានកត់ត្រាក្នុងបញ្ជីគណនេយ្យ ។

## ១.៤. ពន្ធអប្បបរមា

ពន្ធអប្បបរមាជាពន្ធមួយដាច់ដោយឡែកនិងផ្សេងពីពន្ធលើប្រាក់ចំណេញ ។ ពន្ធនេះត្រូវបង់ដោយអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស លើកលែងតែគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ តាមអត្រា ១ ភាគរយលើផលរបរប្រចាំឆ្នាំ រួមបញ្ចូលទាំងពន្ធអាករនានា វៀរលែងតែអាករលើតម្លៃបន្ថែម ។ ពន្ធនេះត្រូវបង់នៅពេលទូទាត់ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ ហើយអាចត្រូវបានកាត់បន្ថយដោយពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ ។

## ១.៥. ពន្ធលើប្រាក់ចំណេញមូលធន

ការយកពន្ធទ្វេដងលើប្រាក់ចំណេញសារជីវកម្មអាចត្រូវចៀសវាងបាន ដោយការផ្តល់ភាគចំណេញក្រោយកាត់ពន្ធដល់បុគ្គលទាំងឡាយ ដែលទទួលផលពីប្រាក់ចំណេញ ដែលបែងចែកដោយសារជីវកម្ម ដែលបានទូទាត់ពន្ធលើប្រាក់ចំណេញរួច ។ នៅពេលគ្មានភាគចំណេញក្រោយកាត់ពន្ធផ្ទាល់ខ្លួនចំពោះការបែងចែកប្រាក់ចំណេញសារជីវកម្ម មានការជំរុញលើកទឹកចិត្តក្នុងការមិនបែងចែកប្រាក់ចំណេញសារជីវកម្មជាភាគលាភ ក៏ប៉ុន្តែរក្សាទុកប្រាក់ចំណេញទាំងនោះនៅក្នុងក្រុមហ៊ុន ដើម្បីការវិនិយោគបន្តទៅថ្ងៃមុខ ជាហេតុនាំឱ្យរួចពន្ធផ្ទាល់ខ្លួន ។ ប្រាក់ចំណេញមិនបានបែងចែកទៅសមាជិករួមទុន ត្រូវបានបន្ថែមទៅលើតម្លៃមូលធនរបស់ក្រុមហ៊ុន ហើយអាចប្រើប្រាស់ក្នុងការធ្វើហិរញ្ញប្បទានវិនិយោគដែលឥតត្រូវបានគិតពន្ធ ។ ដោយការរក្សាទុក ជាជាងការទូទាត់ប្រាក់ចំណេញនោះឱ្យសមាជិករួមទុនសារជីវកម្មផ្តល់សមាជិករួមទុនម្នាក់ៗ នូវផលប្រយោជន៍លើប្រាក់ចំណេញមូលធន។

ពន្ធលើប្រាក់ចំណេញមូលធន ទោះជាយ៉ាងណាត្រូវបានគិតជាកាតព្វកិច្ចពន្ធនៅពេលដែលបុគ្គលម្នាក់លក់ទ្រព្យ ឬ ភាគហ៊ុនរបស់ក្រុមហ៊ុន ។ ពន្ធលើប្រាក់ចំណេញមូលធនត្រូវបានគិតអត្រាថេរ ។

## ២. ពន្ធលើកម្មសិទ្ធិ និង ទ្រព្យសម្បត្តិ

ពន្ធលើកម្មសិទ្ធិ និង ទ្រព្យសម្បត្តិអាចត្រូវបានគិតលើចំណែកនៃកម្មសិទ្ធិ (អាចទូទាត់បាន) និង



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

អាចគិតពន្ធជារៀយៗ តាមប្រភេទឯកតា ឬ អាចគិតលើការកាន់កាប់កម្មសិទ្ធិសរុបរបស់បុគ្គលម្នាក់ ឬ តាមតម្លៃពិតតាមធម្មជាតិនៃពន្ធផ្ទាល់ខ្លួន ។ ការជជែកវែកញែកលើការពន្ធលើទ្រព្យសម្បត្តិអាចនឹងត្រូវគិតលើផល-ប្រយោជន៍ និង លទ្ធភាពក្នុងការបង់ពន្ធ ។ នៅកម្ពុជា ពន្ធលើកម្មសិទ្ធិមានទម្រង់ជាពន្ធលើការជួលកម្មសិទ្ធិ ។

**១.៦. ពន្ធលើការជួលកម្មសិទ្ធិ ឬ ទ្រព្យសម្បត្តិ អាជីវកម្ម** (ក្រៅពីអាជីវកម្មទាំងឡាយដែលស្ថិតនៅក្នុងរបបស្វ័យប្រកាស) ការជួលដីធ្លី អាគារ សម្ភារៈ ឃ្លាំង ជាដើម ត្រូវជាប់ពន្ធលើការជួលកម្មសិទ្ធិទាំងអស់ ។ ពន្ធដែលត្រូវគិតនៅអត្រា ១០% លើតម្លៃជួល ។ ពន្ធនេះគិតដោយផ្ទាល់លើម្ចាស់កម្មសិទ្ធិ ប៉ុន្តែមិនកាត់យកពីការទូទាត់ប្រាក់ជួល ដែលធ្វើឡើងដោយសហគ្រាសស្ថិតនៅក្រោមរបបស្វ័យប្រកាសឡើយ ។ ម្ចាស់កម្មសិទ្ធិដែលមានប្រាក់ចំណូលប្រចាំខែ បានមកពីការជួលតិចជាង ៥០០.០០០ រៀល ត្រូវទទួលបានការអនុគ្រោះពន្ធ ។

## គ. ពន្ធលើការប្រើប្រាស់

ពន្ធលើការលក់ ក៏ដូចជាពន្ធលើប្រាក់ចំណូលដែរ ត្រូវបានគិតពន្ធលើលំហូរសាច់ប្រាក់ចូល ដែលបង្កើតឡើងនៅក្នុងផលិតកម្មនៃទិន្នផលបច្ចុប្បន្ន ។ ពន្ធលើប្រាក់ចំណូលត្រូវបានគិតលើប្រាក់ចំណូលសុទ្ធ ដែលរកបានដោយគ្រួសារ ។ ពន្ធលើការលក់ ត្រូវគិតលើការលក់របស់ក្រុមហ៊ុនអាជីវកម្ម ។ ពន្ធលើការលក់ខុសពីពន្ធលើប្រាក់ចំណូលត្រង់ថា ពន្ធទាំងនេះមានឯកតាមិនដូចពន្ធផ្ទាល់ខ្លួនឡើយ ។

**១.៧. អាករលើតម្លៃបន្ថែម:** អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសដែលធ្វើការផ្គត់ផ្គង់ជាប់អាករ ត្រូវមានកាតព្វកិច្ចចុះបញ្ជីអាករលើតម្លៃបន្ថែម និងប្រមូលអាករលើតម្លៃបន្ថែម លើការផ្គត់ផ្គង់ទំនិញឬសេវាឱ្យអតិថិជន ។

ទំនិញ សំដៅដល់ទ្រព្យរូបី ក្រៅពីដីធ្លី និងប្រាក់កាស រីឯសេវាសំដៅដល់ការផ្តល់អ្វីមួយដែលមានតម្លៃក្រៅពីទំនិញ ដីធ្លី និងប្រាក់កាស ។

ការផ្គត់ផ្គង់ជាប់អាករ សំដៅដល់÷

- ការផ្គត់ផ្គង់ទំនិញ ឬសេវាដោយបុគ្គលជាប់អាករនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- ការដកយកទំនិញមកប្រើប្រាស់ផ្ទាល់ខ្លួនដោយបុគ្គលជាប់អាករ
- ការផ្តល់ជាអំណោយ ឬការផ្គត់ផ្គង់ក្រោមតម្លៃពិតនូវទំនិញ ឬសេវាដោយបុគ្គលជាប់អាករ
- ការនាំចូលទំនិញមកក្នុងតំបន់ត្រួតពិនិត្យគយនៃព្រះរាជាណាចក្រកម្ពុជា ។

ការផ្គត់ផ្គង់មិនជាប់អាករមានដូចតទៅ÷

- សេវាប្រៃសណីយ៍សាធារណៈ
- សេវារបស់មន្ទីរពេទ្យ និងគ្លីនិក សេវាខាងវេជ្ជសាស្ត្រ និងទន្តសាស្ត្រនិងការលក់ទំនិញបន្ទាប់បន្សំ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ខាងវេជ្ជសាស្ត្រនិងទន្តសាស្ត្រ ដែលទាក់ទិននឹងការបំពេញសេវាទាំងនេះ

- សេវាដឹកជញ្ជូនអ្នកដំណើរដោយប្រព័ន្ធដឹកជញ្ជូនសាធារណៈ ដែលជាកម្មសិទ្ធិទាំងស្រុងរបស់រដ្ឋ
- សេវាធានារ៉ាប់រង
- សេវាជាមូលដ្ឋានខាងហិរញ្ញវត្ថុ ដែលត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ការនាំចូលសម្ភារៈប្រើប្រាស់ផ្ទាល់ខ្លួនដែលរួចពន្ធគយ ក្នុងកម្រិតតម្លៃដែលត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- សកម្មភាពមិនស្វែងរកចំណេញដើម្បីបំរើផលប្រយោជន៍សាធារណៈ ដែលបានទទួលស្គាល់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។
- ការនាំចូលនិងការទិញទំនិញសម្រាប់ ឬដោយបេសកកម្មទូត និងកុងស៊ុលបរទេសអង្គការអន្តរជាតិ និងទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា សម្រាប់យកមកប្រើនៅក្នុងការបំពេញមុខងារជាផ្លូវការរបស់ខ្លួន ។

អត្រាអាករលើតម្លៃបន្ថែមមាន ៖

- ១០% សម្រាប់ការនាំចូល ឬការផ្គត់ផ្គង់ទំនិញឬសេវាក្នុងព្រះរាជាណាចក្រកម្ពុជា
- ០% សម្រាប់ការនាំចេញ ។

ការគណនាប្រាក់អាករត្រូវបង់ ៖

- ប្រាក់អាករដែលបានបង់នៅពេលនាំចូលទំនិញ ឬប្រាក់អាករដែលបានបង់លើការទិញ ទំនិញឬ សេវាសម្រាប់ប្រកបអាជីវកម្ម ហៅថា «**អាករលើធាតុចូល**»
- ប្រាក់អាករដែលបានគិតយកពីអតិថិជនពីការផ្គត់ផ្គង់ទំនិញឬសេវា ហៅថា «**អាករលើធាតុចេញ**»

**ប្រាក់អាករត្រូវបង់ = អាករលើធាតុចេញ - អាករលើធាតុចូល ៗ**

អាករលើធាតុចូលដែលមិនអាចកាត់កងបាន ៖

អាករលើធាតុចូលដែលមិនអាចកាត់កងបានរួមមានប្រាក់អាករដែលបានបង់លើ ៖

- ចំណាយទទួលភ្ញៀវ ការកំសាន្ត ឬការសម្រាកលំហែ លើកលែងតែបុគ្គលជាប់អាករមានអាជីវកម្មជាអ្នកផ្គត់ផ្គង់ការទទួលភ្ញៀវ ការកំសាន្ត ឬការសម្រាកលំហែ ។
- ការទិញឬការនាំចូល រថយន្ត លើកលែងតែបុគ្គលជាប់អាករប្រកបអាជីវកម្មជាអ្នកលក់ ឬជួលរថយន្ត។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

- ការទិញឬការនាំចូលផលិតផលតេលសិលាមួយចំនួន លើកលែងតែបុគ្គលជាប់អាករប្រកបអាជីវកម្មជាអ្នកផ្គត់ផ្គង់ផលិតផលតេលសិលាទាំងនោះ ។

អ្នកជាប់ពន្ធដែលធ្វើការផ្គត់ផ្គង់ជាប់អាករនូវទំនិញឬសេវា ត្រូវទទួលខុសត្រូវក្នុងការបង់ប្រាក់អាករជូនរដ្ឋបាលសារពើពន្ធ យ៉ាងយឺតបំផុតត្រឹមថ្ងៃទី២០ នៃខែបន្ទាប់ពីខែដែលមានការផ្គត់ផ្គង់ ។

**១.៨. អាករលើផលរបរ** អាករលើផលរបរអាជីវកម្មប្រចាំខែ ត្រូវអនុវត្តលើបុគ្គលទាំងឡាយនៅក្រោមរបបម៉ៅការ។ កសិផលលក់ដោយផលិតករដំបូងគេ (ប៉ុន្តែមិនមែនជាឈ្មួញ) និងឈ្មួញចល័ត និងការកសាងអចិន្ត្រៃយ៍ខ្នាតតូច ដែលត្រូវបានកំណត់ដោយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និងសហគ្រាសដែលធ្វើប្រតិបត្តិការដោយច្បាប់ស្តីពីវិនិយោគ ដែលនឹងត្រូវគិតអត្រាពន្ធតែមួយ ២% ។

**១.៩. អាករពិសេសលើទំនិញ និង សេវាមួយចំនួន** ពន្ធលើផលិតផលមួយចំនួន ទាំងផលិតនៅក្នុងស្រុក និងនាំចូល និងសេវាផ្សេងៗ ។ ការបង់ពន្ធអាករពិសេសលើបារីត្រូវបានធានាដោយការបិទតែម ។

ទំនិញដែលត្រូវជាប់អាករពិសេសលើទំនិញ និង សេវាមួយចំនួន ÷

- រថយន្ត (៣០%)
- គ្រឿងបន្លាស់ (២០%) និង
- ម៉ូតូ និង គ្រឿងបន្លាស់ (១០%)
- ផលិតផលតេលសិលា (២០%)
- ភេសជ្ជៈ និង គ្រឿងស្រវឹង (១០%)
- ស្រាបៀរ (២០%)

សេវាខាងក្រោមនេះត្រូវជាប់អាករលើសេវាកម្ម ÷

- សេវាកំសាន្ត (១០%)
- សេវាដឹកជញ្ជូនអ្នកដំណើរតាមអាកាស និង សេវាទូរស័ព្ទ (១០%) ។

**១.១០. ពន្ធគយលើការនាំចូល** ពន្ធគយលើការនាំចូល ជាពន្ធលើការលក់ផលិតផលនាំចូលពីបរទេសនៅក្នុងស្រុក ។ ដូច្នេះ ពន្ធនាំចូល គឺជាពន្ធរើសអើង ដែលធ្វើឱ្យទំនិញបរទេសមានតម្លៃថ្លៃជាងទំនិញផលិតនៅក្នុងស្រុក ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

តារាងពន្ធគយ (ផ្អែកលើចំណាត់ថ្នាក់របស់ប្រព័ន្ធសុខដុមនីយកម្ម) ដែលបានគិតពន្ធលើទំនិញនាំចេញទាំងអស់ ។ អត្រាសំខាន់ៗមាន ៤ ប្រភេទ÷

១- អត្រា ០%

២- អត្រា ៧% លើទំនិញចាំបាច់ និង វត្ថុធាតុ ដើមមូលដ្ឋាន

៣- អត្រា ១៥% លើទំនិញពាក់កណ្តាលសម្រេច គ្រឿងម៉ាស៊ីន និង សម្ភារៈ និង

៤- អត្រា ៣៥% លើទំនិញប្រើប្រាស់ និង វត្ថុធាតុដើមសម្រាប់សំណង់ ។ មាស និង ប្រាក់ត្រូវគិតពន្ធធម្មតា ០,៣% ។

អត្រាទាំងអស់ត្រូវគិតតាមតម្លៃ និងពន្ធគយទាំងអស់ត្រូវគិតតាមមូលដ្ឋាន CIF លើកតែផលិតផលតេលសិលា ដីគីមី ដែលតម្លៃនៃគោលបំណងយកពន្ធគយត្រូវបានកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ ការលើកលែងអាករលើការនាំចូលរួមមាន÷

១- ការនាំចូលសម្រាប់គម្រោង និង ការវិនិយោគអនុម័តដោយក្រុមប្រឹក្សាអភិវឌ្ឍន៍ជាតិ នៅពេលនាំចូល

២- ថ្នាំបាណកឃាត ថ្នាំកំចាត់សត្វល្អិតចង្រៃ និង គ្រឿងយន្តកសិកម្ម (លើកលែងតែត្រាក់ទ័រ) និង

៣- ការនាំចូលរបស់ស្ថានទូត អង្គការអន្តរជាតិ ដែលផ្តល់ជំនួយមនុស្សធម៌ និង គម្រោងហិរញ្ញប្បទានដោយអំណោយ និង ជំនួយទ្វេភាគី ។

### ១.១១. ការផ្ទេរតម្លៃ (Transfer pricing)

នៅក្នុងមាត្រា ១៨ នៃច្បាប់ពន្ធអនុញ្ញាតអោយអាជ្ញាធរមានសមត្ថកិច្ចកម្ពុជា មានសិទ្ធិអំណាចទូលំទូលាយក្នុងការបែងចែកឡើងវិញ លើប្រាក់ចំណូល និងចំណាយរវាងបុគ្គលជាប់ទាក់ទិន (Related Parties) ដើម្បីការពារ ការគេចវេសពន្ធ តាមរយៈការផ្ទេរតម្លៃ ដើម្បីកាត់បន្ថយប្រាក់ចំណេញជាប់ពន្ធ ។

## ២. ពន្ធដែលត្រូវបង់ចូលថវិកាខេត្ត-ក្រុង

**២.១. ពន្ធលើដីទំនេរ** ពន្ធលើដីធ្លី ដែលមាននៅក្នុងទីក្រុង និង តំបន់ ដែលពុំមានសំណង់ ឬ មានសំណង់ប៉ុន្តែមិនបានប្រើប្រាស់ ។ ពន្ធត្រូវបានគណនានៅអត្រា ២% នៃតម្លៃដី ដែលត្រូវបានវាយតម្លៃដោយគណៈកម្មការវាយតម្លៃដីទំនេរនៅថ្ងៃទី ៣០ មិថុនា ជារៀងរាល់ឆ្នាំ ។ ដីមានទំហំ ១.២០០ ម៉ែត្រការេពុំត្រូវបានគិតពន្ធឡើយ ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ម្ចាស់ដីត្រូវបានតម្រូវឱ្យបង់ពន្ធនៅរៀងរាល់ថ្ងៃទី ៣០ ខែ វិច្ឆិកា ជារៀងរាល់ឆ្នាំ ។

**២.២. ពន្ធប្រថាប់ត្រា** (ពន្ធលើការផ្ទេរកម្មសិទ្ធិ) មានឯកសារមួយចំនួនទាក់ទងនឹងការបង្កើត ការរំលាយ ឬ បង្រួមចូលគ្នានៃអាជីវកម្ម ឬ ការផ្ទេរឈ្មោះកម្មសិទ្ធិទ្រព្យសម្បត្តិមួយចំនួន (ដូចជា ដី សំណង់អាគារ ជំនិះ យានយន្ត និង នាវា) នឹងត្រូវជាប់ពន្ធប្រថាប់ត្រា ។ ពន្ធនេះនឹងត្រូវគិតលើអត្រា ៤% នៃតម្លៃត្រូវផ្ទេរ ។

ការផ្ទេរកម្មសិទ្ធិ ដែលបញ្ជាដោយរដ្ឋត្រូវបានអនុគ្រោះពន្ធ ដូចជាការផ្ទេររបស់រដ្ឋាភិបាល ការប្រើប្រាស់សាធារណៈ និង អង្គការសប្បុរសធម៌មិនានា ។ ការលក់យានជំនិះក៏ត្រូវបានអនុគ្រោះពន្ធដែរ ប្រសិនបើអ្នកលក់ត្រូវបង់ពន្ធលើផលរបរ ឬ ពន្ធលើប្រាក់ចំណេញ ។

**២.៣. ពន្ធប៉ាតង់** ការចុះបញ្ជីប្រចាំឆ្នាំ ឬ តម្លៃអជ្ញាប័ណ្ណ ត្រូវបានគិតពន្ធលើគ្រប់អាជីវកម្មឧស្សាហកម្ម និង សេវាកម្ម (ទាំង អ្នកបង់ពន្ធរបបស្វ័យប្រកាស និង របបម៉ៅការ) ។ មូលដ្ឋានគិតពន្ធគឺ ផលរបរពីឆ្នាំមុន ឬ ការប៉ាន់ប្រមាណលើផលរបរ ។ អាជីវកម្មថ្មីត្រូវបានគិតពន្ធលើមូលដ្ឋាននៃការប៉ាន់ប្រមាណ ។ កសិករ និង គ្រួសារធ្វើអាជីវកម្មត្រូវបានទទួលការអនុគ្រោះពន្ធប៉ាតង់ ។ ប្រកាសនីយប័ត្រពន្ធប៉ាតង់ត្រូវបានបង្ហាញនៅបរិវេណ ឬ ទីតាំងអាគារអាជីវកម្ម ។ អ្នកបង់ពន្ធត្រូវបញ្ជូនបញ្ជីពន្ធប៉ាតង់ និងទូទាត់ពន្ធនេះនៅចុងខែ មីនា ជារៀងរាល់ឆ្នាំ ។ ចំពោះអាជីវកម្ម និង ឧស្សាហកម្ម និង ចំពោះសេវាកម្ម ពន្ធប៉ាតង់ត្រូវបានគិតតាមផលរបរប្រចាំ ។

| | | | | | |
|---|---|---|---|---|---|
| ពី | ០ | ទៅ | ៧.៥០០.០០០ រៀល | ត្រូវបង់ពន្ធប៉ាតង់ | ១៥.០០០៛ |
| ពី | ៧.៥០០.០០០ ៛ | ទៅ | ១១២.៥០០.០០០ ៛ | ត្រូវបង់ពន្ធប៉ាតង់ | ២១.០០០ ៛ |
| ពី | ១២.៥០០.០០១ ៛ | ទៅ | ២៥.០០០.០០០ ៛ | ត្រូវបង់ពន្ធប៉ាតង់ | ២៧.០០០៛ |
| ពី | ២៥.០០០.០០១៛ | ទៅ | ៣០.០០០.០០០៛ | ត្រូវបង់ពន្ធប៉ាតង់ | ៤០.០០០ ៛ |
| ពី | ៣០.០០០.០០១៛ | ទៅ | ៣៧.៥០០.០០០ ៛ | ត្រូវបង់ពន្ធប៉ាតង់ | ៦០.០០០៛ |
| ពី | ៣៧.៥០០.០០១ ៛ | ទៅ | ៥០០.០០០ ៛ | ត្រូវបង់ពន្ធប៉ាតង់ | ៩០.០០០ ៛ |
| ពី | ៥០.០០០.០០១ ៛ | ទៅ | ៦២.០០០.០០០៛ | ត្រូវបង់ពន្ធប៉ាតង់ | ១៤០.០០០ ៛ |
| ពី | ៦២.០០០.០០១៛ | ទៅ | ៧៥.០០០.០០០ ៛ | ត្រូវបង់ពន្ធប៉ាតង់ | ១៩០.០០០ ៛ |
| ពី | ៧៥.០០០.០០១ ៛ | ទៅ | ១០០ លាន ៛ | ត្រូវបង់ពន្ធប៉ាតង់ | ២៤០.០០០ ៛ |
| ពី | ១០០.០០០.០០១៛ | ទៅ | ១ កោដិ ៛ | ត្រូវបង់ពន្ធប៉ាតង់ | ០,១% នៃផលរបរ |



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ២.៤. អាករបំភ្លឺសាធារណៈ

អាករសម្រាប់បំភ្លឺសាធារណៈ ត្រូវបានកំណត់តាមអត្រា ៣% លើការផ្គត់ផ្គង់គ្រប់ដំណាក់កាលនូវសុរាម៉េរ៉យនិង បារី ។ អ្នកជាប់ពន្ធដែលធ្វើការផ្គត់ផ្គង់ផលិតផលទាំងនេះត្រូវទទួលខុសត្រូវក្នុងការបង់ប្រាក់អាករនេះជូនរដ្ឋបាលសារពើពន្ធ យ៉ាងយឺតបំផុតត្រឹមថ្ងៃ ទី១៥ នៃខែបន្ទាប់ពីខែដែលមានការផ្គត់ផ្គង់ ។

## ២.៥. ពន្ធលើសត្តឃាត

ពន្ធនេះយកពីមណ្ឌលសត្តឃាតនានាផ្អែកតាមតម្លៃនៃបសុសត្វ ។ ពន្ធសត្តឃាតត្រូវបានលើកលែងចំពោះ÷

១- សត្តឃាត ដើម្បីអបអរពិធីបុណ្យប្រពៃណី

២- សត្តឃាតសម្រាប់គោលដៅស្រាវជ្រាវ និង

៣- សត្វសម្លាប់ដោយគ្រោះថ្នាក់ ។

អត្រាពន្ធតែមួយ ៣% ត្រូវបានកំណត់យកលើតម្លៃសត្វមួយក្បាលៗ ។

## ២.៦. ពន្ធលើជំនិះយានយន្ត

ពន្ធលើជំនិះយានយន្តត្រូវបានយកពីរថយន្ត និង ទូកជាប្រចាំឆ្នាំតាមការកំណត់ដូចតទៅ÷

- រថយន្តសណ្តោងៈ ១៦០.០០០ រៀល

- ឡាន÷

  - ចាប់ពីកម្លាំង ៩ សេះទៅ យកពន្ធ ៣៧.៥០០ និង ៥០.០០០ រៀល
  - កម្លាំងពី ៩ ទៅ ១២ សេះ យកពន្ធ ៥០.០០០ ទៅ ៧៥.០០០ រៀល
  - កម្លាំងលើសពី ១២ សេះ យកពន្ធ ៨៧.៥០០ ទៅ ១២៥.០០០ រៀល

- ម៉ូតូត្រូវគិតពន្ធ ៣.០០០ ទៅ ៧.៥០០ រៀល

- ទូកកម្លាំងតូច ត្រូវគិតពន្ធ ៥.០០០ រៀល

- នាវាដឹកទំនិញ (លើសពី ២.០០០ តោន) ត្រូវគិតពន្ធ ១.២០០.០០០ រៀល

- នាវានេសាទសមុទ្រ (មានកម្លាំងលើសពី ៥០០ សេះ) ត្រូវគិតពន្ធ ៣០០.០០០ រៀល ។

**២.៧. ពន្ធតែមប្រើ** ពន្ធអាចយកបានតាមរយៈតែមប្រើ ដែលបិទភ្ជាប់ទៅនឹងឯកសារផ្លូវការនានា និង បដាផ្សាយពាណិជ្ជកម្មធំៗ ។ អត្រាពន្ធមានខុសៗគ្នាទៅតាមកត្តាកំណត់ផ្សេងៗដូចជាទីតាំងដាក់បដា ការតាំងភ្លើងបំភ្លឺ និង ការប្រើប្រាស់ភាសា (ភាសាបរទេស ឬ ភាសាខ្មែរ) ។

## ៥. សមិទ្ធកម្មសារពើពន្ធនៅកម្ពុជា

### ៥.១. គោលនយោបាយសារពើពន្ធ

រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវកំណែទម្រង់សារពើពន្ធយ៉ាងទូលំទូលាយ ហើយចំណូលពន្ធដែលប្រមូលដោយអគ្គនាយកដ្ឋានពន្ធដារបានកើនឡើងចំនួន ១១ ដងក្នុងរយៈពេល ១១ ឆ្នាំកន្លងទៅនេះ ពី ១៥១,៨ ពាន់លានរៀលនៅក្នុងឆ្នាំ ១៩៩៨ ដល់ ១,៧៣៥ ពាន់លានរៀល នៅក្នុងឆ្នាំ ២០០៨ កន្លងទៅនេះ ។

ចំណូលពន្ធបានកើនឡើងជាប្រចាំបន្ទាប់ពីការដាក់អោយអនុវត្តនូវអាករលើតម្លៃបន្ថែមចាប់តាំងពីថ្ងៃទី ១ ខែ មករា ឆ្នាំ ១៩៩៩ ដែលដាក់អោយអនុវត្តចំពោះសហគ្រាសដែលស្ថិតនៅក្នុងរបបស្វ័យប្រកាស ។ នាពេលបច្ចុប្បន្ននេះ អាករលើតម្លៃបន្ថែមកំពុងអនុវត្តចំពោះសហគ្រាសធំ និង មធ្យម ។

**តារាងលេខ ១- ចំណូលពន្ធប្រមូលដោយអគ្គនាយកដ្ឋានពន្ធដារ (ពាន់លានរៀល)**

| ឆ្នាំ | 1998 | 1999 | 2000 | 2001 | 2002 | 2003 | 2004 | 2005 | 2006 | 2007 | 2008 |
|---|---|---|---|---|---|---|---|---|---|---|---|
| ចំណូលពន្ធ | 151.8 | 185.1 | 270.9 | 292.9 | 318.8 | 384.3 | 481.1 | 634.3 | 8856 | 1,259 | 1,735 |

*ប្រភព: ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ*

នៅក្នុងឆ្នាំ ២០០០ ឆ្នាំ ២០០៣ និង ឆ្នាំ ២០០៥ អគ្គនាយកដ្ឋានពន្ធដារបានអនុវត្តនូវការប្រមូលពន្ធតាមរបបពិត ចំពោះសហគ្រាសធុនមធ្យម និង ធុនធំ នៅក្នុងខេត្ត- ក្រុងចំនួន ១៦ ។ សហគ្រាសទាំងអស់ដែលស្ថិតនៅក្នុងរបបស្វ័យប្រកាសត្រូវបង់អាករលើតម្លៃបន្ថែម ។ នាពេលបច្ចុប្បន្ននេះ របបស្វ័យប្រកាសត្រូវបានអនុវត្តនៅក្នុងគ្រប់ខេត្តទាំងអស់ទូទាំងព្រះរាជាណាចក្រកម្ពុជា និង នៅក្នុងខណ្ឌទាំង ៧ នៃរាជធានីភ្នំពេញ ។ នៅចុងឆ្នាំ ២០០៨ កន្លងទៅនេះ មានសហគ្រាសចុះបញ្ជីចំនួន ១១.១៩៦ ដែលក្នុងនោះសហគ្រាស ចំនួន ១.៧៩៣ ជាសហគ្រាសធុនធំ និង សហគ្រាសចំនួន ៩.៤០៣ ជាសហគ្រាសធុនតូច និង មធ្យម ។

នៅក្នុងឆ្នាំ ២០០៣ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុបានធ្វើវិសោធនកម្មលើច្បាប់ស្តីពីសារពើពន្ធឆ្នាំ ១៩៩៧ ជាពិសេស លើបទប្បញ្ញត្តិដែលពាក់ព័ន្ធនឹងច្បាប់ស្តីពីវិនិយោគ ដោយផ្តោតជាសំខាន់លើចំណុចមួយចំនួន


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ដូចតទៅៈ

- ការធ្វើវិសោធនកម្មលើរយៈពេលលើកលែងពន្ធចំពោះគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលទទួលការលើកលែងពន្ធ ។
- ការដាក់អោយអនុវត្តនូវអត្រារំលស់ពិសេសចំនួន ៤០% ចំពោះគម្រោងវិនិយោគណាដែលមិនចង់អនុវត្តនូវរយៈពេលលើកលែងពន្ធលើពន្ធលើប្រាក់ចំណេញ ។
- ការកែប្រែនូវប្រព័ន្ធរំលស់ដោយអនុវត្តនូវវិធីសាស្ត្ររំលស់ស្មើភាគ (Straight line method) ចំពោះអាគារ និង វិធីសាស្ត្ររំលស់ថយចុះជាលំដាប់ (Declining balance method) ចំពោះទ្រព្យសកម្មផ្សេងទៀត ។
- ការដាក់អោយអនុវត្តនូវពន្ធកាត់ទុកលើប្រាក់ចំណេញបន្ថែមលើការបែងចែកភាគលាភ ។
- ការកាត់បន្ថយនូវអត្រាពន្ធកាត់ទុកលើអនិវាសនជន ។
- ការកាត់បន្ថយនូវអត្រាពន្ធកាត់ទុកលើនិវាសនជន ដែលអត្រាត្រូវបានកាត់បន្ថយពី ១៥% មកនៅត្រឹមអត្រា ៦% ចំពោះការប្រាក់ដែលធនាគារ ឬស្ថាប័នសញ្ជ័យធនក្នុងស្រុកបង់ឱ្យទៅអ្នកជាប់ពន្ធនិវាសនជន ដែលមានគណនីបញ្ញើមានកាលកំណត់ និង កាត់បន្ថយពី ៥% មកនៅត្រឹមអត្រា ៤% ចំពោះការប្រាក់ដែលធនាគារ ឬស្ថាប័នសញ្ជ័យធនក្នុងស្រុកបង់ឱ្យទៅអ្នកជាប់ពន្ធនិវាសនជន ដែលមានគណនីសន្សំគ្មានកាលកំណត់ ។
- បង្កើនអត្រាពន្ធលើប្រាក់បៀវត្សសម្រាប់អនិវាសនជន ពី ១៥% ដល់អត្រា ២០% ។
- ការឈប់អនុវត្តនូវពន្ធអប្បបរមា និង លើកលែងពីការបង់ប្រាក់រំដោះពន្ធលើប្រាក់ចំណេញប្រចាំខែតាមអត្រា ១% នៃផលរបរចំពោះគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលស្ថិតក្នុងរយៈពេលលើកលែងពន្ធ ។
- ការកែលម្អនូវវិធានមួយចំនួន ដើម្បីពង្រឹងការប្រមូលពន្ធ ។

អគ្គនាយកដ្ឋានពន្ធដារបានបង្កើតឡើងនូវការិយាល័យសហគ្រាសធុនធំ ដើម្បីធានាអោយបាននូវការគ្រប់គ្រងអោយបានល្អប្រសើរនូវសហគ្រាសចំនួន ៦០០ ដោយតម្រូវអោយសហគ្រាសទាំងនេះបង់ពន្ធតាមប្រព័ន្ធធនាគារនៃធនាគារជាតិនៃកម្ពុជា ។ ការិយាល័យនេះប្រមូលចំណូលពន្ធបានចំនួន ៨០%នៃចំណូលពន្ធសរុបដែលអគ្គ-នាយកដ្ឋានប្រមូលបាន ។ ការិយាល័យសហគ្រាសតូច និង មធ្យមក៏ត្រូវបានបង្កើតឡើងដើម្បីគ្រប់គ្រងអោយបានជិតដល់នូវសហគ្រាសទាំងនេះ ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ៥.២. រដ្ឋបាលសារពើពន្ធ

អគ្គនាយកដ្ឋានពន្ធដារបានកែលម្អនូវសេវាសម្រាប់អ្នកបង់ពន្ធ ដោយបង្កើតឡើងនូវអង្គភាពនៅតាមខេត្ត - ក្រុង ដើម្បីកែលម្អនូវសេវា និង ទំនាក់ទំនងជាមួយអ្នកបង់ពន្ធ ។

អគ្គនាយកដ្ឋានពន្ធដារបានពង្រឹងនូវសវនកម្មលើសហគ្រាសធំ និង មធ្យម និង បង្កើនការផ្លាស់ប្តូរព័ត៌មានរវាងនាយកដ្ឋានដែលមានការពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក៏ដូចជាជាមួយក្រសួង- ស្ថាប័នផ្សេងទៀត ដើម្បីកែលម្អនូវការធ្វើសវនកម្មនៃសហគ្រាសទាំងនេះ ។ ទន្ទឹមនឹងនេះ អគ្គនាយកដ្ឋានបានបង្កើនចំនួនសវនកម្ម និង សហគ្រាសដែលត្រូវធ្វើសវនកម្ម ។ នាយកដ្ឋានក៏បានរៀបចំនូវវិសោធនកម្មនៃលិខិតបទដ្ឋាន និង កម្មវិធីសវនកម្មពន្ធចំពោះសហគ្រាសទាំងនេះផងដែរ ។

**តារាងទី ២- លទ្ធផលនៃសវនកម្មពន្ធលើសហគ្រាសធុនធំ និង មធ្យម ពីឆ្នាំ ១៩៩៨ ដល់ ឆ្នាំ ២០០៨**

| ឆ្នាំ | 1998 | 1999 | 2000 | 2001 | 2002 | 2003 | 2004 | 2005 | 2006 | 2007 | 2008 |
|---|---|---|---|---|---|---|---|---|---|---|---|
| ចំណូល | 3.6 | 13.1 | 26.4 | 122.5 | 73.4 | 104.5 | 148.3 | 351.8 | 487.5 | 467.5 | 751.7 |

*ប្រភព: ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ*

អគ្គនាយកដ្ឋានពន្ធដារបានអនុវត្តយ៉ាងហ្មឺងម៉ាត់នូវបទប្បញ្ញត្តិនៃច្បាប់ស្តីពីសារពើពន្ធ ជាពិសេសនីតិវិធីតឹងទារបំណុលពន្ធ រួមមាន៖

- ការឃាត់ទុកគណនីរបស់អ្នកជាប់ពន្ធនៅធនាគារនៃកម្ពុជា និង នៅរតនាគារជាតិ
- ការបញ្ឈប់ប្រតិបត្តិការនាំចេញ-នាំចូលដោយរដ្ឋបាលគយ
- ការទុកជាមោឃៈនូវលិខិតអនុញ្ញាតនិងអាជ្ញាប័ណ្ណផ្សេងៗរបស់អ្នកជាប់ពន្ធដើម្បីអនុវត្តសកម្មភាពណាមួយ
- ការបញ្ឈប់ការលើកលែងពន្ធសម្រាប់គម្រោងដែលអនុម័តអោយក្រុមប្រឹក្សាដើម្បីអភិវឌ្ឍន៍កម្ពុជា
- ការហាមឃាត់មិនអោយចូលរួមក្នុងកិច្ចការលទ្ធកម្មសាធារណៈរបស់រដ្ឋ ។

**តារាងទី ៣- លទ្ធផលនៃការប្រមូលបំណុលពន្ធ ពីឆ្នាំ ១៩៩៨ ដល់ ឆ្នាំ ២០០៨**

| ឆ្នាំ | 1998 | 1999 | 2000 | 2001 | 2002 | 2003 | 2004 | 2005 | 2006 | 2007 | 2008 |
|---|---|---|---|---|---|---|---|---|---|---|---|
| ចំណូល | 0.5 | 10.9 | 33.4 | 15.3 | 33.0 | 70.8 | 41.0 | 39.4 | 56.4 | 53.9 | 44.5 |


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

*ប្រភពៈ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ*

ចាប់តាំងពីឆ្នាំ ១៩៩៨ ដល់ឆ្នាំ ២០០៨ អគ្គនាយកដ្ឋានពន្ធដារបានបណ្តុះបណ្តាលនូវមន្ត្រីចំនួន ១.៨០០ នាក់ខាងផ្នែកមុខវិជ្ជាគណនេយ្យទូទៅ ភាសាអង់គ្លេស កុំព្យូទ័រ និង អនុញ្ញាអន្តរជាតិស្តីពីសារពើពន្ធ ។ អគ្គនាយកដ្ឋានបានជ្រើសរើសនូវមន្ត្រីចំនួន ២៩ រូប ក្នុងឆ្នាំ ២០០១ មន្ត្រីចំនួន ៦០ រូបក្នុងឆ្នាំ ២០០៣ និង មន្ត្រីចំនួន ២១២ រូប ក្នុងឆ្នាំ ២០០៧ ។

អគ្គនាយកដ្ឋានពន្ធដារបានពង្រឹងនូវប្រព័ន្ធព័ត៌មានវិទ្យា ដោយបង្កើតនូវប្រព័ន្ធទិន្នន័យអ្នកជាប់ពន្ធ ការបំពាក់នូវកំព្យូទ័រនៅតាមសាខាពន្ធដារខេត្ត-ក្រុង ដើម្បីប្រមូលទិន្នន័យ និង លិខិតប្រកាសសារពើពន្ធនៃសហគ្រាសដែលអនុវត្តនូវរបបស្វ័យប្រកាស ។

## ៦. ការវិភាគប្រៀបធៀបនូវរដ្ឋបាលសារពើពន្ធ

អគ្គាធិការដ្ឋាននៃក្រសួងហិរញ្ញវត្ថុបារាំងបានធ្វើការសិក្សាប្រៀបធៀប ស្តីពីកិច្ចដំណើរការនៃរដ្ឋបាលសារពើពន្ធនៅក្នុងប្រទេសចំនួន ៩ ដើម្បីកត់ត្រាទុកនូវគំរូនៃការរៀបចំរចនាសម្ព័ន្ធស្ថាប័ន ការអនុវត្ត និង ចំណាយរដ្ឋបាលក្នុងការប្រមូលពន្ធ (www.finances.gouv.fr/actualités) ។

ការសិក្សានេះបានកត់សម្គាល់នូវចំណុចសំខាន់ៗមួយចំនួនៈ

- សញ្ញាណនៃការ «***គោរពដោយស្ម័គ្រចិត្ត និង ដោយឯកឯង***» នូវច្បាប់ស្តីពីសារពើពន្ធត្រូវបានអនុវត្តដោយរដ្ឋបាលសារពើពន្ធស្ទើរតែទាំងអស់ ។ សញ្ញាណនេះអនុញ្ញាតអោយរដ្ឋបាលសារពើពន្ធអាចបែងចែកអោយដាច់ពីគ្នានូវអ្នកជាប់ពន្ធដែលគោរពច្បាប់សារពើពន្ធ និង អ្នកជាប់ពន្ធដែលមិនគោរពច្បាប់ ។ ការគោរពច្បាប់សារពើពន្ធដោយស្ម័គ្រចិត្តមានប្រសិទ្ធភាពជាងសកម្មភាពចាប់បង្ខំ ដូចជាការធ្វើសវនកម្មសារពើពន្ធ ។ ប្រការនេះបានដាក់ចេញទិសដៅដើម្បីជំនួសនូវវប្បធម៌សង្ស័យ ដោយការ «***គោរពដោយស្ម័គ្រចិត្ត***» នូវច្បាប់ស្តីពីសារពើពន្ធ តាមរយៈការពង្រឹងសេវាបម្រើដល់អ្នកជាប់ពន្ធ និង ការផ្តោតការយកចិត្តទុកដាក់ដល់ការធ្វើសវនកម្មតែលើក្រុមដែលមានហានិភ័យខ្ពស់ ។
- ការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មានវិទ្យា គឺជាអាទិភាពនៃយុទ្ធសាស្ត្រពង្រឹងរដ្ឋបាលសារពើពន្ធ ។ យើងសង្កេតឃើញថាប្រព័ន្ធព័ត៌មានសារពើពន្ធបានវិវត្តតាមទិសដៅដូចខាងក្រោមៈ
  - ពីការរៀបចំរដ្ឋបាលសារពើពន្ធតាមប្រភេទពន្ធដែលត្រូវប្រមូល ទៅកាន់ការរៀបចំរដ្ឋបាលសារពើពន្ធតាមមុខសញ្ញានៃអ្នកជាប់ពន្ធ (ដូចជាការិយាល័យសហគ្រាសតូច មធ្យម និង ធំ) ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

- ពីការផ្តោតសកម្មភាពទៅលើអង្គការផ្ទៃក្នុង ទៅកាន់ការផ្តោតសកម្មភាពទៅលើតម្រូវការ និង លក្ខណៈពិសេសនៃអ្នកបង់ពន្ធ ។

- ពីការប្រើប្រាស់ឯកសារជាក្រដាស ទៅកាន់ការប្រើប្រាស់ឯកសារអេឡិចត្រូនិច ។

- ពីការពិនិត្យឯកសារតាមកញ្ចប់សកម្មភាព ទៅកាន់ការពិនិត្យឯកសារទាន់ពេលភ្លាមៗ ។

- ពីសវនកម្មទូទៅលើគ្រប់សហគ្រាស ទៅកាន់សវនកម្មផ្តោតទៅលើសហគ្រាសដែលមានហានិភ័យខ្ពស់។

• ទិសដៅរួមនៃការវិវត្តស្ថាប័នសារពើពន្ធឆ្ពោះទៅកាន់គំរូមួយរួម ដែលមានរដ្ឋបាលសារពើពន្ធវិវត្តយ៉ាងលឿន ។ គំរូដែលគេតែងតែជួបប្រទះញឹកញាប់ជាងគេ គឺជាការរៀបចំរដ្ឋបាលសារពើពន្ធដោយឈរលើមូលដ្ឋានល្បាយនៃគោលការណ៍ភូមិសាស្ត្រ- ដែនដី (តាមខេត្ត- ខ័ណ្ឌ) ជាមួយនឹងការបង្កើតការិយាល័យជំនាញគ្រប់គ្រងសហគ្រាសធុនធំ ។ រដ្ឋបាលសារពើពន្ធខ្លះប្រមូលពន្ធសម្រាប់រដ្ឋបាលសាធារណៈផ្សេងទៀត ។ ប្រទេសខ្លះរៀបចំរដ្ឋបាលសារពើពន្ធ ដោយឈរលើគំរូនៃទីភ្នាក់ងារដែលឯករាជ្យពីក្រសួងហិរញ្ញវត្ថុ ដែលមានស្វ័យភាពកម្រិតណាមួយក្នុងការគ្រប់គ្រង និង អនុវត្តនូវវិធានគ្រប់គ្រងលើកទឹកចិត្តជាងរដ្ឋបាលកណ្តាល ។ ទីភ្នាក់ងារទាំងនេះមានការទទួលខុសត្រូវចំពោះការសម្រេចបានតាមគោលដៅ ដែលបានដាក់ចេញ និង ត្រូវត្រួតពិនិត្យយ៉ាងល្អិតល្អន់តាមក្រោយ ។

ជារួម ចំនួននៃការិយាល័យសារពើពន្ធតាមមូលដ្ឋានមានចំនួន ជាមធ្យម ១០ ការិយាល័យសម្រាប់ប្រជាជន ១ លាននាក់ ឬ ១៥០ សម្រាប់ប្រទេសដែលមានផ្ទៃដីចំនួន ១០០.០០០ គីឡូម៉ែត្រក្រឡា ។

ចំណាយគ្រប់គ្រងរដ្ឋបាលសារពើពន្ធអាចប្រែប្រួលពី ០,៥% ទៅ ១,៧%នៃចំណូលដែលប្រមូលបាន (ចំណាយមធ្យមស្មើនឹង ១,១% )។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ឧបសម្ព័ន្ធ ៣

## ថវិកា:

## គោលការណ៍គន្លឹះ

ប្រព័ន្ធហិរញ្ញវត្ថុហិរញ្ញវត្ថុសាធារណៈនៃព្រះរាជាណាចក្រកម្ពុជា មានប្រភពមកពីប្រព័ន្ធនៃប្រទេសបារាំង មុនឆ្នាំ ១៩៧០ និងដែលត្រូវបានរៀបរយដោយច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ប្រកាសអោយប្រើដោយព្រះរាជក្រម លេខ ០១ ន.ស. ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ។ ច្បាប់នេះត្រូវបានជំនួសដោយច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដែលត្រូវបានអនុម័តកាលពីថ្ងៃទី ៤ ខែ មេសា ឆ្នាំ ២០០៨ និង ដែលត្រូវបានប្រកាសអោយប្រើប្រាស់ដោយព្រះរាជក្រមលេខ ន.ស./រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ។

### ១-គោលការណ៍ជាសារវ័ន្ត

យោងតាមមាត្រា ៥ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុហិរញ្ញវត្ថុសាធារណៈ ថវិកាត្រូវមានគោលការណ៍គន្លឹះ ១១ យ៉ាងដែលត្រូវអនុវត្តដាច់ខាតគឺ:

១. ភាពជាអាជ្ញា ។

២. ការិយបរិច្ឆេទមានកាលកំណត់មួយឆ្នាំ ។

៣. ភាពគ្រប់ជ្រុងជ្រោយ ។

៤. ឯកត្តភាព ។

៥. សកលភាព ។

៦. វិសេសភាព ។

៧. តុល្យភាព ។

៨. គណនេយ្យភាព ។

៩. តម្លាភាព ។

១០. ស្ថិរភាព ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

១១. សមិទ្ធកម្ម ។

ក៏ប៉ុន្តែ គោលការណ៍ជាសារវ័ន្តដែលត្រូវអនុវត្តជាចាំបាច់មានដូចតទៅ៖ ការិយបរិច្ឆេទមានកាលកំណត់មួយឆ្នាំ ឯកត្តភាព សកលភាព វិសេសភាព និង តុល្យភាព ។

## ១.១. ការិយបរិច្ឆេទមានកាលកំណត់មួយឆ្នាំ

គោលការណ៍នៃការិយបរិច្ឆេទមានកាលកំណត់មួយឆ្នាំមានចែងក្នុងមាត្រា ៩ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុហិរញ្ញវត្ថុសាធារណៈ ដូចតទៅ ÷ «ច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំគ្រោង និងអនុញ្ញាតសម្រាប់ឆ្នាំនីមួយៗនូវប្រភពធនធាន និង បន្ទុកដែលត្រូវចំណាយសរុបរបស់រដ្ឋ ដើម្បីបម្រើឱ្យរបៀបវារៈគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និង សង្គមដោយគិតគូរដល់ការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច សមតាហិរញ្ញវត្ថុ និង រូបិយវត្ថុជាសារវ័ន្ត ពិសេស តាមរយៈការធានាឱ្យបាននូវតុល្យភាពថវិកា» ។ ច្បាប់ស្តីពីហិរញ្ញវត្ថុប្រចាំឆ្នាំអាចនឹងត្រូវកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុកែតម្រូវ ដែលអនុញ្ញាតអោយមានការផ្ទេរនូវឥណទានថវិកា ពីក្រសួង ឬ ពីស្ថាប័នសាធារណៈមួយ ទៅក្រសួង ឬ ស្ថាប័នសាធារណៈមួយទៀត ។ ក៏ប៉ុន្តែ ក្នុងការអនុវត្តជាក់ស្តែង មិនដែលមានការផ្ទេរឥណទានថវិកាពីក្រសួង ឬ ស្ថាប័នសាធារណៈ ទៅក្រសួង ឬ ស្ថាប័នសាធារណៈមួយទៀតទេ ។ ក្រសួងដែលប្រើប្រាស់ឥណទានថវិកាមិនគ្រប់អាចទទួលបាននូវឥណទានថវិកាបន្ថែម តាមរយៈការអនុម័តនូវអនុក្រឹតបំពេញបន្ថែមឥណទានថវិកាតែម្តង ។ ដោយឡែក ក្រសួងណាដែលប្រើប្រាស់ឥណទានថវិកាមិនអស់ នឹងត្រូវលប់ចោលនៅចុងឆ្នាំតែម្តង ។ ការប្រើប្រាស់ឥណទានថវិកាលើសពីច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ឬ មិនគ្រប់តាមឥណទានថវិកាប្រចាំឆ្នាំនឹងត្រូវបូកសរុប នៅក្នុងច្បាប់ទូទាត់ថវិកាដែលត្រូវដាក់ជូនរដ្ឋសភាអនុម័ត និង ដាក់ជូនព្រឹទ្ធសភាពិនិត្យតែម្តង» ។

ការិយបរិច្ឆេទនៃឆ្នាំថវិកាចាប់ផ្តើមនៅថ្ងៃទី ០១ ខែ មករា ហើយបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ (មាត្រា ៩ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ) ។

ប្រសិនបើសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ មិនត្រូវបានអនុម័តមុនថ្ងៃទី ០១ ខែ មករា នៃឆ្នាំការិយបរិច្ឆេទទេនោះ ថវិកាឆ្នាំមុនត្រូវបានបន្តដោយស្របច្បាប់ក្នុងលក្ខខណ្ឌដូចខាងក្រោម៖

១- ចំណូលសារពើពន្ធ ចំណូលមិនមែនសារពើពន្ធ និងចំណូលគ្រប់ប្រភេទផ្សេងទៀត ត្រូវបានអនុញ្ញាត និងបន្តឱ្យប្រមូលក្នុងលក្ខខណ្ឌ និងតាមបែបបទដែលបានកំណត់ក្នុងច្បាប់ហិរញ្ញវត្ថុពីមុន និងក្នុងក្របខ័ណ្ឌច្បាប់ព្រមទាំងបទបញ្ញាដែលមានជាធរមាន ។

២- ចំណាយចរន្ត ក្រៅពីបន្ទុកបំណុលសាធារណៈ នៅតែបន្តអនុវត្តតាមក្របខ័ណ្ឌនៃថវិកាឆ្នាំមុន ដោយ



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

គិតតាមវិធីមួយភាគដប់ពីរជាបណ្តោះអាសន្នក្នុងខែនីមួយៗរហូតដល់ថវិកាថ្មីត្រូវបានអនុម័ត ។

៣- ចំណាយមូលធននៃថវិកាក្រៅពីវិលស់បំណុលសាធារណៈ នៅតែបន្តអនុវត្តតាមក្របខ័ណ្ឌនៃថវិកាឆ្នាំមុន ក្នុងក្របខ័ណ្ឌឥណទានទូទាត់ដែលនៅទំនេរ ហើយអាចលើសពីនេះប្រសិនបើចាំបាច់ ដោយមិនឱ្យការទូទាត់នោះ លើសពីកម្រិតឥណទានភ្ជាប់សន្យាដែលបានអនុម័តក្នុងថវិកាឆ្នាំមុន ។

៤- ចំណាយទាំងឡាយ ដែលជាកាតព្វកិច្ចទាក់ទងទៅនឹងសមាជិកភាពរបស់កម្ពុជាក្នុងស្ថាប័នអន្តរជាតិ និង អន្តររដ្ឋាភិបាល និងកាតព្វកិច្ចទាក់ទងទៅនឹងបន្ទុកបំណុលសាធារណៈ រួមមានការវិលស់ប្រាក់ដើម ការបង់ការប្រាក់ កម្រៃសេវា និង/ឬ ការបង់ពិន័យជាយថាហេតុ ត្រូវបានរ៉ាប់រងជាបន្តមិនឱ្យដាច់តាមកិច្ចព្រមព្រៀងជាធរមាន ។

## ១.២. ឯកត្តភាព

គោលការណ៍ឯកកត្តភាពថវិកាមានន័យថា៖

ទីមួយ- ចំណូលទាំងអស់ និង ចំណាយទាំងអស់ត្រូវតែដាក់អោយរដ្ឋសភាអនុម័តសម្រាប់ឆ្នាំខាងមុខ ។

ទីពីរ- ចំណូល និង ចំណាយទាំងនេះត្រូវតែបង្ហាញ ដោយព្រមៗគ្នាតែម្តង ដើម្បីបង្ហាញពីការខិតខំប្រឹងប្រែងក្នុងការប្រមូលចំណូល និង ការអនុវត្តចំណាយ និង ឆ្លុះបញ្ចាំងពីស្ថានភាពជាក់ស្តែងនៃតុល្យភាពនៃថវិកា ។

ជាក់ស្តែង រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាតម្រូវអោយបង្កើត ឬ កែប្រែពន្ធដោយច្បាប់ ។ ពន្ធ អាករ និងចំណូលសារពើពន្ធផ្សេងៗ ត្រូវកំណត់ដោយច្បាប់ និងត្រូវប្រមូល និងត្រួតពិនិត្យដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (មាត្រា១៦ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ) ។ គ្រប់ក្រសួង និងស្ថាប័នប្រហាក់ប្រហែលសាធារណៈទាំងអស់ត្រូវរាយការណ៍អោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុបានដឹងពីចំណូលទាំងអស់ «ដើម្បីចាត់ថ្នាក់ចំណូលទាំងនោះនៅក្នុងមាតិកាចំណូលថវិកាអោយបានសមស្រប» (មាត្រា ៥០ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ) ។

## ១.៣. សកលភាព

គោលការណ៍សកលភាពមានន័យថា៖

ទីមួយ- មិនត្រូវយកចំណូល ទៅកាត់កងជាមួយចំណាយឡើយ (ដោយកត់ត្រាតែផលសងនៅក្នុងថវិកា) ហើយ **គោលការណ៍នៃការមិនកាត់កង** នេះ (Principe de non-contraction) មានចែងក្នុងមាត្រា ១៩ នៃ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ច្បាប់ស្តីពីហិរញ្ញវត្ថុសាធារណៈ៖

«ចំណូលត្រូវកត់ត្រាចូលទាំងស្រុងហើយមិនត្រូវយកទៅកាត់កងដោយត្រង់ ជាមួយចំណាយឡើយ ។ ការបង្កើនដោយអាណាប័កនូវទឹកប្រាក់នៃឥណទានដែលបានអនុម័ត ដោយសំអាងលើប្រាក់ចំណូលពិសេសណាមួយត្រូវបានហាមឃាត់ដាច់ខាត» ។

ទីពីរ- **គោលការណ៍នៃការមិនវិភាជន៍សម្រាប់តែមុខសញ្ញាពិសេស** (Principe de la non-affectation) បានចែងថា៖

«ចំណូលទាំងមូលត្រូវវិភាជន៍សម្រាប់រាលមុខសញ្ញាចំណាយទាំងអស់ ។ ប៉ុន្តែ ចំណូលខ្លះអាចត្រូវវិភាជន៍សម្រាប់តែមុខសញ្ញាចំណាយជាក់ស្តែងណាមួយក្នុងទម្រង់ និងក្រោមលក្ខខណ្ឌដែលត្រូវកំណត់ដោយច្បាប់» (មាត្រា ២០ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ) ។

## ១.៤.វិសេសភាព

ចំណូល និង ចំណាយថវិកាត្រូវបង្ហាញអោយដាក់ដោយឡែកពីគ្នានៅក្នុងថវិកា តាមមាតិកាថវិកាដែល

***ចំណាត់ថ្នាក់ចំណូលតាមច្បាប់ស្តីពីប្រព័ន្ធថវិកា ឆ្នាំ ១៩៩៣ ដែលប្រើប្រាស់ដល់ឆ្នាំ ២០០៦***

***ពន្ធ និង អាករ***

- ពន្ធលើប្រាក់ចំណូល លើប្រាក់ចំណេញ និង លើកំណើនមូលធន
- ពន្ធលើទ្រព្យសម្បត្តិ
- ពន្ធផ្ទៃក្នុងលើទំនិញ និង សេវា
- ពន្ធលើពាណិជ្ជកម្មអន្តរជាតិ

***ចំណូលមិនមែនសារពើពន្ធ***

- ចំណូលពីទ្រព្យសម្បត្តិរដ្ឋ
- ចំណូលមិនមែនសារពើពន្ធឯទៀត

***ចំណូលជាមូលធន***

- ចំណូលផ្ទៃក្នុងជាមូលធន
- ជំនួយក្រៅប្រទេស
- កម្ចី

*(មាត្រា ៦ និង មាត្រា ៧ នៃច្បាប់ស្តីពីប្រព័ន្ធថវិកា ឆ្នាំ ១៩៩៣)*
*ចំណាត់ថ្នាក់លម្អិតត្រូវបានកំណត់ដោយប្រកាសនៃរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

កំណត់ដោយរដ្ឋសភា ។ មាត្រា ១៣ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសាធារណៈបែងចែកធនធានអចិន្ត្រៃយ៍របស់រដ្ឋ តាម


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

**ចំណាត់ថ្នាក់ចំណូលតាមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ ២០០៨**

***ចំណូលចរន្ត***

- ក្រុមទី ១: ចំណូលពិត
    - ប្រភេទទី ១: ចំណូលសារពើពន្ធ
    - ប្រភេទទី ២: ចំណូលមិនមែនសារពើពន្ធ
- ក្រុមទី ២: ចំណូលតាមដីកា
    - ប្រភេទទី ៣: ចំណូលតាមដីកា

***ចំណូលជាមូលធន***

- ក្រុមទី ១: ចំណូលពិត
    - ប្រភេទទី ១: ចំណូលពីប្រភពផ្ទាល់
    - ប្រភេទទី ២: ចំណូលពីប្រភពខាងក្រៅ
- ក្រុមទី ២: ចំណូលតាមដីកា
    - ប្រភេទទី ៣: ចំណូលតាមដីកា

ប្រភេទចំណូលនីមួយៗ ត្រូវបានធ្វើចំណាត់ថ្នាក់ជាជំពូក គណនី អនុគណនី និង ជាយថាហេតុអាចលម្អិតជាងនេះទៀត ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ក្រុម និង ប្រភេទចំណូល ហើយមាត្រា ២២ បែងចែកចំណាយតាមក្រុម និងប្រភេទចំណាយ ។

ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈបានធ្វើការកែប្រែនូវមាតិកាថវិកា ដើម្បីអោយមានសង្គតិភាពជាមួយ

**ចំណាត់ថ្នាក់ចំណាយតាមច្បាប់ស្តីពីប្រព័ន្ធថវិកា ឆ្នាំ ១៩៩៣ ដែលប្រើប្រាស់ដល់ឆ្នាំ ២០០៦**

***ចំណាយចរន្ត***

- មធ្យោបាយសេវា
- ចំណាយការប្រាក់
- អន្តរាគមន៍សាធារណៈ
- ចំណាយផ្សេងៗ និង ពុំបានគ្រោងទុក

***ចំណាយមូលធន*** *(វិសោធនកម្មដោយច្បាប់ស្តីពីហិរញ្ញវត្ថុលេខ ១០ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ មាត្រា ៨)*

- វិនិយោគដោយហិរញ្ញប្បទានក្នុងស្រុក
- វិនិយោគដោយហិរញ្ញប្បទានខាងក្រៅដោយផ្ទាល់
- ការទូទាត់ដើមបំណុល

*(មាត្រា ១៤ និង មាត្រា ១៥ នៃច្បាប់ស្តីពីប្រព័ន្ធថវិកា ឆ្នាំ ១៩៩៣)*

*ចំណាត់ថ្នាក់ចំណាយត្រូវបានកំណត់ដោយប្រកាសនៃរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (មាត្រា ១៧ ថ្មី នៃច្បាប់ស្តីពីប្រព័ន្ធថវិកា ឆ្នាំ ១៩៩៣ ដែលធ្វើវិសោធនកម្មដោយច្បាប់ស្តីពីហិរញ្ញវត្ថុឆ្នាំ ១៩៩៩)*

នឹងប្តូរគណនីថ្មីនៃរតនាគារជាតិ ។ ក្នុងន័យនេះចំណូលត្រូវបានបែងចែកជាពីរក្រុម៖ ក្រុមទី១ ចំណូលពិត និង ក្រុមទី ២ ចំណូលតាមដីកា ។

ចំណូលចរន្តតាមដីកា គឺជាចំណូលពន្ធគយជាបន្ទុករបស់រដ្ឋ ដែលគ្រាន់តែកត់ត្រានៅក្នុងគណនីរតនាគារ ចំពោះករណីដែលមានការលើកលែងពន្ធគយ និង អាករផ្សេងៗ ។ ក្នុងករណីនេះ គណនេយ្យករកត់ត្រានូវចំណាយតាមដីការ ដែលត្រូវផ្ទៀងផ្ទាត់ជាមួយនឹងការកត់ត្រានូវចំណូលតាមដីការនៅក្នុងគណនីរតនាគារផងដែរ ។ ដូច្នេះ ចំណូលតាមដីការមិនមានលំហូរសាច់ប្រាក់ចូលក្នុងគណនីរតនាគារឡើយ ដែលពាក្យសាមញ្ញហៅថាជា **«ចំណូលខ្យល់»** ។ ឧទាហរណ៍ ការអនុវត្តនូវរំលស់ចំពោះការប្រើប្រាស់នូវយានយន្តរបស់រដ្ឋ អាចចាត់ទុកថាជាចំណូលតាមដីកា ដោយសារក្នុងក្របខ័ណ្ឌនៃគណនេយ្យបង្ករដ្ឋត្រូវកត់ត្រានូវរំលស់ក្នុងការប្រើប្រាស់នូវទ្រព្យសកម្មមួយចំនួនដោយមិនចាំបាច់អោយមានលំហូរជាសាច់ប្រាក់ឡើយ ។

***ចំណាត់ថ្នាក់ចំណាយតាមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ ២០០៨***

***ចំណាយចរន្ត***

- <u>ក្រុមទី ១៖ ចំណាយពិត</u>
    - ប្រភេទទី ១៖ មធ្យោបាយសេវា
    - ប្រភេទទី ២៖ បន្ទុកហិរញ្ញវត្ថុ
    - ប្រភេទទី ៣៖ អន្តរាគមន៍សាធារណៈ
    - ប្រភេទទី ៤៖ ចំណាយផ្សេងៗ
- <u>ក្រុមទី ២៖ ចំណាយតាមដីកា និង ចំណាយមិនបានគ្រោងទុក</u>
    - ប្រភេទទី ៥៖ ចំណាយតាមដីកា
    - ប្រភេទទី ៦៖ ចំណាយមិនបានគ្រោងទុក

***ចំណាយជាមូលធន***

- <u>ក្រុមទី ១៖ ចំណាយពិត</u>
    - ប្រភេទទី ១៖ ការទូទាត់ប្រាក់ខ្ចី និង បំណុលប្រហាក់ប្រហែល
    - ប្រភេទទី ២៖ អចលនកម្ម
- <u>ក្រុមទី ២៖ ចំណាយតាមដីកា</u>
    - ប្រភេទទី ៣៖ ចំណាយតាមដីកា

ប្រភេទចំណាយនីមួយៗ ត្រូវបានធ្វើចំណាត់ថ្នាក់ជាជំពូក គណនី អនុគណនី និង ជាយថាហេតុ អាចលម្អិតជាងនេះទៀត ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

*(មាត្រា ២៣ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ឆ្នាំ ២០០៨)*

*ចំណាត់ថ្នាក់លម្អិតត្រូវបានកំណត់ដោយប្រកាសនៃរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ការធ្វើហិរញ្ញប្បទានដោយផ្ទាល់នៃគម្រោង ដោយដៃគូសហប្រតិបត្តិការអភិវឌ្ឍន៍អាចចាត់ទុកថាជាចំណូលជាមូលធនតាមដីកា ដោយគ្រាន់តែកត់ត្រានូវតួលេខតែប៉ុណ្ណោះ ដោយគ្មានលំហូរសាច់ប្រាក់ជាក់ស្តែងឡើយ ។ ការកត់ត្រានូវចំណូលតាមដីកា ត្រូវមានការកត់ត្រាជាបដិកានូវចំណាយតាមដីកា ដែលមានចំនួនដូចគ្នានេះដែរ ។ ដូច្នេះ ចំណាយវិនិយោគដោយដៃគូអភិវឌ្ឍន៍អាចឆ្លុះបញ្ចាំងនៅក្នុងគណនីរដ្ឋបាន ។ ការប្រើប្រាស់នូវចំណាយតាមដីកា អាចពន្យល់បានខាងលើ ដូចក្នុងករណីចំណូលតាមដីកាដែរ ។

## ១.៥. តុល្យភាព

ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដែលប្រកាសអោយប្រើអោយព្រះរាជក្រមលេខ សន/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ បានចែងយ៉ាងច្បាស់លាស់ ពីគោលការណ៍តុល្យភាពនៃថវិកា ។ មាត្រា ៤៧ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈបានចែងថា ÷ «សេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ដែលត្រូវដាក់ជូនរដ្ឋសភា និង ព្រឹទ្ធសភា ត្រូវភ្ជាប់មកជាមួយនូវ ... របាយការណ៍វិភាគពីនិន្នាការ និងការវិវត្តរួមនៃស្ថានភាពសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈបច្ចុប្បន្ន និងការវិភាគលើចរិតលក្ខណៈនៃថវិកាថ្មី ព្រមទាំងបញ្ជាក់អំពីការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច សមតាហិរញ្ញវត្ថុ និង រូបិយវត្ថុជាសារវ័ន្ត ពិសេសតុល្យភាពថវិកា» ។

ម៉្យាងវិញទៀត មាត្រា ៥២ បានចែងថា ÷ « គ្មានវិសោធនកម្មណាមួយ លើសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុអាចត្រូវបានអនុញ្ញាតអោយធ្វើនោះទេ ប្រសិនបើវិសោធនកម្មនោះធ្វើអោយប៉ះពាល់ដល់តុល្យភាពនៃគម្រោងថវិកាដែលបានស្នើឡើង ។ វិសោធនកម្មប្រភេទនេះ អាចធ្វើទៅបានតែក្នុងលក្ខខណ្ឌដូចខាងក្រោម÷

- សំណើចំណាយថ្មី ត្រូវបានប៉ះប៉ូវដោយការលុបចេញ ឬ បន្ថយចំណាយណាមួយផ្សេងទៀត ដើម្បីរក្សាតុល្យភាពថវិកា ។
- សំណើចំណាយថ្មី ត្រូវបានធ្វើឡើងដោយមានភ្ជាប់ជាមួយនូវសំណើសន្សំសំចៃលើប្រភេទចំណាយណាមួយដែលបានស្នើឡើងរួចហើយ ដើម្បីរក្សាតុល្យភាពថវិកា ។
- សំណើចំណាយថ្មី ត្រូវបានធ្វើឡើងដោយមានភ្ជាប់ជាមួយនូវសំណើបង្កើតមុខចំណូលថ្មី ឬ បង្កើនចំណូលដើម្បីរក្សាតុល្យភាពថវិកា ។
- វិសោធនកម្មដែលធ្វើឡើងផ្ទុយនឹងបទប្បញ្ញត្តិខាងលើនៃមាត្រានេះ នឹងត្រូវបានបដិសេធ ហើយទុកជាមោឃៈ» ។

ការធានាអោយបាននូវតុល្យភាពក្នុងការអនុវត្តថវិកាបានស្តែងចេញនៅក្នុងមាត្រា ៦០ នៃច្បាប់ស្តីពីប្រព័ន្ធ


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ហិរញ្ញវត្ថុ ៖ «នៅពេលដែលការវិវត្តនៃចំណូល និងចំណាយស្តែងចេញឱ្យឃើញនូវការបាត់តុល្យភាពថវិកា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចចេញជាប្រកាស ដើម្បីបង្កកមួយចំណែក ឬ ទាំងស្រុងនៃប្រភេទឥណទានមួយចំនួន ដែលបានអនុម័តនៅក្នុងច្បាប់ហិរញ្ញវត្ថុ ។ ក្នុងករណីដែលការបាត់តុល្យភាពនេះ មានលក្ខណៈធ្ងន់ធ្ងររាជរដ្ឋាភិបាលអាចធ្វើនីតិវិធីតាមអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយលុបចោល មួយចំណែក ឬ ទាំងស្រុងនៃប្រភេទឥណទានមួយចំនួន ដែលបានអនុម័តក្នុងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ» ។

## ១.៦. ប្រព័ន្ធគ្រប់គ្រង និង ប្រព័ន្ធការិយបរិច្ឆេទ

ប្រព័ន្ធថវិកាមានពីរប្រភេទ គឺ៖

- ប្រព័ន្ធគ្រប់គ្រង និង
- ប្រព័ន្ធការិយបរិច្ឆេទ

ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ ២០០៨ មិនបានចែងលម្អិតពីប្រព័ន្ធគ្រប់គ្រង និង ប្រព័ន្ធការិយបរិច្ឆេទឡើយ ។ មាត្រា ៧៤ គ្រាន់តែចែងថា ៖ «ប្រព័ន្ធគណនេយ្យសាធារណៈត្រូវមានសង្គតិភាពទៅនឹងនិយាមគណនេយ្យអន្តរជាតិ ដែលមានការទទួលស្គាល់ជាទូទៅ ហើយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវចេញប្រកាសកំណត់ប្រព័ន្ធគណនេយ្យនេះ» ។ មាត្រា ៧៥ បន្ថែមទៀតថា ៖ «បទបញ្ញាទូទៅនៃគណនេយ្យសាធារណៈត្រូវកំណត់គ្រប់លក្ខខណ្ឌដែលធ្វើឱ្យប្រតិបត្តិការគណនេយ្យ និង ហិរញ្ញវត្ថុ អាចកត់ត្រាវិភាគ និងគ្រប់គ្រងការអនុវត្តច្បាប់ហិរញ្ញវត្ថុ ប្រកបដោយគណនេយ្យភាព ភាពស័ក្តិសិទ្ធិ និង ប្រសិទ្ធភាព» ។

### ១.៦.១. ប្រព័ន្ធគ្រប់គ្រង

ប្រព័ន្ធគ្រប់គ្រងមានលក្ខណៈផ្ទុយគ្នានឹងប្រព័ន្ធការិយបរិច្ឆេទ ដែលមានលក្ខណៈទំនើបជាង ។ ប្រព័ន្ធគ្រប់គ្រងជាប្រព័ន្ធដែលឈរលើមូលដ្ឋាននៃ **គណនេយ្យបេឡា** (Cash accounting)។ នៅក្នុងប្រព័ន្ធគ្រប់គ្រងចំណូល និង ចំណាយថវិកា គឺជា ***ចំណូលជាសាច់ប្រាក់ដែលបានបង់*** និង ***ចំណាយដែលបានចេញជាអាណត្តិបើកប្រាក់*** ក្នុងរយៈពេលដប់ពីរខែនៃឆ្នាំថវិកា ។

### ១.៦.២. ប្រព័ន្ធការិយបរិច្ឆេទ

ប្រព័ន្ធការិយបរិច្ឆេទ ជាប្រព័ន្ធថវិកាដែលឈរលើមូលដ្ឋាននៃ **គណនេយ្យបង្គរ** (Accrual accounting)។ នៅក្នុងប្រព័ន្ធការិយបរិច្ឆេទ ចំណូល និង ចំណាយថវិកា គឺជា ***ចំណូល*** និង ***ចំណាយថវិកា*** ដែលកើតមានឡើង នៅក្នុងរយៈពេលដែលបង្កើតអោយមានចំណូល និង ចំណាយនេះឡើង ដោយមិនផ្សារភ្ជាប់ទៅនឹង



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ការបង់ចំណូលជាសាច់ប្រាក់ចូលក្នុងបេឡា ឬ ការបើកផ្តល់ចំណាយឡើយ ដែលជាគោលការណ៍នៃគណនេយ្យបង្គរ របស់សហគ្រាស ។

ឧទាហរណ៍នៅពេលដែលក្រសួង- ស្ថាប័នចុះហត្ថលេខាជួលដីទៅអោយក្រុមហ៊ុនឯកជន ចំណូលត្រូវចាប់ គិតពីកាលបរិច្ឆេទនៃកិច្ចសន្យា ដែលបង្កើតអោយមានចំណូល ទោះបីជាការបង់សាច់ប្រាក់ជាក់ស្តែងអាចកើតមាន ឡើងនៅពេលក្រោយក៏ដោយ ។ ដូចគ្នានេះដែរ នៅពេលដែលក្រសួង- ស្ថាប័នចុះហត្ថលេខាទិញទំនិញជាមួយ ក្រុមហ៊ុនឯកជន កិច្ចសន្យានេះបង្កើតអោយមានចំណាយថវិកា ដែលរដ្ឋត្រូវបើកផ្តល់ ទោះបីជាសាច់ប្រាក់ជាក់ស្តែង នឹងត្រូវយកមកទូទាត់ចំណាយ នៅក្រោយពេលប្រគល់- ទទួលទំនិញក៏ដោយ ។

ក៏ប៉ុន្តែ នៅពេលអនុវត្តជាក់ស្តែង គោលការណ៍គណនេយ្យបង្គរដែលជាគោលការណ៍នៃសហគ្រាស មិន អាចយកមកអនុវត្តដោយស្ថាប័នរដ្ឋបានទាំងស្រុងបានឡើយ ។ ចំណូលសារពើពន្ធ គឺចាប់គិតនៅពេលដែល ក្រុមហ៊ុនបង់ចំណូលនេះជាសាច់ប្រាក់ចូលក្នុងគណនីរតនាគារជាតិ ទោះបីជាចំណូលនេះគឺជាចំណូលដែល ក្រុមហ៊ុនត្រូវបង់ចំពោះកាតព្វកិច្ចពន្ធដារនៃឆ្នាំការិយបរិច្ឆេទមុនក៏ដោយ ។

## ២. ការលើកលែងមិនអនុវត្តគោលការណ៍គន្លឹះនៃថវិកា

### ២.១. ការលើកលែងមិនអនុវត្តគោលការណ៍ការិយបរិច្ឆេទមានកាលកំណត់មួយឆ្នាំ

ការធានាចំណាយថវិកាសម្រាប់រយៈពេលច្រើនឆ្នាំ ចំពោះគម្រោងវិនិយោគ គឺជាការបំពានលើ គោលការណ៍ការិយបរិច្ឆេទមានកាលកំណត់មួយឆ្នាំ ។ ឥណទានថវិកាមូលធនមានបីប្រភេទ គឺ ÷ ឥណទាននៃកម្មវិធី ឥណទានភ្ជាប់សន្យា និង ឥណទានទូទាត់ ។

**តារាងលេខ : ឥណទាននៃកម្មវិធី ឆ្នាំ ២០០៦**

| ឈ្មោះគម្រោង | តម្លៃគម្រោង | ចំណាយមុនឆ្នាំ ២០០៦ | កម្រិតទុនវិនិយោគចែកតាមឆ្នាំ | | | | ទុនសល់សម្រាប់ពេលក្រោយ |
|---|---|---|---|---|---|---|---|
| | | | 2006 | 2007 | 2008 | សរុបឆ្នាំ | |
| ជួសជុលប្រព័ន្ធធារាសាស្ត្រស្ទឹងជីនិត | $30 million | $6.2 million | $2 million | $2 million | $3 million | $7 million | $16.7 million |

**ឥណទាននៃកម្មវិធី** គឺជាឥណទានថវិកាដែលឆ្លុះបញ្ចាំងនូវតម្លៃសរុបនៃគម្រោងវិនិយោគតែម្តង ។ ឥណទាននៃកម្មវិធី គឺជាឥណទានថវិកា បែងចែកតាមគម្រោងចំណាយមូលធននៃថវិកាទូទៅរបស់រដ្ឋ ដែលអនុម័ត ដោយរដ្ឋសភា (តារាង គ១) ។ ឥណទាននេះឆ្លុះបញ្ចាំងនូវតម្លៃសរុបនៃគម្រោង ចំណាយមុនឆ្នាំថវិកា កម្រិតទុន វិនិយោគចែកតាមឆ្នាំនីមួយៗ និងទុនសល់សម្រាប់ពេលក្រោយ ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

**ឥណទានភ្ជាប់សន្យា** គឺជាឥណទានវិនិយោគ ដែលអនុញ្ញាតអោយរាជរដ្ឋាភិបាលធ្វើការសន្យា និង អនុម័តនៅក្នុងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ហើយដាក់នៅក្រោមអាណាប័ក សម្រាប់ចំណាយចាំបាច់ក្នុងការអនុវត្ត កិច្ចវិនិយោគ (មាត្រា ២៨ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ)។ ឥណទានភ្ជាប់សន្យាអាចមានតម្លៃគ្មានកំណត់ពេល ។ ឥណទាននេះត្រូវបានយោងពីមួយឆ្នាំទៅមួយឆ្នាំ រហូតដល់ការលុបបំបាត់ជាយថាហេតុ ។

**ឥណទានទូទាត់** គឺជាឥណទានដែលត្រូវបានប្រើប្រាស់សម្រាប់ចេញបញ្ជាចំណាយ ដែលជាបន្ទុករបស់ រដ្ឋ នៅក្នុងកម្រិតនៃឥណទានភ្ជាប់សន្យា ។ ឥណទានទូទាត់ដែលមិនបានប្រើនៅពេលបិទការគ្រប់គ្រង (បញ្ចប់ឆ្នាំ) ត្រូវបានលុបចោល និង អាចអនុញ្ញាតឥណទានថ្មីសម្រាប់ឆ្នាំបន្ទាប់ ។ ដូច្នេះ ឥណទានទូទាត់មានតួនាទីធានាបាន នូវការគោរពតាមគោលការណ៍ការិយបរិច្ឆេទមានកាលកំណត់មួយឆ្នាំ ។

## ២.២. ការលើកលែងមិនអនុវត្តគោលការណ៍ឯកត្តភាព

ការបំពានលើគោលការណ៍ឯកត្តភាពថវិកា ស្ថិតនៅត្រង់ចំណុចដែល ថវិកានៃគ្រឹះស្ថានសាធារណៈ រដ្ឋបាលមិនត្រូវបានបញ្ចូលជាផ្នែកមួយនៃថវិកាទូទៅរបស់រដ្ឋ ។ ដោយឡែក គណនីពិសេសរបស់រតនាគារ និង ថវិកាឧបសម្ព័ន្ធ ក៏ត្រូវបូកបញ្ចូលទៅក្នុងថវិកាទូទៅរបស់រដ្ឋដែរ ។

## ២.៣. ការលើកលែងមិនអនុវត្តគោលការណ៍សកលភាព

មាត្រា ២០ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈបានបើកផ្លូវអោយមានការអនុវត្តខុសគោលការណ៍ សកលភាពនេះ ÷«ចំណូលទាំងមូល ត្រូវវិភាជន៍សម្រាប់រាល់មុខសញ្ញាចំណាយទាំងអស់ ។ ប៉ុន្តែចំណូលខ្លះ អាចត្រូវវិភាជន៍ សម្រាប់តែមុខសញ្ញាចំណាយជាក់ស្តែងណាមួយក្នុងទម្រង់ និងក្រោមលក្ខខណ្ឌដែលត្រូវកំណត់ ដោយច្បាប់» ។

ការមិនអនុវត្តតាមគោលការណ៍សកលភាព និង គោលការណ៍មិនវិភាជន៍សម្រាប់តែមុខសញ្ញាពិសេស (Earmarking) នូវចំណូល និងចំណាយថវិកាត្រូវបានគូសបញ្ជាក់ថែមទៀតនៅក្នុងមាត្រា ១៤ នៃច្បាប់ស្តីពី ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ÷ «គណនីថវិការួមមាន ថវិការដ្ឋ ថវិកាឧបសម្ព័ន្ធ ថវិកាគ្រឹះស្ថានសាធារណៈរដ្ឋបាល និង គណនីពិសេសរតនាគារជាតិ» ។

ថវិកាឧបសម្ព័ន្ធអនុវត្តតែចំពោះគ្រឹះស្ថានរដ្ឋដែលមានលក្ខណៈឧស្សាហកម្ម និងពាណិជ្ជកម្ម ដែលមិនមែន ជានីតិបុគ្គល ។ ថវិកាឧបសម្ព័ន្ធត្រូវបានបង្កើតឡើង និងលុបចោលដោយច្បាប់ស្តីពីហិរញ្ញវត្ថុ ។ ប្រតិបត្តិការនៃ ថវិកាឧបសម្ព័ន្ធត្រូវបានអនុវត្ត តាមលក្ខខណ្ឌ និងតាមវិធានដូចគ្នានឹងប្រតិបត្តិការនៃថវិការដ្ឋដែរ ។ គ្រឹះស្ថាន


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

### *រចនាសម្ព័ន្ធនៃគណនីថវិកា*

មាត្រា ១៤ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈបានចែងថា «គណនីថវិការួមមាន ៖

- ថវិការដ្ឋ
- ថវិកាឧបសម្ព័ន្ធ
- ថវិកាគ្រឹះស្ថានសាធារណៈរដ្ឋបាល និង
- គណនីពិសេសរតនាគារជាតិ»

សាធារណៈមានថវិកាស្វ័យភាព ដែលត្រូវបូកបញ្ចូលទៅក្នុងថវិការដ្ឋដែរ ។ ធនធានចរន្តនៃថវិកាឧបសម្ព័ន្ធ គឺជាចំណូលផ្ទាល់នៃគ្រឹះស្ថានទាំងនេះ និង ការឧបត្ថម្ភធនដែលផ្តល់ដោយថវិកាទូទៅរបស់រដ្ឋ ។ ចំណាយចរន្តនៃថវិកាឧបសម្ព័ន្ធត្រូវអនុវត្ត ទៅតាមវិធាននៃចំណាត់ថ្នាក់ និង ការគ្រប់គ្រង ដែលដូចគ្នានឹងចំណាយចរន្តនៃថវិការបស់រដ្ឋដែរ ។ របៀបរបបដំណើរការនៃអង្គភាពរដ្ឋដែលមានថវិកាឧបសម្ព័ន្ធ និង គ្រឹះស្ថានសាធារណៈរដ្ឋបាលត្រូវកំណត់ដោយអនុក្រឹត្យ ។

រាជរដ្ឋាភិបាលកម្ពុជាបានអនុម័តនូវអនុក្រឹត្យស្តីពីបទបញ្ញានៃថវិកាឧបសម្ព័ន្ធ ដែលកំណត់ថា អង្គភាពអនុវត្តថវិកាឧបសម្ព័ន្ធត្រូវបង្កើតឡើងដោយអនុក្រឹត្យ ។ រដ្ឋមន្ត្រីជាអាណាប័កដើមខ្សែនៃចំណូល និងចំណាយនៃថវិកាឧបសម្ព័ន្ធ ។ អាណាប័កដើមខ្សែអាចប្រគល់សិទ្ធិជូនប្រធានអង្គភាព ដែលមានថវិកាឧបសម្ព័ន្ធដោយអនុក្រឹត្យ។ កិច្ចប្រតិបត្តិការចំណូល និងចំណាយនៃថវិកាឧបសម្ព័ន្ធត្រូវបានប្រតិបត្តិដោយភ្នាក់ងារនៃគណនេយ្យកណ្តាលមួយរូប ដែលតែងតាំងដោយប្រកាសអន្តរក្រសួង ។ មុននឹងធ្វើការទូទាត់ ភ្នាក់ងារនៃគណនេយ្យកណ្តាលត្រូវចុះហត្ថលេខាលើអាណត្តិបើកប្រាក់ទាំងអស់នៃថវិកាឧបសម្ព័ន្ធ ។ គណនេយ្យទូទៅនៃថវិកាឧបសម្ព័ន្ធ ត្រូវបានកាន់កាប់ជាគណនេយ្យទ្វេរភាគ ទៅតាមប្លង់មួយ ដូចគ្នានឹងប្លង់នៃគណនេយ្យទូទៅដែរ ។ គណនេយ្យទូទៅនេះត្រូវអនុញ្ញាតអោយកំណត់ថ្លៃដើមអាជីវកម្ម និងលទ្ធផលហិរញ្ញវត្ថុមូលដ្ឋានសម្រាប់វាយតម្លៃការគ្រប់គ្រងហិរញ្ញវត្ថុ និងប៉ាន់ប្រមាណស្ថានភាពទ្រព្យសកម្ម និង ទ្រព្យអកម្មរបស់អង្គភាព ។ នាដំណាច់ឆ្នាំ ភ្នាក់ងារនៃគណនេយ្យកណ្តាលជាប្រធានគណនេយ្យទូទៅនៃថវិកាឧបសម្ព័ន្ធ ត្រូវរៀបចំនូវគណនីទូទៅនៃអាជីវកម្ម គណនីលទ្ធផល ចំណេញ ខាត និង តុល្យការ ។

ការមិនអនុវត្តមួយទៀតនៃគោលការណ៍សកលភាព គឺការវិភាជន៍ចំណូលសម្រាប់តែមុខសញ្ញាពិសេសដើម្បីជាគុណប្រយោជន៍នៃក្រសួង- ស្ថាប័ន ។ ជាការពិត រាល់ចំណាយដែលខុសពី «ថវិកាដែលបានអនុម័ត» គឺជាការមិនអនុវត្តនូវគោលការណ៍សកលភាព ។ ចំណូលអាចត្រូវបានបង្កើត ដោយការអនុម័តនូវច្បាប់ផ្សេងៗ តាមវិស័យនីមួយៗ ដែលក៏ជាប្រភពនៃការបំពានគោលការណ៍ឯកត្តភាពផងដែរ ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

### នីតិវិធីនៃការកត់ត្រាចំណូល - ចំណាយជាបន្ទុករបស់រដ្ឋ

ការលើកលែងពន្ធអាចអនុវត្តបានក្នុងក្របខ័ណ្ឌច្បាប់ (ច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា) ឬ ក្នុងក្របខ័ណ្ឌនៃការអនុវត្តអនុសញ្ញាអន្តរជាតិ (សម្ភារៈ និង ចលនវត្ថុរបស់ស្ថានទូត របស់ប្រើប្រាស់ផ្ទាល់ខ្លួន និងរថយន្តនៃបុគ្គលិកការទូត) ។

យើងអាចជំនួសការលើកលែងពន្ធនេះបាន ដោយកត់ត្រាពន្ធជាបន្ទុករបស់រដ្ឋ÷ អ្នកដែលទទួលបាននូវការលើកលែងពន្ធត្រូវប្រកាសពន្ធដូចអ្នកបង់ពន្ធធម្មតា ជាអាទិ៍ សេចក្តីប្រកាសគយ និង ការពិនិត្យ និងទទួលស្គាល់ដោយមន្ត្រីគយនៅពេលដែលទំនិញឆ្លងកាត់ការត្រួតពិនិត្យគយ ការប្រកាសប្រាក់ចំណូល និង ការកត់ត្រាពន្ធលើប្រាក់ចំណេញដោយរដ្ឋនៅពេលដែលមានការលើកលែងពន្ធលើប្រាក់ចំណេញ ។

យន្តការនៃការកត់ត្រាពន្ធជាបន្ទុករបស់រដ្ឋទាមទារអោយមានឥណទានថវិកា ដែលអនុញ្ញាតអោយកត់ត្រាចំណូល និងចំណាយជាបន្ទុករបស់រដ្ឋ ហើយការប្រមូលចំណូលត្រូវតែកត់ត្រាទុកក្នុងគណនីចំណូលមួយច្បាស់លាស់ ។ ចំណូលតាមដីកាត្រូវផ្ទៀងផ្ទាត់ជាមួយចំណាយតាមដីកា ។ ដូច្នេះ យន្តការនេះមិននាំអោយមានចលនាលំហូរសាច់ប្រាក់ ឬ ចំណាយថវិកាពិតទេ ។

ថ្លៃដែលត្រូវបង់ចំពោះប្រតិបត្តិការនេះ គឺជាការផ្តល់ការឧបត្ថម្ភដល់មន្ត្រីដែលទទួលបន្ទុកការងារនេះ ។ ទំហំនៃការឧបត្ថម្ភនេះនឹងកើនឡើងទៅតាមទំហំនៃការបង់ពន្ធជាបន្ទុករបស់រដ្ឋ ។ ក៏ប៉ុន្តែ ការផ្តល់ការឧបត្ថម្ភនេះ គឺជាការលើកទឹកចិត្តដល់មន្ត្រីដែលបំពេញការងារ ។

ឥណទានថវិកាសម្រាប់កត់ត្រាការបង់ពន្ធជាបន្ទុករបស់រដ្ឋ ត្រូវតែជាឥណទានអាចវាយតម្លៃបាន ដើម្បីជៀសវាងកុំអោយប្រព័ន្ធនេះស្ទះ នៅពេលដែលអស់ឥណទាន ដោយសារតែការប៉ាន់ស្មានឥណទានដើមឆ្នាំមានទំហំតិចជាងការអនុវត្តជាក់ស្តែង ។ ម៉្យាងវិញទៀត ដើម្បីធានាអោយបាននូវវិន័យថវិកា ត្រូវហាមដាច់ខាតនូវការផ្ទេរឥណទានពីឥណទានសម្រាប់ការកត់ត្រាពន្ធជាបន្ទុករបស់រដ្ឋ ទៅជំពូកផ្សេងទៀតដែលជាប្រភេទឥណទានមានកំហិត ។

រដ្ឋាភិបាលក៏អាចទាមទារអោយកត់ត្រានូវគម្រោងទាំងអស់ចូលក្នុងថវិការដ្ឋ ដោយបង្កើតអោយមាននូវបន្ទាត់ថវិកាសម្រាប់ការបង់ពន្ធ និងការកត់ត្រាចំណាយជាបន្ទុករបស់រដ្ឋ ។ ដូច្នេះ ដៃគូអភិវឌ្ឍន៍ទាំងអស់ទទួលបាននូវការលើកទឹកចិត្ត ដើម្បីដាក់បញ្ចូលនូវរាល់គម្រោងទាំងឡាយនៅក្នុងថវិការដ្ឋ ក្នុងគោលដៅធានាបាននូវការសម្របសម្រួល និងការត្រួតពិនិត្យគម្រោងអភិវឌ្ឍន៍អោយបានល្អប្រសើរជាងមុន ។

ប្រព័ន្ធនេះក៏អនុញ្ញាតផងដែរ ដើម្បីបង្ហាញនៅក្នុងគណនីជាតិនូវថ្លៃនៃគម្រោងទាំងឡាយ ដែលទទួលបាននូវការលើកលែងពន្ធ ។ ដូច្នេះ ទំហំនៃការលើកលែងពន្ធ អាចចាត់ទុកថាជាមូលនិធិបដិភាគរបស់រាជរដ្ឋាភិបាល ជាមួយនឹងគម្រោងហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍ ។

ភាពជាដៃគូរវាងរដ្ឋ និង ផ្នែកឯកជនអាចនាំអោយប៉ះពាល់ដល់គោលការណ៍សកលភាពផងដែរ ។ រដ្ឋបែងចែកធនធានទៅអោយផ្នែកឯកជន ដើម្បីធ្វើហិរញ្ញប្បទានក្នុងការសាងសង់ផ្លូវយកប្រាក់ ។ ការផ្តល់ការលើកទឹកចិត្តដល់ការវិនិយោគ តាមរយៈការកាត់បន្ថយពន្ធ ឬ ការលើកលែងពន្ធ គឺជាការរំលោភលើគោលការណ៍សកលភាព ។ ដូច្នេះ ដើម្បីដោះស្រាយបញ្ហានេះ រដ្ឋត្រូវកត់ត្រាចូលក្នុងថវិកាជាតិ នូវការលើកលែងពន្ធទាំងអស់តាមរូបភាពនៃការយកពន្ធជាបន្ទុករបស់រដ្ឋ ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ២.៤. ការលើកលែងមិនអនុវត្តគោលការណ៍វិសេសភាព

នៅក្នុងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ យើងមិនបាលឃើញពីការរំលោភលើគោលការណ៍វិសេសភាពឡើយ ។

## ២.៥. ការលើកលែងមិនអនុវត្តគោលការណ៍តុល្យភាព

មាត្រា ៦១ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈបានបើកច្រក អោយមានការអនុវត្តថវិកាដោយមិនគិតពីតុល្យភាព ÷ «ក្នុងករណីដែលមានគ្រោះធម្មជាតិ ឬ ភាពចាំបាច់ជាបន្ទាន់ដល់ផលប្រយោជន៍ជាតិ ដោយផ្អែកលើរបាយការណ៍របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រាជរដ្ឋាភិបាលអាចចេញអនុក្រឹត្យបន្ថែមឥណទានដើម្បីប្រើប្រាស់ ។ ឥណទាននេះ ត្រូវអនុម័តដោយច្បាប់កែតម្រូវនៃច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ដែលរាជរដ្ឋាភិបាលត្រូវសុំការយល់ព្រមពីរដ្ឋសភា និងព្រឹទ្ធសភាភ្លាម នៅពេលដែលស្ថានការណ៍ពិសេសទាំងនេះត្រូវបានចប់សព្វគ្រប់» ។

ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ត្រង់មាត្រា ១៦ បានបើកផ្លូវអោយមានការអនុវត្តថវិកាដោយមិនគោរពតាមនូវគោលការណ៍តុល្យភាព ÷ «ក្នុងករណីពិសេស ឬ ក្នុងករណីប្រធានសក្តិ នាយករដ្ឋមន្ត្រីអាចបញ្ជាអោយចំណាយលើសពីឥណទានថវិកា ដើម្បីដោះស្រាយនូវបញ្ហាចាំបាច់ និងជាការប្រញាប់ ហើយត្រូវធ្វើរបាយការណ៍ភ្លាមជូនរដ្ឋសភា» ។

ដើម្បីធ្វើហិរញ្ញប្បទាននូវអតុល្យភាពថវិកា មាត្រា ៦៩ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ បើកច្រកអោយមានការបោះផ្សាយមូលបត្ររដ្ឋ ដោយកំណត់ថា÷ «លក្ខខណ្ឌផ្នែកហិរញ្ញវត្ថុ និង ទំហំទឹកប្រាក់ ...នៃការបោះផ្សាយមូលបត្ររដ្ឋ... ត្រូវកំណត់ដោយច្បាប់ហិរញ្ញវត្ថុ» ។

## ២.៦. ការលើកលែងមិនអនុវត្តប្រព័ន្ធគ្រប់គ្រង

រយៈពេលបន្ថែម ដែលជារយៈពេលដែលរតនាគារអាចបូកសរុបនូវគណនីចំណូល- ចំណាយរតនាគារ គឺជាការបំពានមួយទៅលើគោលការណ៍គ្រប់គ្រង ដែលទាមទារអោយបិទគណនីភ្លាម នៅម៉ោងចុងក្រោយនៃថ្ងៃចុងក្រោយនៃរយៈពេលថវិកា ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ជំពូក ៤

# កម្មវិធីនីយកម្មនៃចំណាយថវិកា

## ១-ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ

**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ** គឺជាឯកសារគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការកាត់បន្ថយភាពក្រីក្រ ដែលរៀបចំឡើងដោយមានការពិគ្រោះយោបល់ និងការពិភាក្សាលម្អិតជាមួយគ្រប់ភាគីទាំងអស់ដែលមានការពាក់ព័ន្ធ រួមមានក្រសួង- ស្ថាប័នរបស់រាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ពហុភាគី ទ្វេភាគី អង្គការសង្គមស៊ីវិល ដែលរួមទាំងព័ត៌មាននៃការអង្កេតផ្លូវការ ការសិក្សាស្រាវជ្រាវ និងឯកសារបោះពុម្ពផ្សាយផ្សេងៗទៀត ដោយកំណត់នូវគោលដៅ និង យុទ្ធសាស្ត្រក្នុងការកាត់បន្ថយភាពក្រីក្រ ការវាយតម្លៃធនធានហិរញ្ញវត្ថុ និងធនធានផ្សេងៗទៀតដែលចាំបាច់ ក៏ដូចជាវិធីសាស្ត្រនៃការត្រួតពិនិត្យ និងវាយតម្លៃ ។ ដូច្នេះ **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ** គឺជាឯកសារគោលនយោបាយដែលត្រូវបានរៀបចំឡើងដោយផ្អែកលើមូលដ្ឋានដ៏រឹងមាំនៃស្ថិរភាពសន្តិភាព សន្តិភាព មូលដ្ឋានសេដ្ឋកិច្ច ព្រមទាំងកំណត់នូវគោលដៅ និងផែនការ ដើម្បីវឌ្ឍនភាពរឹងមាំ និង ប្រកបដោយចីរភាព តាមរបៀបមួយដែលសំយោគនូវផែនការអភិវឌ្ឍន៍តាមវិស័យ និង យុទ្ធសាស្ត្រជាតិក្នុងការកាត់បន្ថយភាពក្រីក្រ ។

**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ** ត្រូវបានរៀបចំឡើងសម្រាប់រយៈពេល ២០០៦-២០១០ ដើម្បីប្រើប្រាស់ជាផែនទីគោចរ សម្រាប់រាជរដ្ឋាភិបាល និង ដៃគូអភិវឌ្ឍន៍ (ស្ថាប័នពហុភាគី ទ្វេភាគី អង្គការសង្គមស៊ីវិល និង អង្គការក្រៅរដ្ឋាភិបាល) ដោយបង្ហាញពីសមិទ្ធិផលដែលសម្រេចបានក្នុងវិស័យម៉ាក្រូសេដ្ឋកិច្ច រូបិយវត្ថុ ហិរញ្ញវត្ថុសាធារណៈ ក៏ដូចជាគោលនយោបាយ និង សមិទ្ធិផលក្នុងវិស័យដូចតទៅ ÷

- ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ
- កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
- កំណែទម្រង់រដ្ឋបាលសាធារណៈ
- កម្មវិធីវិមជ្ឈការ និងវិសហមជ្ឈការ


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

- កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- កសិកម្ម និងការគ្រប់គ្រងធនធានធម្មជាតិ
- ការអភិវឌ្ឍផ្នែកឯកជន
- សមធម៌យេនឌ័រ ភាពក្រីក្រ និង មេរោគហ៊ីវ/ជម្ងឺអេដស៍
- វិស័យសុខាភិបាល និង អប់រំ
- សុខដុមភាវូបនីយកម្ម (នូវនីតិវិធី និងកិច្ចដំណើរការរបស់ដៃគូអភិវឌ្ឍន៍) និង ការតម្រឹមតម្រង់ (នូវនីតិវិធី និងកិច្ចដំណើរការរបស់ដៃគូអភិវឌ្ឍន៍ជាមួយគោលនយោបាយជាតិរបស់កម្ពុជា) ។

**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ** បានកំណត់នូវយុទ្ធសាស្ត្រដើម្បីសម្រេចអោយបាននូវអាទិភាពតាមផ្នែកគោលដៅជាយុទ្ធសាស្ត្រទាំង ៩ នៃ **គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា** ។

## ២. គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា

ដោយផ្អែកលើគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ពិភពលោក នៅក្នុងឆ្នាំ ២០០៣ តាមរយៈដំណើរការពិគ្រោះយោបល់យ៉ាងទូលំទូលាយមួយ ក្នុងចំណោមតួអង្គដែលមានការពាក់ព័ន្ធទាំងអស់ កម្ពុជាបានរៀបចំកំណត់គោលដៅប្រាំបួនផ្ទាល់របស់ខ្លួន ដែលហៅថា **គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា** (កអសក) ដោយបន្ថែមគោលដៅមួយទៀត ដែលមានសារៈសំខាន់ចំពោះប្រទេសជាតិ ។

### ២.១. គោលដៅទីមួយ: លុបបំបាត់ភាពក្រីក្រ និងការអត់ឃ្លានធ្ងន់ធ្ងរ

**ចំណុចដៅទី១: កាត់បន្ថយអោយបានពាក់កណ្តាលរវាងឆ្នាំ ១៩៩៣ និង ២០១៥ នូវសមាមាត្រប្រជាជនដែលមានចំណូលទាបជាងខ្សែបន្ទាត់ភាពក្រីក្រថ្នាក់ជាតិ**

**សូចនាករទី១.១-** កាត់បន្ថយសមាមាត្រប្រជាជន ដែលមានប្រាក់ចំណូលទាបជាងខ្សែបន្ទាត់ភាពក្រីក្រថ្នាក់ជាតិ ពី ៣៩% នៅក្នុងឆ្នាំ ១៩៩៣ ដល់ ១៩,៥% នៅក្នុងឆ្នាំ ២០១៥

**សូចនាករទី១.២-** បង្កើនសមាសភាគប្រជាជនដែលក្រជាងគេបំផុតក្នុងចំណាយថ្នាក់ជាតិ ពី ៧,៤% នៅក្នុងឆ្នាំ ១៩៩៣ ដល់ ១១% នៅក្នុងឆ្នាំ ២០១៥

**សូចនាករទី១.៣-** កាត់បន្ថយសមាមាត្រកុមារធ្វើការងារដែលមានអាយុពី ៥ ឆ្នាំ ដល់ ១៧ ឆ្នាំ ពី ១៦,%



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

នៅក្នុងឆ្នាំ ១៩៩៩ ដល់ ៨% នៅក្នុងឆ្នាំ ២០១៥

**ចំណុចដៅទី២: កាត់បន្ថយអោយបានពាក់កណ្ដាលរវាងឆ្នាំ ១៩៩៣ និង ២០១៥ នូវសមាមាត្រប្រជាជនដែលទទួលរងនូវការអត់ឃ្លាន**

**សូចនាករទី១.៤-** កាត់បន្ថយអត្រាប្រេវ៉ាឡង់នៃកុមារមិនគ្រប់ទម្ងន់ (ទម្ងន់ធៀបនឹងអាយុ <2SD) ដែលមានអាយុក្រោម ៥ ឆ្នាំ ពី ៤៥,៧% នៅក្នុងឆ្នាំ ២០០០ ដល់ ២៧% នៅក្នុងឆ្នាំ ២០១៥

**សូចនាករទី១.៥-** កាត់បន្ថយសមាមាត្រប្រជាជនដែលរស់នៅក្រោមខ្សែបន្ទាត់ម្ហូបអាហារ ពី ២០% នៅក្នុងឆ្នាំ ២០០០ ដល់ ១០% នៅក្នុងឆ្នាំ ២០១៥

**សូចនាករទី១.៦-** កាត់បន្ថយប្រេវ៉ាឡង់នៃកុមារក្រិន (កំពស់ធៀបនឹងអាយុ <2SD) ដែលមានអាយុក្រោម ៥ ឆ្នាំ ពី ៤៤,៦% នៅក្នុងឆ្នាំ ២០០០ ដល់ ២៧% នៅក្នុងឆ្នាំ ២០១៥

**សូចនាករទី១.៧-** កាត់បន្ថយប្រេវ៉ាឡង់នៃកុមារស្គម (ទម្ងន់ធៀបនឹងកំពស់ <2SD) ដែលមានអាយុក្រោម ៥ ឆ្នាំ ពី ១៥% នៅក្នុងឆ្នាំ ២០០០ ដល់ ៩% នៅក្នុងឆ្នាំ ២០១៥

**សូចនាករទី១.៨-** បង្កើនសមាមាត្រគ្រួសារប្រើប្រាស់អំបិលអ៊ីយ៉ូត ពី ១៤% នៅក្នុងឆ្នាំ ២០០០ ដល់ ៩០% នៅក្នុងឆ្នាំ ២០១៥

## ២.២. គោលដៅទីពីរ: សម្រេចអោយបានជានូវការអប់រំមូលដ្ឋានរយ:ពេល៩ឆ្នាំ

**ចំណុចដៅទី៣: ធានាអោយកុមារទាំងអស់បានបញ្ចប់ការសិក្សាកម្រិតបឋមសិក្សានៅមុនដំណាច់ ឆ្នាំ ២០១០ និង ការសិក្សាកម្រិតមូលដ្ឋានរយៈពេល ៩ ឆ្នាំ នៅមុនដំណាច់ឆ្នាំ ២០១៥**

**សូចនាករទី២.១-** បង្កើនអត្រាសុទ្ធចូលរៀនថ្មី ពី ៨១% នៅក្នុងឆ្នាំ ២០០១ ដល់ ១០០% នៅក្នុងឆ្នាំ ២០១០

**សូចនាករទី២.២-** បង្កើនអត្រាសុទ្ធនៃការសិក្សានៅបឋមសិក្សា ពី ៨៧% នៅក្នុងឆ្នាំ ២០០១ ដល់ ១០០% នៅក្នុងឆ្នាំ ២០១០

**សូចនាករទី២.៣-** បង្កើនអត្រាសុទ្ធនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិពី ១៩% នៅក្នុងឆ្នាំ ២០០១ ដល់ ១០០% នៅក្នុងឆ្នាំ ២០១៥

**សូចនាករទី២.៤-** កាត់បន្ថយសមាមាត្រនៃកុមារអាយុ ពី ៦ ដល់ ១៤ ឆ្នាំ ដែលមិនបានចូលរៀន ពី ៣៥% នៅក្នុងឆ្នាំ ១៩៩៩ ដល់ ០% នៅក្នុងឆ្នាំ ២០១៥

**សូចនាករទី២.៥-** បង្កើនអត្រាគង់វង្សនៃសិស្សដែលបានចូលរៀនពីថ្នាក់ទី១ ដល់ ទី ៥ ពី ៥៨% នៅក្នុងឆ្នាំ ២០០១ ដល់ ១០០% នៅក្នុងឆ្នាំ ២០១០

**សូចនាករទី២.៦-** បង្កើនអត្រាគង់វង្សនៃសិស្សដែលបានចូលរៀនពីថ្នាក់ទី១ ដល់ ទី ៦ (ថ្នាក់ចុងក្រោយនៃការសិក្សាបឋមសិក្សា) ពី ៥១% នៅក្នុង ឆ្នាំ ២០០១ ដល់ ១០០% នៅក្នុងឆ្នាំ ២០១០

**សូចនាករទី២.៧-** បង្កើនអត្រាគង់វង្សនៃសិស្សដែលបានចូលរៀនពីថ្នាក់ទី១ ដល់ ទី ៩ (ថ្នាក់ចុងក្រោយនៃការសិក្សាកម្រិតមូលដ្ឋាន) ពី ៣៣% នៅក្នុង ឆ្នាំ ២០០១ ដល់ ១០០% នៅក្នុងឆ្នាំ ២០១៥

**សូចនាករទី២.៨-** បង្កើនអត្រាអក្ខរកម្មនៃអ្នកដែលមានអាយុពី ១៥ ដល់ ២៤ ឆ្នាំ ពី ៨២% នៅក្នុងឆ្នាំ ១៩៩៩ ដល់ ១០០% នៅក្នុងឆ្នាំ ២០១៥

**ចំណុចដៅទី៤: លុបបំបាត់វិសមភាពយេនឌ័រក្នុងការអប់រំកម្រិតមូលដ្ឋានរយៈពេល ៩ ឆ្នាំ**

**សូចនាករទី២.៩-** បង្កើនផលធៀបរវាងសិស្សស្រី និងសិស្សប្រុសនៅបឋមសិក្សា ពី ៨៧% នៅក្នុងឆ្នាំ ២០០១ ដល់ ១០០% នៅក្នុងឆ្នាំ ២០១០

**សូចនាករទី២.៩-** បង្កើនផលធៀបរវាងសិស្សស្រី និងសិស្សប្រុសនៅមធ្យមសិក្សាបឋមភូមិ ពី ៦៣% នៅក្នុងឆ្នាំ ២០០១ ដល់ ១០០% នៅក្នុងឆ្នាំ ២០១០

## ២.៣. គោលដៅទីបី: លើកកម្ពស់សមភាពយេនឌ័រ និងផ្តល់សិទ្ធិអំណាចដល់ស្ត្រី

**ចំណុចដៅទី៥: កាត់បន្ថយគម្លាតយេនឌ័រនៅកម្រិតមធ្យមសិក្សាទុតិយភូមិ និងឧត្តមសិក្សា**

**សូចនាករទី៣.១-** បង្កើនផលធៀបរវាងនិស្សិតស្រី និងនិស្សិតប្រុសនៅកម្រិតមធ្យមសិក្សាទុតិយភូមិ ពី ៤៨% នៅក្នុងឆ្នាំ ២០០១ ដល់ ១០០% នៅក្នុងឆ្នាំ ២០១៥

**សូចនាករទី៣.២-** បង្កើនផលធៀបរវាងនិស្សិតស្រី និងនិស្សិតប្រុសនៅកម្រិតឧត្តមសិក្សា ពី ៣៨% នៅក្នុងឆ្នាំ ២០០១ ដល់ ៨៥% នៅក្នុងឆ្នាំ ២០១៥

**សូចនាករទី៣.៣-** បង្កើនផលធៀបរវាងអក្ខរកម្មស្រី និងបុរស អាយុពី ១៥ ដល់ ២៤ ឆ្នាំ ពី ៨៧% នៅក្នុងឆ្នាំ ១៩៩៨ ដល់ ១០០% នៅក្នុងឆ្នាំ ២០១០

**សូចនាករទី៣.៤-** បង្កើនផលធៀបរវាងអក្ខរកម្មស្រី និងបុរស អាយុពី ២៥ ដល់ ៤៤ ឆ្នាំ ពី ៧៨% នៅក្នុងឆ្នាំ ១៩៩៨ ដល់ ១០០% នៅក្នុងឆ្នាំ ២០១០

**ចំណុចដៅទី៦: លុបបំបាត់គម្លាតយេនឌ័រ សម្រាប់ការងារមានបៀវត្សរ៍នៅគ្រប់វិស័យសេដ្ឋកិច្ច**

**សូចនាករទី៣.៥-** បង្កើនសមាមាត្រស្ត្រីធ្វើការងារមានបៀវត្សរ៍ក្នុងវិស័យកសិកម្ម ពី ៣៥% នៅក្នុងឆ្នាំ ១៩៩៨ ដល់ ៥០% នៅក្នុងឆ្នាំ ២០០៥

**សូចនាករទី៣.៦-** បង្កើនសមាមាត្រស្ត្រីធ្វើការងារមានបៀវត្សរ៍ក្នុងវិស័យឧស្សាហកម្ម ពី ៤៤% នៅក្នុងឆ្នាំ ១៩៩៨ ដល់ ៥០% នៅក្នុងឆ្នាំ ២០០៥

**សូចនាករទី៣.៧-** បង្កើនសមាមាត្រស្ត្រីធ្វើការងារមានបៀវត្សរ៍ក្នុងវិស័យសេវាកម្ម ពី ២១% នៅក្នុងឆ្នាំ ១៩៩៨ ដល់ ៥០% នៅក្នុងឆ្នាំ ២០០៥

**ចំណុចដៅទី៧: លុបបំបាត់គម្លាតយេនឌ័រនៅក្នុងស្ថាប័នសាធារណៈ**

**សូចនាករទី៣.៨-** បង្កើនសមាមាត្រនៃអាសនៈរបស់ស្ត្រីនៅក្នុងរដ្ឋសភា ពី ១២% នៅក្នុង ឆ្នាំ ២០០៣ ដល់ ៣០% នៅក្នុងឆ្នាំ ២០១៥

**សូចនាករទី៣.៩-** បង្កើនសមាមាត្រនៃអាសនៈរបស់ស្ត្រីនៅក្នុងព្រឹទ្ធសភា ពី ១៣% នៅក្នុង ឆ្នាំ ២០០៣ ដល់ ៣០% នៅក្នុងឆ្នាំ ២០១៥

**សូចនាករទី៣.១០-** បង្កើនសមាមាត្រស្ត្រីជារដ្ឋមន្ត្រី ពី ៨% នៅក្នុង ឆ្នាំ ២០០៣ ដល់ ៥% នៅក្នុងឆ្នាំ ២០១៥

**សូចនាករទី៣.១១-** បង្កើនសមាមាត្រស្ត្រីជារដ្ឋលេខាធិការ ពី ៦% នៅក្នុង ឆ្នាំ ២០០៣ ដល់ ១៨% នៅក្នុងឆ្នាំ ២០១៥

**សូចនាករទី៣.១២-** បង្កើនសមាមាត្រស្ត្រីជាអនុរដ្ឋលេខាធិការ ពី ៥% នៅក្នុង ឆ្នាំ ២០០៣ ដល់ ២០% នៅក្នុងឆ្នាំ ២០១៥

**សូចនាករទី៣.១៣-** បង្កើនសមាមាត្រស្ត្រីជាអភិបាលខេត្ត ពី ០% នៅក្នុង ឆ្នាំ ២០០៣ ដល់ ១០% នៅក្នុងឆ្នាំ ២០១៥

**សូចនាករទី៣.១៤-** បង្កើនសមាមាត្រស្ត្រីជាអភិបាលខេត្តរង ពី ១% នៅក្នុង ឆ្នាំ ២០០៣ ដល់ ១៥% នៅក្នុងឆ្នាំ ២០១៥

**សូចនាករទី៣.១៥-** បង្កើនសមាមាត្រស្ត្រីជាសមាជិកក្រុមប្រឹក្សាឃុំ- សង្កាត់ ពី ៨% នៅក្នុង ឆ្នាំ ២០០៣



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ដល់ ២៥% នៅក្នុងឆ្នាំ ២០១៥

**ចំណុចដៅទី៨: លុបបំបាត់រាល់គ្រប់ទម្រង់នៃអំពើហិង្សាចំពោះស្ត្រី និងកុមារ**

**សូចនាករទី៣.១៦-** បង្កើនអត្រានៃប្រជាជនដែលដឹងថាអំពើហិង្សាចំពោះស្ត្រី គឺជាអាកប្បកិរិយាខុសឆ្គង និងជាអំពើឧក្រិដ្ឋ អោយបានដល់ ១០០% នៅក្នុងឆ្នាំ ២០១៥

**សូចនាករទី៣.១៧-** បង្កើនអត្រានៃករណីអំពើហិង្សាក្នុងគ្រួសារ ដែលត្រូវបានពិគ្រោះយោបល់ដោយបុគ្គលិកដែលមានជំនាញ អោយបានដល់ ១០០% នៅក្នុងឆ្នាំ ២០១៥

**សូចនាករទី៣.១៨-** អនុម័ត និងអនុវត្តច្បាប់ប្រឆាំងអំពើហិង្សាចំពោះស្ត្រី និងកុមារ ដោយអនុលោមទៅតាមនិយាមអន្តរជាតិ នៅឆ្នាំ ២០០៥

**សូចនាករទី៣.១៩-** ប្រមូលទិន្នន័យស្ថិតិប្រចាំឆ្នាំ ដើម្បីត្រួតពិនិត្យអំពើហិង្សាចំពោះស្ត្រី អោយបានមុនឆ្នាំ ២០០៥

**សូចនាករទី៣.២០-** តាក់តែងឡើង និងអនុវត្តផែនការទប់ស្កាត់អំពើហិង្សា នៅឆ្នាំ ២០០៥

## ២.៤. គោលដៅទីបួន: កាត់បន្ថយអត្រាមរណភាពកុមារ

**ចំណុចដៅទី៩: បន្ថយអត្រាមរណភាពកុមារអាយុក្រោម ៥ ឆ្នាំ**

**សូចនាករទី៤.១-** កាត់បន្ថយអត្រាមរណភាពកុមារអាយុក្រោម ៥ ឆ្នាំ ក្នុង ១.០០០ កំណើតរស់ ពី ១២៤% នៅក្នុងឆ្នាំ ១៩៩៨ ដល់ ៦៥% នៅក្នុងឆ្នាំ ២០១៥

**សូចនាករទី៤.២-** កាត់បន្ថយអត្រាមរណភាពទារក ក្នុង ១.០០០ កំណើតរស់ ពី ៩៥% នៅក្នុងឆ្នាំ ១៩៩៨ ដល់ ៥០% នៅក្នុងឆ្នាំ ២០១៥

**សូចនាករទី៤.៣-** បង្កើនសមាមាត្រកុមារអាយុក្រោម ១ ឆ្នាំ បានទទួលការចាក់ថ្នាំការពារជម្ងឺកញ្រ្ជិល ពី ៤១,៤% នៅក្នុងឆ្នាំ ២០០០ ដល់ ៩០% នៅក្នុងឆ្នាំ ២០១៥

**សូចនាករទី៤.៤-** បង្កើនសមាមាត្រកុមារអាយុក្រោម ៦-៥៩ ខែ បានទទួលថ្នាំវិតាមីនអា ពី ២៨% នៅក្នុងឆ្នាំ ២០០០ ដល់ ៩០% នៅក្នុងឆ្នាំ ២០១៥

**សូចនាករទី៤.៥-** បង្កើនសមាមាត្រកុមារអាយុក្រោម ១ ឆ្នាំ បានទទួលការចាក់ថ្នាំការពារជម្ងឺខាន់ស្លាក់


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ក្អកមាន់ និងតេតាណូស ពី ៤៣% នៅក្នុងឆ្នាំ ២០០០ ដល់ ៩០% នៅក្នុងឆ្នាំ ២០១៥

**សូចនាករទី៤.៦-** បង្កើនសមាមាត្រទារកត្រូវបានបំបៅដោះដល់អាយុ ៦ ខែ ពី ១១,៤% នៅក្នុងឆ្នាំ ២០០០ ដល់ ៤៩% នៅក្នុងឆ្នាំ ២០១៥

**សូចនាករទី៤.៧-** បង្កើនសមាមាត្រនៃម្តាយដែលចាប់ផ្តើមបំបៅដោះទារកទើបនឹងកើតក្នុងរយៈពេលមួយម៉ោងនៃកំណើត ពី ១១% នៅក្នុងឆ្នាំ ២០០០ ដល់ ៦២% នៅក្នុងឆ្នាំ ២០១៥

## ២.៥. គោលដៅទីប្រាំ: លើកកម្ពស់សុខភាពមាតា

### ចំណុចដៅទី១០: បន្ថយអត្រាមរណភាពមាតា

**សូចនាករទី៥.១-** កាត់បន្ថយអត្រាមរណភាពមាតាក្នុង ១០០.០០០ កំណើតកូន ពី ៤៣៧% នៅក្នុងឆ្នាំ ១៩៩៧ ដល់ ៦៥% នៅក្នុងឆ្នាំ ២០១៥

**សូចនាករទី៥.២-** កាត់បន្ថយអត្រាលទ្ធភាពផ្តល់កំណើតសរុប ពី ៤ នៅក្នុងឆ្នាំ ១៩៩៨ ដល់ ៣ នៅក្នុងឆ្នាំ ២០១៥

**សូចនាករទី៥.៣-** បង្កើនសមាមាត្រនៃការសម្រាលកូន ដោយបុគ្គលិកសុខាភិបាលដែលមានជំនាញ ពី ៣២% នៅក្នុងឆ្នាំ ២០០០ ដល់ ៨០% នៅក្នុងឆ្នាំ ២០១៥

**សូចនាករទី៥.៤-** បង្កើនសមាមាត្រនៃស្ត្រីរៀបការដែលប្រើប្រាស់វិធីពន្យារកំណើតទំនើប ពី ១៨,៥% នៅក្នុងឆ្នាំ ២០០០ ដល់ ៦០% នៅក្នុងឆ្នាំ ២០១៥

**សូចនាករទី៥.៥-** បង្កើនសមាមាត្រនៃស្ត្រីមានផ្ទៃពោះ ដែលទទួលការពិគ្រោះមុនពេលសម្រាលកូនបានពីរដង ឬ ច្រើនជាងជាមួយបុគ្គលិកសុខាភិបាលដែលមានជំនាញ ពី ៣០,៥% នៅក្នុងឆ្នាំ ២០០០ ដល់ ៩០% នៅក្នុងឆ្នាំ ២០១៥

**សូចនាករទី៥.៦-** កាត់បន្ថយសមាមាត្រស្ត្រីមានផ្ទៃពោះ ដែលមានជម្ងឺស្លេកស្លាំងខ្វះជាតិដែក ពី ៦៦% នៅក្នុងឆ្នាំ ២០០០ ដល់ ៣៣% នៅក្នុងឆ្នាំ ២០១៥

**សូចនាករទី៥.៧-** កាត់បន្ថយសមាមាត្រស្ត្រីអាយុ ១៥ ដល់ ៤៩ ឆ្នាំ ដែលមានផលធៀបទម្ងន់នឹងកម្ពស់ក្រោម ១៨,៥ គក/ម៉ែតការ៉េ ពី ២១% នៅក្នុងឆ្នាំ ២០០០ ដល់ ៨% នៅក្នុងឆ្នាំ ២០១៥

**សូចនាករទី៥.៨-** កាត់បន្ថយសមាមាត្រស្ត្រីអាយុ ១៥ ដល់ ៤៩ ឆ្នាំ ដែលមានជម្ងឺស្លេកស្លាំងខ្វះជាតិដែក



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ពី ៥៨% នៅក្នុងឆ្នាំ ២០០០ ដល់ ១៩% នៅក្នុងឆ្នាំ ២០១៥

**សូចនាករទី៥.៩-** បង្កើនសមាមាត្រនៃស្ត្រីមានផ្ទៃពោះ ដែលសម្រាលកូនដោយការវះកាត់ ពី ០,៨% នៅក្នុងឆ្នាំ ២០០០ ដល់ ៤% នៅក្នុងឆ្នាំ ២០១៥

## ២.៦. គោលដៅទីប្រាំមួយ: ប្រយុទ្ធប្រឆាំងនឹងមេរោគហ៊ីវ/ជម្ងឺអេដស៍ គ្រុនចាញ់ និងជម្ងឺដទៃទៀត

**ចំណុចដៅទី១១: បន្ថយការរីករាលដាលនៃមេរោគហ៊ីវ/ជម្ងឺអេដស៍**

**សូចនាករទី៦.១-** កាត់បន្ថយអត្រាប្រេវ៉ាឡង់ មេរោគហ៊ីវក្នុងចំណោមមនុស្សពេញវ័យ អាយុពី ១៥ ដល់ ៤៩ ឆ្នាំ ពី ២,៦% នៅក្នុងឆ្នាំ ២០០២ ដល់ ១,៨% នៅក្នុងឆ្នាំ ២០១៥

**សូចនាករទី៦.២-** កាត់បន្ថយអត្រាប្រេវ៉ាឡង់ មេរោគហ៊ីវក្នុងចំណោមស្ត្រីមានផ្ទៃពោះ អាយុពី ១៥ ដល់ ២៤ ឆ្នាំបានពិនិត្យផ្ទៃពោះមុនពេលសម្រាល ពី ២,៧% នៅក្នុងឆ្នាំ ២០០២ ដល់ ១,៥% នៅក្នុងឆ្នាំ ២០១៥

**សូចនាករទី៦. ៣-** បង្កើនសមាមាត្រការប្រើប្រាស់ស្រោមអនាម័យក្នុងចំណោមស្ត្រីរកស៊ីផ្លូវភេទ ក្នុងពេលរួមភេទចុងក្រោយ ពី ៩១% នៅក្នុងឆ្នាំ ២០០២ ដល់ ៩៨% នៅក្នុងឆ្នាំ ២០០៥

**សូចនាករទី៦.៤-** បង្កើនសមាមាត្រនៃយុវជនអាយុពី ១៥ ដល់ ២៤ ឆ្នាំ ដែលបានរាយការណ៍ការប្រើប្រាស់ស្រោមអនាម័យក្នុងពេលរួមភេទជាមួយដៃគូមិនទៀងទាត់ ពី ៨២% នៅក្នុងឆ្នាំ ២០០២ ដល់ ៩៥%នៅក្នុងឆ្នាំ ២០១៥

**សូចនាករទី៦.៥-** បង្កើនសមាមាត្រនៃការប្រើប្រាស់ស្រោមអនាម័យ ដែលបានរាយការណ៍ដោយស្ត្រីរៀបការ ដែលដឹងខ្លួនថាស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់ ពី ១% នៅក្នុងឆ្នាំ ២០០០ ដល់ ១០% នៅក្នុងឆ្នាំ ២០១៥

**សូចនាករទី៦.៦-** បង្កើនសមាមាត្រនៃស្ត្រីពិនិត្យផ្ទៃពោះមុនសម្រាល ដែលមានផ្ទុកមេរោគអេដស៍ ហើយបានចូលរួមក្នុងកម្មវិធីបង្ការការឆ្លងពីម្ដាយទៅកូន ពី ២,៧% នៅក្នុងឆ្នាំ ២០០២ ដល់ ៥០% នៅក្នុងឆ្នាំ ២០១៥

**សូចនាករទី៦.៧-** បង្កើនសមាមាត្រនៃអ្នកជម្ងឺអេដស៍ ដែលបានទទួលថ្នាំប្រឆាំងការឆ្លងមេរោគអេដស៍ ពី ៣% នៅក្នុងឆ្នាំ ២០០២ ដល់ ៧៥% នៅក្នុងឆ្នាំ ២០១៥

**ចំណុចដៅទី១២: បន្ថយការរីករាលដាលនៃជម្ងឺគ្រុនចាញ់ ជម្ងឺគ្រុនឈាម និងជម្ងឺរបេង**

**សូចនាករទី៦.៨-** កាត់បន្ថយអត្រាស្លាប់ដោយជម្ងឺគ្រុនចាញ់ ដែលបានរាយការណ៍ដោយមណ្ឌលសុខភាពសាធារណៈ ពី ០,៤% នៅក្នុងឆ្នាំ ២០០០ ដល់ ០,១% នៅក្នុងឆ្នាំ ២០១៥


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

**សូចនាករទី៦.៩-** បង្កើនសមាមាត្រនៃប្រជាជននៅតំបន់មានជម្ងឺគ្រុនចាញ់ខ្ពស់ ដែលប្រើប្រាស់មុងជ្រលក់ថ្នាំកាលពីយប់កន្លងមក ពី ៥៧% នៅក្នុងឆ្នាំ ២០០២ ដល់ ៩៨% នៅក្នុងឆ្នាំ ២០១៥

**សូចនាករទី៦.១០-** កាត់បន្ថយចំនួនអ្នកជម្ងឺគ្រុនចាញ់ ដែលទទួលបានការព្យាបាលនៅមណ្ឌលសុខភាពសាធារណៈ ក្នុងប្រជាជន ១.០០០ នាក់ ពី ១១,៤% នៅក្នុងឆ្នាំ ២០០០ ដល់ ៤% នៅក្នុងឆ្នាំ ២០១៥

**សូចនាករទី៦.១១-** បង្កើនសមាមាត្រនៃសេវាសុខភាពសាធារណៈ ដែលអាចបញ្ជាក់ពីរោគវិនិច្ឆ័យជម្ងឺគ្រុនចាញ់បានជាក់លាក់ ៩៥% តាមរូបមន្តជាតិ ពី ៦០% នៅក្នុងឆ្នាំ ២០០២ ដល់ ៩៥% នៅក្នុងឆ្នាំ ២០១៥

**សូចនាករទី៦.១២-** កាត់បន្ថយចំនួនអ្នកជម្ងឺគ្រុនឈាម ដែលទទួលបានការព្យាបាលនៅក្នុងមណ្ឌលសុខភាពសាធារណៈ ក្នុងប្រជាជន ១.០០០ នាក់ ពី ១ នៅក្នុងឆ្នាំ ២០០១ ដល់ ០,៤ នៅក្នុងឆ្នាំ ២០១៥

**សូចនាករទី៦.១៣-** កាត់បន្ថយអត្រាស្លាប់ដោយជម្ងឺគ្រុនឈាម ដែលបានរាយការណ៍ដោយមណ្ឌលសុខភាពសាធារណៈ ពី ១,៥ នៅក្នុងឆ្នាំ ២០០៣ ដល់ ០,៣ នៅក្នុងឆ្នាំ ២០១៥

**សូចនាករទី៦.១៤-** កាត់បន្ថយអត្រាប្រេវ៉ាឡង់នៃជម្ងឺរបេងស្ទួតវិជ្ជមាន ក្នុងចំណោមប្រជាជន ១០០.០០០ នាក់ ពី ៤២៨ នៅក្នុងឆ្នាំ ១៩៩៧ ដល់ ១៣៥ នៅក្នុងឆ្នាំ ២០១៥

**សូចនាករទី៦.១៥-** កាត់បន្ថយអត្រាស្លាប់ដោយជម្ងឺរបេង ក្នុងចំណោមប្រជាជន ១០០.០០០ នាក់ ពី ៩០ នៅក្នុងឆ្នាំ ១៩៩៧ ដល់ ៣២ នៅក្នុងឆ្នាំ ២០១៥

**សូចនាករទី៦.១៦-** បង្កើនសមាមាត្រនៃអ្នកដែលបានប៉ាន់ស្មានថាមានករណីរបេងស្ទួតវិជ្ជមានថ្មី បានរកឃើញការព្យាបាលដោយមានការត្រួតពិនិត្យផ្ទាល់ ពី ៥៧% នៅក្នុងឆ្នាំ ២០០២ ដល់ជាង ៧០% នៅក្នុងឆ្នាំ ២០១០ និង ២០១៥

**សូចនាករទី៦.១៧-** រក្សាសមាមាត្រនៃអ្នកជម្ងឺរបេងស្ទួតវិជ្ជមានដែលបានកត់ត្រា ហើយបានព្យាបាលប្រកបដោយដោយជោគជ័យ ក្រោមការព្យាបាលដោយមានការត្រួតពិនិត្យផ្ទាល់ អោយបានច្រើនជាង ៨៥% រហូតដល់ឆ្នាំ ២០០៥

## ២.៧. គោលដៅទីប្រាំពីរ: ធានានិរន្តរភាពបរិស្ថាន

**ចំណុចដៅទី១៣: បញ្ចូលគោលការណ៍អភិវឌ្ឍន៍ប្រកបដោយចីរភាព នៅក្នុងគោលនយោបាយ និងកម្មវិធីជាតិ និងបង្កើនធនធានបរិស្ថាន**


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

**សូចនាករទី៧.១-** រក្សានូវផ្ទៃដីគ្របដណ្តប់ដោយព្រៃឈើអោយនៅដូចក្នុងឆ្នាំ ២០០០ ក្នុងអត្រា ៦០% នៃផ្ទៃដីសរុប អោយបានរហូតដល់ឆ្នាំ ២០១៥

**សូចនាករទី៧.២-** រក្សានូវផ្ទៃដីតំបន់ការពារធម្មជាតិចំនួន ២៣ កន្លែង ដែលមានផ្ទៃដីសរុបចំនួន ៣,៣ លានហិកតា ដូចក្នុងឆ្នាំ ១៩៩៣ អោយបានគង់វង្សរហូតដល់ឆ្នាំ ២០១៥

**សូចនាករទី៧.៣-** រក្សានូវតំបន់អភិរក្សព្រៃឈើថ្មីទាំង ៦ ដែលមានផ្ទៃដីសរុបចំនួន ១,៣៥ លានហិកតា អោយបានរហូតដល់ឆ្នាំ ២០១៥

**សូចនាករទី៧.៤-** បង្កើនចំនួនអ្នកអភិរក្សតំបន់ការពារធម្មជាតិ ពីចំនួន ៦០០០ នៅក្នុងឆ្នាំ ២០០១ ដល់ ១.២០០ ក្នុងឆ្នាំ ២០១៥

**សូចនាករទី៧.៥-** រក្សាចំនួនអ្នកអភិរក្សតំបន់ព្រៃឈើ អោយនៅត្រឹមចំនួន ៥០០ នាក់ អោយបានរហូតដល់ឆ្នាំ ២០១៥

**សូចនាករទី៧.៦-** បង្កើនសមាមាត្រឡូតិ៍នេសាទ ដែលប្រគល់ជូនសហគមន៍មូលដ្ឋាន ពី ៥៦% នៅក្នុងឆ្នាំ ១៩៩៨ ដល់ ៦០% នៅក្នុងឆ្នាំ ២០១៥

**សូចនាករទី៧.៧-** បង្កើនចំនួនសហគមន៍ឡូតិ៍នេសាទមូលដ្ឋានពី ២៦៤ នៅក្នុងឆ្នាំ ២០០០ ដល់ ៥៨៩ នៅក្នុងឆ្នាំ ២០១៥

**សូចនាករទី៧.៨-** បង្កើនផ្ទៃដីជម្រកសុវត្ថិភាពមច្ឆា ពី ២៦៤.៥០០ ហិកតា នៅក្នុងឆ្នាំ ២០០០ ដល់ ៥៨០.០០០ នៅក្នុងឆ្នាំ ២០១៥

**សូចនាករទី៧.៩-** កាត់បន្ថយការប្រើប្រាស់អុសដុតរបស់គ្រួសារ ពី ៩២% នៅក្នុងឆ្នាំ ១៩៩៣ ដល់ ៥២% នៅក្នុងឆ្នាំ ២០១៥

**ចំណុចដៅទី១៤៖ កាត់បន្ថយអោយបានពាក់កណ្តាល សមាមាត្រប្រជាជនដែលគ្មានលទ្ធភាពប្រើប្រាស់ទឹកស្អាតជាប្រចាំនៅដំណាច់ឆ្នាំ ២០១៥**

**សូចនាករទី៧.១០-** បង្កើនសមាមាត្រប្រជាជនជនបទ ដែលមានលទ្ធភាពប្រើប្រាស់ប្រភពទឹកស្អាត ពី ២៤% នៅក្នុងឆ្នាំ ១៩៩៨ ដល់ ៨០% នៅក្នុងឆ្នាំ ២០១៥

**សូចនាករទី៧.១១-** បង្កើនសមាមាត្រប្រជាជនទីប្រជុំជន ដែលមានលទ្ធភាពប្រើប្រាស់ប្រភពទឹកស្អាត ពី



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

៦០% នៅក្នុងឆ្នាំ ១៩៩៨ ដល់ ៨០% នៅក្នុងឆ្នាំ ២០១៥

**ចំណុចដៅទី១៥:** **កាត់បន្ថយអោយបានពាក់កណ្ដាល សមាមាត្រប្រជាជនដែលគ្មានលទ្ធភាពប្រើប្រាស់អនាម័យប្រសើរជាងមុន ជាប្រចាំនៅដំណាច់ឆ្នាំ ២០១៥**

**សូចនាករទី៧.១២-** បង្កើនសមាមាត្រប្រជាជនជនបទ ដែលមានលទ្ធភាពទទួលបានប្រព័ន្ធអនាម័យប្រសើរឡើង ពី ៨,៦% នៅក្នុងឆ្នាំ ១៩៩៦ ដល់ ៣០% នៅក្នុងឆ្នាំ ២០១៥

**សូចនាករទី៧.១៣-** បង្កើនសមាមាត្រប្រជាជនទីក្រុង/ជនបទ ដែលមានលទ្ធភាពទទួលបានប្រព័ន្ធអនាម័យប្រសើរឡើង ពី ៤៩% នៅក្នុងឆ្នាំ ១៩៩៨ ដល់ ៧៤% នៅក្នុងឆ្នាំ ២០១៥

**ចំណុចដៅទី១៦:** **បង្កើនអត្រាប្រជាជនមានប័ណ្ណកម្មសិទ្ធិដីធ្លីទូទាំងប្រទេស ទាំងទីក្រុង និង ជនបទ នៅមុនដំណាច់ឆ្នាំ ២០១៥**

**សូចនាករទី៧.១៤-** បង្កើនអត្រាប្រជាជនមានប័ណ្ណកម្មសិទ្ធិដីធ្លីទូទាំងប្រទេស ទាំងទីក្រុង និងជនបទ នៅមុនដំណាច់ឆ្នាំ ២០១៥

## ២.៨. គោលដៅទីប្រាំបី: បង្កើនភាពជាដៃគូជាសកលសម្រាប់កិច្ចអភិវឌ្ឍន៍

**ពីចំណុចដៅទី១៧ ដល់ ២៣:** **សម្រាប់ដៃគូអភិវឌ្ឍន៍ក្រៅប្រទេសមានភាពទូលំទូលាយ សម្រាប់ក្នុងប្រទេសពុំមានចំណុចដៅច្បាស់លាស់**

## ២.៩. គោលដៅទីប្រាំបួន: ការដោះមីន យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ និងការសង្គ្រោះជនរងគ្រោះដោយសារមីន

**ចំណុចដៅទី២៤:** **ឆ្ពោះទៅរកអត្រាគ្រោះថ្នាក់សូន្យដោយសារមីន និងគ្រាប់មិនទាន់ផ្ទុះ**

**សូចនាករទី៩.១-** កាត់បន្ថយចំនួនជនរងគ្រោះដោយសារមីន អោយអស់ដល់សូន្យនៅត្រឹមឆ្នាំ ២០១២

**សូចនាករទី៩.២-** បោសសម្អាតតំបន់ដែលសង្ស័យថាមានមីនអោយអស់ អោយបានមុនឆ្នាំ ២០១២

**ចំណុចដៅទី២៥:** **លុបបំបាត់ផលប៉ះពាល់ជាវិជ្ជមានដល់មនុស្សជាតិ និងសេដ្ឋកិច្ច សង្គមកិច្ច ដោយសារមីន និងគ្រាប់មិនទាន់ផ្ទុះ នៅឆ្នាំ ២០១៥**

**សូចនាករទី៩.៣-** បង្កើតក្របខ័ណ្ឌការងារជំនួយទូលំទូលាយដល់ជនរងគ្រោះ មុនឆ្នាំ ២០០៥

**សូចនាករទី៩.៤–** បង្កើតកញ្ចប់ជំនួយ និងធ្វើសមាហរណកម្មទៅក្នុងសង្គមដល់ជនរងគ្រោះដោយសារគ្រាប់មីន និងគ្រាប់មិនទាន់ផ្ទុះ

## ៣-ការសម្របសម្រួលហិរញ្ញប្បទានដើម្បីអភិវឌ្ឍន៍

**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ** បានដាក់ចេញនូវផែនការពង្រឹងភាពជាដៃគូ ក្នុងគោលដៅបង្កើនប្រសិទ្ធភាពនៃហិរញ្ញប្បទានពហុភាគី និង ទ្វេភាគីដើម្បីអភិវឌ្ឍន៍ ដែលរួមមាន៖

- វេទិកាពិភាក្សាពិគ្រោះយោបល់ប្រចាំឆ្នាំ ត្រូវបានរៀបចំឡើងក្រោមភាពជាម្ចាស់ដ៏ពេញលេញរបស់កម្ពុជា ហើយដែលមានឈ្មោះថា **វេទិកាសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា** ។

- យន្តការសម្របសម្រួលរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ត្រូវបានពង្រឹង និងកែលម្អ៖ **គណៈកម្មការសម្របសម្រួលរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍** ដែលដឹកនាំដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជួបប្រជុំគ្នាក្នុងមួយឆ្នាំបីដង ដើម្បីពិភាក្សាបញ្ហារួម និងមានភារកិច្ចសម្របសម្រួល **ក្រុមការងារបច្ចេកទេស**ទាំង ១៨ ដែលមានតំណាងមកពីរាជរដ្ឋាភិបាល និង ដៃគូអភិវឌ្ឍន៍ ។ ។ ទន្ទឹមនឹងនេះ **គណៈកម្មការសម្របសម្រួលរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍** បានរៀបចំ និងអនុម័តនូវសូចនាករតាមដានរួម ដើម្បីវាស់វែងនូវសមិទ្ធិផលដែលសម្រេចបាន និងដាក់ចេញនូវគោលដៅនៃកំណែទម្រង់ក្នុងគ្រប់វិស័យ ។

- **ក្រុមការងារបច្ចេកទេស** ដំណើរការងាររបស់ខ្លួនដើម្បីសម្របសម្រួល និងតាមដានត្រួតពិនិត្យវឌ្ឍនភាពអោយបានប្រសើរជាងមុន នៅកម្រិតវិស័យ ។ ក្រុមការងារបច្ចេកទេសនីមួយៗបានកំណត់ឡើងវិញនូវតួនាទី និងការទទួលខុសត្រូវរបស់ខ្លួន និងបានដាក់ចេញនូវគោលការណ៍ណែនាំច្បាស់លាស់ ដោយមានសង្គតិភាពជាមួយនឹងគ្នាទៅវិញទៅមក ហើយដំណើរការដោយឯករាជ្យពីគ្នា ។

- **ដៃគូអភិវឌ្ឍន៍ក្រៅប្រទេស** សហការគ្នាច្រើនជាងមុននៅក្នុងចំណោមពួកគេ ហើយលើកជូនរាជរដ្ឋាភិបាលកម្ពុជា នូវបញ្ហាបារម្ភរួមរបស់ពួកគេ ។

- រាជរដ្ឋាភិបាលកម្ពុជាបានប្តេជ្ញាអនុវត្តនូវ «**សេចក្តីថ្លែងការណ៍ទីក្រុងប៉ារីសស្តីពីប្រសិទ្ធភាពនៃជំនួយ**» ដើម្បីបង្កើនប្រសិទ្ធភាពនៃ**ហិរញ្ញប្បទានដើម្បីអភិវឌ្ឍន៍** ។

- រាជរដ្ឋាភិបាលកម្ពុជាបានអនុម័តនូវ «**ផែនការសកម្មភាពស្តីពីសុខដុមនីយកម្ម ការតម្រឹមតម្រង់ និងលទ្ធផលសម្រាប់ឆ្នាំ ២០០៦-២០១០**» ដើម្បីអនុវត្តអោយមានប្រសិទ្ធភាពនូវ **ហិរញ្ញប្បទានដើម្បី**



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

**អភិវឌ្ឍន៍** និងធានាបាននូវការទទួលខុសត្រូវរបស់ភាគីទាំងសងខាង ។

- រាជរដ្ឋាភិបាលកម្ពុជាបានអនុម័តនៅក្នុងឆ្នាំ ២០០៦ នូវ «**ក្របខ័ណ្ឌយុទ្ធសាស្រ្តស្តីពីការគ្រប់គ្រងកិច្ចសហប្រតិបត្តិការដើម្បីអភិវឌ្ឍន៍**» ក្នុងគោលដៅកំណត់អោយបានច្បាស់នូវតួនាទី និងភារកិច្ចរបស់ក្រសួង- ស្ថាប័នទាំងអស់របស់រាជរដ្ឋាភិបាល ក្នុងការកៀងគរធនធានក្រៅប្រទេស និងសម្របសម្រួល**ហិរញ្ញប្បទានដើម្បីអភិវឌ្ឍន៍** ។
- រាជរដ្ឋាភិបាលកម្ពុជាបានអនុម័តនៅក្នុងឆ្នាំ ២០០៦ នូវ «**គោលការណ៍ណែនាំប្រតិបត្តិថ្នាក់ជាតិស្តីពីការអនុវត្តជំនួយ**» និង «**នីតិវិធីប្រតិបត្តិរួមស្តីពីកម្ចី**» ដោយសហការជាមួយធនាគារអភិវឌ្ឍន៍អាស៊ី និងធនាគារពិភពលោក ។
- រាជរដ្ឋាភិបាលកម្ពុជាបានរៀបចំ និងអនុម័តនូវ **ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ** ដែលត្រូវបានរៀបចំឡើងដោយឈរលើ **យុទ្ធសាស្រ្តចតុកោណ** ប្រកបដោយការគិតគូគ្រប់ជ្រុងជ្រោយលើគ្រប់វិស័យ តាមរយៈការពិគ្រោះយោបល់យ៉ាងទូលំទូលាយជាមួយគ្រប់ដៃគូទាំងអស់ និងជាលទ្ធផលនៃការប្រមូលបញ្ចូលគ្នានូវឯកសារនានា មានជាអាទិ៍ **គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជាជាតិ** **យុទ្ធសាស្រ្តជាតិកាត់បន្ថយភាពក្រីក្រ** **គោលនយោបាយជាតិប្រជាជន** ដោយមានទាំងការគិតគូពីប្រភពហិរញ្ញប្បទាន និង **ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម** ផងដែរ ។

## ៤. ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម

### ៤.១. ក្របខ័ណ្ឌទូទៅ

**ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម** គឺជាឧបករណ៍កម្មវិធីនីយកម្មនៃចំណាយសាធារណៈ ដោយគិតគូរពីកំហិត និងគោលដៅ ។ **ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម** ត្រូវដាក់ជាផ្នែកមួយនៃ **ផែនការយុទ្ធសាស្រ្តអភិវឌ្ឍជាតិ** ដោយមានការកំណត់នូវទឹកប្រាក់ហិរញ្ញប្បទាន ។ ក្របខ័ណ្ឌនេះបែងចែកថវិកាតាមទិសដៅ ដែលរៀបចំឡើងតាមតួនាទី និង កម្មវិធីសម្រាប់រយៈពេលពី ៥ ទៅ ១០ ឆ្នាំ ។ ដោយឈរលើមូលដ្ឋាននៃធនធានដែលមានចីរភាព **ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម** កំណត់នូវកញ្ចប់ថវិកាចំណាយ ដោយគិតគូរពីគោលដៅ និងអន្តរប្រតិសកម្មរវាងគោលដៅ ដែលបានដាក់ចេញ ។ ឧទាហរណ៍មួយនៃអន្តរប្រតិសកម្មរវាងគោលដៅ គឺចំនួនសិស្សចូលរៀន ដែលអាស្រ័យលើការធ្វើផែនការនីយកម្មគ្រួសារ និង ការពន្យាកំណើត និង លើគោលនយោបាយក្នុងការចាក់ថ្នាំបង្ការ ។


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

**ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម** ក្នុងកម្រិតទូទៅ ត្រូវចាប់ផ្តើមពី **ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម** តាមវិស័យ÷វិស័យសុខាភិបាល អប់រំ ហេដ្ឋារចនាសម្ព័ន្ធ សមាហរណកម្មអន្តរជាតិ បរិស្ថាន ។ល។

ការគណនាធនធានអោយមានចីរភាព អាចប៉ាន់ស្មានគិតជាសមាមាត្រនៃផលិតផលសរុបក្នុងស្រុក (ផសស) ឬ តាមវិធីសាស្រ្តដែលមានលក្ខណៈស្មុគស្មាញជាងនេះ ដោយលាយចម្រុះនូវ÷ សមាមាត្រនៃ ផសស សមាមាត្រនៃការនាំចូល សមាមាត្រនៃប្រាក់ចំណូលនៃគេហជន ជាដើម ។ល។ ការគណនានេះត្រូវឈរលើមូលដ្ឋាននៃការព្យាករណ៍ម៉ាក្រូសេដ្ឋកិច្ច ។

ចំណាយត្រូវគិតគូផងដែរនូវ «**វិធានការចាស់ដែលបានអនុម័តរួច**» ដែលត្រូវផ្ទៀងផ្ទាត់ជាមួយនឹងចំណាយថវិកា ដែលរដ្ឋត្រូវផ្តល់ក្នុងរយៈពេលកន្លងមក ហើយធនធានដែលនៅសល់ អាចទុកសម្រាប់ធ្វើហិរញ្ញប្បទាននៃ «**វិធានការថ្មី**» ។

---

***ចំណាយចរន្ត***

ចំណាយវិនិយោគត្រូវមានសង្គតិភាពជាមួយនឹងចំណាយចរន្ត ដែលចាំបាច់សម្រាប់ដំណើរការ នៅពេលដែលការងារសាងសង់ត្រូវបានបញ្ចប់ ។ ដូច្នេះ ការគណនាកំណត់ចំណាយចរន្ត សម្រាប់កិច្ចដំណើរការត្រូវតែគិតគូអោយបានមុនពេល ដែលការងារត្រូវបានបញ្ចប់ ។

ឧទាហរណ៍ ការសាងសង់សាលារៀនត្រូវរៀបចំឡើង ដោយដាក់អោយអនុវត្តនូវនីតិវិធីលទ្ធកម្មសាធារណៈការចាប់ផ្តើមការងាររបស់អ្នកម៉ៅការសាងសង់ ការបំពេញការងារសាងសង់ និង ការប្រគល់-ទទួលសាលារៀនដែលសង់រួច ។

ដើម្បីធានាបាននូវការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពនូវធនធានសាធារណៈ យើងត្រូវរៀបចំផែនការសាងសង់អោយបានត្រឹមត្រូវ ដោយធ្វើការដេញថ្លៃប្រកួតប្រជែង ដោយលៃលកធ្វើយ៉ាងណា អោយការងារសាងសង់ត្រូវបានបញ្ចប់ ហើយសាលារៀនអាចដាក់អោយសិស្សចូលរៀនបាន នៅដើមឆ្នាំសិក្សា ។

ដើម្បីអោយសាលារៀនអាចដំណើរការបាន ថ្នាក់រៀនត្រូវបំពាក់ដោយឧបករណ៍ សម្ភារៈ មាន តុ កៅអី និង ក្តារឃៀន ជាដើម ។ល។ ទន្ទឹមនឹងនេះ ត្រូវមានសៀវភៅសិក្សាដែលត្រូវបញ្ជាទិញអោយទាន់ពេល និងទូទាត់ដោយថវិកា ។

ម្យ៉ាងវិញទៀត ក្រសួងអប់រំ យុវជន និងកីឡាត្រូវដាក់ចេញនូវផែនការជ្រើសរើសគ្រូអោយបាន ២ ទៅ ៣ ឆ្នាំមុន ដែលត្រូវឆ្លងកាត់វគ្គបណ្តុះបណ្តាលគរុកោសល្យ និង ត្រូវជ្រើសរើសបុគ្គលិកអោយមកបម្រើការ អោយបានទាន់ពេលវេលា ។

សរុបមក យើងឃើញថា ក្រសួងអប់រំ យុវជន និង កីឡាត្រូវមានថវិកាដំណើរការសាលារៀនអោយបានមុនពេលដែលសាលារៀននេះត្រូវបានប្រគល់-ទទួលពីអ្នកម៉ៅការសាងសង់ទៅទៀត ។

---

ធនធានថវិកាប្រកបដោយចីរភាព ត្រូវបានបែងចែកតាមកញ្ចប់ថវិកា តាមក្រសួង-ស្ថាប័នរដ្ឋ ដោយប្រើប្រាស់នូវបច្ចេកទេសក្នុងការធ្វើវិចារណកម្មចំណាយថវិកា និង វិធីសាស្រ្ត «**ផែនការនីយកម្ម-កម្មវិធីនីយកម្ម និង ថវិកានីយកម្ម**» ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

តាមធម្មតា នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួន នាយកដ្ឋានថវិកា និងហិរញ្ញវត្ថុនៃក្រសួង ស្ថាប័នរដ្ឋ ជាអង្គភាពទទួលបន្ទុករៀបចំនូវ **ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម** តាមផ្នែកនេះ ហើយក្រសួងផែនការជាក្រសួង ដែលទទួលខុសត្រូវខាងផ្នែករៀបចំ **ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម** ក្នុងកម្រិតជាតិទាំងមូល ។

## ៤.២. ការដាក់អោយអនុវត្តនូវក្របខ័ណ្ឌចំណាយរយៈពេលមធ្យមនៅកម្ពុជា

នៅព្រះរាជាណាចក្រកម្ពុជា **ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម** ត្រូវបានរៀបចំឡើង និងដាក់អោយអនុវត្តនៅក្នុងឆ្នាំ ២០០២ ដោយមានការឧបត្ថម្ភគាំទ្រតាមរយៈជំនួយបច្ចេកទេសរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ដែលជា សមាសធាតុមួយយ៉ាងសំខាន់នៃកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ **ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម** គឺជាដំណើរការរៀបចំថវិកា ដែលទាមទារអោយមានការវិវត្តនូវប្រព័ន្ធថវិកាតាមទិសដៅសំខាន់ៗបី ដូចតទៅ ÷

- **ទីមួយ**- កំណត់នូវក្របខ័ណ្ឌសម្រាប់រយៈពេលច្រើនឆ្នាំ ដើម្បីរៀបចំផែនការចំណូលអោយបានស៊ិតស៊ិរ មានសង្គតិភាព និង មានភាពប្រាកដនិយម ក្នុងគោលដៅទប់ស្កាត់នូវវិសោធនកម្មរយៈពេលខ្លីក្នុងការបើកផ្តល់ថវិកា ដូចជាការកាត់បន្ថយឥណទានថវិកាភ្លាមៗ ដែលអាចបង្កអោយមានភាពមិនច្បាស់លាស់ និង អាកប្ប-កិរិយាអវិជ្ជមាន ហើយនាំអោយការបើកផ្តល់ថវិកាដល់ក្រសួង ស្ថាប័នប្រតិបត្តិ និងដល់រដ្ឋបាលមូលដ្ឋាន មានការយឺតយ៉ាវ និងមានភាពមិនប្រក្រតី ។
- **ទីពីរ**- ការយកចិត្តទុកដាក់ដល់ការបែងចែកថវិកាជាអាទិភាព ដល់កម្មវិធីថវិកា ដែលឆ្លើយតបទៅនឹងយុទ្ធសាស្ត្រ និង គោលដៅសមិទ្ធកម្មដែលត្រូវសម្រេចបាន ។
- **ទីបី**- កែលម្អព័ត៌មាន តាមរយៈការផ្តល់ថវិកាអោយបានច្រើនដល់អង្គភាពទទួលខុសត្រូវ និង ទាមទារអោយសម្រេចបាននូវលទ្ធផល និង ការកែលម្អនូវប្រព័ន្ធសម្រេចចិត្ត និង ប្រព័ន្ធគ្រប់គ្រង ។

ជាការពិតណាស់ យើងមិនត្រូវផ្តោតការយកចិត្តទុកដាក់ខ្លាំងពេក ទៅលើ **ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម** ដែលមានលក្ខណៈជាទ្រឹស្តី ដោយចាត់ទុកវាជាឱសថទិព្វដែលអាចដោះស្រាយរាល់បញ្ហាគ្រប់គ្រងថវិកាបានឡើយ ។ ក៏ប៉ុន្តែ ត្រូវចាត់ទុកថា **ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម** គឺជាមធ្យោបាយមួយសម្រាប់ធ្វើកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ ហើយជាពិសេសសម្រាប់ប្រទេសកម្ពុជា **ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម** អាចជួយ ÷

- ធានាអោយបាននូវការបែងចែកឥណទានថវិកា ដោយអនុលោមតាមអាទិភាពជាយុទ្ធសាស្ត្រ ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម ឆ្នាំ ២០០៨-២០១០

| | 2007 | | 2008 | | 2009 | | 2010 | |
|---|---|---|---|---|---|---|---|---|
| | Bil. riel | % PIB | Bil. riel | % PIB | Bil. riel | % PIB | Bil. riel | % PIB |
| ចំណាយចរន្ត | 2,973.6 | 8.49% | 3,637.0 | 8.67% | 4,359.0 | 9.23% | 4,557.0 | 9.08% |
| សុខាភិបាល | 343.3 | 0.98% | 372.9 | 0.89% | 503.8 | 1.07% | 588.5 | 1.17% |
| អប់រំ | 491.3 | 1.40% | 506.0 | 1.21% | 742.5 | 1.57% | 867.3 | 1.73% |
| កិច្ចការនារី | 14.9 | 0.04% | 18.7 | 0.04% | 25.5 | 0.05% | 30.5 | 0.06% |
| យុត្តិធម៌ | 15.6 | 0.04% | 17.6 | 0.04% | 26.9 | 0.06% | 30.5 | 0.06% |
| សង្គមកិច្ច | 129.0 | 0.37% | 138.6 | 0.33% | 181.4 | 0.38% | 169.1 | 0.34% |
| វិស័យកសិកម្ម | 112.7 | 0.32% | 116.7 | 0.28% | 171.9 | 0.36% | 195.4 | 0.39% |
| ក- ក្រសួងកសិកម្ម | 57.6 | 0.16% | 63.1 | 0.15% | 76.9 | 0.34 | 87.4 | 0.17% |
| ខ- ក្រសួងអភិវឌ្ឍន៍ | 34.7 | 0.10% | 32.2 | 0.08% | 63.7 | 0.17 | 72.4 | 0.14% |
| គ- ក្រសួងធនធានទឹក | 20.4 | 0.06% | 21.4 | 0.05% | 31.3 | 0.07% | 35.6 | 0.07% |
| ដែនដី នគរូបនីយកម្ម | 15.3 | 0.04% | 16.4 | 0.04% | 24.0 | 0.05% | 22.4 | 0.04% |
| យោធា និងសន្តិសុខ | 615.8 | 1.76% | 789.9 | 1.88% | 895.8 | 1.90% | 989.4 | 1.97% |
| ផសស | 35,042 | | 41,968 | | 47,244 | | 50,166 | |
| កំណើន ផសស | 10.2% | | 6.8% | | 6.0% | | 3.0% | |

* ជាក់ស្តែង

*ប្រភពៈ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ*

- សម្រួលដល់ការប្រើប្រាស់ធនធានអោយមានប្រសិទ្ធភាព និង ភាពសក្តិសិទ្ធខ្ពស់ ដោយក្រសួង ស្ថាប័នចំណាយអាចដំណើរការដោយស្វ័យភាពខ្ពស់ និង មានការទទួលខុសត្រូវខ្លាំងជាងមុន ដើម្បីសម្រេចបាននូវលទ្ធផលល្អប្រសើរដោយប្រើប្រាស់ធនធានមានការសន្សំសំចៃ ។

**ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម សម្រាប់ឆ្នាំ ២០០៨-២០១០** ត្រូវបានរៀបចំឡើងសម្រាប់តែវិស័យជាអាទិភាពដូចជា ÷ អប់រំ សុខាភិបាល កសិកម្ម អភិវឌ្ឍន៍ជនបទ ធនធានទឹក យុត្តិធម៌ និង កិច្ចការនារី ។ លក្ខណៈសម្បត្តិនៃ **ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម** មានដូចតទៅ÷

- **ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម** សម្រាប់រយៈពេលបីឆ្នាំ ដោយផ្តោតលើតែចំណាយចរន្ត ដោយឈរលើមូលដ្ឋាននៃចំណាត់ថ្នាក់ថវិកា តាមមុខងារ ។



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

- ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច ដោយឈរលើមូលដ្ឋាននៃការព្យាករណ៍រយៈពេលមធ្យម ដោយមានកំណត់កញ្ចប់ថវិកាសរុប និងកញ្ចប់ថវិកាតាមផ្នែកសម្រាប់ចំណាយសាធារណៈ ។

- ក្របខ័ណ្ឌតាមផ្នែក ដោយគិតគូពីយុទ្ធសាស្ត្រ និងគោលនយោបាយតាមផ្នែកនីមួយៗ ។

**ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម សម្រាប់ឆ្នាំ ២០០៨-២០១០** បានដាក់ចេញនូវវិធានការគោលនយោបាយ ក្នុងគោលដៅជម្រុញកម្ពុជាអោយបោះជំហានឆ្ពោះទៅកាត់ការអភិវឌ្ឍប្រកបដោយចីរភាព ។ ក្របខ័ណ្ឌនេះមានផែនការបង្កើនចំណាយទៅលើវិស័យសុខាភិបាល អប់រំ កសិកម្ម អភិវឌ្ឍន៍ជនបទ យុត្តិធម៌ និងកិច្ចការនារី ។ ដើម្បីសម្រេចបានតាមគោលដៅនេះ រាជរដ្ឋាភិបាលមានការប្តេជ្ញាចិត្តធ្វើការវិភាជន៍ឡើងវិញនូវធនធាន និង ចំណាយថវិកាដើម្បីអនុវត្តនូវអាទិភាពតាមផ្នែករបស់កម្ពុជា ។

**ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម សម្រាប់ឆ្នាំ ២០០៨-២០១០** បានព្យាករណ៍បង្កើនចំណាយចរន្តពី ១០,៦%នៃផសស នៅក្នុងឆ្នាំ ២០០៤ ដល់ ១២,៣%នៃផសស នៅក្នុងឆ្នាំ ២០០៧ ។ បើគិតជាសាច់ប្រាក់ជាក់ស្តែង ចំណាយថវិកាចរន្តត្រូវបានព្យាករណ៍ថានឹងកើនឡើង ពី ១.៨៩១ ពាន់លានរៀល នៅក្នុងឆ្នាំ ២០០៤ ដល់ ២.៧៧១ ពាន់លានរៀល នៅក្នុងឆ្នាំ ២០០៧ ពោលគឺកំណើនជាមធ្យមចំនួន ៣៦% ដែលជាអត្រាកំណើនប្រហាក់ប្រហែលនឹងកំណើនផលិតផលសរុបក្នុងស្រុកតាមថ្លៃចរន្តដែរ ។

ក្នុងក្របខ័ណ្ឌនៃកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ និងកំណែទម្រង់តាមផ្នែក **ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម** បានព្យាករណ៍បង្កើនយ៉ាងខ្លាំងនូវចំណាយលើវិស័យសេដ្ឋកិច្ច និងសង្គមកិច្ច ÷

- ចំណាយលើវិស័យសុខាភិបាលត្រូវបានប៉ាន់ស្មានថានឹងកើនឡើងពី ១,២៤%នៃផសស ដល់ ១,៤៥%នៃផសស ដើម្បីធានាអោយបាននូវហិរញ្ញប្បទានប្រកបដោយស្ថិរភាព និង រយៈពេលវែងនូវវិស័យសុខាភិបាល ។ ចំណាយលើវិស័យសុខាភិបាលនឹងសម្រេចបានចំនួន ៣២៦ ពាន់លានរៀល (តាមសម្មតិកម្មមូលដ្ឋាន) នៅក្នុងឆ្នាំ ២០០៧ ដែលមានកំណើនជាមធ្យមចំនួន ២៥ ពាន់លានរៀល ឬ ៣៦% ក្នុងមួយឆ្នាំ ចាប់ពីឆ្នាំ ២០០៤ ។

- កំណើនចំណាយលើវិស័យអប់រំ ដើម្បីធានាបាននូវការអនុវត្តនូវគោលនយោបាយ «**អប់រំសម្រាប់ទាំងអស់គ្នា**» និង ជម្រុញដល់ការផ្សព្វផ្សាយចំណេះដឹង និង តក្កកម្ម ។ ចំណាយអប់រំបានគ្រោងនឹងកើនឡើងពី ៣៥៥ ពាន់លានរៀល នៅក្នុងឆ្នាំ ២០០៤ ដល់ ៤៨៨ ពាន់លានរៀល (តាមសម្មតិកម្មមូលដ្ឋាន) នៅក្នុងឆ្នាំ ២០០៧ ដែលមានកំណើនជាមធ្យមចំនួន ៣៣ ពាន់លានរៀល ឬ ៣៤% ក្នុងមួយឆ្នាំ ចាប់ពីឆ្នាំ ២០០៤ ។ គិតជាសមាមាត្រនៃ ផសស ចំណាយអប់រំនឹងកើនឡើងពី ១,៩៣%នៃផសស នៅក្នុងឆ្នាំ ២០០៤ ដល់ ២,១៧%នៃផសស នៅក្នុងឆ្នាំ ២០០៧ ។


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

- ការបង្កើននូវហិរញ្ញប្បទានដល់វិស័យកសិកម្មទាំងមូល ដោយចំណាយលើវិស័យកសិកម្មបានគ្រោងថានឹងកើនឡើងពី ០,៤៧%នៃផសស នៅក្នុងឆ្នាំ ២០០៤ ដល់ ០,៦៨%នៃផសស នៅក្នុងឆ្នាំ ២០០៧ ។ ថវិកាសម្រាប់វិស័យកសិកម្មត្រូវបានបែងចែកដូចតទៅ ÷ (១) ថវិកាសម្រាប់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទត្រូវបានគ្រោងថានឹងកើនឡើងពី ៤៧ ពាន់លានរៀល ដល់ ៦០ ពាន់លានរៀល (២) ថវិកាសម្រាប់ក្រសួងអភិវឌ្ឍន៍ជនបទត្រូវបានគ្រោងថានឹងកើនឡើងពី ២៣ ពាន់លានរៀល ដល់ ៣០ ពាន់លានរៀល និង ថវិកាសម្រាប់ក្រសួងធនធានទឹក និង ឧតុនិយមត្រូវបានគ្រោងថានឹងកើនឡើងពី ១៦ ពាន់លានរៀល ដល់ ២៥ ពាន់លានរៀល ។
- ការបង្កើននូវថវិការបស់ក្រសួងសាធារណៈការ និង ដឹកជញ្ជូន ដែលនឹងកើនឡើងពី ១៥ ពាន់លានរៀល នៅក្នុងឆ្នាំ ២០០៤ ដល់ ២៤ ពាន់លានរៀល នៅក្នុងឆ្នាំ ២០០៦ ។
- ការបង្កើនចំណាយសម្រាប់កិច្ចការនារី និង វិស័យយុត្តិធម៌ ដែលថវិការបស់ក្រសួងកិច្ចការនារីនឹងកើនឡើង ពី ៧២ ពាន់លានរៀលនៅក្នុងឆ្នាំ ២០០៤ ដល់ ១០០ ពាន់លានរៀល នៅក្នុងឆ្នាំ ២០០៧ ។ ថវិការបស់ក្រសួងយុត្តិធម៌ត្រូវបានគ្រោងថានឹងកើនឡើងពី ១៣ ពាន់លានរៀល នៅក្នុងឆ្នាំ ២០០៤ ដល់ ២០ ពាន់លានរៀល នៅក្នុងឆ្នាំ ២០០៧ ។

**ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម** ត្រូវឈរលើមូលដ្ឋាននៃការព្យាករណ៍ម៉ាក្រូសេដ្ឋកិច្ច និង កម្មវិធីវិនិយោគសាធារណៈរំកិល ៣ ឆ្នាំ ក៏ដូចជាការព្យាករណ៍ចំណាយចរន្ត និង ចំណាយវិនិយោគនៃថវិកាជាតិ ។ ដូច្នេះ **ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម** គឺជាការអនុវត្តនូវឧបករណ៍ផែនការនីយកម្មថវិកាសម្រាប់ច្រើនឆ្នាំ ។

## ៥. ការព្យាករណ៍ម៉ាក្រូសេដ្ឋកិច្ច

ការព្យាករណ៍ម៉ាក្រូសេដ្ឋកិច្ច គឺជាដំណាក់កាលទីមួយនៃការរៀបចំថវិកា ។ តាមរយៈការវិភាគនៃស្ថានភាពសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង សេណារីយ៉ូនៃការវិវត្តនៃស្ថានភាពសេដ្ឋកិច្ចក្នុងរយៈពេលខ្លី និង រយៈពេលមធ្យម យើងអាចកំណត់បាននូវបរិមាណនៃកញ្ចប់ថវិកា ទាំងខាងចំណូល ទាំងខាងចំណាយ ។ ដំណើរការរៀបចំថវិកាត្រូវកំណត់នូវអាទិភាព និង ជម្រើសផ្សេងៗ ដើម្បីធានាអោយបាននូវកិច្ចដំណើរការដោយធម្មតានូវក្បាលម៉ាស៊ីនរដ្ឋ និងចូលរួមវិភាគទានក្នុងការអនុវត្តនូវការវិនិយោគ ដែលចាំបាច់សម្រាប់ការផ្តល់សេវាសាធារណៈជាមូលដ្ឋាន ដោយគាំទ្រដល់កំណើនសេដ្ឋកិច្ច និង រក្សាអោយបាននូវតុល្យភាពជាមូលដ្ឋាន ខាងផ្នែកហិរញ្ញវត្ថុ និង រូបិយវត្ថុ ។

ការព្យាករណ៍នៃក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច អាចចែកចេញជាផ្នែកសំខាន់ៗដូចតទៅ ÷


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

## ៥.១. ការព្យាករណ៍នៃវិស័យពិត

ការព្យាករណ៍នៃវិស័យពិតត្រូវឈរលើមូលដ្ឋាននៃការព្យាករណ៍នៃគណនីជាតិ និង ការព្យាករណ៍ថ្លៃទំនិញ ក្នុងក្របខ័ណ្ឌនៃផែនការអភិវឌ្ឍន៍រយៈពេលមធ្យម របាយការណ៍ស្តីពីស្ថានភាពសេដ្ឋកិច្ច នៅក្នុងសេចក្តីថ្លែងហេតុ នៃច្បាប់ស្តីពីហិរញ្ញវត្ថុប្រចាំឆ្នាំ និង កម្មវិធីត្រួតពិនិត្យមាត្រា ៤ នៃមូលនិធិហិរញ្ញវត្ថុអន្តរជាតិ ។

ទោះបីជាក្នុងកាលៈទេសៈណាទាំងអស់ តួលេខរបស់រាជរដ្ឋាភិបាលត្រូវបានចាត់ទុកជាតួលេខជាអាទិភាព សម្រាប់យកមកពិចារណា និង សម្រាប់យកមករៀបចំថវិកា ។ ក៏ប៉ុន្តែ ប្រសិនបើមានបញ្ហាសង្គតិភាពជារួម ដែលពាក់ព័ន្ធនឹងតួលេខផ្លូវការដែលត្រូវប្រើ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងរៀបចំឡើងនូវកិច្ចពិភាក្សា ជាមួយក្រសួងស្ថាប័ន ដែលមានការពាក់ព័ន្ធ ដើម្បីពិនិត្យតួលេខឡើងវិញ និង កំណត់យកតួលេខជាផ្លូវការដែលមានមូលដ្ឋានច្បាស់លាស់ ឬ ត្រូវកែតម្រូវតាមការចាំបាច់ ។

ក្នុងដំណាក់កាលនេះ យើងត្រូវគូសបញ្ជាក់ជាពិសេស លើភាពសមស្រប និង សង្គតិភាពនៃតួលេខ ដើម្បីធានាអោយបាននូវក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច ដែលត្រឹមត្រូវ និងឆ្លុះបញ្ចាំងនូវភាពប្រាកដនិយមជាក់ស្តែង ។ ការវិភាគត្រូវផ្តោតលើទំនាក់ទំនងប្រតិសកម្មនៅក្នុងវិស័យនីមួយៗ និង រវាងវិស័យផ្សេងៗនៃសេដ្ឋកិច្ចជាតិ ការវិវត្តិជាប្រវត្តិសាស្រ្ត ភាពគ្របដណ្តប់យ៉ាងពេញលេញនូវក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច ជាមួយនឹងបរិស្ថានសេដ្ឋកិច្ចផ្ទៃក្នុង និង នៅក្នុងសកលលោក ក៏ដូចជាសង្គតិភាពជាមួយទ្រឹស្តីសេដ្ឋកិច្ចសំខាន់ៗ ។

ចាំបាច់ត្រូវគូសបញ្ជាក់ថា ការរៀបចំក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច គឺជាដំណាក់កាលមួយដ៏សំខាន់នៃការរៀបចំថវិកា ។ ដូច្នេះហើយ ទើបក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើការរៀបចំក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចនេះ ដើម្បីកុំអោយមានការប៉ះពាល់ទៅលើដំណើរការរៀបចំថវិកាទាំងមូល ។

ជារួម គុណភាពនៃក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចអាស្រ័យលើកត្តាដូចតទៅ ÷ (ក) ទ្រឹស្តីសេដ្ឋកិច្ច និង ហិរញ្ញវត្ថុជារួម (ខ) ទិន្នន័យនៃសេដ្ឋកិច្ចជាតិតាមផ្នែកសំខាន់ៗ (គ) បរិស្ថានផ្ទៃក្នុង និង បរិស្ថានខាងក្រៅនៃសេដ្ឋកិច្ចជាតិ (ឃ) បច្ចេកទេសស្ថិតិជាមូលដ្ឋាន (អត្រា លេខជាមធ្យម សន្ទស្សន៍ ។ល។) ។

## ៥.២. ការព្យាករណ៍ហិរញ្ញវត្ថុសាធារណៈ

ការព្យាករណ៍ហិរញ្ញវត្ថុសាធារណៈ គឺជាការរៀបចំនូវ **តារាងប្រតិបត្តិការហិរញ្ញវត្ថុរបស់រដ្ឋ** (TOFE) ដោយសហការយ៉ាងជិតស្និទ្ធជាមួយនាយកដ្ឋានសំខាន់ៗរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយផ្តោតលើចំណូល ចំណាយថវិកា ការធ្វើហិរញ្ញប្បទានពីខាងក្រៅ ដើម្បីកំណត់អោយបានច្បាស់នូវឱនភាព ឬ អតិរេកនៃជញ្ជីងថវិកាចរន្ត ឬ ជញ្ជីងថវិកាសរុប ក្នុងគោលដៅកំណត់ពីបរិមាណដែលត្រូវធ្វើហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍ ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ដើម្បីធានាអោយបាននូវសង្គតិភាព ការព្យាករណ៍ចំណូលត្រូវតែសមស្របជាមួយនឹងកម្រិតនៃការនាំចូល (ដើម្បីប៉ាន់ស្មានចំណូលគយ) និង ផលិតផលសរុបក្នុងស្រុក ដោយដកចេញនូវវិស័យកសិកម្មដែលមិនយកពន្ធ (ដើម្បីប៉ាន់ស្មានចំណូលប្រមូលដោយអគ្គនាយកដ្ឋានពន្ធដារ) ។ តារាងនៃគម្រោងថវិកានេះត្រូវបញ្ចូលផងដែរនូវកាតព្វកិច្ចសេវាការប្រាក់ និងទូទាត់បំណុល ដែលរតនាគារជាតិត្រូវបើកផ្តល់ ។

## ៥.៣. ការគណនាចំណូលថវិកា

### ៥.៣.១. ការព្យាករណ៍ចំណូលចរន្តនៃថវិកា

ការព្យាករណ៍ចំណូលចរន្តអាស្រ័យលើប្រភពនៃចំណូលពន្ធ និង ចំណូលមិនមែនសារពើពន្ធ ÷

**ទីមួយ**- អគ្គនាយកដ្ឋានគយ និង រដ្ឋាករ អគ្គនាយកដ្ឋានពន្ធដារ នាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ នាយកដ្ឋានចំណូលមិនមែនសារពើពន្ធនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមានតួនាទីធ្វើការព្យាករណ៍ចំណូលដែលត្រូវប្រមូលដូចជា ÷ ពន្ធ អាករ ពន្ធគយ អាករពិសេស ពន្ធផ្សេងៗទៀត ចំណូលមិនមែនសារពើពន្ធ ។ល។ មន្ទីរហិរញ្ញវត្ថុខេត្ត - ក្រុងត្រូវព្យាករណ៍ចំណូលដែលត្រូវប្រមូលនៅថ្នាក់ខេត្ត និង ផ្តល់ជូនដល់នាយកដ្ឋានថវិកា ដើម្បីធ្វើសំយោគ និង ធ្វើការព្យាករណ៍ ។

**ទីពីរ**- ទន្ទឹមនឹងនេះ ក្រសួងដែលត្រូវប្រមូលចំណូលពុំមែនសារពើពន្ធ នៅតាមវិស័យរបស់ខ្លួន ត្រូវបំពេញតារាងចំណូល និងប្រគល់ជូនដល់នាយកដ្ឋានថវិកា ដើម្បីបូកសរុប ទៅតាមបញ្ជីចំណូល ដោយមានការព្យាករណ៍កត់ចូលតាមមាតិកាថវិកាសមស្រប ។ ចំណូលថវិកាទាំងអស់ គឺជាផ្នែកមួយមិនអាចខ្វះបាននៃចំណូលថវិកាទូទៅរបស់រដ្ឋ ។

**ទីបី**- ការវាយតម្លៃកំណត់នូវចំណូលសារពើពន្ធ ដែលមានចំណូលពន្ធប្រមូលដោយអគ្គនាយកដ្ឋានពន្ធដារ និង ចំណូលពន្ធគយ និងពន្ធផ្សេងទៀត ប្រមូលដោយអគ្គនាយកដ្ឋានគយ និង រដ្ឋាករ ដោយឈរលើមូលដ្ឋានដូចតទៅ ÷

- សមិទ្ធផលដែលសម្រេចបាននៅក្នុងឆ្នាំបច្ចុប្បន្ន
- ការគិតគូបញ្ចូលនូវអតិផរណា និងផលប៉ះពាល់របស់វាទៅលើមូលដ្ឋានពន្ធ
- ការព្យាករណ៍ស្ថានភាពម៉ាក្រូសេដ្ឋកិច្ច
- ការធ្វើវិសោធនកម្ម ឬ ផែនការធ្វើវិសោធនកម្មនៃអត្រាពន្ធ និង មូលដ្ឋានយកពន្ធ


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

- ចំណូលសារពើពន្ធបន្ថែម ដែលបានមកពីការអនុវត្តពន្ធថ្មី

ក្នុងគោលដៅនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានដាក់ចេញនូវវិធានការទាមទារអោយគ្រប់អគ្គនាយកដ្ឋាន និង នាយកដ្ឋានទាំងអស់សហការគ្នាយ៉ាងជិតស្និទ្ធ ដើម្បីពង្រឹងវិធីសាស្ត្រព្យាករណ៍ចំណូលអោយបានសុក្រិតជាងមុន តាមរយៈការរៀបចំគោលនយោបាយគៀងគរចំណូល និងបង្កើតឡើងនូវគំរូម៉ាក្រូសេដ្ឋកិច្ច ដែលនឹងក្លាយជាឧបករណ៍ដ៏មានប្រសិទ្ធភាពក្នុងការព្យាករណ៍កំណើនសេដ្ឋកិច្ច និង ចំណូលថវិការដ្ឋ ។ ក្នុងន័យនេះ នាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ នឹងពង្រឹងថែមទៀតនូវសមត្ថភាពស្ថាប័នក្នុងការវិភាគចំណូល- ចំណាយថវិការដ្ឋ ដោយពិនិត្យមើលនូវនិន្នាការនៃការប្រមូលចំណូល តាមប្រភេទពន្ធ អាករ និង ចំណូលមិនមែនសារពើពន្ធនីមួយៗ ដោយផ្តោតជាសំខាន់លើទិសដៅនៃកំណែទម្រង់សារពើពន្ធ និង ការអនុវត្តនូវពន្ធថ្មី ជាពិសេសចំណូលពីធនធានរ៉ែ ប្រេងកាត និង ឧស្ម័ន ។

### ៥.៣.២. ការព្យាករណ៍ចំណូលមូលធននៃថវិកា

ការព្យាករណ៍ចំណូលមូលធននៃថវិការដ្ឋត្រូវបានរៀបចំឡើងតាមប្រភពចំណូល ដូចគ្នានឹងការព្យាករណ៍ចំណូលចរន្តដែរ ÷

- ចំណូលពីឯកជនភាវូបនីយកម្មនៃទ្រព្យសម្បត្តិរដ្ឋត្រូវរៀបចំឡើងតាមក្រសួង ស្ថាប័នដែលគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋផ្ទាល់តែម្តង តាមផែនការឯកជនភាវូបនីយកម្មរបស់រាជរដ្ឋាភិបាល ។ នាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុប្រមូលផ្ទុំតួលេខ និងប៉ាន់ស្មានចំណូលដែលត្រូវប្រមូលបានពីការធ្វើឯកជនភាវូបនីយកម្មនៅតាមក្រសួង- ស្ថាប័ននៅរដ្ឋបាលកណ្តាល និងនៅតាមខេត្ត- ក្រុង ហើយពិភាក្សាជាមួយនាយកដ្ឋានថវិកា ដើម្បីដាក់ចូលក្នុងសេចក្តីព្រាងថវិកា ។
- ការព្យាករណ៍ចំណាយសេវាការប្រាក់ និង ការទូទាត់ប្រាក់ខ្ចី ឬ បុរេប្រទានដែលផ្តល់ជូនសហគ្រាសសាធារណៈតាមតារាងរំលស់បំណុល ដែលរៀបចំឡើងដោយអង្គភាពគ្រប់គ្រងបំណុលសាធារណៈនៃនាយកដ្ឋានវិនិយោគ និង សហប្រតិបត្តិការអន្តរជាតិ ។
- ប្រាក់ខ្ចីពីប្រភពក្នុងស្រុក ក្នុងករណីដែលរាជរដ្ឋាភិបាលសម្រេចចិត្តគៀងគរបំណុលក្នុងស្រុក ដើម្បីធ្វើហិរញ្ញប្បទានឱនភាពថវិកា ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវពិគ្រោះយោបល់ជាមួយនឹងធនាគារជាតិនៃកម្ពុជា ដើម្បីកំណត់នូវបរិមាណ និងប្រភេទបំណុលបែបនេះ ដោយសារតែការធ្វើហិរញ្ញប្បទានក្នុងស្រុកអាចនឹងនាំអោយប៉ះពាល់ដល់ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ជាពិសេស អតិផរណា ។
- ហិរញ្ញប្បទានក្រៅប្រទេសពហុភាគី និងទ្វេភាគី ក្រោមរូបភាពជាកម្ចី និងជំនួយឥតសំណង ដើម្បីដាក់ចូលទៅ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ក្នុងថវិកាជាតិតែម្តង ។ ដោយឡែក កម្ចី និងជំនួយឥតសំណងដែលផ្តល់ដោយធនាគារពិភពលោក និង ធនាគារអភិវឌ្ឍន៍អាស៊ី និងកម្ចីទ្វេរភាគី ត្រូវបានដាក់ចូលទាំងស្រុងនៅក្នុងចំណូលមូលធននៃថវិការដ្ឋ ។ ដោយឡែក ជំនួយឥតសំណងដែលផ្តល់ដោយដៃគូអភិវឌ្ឍន៍ដទៃទៀតនឹងត្រូវយកមកពិនិត្យ ហើយជ្រើសរើស តែផ្នែកណា ដែលពាក់ព័ន្ធនឹងការធ្វើវិនិយោគ និងការផ្តល់ជំនួយបច្ចេកទេសពាក់ព័ន្ធនឹងការធ្វើវិនិយោគ ប៉ុណ្ណោះ ដែលនឹងដាក់ចូលក្នុងថវិការដ្ឋ ។ ជំនួយក្រោមរូបភាពជាការផ្តល់ជំនួយបច្ចេកទេសទូទៅ (ដែល ភាគច្រើនជាប្រាក់បៀវត្សនៃកុងស៊ុលតង់) ការផ្តល់ជំនួយបន្ទាន់ជាគ្រឿងឧបភោគ បរិភោគ ចំណាយចរន្តនៃ អង្គការក្រៅរដ្ឋាភិបាលមិនត្រូវបានយកមកបញ្ចូលក្នុងថវិការដ្ឋឡើយ ។ នៅពេលអនាគត នៅពេលដែល ហិរញ្ញប្បទានអភិវឌ្ឍន៍ទាំងនេះត្រូវបានចាត់ថ្នាក់តាមចំណាត់ថ្នាក់សេដ្ឋកិច្ចនៃថវិការដ្ឋ យើងអាចបញ្ចូល ហិរញ្ញប្បទានអភិវឌ្ឍន៍ទាំងស្រុង ចូលក្នុងថវិការដ្ឋបាន ។ ដើម្បីព្យាករណ៍អោយបានសុក្រិត នូវហិរញ្ញប្បទាន អភិវឌ្ឍន៍ យើងត្រូវដាក់ចូលតែ កម្ចី និងជំនួយឥតសំណងដែលផ្តល់ដោយធនាគារពិភពលោក និង ធនាគារ អភិវឌ្ឍន៍អាស៊ី និងកម្ចីទ្វេរភាគីណាដែលមានចុះកិច្ចព្រមព្រាងរួចហើយ ។ ដោយឡែកចំពោះគម្រោងផ្សេង ទៀត ការព្យារណ៍ត្រូវឈរលើមូលដ្ឋាននៃ **ផែនការវិនិយោគសាធារណ:** (PIP) ដោយបញ្ចូលទាំងស្រុងនូវ គម្រោង ដែលកំពុងអនុវត្ត និងត្រឹមតែមួយចំណែកប៉ុណ្ណោះ (៥០%) នៃគម្រោងការដែលបានសន្យា (Committed projects) ឬ ត្រឹម ២០%នៃគម្រោងការដែលស្ថិតនៅក្នុងការពិចារណា (Projects in the pipelines) ។

- ក្នុងបរិការណ៍នេះ យើងត្រូវពិនិត្យអោយបានលម្អិត នូវចំណាយបដិភាគរបស់រដ្ឋ ជាមួយនឹងគម្រោងដែលផ្តល់ ហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍ពហុភាគី និង ទ្វេរភាគី ។ ចំណាយបដិភាគត្រូវបានព្យាករណ៍ដោយឈរលើ មូលដ្ឋាននៃការចុះកិច្ចព្រមព្រាងរវាងរាជរដ្ឋាភិបាលកម្ពុជា ជាមួយនឹងដៃគូអភិវឌ្ឍន៍នីមួយៗ ដែលជាអាទិភាព នៃចំណាយថវិការដ្ឋ និងឆ្លុះបញ្ចាំងនូវល្បឿននៃការអនុវត្តនូវគម្រោងការទៅតាមផែនការដែលបានដាក់ចេញ ។ នាយកដ្ឋានវិនិយោគ និងសហប្រតិបត្តិការអន្តរជាតិរៀបចំឡើងនូវបញ្ជីគម្រោង ដែលនឹងត្រូវអនុវត្តនៅក្នុងឆ្នាំ ថវិកាដែលត្រូវរៀបចំ ដោយមានឈ្មោះគម្រោង ឈ្មោះអ្នកផ្តល់ហិរញ្ញប្បទាន ទឹកប្រាក់គម្រោង និង ចំណាយ បដិភាគដែលរដ្ឋត្រូវចេញ ដើម្បីអនុវត្តគម្រោង ។

## ៥.៤. ការរៀបចំចំណាយថវិកា

### ៥.៤.១. ការព្យាករណ៍ចំណាយចរន្តនៃថវិកា

នាយកដ្ឋានថវិកាទទួលបន្ទុកបញ្ចូលនូវសូចនាករសំខាន់ៗនៃការព្យាករណ៍ម៉ាក្រូសេដ្ឋកិច្ច ទៅក្នុងក្របខ័ណ្ឌ ថវិកាជាតិ ដោយកំណត់នូវផលិតផលសរុបក្នុងស្រុក (ផសស) តាមថ្លៃចរន្ត និងសន្ទុះកំណើនចំណូល និងចំណាយ



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ថវិកា ដោយគិតជាភាគរយនៃផសស ។ បន្ទាប់មកនាយកដ្ឋានថវិការៀបចំកញ្ចប់ថវិកាសរុប ដោយបែងចែកចំណូល តាមមុខសញ្ញាចំណូលធំៗ និងបែងចែកចំណាយជាកញ្ចប់ថវិការបស់ក្រសួង ស្ថាប័ននីមួយៗ ដោយឈរលើមូលដ្ឋាននៃ **ផែនការយុទ្ធសាស្ត្រថវិកា** (Budge Strategic Plan) ដែលក្រសួង- ស្ថាប័នទាំងអស់ត្រូវរៀបចំ និង ដាក់ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុពិនិត្យ ពីខែមីនា ដល់ខែ ឧសភា ។ ដោយឈរលើមូលដ្ឋាននៃ **ផែនការយុទ្ធសាស្ត្រថវិកា** នេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុចេញសារាចរបែងចែកកញ្ចប់ថវិកាជូនដល់គ្រប់ក្រសួង ស្ថាប័ននៃរាជរដ្ឋាភិបាល ។ ដោយឈរលើមូលដ្ឋាននៃកញ្ចប់ថវិកា ក្រសួង ស្ថាប័នបែងចែកថវិកាតាមរដ្ឋបាលកណ្តាល និង រដ្ឋបាលខេត្ត- ក្រុង ។ ការព្យាករណ៍ចំណាយថវិកាត្រូវបានរៀបចំឡើង តាមចំណាត់ថ្នាក់នៃមាតិកាថវិកា ÷

**ប្រភេទទីមួយ: មធ្យោបាយសេវា**

- **ការទិញ**- សម្ភារៈផ្គត់ផ្គង់ថែទាំ សម្ភារៈផ្គត់ផ្គង់ផ្នែករដ្ឋបាល សំលៀកបំពាក់ និងការតុបតែង សម្ភារៈតូចតាចសង្ហារឹម និងសម្ភារៈបរិក្ខារ ថាមពល និងទឹក
- **សេវាខាងក្រៅ**- ការជួលមធ្យោបាយដឹកជញ្ជូន សោហ៊ុយបណ្តុះបណ្តាលបុគ្គលិកក្នុង និងក្រៅប្រទេស ការថែទាំ និងជួសជុល សោហ៊ុយសិក្សាពិសោធន៍ សោហ៊ុយនៃការប្រើប្រាស់សេវា និងសោហ៊ុយនៃការប្រើប្រាស់សិទ្ធិ សោហ៊ុយដឹកជញ្ជូន
- **សេវាខាងក្រៅផ្សេងៗ**- ទំនាក់ទំនងសាធារណៈនិងផ្សព្វផ្សាយ ចំណាយទូទាត់សាហ៊ុយក្នុងប្រទេស ចំណាយទូទាត់សាហ៊ុយក្រៅប្រទេស សោហ៊ុយប្រៃសណីយ៍ និងទូរគមនាគមន៍
- **បន្ទុកបុគ្គលិក**- លាភការ និងប្រាក់បំណាច់ រង្វាន់ ប្រាក់វិភាជន៍សង្គម
- **អន្តរាគមន៍សាធារណៈ**: - ឧបត្ថម្ភកធន និងជំនួយសង្គម
- **ចំណាយផ្សេងៗ**- ពន្ធ និងអាករ

ជារួម សំណើចំណាយពីក្រសួង ស្ថាប័នត្រូវតែវិភាគយ៉ាងល្អិតល្អន់ ទៅតាមការចាំបាច់ និងតម្រូវការជាក់ស្តែងរបស់ក្រសួងនីមួយៗ និងដើម្បីអោយសមស្របតាមការប៉ាន់ស្មាន ។ ចំណាយទាំងនេះត្រូវមានឯកសារគាំទ្រតាមជំពូក គណនី និង អនុគណនី និងត្រូវពិភាក្សាដោយមន្ត្រីជំនាញ ឬ ត្រូវបញ្ជូនអោយក្រសួងសាមីពិនិត្យឡើងវិញប្រសិនបើមានការចាំបាច់ ។



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

### ៥.៤.២. ការព្យាករណ៍បន្ទុកបុគ្គលិកនៃថវិកាចរន្ត

#### ក- មន្ត្រីរាជការដែលមានស្រាប់

**បន្ទុកបុគ្គលិក** គឺជាផ្នែកមួយយ៉ាងសំខាន់នៃថវិកាចរន្ត ដែលមានចំណែកជាមធ្យម ស្មើនឹង ៣% នៃផលិតផលសរុបក្នុងស្រុក ឬ ៤០%នៃថវិកាចរន្ត ។ ការព្យាករណ៍បន្ទុកបុគ្គលិកធ្វើឡើងដោយឈរលើមូលដ្ឋាននៃចំណាយមធ្យមសម្រាប់បុគ្គលិកម្នាក់ៗ (បៀវត្សមូលដ្ឋាន លាភការ ប្រាក់បំណាច់ រង្វាន់ និងប្រាក់វិភាជន៍សង្គម) ហើយត្រូវគុណនឹងចំនួនបុគ្គលិកដែលមាននៅក្នុងក្រសួង- ស្ថាប័ននីមួយៗ ។ ចំនួនបុគ្គលិកត្រូវឈរលើចំនួនជាក់ស្តែង ដោយបូកបន្ថែមនូវផែនការជ្រើសរើសបុគ្គលិកសម្រាប់ឆ្នាំថ្មី ដោយរួមទាំងបុគ្គលិកក្របខ័ណ្ឌអចិន្ត្រៃយ៍ បុគ្គលិកជាប់ជាប់កិច្ចសន្យា និងបុគ្គលិកអណ្តែត ។ ឧទាហរណ៍ នៅក្នុងឆ្នាំ ២០០៨ ប្រាក់បៀវត្សរ៍មធ្យមរបស់មន្ត្រីរាជការស្មើនឹង ២៤៦.០០០ រៀល (៦០ ដុល្លារអាមេរិក) ។ ដូច្នេះ ការប៉ាន់ស្មានបន្ទុកបុគ្គលិក ត្រូវតែមានការពិភាក្សាយ៉ាងជិតស្និទ្ធជាមួយក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល និង ដោយឈរលើមូលដ្ឋាននៃបញ្ជីឈ្មោះមន្ត្រីរាជការគ្រប់គ្រងតាមប្រព័ន្ធព័ត៌មានវិទ្យា ។ ឥណទានបន្ទុកបុគ្គលិក ជាប្រភេទឥណទានដែលអាចប៉ាន់ប្រមាណបានពោលគឺ ប្រសិនបើឥណទានប្រភេទនេះមិនគ្រប់ចំនួនតាមច្បាប់ហិរញ្ញវត្ថុ ដែលបានអនុម័តទេ នោះរដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុអាចចេញប្រកាសបន្ថែមឥណទាននៅក្នុងឆ្នាំតែម្តង ។

#### ខ- ការជ្រើសរើសមន្ត្រីរាជការថ្មី

ដើម្បីជៀសវាងការប៉ោង ចំនួនមន្ត្រីរាជការលើសពីតម្រូវការនៃមុខងារសាធារណៈ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវគោលនយោបាយយ៉ាងតឹងរឹង ក្នុងការគ្រប់គ្រងការជ្រើសរើសមន្ត្រីរាជការតាមក្រសួង- ស្ថាប័នរបស់រាជរដ្ឋាភិបាល ។

ជាធម្មតា សាលាភូមិន្ទរដ្ឋបាលមានភារកិច្ចបណ្តុះបណ្តាលមន្ត្រីរាជការ ។ និស្សិតដែលប្រឡងជាប់សាលាភូមិន្ទរដ្ឋបាលទទួលបាននូវក្របខ័ណ្ឌជាមន្ត្រីរាជការ ជាស្វ័យប្រវត្តិតែម្តង ។ បន្ទាប់ពីរៀនចប់ មន្ត្រីទាំងនោះនឹងត្រូវបានផ្ទេរក្របខ័ណ្ឌមកក្រសួង ដែលខ្លួនបម្រើការងារតែម្តង ។

ម៉្យាងវិញទៀត ក្រសួង- ស្ថាប័នអាចស្នើសុំជ្រើសរើសមន្ត្រីរាជការបន្ថែម តាមរយៈការប្រឡងប្រជែងដោយត្រូវមានការយល់ព្រមពីសំណាក់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និងក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ជាមុនសិន ។ ដើម្បីសម្រួលដល់ការធ្វើផែនការនីយកម្ម ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាលធ្វើផែនការជ្រើសរើសមន្ត្រីប្រចាំឆ្នាំ ដោយបែងចែកតាមក្រសួង- ស្ថាប័នជាមុន ដើម្បីឆ្លើយតបតាមតម្រូវការជាក់ស្តែងរបស់ក្រសួងនីមួយៗ ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

### ៥.៤.៣. ការព្យាករណ៍ជញ្ជីងទូទាត់

ការព្យាករណ៍ជញ្ជីងទូទាត់ត្រូវរៀបចំឡើងដោយឈរលើមូលដ្ឋាននៃសូចនាករសំខាន់ៗ ការនាំចេញនូវមុខទំនិញសំខាន់ៗសម្រាប់កម្ពុជា ដូចជាសម្លៀកបំពាក់ ស្រូវ កៅស៊ូ ពោត សណ្តែក ការនាំចូលនូវមុខទំនិញសំខាន់ៗ ដូចជាផលិតផលតេលសិលា ក្រណាត់សម្រាប់ឧស្សាហកម្មកាត់ដេរ សេវាសំខាន់ៗ ដូចជាទេសចរណ៍ ការផ្ទេរឯកជន និងការផ្ទេរចរន្ត ដែលជាមូលដ្ឋានដ៏សំខាន់សម្រាប់គណនាជញ្ជីងទូទាត់ចរន្ត ។

ការព្យាករណ៍ជញ្ជីងទូទាត់ត្រូវផ្តោតផងដែរទៅលើចលនាមូលធន ជាពិសេសកម្ចីពីក្រៅប្រទេស ការទូទាត់សងបំណុល និង វិនិយោគផ្ទាល់ពីក្រៅប្រទេស ។

ការព្យាករណ៍ជញ្ជីងទូទាត់ទូទៅ ដោយឈរលើមូលដ្ឋាននៃការព្យាករណ៍ជញ្ជីងទូទាត់ចរន្ត គណនីមូលធន និងគណនីហិរញ្ញវត្ថុ អាចអោយយើងអាចព្យាករណ៍បាននូវនិន្នាការនៃទុនបម្រុងអន្តរជាតិ ដើម្បីអោយមានសង្គតិភាពជាមួយនឹងការព្យាករណ៍រូបិយវត្ថុទូទៅ ។

### ៥.៤.៤. ការព្យាករណ៍រូបិយវត្ថុ

ការព្យាករណ៍រូបិយវត្ថុអនុញ្ញាតអោយយើងកំណត់នូវទ្រព្យសកម្មក្រៅប្រទេស ឥណទានក្រៅប្រទេស រូបិយវត្ថុទូទៅ និង ព្យាករណ៍នូវធនធានចាំបាច់សម្រាប់ធ្វើហិរញ្ញប្បទានឱនភាពជញ្ជីងទូទាត់ចរន្ត ។ ការព្យាករណ៍នេះ គឺជាចំណុចចុងក្រោយនៃកម្មវិធីនីយកម្មរូបិយវត្ថុ ។

ដំណាក់កាលសំខាន់ៗនៃការព្យាករណ៍រូបិយវត្ថុ មានដូចតទៅ៖

ទីមួយ- ការព្យាករណ៍បរិមាណរូបិយវត្ថុ ដោយឈរលើមូលដ្ឋាននៃផលិតផលសរុបតាមថ្លៃបច្ចុប្បន្ន និង សម្មតិកម្មស្តីពីស្ថិរភាពនៃល្បឿនចរាចររូបិយវត្ថុ ។ សូចនាករនេះអាចបំបែកទៅជា រូបិយវត្ថុក្រៅប្រព័ន្ធធនាគារ ប្រាក់បញ្ញើមានកាលកំណត់ និង ប្រាក់បញ្ញើគ្មានកាលកំណត់ ។

ទីពីរ- ការកំណត់ទ្រព្យសកម្មក្នុងស្រុកសុទ្ធ ដែលជាផលដកនៃបរិមាណរូបិយវត្ថុទូទៅ និង ទ្រព្យសកម្មក្រៅប្រទេសសុទ្ធ ។

ទីបី- ការព្យាករណ៍ផ្សេងៗ ដោយសារតែគ្មានព័ត៌មាន ។

ទីបួន- ការគណនាឥណទានក្នុងស្រុក ដែលជាផលដកនៃទ្រព្យសកម្មក្នុងស្រុកសុទ្ធ និង ផ្សេងៗ ។

ទីប្រាំ- ការកំណត់ឥណទានផ្តល់ជូនដល់ផ្នែកឯកជន ដែលជាផលដកនៃឥណទានរដ្ឋាភិបាល និងឥណទាន

ផ្ដេក្នុង ។

## ៦. កម្មវិធីវិនិយោគសាធារណៈ

**កម្មវិធីវិនិយោគសាធារណៈ** ជាឯកសារគោលនយោបាយរំកិលសម្រាប់រយៈពេលពីឆ្នាំ ដែលផ្ដោតតែលើគម្រោងការនៃចំណាយមូលធន ដែលធ្វើហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍បែងចែកតាមវិស័យ ។ ដូច្នេះ យើងឃើញថាឯកសារគោលនយោបាយសំខាន់ៗមានដូចតទៅ÷

ទីមួយ- **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ** ដែលជាឯកសារសម្រាប់រយៈពេលប្រាំឆ្នាំ ។

ទីពីរ- **កម្មវិធីវិនិយោគសាធារណៈ** ដែលជាឯកសាររំកិលរយៈពេលបីឆ្នាំ ។

ទីបី- **ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច** ។

ទីបួន- **ផែនការយុទ្ធសាស្ត្រថវិកា** ដែលជាឯកសាររយៈពេលមួយឆ្នាំ ។

ទីប្រាំ- **ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម** ដែលជាឯកសារសម្រាប់រយៈពេលបីឆ្នាំ ។

ទីប្រាំមួយ- **ថវិកាជាតិ** ដែលជាឯកសារសម្រាប់រយៈពេលមួយឆ្នាំ ហើយដែលជាផលិតផលចុងក្រោយនៃឯកសារខាងលើទាំងអស់ ។

នៅក្នុងឆ្នាំ ១៩៩៥ រាជរដ្ឋាភិបាលកម្ពុជាបានរៀបចំនូវ **កម្មវិធីវិនិយោគសាធារណៈ** លើកទីមួយសម្រាប់រយៈពេល ១៩៩៦-១៩៩៨ ក្រោមជំនួយបច្ចេកទេសរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ហើយដែលត្រូវបានរដ្ឋសភាអនុម័ត ក្នុងគោលដៅសម្រួលដល់ការរៀបចំចំណាយវិនិយោគនៃថវិការដ្ឋ ។ ក៏ប៉ុន្តែ **កម្មវិធីវិនិយោគសាធារណៈ** បានត្រឹមតែជាកម្រងនៃគម្រោងវិនិយោគដែលគ្រប់ក្រសួង- ស្ថាប័នចង់អនុវត្តប៉ុណ្ណោះ (Shopping list) ដោយសារតែទំហំទឹកប្រាក់ដែលស្នើសុំធ្វើហិរញ្ញប្បទានមានទំហំច្រើនពេក លើសពីលទ្ធភាពជាក់ស្ដែងនៃហិរញ្ញប្បទានពហុភាគី និង ទ្វេភាគី ដែលធ្វើអោយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុមិនអាចបញ្ចូលគម្រោងទាំងនោះចូលក្នុងថវិកាជាតិបាន ។

ក្រសួងសេដ្ឋកិច្ចនិង ហិរញ្ញវត្ថុបញ្ចូលក្នុងថវិកាជាតិ តែគម្រោងណាដែល ដៃគូអភិវឌ្ឍន៍សន្យាផ្ដល់ហិរញ្ញប្បទាននៅក្នុងឆ្នាំថវិកាតែប៉ុណ្ណោះ តាមរយៈការចុះហត្ថលេខាលើកិច្ចព្រមព្រាង ឬ អនុស្សារណៈជាមួយរាជរដ្ឋាភិបាល ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ដូច្នេះហើយ ក្រសួងសេដ្ឋកិច្ចនិង ហិរញ្ញវត្ថុមានការប្រយ័ត្នប្រយែងយ៉ាងខ្លាំង ក្នុងការដាក់បញ្ចូលទិន្នន័យនៃ **កម្មវិធីវិនិយោគសាធារណៈ** ចូលទៅក្នុងចំណាយវិនិយោគនៃច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ដើម្បីកុំអោយគម្រោងទាំងនេះ ក្លាយទៅជាចំណាយខ្យល់ ដែលបំប៉ោងថវិកាវិនិយោគតែប៉ុណ្ណោះ ។ ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈបែងចែកឥណទានថវិកាមូលធនជាបីប្រភេទ គឺ ÷ ឥណទាននៃកម្មវិធី ឥណទានភ្ជាប់សន្យា និង ឥណទានទូទាត់ ។

**ឥណទាននៃកម្មវិធី** គឺជាឥណទានថវិកាដែលឆ្លុះបញ្ចាំងនូវតម្លៃសរុបនៃគម្រោងវិនិយោគតែម្តង ។ ឥណទាននៃកម្មវិធី គឺជាឥណទានថវិកា បែងចែកតាមគម្រោងចំណាយមូលធននៃថវិកាទូទៅរបស់រដ្ឋ ដែលអនុម័តដោយរដ្ឋសភា (តារាង គ១) ។ ឥណទាននេះឆ្លុះបញ្ចាំងនូវតម្លៃសរុបនៃគម្រោង ចំណាយមុនឆ្នាំថវិកា កម្រិតទុនវិនិយោគចែកតាមឆ្នាំនីមួយៗ និងទុនសល់សម្រាប់ពេលក្រោយ ។

**ឥណទានភ្ជាប់សន្យា** គឺជាឥណទានវិនិយោគ ដែលអនុញ្ញាតអោយរាជរដ្ឋាភិបាលធ្វើការសន្យា និង អនុម័តនៅក្នុងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ហើយដាក់នៅក្រោមអាណាប័ក សម្រាប់ចំណាយចាំបាច់ក្នុងការអនុវត្តកិច្ចវិនិយោគ (មាត្រា ២៨ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ)។ ឥណទានភ្ជាប់សន្យាអាចមានតម្លៃគ្មានកំណត់ពេល ។ ឥណទាននេះត្រូវបានយោងពីមួយឆ្នាំទៅមួយឆ្នាំ រហូតដល់ការលុបបំបាត់ជាយថាហេតុ ។

**ឥណទានទូទាត់** គឺជាឥណទានដែលត្រូវបានប្រើប្រាស់សម្រាប់ចេញបញ្ជាចំណាយ ដែលជាបន្ទុករបស់រដ្ឋ នៅក្នុងកម្រិតនៃឥណទានភ្ជាប់សន្យា ។ ឥណទានទូទាត់ដែលមិនបានប្រើនៅពេលបិទការគ្រប់គ្រង (បញ្ចប់ឆ្នាំ) ត្រូវបានលុបចោល និង អាចអនុញ្ញាតឥណទានថ្មីសម្រាប់ឆ្នាំបន្ទាប់ ។ ដូច្នេះ ឥណទានទូទាត់មានតួនាទីធានាបាននូវការគោរពតាមគោលការណ៍ការិយបរិច្ឆេទមានកាលកំណត់មួយឆ្នាំ ។

ឥណទានថវិកាទាំងបីប្រភេទនេះមានទំនាក់ទំនងនឹងគ្នាដូចតទៅ ÷

**{ឥណទាននៃកម្មវិធី > ឥណទានភ្ជាប់សន្យា > ឥណទានទូទាត់}** ក្នុងដំណាក់កាលអនុវត្តគម្រោង ឬ កម្មវិធី ។ ក៏ប៉ុន្តែ នៅពេលដែលការអនុវត្តគម្រោងចប់សព្វគ្រប់ ទំនាក់ទំនងនេះនឹងក្លាយទៅជា ÷

**{ឥណទាននៃកម្មវិធី = ឥណទានភ្ជាប់សន្យា = ឥណទានទូទាត់}**

យើងអាចនិយាយបានថា ÷

ទីមួយ-**ឥណទាននៃកម្មវិធី** គឺជាថ្លៃគម្រោងសរុប ដែលរដ្ឋទទួលបាននូវការអនុញ្ញាតអោយលើកគម្រោងនេះឡើង ដោយមិនពាក់ព័ន្ធអ្វីទាំងអស់ជាមួយនឹងទិដ្ឋភាពច្បាប់នៃការធានាចំណាយថវិកា ជាមួយនឹងអ្នកម៉ៅការសំណង់ឡើយ ។ ឥណទាននេះអាចនឹងត្រូវបានបង្កើន ដើម្បីពិនិត្យឡើងវិញនូវថ្លៃ ឬ នៅពេលដែលទំហំ


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

នៃគម្រោងអាចកើនឡើង ដោយគ្មានការគ្រោងទុកជាមុន ។

ទីពីរ- **ឥណទានភ្ជាប់សន្យា** ត្រូវស្មើនឹងបរិមាណ ដែលអាណាប័កទទួលបន្ទុកអនុវត្តគម្រោងនេះ បានទទួលការអនុញ្ញាតអោយធានាចំណាយ នៅក្នុងរយៈពេលនៃឆ្នាំថវិកា ។ **ឥណទានភ្ជាប់សន្យា** ត្រូវតែដកចេញជារៀងរាល់ឆ្នាំពី **ឥណទាននៃកម្មវិធី** ។ **ឥណទានភ្ជាប់សន្យា** នេះអាចនឹងត្រូវបានប្រើប្រាស់លើសរយៈពេលនៃថវិកាប្រចាំឆ្នាំទៅទៀត ក្នុងក្របខ័ណ្ឌនៃការធ្វើលទ្ធកម្មសាធារណៈ ដែលរយៈពេលអនុវត្តគម្រោងអាចមានចំនួនច្រើនឆ្នាំ ។

ទីបី- **ឥណទានទូទាត់**ត្រូវស្មើនឹងទំហំទឹកប្រាក់ ដែលរតនាគារត្រូវបើកផ្តល់ ដើម្បីអនុវត្តថវិកាប្រចាំឆ្នាំ។ ដូច្នេះ **ឥណទានទូទាត់** មិនអាចផ្ទេរពីមួយឆ្នាំ ទៅមួយឆ្នាំទៀតឡើយ ។

ជាធម្មតា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដាក់ចូលក្នុងថវិកាប្រចាំឆ្នាំ តែគម្រោងណានៃ **កម្មវិធីវិនិយោគសាធារណៈ** ដែលមានហិរញ្ញប្បទាន ហើយដែលច្បាស់ថា នឹងត្រូវអនុវត្តនៅក្នុងឆ្នាំនោះ ពោលគឺ ÷

ទី១- គម្រោងដែលកំពុងអនុវត្ត ដែលការអនុវត្តគម្រោងនេះនឹងត្រូវបន្តនៅក្នុងឆ្នាំនៃថវិកា ឬ ត្រូវបន្តយូរថែមទៀត ។

ទី២- គម្រោងដោយហិរញ្ញប្បទានក្នុងស្រុក ដែលកំពុងអនុវត្ត និង គម្រោងថ្មីដោយហិរញ្ញប្បទានក្នុងស្រុក ដែលមិនទាមទារអោយរដ្ឋផ្តល់ហិរញ្ញប្បទានច្រើនពេកឡើយ ហើយដែលមិនត្រូវបានលើកយកមកស្នើសុំអោយធ្វើហិរញ្ញប្បទានក្រៅប្រទេស ។

ទី៣- គម្រោងដោយហិរញ្ញប្បទានក្រៅប្រទេស ដែលដៃគូអភិវឌ្ឍន៍បានផ្តល់កិច្ចសន្យាយ៉ាងច្បាស់លាស់ និងបានចុះហត្ថលេខាជាមួយរាជរដ្ឋាភិបាល នូវកិច្ចព្រមព្រាងស្តីពីការអនុវត្តនូវគម្រោងទាំងនោះ ។ ការធ្វើហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍អាចអនុវត្តបាន តាមរយៈការផ្តល់ថវិកាដោយផ្ទាល់ (ដោយផ្ទេរថវិកាចូលទៅក្នុងគណនីរតនាគារជាតិ នៅធនាគារជាតិនៃកម្ពុជា) ឬ ដោយការទូទាត់ផ្ទាល់រវាងដៃគូអភិវឌ្ឍន៍ និង ក្រុមហ៊ុនអនុវត្តគម្រោង ដោយគ្រាន់តែផ្តល់ព័ត៌មានស្តីពីការបើកផ្តល់ថវិកាដើម្បីអនុវត្តគម្រោង ឬ នៅពេលដែលគម្រោងនេះត្រូវបានអនុវត្តរួចហើយទាំងស្រុង ។

ការធ្វើហិរញ្ញប្បទានក្រៅប្រទេសអាចទាមទារអោយថវិកាជាតិ ផ្តល់នូវបដិការ ដែលអាចមានរូបភាពជាការលើកលែងពន្ធគយ និងអាករ នៅពេលដែលទំនិញ ឬ ផលិតផលនេះត្រូវបាននាំចូល ។ ប្រការនេះត្រូវតែផ្ទៀងផ្ទាត់ជាមួយចំណូល- ចំណាយ តាមក្បួនគណនេយ្យទ្វេរភាគ ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

**ថវិកា ឆ្នាំ ២០០៧**

| | |
|---|---|
| ឥណទាននៃកម្មវិធីសរុប៖ | ៧.៤៥៥.១៦៩ លានរៀល |
| ឥណទានភ្ជាប់សន្យា៖ | ២.៦០៧.០៣៣ លានរៀល |
| ឥណទានទូទាត់៖ | ១.៧៨៥.១៣៣ លានរៀល |

**ឥណទានភ្ជាប់សន្យា** ត្រូវបានបែងចែកដូចតទៅ៖

| | |
|---|---|
| ឥណទានភ្ជាប់សន្យាដោយហិរញ្ញប្បទានក្នុងប្រទេស៖ | ៥៧៥.១៣៣ លានរៀល |
| ឥណទានភ្ជាប់សន្យាដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់៖ | ១.៩៣១.៩០០ លានរៀល |
| ឥណទានភ្ជាប់សន្យាសម្រាប់បំណុលសាធារណៈ៖ | ១០០.០០០ លានរៀល |
| | ២.៦០៧.០៣៣ លានរៀល |

**ឥណទានទូទាត់** ត្រូវបានបែងចែកដូចតទៅ៖

| | |
|---|---|
| ឥណទានទូទាត់ដោយហិរញ្ញប្បទានក្នុងប្រទេស៖ | ៥៧៥.១៣៣ លានរៀល |
| ឥណទានទូទាត់ដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់៖ | ១.១១០.០០០ លានរៀល |
| ឥណទានទូទាត់សម្រាប់បំណុលសាធារណៈ៖ | ១០០.០០០ លានរៀល |
| | ១.៧៨៥.១៣៣ លានរៀល |


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

# ជំពូក ៥

# ការរៀបចំថវិកា

## ១-ប្រតិទិន

ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុហិរញ្ញវត្ថុសាធារណៈ ដែលត្រូវបានអនុម័តកាលពីថ្ងៃទី ៤ ខែ មេសា ឆ្នាំ ២០០៨ និង ដែលត្រូវបានប្រកាសអោយប្រើប្រាស់ដោយព្រះរាជក្រមលេខ ន.ស./រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ត្រង់មាត្រា ៣៩ បានកំណត់នូវក្របខ័ណ្ឌនៃការរៀបចំថវិកា និងប្រតិទិនថវិកា ។ តាមមាត្រា ៣៩ នៃច្បាប់នេះ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំតាមប្រតិទិន ខាងក្រោមនេះ÷

***ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា «ពីខែមិនា ដល់ខែឧសភា»*** : នៅសប្តាហ៍ទី១នៃខែមីនា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រៀបចំក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម ដែលមានសង្គតិភាពទៅនឹងក្របខ័ណ្ឌគោលនយោបាយជាតិសម្រាប់ការអភិវឌ្ឍ ដើម្បីដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ និងសម្រេច ។ នៅសប្តាហ៍ទីមួយនៃខែមេសា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវចេញសារាចរណែនាំស្តីពីការរៀបចំ **ផែនការយុទ្ធសាស្ត្រថវិកា** ដោយផ្អែកលើក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និង គោលនយោបាយហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម ដែលបានកំណត់ដោយរាជរដ្ឋាភិបាល។

រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័ន ប្រធានអង្គភាពសាធារណៈប្រហាក់ប្រហែល និងអភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវរៀបចំ **ផែនការយុទ្ធសាស្ត្រថវិកា** ចក្ខុវិស័យ គោលបំណង គោលដៅនៃកម្មវិធី និងផែនការសកម្មភាពជាអទិភាពរបស់ក្រសួង- ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល និង រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលបម្រើអោយនយោបាយជាអាទិភាពរបសវិស័យ និងគោលនយោបាយជាតិសម្រាប់ការអភិវឌ្ឍ។ ផែនការយុទ្ធសាស្ត្រថវិកាទាំងនេះត្រូវផ្ញើមករដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ យ៉ាងយឺតបំផុតត្រឹមថ្ងៃទី ១៥ ខែ ឧសភា ។

***ការរៀបចំកញ្ចប់ថវិកា (ពីខែមិថុនា ដល់ ខែកញ្ញា):*** នៅសប្តាហ៍ទី១នៃខែមិថុនារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុរៀបចំសេចក្តីព្រាងសារាចរណែនាំស្តីពីបច្ចេកទេសនៃការរៀបចំថវិកា ដោយបញ្ជាក់ជូននូវទម្រង់ និងនីតិវិធីនៃការរៀបចំគម្រោងថវិកា ព្រមទាំងធ្វើកំណត់បង្ហាញនិងឯកសារពាក់ព័ន្ធ ដែលត្រូវភ្ជាប់មក



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ជាមួយ ដើម្បីដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ និងសម្រេច ហើយផ្ញើជូនក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីរៀបចំគម្រោងចំណូល ចំណាយថវិកាលម្អិតរបស់ខ្លួន ។ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័ន ប្រធានអង្គភាពសាធារណៈប្រហាក់ប្រហែល និងអភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវរៀបចំនូវគម្រោងចំណូល ចំណាយថវិកាលម្អិតរបស់ខ្លួន សម្រាប់រដ្ឋបាលថ្នាក់ជាតិ និង រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយផ្អែកលើមូលដ្ឋានសារាចរណែនាំស្តីពីបច្ចេកទេសនៃការរៀបចំគម្រោងថវិកា និង អាទិភាពនៃគោលនយោបាយរបស់ខ្លួន ។ គម្រោងថវិកាទាំងនេះ ត្រូវផ្ញើមករដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុយ៉ាងយឺតបំផុតត្រឹមថ្ងៃទី ១៥ ខែកក្កដា ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ធ្វើការប្រមូលផ្តុំបូកសរុបនូវគម្រោងចំណូលចំណាយថវិការបស់ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល ខេត្ត និង រាជធានីដែលបានស្នើឡើង ។

នៅក្នុងអំឡុងខែសីហាទាំងមូល ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុអញ្ជើញរដ្ឋមន្ត្រី ប្រធានគ្រប់ស្ថាប័ន និងប្រធានអង្គភាពប្រហាក់ប្រហែល ព្រមទាំងអភិបាលខេត្តគ្រប់ និង រាជធានី មកពិភាក្សាការពារគម្រោងថវិការបស់ខ្លួន ដើម្បីសម្របសម្រួលនូវគម្រោងចំណូល ចំណាយថវិកាទាំងនោះអោយបានសមស្របទៅតាមបទប្បញ្ញត្តិនៃការណែនាំដោយមានការកាត់បន្ថយចំណាយដែលមិនចាំបាច់ និងបង្កើនចំណូលអោយបានសមស្រប ។ នៅក្នុងអំឡុងខែកញ្ញាទាំងមូល ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុធ្វើការបូកសរុបចំណូល ចំណាយរដ្ឋទាំងមូល ដើម្បីតុល្យភាពថវិកាឡើងវិញ រួចរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុ និងធ្វើកំណត់បង្ហាញនៃសេចក្តីព្រាងច្បាប់នេះ ។

***ការអនុម័តថវិកា (ពីខែតុលា ដល់ ខែធ្នូ):*** នៅសប្តាហ៍ទីមួយនៃខែតុលា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបញ្ជូនសេចក្តីព្រាងច្បាប់នេះ ដើម្បីដាក់ជូនគណៈរដ្ឋមន្ត្រីពិនិត្យសម្រេច រួចដាក់ជូនរដ្ឋសភានៅសប្តាហ៍ទីមួយនៃខែវិច្ឆិកា ដើម្បីពិនិត្យអនុម័ត និងដាក់ជូនព្រឹទ្ធសភា នៅសប្តាហ៍ទីមួយនៃ ខែធ្នូ ដើម្បីអោយសេចក្តីព្រាងច្បាប់នេះ ត្រូវបានអនុម័តជាស្ថាពរមុនថ្ងៃទី ២៥ ខែធ្នូ ។

## ២-ចំណាត់ថ្នាក់មុខងារនៃរដ្ឋបាលសាធារណៈ

រចនាសម្ព័ន្ធនៃរដ្ឋាភិបាលប្រែប្រួលទៅតាមពេលវេលា និងស្ថានភាពនៃប្រទេសនីមួយៗ ។ ករណីនេះធ្វើអោយមានការលំបាក ក្នុងការប្រៀបធៀបប្រទេសតែមួយ ពីពេលមួយទៅពេលមួយទៀត និង ក្នុងការប្រៀបធៀបពីប្រទេសមួយទៅប្រទេសមួយទៀត ។ ដើម្បីដោះស្រាយបញ្ហាលំបាកទាំងនេះ **មូលនិធិរូបិយវត្ថុអន្តរជាតិ** បានបង្កើតចំណាត់ថ្នាក់មុខងារនៃរដ្ឋបាលសាធារណៈ ដែលជាភាសាអង់គ្លេសហៅថា (Classification of Functions of Government—COFOG) ។ ចំណាត់ថ្នាក់នេះត្រូវបានយកមកសម្រិតសម្រាំងអោយលម្អិតដោយអង្គការសហប្រជាជាតិ ។ ចំណាត់ថ្នាក់មុខងារនៃរដ្ឋបាលសាធារណៈគឺ ការរៀបចំមុខងាររដ្ឋបាលសាធារណៈអោយមានលក្ខណៈសកល និង ជាអចិន្ត្រៃយ៍ ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ចំណាត់ថ្នាក់មុខងារនៃមុខងារសាធារណៈ

*(ដកចេញពី GFMS 2001 ឧបសម្ព័ន្ធទី ៤)*

**០១- រដ្ឋបាលទូទៅនៃមុខងារសាធារណៈ**

*០១១- ស្ថាប័ននីតិប្រតិបត្តិ ស្ថាប័ននីតិបញ្ញត្តិ រដ្ឋបាលហិរញ្ញវត្ថុ និង សារពើពន្ធ និង ការបរទេស*

០១១១- ស្ថាប័ននីតិប្រតិបត្តិ ស្ថាប័ននីតិបញ្ញត្តិ

០១១២- រដ្ឋបាលហិរញ្ញវត្ថុ និង សារពើពន្ធ

០១១៣- ការបរទេស

*០១២- ជំនួយសេដ្ឋកិច្ចក្រៅប្រទេស*

០១២១- ជំនួយសេដ្ឋកិច្ចអោយប្រទេសកំពុងអភិវឌ្ឍ ឬ ប្រទេសអន្តរកាល

០១២២- ជំនួយសេដ្ឋកិច្ចតាមរយៈអង្គការអន្តរជាតិ

*០១៣- រដ្ឋបាលទូទៅ*

០១៣១- រដ្ឋបាលទូទៅខាងផ្នែកបុគ្គលិក

០១៣២- រដ្ឋបាលទូទៅខាងផ្នែកផែនការនីយកម្ម និងស្ថិតិ

០១៣៣- រដ្ឋបាលទូទៅឯទៀត

*០១៤- ការស្រាវជ្រាវជាមូលដ្ឋាន*

*០១៥- ការស្រាវជ្រាវខាងផ្នែករដ្ឋបាលទូទៅនៃមុខងារសាធារណៈ*

*០១៦- រដ្ឋបាលទូទៅ ផ្សេងៗ*

*០១៧- ប្រតិបត្តិការបំណុលសាធារណៈ*

*០១៨- ការផ្ទេរទូទៅរវាងរដ្ឋបាលសាធារណៈ*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

**០២- ការពារជាតិ**

*០២១-  វិស័យការពារយោធា*

*០២២-  វិស័យការពារស៊ីវិល*

*០២៣-  ជំនួយយោធាផ្តល់អោយបរទេស*

*០២៤-  ការស្រាវជ្រាវខាងផ្នែកយោធា*

*០២៥-  វិស័យការពារជាតិ ដែលមិនអាចចាត់ថ្នាក់កន្លែងផ្សេង*

**០៣- សណ្តាប់ធ្នាប់ និងសន្តិសុខសាធារណៈ**

*០៣១-  នគរបាល*

*០៣២-  កិច្ចការពារជនស៊ីវិល*

*០៣៣-  តុលាការ*

*០៣៤-  ពន្ធនាគារ*

*០៣៥-  ការស្រាវជ្រាវខាងផ្នែកសណ្តាប់ធ្នាប់ និងសន្តិសុខសាធារណៈ*

*០៣៦-  សណ្តាប់ធ្នាប់ និងសន្តិសុខដែលមិនអាចចាត់ថ្នាក់កន្លែងផ្សេង*

**០៤- រដ្ឋបាលសេដ្ឋកិច្ច**

*០៤១-  វិស័យសេដ្ឋកិច្ចទូទៅ ពាណិជ្ជកម្ម និង ពលកម្ម*

០៤១១-  សេដ្ឋកិច្ចទូទៅ និងពាណិជ្ជកម្ម

០៤១២  រដ្ឋបាលទូទៅខាងផ្នែកពលកម្ម

*០៤២-  កសិកម្ម ព្រៃឈើ ជលផល និង ការបរបាញ់សត្វ*

០៤២១-  កសិកម្ម

០៤២២-  ព្រៃឈើ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

០៤២៣- ជលផល និង ការបរបាញ់សត្វ

*០៤៣- ចំហេះ និង ថាមពល*

០៤៣១- ធ្យូងថ្ម និងរ៉ែឆេះរឹងឯទៀត

០៤៣២- ប្រេង និងឧស្ម័នធម្មជាតិ

០៤៣៣- ចំហេះបរមាណូ

០៤៣៤- ចំហេះឯទៀត

០៤៣៥- អគ្គិសនី

០៤៣៥- ថាមពលមិនមែនអគ្គិសនី

*០៤៤- ឧស្សាហកម្មជីកយករ៉ែ កម្មន្តសាល សំណង់*

០៤៤១- ការជីកយកធនធានរ៉ែ ដែលមិនមែនរ៉ែចំហេះ

០៤៤២- ឧស្សាហកម្មកម្មន្តសាល

០៤៤៣- សំណង់

*០៤៥- ការដឹកជញ្ជូន*

០៤៥១- ការដឹកជញ្ជូនផ្លូវ- ថ្នល់

០៤៥២- ការដឹកជញ្ជូនផ្លូវទឹក

០៤៥៣- ការដឹកជញ្ជូនផ្លូវដែក

០៤៥៤- ការដឹកជញ្ជូនផ្លូវអាកាស

០៤៥៥- បំពង់ប្រេង និង ប្រព័ន្ធដឹកជញ្ជូនឯទៀត

*០៤៦- គមនាគមន៍*

*០៤៧- វិស័យសកម្មភាពឯទៀត*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

០៤៧១-	ការបែងចែក និង ឃ្លាំង

០៤៧២-	សណ្ឋាគារ និង ភោជនីយដ្ឋាន

០៤៧៣-	ទេសចរណ៍

០៤៧៤-	គម្រោងអភិវឌ្ឍន៍ពហុវិស័យ

*០៤៨- ស្រាវជ្រាវ និង អភិវឌ្ឍន៍ក្នុងវិស័យសេដ្ឋកិច្ច*

០៤៨១-	ស្រាវជ្រាវ និងអភិវឌ្ឍន៍ក្នុងវិស័យសេដ្ឋកិច្ចទូទៅ ពាណិជ្ជកម្ម និង ពលកម្ម

០៤៨២-	ស្រាវជ្រាវ និងអភិវឌ្ឍន៍ក្នុងវិស័យកសិកម្ម ព្រៃឈើ ជលផល និងការបរបាញ់សត្វ

០៤៨៣-	ស្រាវជ្រាវ និងអភិវឌ្ឍន៍ក្នុងវិស័យចំហេះ និងថាមពល

០៤៨៤-	ស្រាវជ្រាវ និងអភិវឌ្ឍន៍ក្នុងវិស័យឧស្សាហកម្មជីកយករ៉ែ កម្មន្តសាល និងសំណង់

០៤៨៥-	ស្រាវជ្រាវ និងអភិវឌ្ឍន៍ក្នុងវិស័យដឹកជញ្ជូន

០៤៨៦-	ស្រាវជ្រាវ និងអភិវឌ្ឍន៍ក្នុងវិស័យគមនាគមន៍

០៤៨៧-	ស្រាវជ្រាវ និងអភិវឌ្ឍន៍ក្នុងវិស័យផ្សេងទៀត

*០៤៩- វិស័យសេដ្ឋកិច្ចឯទៀត ដែលមិនអាចចាត់ថ្នាក់បាន*

**០៥- កិច្ចការពារបរិស្ថាន**

*០៥១- ការគ្រប់គ្រងកាកសំណល់*

*០៥២- ការគ្រប់គ្រងទឹកក្រខ្វក់*

*០៥៣- ការប្រយុទ្ធនឹងការបំពុល*

*០៥៤- ការអភិរក្សជីវចម្រុះ និង កិច្ចការពារធម្មជាតិ*

*០៥៥- ស្រាវជ្រាវ និងអភិរក្សក្នុងវិស័យកិច្ចការពារបរិស្ថាន*

*០៥៦- កិច្ចការពារបរិស្ថាន ដែលមិនអាចចាត់ថ្នាក់បាន*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

**០៦- លំនៅដ្ឋាន និងបរិក្ខាសម្ភូហភាព**

*០៦១- លំនៅដ្ឋាន*

*០៦២- បរិក្ខាសម្ភូហភាព*

*០៦៣- ការផ្គត់ផ្គង់ទឹក*

*០៦៤- បំភ្លឺសាធារណៈ*

*០៦៥- ស្រាវជ្រាវ និងអភិវឌ្ឍន៍ក្នុងវិស័យលំនៅដ្ឋាន និងបរិក្ខារួម*

*០៦៦- លំនៅដ្ឋាន និងបរិក្ខារួម ដែលមិនអាចចាត់ថ្នាក់បាន*

**០៧- សុខាភិបាល**

*០៧១- ផលិតផល ឧបករណ៍ និងសម្ភារៈពេទ្យ*

០៧១១- ផលិតផលថ្នាំពេទ្យ

០៧១២- ផលិតផលពេទ្យផ្សេងៗ

០៧១៣- ឧបករណ៍ និងសម្ភារៈព្យាបាល

*០៧២- សេវាឡានសង្គ្រោះបន្ទាន់*

០៧២១- សេវាពេទ្យទូទៅ

០៧២២- សេវាពេទ្យឯកទេសកម្ម

០៧២៣- សេវាធ្មេញ

០៧២៤- សេវាពេទ្យផ្សេងៗ

*០៧៣- សេវាមន្ទីរពេទ្យ*

០៧៣១- សេវាមន្ទីរពេទ្យទូទៅ

០៧៣២- សេវាមន្ទីរពេទ្យឯកទេស



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

០៧៣៣- សេវាមណ្ឌលសុខភាព និងមណ្ឌលគាំពារមាតា និងទារក

០៧៣៤- សេវាផ្ទះសម្រាក និងផ្ទះព្យាបាល

*០៧៤- សេវាសុខាភិបាលសាធារណៈ*

*០៧៥- ស្រាវជ្រាវ និងអភិវឌ្ឍន៍ក្នុងវិស័យសុខាភិបាលសាធារណៈ*

*០៧៦- សុខាភិបាល ដែលមិនអាចចាត់ថ្នាក់បាន*

**០៨- លំហែកំសាន្ត វប្បធម៌ និង សាសនា**

*០៨១- សេវាលំហែកំសាន្ត និងកីឡា*

*០៨២- សេវាវប្បធម៌*

*០៨៣- សេវាផ្សាយវិទ្យុ ទូរទស្សន៍ និង បោះពុម្ពផ្សាយ*

*០៨៤- សាសនា និងសេវាគមនាគមន៍ផ្សេងទៀត*

*០៨៥- ស្រាវជ្រាវ និងអភិវឌ្ឍន៍ក្នុងវិស័យលំហែកាយ វប្បធម៌ និងសាសនា*

*០៨៦- លំហែកំសាន្ត វប្បធម៌ និងសាសនា ដែលមិនអាចចាត់ថ្នាក់បាន*

**០៩- អប់រំ**

*០៩១- អប់រំមត្តេយ្យសិក្សា និង កម្រិតបឋមសិក្សា*

០៩១១- អប់រំមត្តេយ្យសិក្សា

០៩១២- អប់រំកម្រិតបឋមសិក្សា

*០៩២- អប់រំកម្រិតមធ្យមសិក្សា*

០៩២១- អប់រំកម្រិតមធ្យមសិក្សាបឋមភូមិ

០៩២២- អប់រំកម្រិតមធ្យមសិក្សាទុតិយភូមិ

*០៩៣- អប់រំក្រោយមធ្យមសិក្សា*

*០៩៤- អប់រំកម្រិតឧត្តមសិក្សា*

០៩៤១- អប់រំកម្រិតឧត្តមសិក្សាមិនមែនថ្នាក់បណ្ឌិត

០៩៤២- អប់រំកម្រិតឧត្តមសិក្សាថ្នាក់បណ្ឌិត

*០៩៥- អប់រំទូទៅ*

*០៩៦- សេវាឧបសម្ព័ន្ធនឹងអប់រំ*

*០៩៧- ស្រាវជ្រាវ និងអភិវឌ្ឍន៍ក្នុងវិស័យអប់រំ*

*០៩៨- អប់រំ ដែលមិនអាចចាត់ថ្នាក់បាន*

**១០- កិច្ចការពារសង្គម**

*១០១- ជម្ងឺ និងការបាត់បង់ពលកម្ម*

១០១១- ជម្ងឺ

១០១២- ការបាត់បង់ពលកម្ម

*១០២- ភាពចាស់ជរា*

*១០៣- កុមារកំព្រា*

*១០៤- គ្រួសារ និង កុមារ*

*១០៥- ការបាត់អាជីព*

*១០៦- លំនៅស្ថាន*

*១០៧- ការស្ថិតក្រៅសង្គម ដែលមិនអាចចាត់ថ្នាក់បាន*

*១០៨- ស្រាវជ្រាវ និងអភិវឌ្ឍន៍ក្នុងវិស័យសុវត្ថិភាពសង្គម*

*១០៩- សុវត្ថិភាពសង្គម ដែលមិនអាចចាត់ថ្នាក់បាន*

## ៣. ការរៀបចំថវិកាតាមកម្មវិធី និងតាមផ្នែក

ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុហិរញ្ញវត្ថុសាធារណៈ ដែលត្រូវបានប្រកាសអោយប្រើប្រាស់ដោយព្រះរាជក្រម លេខ ន.ស./រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ បានជំនួសទាំងស្រុងនូវច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១ ន.ស. ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣÷

មាត្រា ២៤ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុហិរញ្ញវត្ថុសាធារណៈបានចែងថា៖ «ច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ វិភាជន៍ឥណទានទៅតាមក្រសួង ស្ថាប័ន និង អង្គភាពសាធារណៈប្រហាក់ប្រហែល ដោយឆ្លុះបញ្ចាំងអោយឃើញផងដែរនូវថវិកាឧបសម្ព័ន្ធ និងថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ទៅតាមប្រភេទចំណាយចរន្ត និង ចំណាយមូលធន ។ ក្រសួង ស្ថាប័ន ឬ អង្គភាពសាធារណៈប្រហាក់ប្រហែលទាំងនោះ ប្រមូលផ្តុំឥណទានទាំងអស់សម្រាប់បម្រើការងាររបស់ខ្លួននៅរដ្ឋបាលថ្នាក់ជាតិ» ។

មាត្រា ២៥ លើកឡើងថា៖ «ឥណទានថវិកា ដែលបានអនុម័តដោយច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ត្រូវបានបែងចែកលម្អិតនៅក្នុងផ្ទៃក្នុងប្រភេទនីមួយៗនៅតាមលក្ខណៈ និងគោលដៅនៃឥណទានថវិកា ។ ឥណទានទាំងនេះ អាចធ្វើជាកម្មវត្ថុសម្រាប់ការរៀបចំថវិកាតាមកម្មវិធី និង ការប្រមូលផ្តុំតាមវិស័យផងដែរ ។ ការរៀបចំថវិកាតាមកម្មវិធីត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ» ។

**និម្មាបកម្មថវិកាថ្មី**




ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១ ន.ស. ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ មាត្រា ១៧ អនុញ្ញាតអោយច្បាប់ស្តីពីហិរញ្ញវត្ថុប្រចាំឆ្នាំបែងចែកឥណទាន ទៅតាមលក្ខណៈ ឬ គោលដៅសេដ្ឋកិច្ចរបស់វា ពោលគឺ តាមជំពូក ប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ដែលជា «មធ្យោបាយ»នៃថវិកា។

ការបែងចែកឥណទានថវិកាតាមគោលដៅសេដ្ឋកិច្ចដូច្នេះមិនបានផ្តល់នូវព័ត៌មានអោយបានគ្រប់គ្រាន់ សម្រាប់ការវិភាគការប្រើប្រាស់ថវិកាឡើយ ។ ដូច្នេះហើយ កំណែទម្រង់មាតិកាថវិកា និង មាតិកាគណនី ជាពិសេសប្លង់គណនីថ្មី ដែលត្រូវបានដាក់អនុវត្តជាមួយនឹងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៧ មានដាក់ចេញនូវលេខកូដនៃមាតិកាថវិកា ដែលមានលក្ខណៈស្រដៀងគ្នាទៅនិងប្លង់គណនីនៃវិស័យឯកជនដែរ ដោយមានការគិតគូបន្ថែមនូវលក្ខណៈពិសេសរបស់រដ្ឋ ។

**បេសកកម្ម** គឺជាគោលនយោបាយធំៗរបស់រដ្ឋ ។ បេសកកម្មត្រូវបានបង្កើតឡើងដោយរាជរដ្ឋាភិបាល ដែលអាចគ្របដណ្តប់ក្រសួង- ស្ថាប័នតែមួយ ឬ អាចជា **បេសកម្មកម្មអន្តរក្រសួង** ។ បេសសកម្មគ្របដណ្តប់កម្មវិធីមួយចំនួន ។ នៅប្រទេសបារាំង រដ្ឋសភាអនុម័តថវិកាដោយឈរលើមូលដ្ឋាននៃការបែងចែកឥណទាន តាមបេសកម្ម ។ ក្នុងករណីនៃព្រះរាជាណាចក្រកម្ពុជា រដ្ឋសភាអនុម័តថវិកាដោយឈរលើមូលដ្ឋាននៃការបែងចែកឥណទានថវិកាតាមក្រសួង- ស្ថាប័ន ។

**កម្មវិធី** កំណត់នូវក្របខ័ណ្ឌដើម្បីអនុវត្តនូវគោលនយោបាយសាធារណៈ ។ នៅក្នុងប្រព័ន្ធនៃប្រទេសបារាំង **កម្មវិធី** គឺជាបន្ទាត់ថវិកា ឬ ឯកតានៃការអនុម័តរបស់រដ្ឋសភា ។ **កម្មវិធី** គឺជាក្រុមនៃអនុកម្មវិធី ឬ/និង ក្រុមនៃចង្កោមសកម្មភាពដែលមានលក្ខណៈឯករាជ្យ តែមានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធ ហើយត្រូវបានរៀបចំឡើងដើម្បីរួមចំណែកសម្រេចបាននូវគោលបំណង គោលនយោបាយរួមមួយ និងមានបញ្ជាក់ពីសកម្មភាព ដែលត្រូវអនុវត្តលទ្ធផលក្នុងឆ្នាំ លទ្ធផលចុងក្រោយ ព្រមទាំងសូចនាករដែលជាមូលដ្ឋានសម្រាប់ការត្រួតពិនិត្យ និង វាយតម្លៃលទ្ធផលសម្រេចបានពីការអនុវត្តកម្មវិធី ។ **កម្មវិធី** អាចត្រូវបានបែងចែកជាអនុកម្មវិធី ។ កម្មវិធីត្រូវតែស្ថិតនៅក្រោមការគ្រប់គ្រងរបស់មន្ត្រីគ្រប់គ្រងកម្មវិធីម្នាក់ ។

**កម្មវិធី** ត្រូវកំណត់ផងដែរនូវចំណាយសម្រាប់សកម្មភាព និង មធ្យោបាយនៅក្នុងកម្មវិធីនីមួយៗ ។ ម៉្យាងវិញទៀត កម្មវិធីត្រូវកំណត់នូវគោលដៅរបស់ខ្លួនអោយបានជាក់លាក់ លទ្ធផលដែលត្រូវទទួលបាន និង សូចនាករដែលវាស់ស្ទង់នូវលទ្ធផលទាំងនោះ ។

## ៣.១. ការរៀបចំថវិកាតាមកម្មវិធី សកម្មភាព និងតាមផ្នែក ព្រមទាំងចំណាយ

**កម្មវិធី** ត្រូវតែបែងចែកតាមសកម្មភាពលម្អិតថែមទៀត ។ សកម្មភាពទាំងនេះកំណត់នូវសេវាសាធារណៈ ដែលត្រូវផ្តល់ដល់អ្នកប្រើប្រាស់ គោលដៅនៃយោបាយនៃការធ្វើអន្តរាគមន៍ ឬ មុខងារដែលត្រូវបំពេញ ។ គេត្រូវកំណត់ផងដែរនូវចំណាយសម្រាប់សកម្មភាពនីមួយៗ ដូចជាចំណាយបុគ្គលិក ព្រមទាំងការកំណត់នូវមធ្យោបាយជាសម្ភារៈ និងអចលនវត្ថុដែលត្រូវយកមកអនុវត្តនូវរាល់សកម្មភាពទាំងនោះ ។ គេត្រូវពន្យល់ដោយលម្អិតនូវ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

***គោលដៅរួម គោលដៅពិសេស គោលដៅប្រតិបត្តិ ចំណុចដៅ***

ដៃគូរអភិវឌ្ឍន៍ជាច្រើនបានកំណត់នូវសញ្ញាណ **គោលដៅរួម** **គោលដៅពិសេស** **លទ្ធផលដែលរំពឹងទុក** **សកម្មភាព** និង **មធ្យោបាយ** នៅក្នុងវាក្យស័ព្ទ ដែលគេប្រើប្រាស់រាល់ថ្ងៃ ។

ម្យ៉ាងវិញទៀត ពាក្យនីមួយៗខាងលើតែងតែផ្សារភ្ជាប់ទៅនឹង **សូចនាករដែលអាចផ្ទៀងផ្ទាត់បានជាសត្យា-នុម័ត គោលដៅជាតួលេខ សមិទ្ធផលសម្រេចបានជាតួលេខ ប្រភពនៃការផ្ទៀងផ្ទាត់ និង សម្មតិកម្ម** ។

នៅពេលដែលគេវិភាគសមិទ្ធផលរបស់ស្ថាប័ននីមួយៗ ដោយបំបែកជាផ្នែកតូចៗរបស់វា យើងទទួលបាននូវ **លទ្ធផល** កម្រិតខ្ពស់មួយ ដែលក្លាយទៅជា **គោលដៅ** សម្រាប់ស្ថាប័នដែលមានឋានានុក្រមទាបជាង ។ ឧទាហរណ៍ ការថែទាំផ្លូវថ្នល់មាន **គោលដៅរួម** គឺ កែលម្អនូវចរាចរណ៍តាមដងផ្លូវ ។ រីឯគោលដៅពិសេសរបស់វា គឺ ការថែទាំផ្លូវកៅស៊ូ រីឯលទ្ធផលដែលនឹងសម្រេចបាន គឺការថែទាំផ្លូវកៅស៊ូប្រវែង ១.០០០ គីឡូម៉ែត្រ ដោយប្រើប្រាស់នូវថវិកាដែលបានគ្រោងទុក ។

**លទ្ធផល**ដែលរំពឹងទុកនេះ គឺ ការជួសជុលផ្លូវកៅស៊ូប្រវែង ១.០០០ គម បានក្លាយទៅជា **គោលដៅ** របស់នាយកដ្ឋានផ្លូវ- ថ្នល់នៃក្រសួងសាធារណៈការ និងដឹកជញ្ជូនទៅវិញ ។ ដោយឈរលើមូលដ្ឋាននៃគោលដៅនេះ នាយកដ្ឋានរៀបចំនូវសកម្មភាពរបស់ខ្លួន និងកំណត់នូវលទ្ធផលដែលរំពឹងទុក ដោយរៀបចំផែនការជួសជុលផ្លូវតាមខេត្ត- ក្រុងផ្សេងៗ និងតាមឆ្នាំនៃការអនុវត្តគម្រោង ក៏ដូចជាកំណត់នូវមធ្យោបាយជាសំភារៈនិង កៀងគរធនធានហិរញ្ញវត្ថុ ។

ទន្ទឹមនឹងនេះដែរ នាយកដ្ឋានស្ពាន- ថ្នល់អាចបែងចែក**គោលដៅ**ដែលបានកំណត់នេះ ទៅអោយមន្ទីរសាធារណៈការ និងដឹកជញ្ជូនខេត្ត- ក្រុង ដែលទទួលបន្ទុកថែទាំផ្លូវដើម្បីអនុវត្ត ។ ឧទាហរណ៍ មន្ទីរសាធារណៈការ និងដឹកជញ្ជូនខេត្តកំពតមាន **គោលដៅ**ជួសជុលផ្លូវប្រវែង ១០០ គីឡូម៉ែត្រ ទៅតាមកម្រិតថវិការបស់ខ្លួន ។

**គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍**

គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍បានកំណត់នូវ**គោលដៅ**រួមចំនួន «៨» (ព្រះរាជាណាចក្រកម្ពុជាបានបន្ថែមគោលដៅទីប្រាំបួនថែមទៀត គឺការដោះមីន) **ចំណុចដៅ** ចំនួន ១៨ និង **សូចនាករ** ចំនួន ៤៨ ។

**វាក្យស័ព្ទផ្សេងទៀត**

គេក៏ប្រើប្រាស់ផងដែរនូវវាក្យស័ព្ទ **គោលបំណងរួម** ដើម្បីពិពណ៌នាពី **គោលដៅរួម** និង **ចំណុចដៅ** ដើម្បីពិពណ៌នាពី **គោលដៅពិសេស**។

ការចាំបាច់ដែលត្រូវមានចំណាយទាំងនេះ÷ ការបែងចែកចំណាយតាមសេវាដែលបានអនុម័ត និងវិធានការថ្មីនឹងត្រូវសាបរលាបជាបណ្តើរៗ ដោយសារតែថវិកាត្រូវបានរៀបចំតាមកម្មវិធី ។

ការវិភាគប្រភេទនៃចំណាយត្រូវធ្វើឡើង ដោយអនុលោមតាមចំណាត់ថ្នាក់តាមមាតិកាសេដ្ឋកិច្ច និងវិធានថវិកា (ចំណាយបុគ្គលិក ចំណាយផ្សេងៗ ចំណាយកម្មវិធីច្រើនឆ្នាំ និង ឥណទានប្រចាំឆ្នាំ ថវិកាឧបសម្ព័ន្ធ និងគណនីពិសេសនៃរតនាគារ និង ស្ថាប័នសាធារណៈជាដើម) ។ ការជ្រើសរើសគោលដៅត្រូវតែឆ្លុះបញ្ចាំងនូវ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

***សូចនាករ***

**សូចនាករធាតុចូល** (Input): ជាធាតុផ្សំដែលចាំបាច់ដើម្បីអាចអោយគម្រោងមួយដំណើរការទៅបាន ។ បរិមាណ **ធាតុចូល** និងបញ្ជីមុខធាតុចូលនេះ ផ្សំបញ្ចូលគ្នាទើបអាចបង្កើតជាធាតុចេញបាន ។ ធាតុចូលប្រៀបដូចជាវត្ថុធាតុដើមនៅក្នុងផលិតកម្ម ។ ឧទាហរណ៍ ការជួសជុលថែទាំផ្លូវត្រូវការកម្លាំងពលកម្ម កៅស៊ូក្រាលថ្នល់ គ្រួស ជាដើម ។ ធាតុចូលទាំងនោះអាចវាស់វែងបាន ជាចំនួនម៉ោង តោន ។ល។ ឧទាហរណ៍ គម្រោងកាត់បន្ថយភាពក្រីក្រ គឺយើងប្រើធនធានហិរញ្ញវត្ថុ ធនធានមនុស្ស និងការសម្របសម្រួលគោលនយោបាយ ជាធាតុចូល ។

**សូចនាករធាតុចេញ** (Output): ជាផលដែលកើតក្រោយពេលដែលធាតុចូលបានផ្សំ និងមានអន្តរសកម្មរវាងគ្នា ។ ការជួសជុលផ្លូវមាន **ធាតុចេញ** ជាផ្លូវបានជួសជុលរួច តាមរយៈការប្រើប្រាស់ធាតុចូលខាងដើម រួមទាំងការគ្រប់គ្រងផងដែរ ។ ឧទាហរណ៍ ក្នុងគម្រោងកាត់បន្ថយភាពក្រីក្រ ការបង្កើនទិន្នផលស្រូវជាធាតុចេញមួយ ។

**សូចនាករលទ្ធផល** (Outcome): ការប្រើប្រាស់ធាតុចេញអោយកើតជាផលប្រយោជន៍ផ្សេងទៀត គឺជា **លទ្ធផល** ។ ក្នុងន័យនេះ មិនមែនគ្រប់ ធាតុចេញ ទាំងអស់សុទ្ធតែមានលទ្ធផលល្អនោះទេ ។ ប្រសិនបើផ្លូវដែលជួសជុលរួចនោះ មិនមានការប្រើប្រាស់ **លទ្ធផល** ក៏គ្មានដែរ ។ ដូច្នេះ លទ្ធផលអាចមានទាំងល្អ ទាំងអាក្រក់ ពីធាតុចេញតែមួយដូចគ្នា។ ឧទាហរណ៍ ការជួសជុលផ្លូវធ្វើអោយផ្លូវអាចធ្វើដំណើរបានស្រួល ។ ក្នុងគម្រោងកាត់បន្ថយភាពក្រីក្រ ការបង្កើនទិន្នផងស្រូវបានធ្វើអោយចំណូលប្រជាជនកើនឡើង នេះជា **លទ្ធផល** ។

**សូចនាករផលប៉ះពាល់** (Impact): លទ្ធផលពីការប្រើប្រាស់នឹងធ្វើអោយប៉ះពាល់ ឬ បញ្ចេញអានុភាពលើសកម្មភាពដ៏ទៃផ្សេងទៀត ដែលយើងហៅកាត់ថា **ផល់ប៉ះពាល់** ។ ឧទាហរណ៍ ការធ្វើដំណើរបានស្រួលនាំអោយតម្លៃទំនិញធ្លាក់ចុះ ចំណេញពេលវេលាជាដើម ។ ទាំងនេះជាផលប៉ះពាល់ពីគម្រោង ឬ សកម្មភាព ។ ផលប៉ះពាល់នៃគម្រោងកាត់បន្ថយភាពក្រីក្រ គឺ ភាពក្រីក្រធ្លាក់ចុះ និងសុខុមាលភាពរបស់ប្រជាជនល្អប្រសើរ ដែលជាលទ្ធផលនៃកំណើនចំណូលរបស់ប្រជាជន ។

អាទិភាពនៃគោលយោបាយ និង យុទ្ធសាស្ត្ររបស់ក្រសួងនីមួយៗ ។

### ៣.១.១. ការរៀបចំថវិកាតាមផ្នែក

**ផ្នែក** នីមួយៗឆ្លុះបញ្ចាំងពីមុខងារនៃការអនុវត្តនូវគោលនយោបាយ និង ការផ្តល់សេវា ក៏ដូចជាមុខងារនៃការគ្រប់គ្រងមធ្យោបាយដែលមិនអាចត្រូវបានកំណត់ក្រោមទម្រង់ជាកម្មវិធី ។ ផ្នែកទាំងនេះមានគោលដៅជួយដល់ការអនុវត្តកម្មវិធី ឬ ត្រូវបានបែងចែកទាំងស្រុង ឬ តាមផ្នែកខ្លះៗនៃកម្មវិធី ។

### ៣.១.២. គោលដៅ

**គោលដៅ** មានលក្ខណៈច្បាស់លាស់ជាង គោលបំណងទូទៅនៃគោលនយោបាយ ហើយអាចប្រែប្រួលទៅតាមពេលវេលា ។ គោលដៅត្រូវបានកំណត់អោយបានច្បាស់លាស់ ដើម្បីអាចអោយយើងវាស់វែងនូវលទ្ធផលដែលត្រូវសម្រេចអោយបាន ។ **គោលដៅ** មានតួនាទីប្រែក្លាយអាទិភាព អោយទៅជាសកម្មភាព ។ ដូច្នេះ



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

***ការសន្សំសំចៃ ប្រសិទ្ធភាព និង ភាពស័ក្តិសិទ្ធ***

**ការសន្សំសំចៃ**: វាស់វែងចំណាយដើម្បីសម្រេចបាននូវសកម្មភាព ដូចជាការដេញថ្លៃសាងសង់ផ្លូវអាចអោយយើងកាត់បន្ថយចំណាយ ដោយសារមានការប្រណាំងប្រជែងពីក្រុមហ៊ុនផ្សេងៗគ្នា ដោយធានាបានផងដែរនូវគុណភាពខ្ពស់ ។

**ប្រសិទ្ធភាព** (Efficient): គឺការសម្រេចបានតាម **គោលដៅ** ដោយប្រើប្រាស់នូវធនធាន ជាអប្បរមា ។ ប្រសិទ្ធភាពផ្តោតទៅលើទំនាក់ទំនងរវាង **លទ្ធផល** និង **មធ្យោបាយ** ដែលជាសញ្ញាណនៃ **ផលិតភាព** ។

**ភាពស័ក្តសិទ្ធិ** (Effective): គឺការសម្រេចបានតាម **គោលដៅ** ទោះបីជាត្រូវប្រើប្រាស់នូវធនធានប៉ុន្មានក៏ដោយ ។ សញ្ញាណនៃភាពស័ក្តិសិទ្ធិ គឺការធានាអោយ **លទ្ធផល** សមស្របទៅនឹង **គោលដៅ** ។

សរុបមក យើងអាចសម្រេចបាននូវ **ប្រសិទ្ធភាព** តែគ្មាន **ភាពស័ក្តិសិទ្ធិ** ហើយទន្ទឹមនឹងនេះ យើងក៏អាចសម្រេចបាននូវ **ភាពស័ក្តិសិទ្ធិ** តែគ្មាន **ប្រសិទ្ធភាព** ដូច្នេះដែរ ។

គោលដៅត្រូវតែផ្សារភ្ជាប់ជាមួយនឹង **សូចនាករ**លទ្ធផល ។ គោលដៅ អាចវាស់វែងបានអោយសារតែសូចនាករលទ្ធផលទាំងនេះ ដែលបង្ហាញពីកម្រិតនៃការអនុវត្ត ដោយប្រើធៀបនឹង **ចំណុចដៅ** ដែលត្រូវសម្រេចបាន ក្នុងរយៈពេលមួយសមស្រប ។ ដើម្បីវាស់វែងសមិទ្ធកម្ម **គោលដៅយុទ្ធសាស្ត្រ** កំណត់ដោយកម្មវិធី ត្រូវបំបែកចេញជា **គោលដៅប្រតិបត្តិ** សម្រាប់អ្នកទទួលខុសត្រូវតាមសកម្មភាពនិមួយៗ ។

**គោលដៅ សូចនាករ** របស់វា និង **ចំណុចដៅ** ត្រូវបានវាយតម្លៃដោយឈរលើ **សមិទ្ធកម្ម** ក្រោមទិដ្ឋភាពផ្សេងៗ ÷ **ប្រសិទ្ធិភាព** សេដ្ឋកិច្ច- សង្គម **គុណភាព** សម្រាប់អ្នកប្រើប្រាស់ និង **ប្រសិទ្ធភាព** នៃការគ្រប់គ្រង ។

## ៣.១.៣. សូចនាករ

យើងអាចតាមដានការអនុវត្ត និងវាយតម្លៃអំពីសមិទ្ធកម្មនៃកម្មវិធី តាមរយៈ **សូចនាករ** នានា ។ សូចនាករទាំងនេះអាចត្រូវបានកំណត់ ដោយឈរលើមូលដ្ឋាននៃកត្តារូបិយវត្ថុ (ឧទាហរណ៍ ចំណូល និងចំណាយ) ឬ ដោយឈរលើមូលដ្ឋាននៃកត្តាគុណភាព (ឧទាហរណ៍ កង្វះខាតស្បៀង ឬ កត្តាពេញចិត្ត) ។ យើងអាចប្រមូលទិន្នន័យពាក់ព័ន្ធនឹងសូចនាករទាំងនេះ ដោយប្រើប្រាស់ប្រព័ន្ធរដ្ឋបាន ឬ ប្រព័ន្ធស្ថិតិ ឬ តាមរយៈការអង្កេត (ការអង្កេតប្រជាជន ជំរឿន ការអង្កេតលើការពេញចិត្ត) ។

**សូចនាករ** ត្រូវតែមានលក្ខណៈត្រឹមត្រូវ អាចយល់បាន គួរអោយទុកចិត្តបាន សាមញ្ញ បង្ហាញពីសភាពការណ៍ មានសត្យានុម័ត ប្រែប្រួលទៅតាមព្រឹត្តការណ៍ដែលយើងវាស់វែង មានលក្ខណៈជាក់លាក់ ស្មោះត្រង់ អាចផ្ទៀងផ្ទាត់បាន ព្រមទាំងអាចរកបាន អាចចែករំលែក និងទទួលស្គាល់ដោយភាគីដែលមានការពាក់ព័ន្ធ ដោយគ្រាន់តែត្រូវចំណាយដ៏សមរម្យ ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

| | **ស័ក្តិសិទ្ធិ (Effective)** | **អស័ក្តិសិទ្ធិ** |
|---|---|---|
| **ប្រសិទ្ធភាព (Efficient)** | សម្រេចបាននូវគោលដៅ ដោយប្រើប្រាស់ធនធានអប្បបរមា | ការប្រើប្រាស់ធនធានតិចមិនអាចនាំអោយសម្រេចបាននូវគោលដៅឡើយ |
| **អប្រសិទ្ធភាព** | សម្រេចបានតាមគោលដៅ តែដោយប្រើប្រាស់ធនធានបន្ថែម | ការប្រើប្រាស់ធនធានលើស ហើយនៅតែមិនអាចសម្រេចបាននូវគោលដៅ |

### ៣.១.៤. គុណភាពសេវា

គុណភាពមានលក្ខណៈពីរយ៉ាង ដែលពាក់ព័ន្ធនឹងផលិតផលពាក់កណ្តាលសម្រេច និង លទ្ធផលចុងក្រោយ ។ គុណភាពនៃការផ្តល់សេវាមានការពាក់ព័ន្ធយ៉ាងជិតស្និទ្ធជាមួយនឹងការវិភាគពីប្រសិទ្ធភាព៖ បរិមាណនៃសេវាដែលផលិត និង គុណភាពត្រូវតែត្រួតពិនិត្យអោយបានជិតដល់ ក្នុងពេលតែមួយ ។ គុណភាព គឺជាសមាសធាតុដែលមានសារៈសំខាន់បំផុតសម្រាប់អ្នកប្រើប្រាស់ ហើយដែលចូលរួមក្នុងការកំណត់នូវភាពស័ក្តិសិទ្ធិនៃសកម្មភាពនីមួយៗ ។ នៅក្នុងឧបករណ៍វង្វាស់វង្វាល់គុណភាព យើងសង្កេតឃើញនូវទិដ្ឋភាពពីរ៖ ចំណុចសំខាន់ដែលត្រូវវាស់វែងផ្តោតលើផលិតផល ចំណែកឯការវាយតម្លៃពីសេវាផ្គត់ផ្គង់ត្រូវធ្វើឡើង តាមរយៈអង្កេតស្តីពីការពេញចិត្តពាក់ព័ន្ធនឹងលទ្ធផលចុងក្រោយ ។

### ៣.១.៥. ភាពស័ក្តិសិទ្ធិក្នុងការដឹកនាំ

យើងបានពិភាក្សារួចមកហើយ នូវភាពខុសគ្នារវាងភាពស័ក្តិសិទ្ធិ និង ប្រសិទ្ធភាព ។ នៅក្នុងត្រីកោណនៃការគ្រប់គ្រងខាងក្រោម យើងឃើញនូវមុំបីសំខាន់ៗ គឺ ÷ គោលដៅ លទ្ធផល និង មធ្យោបាយ ។ **ភាពស័ក្តិសិទ្ធិ** គឺ

**ត្រីកោណនៃការគ្រប់គ្រង**



ការសម្រេចបាននូវ **លទ្ធផល** ដូច **គោលដៅ** ដែលបានដាក់ចេញ ។ ចំណែកឯ **ប្រសិទ្ធភាព** វិញ គឺជាការសម្រេចបាននូវ **លទ្ធផល** ដូច **គោលដៅ** ដែលបានដាក់ចេញ ដោយប្រើប្រាស់នូវ **មធ្យោបាយ** ជាអប្បបរមា ។ ប្រការនេះមានន័យថា យើងអាចសម្រេចបាននូវ **ភាពស័ក្តិសិទ្ធិ** ក៏ប៉ុន្តែ **លទ្ធផល** ដែលសម្រេចបាននេះ អាចគ្មាន **ប្រសិទ្ធភាព** ដោយសារតែយើងបានប្រើប្រាស់នូវ **ធនធាន** ច្រើន ។

### ៣.១.៦. ការដោះដូរមុខសញ្ញានៃធនធានថវិកា

ការអនុវត្តនូវការគ្រប់គ្រងដែលផ្តោតលើគោលដៅ និង លទ្ធផល ទាមទារអោយមានការទទួលខុសត្រូវ ការត្រួតពិនិត្យ និងការផ្លាស់ប្តូរព័ត៌មានទៅវិញទៅមក ។ មធ្យោបាយ ឬ ឥណទានថវិកា**អាចដូរមុខសញ្ញាចំណាយ** (Fongible) បាន ដែលមានន័យថា អ្នកគ្រប់គ្រងកម្មវិធីថវិកាមានសេរីភាព ក្នុងកម្រិតណាមួយនោះ ក្នុងការប្រើប្រាស់ធនធានដែលខ្លួនមាន ដោយអាចផ្លាស់ប្តូរមុខសញ្ញានៃធនធានថវិកាដែលខ្លួនគ្រប់គ្រង ដោយមានភាពទន់ភ្លន់ ។ មានន័យថា អាណាប័កអាចយកឥណទានសម្រាប់បើកប្រាក់បៀវត្សយកទៅប្រើប្រាស់សម្រាប់កិច្ចដំណើរការនៃសកម្មភាពគម្រោង (តាមស្មារតីនៃការអនុវត្តនៅប្រទេសបារាំងនាពេលបច្ចុប្បន្ននេះ) ។ ក៏ប៉ុន្តែ **ការអាចដូរមុខសញ្ញាចំណាយ** (Fongibility) អាចមានលក្ខណៈវិសមាមាត្រ (Assymetric) ដោយហេតុថា អ្នកគ្រប់គ្រងកម្មវិធីអាចយកឥណទានដែលសន្សំបានពីប្រាក់បៀវត្សរ៍ យកទៅប្រើប្រាស់ជាចំណាយដំណើរការបាន ក៏ប៉ុន្តែមិនអាចយកឥណទានថវិកាសម្រាប់កិច្ចដំណើរការ យកទៅបង្កើនឥណទានបៀវត្សរ៍បានឡើយ ។ គោលនយោបាយនេះមានគោលដៅកាត់បន្ថយចំនួនមន្ត្រីមុខងារសាធារណៈនៅបារាំង ដែលមានចំនួនលើសលប់ពីសេចក្តីត្រូវការ ។

### ៣.១.៧. គ្រឹះស្ថានសាធារណៈ និង តួអង្គអនុវត្តគោលនយោបាយសាធារណៈដទៃទៀត

ថ្វីត្បិតតែតួអង្គមួយចំនួនរបស់រដ្ឋ មានស្វ័យភាពគតិយុត្តិ (គ្រឹះស្ថានសាធារណៈ អាជ្ញាធរនីយ័តករអង្គភាពឯកជន ។ល។) និងមានស្វ័យភាពហិរញ្ញវត្ថុ (ដោយសារធនធានហិរញ្ញវត្ថុមួយភាគនៃតួអង្គទាំងនេះមានប្រភពផ្សេងពីថវិការរដ្ឋ) ក៏អង្គភាពទាំនេះចូលរួមយ៉ាងសកម្មក្នុងការរៀបចំ និងអនុវត្តនូវគោលនយោបាយសាធារណៈរបស់រដ្ឋ ។

ដូច្នេះហើយ ទើបនៅក្នុងកម្មវិធី យើងត្រូវបញ្ចូលនូវក្រសួង ស្ថាប័ន និង តួអង្គដែលផ្តល់សេវាសាធារណៈប្រហាក់ប្រហែលគ្នានេះ ដើម្បីអោយមានចក្ខុវិស័យរួមនៃសកម្មភាពរបស់រដ្ឋ ក្នុងគោលដៅពង្រឹងដល់ការតាមដាន និងវាយតម្លៃសមិទ្ធកម្មរបស់រាជរដ្ឋាភិបាល ។

## ៣.២. កម្មវិធី និង គម្រោង

ថវិកាជាតិតែងតែបញ្ចូលនូវបញ្ជីគម្រោងវិនិយោគ ដែលធ្វើហិរញ្ញប្បទានដោយថវិការដ្ឋ ដោយថវិការដ្ឋ និងថវិការបស់ដៃគូអភិវឌ្ឍន៍ និង ដោយដៃគូអភិវឌ្ឍន៍ផ្ទាល់តែម្តង ។

សញ្ញាណគម្រោងវិនិយោគត្រូវបានយើងពន្យល់រួចមកហើយនៅក្នុងជំពូកមុនៗ ។ ម្យ៉ាងទៀត មានសៀវភៅជាច្រើនដែលបានពន្យល់យ៉ាងក្បោះក្បាយអំពីការគ្រប់គ្រងគម្រោងដោយដៃគូអភិវឌ្ឍន៍ ។ យើងក៏ធ្លាប់បានលើកឡើងដែរពី «**បទបញ្ញត្តិពីការគ្រប់គ្រងវដ្តនៃគម្រោង**» របស់ **សហគមន៍អ៊ឺរ៉ុប** ។

ជាគោលការណ៍ គម្រោងនីមួយៗមានលក្ខណៈពិសេសខុសពីគេ ដូចជាការសាងសង់សាលារៀន ។ ដូច្នេះ កម្មវិធី គឺជាសកម្មភាពរួមដែលអូសបន្លាយអស់រយៈពេលដ៏យូរ ដូចជាកម្មវិធីសាងសង់សាលារៀន ជាដើម ដែលអាចជាកម្រងនៃកម្មវិធីមួយចំនួន ។

គម្រោងមួយមិនមែនផ្តោតទៅលើតែការវិនិយោគប៉ុណ្ណោះទេ ។ គម្រោង **ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដោយប្រព័ន្ធព័ត៌មានវិទ្យា** និង **គម្រោងដាក់អោយអនុវត្តថវិកាតាមកម្មវិធី** គឺជាគម្រោងដែលផ្តោតទៅលើសកម្មភាពជាប្រចាំរបស់រដ្ឋបាលសាធារណៈ ពោលគឺ ដើម្បីផ្តល់នូវការព្យាបាល បង្រៀនសិស្ស ថែទាំផ្លូវ ។ ល។ ដែលរួមបញ្ចូលផងដែរនូវសញ្ញាណគម្រោង ។

## ៣.៣. កម្មវិធី និង គម្រោងនៅក្នុងថវិកាឆ្នាំ ២០០៧

**កម្មវិធី** ត្រូវបានដាក់អោយអនុវត្តជាលើកដំបូង នៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៧ នៅក្នុងក្រសួងចំនួន ៧ របស់រាជរដ្ឋាភិបាល ÷ ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសុខាភិបាល ក្រសួងកិច្ចការនារី ក្រសួងយុត្តិធម៌ ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង ក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ ។

### *៣.៣.១. ក្រសួងអប់រំ យុវជន និងកីឡា*

ថវិការតាមកម្មវិធីរបស់ក្រសួងអប់រំ យុវជន និងកីឡាមាន **កម្មវិធី** ចំនួន ៥ ដែលចែកចេញជា **អនុកម្មវិធី** ចំនួន ២៤ និង **សកម្មភាព** មួយចំនួនទៀត ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## កម្មវិធីទី ១ - ការអភិវឌ្ឍអប់រំចំណេះទូទៅ និងអប់រំក្រៅប្រព័ន្ធ

### *អនុកម្មវិធី ១.១. ការពង្រីកការអប់រំកុមារតូច*

១.១.១ . កម្មវិធីអប់រំ មត្តេយ្យសិក្សា សម្រាប់កុមារអាយុ ៥ ឆ្នាំ ត្រៀមចូលរៀនថ្នាក់ទី ១ នៅសាលាបឋមសិក្សា

១.១.២ . សាកល្បងកម្មវិធីអប់រំកុមារតូចផ្អែកលើសហគមន៍ និងតាមផ្ទះ

១.១.៣. ពង្រឹងការគាំទ្រ និងពិនិត្យតាមដាន

### *អនុកម្មវិធី ១.២ ការពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការអប់រំនៅបឋមសិក្សា*

១.២.១. ថវិកាដំណើរការសាលារៀន

១.២.២. ថវិកាពង្រឹងគុណភាពបង្រៀន និងរៀន

១.២.៣. ថវិកាពង្រឹងការពិនិត្យតាមដាន និងកសាងសមត្ថភាព

### *អនុកម្មវិធី ១.៣. ការពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការអប់រំនៅមធ្យមសិក្សា*

១.៣.១. ការពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការអប់រំនៅមធ្យមសិក្សាបឋមភូមិ

១.៣.២. ការពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការអប់រំនៅមធ្យមសិក្សាទុតិយភូមិ

### *អនុកម្មវិធី ១.៤. ការចូលរៀនប្រកបដោយសមធម៌ និងផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រជួបការលំបាក*

១.៤.១. អាហារូបករណសិស្សក្រីក្រ

១.៤.២. ការផ្តល់ថវិកាដល់គណៈកម្មការទ្រទ្រង់អាហារូបករណ៍សិស្សក្រីក្រ

១.៤.៣. ការគ្រប់គ្រង និងការពិនិត្យតាមដាន

### *អនុកម្មវិធី ១.៥. ការពង្រីកការអប់រំក្រៅប្រព័ន្ធ*

១.៥.១. ពង្រឹងសមត្ថភាពមន្ត្រី

១.៥.២. ដំណើរការកម្មវិធីអក្ខរកម្មវិជ្ជាជីវៈ និងបំណិនជីវិត

១.៥.៣. ការអភិវឌ្ឍកម្មវិធីចូលរៀនឡើងវិញ និងកម្មវិធីសមមូល



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

១.៥.៤. ការពិនិត្យតាមដាន និងវាយតម្លៃកម្មវិធី

**កម្មវិធីទី ២- ការអភិវឌ្ឍការអប់រំ បណ្តុះបណ្តាលបច្ចេកទេសឧត្តមសិក្សា និងស្រាវជ្រាវវិទ្យាសាស្ត្រ**

*អនុកម្មវិធី ២.១. ការពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការអប់រំនៅឧត្តមសិក្សា*

*អនុកម្មវិធី ២.២. ការពង្រឹងគុណភាព និងប្រសិទ្ធភាពនៅសាកលវិទ្យាល័យភ្នំពេញ*

*អនុកម្មវិធី ២.៣. ការពង្រឹងគុណភាព និងប្រសិទ្ធភាព នៅសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ*

*អនុកម្មវិធី ២.៤. ការពង្រឹងគុណភាព និងប្រសិទ្ធភាព នៅសាកលវិទ្យាល័យវេទមហាប្ញសី*

*អនុកម្មវិធី ២.៥. ការពង្រឹងគុណភាព និងប្រសិទ្ធភាព នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា*

*អនុកម្មវិធី ២.៦. ការពង្រឹងគុណភាព និងប្រសិទ្ធភាព នៅវិទ្យាស្ថានជាតិអប់រំ*

*អនុកម្មវិធី ២.៧. ការពង្រឹងគុណភាព និងប្រសិទ្ធភាព នៅសាកលវិទ្យាល័យស្វាយរៀង*

*អនុកម្មវិធី ២.៨. ការពង្រឹងគុណភាព និងប្រសិទ្ធភាព នៅសាកលវិទ្យាល័យមានជ័យ*

*អនុកម្មវិធី ២.៩. ការពង្រឹងគុណភាព និងប្រសិទ្ធភាព នៅសាកលវិទ្យាល័យបាត់ដំបង*

**កម្មវិធីទី ៣- ការអភិវឌ្ឍយុវជន និងកីឡា**

*អនុកម្មវិធី ៣.១. ការយល់ដឹងរបស់យុវជនអំពីជម្ងឺអេដស៍ និងការពង្រឹងសកម្មភាពយុវជន*

*អនុកម្មវិធី ៣.២. ការអភិវឌ្ឍវិស័យកីឡា*

**កម្មវិធីទី ៤- ការពង្រឹងអភិបាលកិច្ចល្អ**

*អនុកម្មវិធី ៤.១. ការពិនិត្យតាមដាន និងវាយតម្លៃការបំពេញការងារវិស័យអប់រំទាំងមូល*

*អនុកម្មវិធី ៤.២. អធិការកិច្ចរដ្ឋបាល និងហិរញ្ញវត្ថុ*

*អនុកម្មវិធី ៤.៣. សវនកម្មផ្ទៃក្នុង*

**កម្មវិធីទី ៥- ការគាំទ្រ និងការគ្រប់គ្រងសេវាអប់រំ**

*អនុកម្មវិធី ៥.១. ការអភិវឌ្ឍគោលនយោបាយ និងពង្រឹងប្រព័ន្ធផែនការអប់រំ ។*

*អនុកម្មវិធី ៥.២. ការអភិវឌ្ឍការងារបណ្តុះបណ្តាល និងវិក្រឹតការគ្រូបង្រៀន*

*អនុកម្មវិធី ៥.៣. ការអភិវឌ្ឍសម្ភារៈ និងសៀវភៅសិក្សា*

*អនុកម្មវិធី ៥.៤. ការគ្រប់គ្រង និងពង្រឹងប្រសិទ្ធភាពធនធានមនុស្ស*

*អនុកម្មវិធី ៥.៦. ការអភិវឌ្ឍសមត្ថភាពការងារគ្រប់គ្រងផែនការ ហិរញ្ញវត្ថុ និងមូលដ្ឋានសម្ភារៈ*

### ៣.៣.២. ក្រសួងសុខាភិបាល

**កម្មវិធីទី១- បន្ថយការឈឺ និងស្លាប់របស់មាតា ទារក និងកុមារ និងការលើកកំពស់សេវាសុខភាព**

*អនុកម្មវិធី ១.១. លើកកំពស់ស្ថានភាព អាហាររូបត្ថម្ភរបស់មាតា និងកុមារ*

*អនុកម្មវិធី ១.២. លើកកំពស់លទ្ធភាពមកទទួលយកព័ត៌មាន និងសេវាសុខភាពបន្តពូជមានគុណភាព*

*អនុកម្មវិធី ១.៣. លើកកំពស់លទ្ធភាពមកទទួលយកសេវាសុខភាព សារវន្តសម្រាប់មាតា និងទារក និងការប្រព្រឹត្ត ការថែទាំសុខភាពតាមគ្រួសារបានល្អប្រសើរ*

*អនុកម្មវិធី ១.៤. ធានានូវលទ្ធភាពមកទទួលយកសេវាសុខភាពសារវន្តសម្រាប់កុមារ និងការប្រព្រឹត្ត ការថែទាំសុខភាពតាមគ្រួសារបានល្អប្រសើរ*

**កម្មវិធីទី ២- បន្ថយអត្រាឈឺ និងអត្រាស្លាប់ដោយសារជម្ងឺអេដស៍ របេង គ្រុនចាញ់ និងជម្ងឺឆ្លងដទៃទៀត**

*អនុកម្មវិធី ២.១. កាត់បន្ថយអត្រាប្រេវ៉ាឡង់នៃមេរោគហ៊ីវឱ្យទាបជាង ១% (០.៦%-០.៩%) នៅដំណាច់ឆ្នាំ ២០១៥*

*អនុកម្មវិធី ២.២. បង្កើនការរស់រានមានជីវិតរបស់អ្នកផ្ទុកមេរោគអេដស៍/មានជម្ងឺអេដស៍លើសពី ៧៥% នៅដំណាច់ឆ្នាំ ២០១៥*

*អនុកម្មវិធី ២.៣. សម្រេចបានអត្រាស្រាវជ្រាវជម្ងឺរបេងខ្ពស់លើសពី ៧០% និងរក្សាអត្រាជាសះស្បើយកម្រិតខ្ពស់លើសពី ៨៥% នៃករណីជម្ងឺរបេងស្ងួតបេកាវិជ្ជមាននៅដំណាច់ឆ្នាំ ២០១៥*

*អនុកម្មវិធី ២.៤. កាត់បន្ថយការស្លាប់ដោយជម្ងឺគ្រុនចាញ់ ៥០%និងអត្រាឈឺ ៣០%ធៀបនឹងឆ្នាំ ២០០៦ ក្នុងចំណោមប្រជាជនទូទៅនៅដំណាច់ឆ្នាំ ២០១៥*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

*អនុកម្មវិធី ២.៥. កាត់បន្ថយបន្ទុកនៃជម្ងឺឆ្លងដទៃទៀត*

**កម្មវិធីទី ៣. បន្ថយបន្ទុកជម្ងឺមិនឆ្លង និងបញ្ហាសុខភាពដទៃទៀត**

*អនុកម្មវិធី ៣.១. កាត់បន្ថយកត្តាហានិភ័យនិងហេតុនាំទៅរកជម្ងឺមិនឆ្លងៈ ទឹកនោមផ្អែម ជម្ងឺបេះដូង-សរសៃឈាម មហារីក សុខភាពផ្លូវចិត្ត ការប្រើប្រាស់គ្រឿងញៀន គ្រោះថ្នាក់ និងរបួស ការថែទាំភ្នែក សុខភាពមាត់ធ្មេញ*

*អនុកម្មវិធី ៣.២. លើកកំពស់លទ្ធភាពមកទទួលយកសេវាព្យាបាល និងការស្តារនិតិសម្បទា បង្ការឡើងដោយជម្ងឺមិនឆ្លងៈ ទឹកនោមផ្អែម ជម្ងឺបេះដូង- សរសៃឈាម មហារីក សុខភាពផ្លូវចិត្ត ការប្រើប្រាស់គ្រឿងញៀន គ្រោះថ្នាក់ និងរបួស ការថែទាំភ្នែក សុខភាពមាត់ធ្មេញ*

*អនុកម្មវិធី ៣.៣. ធានាដំណើរការមុខងារសារវ័ន្តនៃសុខភាពសាធារណៈ សុខភាព បរិស្ថានសុវត្ថិភាព ចំណីអាហារ ការគ្រប់គ្រងគ្រោះមហន្តរាយ និងការត្រៀមលក្ខណៈ (សម្រាប់គ្រាអាសន្ន)*

**កម្មវិធីទី ៤: ពង្រឹងប្រព័ន្ធសុខាភិបាល**

*អនុកម្មវិធី ៤.១. ការផ្តល់សេវាសុខភាព*

*អនុកម្មវិធី ៤.២. ហិរញ្ញប្បទានការថែទាំសុខភាព*

*អនុកម្មវិធី ៤.៣. ធនធានមនុស្សសុខាភិបាល*

*អនុកម្មវិធី ៤.៤. ប្រព័ន្ធព័ត៌មានសុខាភិបាល*

*អនុកម្មវិធី ៤.៤. អភិបាលកិច្ចវិស័យសុខាភិបាល*

### ៣.៣.៣. ក្រសួងកិច្ចការនារី

**កម្មវិធីទី ១: ការលើកកម្ពស់ស្ថានភាពស្ត្រី និងតម្លៃគ្រួសារខ្មែរ**

*អនុកម្មវិធី ១.១. លើកកំពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ*

សកម្មភាពទី ១.១.១. រៀបចំកិច្ចប្រជុំរបស់គណកម្មការលើកកំពស់សីលធម៌សង្គម និងតម្លៃគ្រួសារខ្មែរ

សកម្មភាពទី ១.១.២. ការអប់រំបំណិនជីវិត និងអភិវឌ្ឍន៍សង្គម

សកម្មភាពទី ១.១.៣. ពង្រឹងសមត្ថភាពគ្រូបង្គោលថ្នាក់ក្រសួង- ខេត្ត និងស្រុក



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

សកម្មភាពទី ១.១.៤. ពង្រឹងសមត្ថភាពអ្នកអប់រំថ្នាក់ភូមិ និង អាជ្ញាធរភូមិ ឃុំ និងមជ្ឈមណ្ឌលក្នុងកិច្ចអភិវឌ្ឍន៍

សកម្មភាពទី ១.១.៥. ពង្រឹងសមត្ថភាពអាជ្ញាធរមូលដ្ឋានថ្នាក់ភូមិ ឃុំ និងស្រុកនៃខេត្តគោលដៅទាំង៦

សកម្មភាពទី ១.១.៦. ត្រួតពិនិត្យតាមដានលើដំណើរការអប់រំនៅសហគមន៍

សកម្មភាពទី ១.១.៧. ដំណើរការអប់រំផ្សព្វផ្សាយនៅសហគមន៍ទាំង ៦ ខេត្ត

សកម្មភាពទី ១.១.៨. បូកសរុបលទ្ធផលប្រចាំឆ្នាំ ២០០៩

សកម្មភាពទី ១.១.៩. ទប់ស្កាត់អំពើរំលោភសេពសន្ថវៈលើស្ត្រី/កុមារ

សកម្មភាពទី ១.១.៥. ពង្រឹងសកម្មភាពភ្នាក់ងារនគរបាលយុត្តិធម៌នៃក្រសួងកិច្ចការនារី

*អនុកម្មវិធី ១.២. ការរៀបចំផែនការស្ថិតិ និងតាមដានវាយតម្លៃឆ្លើយតបនឹងយេនឌ័រ*

សកម្មភាពទី ១.២.១. ដំណើរការរៀបចំថវិកា និង គម្រោងវិនិយោគ

សកម្មភាពទី ១.២.២. រៀបចំវគ្គបណ្តុះបណ្តាលដើម្បីប្រមូលព័ត៌មាន និង ទិន្នន័យ

សកម្មភាពទី ១.២.៣. បណ្តុះបណ្តាលស្តីពីវិធីសាស្រ្តត្រួតពិនិត្យ និង វាយតម្លៃគម្រោង

សកម្មភាពទី ១.២.៤. កិច្ចប្រជុំត្រួតពិនិត្យលទ្ធផលសម្រេចបានរបស់កម្មវិធី

សកម្មភាពទី ១.២.៥. ពង្រឹងគុណភាពបច្ចេកទេស និងសមត្ថភាពសវនករផ្ទៃក្នុង

*អនុកម្មវិធី ១.៣. ផ្សព្វផ្សាយកម្មវិធីនារីរតនៈ និងអភិវឌ្ឍន៍សេដ្ឋកិច្ចគ្រួសារ*

សកម្មភាពទី ១.៣.១. ចុះយកព័ត៌មាននៅតាមបណ្តាខេត្ត-ក្រុង និងស្ថាប័នពាក់ព័ន្ធលើវិស័យទាំង៥នៃផែនការនារីរតនៈរបស់ក្រសួងកិច្ចការនារី

សកម្មភាពទី ១.៣.២. ជួលស្ថានីយវិទ្យុចំនួន ៣ ប៉ុស្តិ៍ដើម្បីចាក់ផ្សាយឯកសារអប់រំវិទ្យុនាទី នារីរតនៈ

សកម្មភាពទី ១.៣.៣. សិក្សាជាមូលដ្ឋាន និង ប៉ាន់ប្រមាណតម្រូវការបង្កើតមុខរបរ និងជំនាញក្នុងវិស័យកែច្នៃម្ហូបអាហារក្នុងខេត្តកំពង់ចាម និង ខេត្តកំពង់ស្ពឺ



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

សកម្មភាពទី ១.៣.៤. បំពាក់បំប៉នជំនាញដល់គ្រូបង្គោល និង មន្ត្រីមជ្ឈមណ្ឌល

សកម្មភាពទី ១.៣.៥. បណ្តុះបណ្តាលជំនាញកែឆ្នៃចំណីអាហារដល់ស្ត្រីនៅសហគមន៍ដើម្បីបង្កើតមុខរបរ

សកម្មភាពទី ១.៣.៦. ពិនិត្យតាមដាន និងវាយតម្លៃលើគម្រោងកែឆ្នៃចំណីអាហារ

### ៣.៣.៤. ក្រសួងយុត្តិធម៌

#### កម្មវិធីទី ១: ពង្រឹងសេវាយុត្តិធម៌ជូនប្រជាពលរដ្ឋ

*អនុកម្មវិធីទី ១.១. ផ្សព្វផ្សាយច្បាប់ដល់ប្រជាពលរដ្ឋ ដើម្បីកាត់បន្ថយបទល្មើស*

*អនុកម្មវិធីទី ១.២ កសាងច្បាប់ខាងវិស័យយុត្តិធម៌ ដើម្បីអោយទៅជានីតិរដ្ឋ*

*អនុកម្មវិធីទី ១.៣. ធ្វើអធិការកិច្ច ដើម្បីពង្រឹងការអនុវត្តច្បាប់*

*អនុកម្មវិធីទី ១.៤. ការបណ្តុះបណ្តាលពង្រឹងសមត្ថភាពក្នុងការអនុវត្តច្បាប់*

#### កម្មវិធីទី ២: ការកសាងច្បាប់វិស័យយុត្តិធម៌

*អនុកម្មវិធីទី ២.១. ប្រជុំពិភាក្សាសេចក្តីព្រាងច្បាប់ប្រចាំសប្តាហ៍*

*អនុកម្មវិធីទី ២.២ សិក្ខាសាលាពិភាក្សាច្បាប់*

*អនុកម្មវិធីទី ២.៣. សម្ភារះបរិក្ខា*

#### កម្មវិធីទី ៣: ការត្រួតពិនិត្យលើសេវាយុត្តិធម៌ ដើម្បីពង្រឹងការអនុវត្ត

*អនុកម្មវិធីទី ៣.១. អធិការកិច្ចលើកិច្ចការរដ្ឋបាលតុលាការ*

*អនុកម្មវិធីទី ៣.២ អធិការកិច្ចពន្ធនាគារតាមរយៈអយ្យការ*

*អនុកម្មវិធីទី ៣.៣. អធិការកិច្ចការអនុវត្តសាលក្រម*

*អនុកម្មវិធីទី ៣.៤. អធិការកិច្ចចំណាយ និងចំណាយថវិកា*

#### កម្មវិធីទី ៤: ការពង្រឹងសមត្ថភាព ដើម្បីសេវាយុត្តិធម៌បានល្អ

*អនុកម្មវិធីទី ៤.១. បំពាក់បំប៉នច្បាប់ទើបចូលជាធរមានចំពោះចៅក្រម*

*អនុកម្មវិធីទី ៤.២ បំពាក់បំប៉នច្បាប់ និងជំនាញដល់ក្រឡាបញ្ជី និងមន្ត្រីក្រសួង*

## ៣.៣.៥. ក្រសួងអភិវឌ្ឍន៍ជនបទ

### កម្មវិធីទី ១: វិស័យកសាង និងលើកកំពស់សមត្ថភាព

***អនុកម្មវិធីទី ១.១. ការរៀបចំទិន្នន័យសម្រាប់ផែនការអភិវឌ្ឍន៍ជនបទ***

*សកម្មភាពទី ១.១.១. បណ្តុះបណ្តាលមន្ត្រីថ្នាក់ខេត្តចំនួន ៨ ខេត្ត ពីការកសាងផែនការហិរញ្ញវត្ថុ និងស្ថិតិមេ*

*សកម្មភាពទី ១.១.២. ជួសជុលកែលំអបន្ទប់ទាយកដ្ឋានផែនការ និងទំនាក់ទំនងសាធារណៈ*

*សកម្មភាពទី ១.១.៣. ការរៀបចំផែនការមូលដ្ឋានចម្រុះ*

*សកម្មភាពទី ១.១.៤. ការបោះពុម្ពផ្សាយឯកសារវឌ្ឍនភាពរបស់ក្រសួង អ ជ ទ*

*សកម្មភាពទី ១.១.៥. ត្រួតពិនិត្យ និងវាយតម្លៃគម្រោង*

*អនុកម្មវិធីទី ១.១.៦. ការពង្រឹងសមត្ថភាពស្ថាប័នថ្នាក់កណ្តាល*

*សកម្មភាពទី ១.១.៧. បណ្តុះបណ្តាលយេនឌ័រ និងកាស្វែងរកការគាំទ្រមតិ*

*សកម្មភាពទី ១.១.៨. ការបណ្តុះបណ្តាលចំនួន ០៣ វគ្គ*

*អនុកម្មវិធីទី ១.១.៩. ការពង្រឹងសមត្ថភាពស្ថាប័នថ្នាក់សហគមន៍*

*សកម្មភាពទី ១.១.១០. ពង្រឹងសមត្ថភាពគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ (គ.អ.ភ)*

*សកម្មភាពទី ១.១.១២. អភិវឌ្ឍន៍ភូមិចំនួន ៣ ភូមិ ក្នុងខេត្ត ស្វាយរៀង បាត់ដំបង និងប៉ៃលិន*

*សកម្មភាពទី ១.១.១៣. អប់រំក្រៅប្រព័ន្ធ*

*សកម្មភាពទី ១.១.១៤. សន្តិសុខស្បៀងជាលក្ខណៈគ្រួសារ នៅខេត្តតាកែវ និងកំពត*

*សកម្មភាពទី ១.១.១៥. ពង្រឹងការងារជំនាញមូលដ្ឋាននៅខេត្តតាកែវ និងកំពង់ស្ពឺ*

*សកម្មភាពទី ១.១.១៦. ពង្រឹងការងារជំនាញមូលដ្ឋាននៅខេត្ត ព្រៃវែង និងស្វាយរៀង*

*សកម្មភាពទី ១.១.១៧. ការអភិវឌ្ឍជនជាតិដើមភាគតិច*

### កម្មវិធីទី ២ : វិស័យស្តារកសាង និងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធជនបទ

*អនុកម្មវិធីទី ២.១. ការងារថែទាំផ្លូវលំជា ប្រចាំ ចំនួន ៨៦ ខ្សែ ប្រវែងសរុប ៩២៣.៨៣ គ.ម ស្ថិតនៅ ក្នុង ២៤ ខេត្ត-ក្រុង*

*អនុកម្មវិធី ២.២. ការងារថែទាំផ្លូវលំជាលក្ខណៈខួប ចំនួន ៦៤ ខ្សែ ប្រវែងសរុប ៦៤៦.២៥ គ.ម ស្ថិតនៅក្នុង ២៤ខេត្ត-ក្រុង*

*អនុកម្មវិធី ២.៣. ការសាងសង់ផ្លូវកំរាលកៅស៊ូ ប្រវែង ៨០០ គម ស្ថិតនៅ ... ខេត្ត-ក្រុង*

### កម្មវិធីទី ៣: វិស័យលើកកំពស់សុខភាព អនាម័យ និងសេដ្ឋកិច្ចជនបទ

***អនុកម្មវិធីទី ៣.១. ការផ្គត់ផ្គង់ទឹកស្អាតនៅតាមបណ្តាខេត្តគោលដៅចំនួន ១៥ គឺ បាត់ដំបង ពោធិសាត់ ព្រះវិហារ កំពត កំពង់ស្ពឺ កោះកុង សៀមរាប បន្ទាយមានជ័យ ស្ទឹងត្រែង ក្រចេះ ឧត្តមានជ័យ ខេត្តកែប និង ក្រុងព្រះសីហនុ***

សកម្មភាពទី ៣.១.១. សាងសង់អណ្តូងស្នប់ថ្មីចំនួន ១៦០ កន្លែង នៅខេត្តគោលដៅចំនួន ១០ គឺ : បន្ទាយមានជ័យ កំពត កោះកុង ខេត្តកែប បាត់ដំបង ព្រះវិហារ ពោធិសាត់ ក្រចេះ តាកែវ និង កំពង់ចាម

សកម្មភាពទី ៣.១.២. ជួសជុលអណ្តូងស្នប់ និង អណ្តូងលូ ចំនួន ១៥០០ អណ្តូង នៅខេត្តគោលដៅ ចំនួន ១២: បាត់ដំបង ពោធិសាត់ ព្រះវិហារ កំពត កំពង់ស្ពឺ កោះកុង សៀមរាប បន្ទាយមានជ័យ ស្ទឹងត្រែង ក្រុងកែប ក្រុងព្រះសីហនុ ឧត្តរមានជ័យ និងខេត្តកំពង់ចាម

សកម្មភាពទី ៣.១.៣. ស្តារស្រះទឹកសហគមន៍ ០៣ កន្លែង នៅកំពង់ចាម

សកម្មភាពទី ៣.១.៤. សាងសង់អាងត្រងទឹកភ្លៀងបេតុងចំណុះ ៥ ម៣ ចំនួន ៣០កន្លែង នៅខេត្តស្ទឹងត្រែង

សកម្មភាពទី ៣.១.៥. រៀបចំប្រព័ន្ធចែកចាយទឹកស្អាតនៅសហគមន៍ ១ កន្លែង នៅខេត្តស្ទឹងត្រែង

***អនុកម្មវិធីទី ៣.២ លើកកំពស់ការយល់ដឹងអនាម័យជនបទ***

សកម្មភាពទី ៣.២.១. រៀបចំបណ្តាញអនុវត្តសកម្មភាពគម្រោងតាមភូមិគោលដៅ និងការកសាងសមត្ថភាពអ្នកស្ម័គ្រចិត្តតាមភូមិ និង មន្ត្រីមន្ទីរ អ.ជ.ប ដែលអនុវត្តគម្រោង

សកម្មភាពទី ៣.២.៣. ជម្រុញ និងលើកកំពស់ការអនុវត្តអនាម័យល្អ តាមភូមិគោលដៅ ទាំង ៨០ ក្នុងខេត្ត ៨ គឺ ខេត្តតាកែវ ខេត្តប៉ៃលិន ខេត្តបន្ទាយមានជ័យ ខេត្តកំពង់ចាម ខេត្តកែប និង ខេត្តស្ទឹងត្រែង

អនុកម្មវិធីទី ៣.២.៣. ផ្តល់បច្ចេកទេសជំនាញ ដើម្បីបង្កើតមុខរបរ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

សកម្មភាពទី ៣.២.៤. បណ្ដុះបណ្ដាលបច្ចេកទេសផលិតចង្ក្រាន នាងកញ្ច្រី និងចង្ក្រាន ជីវៈឧស្ម័ននៅខេត្តកំពង់ឆ្នាំង តាកែវ និងកំពត

សកម្មភាពីទី ៣.២.៥. ផ្សព្វផ្សាយទីផ្សារចង្ក្រាននាងកញ្ច្រី និងចង្ក្រានជីវៈឧស្ម័ន

### ៣.៣.៦. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

#### កម្មវិធីទី១ - បង្កើនផលិតភាព និងពិពិធកម្មកសិកម្ម

***អនុកម្មវិធី ១.១. ការគ្រប់គ្រងកែលម្អជីជាតិដី និង ការសិក្សាចំណាត់ថ្នាក់ដី សម្រាប់កំណត់តំបន់ដាំដុះ និងផែនការប្រើប្រាស់ដីធ្លី***

***អនុកម្មវិធី ១.២. ការការពារដំណាំកសិកម្ម និងការបង្កើនទិន្នផលដំណាំដោយប្រព័ន្ធគ្រប់គ្រងដំណាំចម្រុះ***

***អនុកម្មវិធី ១.៣. កែលំអប្រព័ន្ធព័ត៌មានស្ថិតិ កសិកម្ម***

***អនុកម្មវិធី ១.៤. ជម្រុញផលិតកម្មសត្វ ត្រួតពិនិត្យ អនាម័យសត្វ និង ប្រយុទ្ធប្រឆាំង នឹង ជម្ងឺឆ្លងសត្វ***

***អនុកម្មវិធី ១.៥. ជម្រុញការត្រួតពិនិត្យ និងការគ្រប់គ្រងសម្ភារៈកសិកម្ម***

***អនុកម្មវិធី ១.៦. បង្កើនការយល់ដឹងអំពីបច្ចេកទេសប្រើប្រាស់ និងគ្រប់គ្រងគ្រឿងយន្តកសិកម្ម***

***អនុកម្មវិធី ១.៧. ពង្រឹង និងជម្រុញការងារផ្សព្វផ្សាយកសិកម្ម***

***អនុកម្មវិធី ១.៨. ពង្រឹង និងជម្រុញការវិនិយោគឯកជនពាក់ព័ន្ធ និងការបង្កើនផលិតភាពកសិកម្ម***

#### កម្មវិធីទី២ - ជម្រុញការចូលទីផ្សារនៃផលិតកម្មកសិកម្ម

***អនុកម្មវិធី ២.១. បង្កើនការយល់ដឹងការកែច្នៃកសិផល និងបច្ចេកវិទ្យាក្រោយពេលប្រមូលផលកសិផល***

***អនុកម្មវិធី ២.២ ពង្រឹងយន្តការត្រួតពិនិត្យ និងអនុវត្តវិធានការអនាម័យ និងភូតគាមអនាម័យលើផលិតផលកសិកម្ម និងលើកកំពស់ស្តង់ដា គុណភាព សុវត្ថិភាពកសិផល***

#### កម្មវិធីទី៣ - ពង្រឹងស្ថាប័នក្របខ័ណ្ឌច្បាប់ និងអភិវឌ្ឍន៍ធនធានមនុស្ស

***អនុកម្មវិធី ៣.១. លើកកំពស់ការអភិវឌ្ឍ និងពង្រឹងក្របខ័ណ្ឌច្បាប់***



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

**កម្មវិធីទី៤ - ការគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាព**

*អនុកម្មវិធី ៤.១. ពង្រឹងការគ្រប់គ្រង និងអភិវឌ្ឍន៍សហគមន៍នេសាទ*

*អនុកម្មវិធី ៤.២ កែទម្រង់ឡូត៍នេសាទ*

*អនុកម្មវិធី ៤.៣. ជម្រុញការអភិវឌ្ឍន៍វារីវប្បកម្ម*

*អនុកម្មវិធី ៤.៤. ពង្រឹងការអនុវត្តច្បាប់ និងបង្កើនការយល់ដឹងអំពីសារៈសំខាន់នៃធនធានជលផល ប្រកបដោយនិរន្តរភាព*

*អនុកម្មវិធី ៤.៥. ការងារស្រាវជ្រាវ និងអភិវឌ្ឍន៍នេសាទទឹកសាប*

*អនុកម្មវិធី ៤.៦. បង្កើនការយល់ដឹងការកែច្នៃផលជលផល និងបច្ចេកវិទ្យាក្រោយពេលប្រមូលផលជលផល*

**កម្មវិធីទី ៥ - ការគ្រប់គ្រង ធនធានព្រៃឈើ និង សត្វព្រៃប្រកបដោយនិរន្តរភាព**

*អនុកម្មវិធី ៥.១. ជម្រុញការដាំឈើឡើងវិញ និងស្តារដីព្រៃឈើរេចរិល*

*អនុកម្មវិធី ៥.២ ការធ្វើចំណាត់ថ្នាក់ដីព្រៃឈើ ការកំណត់ព្រំប្រទល់ដែនព្រៃឈើ*

*អនុកម្មវិធី ៥.៣. ទប់ស្កាត់ លុបបំបាត់ និងបង្ក្រាបការកាប់រាន ដុត ឈូសឆាយ និងហ៊ុំព័ទ្ធដីព្រៃ ដើម្បីយកធ្វើជាកម្មសិទ្ធិ*

*អនុកម្មវិធី ៥.៤. ពង្រឹង និងជម្រុញការវិនិយោគលើការអភិវឌ្ឍន៍វិស័យព្រៃឈើ និងទីផ្សារផល-អនុផលព្រៃឈើ*

*អនុកម្មវិធី ៥.៥. ពង្រឹងប្រសិទ្ធភាពក្នុងការគ្រប់គ្រង ការអភិរក្សធនធានព្រៃឈើ និងសត្វព្រៃ*

*អនុកម្មវិធី ៥.៦. ជម្រុញការចូលរួមចំណែកនៃវិស័យព្រៃឈើ ទៅក្នុងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងកាត់បន្ថយភាពក្រីក្រដោយពង្រឹង ការគ្រប់គ្រង និងរៀបចំសហគមន៍ព្រៃឈើ*

*អនុកម្មវិធី ៥.៧. បង្កើនយល់ដឹងសាធារណៈអំពីសារៈប្រយោជន៍នៃព្រៃឈើ និងផ្សព្វផ្សាយអំពីគោលនយោបាយព្រៃឈើ*

### ៣.៣.៧. ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ

**កម្មវិធីទី១ - អភិវឌ្ឍន៍ការអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈ ឱ្យប្រកបដោយគុណភាព និងមានការចូលរៀន**



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

### ដោយសមធម៌

*អនុកម្មវិធី ១.១. ពង្រឹង និងពង្រីកសេវាលេខាធិការដ្ឋាន គណៈកម្មាធិការជាតិបណ្តុះបណ្តាល*

*អនុកម្មវិធី ១.២. ផ្តល់សេវាបច្ចេកទេសការងារគ្រប់គ្រងគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ*

*អនុកម្មវិធី ១.៣. កែលំអគុណភាព និងប្រសិទ្ធភាពដល់គ្រឹះស្ថានបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈរយៈពេលវែង*

*អនុកម្មវិធី ១.៤. កែលំអគុណភាព និងប្រសិទ្ធភាពដល់គ្រឹះស្ថានបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈរយៈពេលខ្លី*

*អនុកម្មវិធី ១.៥. មូលនិធិជាតិបណ្តុះបណ្តាលដើម្បីកាត់បន្ថយភាពក្រីក្រ*

*អនុកម្មវិធី ១.៦. ធ្វើអោយប្រពន្ធ័អប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈធានាបាននូវគុណភាព*

*អនុកម្មវិធី ១.៧. អភិវឌ្ឍប្រព័ន្ធព័ត៌មានទីផ្សារការងារ និងធានានូវការហ្វឹកហ្វឺនកូនជាង*

*អនុកម្មវិធី ១.៨. ផ្តល់សេវាអប់រំពិសេស*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ជំពូកទី ៦

# ការអនុវត្តថវិកា

## ១. ការបែងចែកឥណទានថវិកា

### ១.១. ការបែងចែកឥណទាន

**ច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ** ដែលអនុម័តដោយរដ្ឋសភា វិភាជន៍ឥណទានទៅតាមក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈប្រហាក់ប្រហែល ដោយឆ្លុះបញ្ចាំងឱ្យឃើញផងដែរនូវថវិកាឧបសម្ព័ន្ធ និងថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ទៅតាមប្រភេទចំណាយចរន្ត និងចំណាយមូលធន ។ ក្រោយពីច្បាប់នេះត្រូវបានរដ្ឋសភាអនុម័ត និងព្រឹទ្ធសភាពិនិត្យយល់ព្រម ច្បាប់នេះត្រូវប្រកាសអោយប្រើដោយព្រះរាជក្រម ដែលឡាយព្រះហស្ថលេខាដោយព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ។

ឥណទានថវិកា ដែលបានអនុម័តដោយច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ត្រូវបានបែងចែកលម្អិតនៅក្នុងផ្នែកក្នុងប្រភេទនីមួយៗទៅតាមលក្ខណៈ និងគោលដៅនៃឥណទានថវិកា ដោយអនុក្រឹត្យរបស់រាជរដ្ឋាភិបាល ។ បន្ទាប់ពីច្បាប់ស្តីពីហិរញ្ញវត្ថុប្រចាំឆ្នាំចូលជាធរមាន ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវរៀបចំអនុក្រឹត្យបែងចែកឥណទានថវិកាតាមជំពូក ដើម្បីដាក់ជូននាយករដ្ឋមន្ត្រីចុះហត្ថលេខា ។ ការបែងចែកឥណទានត្រៀមបម្រុង (ចំណាយចរន្ត «បន្ទុកហិរញ្ញវត្ថុ» និង «ចំណាយមិនបានគ្រោងទុក» ដែលទុកសម្រាប់សងការប្រាក់នៃប្រាក់ខ្ចី និងបន្ទុកហិរញ្ញវត្ថុផ្សេងៗព្រមទាំងឥណទានត្រៀមបម្រុងសម្រាប់ចំណាយផ្សេងៗ លើមុខសញ្ញាដែលកើតឡើងជាយថាហេតុ) តាមក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈប្រហាក់ប្រហែលនីមួយៗត្រូវធ្វើឡើងដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។ ការរៀបចំថវិកាតាមកម្មវិធី ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ប្លង់គណនីថ្មី និង និងមាតិកាថវិកាថ្មីដែលឆ្លុះបញ្ចាំងនូវប្លង់គណនីនេះ មានគោលដៅដូចតទៅ៖

- បែកចែកចំណាយថវិកាតាម **ចំណាត់ថ្នាក់សេដ្ឋកិច្ច (ជំពូក ៦០**- ការទិញ **ជំពូក ៦១**- សេវាខាងក្រៅ **ជំពូក ៦២**- សេវាខាងក្រៅផ្សេងៗ **ជំពូក ៦៣**- ពន្ធ និងអាករ **ជំពូក ៦៤**- បន្ទុកបុគ្គលិក **ជំពូក ៦៥** - ឧបត្ថម្ភកធន និងជំនួយសង្គម ) ។ ចំណាត់ថ្នាក់មាតិកាថ្មីឆ្លុះបញ្ចាំងពីគណនីនៃគណនេយ្យជាតិ និងប្លង់គណនីថ្មី ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

- បែងចែកចំណាយថវិកា តាម **ចំណាត់ថ្នាក់មុខងារ** (រដ្ឋបាលទូទៅ រដ្ឋបាលសង្គមកិច្ច រដ្ឋបាលហិរញ្ញវត្ថុ ការពារជាតិ និងសន្តិសុខ) ។ នៅក្នុងផ្នែកនីមួយៗ ឥណទានថវិកាត្រូវបានបែងចែកតាមក្រសួង ស្ថាប័ន ។
- បែងចែកចំណាយថវិកា ទៅតាម **កម្មវិធី** ។

ការបែងចែកឥណទានថវិកានៅក្នុងជំពូកនីមួយៗ ទៅតាមគណនី និង អនុគណនី ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ បន្ទាប់ពីអនុក្រឹត្យបែងចែកឥណទានថវិកា ត្រូវបានចុះហត្ថលេខាដោយនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុរៀបចំប្រកាស បែងចែកឥណទានថវិការបស់ក្រសួង ស្ថាប័ន តាមគណនី អនុគណនី តាមរដ្ឋបាលកណ្តាល និង រដ្ឋបាលខេត្ត- ក្រុង ។

រដ្ឋមន្ត្រី ប្រធានស្ថាប័ន និងប្រធានអង្គភាពសាធារណៈ ប្រហាក់ប្រហែលជាអាណាប័កដើមខ្សែនៃថវិការបស់ខ្លួន ទាំងនៅរដ្ឋបាលថ្នាក់ជាតិ និងទាំងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ តាមខ្សែបណ្តោយដែលស្ថិតក្រោមឱវាទ ។ អាណាប័កដើមខ្សែជាអ្នកបញ្ជាចំណូល និងបញ្ជាចំណាយថវិកាតាមផ្នែករៀងៗខ្លួន ។

រដ្ឋមន្ត្រី ប្រធានស្ថាប័ន និង ប្រធានអង្គភាពសាធារណៈ ប្រហាក់ប្រហែល អាចប្រគល់សិទ្ធិជូនអភិបាលរដ្ឋបាលថ្នាក់ក្រោមជាតិ ជាអាណាប័កផ្ទេរសិទ្ធិ សម្រាប់កិច្ចប្រតិបត្តិការហិរញ្ញវត្ថុនៃថវិកាក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ រដ្ឋមន្ត្រី ប្រធានស្ថាប័ន និង ប្រធានអង្គភាពសាធារណៈប្រហាក់ប្រហែល ដែលជាអាណាប័កដើមខ្សែនៃថវិការបស់ខ្លួនអាចប្រគល់សិទ្ធិជូនប្រធានអង្គភាពក្រោមឱវាទប្រធានមន្ទីរជំនាញខេត្ត និងរាជធានី ជាអាណាប័កផ្ទេរសិទ្ធិសម្រាប់កិច្ចប្រតិបត្តិការហិរញ្ញវត្ថុនៃថវិកា បន្ទាប់ពីមានការយល់ព្រមជាមុនពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

### ១.២. ការធ្វើវិសោធនកម្មលើការបែងចែកឥណទាន

ដោយសារតែការព្យាករណ៍ចំណូល និងចំណាយមិនបានសុក្រឹត ដែលបង្កើតអោយមានភាពមិនច្បាស់លាស់នៅក្នុងការអនុវត្តថវិកា ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈបានបើកច្រកអោយរាជរដ្ឋាភិបាល អោយមានការកែប្រែការបែងចែកឥណទាន នៅពេលអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុប្រចាំឆ្នាំ ។

ការផ្ទេរឥណទានពីក្រសួង ស្ថាប័ន ឬ អង្គភាពសាធារណៈប្រហាក់ប្រហែលមួយទៅមួយទៀត ត្រូវកំណត់ដោយ **ច្បាប់ហិរញ្ញវត្ថុកែតម្រូវ** ។ ប៉ុន្តែការផ្ទេរឥណទានពីក្រសួងមួយ ពីស្ថាប័ន ឬ ពីអង្គភាពសាធារណៈប្រហាក់ប្រហែល មួយទៅមួយទៀត ដោយភាពចាំបាច់នៃការងារពិនិត្យឡើងវិញ ឬ ពង្រឹងរចនាសម្ព័ន្ធ ឬ រដ្ឋបាលរបស់រាជរដ្ឋាភិបាល អាចប្រព្រឹត្តទៅបានដោយ **អនុក្រឹត្យ** ក្នុងករណីការផ្ទេរឥណទាននេះ មិនកែប្រែមុខ


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ចំណាយ និងការបែងចែកឥណទានតាមជំពូកនីមួយៗទេ ។ ការផ្ទេរឥណទានថវិកា គឺជាការកែប្រែឡើងវិញនូវមុខសញ្ញាចំណាយនៃឥណទានថវិកានោះ ។ ដូច្នេះហើយ ទើបច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈតម្រូវអោយការផ្ទេរឥណទានថវិកានេះត្រូវអនុម័តដោយអនុក្រឹត្យ ដែលចុះហត្ថលេខាដោយនាយករដ្ឋមន្ត្រី តាមសំណើរបស់រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

ការបង្វែរឥណទានពីជំពូកមួយទៅជំពូកមួយ នៅផ្ទៃក្នុងថវិការបស់ក្រសួង ស្ថាប័ន ឬ អង្គភាពសាធារណៈប្រហាក់ប្រហែលត្រូវធ្វើឡើងដោយអនុក្រឹត្យ ក្នុងករណីមិនកែប្រែឥណទានចំណាយមូលធនសម្រាប់វិនិយោគទៅជាឥណទានចំណាយចរន្តសម្រាប់ដំណើរការ ។ ទន្ទឹមនឹងនេះ រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចធ្វើសំណើអនុក្រឹត្យបែងចែកឥណទានថវិកា ដែលកត់ត្រានៅក្នុង **ចំណាយមិនបានគ្រោងទុក** ក្រោមរូបភាពនៃឥណទានបន្ថែមជាគុណប្រយោជន៍ដល់ជំពូកផ្សេងៗរបស់ក្រសួង ស្ថាប័ន ឬ អង្គភាពសាធារណៈប្រហាក់ប្រហែលនានា ដើម្បីទូទាត់ចំណាយដែលមិនបានគ្រោងទុក ។

ម៉្យាងវិញទៀត រាជរដ្ឋាភិបាលអាចចេញអនុក្រឹត្យបន្ថែមឥណទាន ដើម្បីអោយក្រសួង ស្ថាប័នប្រើប្រាស់ក្នុងករណីដែលមានគ្រោះធម្មជាតិ ឬ ភាពចាំបាច់ជាបន្ទាន់ដល់ផលប្រយោជន៍ជាតិ ដោយផ្អែកលើរបាយការណ៍របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ ឥណទាននេះ ត្រូវអនុម័តដោយច្បាប់កែតម្រូវនៃច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ដែលរាជរដ្ឋាភិបាលត្រូវសុំការយល់ព្រមពីរដ្ឋសភា និងព្រឹទ្ធសភាភ្លាម នៅពេលដែលស្ថានការណ៍ពិសេសទាំងនេះត្រូវបានចប់សព្វគ្រប់ ។

ការបង្វែរឥណទានពីគណនីមួយទៅគណនីមួយ ឬ ពីអនុគណនីមួយទៅអនុគណនីមួយនៅក្នុងជំពូកតែមួយ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ ឥណទានដែលលែងមានមុខសញ្ញាប្រើប្រាស់ នៅក្នុងការិយបរិច្ឆេទនៃឆ្នាំថវិកា អាចត្រូវបានលុបចោលដោយ ប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រោយពីបានទទួលព័ត៌មាន ពីរដ្ឋបាលថ្នាក់ជាតិ ឬ រដ្ឋបាលថ្នាក់ក្រោមជាតិ ។

ទន្ទឹមនឹងនេះ នៅពេលដែលការវិវត្តនៃចំណូល និងចំណាយស្តែងចេញឱ្យឃើញនូវការបាត់តុល្យភាពថវិកា រដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចចេញជាប្រកាស ដើម្បីបង្កកមួយចំណែក ឬ ទាំងស្រុងនៃប្រភេទឥណទានមួយចំនួន ដែលបានអនុម័តនៅក្នុងច្បាប់ហិរញ្ញវត្ថុ ។ ក្នុងករណីដែលការបាត់តុល្យភាពនេះមានលក្ខណៈធ្ងន់ធ្ងររាជរដ្ឋាភិបាល អាចធ្វើនីតិវិធីតាមអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយលុបចោលមួយចំណែក ឬ ទាំងស្រុងនៃប្រភេទឥណទានមួយចំនួន ដែលបានអនុម័តក្នុងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ។

ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុបានបើកច្រក អោយធ្វើនិយ័តភាវូបនីយកម្មនៃការប្រែប្រួលឥណទានថវិកា



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

នៅក្នុងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំបន្ទាប់ ប្រសិនបើច្បាប់កែតម្រូវនៃច្បាប់ហិរញ្ញវត្ថុពុំអាចធ្វើទៅកើត ក្នុងត្រីមាសទី ៤ នៃការិយបរិច្ឆេទនៃច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំសម្រាប់ការគ្រប់គ្រងឆ្នាំនីមួយៗ ។

## ២. ការធ្វើវិសោធនកម្មថវិកា

យើងឃើញពីខាងដើមថា ទោះបីជាការរៀបចំថវិកាមានលក្ខណៈសុក្រឹតយ៉ាងណាក៏ដោយ ការអនុវត្តថវិកាទាមទារអោយមានការធ្វើវិសោធនកម្មនៃច្បាប់ស្តីពីហិរញ្ញវត្ថុប្រចាំឆ្នាំ ដើម្បីអោយថវិកាឆ្លុះបញ្ចាំងនូវទិដ្ឋភាពប្រាកដនិយម ។ ការធ្វើវិសោធនកម្មត្រូវធ្វើឡើងទៅតាមគោលការណ៍ «**អ្នកដែលអនុម័តថវិកា គឺជាអ្នកត្រូវអនុម័តលើវិសោធនកម្មថវិកា**» ។

រដ្ឋសភាអនុម័តច្បាប់ស្តីពីហិរញ្ញវត្ថុប្រចាំឆ្នាំ ដោយបែងចែកឥណទានថវិកាតាមក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈប្រហាក់ប្រហែល ដោយឆ្លុះបញ្ចាំងនូវថវិកាឧបសម្ព័ន្ធ និងថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ទៅតាមប្រភេទចំណាយចរន្ត និងចំណាយមូលធន ដូចមាននៅក្នុង **តារាង «ខ» ចំណាយថវិកាទូទៅរបស់រដ្ឋ តារាង «គ១» ចំណាយជាមូលធននៃថវិកាទូទៅរបស់រដ្ឋ (ឥណទាននៃកម្មវិធី) តារាង «គ២» ចំណាយជាមូលធននៃថវិកាទូទៅរបស់រដ្ឋ (ឥណទាននៃកម្មវិធី) តារាង «គ៣» ចំណាយជាមូលធននៃថវិកាទូទៅរបស់រដ្ឋ (ឥណទាននៃកម្មវិធី និង ឥណទានភ្ជាប់សន្យា) តារាង «ឃ» ចំណាយជាមូលធននៃថវិកាទូទៅរបស់រដ្ឋ (ឥណទានភ្ជាប់សន្យា និង ឥណទានទូទាត់)** ដែលជាតារាងភ្ជាប់ជាមួយនឹងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំនីមួយៗ ។

ការកែប្រែផ្សេងៗទៀតលើ **ច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ** ក្រៅពីអ្វីដែលបានលើកឡើងនៅក្នុងផ្នែក ទី២ ដែលពាក់ព័ន្ធនឹងវិសោធនកម្មលើការបែងចែកឥណទានថវិកា អាចធ្វើទៅបាននៅក្នុងអំឡុងពេលនៃឆ្នាំថវិកាតាមរយៈ **ច្បាប់កែតម្រូវនៃច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ** ដែលត្រូវដាក់ជូនរដ្ឋសភា និងព្រឹទ្ធសភាអនុម័ត ដូចការអនុម័តច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំដែរ (មាត្រា ៦២នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ)។

## ៣. កម្មវិធីសកម្មភាពជាអាទិភាព

នៅក្នុងឆ្នាំ ២០០០ រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតឡើងនូវក្របខ័ណ្ឌ និង យន្តការដើម្បីអនុវត្ត **កម្មវិធីសកម្មភាពជាអាទិភាព** (Priority Action Program) ដែលជាកម្មវិធីកំណែទម្រង់ថវិកាមួយដើម្បីធានានូវការអនុវត្ត អោយមានប្រសិទ្ធភាពនូវគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងការកាត់បន្ថយភាពក្រីក្រ និង បង្កើត


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

បាននូវល័ក្ខខ័ណ្ឌគ្រប់គ្រាន់សំរាប់ការហក់ឡើងនៃសេដ្ឋកិច្ចជាតិ និង ធានាអោយមាននូវការបែងចែកប្រកបទៅដោយសមធម៌ នូវផ្លែផ្កាដែលបានមកពីកំណើនសេដ្ឋកិច្ចនេះ ។

**កម្មវិធីសកម្មភាពជាអាទិភាព** ធានាអោយបាននូវការផ្លាស់ប្តូរប្រកបដោយគុណភាព តាមរយៈការបន្ថយការត្រួតពិនិត្យហិរញ្ញវត្ថុមុនចំណាយ (Ex-ante control ) និង ពង្រឹងការត្រួតពិនិត្យក្រោយចំណាយ (Ex-post audit) ដើម្បីអនុវត្តអោយបានសម្រេច តាមគោលនយោបាយជម្រុញកិច្ចអភិវឌ្ឍន៍អោយបានដល់ភូមិ- ឃុំ ។ វិធានការទាំងនេះ គឺ ការកំណត់នូវបទដ្ឋានបច្ចេកទេសក្នុងការពិនិត្យ និង តាមដានការចំណាយថវិកា អោយចំទិសដៅអាទិភាពរបស់វិស័យនីមួយៗ និង អោយបានដល់អង្គភាពមូលដ្ឋាននៅតាមស្រុក ភូមិ និង ឃុំ ដោយបានកាត់បន្ថយនូវនីតិវិធីក្នុងការបើកផ្តល់ថវិកាសំរាប់វិស័យអាទិភាព ដោយធ្វើអោយមន្ទីរជំនាញ និង អង្គភាពថ្នាក់កណ្តាលដែលជ្រើសរើសដើម្បីអនុវត្តកម្មវិធីសកម្មភាព ជាអាទិភាព ដំណើរការជា **អង្គភាពគ្រប់គ្រងថវិកា** (Budget Management Center-BMC) ដែលអាចគ្រប់គ្រងថវិកាដោយខ្លួនឯងផ្ទាល់ នៅក្នុងក្រសួងដែលអនុវត្តនូវ **កម្មវិធីសកម្មភាពជាអាទិភាព** ក្នុងគោលដៅសម្រួលដល់ការតាមដានការអនុវត្តកម្មវិធី ។ ក្នុងន័យនេះមានការដាក់អោយអនុវត្តនូវការត្រួតពិនិត្យលទ្ធផលដែលសម្រេចបានក្រោយចំណាយ ដោយប្រៀបធៀបនឹងគោលដៅ ។

ការបង្កើត **អង្គភាពគ្រប់គ្រងថវិកា** គឺជាវិធានការមួយដើម្បីបង្កើនប្រសិទ្ធភាពក្នុងការអនុវត្តចំណាយថវិកា ជៀសវាងនូវការយឺតយ៉ាវ និង ភាពមិនទៀតទាត់ក្នុងការបើកផ្តល់ថវិកា និងបង្កលក្ខណៈអោយមានភាពទន់ភ្លន់សម្រាប់មន្ត្រីនៃអង្គភាពជំនាញក្នុងការគ្រប់គ្រង អនុវត្តផែនការសកម្មភាព និងផ្តល់សេវាសាធារណៈ អោយមានប្រសិទ្ធភាពខ្ពស់ ។ អង្គភាពគ្រប់គ្រងថវិកា គឺជាអង្គភាពមួយ ដែលទទួលខុសត្រូវផ្ទាល់ចំពោះថវិកាដែលខ្លួនទទួលបាន ហើយមានលក្ខណៈសម្បត្តិដូចតទៅ៖

- មានថវិកាផ្ទាល់ខ្លួន ។
- មានក្រុមគ្រប់គ្រងផ្ទាល់ខ្លួន ដែលទទួលខុសត្រូវក្នុងការអនុវត្តថវិកា និងការផ្តល់សេវាសាធារណៈ ។
- មានផែនការការងារសកម្មភាពដែលត្រូវបំពេញ ។
- ត្រូវផ្ទៀងផ្ទាត់លទ្ធផលដែលទទួលបាន ជាមួយគោលដៅដែលបានដាក់ចេញនៅក្នុងផែនការ ។

ក៏ប៉ុន្តែក្នុងការអនុវត្ត **ផែនការសកម្មភាពជាអាទិភាព** មិនអាចប្រព្រឹត្តទៅតាមនិតិវិធីធម្មតា ដែលតម្រូវអោយមាន ជាបឋមអោយធានាចំណាយ កិច្ចជំរះបញ្ជី ការធ្វើអាណត្តិបើកប្រាក់ និង ទើបអាច បើកផ្តល់ប្រាក់ជូន ។



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ដូច្នេះ ទើបក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បានដាក់អោយអនុវត្តនូវនីតិវិធីបុរេប្រទានសម្រាប់ការអនុវត្ត **ផែនការសកម្មភាពជាអាទិភាព** ដើម្បីជួយសម្រួលក្នុងការបើកផ្តល់ និង កាត់បន្ថយនីតិវិធីត្រួតពិនិត្យជាមុន ដែលមានលក្ខណៈតឹងតែង និង មានលក្ខណៈមជ្ឈការខ្លាំងពេក ។

ដើម្បីអាចទទួលប្រាក់បុរេប្រទាន **អង្គភាពគ្រប់គ្រងថវិកា** ត្រូវលើកសំណើសុំបុរេប្រទានប្រចាំត្រីមាស ទៅអាណាប័ក ដែលទទួលបន្ទុកគ្រប់គ្រងឥណទាន សំរាប់បើកផ្តល់ និង កត់ត្រានូវមុខចំណាយដែលខ្លួនត្រូវធ្វើ ។ សំណើសុំនេះត្រូវភ្ជាប់មកជាមួយនូវផែនការសកម្មភាពរបស់អង្គភាពចំណាយនីមួយៗ ដោយមានរាយមុខចំណាយ និង គោលដៅដែលត្រូវសំរេចប្រចាំត្រីមាសនីមួយៗ ។ ផែនការសកម្មភាពនេះ ត្រូវយកទៅផ្ទៀងផ្ទាត់ជាមួយ លទ្ធផលដែលត្រូវសំរេចបាន នៅក្នុងដំណាក់កាលធ្វើសវនកម្ម ។

ក្រោយពីបានទទួលលិខិតអនុញ្ញាតផ្តល់បុរេប្រទាន និង ក្រោយពីបានពិនិត្យឃើញថាត្រឹមត្រូវ ហើយ គណនេយ្យករមុខការរបស់រតនាគារត្រូវ រៀបចំនូវគណនេយ្យទ្វេរភាគ សំរាប់កិច្ចដំណើរការនៃផែនការសកម្មភាព ការងារជាអាទិភាព កត់ត្រាខាងឥណពន្ធ គណនី (ចំណាយបណ្តោះអាសន្ន) កត់ត្រាខាងឥណទាន គណនី (បេឡាសាច់ប្រាក់) ឬ គណនីប្រាក់បញ្ញើរបស់ **អង្គភាពគ្រប់គ្រងថវិកា** ។

**អង្គភាពគ្រប់គ្រងថវិកា** ត្រូវផ្តល់លិខិតយុត្តិការចំណាយទាំងអស់អោយអាណាប័ក ដើម្បីធ្វើការទូទាត់ ប្រាក់ដែលបានចំណាយជាបណ្តើរៗ ដោយមិនចាំបាច់រង់ចាំចំណាយអោយអស់នូវបុរេប្រទានប្រចាំត្រីមាសឡើយ ។ ប្រការនេះ នឹង ជួយសម្រួលដល់កិច្ចដំណើរការនៃអង្គភាព គ្រប់គ្រងថវិកា និង ជួយពង្រឹងដល់ការគ្រប់គ្រង ហិរញ្ញវត្ថុរបស់អង្គភាពគ្រប់គ្រងថវិកា ។ លិខិតយុត្តិការទាំងអស់ដែលត្រូវបញ្ជូនទៅឱ្យអាណាប័កត្រូវប្ញកសរុប ដោយមានដីកាអម ។

អាណាប័កត្រូវបញ្ជូននូវអាណត្តិបើកប្រាក់ សលាកប័ត្រកត់ត្រាចំណាយ និង ត្រួតពិនិត្យ ហិរញ្ញវត្ថុ ព្រម ទាំងសក្ខីប័ត្រយុត្តិការមកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីធ្វើនិយ័តភាពចំណាយបុរេប្រទាន ។ សំណុំលិខិត ទាំងនេះ ត្រូវបានបញ្ជូនជាបន្តទៅមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ដើម្បីពិនិត្យភាពត្រឹមត្រូវ ផ្តល់យោបល់ លើសំណុំលិខិត ចុះបញ្ជីកាចំណាយតាមមាតិកាថវិកា និង ចុះទិដ្ឋាការ ។ មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ត្រូវផ្ទៀងផ្ទាត់លទ្ធផលដែល សម្រេចបាន ជាមួយនឹងផែនការសកម្មភាពរបស់អង្គភាពគ្រប់គ្រងថវិកានីមួយៗ ដែលបានដាក់ជូននៅពេលស្នើ សុំបុរេប្រទាន ។ បន្ទាប់មក ត្រូវបញ្ជូនសំណុំលិខិតទាំងអស់មានអាណត្តិបើកប្រាក់ និង លិខិតយុត្តិការទៅរតនាគារ ដើម្បីធ្វើនិយ័តភាពចំណាយ ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ជំពូកទី ៧

# ការគ្រប់គ្រងក្របខ័ណ្ឌមន្ត្រីរាជការ និង បញ្ជីបើកប្រាក់បៀវត្សរ៍

ការគ្រប់គ្រងចំនួនមន្ត្រីរាជការ និងការគណនាចំណាយប្រាក់បៀវត្សរ៍ នៅក្នុងការរៀបចំច្បាប់ស្តីពីហិរញ្ញវត្ថុត្រូវបានរៀបចំឡើងតាមបច្ចេកទេសផ្សេងពីគ្នា ។

## ១. ការគ្រប់គ្រងក្របខ័ណ្ឌមន្ត្រីរាជការ

ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុហិរញ្ញវត្ថុសាធារណៈមិនបាលលើកឡើងយកមកពិភាក្សា នូវបញ្ហាស្តីពីការគ្រប់គ្រងក្របខ័ណ្ឌមន្ត្រីរាជការឡើយ ។ ប្រទេស ដែលមានប្រព័ន្ធថវិកាបារាំង និង ប្រព័ន្ធថវិកាបែប **អង់គ្លេ-សាក់សុង** អនុវត្តនូវប្រព័ន្ធគ្រប់គ្រងមន្ត្រីរាជការខុសគ្នា៖

- នៅប្រទេសបារាំង ការគ្រប់គ្រងក្របខ័ណ្ឌមន្ត្រី រាជការឈរលើមូលដ្ឋាននៃចំនួនមន្ត្រី ដែលត្រូវអនុម័តដោយច្បាប់ស្តីពីហិរញ្ញវត្ថុប្រចាំឆ្នាំ (Emploi budgétaire) ពោល គឺចំនួនមន្ត្រីរាជការដែលថវិកាប្រចាំឆ្នាំអនុញ្ញាតអោយជ្រើសរើស ដើម្បីបម្រើមុខងារសាធារណៈ ។ ប្រព័ន្ធថវិកានៃព្រះរាជាណាចក្រកម្ពុជាក៏ទាមទារអោយមានតារាងចំនួនមន្ត្រីរាជការភ្ជាប់ជាឧបសម្ព័ន្ធនៃច្បាប់ស្តីពីហិរញ្ញវត្ថុប្រចាំឆ្នាំដែរ ។ ក៏ប៉ុន្តែ បន្ទុកបុគ្គលិក គឺជាប្រភេទឥណទានដែលអាចវាយតម្លៃបាន ។ ដូច្នេះ បរិមាណឥណទានអាចប្រែប្រួលទៅតាមស្ថានភាពចំនួនមន្ត្រីរាជការជាក់ស្តែងតែម្តង ។

- ប្រព័ន្ធថវិកាបែប **អង់គ្លេ-សាក់សុង** អនុវត្តនូវប្រព័ន្ធគ្រប់គ្រងមន្ត្រីរាជការ ដែលមានឈ្មោះថា «**ការគ្រប់គ្រងចំនួនកន្លែងធ្វើការក្នុងស្ថាប័ន** (Establishment control)» ពោល គឺការរៀបចំស្ថាប័នដែលធានាអោយបាន នូវការប្រើប្រាស់នូវមន្ត្រីរាជការនៃមុខងារសាធារណៈ ប្រកបដោយប្រសិទ្ធភាព៖ ចំនួនមន្ត្រី កម្រិតកាំប្រាក់បៀវត្សរ៍ និងមុខជំនាញ ត្រូវតែសមស្របនឹងការងារ ដែលត្រូវបំពេញ ។ កាំប្រាក់បៀវត្សរ៍ត្រូវបានរៀបចំឡើង ដោយមានសង្គតិភាពជាមួយនឹងវិធានដែលផ្សារភ្ជាប់ប្រាក់បៀវត្សរ៍ ទៅនឹងកាំប្រាក់ ។

នៅក្នុងប្រព័ន្ធ «**ការគ្រប់គ្រងស្ថាប័ន**» ការបែងចែករវាង **កន្លែងធ្វើការ** ដែលកំណត់តាម **មុខងារ** និងកន្លែងធ្វើការដែលមិនបានកំណត់តាមមុខងារ មានសារៈសំខាន់ខ្លាំងណាស់ ។ ក្រសួងនីមួយៗអាចជ្រើសរើស



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

មន្ត្រីរាជការ ដើម្បីបំពេញកន្លែងធ្វើការដែលនៅទំនេរ ក៏ប៉ុន្តែមិនអាចបន្ថែមចំនួនកន្លែងធ្វើការសម្រាប់ស្ថាប័ននីមួយៗឡើយ ។ ក្រសួងណាដែលចង់បន្ថែមចំនួនកន្លែងធ្វើការ ត្រូវធ្វើពាក្យមកស្នើសុំ **គណៈកម្មការមុខងារសាធារណៈ** ដែលត្រូវធ្វើការវាយតម្លៃពីកំណើនការងារក្នុងក្រសួងនោះ ឬ ផលប៉ះពាល់នៃការអនុវត្តគោលនយោបាយថ្មី ទៅលើការងារដែលត្រូវបំពេញ ហើយបន្ទាប់មកត្រូវកែប្រែចំនួនមន្ត្រីរាជការដែលក្រសួងនោះត្រូវមាន ។ ការវាយតម្លៃនេះត្រូវរៀបចំឡើង ដោយសហការយ៉ាងជិតស្និទ្ធជាមួយក្រសួងហិរញ្ញវត្ថុ ដើម្បីធានាអោយបាននូវការទទួលនូវឥណទានថវិកាបន្ថែមសមស្រប ដើម្បីផ្តល់ជូនមន្ត្រីរាជការ នៅពេលដែលចំនួនមន្ត្រីកើនឡើង ។ ដូច្នេះ ឥណទានថវិកាសម្រាប់ **បន្ទុកបុគ្គលិក** ត្រូវតែពាក់ព័ន្ធយ៉ាងជិតស្និទ្ធជាមួយនឹងបញ្ជីចំនួនមន្ត្រីរាជការនៅក្នុងស្ថាប័ន ដែលត្រូវកំណត់ដោយប្រធាន **គណៈកម្មការមុខងារសាធារណៈ**។ ប្រព័ន្ធគ្រប់គ្រងមន្ត្រីរាជការ និង **បញ្ជីបើកប្រាក់បៀវត្សរ៍** ដែលមានសមាហរណកម្មនឹងគ្នា មានសារៈសំខាន់ណាស់សម្រាប់ការគ្រប់គ្រងមុខងារសាធារណៈ ។ មន្ត្រីរាជការដែលត្រូវចុះឈ្មោះបន្ថែមទៅក្នុងបញ្ជីបើកប្រាក់បៀវត្សរ៍ ត្រូវតែជ្រើសរើស ឬ តែងតាំងសម្រាប់តែកន្លែងដែលទំនេរ នៅក្នុងចំណោមនៃចំនួនមន្ត្រីដែលត្រូវបានអនុម័តប៉ុណ្ណោះ ។

ទស្សនាទានរបស់បារាំងស្តីពី «**ចំនួនមន្ត្រីក្នុងថវិកា** (Emploi budgétarie)» មានលក្ខណៈខុសពីទស្សនាទាន «**ការគ្រប់គ្រងចំនួនកន្លែងធ្វើការក្នុងស្ថាប័ន** (Establishment control)» ។ «**ចំនួនមន្ត្រីក្នុងថវិកា**» គឺជាចំនួនអាសនៈដែលក្រសួងនីមួយៗត្រូវកំណត់ ដើម្បីអាចជ្រើសរើសមន្ត្រីរាជការ ។ អាសនៈ ឬ «**ចំនួនមន្ត្រីក្នុងថវិកា**» នេះ ត្រូវតែបង្កើតឡើងដោយច្បាប់ ដូចជា ច្បាប់ស្តីពីហិរញ្ញវត្ថុប្រចាំឆ្នាំ ឬ ច្បាប់បង្កើតក្រសួងនោះ ដែលមានឧបសម្ព័ន្ធ ជាតារាងមន្ត្រីរាជការ ដោយកំណត់នូវចំនួនមន្ត្រីរាជការ និង រយៈពេលដែលត្រូវជ្រើសរើសមន្ត្រីដើម្បីបំពេញតាមភារៈកិច្ចរបស់ក្រសួងនីមួយៗ ។ «**ចំនួនមន្ត្រីក្នុងថវិកា**» ត្រូវមានចំណាត់ថ្នាក់ទៅតាម **ឋានៈ** និង **យថាប្រភេទ** នៅក្នុងមុខងារសាធារណៈ ជាទូទៅ គឺ ÷

- ប្រភេទ «**ក**» សម្រាប់ ឧត្តមមន្ត្រី
- ប្រភេទ «**ខ**» សម្រាប់ វរៈមន្ត្រី
- ប្រភេទ «**គ**» សម្រាប់ មន្ត្រីក្រមការ

អាសនៈនេះអាចតម្រែតម្រង់ទៅតាមសភាពការណ៍ជាក់ស្តែង ។ គេអាចជ្រើសរើសមន្ត្រីរាជការ ដើម្បីបំពេញតួនាទី ដែលខ្ពស់ជាងឋានៈរបស់គេនោះ ក៏ប៉ុន្តែ គេមិនអាចជ្រើសរើសមន្ត្រីរាជការដែលមានឋានៈខ្ពស់ ដើម្បីយកមកបំពេញតួនាទីទាបជាងនោះទេ ពោល គឺ «អាសនៈត្រូវតែធំជាងទំហំមនុស្សដែលអង្គុយ» ។ ពេលខ្លះ គេអាច


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

យកអាសនៈតូចៗពីរ ដើម្បីបញ្ចូលគ្នាតែមួយ ដើម្បីជ្រើសរើសឧត្តមមន្ត្រីមួយរូប ដើម្បីបំពេញទៅតាមលក្ខណៈវិនិច្ឆ័យ ដែលបានកំណត់ ។ ទន្ទឹមនឹងនេះ គេក៏អាចជ្រើសរើសវរៈមន្ត្រីពីររូប ដើម្បីយកមកបំពេញអាសនៈរបស់ឧត្តមមន្ត្រីមួយរូបផងដែរ ក្នុងគោលដៅបំបែកអាសនៈជាពីរ ។

ច្បាប់ស្តីពីហិរញ្ញវត្ថុប្រចាំឆ្នាំមានភ្ជាប់ជាមួយនូវឧបសម្ព័ន្ធនៃចំនួនមន្ត្រីរាជការ បែងចែកតាមយថាប្រភេទ ក្រសួង ស្ថាប័ន ឥណទានថវិកាសម្រាប់ប្រាក់បៀវត្សរ៍បន្ថែម គ្រឹះស្ថានសាធារណៈ ហើយ ប្រសិនបើចាំបាច់តាមខេត្ត-ក្រុង និង រដ្ឋបាលថ្នាក់ក្រោមជាតិ ។ បទប្បញ្ញត្តិថវិកាហាមឃាត់នូវការយកគណនីពិសេសរតនាគារដើម្បីមកបើកប្រាក់បៀវត្សរ៍ ។ គេអាចគ្រប់គ្រង «**ចំនួនមន្ត្រីក្នុងថវិកា**» ដោយឈរលើមូលដ្ឋាននៃ **ចំនួនមន្ត្រីរាជការសរុប** ឬ **ចំនួនមន្ត្រីរាជការរើសថ្មីប្រចាំឆ្នាំ** ។

## ១.១. ការគ្រប់គ្រង «ចំនួនមន្ត្រីក្នុងថវិកា» តាមចំនួនមន្ត្រីរាជការសរុប

វិធីសាស្ត្រគ្រប់គ្រង «**ចំនួនមន្ត្រីក្នុងថវិកា**» តាមចំនួនមន្ត្រីរាជការសរុប គឺជាវិធីសាស្ត្រមួយយ៉ាងសាមញ្ញ ប្រសិនបើមានតារាងឧបសម្ព័ន្ធ «**ចំនួនមន្ត្រីក្នុងថវិកា**» ដោយបែងចែកតាមឆ្នាំនីមួយៗ ។ គេអាចកំណត់ «**ចំនួនប៉ុស្តិ៍ថវិកា**» តាមឆ្នាំ តាមក្រសួង-ស្ថាប័ន តាមយថាប្រភេទ និង តាមលេខកូដ ÷ ប៉ុស្តិ៍ថវិកាលេខ ២០០៧ កសហវ **ក-១២** មានន័យថា ប៉ុស្តិ៍ថវិកាសម្រាប់ឆ្នាំ ២០០៧ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ប្រភេទ ក កាំទី ១២ ។ មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុរក្សាទុកនូវតារាងប្រាក់បៀវត្សតាមឆ្នាំ ប្រភេទ និង ប៉ុស្តិ៍ថវិកា ។ នៅពេលដែលមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុទទួលបាននូវសំណើរសុំជ្រើសរើសមន្ត្រីរាជការ សម្រាប់ប៉ុស្តិ៍ថវិកាលេខ ២០០៧ កសហវ **ក-១២** មន្ត្រីនោះត្រូវពិនិត្យដើម្បីកំណត់ថា តើប៉ុស្តិ៍ថវិកានោះនៅទំនេរ ហើយមន្ត្រីដែលត្រូវបានស្នើឡើងមានឋានៈទាបជាង ឬ ស្មើនឹងប៉ុស្តិ៍ថវិកានោះ ។ បន្ទាប់មកមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអាចអោយទិដ្ឋាការលើការជ្រើសរើសនោះ ។ នៅពេលដែលមន្ត្រីត្រូវបានលុបឈ្មោះចេញពីបញ្ជីមន្ត្រីរាជការរបស់ក្រសួងមួយ (ការចូលនិវត្តន៍ ការចូលមរណៈភាព ឬ ការផ្លាស់ប្តូរក្រសួង) ប៉ុស្តិ៍ថវិកានោះអាចនៅទំនេរ ។ គេអាចជ្រើសរើសមន្ត្រីថ្មី ដើម្បីបំពេញប៉ុស្តិ៍ថវិកានោះ ។

ដើម្បីសម្រួលដល់ការគ្រប់គ្រងមន្ត្រីរាជការ ក្រសួង-ស្ថាប័នតែងតែរៀបចំនូវតារាងប៉ុស្តិ៍ថវិកា ដែលមានមន្ត្រី និង ដែលនៅទំនេរ ។ តារាងប៉ុស្តិ៍ថវិកាត្រូវបានដាក់ចូលក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុប្រចាំឆ្នាំ ជាឧបសម្ព័ន្ធ ដោយរួមទាំងច្បាប់ស្តីពីហិរញ្ញវត្ថុកែតម្រូវផងដែរ (នៅពេលមានការបង្កើតប៉ុស្តិ៍ថវិកាថ្មី ឬ ការកាត់បន្ថយចំនួនមន្ត្រី) ។

### ១.២. ការគ្រប់គ្រង «ចំនួនមន្ត្រីក្នុងថវិកា» តាមចំនួនមន្ត្រីរាជការជ្រើសថ្មីប្រចាំឆ្នាំ

វិធីសាស្ត្រនេះអាចប្រើប្រាស់បាន ប្រសិនបើយើងមិនអាចប្រើប្រាស់នូវវិធីសាស្ត្រនៃការគ្រប់គ្រង **«ចំនួនមន្ត្រីក្នុងថវិកា»** តាមចំនួនមន្ត្រីរាជការសរុប ដោយសារតែព័ត៌មានស្តីពីប៉ុស្តិ៍ថវិកាមិនច្បាស់លាស់ ។ វិធីសាស្ត្រនេះអាចត្រូវបានប្រើប្រាស់ជាឧបករណ៍បន្ថែមនឹងវិធីសាស្ត្រនៃការគ្រប់គ្រង **«ចំនួនមន្ត្រីក្នុងថវិកា»** តាមចំនួនមន្ត្រីរាជការសរុប ដើម្បីងាយស្រួលក្នុងគ្រប់គ្រងមន្ត្រីរាជការ ។ វិធីសាស្ត្រតាមគ្រប់គ្រងចំនួនមន្ត្រីជ្រើសថ្មីប្រចាំឆ្នាំតម្រូវអោយកំណត់នូវបញ្ជីឈ្មោះប៉ុស្តិ៍ថវិកាដែលបង្កើតឡើង និង បែងចែកប្រចាំឆ្នាំជូនដល់ក្រសួង- ស្ថាប័នដែលមានការពាក់ព័ន្ធ ដែលត្រូវបញ្ចូលទៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុប្រចាំឆ្នាំ ។ នៅពេលដែលក្រសួងស្នើសុំជ្រើសរើសមន្ត្រី ក្រសួងនីមួយៗគ្រាន់តែផ្តល់ដំណឹងពីប៉ុស្តិ៍ថវិកា ដែលស្នើសុំជ្រើសរើស ។ មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុគ្រាន់តែពិនិត្យមើលថា តើប៉ុស្តិ៍ថវិកានោះនៅទំនេរ ឬ អត់ ។ ពេលខ្លះ នៅពេលដែលប៉ុស្តិ៍ថវិកាត្រូវបានដាក់អោយនៅទំនេរ បេក្ខភាពត្រូវបានស្នើសុំតាមមធ្យោបាយអេឡិចត្រូនិចតែម្តង ។ វិធីសាស្ត្រនេះឈរលើមូលដ្ឋាននៃការគ្រប់គ្រងតម្រូវការរដ្ឋបាល ។ ការគ្រប់គ្រងមន្ត្រីរាជការតាមបែបផ្សេងទៀត អាចអនុវត្តបានតាមរយៈការគ្រប់គ្រងចំនួននិស្សិតដែលចូលរៀនវគ្គបណ្តុះបណ្តាល ។

## ១.៣. ការគ្រប់គ្រងវគ្គបណ្តុះបណ្តាលមន្ត្រីរាជការ

### ១.៣.១. ការគ្រប់គ្រងមន្ត្រីរាជការតាមរយៈការងារបណ្តុះបណ្តាល

ជារៀងរាល់ឆ្នាំ និស្សិតដែលរៀនចប់ទទួលបានសញ្ញាបត្រកម្រិតឧត្តមសិក្សា តែងតែដាក់ពាក្យសុំចូលជាមន្ត្រីរាជការ ។ ជាពិសេស សាលាភូមិន្ទរដ្ឋបាល គឺជាមជ្ឈមណ្ឌលបណ្តុះបណ្តាលមន្ត្រីរាជការ សម្រាប់អោយចូលបម្រើការងារនៅតាមក្រសួង- ស្ថាប័នរបស់រាជរដ្ឋាភិបាល ។ ក្នុងគោលដៅនេះ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវគោលនយោបាយផ្តល់ក្របខ័ណ្ឌជាមន្ត្រីរាជការ ដល់និស្សិតដែលប្រឡងជាប់ចូលរៀនសាលាភូមិន្ទរដ្ឋបាល ដើម្បីអោយពួកគេអាចផ្ទេរក្របខ័ណ្ឌទៅក្រសួងផ្សេងទៀតបាន នៅពេលដែលពួកគេរៀនចប់សាលានេះ ។ នៅពេលដែលពួកគេនៅជានិស្សិតនៅឡើយ និស្សិតដែលសិក្សានៅសាលាភូមិន្ទរដ្ឋបាលទទួលបាននូវក្របខ័ណ្ឌមន្ត្រីរាជការចំណុះអោយទីស្តីការគណៈរដ្ឋមន្ត្រី ។ ចំពោះគ្រឹះស្ថានឧត្តមសិក្សាដទៃទៀត ដែលមិនបណ្តុះបណ្តាលមន្ត្រីរាជការ ដូចជាសាកលវិទ្យាល័យផ្សេងៗក៏ដោយ រដ្ឋអាចផ្តល់ជាកូតានៃប៉ុស្តិ៍ថវិកា ដើម្បីបំពេញមុខងារពិសេសណាមួយ ។ ឧទាហរណ៍ ក្រសួងសុខាភិបាលត្រូវបង្កើតនូវប៉ុស្តិ៍ថវិកា (ចំនួនមន្ត្រីរាជការ) កាំ «ក» ចំនួន ១០ ហើយមន្ត្រី ៣ រូបទៀត ត្រូវបានបញ្ចូលទៅក្នុងក្របខ័ណ្ឌនៃមន្ទីរពេទ្យកាល់ម៉ែត្រ ។

វិធីសាស្ត្រនេះទាមទារអោយមានការយល់ដឹងយ៉ាងច្បាស់នៃរាល់គ្រប់វិធីបណ្តុះបណ្តាល ដើម្បីឈានចូល


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ដល់ការជ្រើសរើសបេក្ខភាពមន្ត្រីរាជការតាមរយៈការប្រឡងប្រជែង រួមទាំមានកម្មវិធីបណ្តុះបណ្តាលនៅបរទេស ។ ក្នុងន័យនេះ នៅពេលដែលនិស្សិតអាហារូបករណ៍ត្រឡប់មកពីបរទេសវិញ រាជរដ្ឋាភិបាលត្រូវផ្តល់ឱកាសដល់និស្សិតដែលរៀនចប់ទាំងនោះ នូវកាលានុវត្តិភាពដើម្បីចូលបម្រើក្នុងក្របខ័ណ្ឌមុខងារសាធារណៈ ។

### ១.៣.២. ការគ្រប់គ្រងមន្ត្រីរាជការតាមរយៈការខារបណ្តុះបណ្តាល

ជាការពិតណាស់ ការគ្រប់គ្រងនូវនិស្សិតដែលទើបនឹងរៀនចប់ ហើយដែលចង់ចូលបម្រើក្នុងក្របខ័ណ្ឌរាជការតម្រូវអោយរាជរដ្ឋាភិបាលគ្រប់គ្រងអោយបានល្អនូវនិស្សិត ដែលត្រូវបានជ្រើសរើសចូលវគ្គបណ្តុះបណ្តាលដោយឈរលើមូលដ្ឋាននៃគោលការណ៍ដូចគ្នានេះដែរ ÷ ការកំណត់នូវវិធីបណ្តុះបណ្តាលដែលឈានទៅជ្រើសរើសនិស្សិតដើម្បីអោយចូលបម្រើការងារក្នុងក្របខ័ណ្ឌរាជការ និង ការគ្រប់គ្រងការជ្រើសរើសមន្ត្រីរាជការប្រចាំឆ្នាំដើម្បីបំពេញតាមតម្រូវការរបស់មុខងារសាធារណៈ ។

ក្នុងន័យនេះ រាជរដ្ឋាភិបាលត្រូវបង្កើតនូវក្របខ័ណ្ឌសម្រាប់ច្រើនឆ្នាំ ដើម្បីផ្តល់នូវក្របខ័ណ្ឌមន្ត្រីរាជការនៅពេលដែលនិស្សិតទាំងនោះប្រឡងជាប់ចូលរៀនគ្រឹះស្ថានឧត្តមសិក្សា រហូតដល់និស្សិតនោះរៀនចប់ទទួលបានសញ្ញាប័ត្រឧត្តមសិក្សា ។ នៅពេលដែលនិស្សិតប្រឡងជាប់ចូលរៀននៅក្នុងសាលាភូមិន្ទរដ្ឋបាល ឬ ទទួលបានអាហារូបករណ៍ទៅរៀននៅបរទេស រាជរដ្ឋាភិបាលត្រូវផ្តល់ក្របខ័ណ្ឌមន្ត្រីរាជការដល់និស្សិតទាំងនោះភ្លាម ។ នៅពេលដែលនិស្សិតទាំងនោះរៀនចប់ទទួលសញ្ញាប័ត្រ ពួកគេនឹងត្រូវបែងចែកអោយចូលបម្រើការងារនៅតាមក្រសួង ស្ថាប័នតាមមុខជំនាញរបស់ខ្លួនដោយស្វ័យប្រវត្តិ ។

## ២. ការគណនាបន្ទុកបុគ្គលិកនៅក្នុងថវិកាជាតិ

**បន្ទុកបុគ្គលិក** ចែកចេញជាពីរ គឺ÷

ទីមួយ- **បៀវត្សរ៍មូលដ្ឋាន** និង

ទីពីរ- **លាភការផ្សេងៗ** ដូចជា លាភការ ប្រាក់បំណាច់ រង្វាន់ និងប្រាក់វិភាជន៍សង្គម ។

ការគណនាបន្ទុកបុគ្គលិកធ្វើឡើង ដោយឈរលើមូលដ្ឋាននៃការប៉ាន់ស្មានចំណាយមធ្យមសម្រាប់បុគ្គលិកម្នាក់ៗ ហើយត្រូវគុណនឹងចំនួនបុគ្គលិកដែលមាននៅក្នុងក្រសួង- ស្ថាប័ននីមួយៗ ។ ចំនួនបុគ្គលិកត្រូវឈរលើចំនួនជាក់ស្តែង ដោយបូកបន្ថែមនូវផែនការជ្រើសរើសបុគ្គលិកសម្រាប់ឆ្នាំថ្មី ដោយរួមទាំងបុគ្គលិកក្របខ័ណ្ឌអចិន្ត្រៃយ៍ បុគ្គលិកជាប់ជាប់កិច្ចសន្យា និងបុគ្គលិកអណ្តែត ។ ឧទាហរណ៍ នៅក្នុងឆ្នាំ ២០០៨ ប្រាក់បៀវត្សរ៍មធ្យមរបស់មន្ត្រីរាជការស្មើនឹង ២៤៦.០០០ រៀល (៦០ ដុល្លារអាមេរិក) ។ ជារួម រាជរដ្ឋាភិបាលនៅក្នុងអាណត្តិទី ៣ នៃរដ្ឋសភា


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

(ឆ្នាំ ២០០៣-២០០៨) និង នៅក្នុងអាណត្តិទី ៤ (ឆ្នាំ ២០០៨-២០១៣) មានគោលនយោបាយបង្កើនប្រាក់បៀវត្សរ៍ ចំនួន ២០% ក្នុងមួយឆ្នាំ លើប្រាក់បៀវត្សរ៍មូលដ្ឋាន ។

**លាភការផ្សេងៗ** ដូចជា លាភការ ប្រាក់បំណាច់ រង្វាន់ និង ប្រាក់វិភាជន៍សង្គមអាស្រ័យលើទំហំ នៃលាភការ និង ចំនួនមន្ត្រីរាជការដែលត្រូវទទួល ។ ម្យ៉ាងវិញទៀត លាភការអាស្រ័យលើរចនាសម្ព័ន្ធនៃប្រាក់បៀវត្សរ៍៖ បៀវត្សរ៍មូលដ្ឋាន លាភការផ្សេងៗ ប្រាក់វិភាជន៍សង្គម ។ល។ នៅពេលដែលរាជរដ្ឋាភិបាលសម្រេចបង្កើនលាភការ ចំណាយសរុបលើលាភការអាចគណនា ដោយគុណចំនួនមន្ត្រីដែលត្រូវទទួលលាភការ ជាមួយនឹងការប៉ាន់ស្មានលាភការមធ្យមសម្រាប់មន្ត្រីម្នាក់ៗ ។

ទន្ទឹមនឹងនេះ ចំណាយលើបន្ទុកបុគ្គលិក ត្រូវផ្តោតទៅលើចំនួនមន្ត្រីរាជការដែលមានក្របខ័ណ្ឌអចិន្ត្រៃយ៍។ ចំណាយបន្ទុកបុគ្គលិកកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ ដោយសារតែការវិវត្តនៅក្នុងបញ្ជីមន្ត្រីរាជការ ដែលមានមន្ត្រីដែលឡើងឋានៈជាស្វ័យប្រវត្តិ ក្នុងរយៈពេល ២ ឆ្នាំម្តង ឧទាហរណ៍ ពី **ឧត្តមមន្ត្រីថ្នាក់លេខ ៥** ទៅ **ឧត្តមមន្ត្រីថ្នាក់លេខ ៤** ។ ការវិវត្តនេះអាចឆ្លុះបញ្ចាំងតាមរយៈការគណនាសន្និស្សន៍ ដោយប្រើនូវវិធីសាស្ត្រស្ថិតិ ដែលយើងហៅថា «**ការបម្រែបម្រួលទៅតាមអាយុ និង ឆ្នាំបម្រើការងារ**» ដែលអាចចែកចេញជា កត្តាចំនួន ៤៖

- G1: ការឡើងឋានៈ និង ការឡើងថ្នាក់ដោយមិនស្វ័យប្រវត្តិ
- T: កម្រិតបច្ចេកទេសៈ ការទទួលបាននូវជំនាញថ្មី
- V: ការឡើងឋានៈ និង ការឡើងថ្នាក់ដោយស្វ័យប្រវត្តិ តាមរយៈពេលបម្រើការងារ
- G2: ការចូលបម្រើការងារ និង ការលប់ឈ្មោះចេញពីក្របខ័ណ្ឌមន្ត្រីរាជការ ដោយទទួលរងនូវផលប៉ះពាល់នៃនិន្នាការពីបញ្ញាសត្វា ÷
    - មន្ត្រីរាជការចាស់ៗបានចូលនិវត្តន៍ និង ជំនួសដោយមន្ត្រីរាជការក្មេងៗ ។ ដូច្នេះ ប្រាក់បៀវត្សរ៍មធ្យមរបស់មន្ត្រីរាជការក្មេងៗ ជាមធ្យមទាបជាងប្រាក់បៀវត្សរ៍មធ្យមរបស់មន្ត្រីរាជការចាស់ៗ ធ្វើអោយយើងអាចសន្សំបាននូវថវិកាមួយចំនួន ។
    - ទន្ទឹមនឹងនេះ មន្ត្រីរាជការចាស់ៗបានចូលនិវត្តន៍ ត្រូវជំនួសដោយមន្ត្រីរាជការក្មេងៗ ដែលមានសញ្ញាបត្រខ្ពស់ ដែលបង្កើននូវបន្ទុកបុគ្គលិកផងដែរ ។

បម្រែបម្រួលនៃចំនួនមន្ត្រីរាជការបណ្តាលមកពី៖ ការកាត់បន្ថយចំនួនមន្ត្រីរាជការ ការចូលមរណភាព



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ការលប់ឈ្មោះចេញ ការលាលែងពីតំណែង និង ជាពិសេសការដាក់មន្ត្រីរាជការអោយចូលនិវត្តន៍ (ដែលអាចគណនាបានដោយឈរលើមូលដ្ឋាននៃបញ្ជីឈ្មោះមន្ត្រីរាជការ និង បញ្ជីបើកប្រាក់បៀវត្សរ៍របស់មន្ត្រីរាជការ) ។

**ស្ថានភាពរបស់មន្ត្រីរាជការ**

ច្បាប់លេខ ៦ ចុះថ្ងៃទី ២១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីសហលក្ខន្តិកៈរបស់មន្ត្រីរាជការមិនមានកំណត់បទប្បញ្ញត្តិពាក់ព័ន្ធនឹងស្ថានភាពផ្សេងៗរបស់មន្ត្រីរាជការឡើយ ÷ ដូចជាមន្ត្រីរាជការដែលកំពុងបំពេញការងារ ដែលផ្តាច់អោយទៅបម្រើការងារនៅក្រសួងផ្សេង ការដាក់មន្ត្រីអោយនៅទំនេរដោយគ្មានប្រាក់បៀវត្សរ៍ មន្ត្រីដែលកំពុងបំពេញកាតព្វកិច្ចយោធា មន្ត្រីដែលគ្មានក្របខ័ណ្ឌ ។ល។ មានតែ មាត្រា ៥ ប៉ុណ្ណោះដែលពិនិត្យនូវបទប្បញ្ញត្តិស្តីពីការដាក់មន្ត្រីអោយនៅទំនេរដោយគ្មានប្រាក់បៀវត្សរ៍ ។

**ការតែងតាំងមន្ត្រីរាជការ**- ការតែងតាំងមន្ត្រីរាជការនៅក្នុងក្របខ័ណ្ឌមុខងារសាធារណៈ នៅពេលដែលរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និង ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល តែងតាំងមន្ត្រីអោយចូលស៊ុបក្នុងក្របខ័ណ្ឌមុខងារសាធារណៈ ។

**ការផ្ទេរមន្ត្រីរាជការ**- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ អាចអនុញ្ញាតអោយផ្ទេរក្របខ័ណ្ឌមន្ត្រីរាជការពីក្រសួងមួយ ទៅបម្រើការនៅក្នុងក្រសួងមួយទៀត តាមការស្នើសុំរបស់មន្ត្រី និង ក្រសួងពាក់ព័ន្ធ ។



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

# ជំពូកទី ៨

# ការត្រួតពិនិត្យការអនុវត្តថវិកា

## ១. តារាងប្រតិបត្តិការហិរញ្ញវត្ថុសាធារណៈ

**តារាងប្រតិបត្តិការហិរញ្ញវត្ថុសាធារណៈ** (TOFE) គឺជាឧបករណ៍ស្ថិតិរបស់រាជរដ្ឋាភិបាលដើម្បីធ្វើការតាមដាន និង ត្រួតពិនិត្យការវិវត្តនូវស្ថានភាពនៃហិរញ្ញវត្ថុសាធារណៈ ជាពិសេសក្នុងការតាមដានការអនុវត្តថវិកា ដោយឈរលើមូលដ្ឋាននៃគណនេយ្យសាធារណៈ ។

ក្នុងន័យនេះ **តារាងប្រតិបត្តិការហិរញ្ញវត្ថុសាធារណៈ** (TOFE) បានក្លាយទៅជាឧបករណ៍មួយដ៏សំខាន់ សម្រាប់ការគ្រប់គ្រងដោយឈរលើមូលដ្ឋានដូចតទៅ ÷

ទីមួយ- តារាង TOFE គឺជាក្របខ័ណ្ឌវិភាគនៃប្រតិបត្តិការហិរញ្ញវត្ថុសាធារណៈ ដែលផ្តោតលើគោលការណ៍នៃគណនេយ្យជាតិ ។

ទីពីរ- តារាង TOFE ត្រូវបានប្រើប្រាស់ជាមូលដ្ឋានសម្រាប់កិច្ចពិភាក្សា ទាំងក្នុងក្របខ័ណ្ឌជាតិ ទាំងក្នុងក្របខ័ណ្ឌនៃកិច្ចពិភាក្សាជាមួយស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ ស្តីពីគោលនយោបាយហិរញ្ញវត្ថុសាធារណៈ និងការអនុវត្តថវិកាជាតិ ។

### ១.១. រចនាសម្ព័ន្ធនៃប្រតិបត្តិការហិរញ្ញវត្ថុសាធារណៈ

**តារាងប្រតិបត្តិការហិរញ្ញវត្ថុសាធារណៈ** (TOFE) ត្រូវបានរៀបចំឡើង ដោយឈរលើក្បួនខ្នាតនៃគណនេយ្យសាធារណៈ តែដោយជំនួស «**ឥណទាន**» ដោយសញ្ញា (+) និង «**ឥណពន្ធ**» ដោយសញ្ញា (-)។ យើងនឹងពិនិត្យមើលនូវគោលការណ៍ជាមូលដ្ឋាននៃការអនុវត្តប្រតិបត្តិការនៅក្នុងរដ្ឋបាលសាធារណៈ ។

#### ១.១.១. និយមន័យបេឡា

**និយាម** នៃការកត់ត្រាតាមគណនេយ្យ **TOFE** មានពីរប្រភេទ÷

ទីមួយ- **និយមន័យបេឡា** (Cash accounting) : ការកត់ត្រាចំណូល និង ចំណាយ ត្រូវឈរលើ



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

មូលដ្ឋាននៃកិរិយបរិច្ឆេទនៃប្រតិបត្តិការសាច់ប្រាក់តែម្តង ពោលគឺចំណូលត្រូវកត់ត្រានៅពេលដែលសាច់ប្រាក់ត្រូវបានបង់ចូលរតនាគារ ហើយចំណាយត្រូវបានកត់ត្រានៅពេលដែលសាច់ប្រាក់ត្រូវបានបើកផ្តល់ចេញពីរតនាគារ ។ **ការកត់ត្រាតាមនិយមន័យបេឡា** នេះអនុញ្ញាតអោយយើងចុះបញ្ជីការគណនី និង វាស់វែងនូវលំហូរសាច់ប្រាក់រវាងរដ្ឋបាលសាធារណៈ និង សេដ្ឋកិច្ចជាតិ ដែលឆ្លុះបញ្ចាំងពីស្ថានភាពជាក់ស្តែងនៃរូបិយវត្ថុ ហើយជាពិសេស គឺស្ថិតិហិរញ្ញវត្ថុ ។

ទីពីរ-**និយមន័យអាណត្តិ** (Commitment base) ការកត់ត្រាចំណូល និង ចំណាយត្រូវធ្វើឡើងនៅពេលព្រឹត្តិការណ៍ដែលបង្កើតអោយមានចំណូល និង ចំណាយកើតឡើងតែម្តង ទោះបីជាគ្មានលំហូរសាច់ប្រាក់ក៏ដោយ ។ ប្រតិបត្តិការត្រូវបានកត់ត្រា នៅពេលដែលកាតព្វកិច្ចត្រូវទទួលឥណទេយ្យ ឬ នៅពេលដែលចំណាយត្រូវបានសន្យាបានករកើតឡើង ។ ពោលគឺ ចំណូលត្រូវកត់ត្រានៅពេលដែលចុះកិច្ចសន្យាជួល ដែលនឹងត្រូវទទួលបានចំណូល ហើយចំណាយត្រូវបានកត់ត្រានៅពេល ដែលចុះកិច្ចសន្យាទិញសម្ភារៈដែលរដ្ឋត្រូវមានកាតព្វកិច្ចទូទាត់ចំណាយ **តាមអាណត្តិ** ។

ប្រព័ន្ធគណនេយ្យ **TOFE** គឺជាប្រព័ន្ធ **និយាមបេឡាកែតម្រូវ** (Modified cash) ÷ **ចំណូល** ត្រូវកត់ត្រាតាម **និយមន័យបេឡា** (Cash-based) តែ **ចំណាយ** ត្រូវកត់ត្រាតាម **និយមន័យអាណត្តិ** (Commitment based) ។ ប្រការនេះបង្កើតអោយមានវិសមាមាត្រ ក្នុងការកត់ត្រាចំណូល និង ចំណាយ ។ ឧទាហរណ៍ តារាង **TOFE** មិនអាចកត់ត្រាបំណុលពន្ធដែលក្រុមហ៊ុនជំពាក់រដ្ឋទេ តែកត់ត្រានូវបំណុលដែលរដ្ឋជំពាក់ក្រុមហ៊ុន ដែលជាមូលហេតុបង្ហាញអោយឃើញថា ឱនភាពថវិកាកើនឡើង ។

ច្បាប់ស្តីពីប្រព័ន្ធថវិកាឆ្នាំ ១៩៩៣ បានកំណត់នូវនិយាមគណនេយ្យតាមប្រព័ន្ធគណនេយ្យបេឡាកែតម្រូវដូចនិយាមគណនេយ្យ **TOFE** ដែរ ពោលគឺ ÷ ចំណូលត្រូវបានកត់ត្រាក្នុងគណនីថវិកានៃរតនាគារនៅពេលបង់សាច់ប្រាក់ជាក់ស្តែង ចំណែកឯចំណាយវិញត្រូវបានកត់ត្រានៅពេលដែលរតនាគារចុះទិដ្ឋាការលើអាណត្តិបើកប្រាក់ថាពិតជាត្រឹមត្រូវមែន ពោល គឺការអនុវត្តនូវនិយាម **បេឡាកែតម្រូវ** ។

ក៏ប៉ុន្តែ ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ ២០០៨ មាត្រា ៧៤ បានធ្វើវិសោធនកម្មលើនិយាមគណនេយ្យសាច់ប្រាក់ ដោយបើកច្រកអោយអនុវត្តនូវនិយាមគណនេយ្យបង្គរ ÷«ប្រព័ន្ធគណនេយ្យសាធារណៈ ត្រូវមានសង្គតិភាពទៅនឹងនិយាមគណនេយ្យអន្តរជាតិ ដែលមានការទទួលស្គាល់ជាទូទៅ ហើយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវចេញប្រកាសកំណត់ប្រព័ន្ធគណនេយ្យនេះ» ។

ដើម្បីកែតម្រូវពីប្រព័ន្ធគណនេយ្យតាមនិយមន័យបេឡា ទៅប្រព័ន្ធគណនេយ្យសន្យា ឬ បង្គរ យើងត្រូវប្តូរ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

**ចំណាយជាសាច់ប្រាក់** ជាមួយនឹង **ការកែតម្រូវចំណាយថវិកា** (ទឹកប្រាក់នៃអាណត្តិដឹកលុំនៅរតនាគារ ដែលមិនទាន់បើកជាសាច់ប្រាក់) ដើម្បីទទួលបាននូវចំណាយថវិកាតាម **និយមន័យអាណត្តិ** ពោលគឺទឹកប្រាក់សរុបនៃអាណត្តិបើកប្រាក់ ដែលរតនាគារបានចុះទិដ្ឋាការ ថាពិតជាត្រឹមត្រូវអាចអោយទូទាត់ជាសាច់ប្រាក់បាន ។

## ១.១.២. និយមន័យអាណត្តិ

គួរកត់សម្គាល់ថាពាក្យថា «**និយមន័យអាណត្តិ**» (Commitment) អាចធ្វើអោយមានការយល់ច្រឡំ ។ នៅក្នុងក្របខ័ណ្ឌ **TOFE** «**និយមន័យអាណត្តិ**» ឬ ភាសាអង់គ្លេសហៅថា **Commitment** ហើយភាសាបារាំងហៅថា **Engagement** មានន័យផ្សេងពីគណនេយ្យសាធារណៈ ។ «**Commitment**» នេះមិនមែន**ការធានាចំណាយ**ឥណទានថវិកាទេ (**Engagement des dépenses**) តែគឺជា **ការសន្យាហិរញ្ញវត្ថុ** របស់រដ្ឋចំពោះអ្នកផ្គត់ផ្គង់ដែលបានបំពេញកាតព្វកិច្ចរបស់ខ្លួនរួចស្រេចតាមកិច្ចសន្យា ពោលគឺបានផ្គត់ផ្គង់នូវទំនិញ ឬ សេវា ដែលបង្កើតឡើងនូវ **បំណុលរបស់រដ្ឋ** ។ នៅក្នុងប្រតិបត្តិការចំណាយ ដំណាក់កាលនេះហៅថា **អាណត្តិកិច្ច** ពោល គឺ រដ្ឋទទួលស្គាល់ជាផ្លូវការនូវ **កាតព្វកិច្ចហិរញ្ញវត្ថុ** របស់ខ្លួន ។

ឧទាហរណ៍នៃដំណាក់កាលអាណត្តិកិច្ចគឺ ÷

- ការផ្គត់ផ្គង់ទំនិញ និងសេវា ÷ ព្រឹត្តិការណ៍ដែលបង្កើតឡើងនូវ **បំណុល** ឬ **ឥណនេយ្យ** របស់រដ្ឋ គឺការផ្គត់ផ្គង់ទំនិញ និង សេវា ។
- សេវាការប្រាក់នៃបំណុលសាធារណៈ ÷ កាលបរិច្ឆេទដល់ថ្ងៃសេវាការប្រាក់ ដែលធ្វើអោយរដ្ឋជំពាក់បំណុលពាក់ព័ន្ធនឹងសេវាការប្រាក់ ។
- ប្រាក់បៀវត្សរ៍ ÷ ប្រសិនបើបៀវត្សរ៍នេះ ជាបៀវត្សរ៍ប្រចាំខែ ប្រសិនបើរដ្ឋមិនបានបើកប្រាក់បៀវត្សរ៍ នៅថ្ងៃចុងក្រោយនៃខែទេ រដ្ឋនឹងជំពាក់បំណុលបៀវត្សរ៍ចាប់ពីថ្ងៃទី ១ នៃខែបន្ទាប់ទៀត ។

ព្រឹត្តិការណ៍ដែលបង្កើត **ឥណនេយ្យ** មិនអាចចុះបញ្ជីនៅថ្ងៃនោះតែម្តង នៅក្នុងគណនេយ្យសាធារណៈបានឡើយ ។ ដូច្នេះ យើងចាត់ទុកថា **និយាមគណនេយ្យអាណត្តិ** នូវកាលបរិច្ឆេទដែលជិតព្រឹត្តិការណ៍នេះជាងគេ ។ នៅប្រទេសកម្ពុជា យើងចាត់ទុកថា ជាចំណាយ **តាមនិយមន័យអាណត្តិ** នៅពេលដែលចំណាយនេះត្រូវបានចុះបញ្ជីក្នុង «**គណនីចំណាយថវិកា**» នៅក្នុងគណនេយ្យទូទៅរបស់រតនាគារ ។ ការចុះបញ្ជីនេះប្រព្រឹត្តទៅនៅពេលដែលគណនេយ្យកររតនាគារ **អនុញ្ញាតអោយទូទាត់អាណត្តិ** បន្ទាប់ពីខ្លួនបានពិនិត្យអាណត្តិនេះហើយបានចុះទិដ្ឋាការលើអាណត្តិនេះថា «**អាចទូទាត់បាន**» ។


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

### ១.១.៣. ការកត់ត្រាដុលនូវចំណូល និង ចំណាយ

នៅក្នុងគណនេយ្យសាធារណៈមាន **វិធានកត់ត្រាដុល** (Traitement sur une base brute) ដែលជាការអនុវត្តនូវគោលការណ៍ **សកលភាពថវិកា** វិធាន **មិនកាត់កង** និង វិធាន **មិនត្រូវចំណូលសម្រាប់ចំណាយពិសេស** ÷ នៅក្នុងថវិកា ចំណូល និង ចំណាយ ត្រូវកត់ត្រាតាមចំនួនដុលតែម្តង ។ ឧទាហរណ៍ មិនត្រូវយកចំណាយក្នុងការទារពន្ធ យកទៅដកពីចំណូលសារពើពន្ធឡើយ ។ ចំណូលសារពើពន្ធត្រូវកត់ត្រាទាំងដុល ចំណែកចំណាយក្នុងការទារពន្ធ ក៏ត្រូវកត់ត្រាជាចំណាយដែរ ដោយមិនត្រូវកត់ត្រាតែចំណូលសុទ្ធឡើយ ។

ក៏ប៉ុន្តែ ចំពោះសកម្មភាពអាជីវកម្មនៃអង្គភាពផលិតកម្មរបស់រដ្ឋបាលសាធារណៈវិញ យើងកត់ត្រាតែអតិរេក ឬ ឱនភាពអាជីវកម្ម តែប៉ុណ្ណោះ នៅក្នុងចំណូល ឬ ចំណាយសាធារណៈ ។

## ១.២. ក្របខ័ណ្ឌគណនេយ្យនៃតារាងប្រតិបត្តិការហិរញ្ញវត្ថុសាធារណៈ

**គណនេយ្យ** គឺជាប្រព័ន្ធកត់ត្រានូវទិន្នន័យជាបរិមាណ តាមតម្លៃទំនិញ ឥណទាន ឬ បំណុលរបស់សហគ្រាសឯកជន ឬ សាធារណៈ ។ ប្រតិបត្តិការនេះត្រូវបានកត់ត្រាក្នុង **គណនី** ដែលជាតារាងមានពីរផ្នែក÷ មួយសម្រាប់តម្លៃដែលឡើង ហើយមួយទៀតសម្រាប់តម្លៃដែលថយចុះ ។ ផ្នែកខាងឆ្វេង ហៅថា **ឥណទេយ្យ** ហើយផ្នែកខាងស្តាំ ហៅថា **ឥណទាន** ។ ដើម្បីទទួលបាននូវ **តុល្យការ** យើងបន្ថែមតុល្យការនេះទៅនឹងផ្នែកដែលមានចំនួនតូចជាង ដើម្បីអោយផ្នែកទាំងពីរស្មើគ្នា ។ ផលដករវាង ឥណទេយ្យ និង ឥណទាន ហៅថា **តុល្យការ** (Solde)។ គណនេយ្យមានពីរប្រភេទ គឺ÷

-**គណនេយ្យឯកត្តភាគ** (Comptabilité en partie simple) គឺប្រព័ន្ធដែលប្រតិបត្តិការនីមួយៗត្រូវបានកត់ត្រានៅក្នុងគណនីតែមួយ ។

-**គណនេយ្យទ្វេភាគ** (Comptabilité en partie double) គឺប្រព័ន្ធដែលប្រតិបត្តិការនីមួយៗត្រូវបានកត់ត្រានៅក្នុងគណនី ២ ដោយចុះបញ្ជីសមាមាត្រនឹងគ្នា ÷ ចំនួនចុះបញ្ជីនៅក្នុងគណនីទី១ នៅក្នុងគណនីឥណទានត្រូវតែស្មើនឹងចំនួនចុះបញ្ជីនៅក្នុងគណនីទី ២ នៅក្នុងគណនីឥណទេយ្យ ។

ក្របខ័ណ្ឌគណនេយ្យនៃ **តារាងប្រតិបត្តិការហិរញ្ញវត្ថុសាធារណៈ (TOFE)** មានលក្ខណៈ ដូចគ្នានឹងប្រព័ន្ធទិន្នន័យសេដ្ឋកិច្ច ឬ ហិរញ្ញវត្ថុដែរ : គណនេយ្យសាធារណៈ ជញ្ជីងទូទាត់ ស្ថានភាពរូបិយវត្ថុ និង គណនេយ្យជាតិ ។ ក៏ប៉ុន្តែ របៀបរបបបង្ហាញ និង សមាសធាតុរបស់វាខុសពីគេ ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

### ១.២.១. TOFE កត់ត្រាជា «លំហូរ» ប៉ុណ្ណោះ

នៅពេលដែលស្ថានភាពនៃអង្កេតរូបិយវត្ថុត្រូវបានកត់ត្រាជា «**ស្តុក**» តារាងតុល្យការរតនាគារត្រូវបានកត់ត្រាជា «**ស្តុក** » និង ជា «**លំហូរ**» (Movements or flows) ផង ។

តារាង **TOFE** មិនប្រើប្រាស់នូវរបៀបបង្ហាញជាតារាងមានពីរជួរ ឥណទេយ្យ/ឥណទាន ឡើយ ។ តារាង **TOFE** រៀបចំឡើងជាលំដាប់លំដោយ (ដោយមានតារាងមួយជួរ) ដោយមានសញ្ញា **+** ដែលតំណាងអោយឥណទាន (ធនធាន) និង សញ្ញា **-** ដែលតំណាងអោយ ឥណទេយ្យ (ការប្រើប្រាស់) ។ វាក្យស័ព្ទ «**ធនធាន/ការប្រើប្រាស់** » ត្រូវបានខ្ចីមកពីគណនេយ្យជាតិ ។

ប្រតិបត្តិការហិរញ្ញវត្ថុឆ្លុះបញ្ចាំងនូវលក្ខណៈដូចតទៅ÷

- សារធាតុនៃប្រតិបត្តិការ
- បរិមាណ
- ទិសដៅ (ប្រភព និង ទិសដៅនៃមូលនិធិ)




### ១.២.២. លំហូរដុល និង លំហូរសុទ្ធ

ដូចយើងបានឃើញខាងពីលើ ចំណូល និង ចំណាយថវិកាត្រូវបានកត់ត្រាដោយឈរលើមូលដ្ឋាន «**ដុល**»។ ប្រតិបត្តិការនៃគណនីហិរញ្ញវត្ថុ (ប្រតិបត្តិការរតនាគារ) ត្រូវបានកត់ត្រា ដោយឈរលើមូលដ្ឋាន «**សុទ្ធ**»: ទិន្នន័យនៅក្នុងតារាងបង្ហាញពីផលដកសុទ្ធរវាងគណនីដើមគ្រា និង គណនីចុងគ្រា ។


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

## ១.៣. សមាសធាតុនៃតារាងប្រតិបត្តិការហិរញ្ញវត្ថុសាធារណ:

| | **តារាងប្រតិបត្តិការហិរញ្ញវត្ថុសាធារណ:** | |
|---|---|---|
| **១** | **ចំណូលក្នុងប្រទេស**<br>១- ចំណូលចរន្ត<br>២- ចំណូលមូលធន | |
| **២** | **ចំណាយថវិកាសរុប**<br>១- ចំណាយចរន្ត<br>២- ចំណាយមូលធន | |
| | **ឱនភាព ឬ អតិរេកចរន្ត និយមន័យអាណត្តិ** (១-១ ដក ២-១)<br>**ឱនភាព ឬ អតិរេកសរុប និយមន័យអាណត្តិ** (១ ដក ២) | |
| | **ការកែតម្រូវចំណាយ** (បម្រែបម្រួលសុទ្ធនៃស្តុកអាណត្តិមិនទាន់ទូទាត់នៅរតនាគារ) | |
| | **ឱនភាព ឬ អតិរេកចរន្ត និយមន័យបេឡា** (និយមន័យអាណត្តិ បូកការកែតម្រូវចំណាយ)<br>**ឱនភាព ឬ អតិរេកសរុប និយមន័យបេឡា** (និយមន័យអាណត្តិ បូកការកែតម្រូវចំណាយ) | |
| | **ហិរញ្ញប្បទាន** | |
| **១** | **ហិរញ្ញប្បទានក្រៅប្រទេស** | |
| **១** | ការគាំទ្រថវិកា<br>ក- ជំនួយ<br>ខ- កម្ចី | |
| **២** | ជំនួយគម្រោង<br>ក- ជំនួយ<br>ខ- កម្ចី | |
| **៣** | ការសងបំណុលក្រៅប្រទេស | |
| **២** | **ហិរញ្ញប្បទានក្នុងប្រទេស** | |
| ១ | ហិរញ្ញប្បទានធនាគារសុទ្ធ | |
| ២ | គណនីផ្សេងទៀតរបស់រាជរដ្ឋាភិបាល | |
| ៣ | ហិរញ្ញប្បទានដោយផ្នែកឯកជន<br>ក- កម្ចីក្នុងស្រុក<br>ខ- ការសងកម្ចីក្នុងស្រុក<br>គ- គណនីឯកជន និង ប្រាក់បញ្ញើមានការធានា | |
| **៤** | កែតម្រូវតាមអត្រាប្តូរប្រាក់ | |
| **៥** | ប្រតិបត្តិការកំពុងដំណើរការ (Outstanding operations or Float) | |


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

## ១.៤. ការពន្យល់ពីតារាងប្រតិបត្តិការហិរញ្ញវត្ថុសាធារណៈ

**តារាងប្រតិបត្តិការហិរញ្ញវត្ថុសាធារណៈ** បង្ហាញនូវប្រតិបត្តិការរបស់រាជរដ្ឋាភិបាលជាពីរផ្នែកៈ

- *ផ្នែកទី ១- គឺជាប្រតិបត្តិការថវិកា*
- *ផ្នែកទី ២- គឺជាប្រតិបត្តិការរតនាគារ*

ប្រតិបត្តិការទាំងពីរត្រូវបានបែងចែកដោយបន្ទាត់មួយ ដែលបូកសរុបផ្នែកទី ១ និងផ្តល់ព័ត៌មានពីលទ្ធផលនៃការអនុវត្តថវិកា: **អតិរេក** ឬ **ឱនភាព** ។

**ផ្នែកទីមួយ** នៃតារាងដែលហៅថា **ផ្នែកខាងលើបន្ទាត់លទ្ធផល** គឺជាប្រតិបត្តិការដែលចប់សព្វគ្រប់ហើយ ពោលគឺ **ប្រតិបត្តិការថវិកា** ។ ក៏ប៉ុន្តែ មានការលើកលែងពីរ ÷

- ***ជំនួយពីរដ្ឋាភិបាលបរទេស និង អង្គការអន្តរជាតិ*** – ថ្វីត្បិតតែចំណូលទាំងនេះមានលក្ខណៈចប់សព្វគ្រប់ហើយ និងត្រូវបានដាក់បញ្ចូលនៅក្នុងថវិកា ចំណូលទាំងនេះត្រូវបានកត់ត្រានៅក្នុងផ្នែកទីពីរនៃតារាងជា **ហិរញ្ញប្បទានក្រៅប្រទេស** ។ ការបង្ហាញរបៀបនេះខុសពីនិយាមនៃ **គោលការណ៍ណែនាំស្តីពីស្ថិតិហិរញ្ញវត្ថុសាធារណៈ** (GFS) ។ ក៏ប៉ុន្តែ ការបង្ហាញរបៀបនេះឆ្លើយតបទៅនឹងតម្រូវការនៃការវិភាគ ។ ម្យ៉ាងវិញទៀត យើងចាំបាច់ត្រូវដឹងផងដែរពីលទ្ធផលថវិកា ដើម្បីកំណត់ពីតម្រូវការនៃហិរញ្ញប្បទាន ។ ជំនួយគឺជាធនធានពិសេសដែលត្រូវបានប្រើប្រាស់ដើម្បីជាប្រភពហិរញ្ញប្បទាននេះ ។
- ***ប្រតិបត្តិការកម្ចី ការបើកផ្តល់សាច់ប្រាក់ និង ការសងប្រាក់*** – គឺជាប្រតិបត្តិការរតនាគារ ។ ក៏ប៉ុន្តែ ការអនុវត្តនៅព្រះរាជាណាចក្រកម្ពុជាបញ្ចូលប្រតិបត្តិការនេះនៅក្នុងថវិកា ក្នុងគោលដៅធ្វើអោយមានលក្ខណៈងាយស្រួល និង សាមញ្ញ ។ នៅក្នុងមាតិកាថវិកាថ្មី ឆ្នាំ ២០០៧ ជំនួយ និងកម្ចីត្រូវបានកត់ត្រានៅក្នុង **គណនីថ្នាក់ ១-ចំណាយ និង ចំណូលវិនិយោគ:** គណនីមូលធន នៅក្នុងគណនី ១៣ ជំនួយវិនិយោគ និងក្នុងគណនី ១៦២ កម្ចីពីអង្គការបរទេស និង គណនី ១៦៣ កម្ចីពីរដ្ឋាភិបាលបរទេស ។ នៅក្នុងតារាង TOFE ប្រតិបត្តិការកម្ចីត្រូវបានដាក់នៅក្នុងផ្នែកទីពីរនៃតារាង ។

**ផ្នែកទីពីរ** នៃតារាងដែលហៅថា **ផ្នែកខាងក្រោមបន្ទាត់លទ្ធផល** ដែលយើងហៅថា **ហិរញ្ញប្បទាន** បរិយាយពីការធ្វើហិរញ្ញប្បទាននៃឱនភាពថវិកា ឬ ក្នុងករណីដែលមានអតិរេក បរិយាយពីរបៀបនៃការប្រើប្រាស់នៃអតិរេកថវិកានេះ ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

នៅក្នុងផ្នែកទីពីរនេះ ជំនួយ និង ប្រតិបត្តិការបណ្តោះអាសន្ន ឬ «ប្រតិបត្តិការរតនាគារ»: កម្ចី និង ការសងបំណុល គណនីបុរេប្រទាន និង បញ្ញើរតនាគារនៅធនាគារជាតិនៃកម្ពុជា បញ្ញើបុគ្គល និង បញ្ញើសហគ្រាសសាច់ប្រាក់រតនាគារ ។ល។ យើងពិនិត្យគោលការណ៍ជាមូលដ្ឋាន ដែលអនុញ្ញាតអោយកំណត់ទំហំប្រតិបត្តិការរបស់រដ្ឋបាលសាធារណៈ ដែលត្រូវបានអនុម័តនៅក្នុង **គោលការណ៍ណែនាំស្តីពីស្ថិតិហិរញ្ញវត្ថុសាធារណៈ** ឬ នៅក្នុង **តារាងប្រតិបត្តិការហិរញ្ញវត្ថុសាធារណៈ** ។

## ១.៥. ការវិភាគនៃតារាងប្រតិបត្តិការហិរញ្ញវត្ថុសាធារណៈ

ប្រព័ន្ធចុះបញ្ជីការនៃគណនីទ្វេភាគបង្កើននូវលទ្ធភាព បង្ហាញតារាងវិភាគនៃ **តារាងប្រតិបត្តិការហិរញ្ញវត្ថុសាធារណៈ** ។ នៅពេលដែលការចុះបញ្ជីការអាចចែកចេញជាពីរក្រុម ផលបូកនៃទិន្នន័យក្នុងក្រុមនីមួយៗ មានចំនួនស្មើគ្នានឹងផលបូកនៃទិន្នន័យក្នុងក្រុមមួយទៀត ហើយទិន្នន័យទាំងពីរមានសញ្ញាផ្ទុយគ្នា ។ លក្ខណៈនៃទិន្នន័យក្នុងក្រុមមួយ អាចយកមកពន្យល់នូវលក្ខណៈនៃក្រុមមួយទៀត ។

**តារាងប្រតិបត្តិការហិរញ្ញវត្ថុសាធារណៈ** គឺជាតារាងសរុប ដែលសង្ខេបគណនីហិរញ្ញវត្ថុសាធារណៈ អបដោយតារាងឧបសម្ព័ន្ធដែលបរិយាយយ៉ាងលម្អិតនូវចំណូល ចំណាយ គម្រោងជំនួញ និង ហិរញ្ញប្បទានធនាគារ ។ យើងនឹងពិនិត្យមើលយ៉ាងពិស្តារនូវសមាសភាពនីមួយៗនៃ **តារាងប្រតិបត្តិការហិរញ្ញវត្ថុសាធារណៈ**÷

### ១.៥.១. ចំណូលក្នុងប្រទេស

ចំណូលថវិកាត្រូវបានអនុវត្តជាបីដំណាក់កាល÷

- **ការកើតឡើង** នៃចំណូលរបស់រដ្ឋ
- **ការកត់ត្រាទុក** ចំណូលរបស់រដ្ឋ
- **ការប្រមូល** ចំណូលរបស់រដ្ឋ

នៅក្នុងស្ថិតិថវិកា ចំណូលត្រូវបានកត់ត្រាដោយឈរលើមូលដ្ឋាននៃការប្រមូលចំណូលជាសាច់ប្រាក់ជាក់ស្តែង ។ ទោះបីជាប្លង់គណនេយ្យថ្មីរបស់រតនាគារឈរលើមូលដ្ឋាននៃគណនីបង្គរក៏ដោយ ការកត់ត្រាចំណូលត្រូវអនុវត្តតាមគោលការណ៍ប្រុងប្រយ័ត្ន ដោយសារតែយើងមិនអាចពឹងផ្អែកទៅលើចំណូល ដែលគ្រាន់តែកត់ត្រាទុក តែមិនទាន់ប្រមូលបាន ដែលអាចនាំអោយបាត់បង់នូវតុល្យភាពនៃថវិកា ។ ការកត់ត្រាចំណូលនៅក្នុងគណនីថវិកា ថ្នាក់ ៧ : ចំណូលសារពើពន្ធក្នុងប្រទេស ។ ការដាក់អោយអនុវត្តនូវប្រព័ន្ធគណនេយ្យបង្គរអាចអោយ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

យើងកត់ត្រា និង តាមដានអោយបានហ្មត់ចត់នូវស្ថានភាពបំណុលដែលត្រូវទារ ដើម្បីបង់ចូលគណនីចំណូលនៃថវិការដ្ឋ ។

ក៏ប៉ុន្តែ ប្រសិនបើនៅពេលដែលចំណូលត្រូវបានយកទៅបង់នៅរតនាគារ ដែលអ្នកបង់ចំណូលមិនបានបញ្ជាក់អោយច្បាស់ពីប្រភពនៃចំណូល ឬ ដោយសារតែចំណូលទាំងនោះមិនបានភ្ជាប់មកជាមួយនូវសលាកបត្រចំណូលដែលអាចអោយរតនាគារអាចចាត់ថ្នាក់ចំណូលទៅក្នុងគណនីរតនាគារបាន សាច់ប្រាក់ត្រូវបង់ចូលបេឡារតនាគារ តែចំណូលត្រូវកត់ត្រាក្នុងគណនីរង់ចាំមួយ រហូតដល់រតនាគារទទួលបាននូវព័ត៌មានគ្រប់គ្រាន់ ឬទទួលបាននូវសលាកបត្រចំណូល ដើម្បីកត់ត្រាចំណូលនោះនៅក្នុងគណនីចំណូលរបស់រតនាគារ ទើបចំណូលនេះនឹងត្រូវបានផ្ទេរពីគណនីរង់ចាំរបស់រតនាគារ អោយចូលទៅក្នុងគណនីចំណូលថវិកាតែម្តង ។ នៅក្នុងក្របខ័ណ្ឌនៃការវិភាគតារាងប្រតិបត្តិការហិរញ្ញវត្ថុសាធារណៈ ការកត់ត្រាចំណូលនៅក្នុងគណនីរង់ចាំ នាំអោយមានផលវិបាកពីរយ៉ាង÷

- ទីមួយ- ចំណូលបង់ចូលក្នុងបេឡារតនាគាររួចហើយ តែមិនបានឆ្លុះបញ្ចាំងនៅក្នុងគណនីចំណូល ។
- ទីពីរ- ការកើនឡើងនៃចំណូលក្នុងគណនីរង់ចាំ ធ្វើអោយមានភាពមិនប្រក្រតីនៅក្នុងសមតុល្យគណនីនេះ នៅដើមគ្រា និង នៅចុងគ្រា ហើយជាហេតុបណ្តាលអោយ «**គណនីប្រតិបត្តិការកំពុងដំណើរការ**» ឡើងប៉ោងខុសប្រក្រតីផងដែរ ដែលជាសញ្ញានៃបញ្ហាដែលកើតមានឡើងនៅក្នុងការអនុវត្តថវិកា (គណនីប្រតិបត្តិការកំពុងដំណើរការកត់ត្រានូវសមតុល្យនៃគណនីរង់ចាំ នៅដើមគ្រា និង ចុងគ្រា) ។

គួរកត់សម្គាល់ថាការបង់ចំណូលមិនមែនសុទ្ធតែបង់ជាសាច់ប្រាក់នោះទេ ។ ចំណូលអាចបង់ជាមូលប្បទានបត្រ និង ជាបង្វែរធនាគារ ពីគណនីតតិយជន មកគណនីចំណូលតែម្តង ។ ទោះបីជាប្រតិបត្តិការនេះមិនបាននាំអោយមានកើននូវសាច់ប្រាក់ ដោយសារតែការទូទាត់ការបង់ពន្ធរបស់ក្រុមហ៊ុនជាមួយនឹងបំណុលពន្ធដែលក្រុមហ៊ុនត្រូវបង់ចូលថវិការដ្ឋ ។ ក៏ប៉ុន្តែ បន្ទាប់ពីការដាក់អោយអនុវត្តនូវប្លង់គណនីថ្មី រតនាគារបានបិទចោលនូវគណនីតតិយជន ដើម្បីជៀសវាងកុំអោយរតនាគារដើរតួនាទីដូចជាធនាគារពាណិជ្ជ ដោយប្រើប្រាស់នូវប្រព័ន្ធធនាគារជាតិនៃកម្ពុជាដើម្បីទទួលការបង់ចំណូលចូលរតនាគារវិញ ។

### ១.៥.២. ចំណាយថវិកា

និយាមស្ថិតិហិរញ្ញវត្ថុសាធារណៈដែលអនុម័តដោយ **គោលការណ៍ណែនាំស្តីពីស្ថិតិហិរញ្ញវត្ថុសាធារណៈ** (GFS) បានកំណត់ថាប្រតិបត្តិការចំណាយត្រូវបានកត់ត្រាតាមនិយមន័យបេឡានៃការបញ្ចេញសាច់ប្រាក់ ។ ក៏ប៉ុន្តែ ការគ្រប់គ្រងថវិកាប្រកបដោយគុណភាពខ្ពស់មិនមែនស្ថិតនៅត្រង់តុល្យភាពសាច់ប្រាក់រវាង

ការបង់ចំណូល និង ការបញ្ចេញសាច់ប្រាក់ចំណាយទេ ។ ការគ្រប់គ្រងថវិកាបានល្អ គឺស្ថិតនៅត្រង់តុល្យភាពរវាងធនធានដែលមាន និង ចំណាយថវិកា ទោះបីជាចំណាយនោះបានទូទាត់ហើយ ឬ មិនទាន់បានទូទាត់ក៏ដោយ ។

ម៉្យាងវិញទៀត អនុក្រឹត្យលេខ ៨២ អនក្រ.បក, ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ មាត្រា ១០៧ បានចែងថា ÷ «ចំណាយត្រូវបានគិតចូលក្នុងថវិកានៃឆ្នាំ ដែលគណនេយ្យករមុខការនៃរតនាគារ បានចុះទិដ្ឋាការលើអាណត្តិបើកប្រាក់» ។ ត្រង់ចំណុចនេះ **តារាងប្រតិបត្តិការហិរញ្ញវត្ថុសាធារណៈ** អនុវត្តខុសពីនិយាមនៃ **គោលការណ៍ណែនាំស្តីពីស្ថិតិហិរញ្ញវត្ថុសាធារណៈ** (GFS) ។ ចំណាយត្រូវបានចុះបញ្ជីការឈរលើមូលដ្ឋាននៃនិយមន័យអាណត្តិ ពោលគឺឈរលើមូលដ្ឋាននៃការចុះទិដ្ឋាការលើអាណត្តិបើកប្រាក់ដោយគណនេយ្យករមុខការនៃរតនាគារ ។

បន្ទាប់ពីចុះទិដ្ឋាការលើអាណត្តិបើកប្រាក់រួចមក គណនេយ្យករចុះបញ្ជីការចំណាយនេះទៅក្នុងគណនេយ្យនៃគណនីថ្នាក់ ៦ ចំណាយប្រតិបត្តិការ ។ ចំណាយត្រូវបានចែកជាពីរផ្នែក÷

- ចំណាយចរន្ត (គណនីថ្នាក់ ៦) និង
- ចំណាយមូលធន (គណនីថ្នាក់ ១)

ចំណាយមូលធន (វិនិយោគ) នាំអោយមានការកើនឡើងនូវទ្រព្យសម្បត្តិរបស់រដ្ឋ ដូចជាការកសាងផ្លូវ ការសាងសង់អាគារ ។ល។ ដោយឈរលើមូលដ្ឋាននៃប្រភពវិនិយោគ ចំណាយមូលធននៅក្នុងតារាង **TOFE** ត្រូវបានកត់ត្រានៅក្នុងប្រភេទចំណាយដូចតទៅ÷

- **ចំណាយដោយហិរញ្ញប្បទានក្នុងស្រុក**- ដែលជាចំណាយវិនិយោគដែលមានប្រតិបត្តិការចំណាយ និងការចុះបញ្ជីការក្នុងគណនីរតនាគារជាតិ ។ វាក្យស័ព្ទ «**ហិរញ្ញប្បទានក្នុងស្រុក**» មានន័យថា ចំណាយទាំងនេះត្រូវធ្វើហិរញ្ញប្បទានដោយ ÷(១) មូលនិធិដែលមានប្រភពពីចំណូលក្នុងស្រុក ដែលត្រូវបានវិភាជន៍ ឬ មិនត្រូវបានវិភាជន៍សម្រាប់ចំណាយវិនិយោគ (២) មូលនិធិដែលមានប្រភពពីជំនួយបរទេស ហើយជំពូក «**ការគាំទ្រថវិកា**» ត្រូវបានវិភាជន៍សម្រាប់តែចំណាយវិនិយោគតែប៉ុណ្ណោះ ។
- **ចំណាយដោយហិរញ្ញប្បទានក្រៅប្រទេស**- ដែលជាចំណាយវិនិយោគដែលមានឈ្មោះថា «**ជំនួយជាគម្រោង**» ដែលប្រតិបត្តិការហិរញ្ញវត្ថុមិនបានឆ្លងកាត់តាមគណនីនៃរតនាគារជាតិឡើយ ។ ចំណាយទាំងនេះទទួលហិរញ្ញប្បទានដោយផ្ទាល់ពី ÷ (១) កម្ចីដែលស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ (ធនាគារពិភពលោក និងធនាគារអភិវឌ្ឍន៍អាស៊ី) ផ្តល់ជូនរាជរដ្ឋាភិបាល (២) ជំនួយ ក្រោមរូបភាពជាគម្រោងវិនិយោគដែលអនុវត្ត


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

និង ធ្វើហិរញ្ញប្បទានដោយផ្ទាល់ដោយដៃគូអភិវឌ្ឍន៍ ។ ជាធម្មតា ជំនួយប្រភេទនេះមិនបានចុះបញ្ជីគណនេយ្យ និង ឆ្លុះបញ្ចាំងនៅក្នុងស្ថិតិថវិកាឡើយ ដោយសារប្រតិបត្តិការហិរញ្ញវត្ថុនេះត្រូវបានអនុវត្តក្រៅប្រព័ន្ធរតនាគារ ។ ក៏ប៉ុន្តែ ជំនួយជាគម្រោងត្រូវបានប៉ាន់ស្មាននៅក្នុងតារាងឧបសម្ព័ន្ធនៃថវិកាជាតិ ។ ដោយសារតែចំណាយដោយហិរញ្ញប្បទានក្រៅប្រទេសមានសារៈសំខាន់យ៉ាងខ្លាំងសម្រាប់កម្ពុជា ចំណាយប្រភេទនេះត្រូវបានបញ្ចូលក្នុងការព្យាករណ៍ថវិកា និង នៅក្នុងតារាង TOFE ។ ហិរញ្ញប្បទានដោយផ្ទាល់ពីបរទេសត្រូវបានកត់ត្រាទាំងស្រុងដោយសរុបរួមតែម្តង ទាំងនៅខាងចំណូល ទាំងនៅខាងចំណាយ (ជាហិរញ្ញប្បទានដែលនៅក្រោមបន្ទាត់) ។ ទិន្នន័យនៃហិរញ្ញប្បទានក្រៅប្រទេសនៅក្នុងថវិកា ជាទិន្នន័យប៉ាន់ស្មាន ដែលត្រូវកែតម្រូវតាមការអនុវត្តជាក់ស្តែង បន្ទាប់ពីរាជរដ្ឋាភិបាលទទួលបាននូវទិន្នន័យជាក់ស្តែងពីដៃគូអភិវឌ្ឍន៍ ។

### ១.៥.៣. ឱនភាព ឬ អតិរេក (និយមន័យអាណត្តិ)

លទ្ធផលដែលទទួលបានពីប្រតិបត្តិការចរន្តនៃថវិកា មានដូចតទៅ៖

**ចំណូលចរន្ត**

**- ចំណាយចរន្ត**

**= អតិរេកចរន្ត** (+)

**ឬ ឱនភាពចរន្ត** (-)

លទ្ធផលសរុប អាចទទួលបានតាមរយៈការគណនា ដោយបញ្ចូលនូវប្រតិបត្តិការនៃចំណូល និង ចំណាយមូលធន ។ គួរកត់សម្គាល់ថា ការបង្ហាញពីប្រតិបត្តិការថវិកាក្នុងតារាង TOFE ខុសគ្នាពីការបង្ហាញនៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុប្រចាំឆ្នាំ ដោយសារតែច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈតម្រូវអោយបង្ហាញថវិកាអោយមានតុល្យភាព ។ ដូច្នេះហើយទើប៖

- នៅក្នុងតារាង TOFE កម្ចី និងជំនួយពីក្រៅប្រទេសត្រូវបានកត់ត្រានៅក្នុងផ្នែកចំណាយ និង នៅក្នុងផ្នែកហិរញ្ញប្បទាន ។ ការបង្ហាញដូច្នេះរំលេចអោយឃើញនូវឱនភាពថវិកាសរុប ដែលត្រូវធ្វើហិរញ្ញប្បទានដោយកម្ចី និង ជំនួយក្រៅប្រទេស ។
- នៅក្នុងតារាងថវិកា កម្ចី និងជំនួយពីក្រៅប្រទេសត្រូវបានកត់ត្រាជាចំណូល និង ជាចំណាយថវិកា ។ ការបង្ហាញដូច្នេះរំលេចអោយឃើញនូវតុល្យភាពរវាងចំណូលថវិកាសរុប និង ចំណាយថវិកាសរុប ដោយអនុលោមតាមគោលការណ៍តុល្យភាព ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

### ១.៥.៤. គំរោតម្រូវចំណាយថវិកា

នៅក្នុងផ្នែកទីមួយនៃតារាង ចំណាយត្រូវបានកត់ត្រាតាម **និយមន័យអាណត្តិ** ពោលគឺចំណាយថវិកា គឺផលបូកនៃចំនួនអាណត្តិទាំងអស់ ដែលរតនាគារបានផ្តល់ទិដ្ឋាការរួច ។

ការទូទាត់អាណត្តិបើកប្រាក់អាចនាំអោយមានការយឺតយ៉ាវដោយសារបញ្ហាបច្ចេកទេស ÷

- តាមប្រព័ន្ធទូទាត់មុនឆ្នាំ ១៩៩៦: បន្ទាប់ពីក្រសួង ស្ថាប័នទទួលព័ត៌មានពីរតនាគារ ដែលបានផ្ទេរសាច់ប្រាក់ចូលគណនីរបស់ខ្លួន ក្រសួង ស្ថាប័នទាំងនោះអាចមកដកសាច់ប្រាក់ ដើម្បីយកទៅទូទាត់អ្នកផ្គត់ផ្គង់ ។
- ចាប់ពីការដាក់អោយអនុវត្តនូវ **ប្រព័ន្ធទូទាត់ដោយផ្ទាល់** ក្នុងឆ្នាំ ១៩៩៦: រតនាគារទូទាត់អ្នកផ្គត់ផ្គង់ដោយផ្ទាល់តែម្តង ។ ប្រសិនបើរតនាគារទូទាត់អ្នកផ្គត់ផ្គង់ជាសាច់ប្រាក់ រតនាគារផ្តល់ព័ត៌មានដល់អ្នកផ្គត់ផ្គង់ជាមុន ។ ប្រសិនបើរតនាគារទូទាត់អ្នកផ្គត់ផ្គង់ ដោយការផ្ទេរតាមធនាគារ បន្ទាប់ពីរតនាគារបានផ្តល់ទិដ្ឋាការលើអាណត្តិបើកប្រាក់រួចមក រតនាគារផ្តល់ព័ត៌មានដល់ធនាគារជាតិនៃកម្ពុជា ដោយស្នើសុំអោយផ្ទេរសាច់ប្រាក់ពីគណនីរតនាគារ ទៅគណនីរបស់អ្នកផ្គត់ផ្គង់ ។
- កង្វះខាតសាច់ប្រាក់ដើម្បីអោយរតនាគារ អាចទូទាត់អ្នកផ្គត់ផ្គង់ភ្លាមៗបាន ។ កង្វះខាតសាច់ប្រាក់បណ្តាលមកពីចំណាយសរុបត្រូវបានអនុវត្តលើសពីចំណូលថវិកា ដែលបង្កើតដោយសារការគ្មានវិន័យថវិកា ។

ដូចនេះ នៅក្នុងពេលណាក៏ដោយ បរិមាណសរុបនៃអាណត្តិដែលរតនាគារបានផ្តល់ទិដ្ឋាការរួច (ដែលជាចំណាយថវិកាសរុប) មិនដែលស្មើនឹងបរិមាណសរុបនៃអាណត្តិដែលរតនាគារបានទូទាត់រួចឡើយ ។

នៅពេលដែលបរិមាណសរុបនៃអាណត្តិដែលរតនាគារបានផ្តល់ទិដ្ឋាការរួច លើសបរិមាណសរុបនៃអាណត្តិបើកប្រាក់ដែលរតនាគារបានទូទាត់រួច នោះស្តុកនៃ **អាណត្តិមិនទាន់បានទូទាត់** នឹងកើនឡើង ។ អាណត្តិមិនទាន់បានទូទាត់ ត្រូវបានប្រើប្រាស់ដើម្បីគណនា **ចំណាយថវិកាតាមនិយមន័យបេឡា** ÷

**ចំណាយថវិកាសរុប - អាណត្តិមិនទាន់បានទូទាត់ = ចំណាយវិកាតាមនិយមន័យបេឡា**

នៅពេលដែលអាណត្តិមិនទាន់បានទូទាត់កើនឡើងខ្លាំង ការអនុវត្តថវិកានឹងជួបប្រទះនឹងបញ្ហាលំបាក ដែលជាសញ្ញានៃការគ្មានវិន័យថវិកា ដែលដាក់សម្ពាធទៅលើការគ្រប់គ្រងសាច់ប្រាក់ ។

ដើម្បីពង្រឹងការគ្រប់គ្រងសាច់ប្រាក់ អាណត្តិដែលមិនទាន់បានទូទាត់ត្រូវបានចាត់ថ្នាក់តាមកាលបរិច្ឆេទក្នុងគោលដៅអនុវត្តចំណាយ អោយបានរលូនតាមសន្ទុះនៃការប្រមូលចំណូល និង ស្ថានភាពនៃអាណត្តិដែល



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

មិនទាន់បានទូទាត់ ។ អាណត្តិមិនទាន់បានទូទាត់ក្នុងរយៈពេលវែងត្រូវបានចាត់ទុកជា **ចំណុលថវិកា** ។ ដូច្នេះ គោលនយោបាយថវិកា គឺត្រូវកាត់បន្ថយបំណុលថវិកា តាមរយៈការបង្កើតចំណូល វិចារណកម្មចំណាយ និង ពង្រឹងការគ្រប់គ្រងសាច់ប្រាក់ ។

### ១.៥.៥. ឱនភាព ឬ អតិរេក (និយមន័យបេឡា)

លទ្ធផលនៃការអនុវត្តថវិកាតាមនិយមន័យបេឡាអាចទទួលបានតាមរយៈ ការកែតម្រូវនៃលទ្ធផល (អតិរេក ឬ ឱនភាព) តាមនិយមន័យអាណត្តិ ÷

- ការកើនឡើងនូវ **ចំណុលថវិកា** (អាណត្តិមិនទាន់ទូទាត់) មានន័យថា **ការធ្វើហិរញ្ញប្បទាននៃថវិកាដោយអ្នកផ្គត់ផ្គង់** ។ **ការកែតម្រូវចំណាយ** មានសញ្ញា «បូក» ។ ប្រការនេះធ្វើអោយឱនភាពសាច់ប្រាក់ថយចុះ ។
- ការថយចុះនូវ **ចំណុលថវិកា** មានន័យថា **ការបើកផ្តល់សាច់ប្រាក់បន្ថែម** ។ **ការកែតម្រូវចំណាយ** មានសញ្ញា «ដក» គឺមានន័យថាចំណាយ ។ ប្រការនេះធ្វើអោយឱនភាពសាច់ប្រាក់ កើនឡើង ។

តុល្យភាពសរុបនៃសាច់ប្រាក់មានសារៈសំខាន់ណាស់ ក្នុងការវិភាគហិរញ្ញវត្ថុ ដោយសារសូចនាករនេះឆ្លុះបញ្ចាំងពីតម្រូវការក្នុងការធ្វើហិរញ្ញប្បទាន ។

ការបង្កើតអោយមាន **សញ្ជ័យសាធារណៈ** មានទិសដៅពង្រឹងនូវការសន្សំសំចៃ ដើម្បីបង្កើតជាមូលដ្ឋានគ្រឹះសម្រាប់ការអភិវឌ្ឍន៍ប្រកបដោយចីរភាព និង ជៀសវាងការធ្វើហិរញ្ញប្បទានដោយធនាគារ ។ សញ្ជ័យសាធារណៈ ដែលសម្រេចបាននឹងត្រូវយកទៅប្រើប្រាស់ក្នុងការសងបំណុល សំរាប់យកទៅប្រើប្រាស់ជាថវិកាបដិភាគក្នុងគម្រោង ដែលធ្វើហិរញ្ញប្បទានពីខាងក្រៅ និង សម្រាប់យកទៅប្រើប្រាស់បន្ថែមក្នុងគម្រោងវិនិយោគសាធារណៈ ដែលធ្វើហិរញ្ញប្បទានដោយថវិកាជាតិ ។

***ដើម្បីអោយសំរេចបាននូវអតិរេកថវិកាចរន្ត*** ត្រូវធានាអោយបាននូវ កំណើនចំណូលជាប្រចាំ អោយលើសកំណើនចំណាយថវិកាជាប្រចាំ ជាពិសេសត្រូវធានាអោយចំណូលចរន្តដែលប្រៀបធៀបនឹង ផសស មានអត្រាលើសចំណាយចរន្តដែលប្រៀបធៀបនឹងផសស ដើម្បីបង្កើតបាននូវអតិរេកថវិកាចរន្ត ក្នុងអត្រាមួយវិជ្ជមានបើប្រៀបធៀបនឹង ផសស ។ អតិរេកថវិកាចរន្តអនុញ្ញាតអោយរដ្ឋបាលសាធារណៈ បានចូលរួមវិភាគទាននៅក្នុងសញ្ជ័យ (Épargne or Savings) សរុប ដែលជាកត្តានៃកំណើនសេដ្ឋកិច្ច ។

ទស្សនទាននៃតុល្យភាពថវិកាសំខាន់ៗមានដូចតទៅ ÷

**១- អតិរេក/ឱនភាពចរន្ត**- ចំណូលចរន្ត- ចំណាយចរន្ត និង (ឥណទានអោយគេខ្ចី- ប្រាក់ដែល



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

គេសង) (Net borrowing or Prêts moins recouvrements)។

**២-អតិរេក/ឱនភាពបឋម** (Primaire)-ចំណូល និង ជំនួយឥតសំណង-ចំណាយដោយមិនគិតចំណាយលើការប្រាក់ និង (ឥណទានអោយគេខ្ចី -ប្រាក់ដែលគេសង [Net borrowing or Prêts moins recouvrements]) ។ គោលដៅនៃតុល្យភាពនេះ គឺមិនចង់គិតពីឥទ្ធិពលនៃឱនភាពក្នុងរយៈពេលមុនមកលើតុល្យភាពថវិកា ដោយផាត់ចេញនូវចំណាយលើការប្រាក់ ។

**៣-អតិរេក/ឱនភាពប្រតិបត្តិការ** (Opérationnel)-ចំណូល និង ជំនួយឥតសំណង-ចំណាយដោយមិនគិតចំណាយលើការប្រាក់ ដែលនាំអោយមានអតិផរណា និង (ឥណទានអោយគេខ្ចី-ប្រាក់ ដែលគេសង [Net borrowing or Prêts moins recouvrements]) ។ ក្នុងស្ថានភាពដែលមានអតិផរណាខ្លាំង គោលដៅនៃតុល្យភាពនេះ គឺកាត់បន្ថយនូវអតិរេក/ឱនភាព ដោយផាត់ចេញនូវចំណាយលើការប្រាក់ ដែលបើកផ្តល់អោយម្ចាស់បំណុលសាធារណៈ ជាហេតុធ្វើអោយមានអតិផរណា ។ ក្នុងករណីនេះ យើងត្រូវយកចំណាយលើការប្រាក់ (Amortissement de la dette) ទៅបូកបញ្ចូលជាមួយនឹងចំណូលទូទាត់បំណុល ដែលដាក់ក្រោមខ្សែបន្ទាត់តុល្យភាព (en-dessous de la ligne)។

តុល្យភាពថវិកាដ៏ទៃទៀតមានដូចតទៅ÷

**៤-តុល្យភាពថវិកាសរុប** = ចំណាយថវិកាសរុប - ចំណូលថវិកា សរុប + ជំនួយ

**៥-តុល្យភាពថវិកាសរុបដោយគ្មានជំនួយ** = តុល្យភាពថវិកាសរុប-ជំនួយ ។

**៦-តុល្យភាពក្រៅប្រទេស** = ចំណាយថវិកាក្រៅប្រទេស-ចំណូលថវិកាពីប្រភពក្រៅប្រទេស ។

**៧-តុល្យភាពថវិកាក្នុងប្រទេស** = តុល្យភាពថវិកាសរុប-តុល្យភាពក្រៅប្រទេស ។

## ២. ការធ្វើហិរញ្ញប្បទានឱនភាពថវិកា

**ហិរញ្ញប្បទាន** ត្រូវ **ស្មើ** តែមាន **សញ្ញាផ្ទុយ** នឹងលទ្ធផលនៃការអនុវត្តថវិកាសរុប (អតិរេក ឬ ឱនភាព) តាមនិយមន័យបេឡា ដែលស្ថិតនៅខាងលើបន្ទាត់ ។

សមាសធាតុនៃហិរញ្ញប្បទាន ស្ថិតទៅខាងក្រោមបន្ទាត់ ។ ហិរញ្ញប្បទានមានដូចតទៅ÷

- **ហិរញ្ញប្បទានខាងក្រៅប្រទេស**: ដែលអាចចាត់ថ្នាក់បានជាពីរប្រភេទ÷

-ដែលមានលក្ខណៈដាច់ស្រាច់: ដូចជា **ជំនួយ** ឬ **កម្ចី**


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

- របៀបក្នុងការផ្តល់ ឬ ការរិភាជន៍: **ការទ្រទ្រង់ថវិកា** ឬ **ជំនួយជាគម្រោង**

- **ហិរញ្ញប្បទានក្នុងស្រុក**: ដែលចែកចេញជាពីរប្រភេទ៖

  - **ហិរញ្ញប្បទានដោយធនាគារ**

  - **ហិរញ្ញប្បទានមិនមែនធនាគារ** តាមរយៈកម្ចីពីផ្នែកឯកជន

## ២.១. ការទ្រទ្រង់ថវិកា

ការទ្រទ្រង់ថវិកា ជាជំនួយ ឬ ជាកម្ចី នាំអោយមានការផ្ទេរនូវមូលនិធិចូលទៅក្នុងគណនីរតនាគារ ។ ការចុះកិច្ចបញ្ជីការនេះអនុវត្តទៅតាមរូបភាពពីរយ៉ាង៖ ជាការចុះបញ្ជីដោយផ្ទាល់ ឬ មួយក៏គ្រាន់តែជាការធ្វើនិយ័តកម្មនៅចុងខែ ទៅតាមគណនីដែលគ្រប់គ្រងដោយនាយកដ្ឋានវិនិយោគ និង សហប្រតិបត្តិការអន្តរជាតិ ។

ក្នុងករណីខ្លះ មូលនិធិត្រូវបានផ្ទេរដោយផ្ទាល់ ដោយដៃគូអភិវឌ្ឍន៍ (នៅក្នុងឆ្នាំ ២០០៨ មានជំនួយទ្រទ្រង់ថវិកាដោយចក្រភពអង់គ្លេស ជប៉ុន សហគមន៍អឺរ៉ុប និង ធនាគារពិភពលោក) ។ ប្រសិនបើជំនួយត្រូវបានផ្តល់ក្រោមរូបភាពជាការនាំចូលទំនិញ (ជំនួយជាទំនិញរបស់ជប៉ុន ឬ ជំនួយជាម្ហូបអាហាររបស់បារាំង) ជំនួយទាំងនេះនឹងត្រូវកត់ត្រានៅពេលទូទាត់តាមថ្លៃលក់ទំនិញ ដែលនាំចូលនៅក្នុងទីផ្សារក្នុងស្រុក ។

## ២.២. ជំនួយជាគម្រោង

តារាង **TOFE** កត់ត្រានូវការធ្វើប្រតិបត្តិការវិនិយោគ ឬ គម្រោងអភិវឌ្ឍន៍ ដែលអនុវត្តក្រៅប្រតិបត្តិការរតនាគារជាតិ ដែលអនុវត្តផ្សេងពីនីតិវិធីដូចមានចែងក្នុង អនុក្រឹត្យលេខ ៨២ អនក្រ.បក, ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ ថាជា **ហិរញ្ញប្បទាន** ក្រោមរូបភាព «**ជំនួយជាគម្រោង**»។ ជំនួយជាគម្រោងមាន៖

- គម្រោងផ្តល់ហិរញ្ញប្បទានដោយផ្ទាល់ដោយដៃគូអភិវឌ្ឍន៍ ជាជំនួយ ។
- គម្រោងផ្តល់ហិរញ្ញប្បទានដោយកម្ចីរបស់ធនាគារពិភពលោក និង ធនាគារអភិវឌ្ឍន៍អាស៊ី ។
- គម្រោងផ្តល់ហិរញ្ញប្បទានដោយកម្ចីរបស់ដៃគូទ្វេភាគីដ៏ទៃទៀត ។

**ជំនួយក្រៅប្រទេស**- ទិន្នន័យស្តីពីជំនួយក្រៅប្រទេសប្រមូលដោយ **ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា** និងបោះផ្សាយជារៀងរាល់ឆ្នាំនៅក្នុងខែ កក្កដា នៃឆ្នាំបន្ទាប់ ។ ដើម្បីរៀបចំថវិកាប្រចាំឆ្នាំ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ជ្រើសរើសយកតែគម្រោងណាដែលមានលក្ខណៈជាការវិនិយោគ ដូចជា ជំនួយបច្ចេកទេសពាក់ព័ន្ធនឹងវិនិយោគ ដូចជាការសិក្សាបឋមពីផ្លូវថ្នល់ និង គម្រោងវិនិយោគ ដើម្បីប៉ាន់ស្មានបញ្ចូលក្នុងថវិកាប្រចាំឆ្នាំ ។ តួលេខជាក់ស្តែង នឹងត្រូវយកមកបញ្ចូលក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុទូទាត់ ។ ជាផ្នែកមួយនៃកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមានគោលនយោបាយ បញ្ចូលជំនួយទាំងអស់នៅក្នុងក្របខ័ណ្ឌថវិកាជាតិ ។ ការងារនេះទាមទារអោយមានការកែលម្អចំណាត់ថ្នាក់ចំណាយគម្រោងជំនួយ ដើម្បីអោយមានសង្គតិភាពជាមួយ ចំណាត់ថ្នាក់ថវិកា ក្នុងគោលដៅរក្សាបាននូវការកត់ត្រាជំនួយទាំងអស់ក្នុងគណនីរតនាគារជាតិ ។

**កម្ចី**- គឺជាកម្ចីផ្តល់ដោយធនាគារពិភពលោក ធនាគារអភិវឌ្ឍន៍អាស៊ី មូលនិធិអន្តរជាតិដើម្បីកិច្ចអភិវឌ្ឍន៍ កសិកម្ម (IFAD) អង្គការអូប៉ិច (OPEC) ជប៉ុន ចិន ។ល។ កម្ចីទាំងនេះត្រូវបានកត់ត្រា៖

- **ជាធនធាន** (ហិរញ្ញប្បទាន) ដោយឈរលើមូលដ្ឋានបេឡាផ្តល់ដោយដៃគូអភិវឌ្ឍន៍ ។ ធនាគារពិភពលោក និង ធនាគារអភិវឌ្ឍន៍អាស៊ីផ្តល់ព័ត៌មានដល់នាយកដ្ឋានវិនិយោគ និង សហប្រតិបត្តិការអន្តរជាតិ ពីការបើកផ្តល់សាច់ប្រាក់៖

  - ការទូទាត់ដោយផ្ទាល់ជាមួយអ្នកផ្គត់ផ្គង់

  - ការផ្ទេរថវិកាចូល «**គណនីគម្រោង**» ដែលគ្រប់គ្រងដោយ **អង្គភាពគ្រប់គ្រងគម្រោង** (PIU) ។

- **ជាចំណាយ** ដោយឈរលើមូលដ្ឋាននៃការទូទាត់៖

  - ដោយផ្ទាល់រវាងដៃគូអភិវឌ្ឍន៍ជាមួយអ្នកផ្គត់ផ្គង់

  - តាមរយៈ **អង្គភាពគ្រប់គ្រងគម្រោង** (PIU) ចូលទៅក្នុង «**គណនីគម្រោង**» ។

ចំពោះកម្ចី/ជំនួយទាំងអស់ ដែលប្រើប្រាស់ «**គណនីគម្រោង**» ទំនាក់ទំនងរវាងចំណាយ និង ចំណូល មានដូចតទៅ ÷

**ចំណាយ** =

ធនធាន (ការបញ្ចេញសាច់ប្រាក់ក្នុងរយៈពេលមួយ)

- កំណើនសមតុល្យនៃគណនីគម្រោង ឬ

\+ ការថយចុះសមតុល្យនៃគណនីពិសេស



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ដូចគ្នានេះដែរ ÷

**ធនធាន** (ការបញ្ចេញសាច់ប្រាក់ក្នុងរយៈពេលមួយ) =

ចំណាយ

+ កំណើនសមតុល្យនៃគណនីពិសេស ឬ

- ការថយចុះសមតុល្យនៃគណនីពិសេស

បម្រែបម្រួលសមតុល្យនៃគណនីពិសេសរបស់គម្រោង ឆ្លុះបញ្ចាំងអោយឃើញនៅក្នុងផ្នែក «ហិរញ្ញប្បទានដោយធនាគារ» ។

## ២.៣. ការសងបំណុលក្រៅប្រទេស

ការសងដើមបំណុលឆ្លុះបញ្ចាំងនៅក្នុងថវិកា ជាចំណាយថវិកា ។ និយាមស្ថិតិនៃហិរញ្ញវត្ថុសាធារណៈ ចាត់ថ្នាក់ការសងដើមបំណុល នៅក្នុងផ្នែក «**ហិរញ្ញប្បទាន**» ដើម្បីអាចគណនានូវហិរញ្ញប្បទានសុទ្ធពីបរទេស ដោយឈរលើមូលដ្ឋាននៃរូបមន្ត÷

**កម្ចីសុទ្ធ** =

ការបញ្ចេញសាច់ប្រាក់កម្ចី

- ការសងដើមបំណុល

## ២.៤. ហិរញ្ញប្បទានដោយធនាគារ

**ហិរញ្ញប្បទានធនាគារ** នៃប្រតិបត្តិការរដ្ឋាភិបាល គឺជាសមាសធាតុដ៏សំខាន់នៃគោលនយោបាយរូបិយវត្ថុ និង ថវិកា ។ ***ប្រសិនបើឱនភាពថវិកាត្រូវបានធ្វើហិរញ្ញប្បទានដោយធនាគារ ការបង្កើនរូបិយវត្ថុទៅនឹងបង្កើតអោយមានអតិផរណា*** ។ ដោយសារមូលហេតុនេះហើយ ទើបហិរញ្ញប្បទានធនាគារសុទ្ធនៃប្រតិបត្តិការរបស់រដ្ឋ គឺជាលក្ខណៈវិនិច្ឆ័យដ៏សំខាន់នៃគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ។

**ហិរញ្ញប្បទានធនាគារ** នៃប្រតិបត្តិការរដ្ឋាភិបាល គឺជាការតាមដានត្រួតពិនិត្យនៃប្រព័ន្ធទិន្នន័យពីរផ្សេងគ្នា ÷



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

- ស្ថិតិហិរញ្ញវត្ថុសាធារណៈ TOFE ឆ្លុះបញ្ចាំងត្រង់ ÷ «**ហិរញ្ញប្បទានដោយធនាគារសុទ្ធ**»

- ស្ថិតិរូបិយវត្ថុ និង ធនាគារ (***អង្កេតរូបិយវត្ថុ***) បញ្ចាំងត្រង់ ÷ «**ឥណទានឲ្យរដ្ឋាភិបាលសុទ្ធ**»

ការផ្ទៀងផ្ទាត់សង្គតិភាពរវាងស្ថិតិទាំងពីរមានសារៈសំខាន់ខ្លាំងណាស់ ។ នៅពេលដែលទិន្នន័យហិរញ្ញប្បទានដោយធនាគារខុសគ្នា មានន័យថាមានកំហុសនៅក្នុងស្ថិតិណាមួយក្នុងចំណោមស្ថិតិទាំងពីរ និង អាចនាំអោយមានផលវិបាកយ៉ាងខ្លាំងក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង ការគ្រប់គ្រងរូបិយវត្ថុ ។

ប្រភពទីមួយដែលអាចធ្វើអោយស្ថិតិទាំងពីរមានទិន្នន័យខុសគ្នា គឺ ដោយសារតារាង TOFE កត់ត្រាទិន្នន័យតាម «**លំហូរ**» (Flow) ក្នុងពេលដែលស្ថិតិអង្កេតរូបិយវត្ថុកត់ត្រាទិន្នន័យតាម «**សន្និធិ**» (Stock) ។ ដូច្នេះ គេអាចបង្កើតទំនាក់ទំនងបានតាម÷

- បម្រែបម្រួលនៃសមតុល្យ «**ឥណទានឲ្យរដ្ឋាភិបាលសុទ្ធ**» រវាងដើមគ្រា និង ចុងគ្រា ។ និង

- «**លំហូរ**» ដែលកត់ត្រាដោយតារាង TOFE នៅក្នុងរយៈពេលនោះដែរ ។

ក្នុងន័យនេះ មូលហេតុចម្បង ដែលនាំអោយមានទិន្នន័យខុសគ្នាមានដូចតទៅ÷

ទីមួយ- ទិន្នន័យដែលត្រួតពិនិត្យនៅក្នុងតារាង TOFE នៅមិនទាន់ដាក់បញ្ចូលរហូតមកទល់ពេលនេះនៅក្នុងស្ថានភាពរូបិយវត្ថុ ។ ឧទាហរណ៍ សាច់ប្រាក់ជាប្រាក់រៀលនៅក្នុងរតនាគារខេត្ត- ក្រុង ដែលកត់ត្រានៅក្នុងគណនីផ្សេងទៀតរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

ទីពីរ- ផ្ទុយទៅវិញ អង្កេតរូបិយវត្ថុមានគណនីរបស់ក្រសួង ស្ថាប័នផ្សេងៗ ដែលក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុមិនអាចគ្រប់គ្រងចលនាលំហូរសាច់ប្រាក់បាន ។ ដូច្នេះ ដើម្បីធានាសង្គតិភាពរវាងប្រព័ន្ធស្ថិតិទាំងពីរនេះ ត្រូវបញ្ចូលទិន្នន័យទាំងនេះទៅក្នុង «**ហិរញ្ញប្បទានដោយធនាគារ**» នៃតារាង TOFE ហើយបដិការនៃការចុះបញ្ជីការនេះ ត្រូវកត់ត្រាទុកក្នុង «**ប្រតិបត្តិការកំពុងដំណើរការ**» ។

បន្ទាប់ពីធ្វើការកែតម្រូវដូចបានលើកឡើងខាងលើ «**ហិរញ្ញប្បទានដោយធនាគារ**» នៃតារាង TOFE នឹងមានសង្គតិភាពជាមួយ «**ឥណទានឲ្យសុទ្ធរដ្ឋាភិបាល**» នៃតារាងអង្កេតរូបិយវត្ថុ ។ តារាងអង្កេតរូបិយវត្ថុចែក «**ឥណទានឲ្យសុទ្ធរដ្ឋាភិបាល**» ជាពីរផ្នែក ÷

- បញ្ញើរដ្ឋាភិបាល ។



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

- ឥណទេយ្យរដ្ឋាភិបាល ។

តារាងឧបសម្ព័ន្ធរបស់តារាង **TOFE** បង្ហាញលម្អិតនូវសមតុល្យ និង លំហូរនៃគណនីផ្សេងៗដែលបញ្ចូលទៅក្នុងផ្នែក «**ហិរញ្ញប្បទានដោយធនាគារ**» ។ ក្នុងចំណោមគណនីទាំងនេះ យើងឃើញមានគណនី «**សាច់ប្រាក់ជាប្រាក់រៀលរបស់រតនាគារ**» ។ តាមនិយាមរបស់ **មូលនិធិរូបិយវត្ថុអន្តរជាតិ** ទុនបម្រុងរបស់រដ្ឋបាលកណ្តាល ក្រោមរូបភាពជា ក្រដាសប្រាក់ កាក់ និង បញ្ញើ មិនត្រូវគិតចូលក្នុងរូបិយវត្ថុទៅឡើយ ។ ដូច្នេះ សាច់ប្រាក់របស់រតនាគារត្រូវតែដកចេញពី «**ហិរញ្ញប្បទានដោយធនាគារ**» ។

## ២.៥. ហិរញ្ញប្បទានដោយផ្នែកឯកជន

គណនី «**ហិរញ្ញប្បទានដោយផ្នែកឯកជន**» ត្រូវបានចែកជាអនុគណនីបីដូចតទៅ៖

**កម្ចីក្នុងប្រទេស**- គឺជាកម្ចីរយៈពេលវែង ដែលសាធារណៈជនផ្តល់អោយរដ្ឋាភិបាល ។ អនុគណនីចុះបញ្ជីការនូវការបញ្ចេញសាច់ប្រាក់ ។

**ការសងបំណុលក្នុងប្រទេស**- គឺជាគណនី ដែលបង្ហាញពីទំហំទឹកប្រាក់នៃការសងបំណុលក្នុងស្រុក ។

**គណនីគតិយជន និង បញ្ញើធ្នាក់ធានា**- ផ្នែកឯកជន (ពាណិជ្ជករ អ្នកនាំចូល និង សហគ្រាស) អាចបើកគណនី (មុនកំណែទម្រង់ឆ្នាំ ២០០៧) ប្រាក់បញ្ញើនៅរតនាគារ ។ ប្រាក់បញ្ញើទាំងនេះត្រូវចុះកិច្ចបញ្ជីការក្នុងគណនីលេខ ៤២៣ ដែលអនុញ្ញាតអោយអ្នកបង់ពន្ធ ជាពិសេសអ្នកត្រូវបង់ពន្ធ និង អាករនាំចូលអាចទូទាត់បានយ៉ាងលឿន និង ងាយស្រួល តាមរយៈការចុះបញ្ជីការ (ការផ្ទេរផ្ទៃក្នុង) នូវចំនួនពន្ធ និង អាករដែលគេត្រូវបង់ជូនទីចាត់ការគយ និង រដ្ឋាករ ក្នុងគោលដៅជម្រុញការងារត្រួតពិនិត្យគយ ។ អ្នកផ្ញើប្រាក់មិនអាចបើកប្រាក់ជាសាច់ប្រាក់បានឡើយ ដោយសារតែគណនីនេះត្រូវបានប្រើប្រាស់សម្រាប់តែទូទាត់ពន្ធ និង អាករតែប៉ុណ្ណោះ ។

បន្ទាប់ពីការដាក់អោយប្រើប្រាស់នូវប្រព័ន្ធទូទាត់ដោយផ្ទាល់ គណនីប្រាក់បញ្ញើដើរតួនាទីមួយផ្សេងទៀតដែលអនុញ្ញាតអោតរតនាគារទូទាត់ជាមួយអ្នកផ្គត់ផ្គង់ តាមរយៈការបង្វែរចូលគណនីរបស់អ្នកផ្គត់ផ្គង់តែម្តង (ចុះបញ្ជីការខាង ឥណទេយ្យ ក្នុងគណនីចំណាយថវិកា និង ឥណទាន ក្នុងគណនីប្រាក់បញ្ញើគតិយជន) ។

ម្យ៉ាងវិញទៀត រតនាគារអនុញ្ញាតអោយអ្នកផ្ញើប្រាក់អាចផ្ទេរកាត់កងរវាងគ្នា និង គ្នា ។ ដូច្នេះ អ្នកផ្ញើប្រាក់ណាដែលមិនត្រូវបង់ពន្ធ និង អាករអាចផ្ទេរឥណទានរបស់ខ្លួន អោយទៅអ្នកផ្ញើប្រាក់ណាដែលត្រូវការបង់ពន្ធ និង អាករ ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ការបើកគណនីអតិយជនបង្កើតអោយមានផលវិបាកដូចតទៅ៖

**ផលវិបាកល្អ:**

- ផ្តល់រតនាគារនូវសាច់ប្រាក់ដែលអាចប្រើប្រាស់ដោយឥតគិតថ្លៃ ដោយសារប្រាក់បញ្ញើអត់មានការប្រាក់ ដែលខុសពីប័ណ្ណរតនាគារ ។
- ផ្តល់ការលើកទឹកចិត្តដល់ការអនុវត្តនូវគោលនយោបាយបដិដុល្លារភាវូបនីយកម្ម ដោយសារប្រតិបត្តិការនៃគណនីប្រាក់បញ្ញើអនុវត្តជាប្រាក់រៀល និង មានទំហំជាច្រើនពាន់លានរៀល ។
- ដោះស្រាយបញ្ហាបំណុលសាច់ប្រាក់ ដែលរដ្ឋជំពាក់ផ្នែកឯកជន និង ផ្នែកឯកជនជំពាក់រដ្ឋ ដោយសារអ្នកផ្គត់ផ្គង់ និង រដ្ឋអាចទូទាត់គ្នាតែម្តង ដោយគ្រាន់តែកាត់កងចុះឡើងប៉ុណ្ណោះ ។ ដូច្នេះ បញ្ហាកង្វះខាតសាច់ប្រាក់ដែលបណ្តាលអោយមានបំណុលថវិកា និង បំណុលពន្ធ អាចដោះស្រាយរួច ។

**ផលវិបាកអាក្រក់:**

- វិធីសាស្ត្រនៃការគ្រប់គ្រងសាច់ប្រាក់របស់រដ្ឋត្រូវតែកែលម្អ ដោយត្រូវធ្វើការព្យាករណ៍នៃកម្រិតប្រាក់បញ្ញើរបស់សហគ្រាសនៅរតនាគារ ។ ទន្ទឹមនឹងនេះ ការអនុវត្តវិធីទូទាត់គ្នារវាងបំណុលថវិកា និង បំណុលពន្ធធ្វើអោយរតនាគារមិនអាចទទួលបាននូវសាច់ប្រាក់ ដើម្បីយកទៅប្រើប្រាស់សម្រាប់ការងារជាអាទិភាព ។
- ការអនុវត្តទូទាត់អ្នកផ្គត់ផ្គង់ តាមរយៈការកាត់កងរវាងគណនីនៅរតនាគារ នាំអោយមានភាពធូររលុងក្នុងការគ្រប់គ្រងចំណាយថវិកា ។

## ៣. សមាសធាតុផ្សេងទៀតនៃតារាងប្រតិបត្តិការហិរញ្ញវត្ថុសាធារណៈ:

### ៣.១. ការកែតម្រូវនៃអត្រាប្តូរប្រាក់

ប្រាក់បញ្ញើជារូបិយប័ណ្ណនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ (ជាពិសេស គណនីរបស់អង្គភាពគ្រប់គ្រងគម្រោង) ដែលកត់ត្រានៅក្នុងហិរញ្ញប្បទានធនាគារត្រូវបានវាយតម្លៃឡើងវិញ ជារៀងរាល់ខែ ទៅតាមការវិវត្តនៃអត្រាប្តូរប្រាក់រៀល-ដុល្លារ ។ បដិការនៃការវាយតម្លៃឡើងវិញនេះ អាចចាត់ទុកថាជា ចំណូល ឬ មួយជាការបាត់បង់ ដែលត្រូវចុះបញ្ជីការនៅក្នុងគណនី «**ការកែតម្រូវនៃអត្រាប្តូរប្រាក់**» ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

### ៣.២. ប្រតិបត្តិការកំពុងដំណើរការ

ផ្នែក «**ប្រតិបត្តិការកំពុងដំណើរការ**» ប្រមូលផ្តុំ គណនីកែតម្រូវ ឬ គណនីឆ្លងកាត់ ផ្សេងៗ ហើយលំហូរនេះមិនអាចត្រូវបានផ្តាច់ចេញពីតារាង ដោយសារទំហំសាច់ប្រាក់មានតិចតួច ឬ មួយដោយសារតែនៅក្នុងរយៈពេលវែង លំហូរនេះនឹងមានតុល្យភាព ដោយជាគោលការណ៍ សមតុល្យនឹងឈានទៅរកសូន្យ ។ គណនីនេះត្រូវបានបង្ហាញលម្អិតនៅក្នុងតារាងឧបសម្ព័ន្ធនៃតារាង **TOFE** ។ ក៏ប៉ុន្តែ នៅពេលមានលំហូរដែលមានសាច់ប្រាក់ច្រើន និង ខុសប្លែកពីធម្មតា ទាមទារអោយមានការបកស្រាយបំភ្លឺ ។

### ៣.៣. កំហុសផ្សេងៗ

«**កំហុសផ្សេងៗ**» កត់ត្រានូវបរិមាណសរុបនៃគណនីតារាង **TOFE** ដែលត្រូវតែស្មើសូន្យ ដោយសារតែឡូស៊ិចនៃការរៀបចំតារាងនេះឡើង ។ ដូចយើងបានឃើញស្រាប់ ប្រព័ន្ធគណនីទ្វេភាគទាមទារអោយមានតារាងបដិការមួយ ដែលត្រូវចុះបញ្ជីការតាមចំនួនដូចគ្នា តែត្រូវមានសញ្ញាផ្ទុយគ្នា នៅគ្រប់ពេលវេលាទាំងអស់ដែលមានការចុះបញ្ជីការ ។ ដូច្នេះហើយ ទំហំទឹកប្រាក់ដែលមាននៅក្នុង «**កំហុសផ្សេងៗ**» នេះ មិនត្រូវអោយលើសខ្លាំងពីចំនួនមួយដែលសមស្របឡើយ ។

### ៣.៤. ប្រតិបត្តិការនៅក្នុងរយៈពេលបន្ថែម

ប្រតិបត្តិការហិរញ្ញវត្ថុសាធារណៈត្រូវបានចែកជាពីរ៖

ទីមួយ- ប្រតិបត្តិការថវិកា

ទីពីរ- ប្រតិបត្តិការរតនាគារ

ប្រតិបត្តិការថវិកាត្រូវអនុវត្តទៅតាមការិយបរិច្ឆេទនៃឆ្នាំថវិកា ដែលចាប់ផ្តើមនៅថ្ងៃទី ១ ខែ មករា ហើយបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ។ នៅចុងខែធ្នូនៃឆ្នាំនីមួយៗ រតនាគារកំណត់ថ្ងៃដែលឈប់ទទួលអាណត្តិបើកប្រាក់ ដើម្បីអាចអោយរតនាគារបិទបញ្ជីការគណនីប្រចាំឆ្នាំ ។ ដូច្នេះ នៅចុងការិយបរិច្ឆេទនៃឆ្នាំថវិកា រតនាគារជាតិបញ្ចប់នូវប្រតិបត្តិការថវិកា តែនៅបន្តនូវប្រតិបត្តិការរតនាគារទៀត រហូតដល់ចប់រយៈពេលបន្ថែម (Période complémentaire) ។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុកំណត់នូវរយៈពេលបន្ថែមនេះ ។

នៅក្នុងរយៈពេលបន្ថែម រតនាគារជាតិបង្កើតឡើងនូវគណនីពីរ៖

- គណនីតុល្យការធម្មតាប្រចាំខែ និង


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

- គណនីនៃតុល្យការបន្ថែម ដែលជាប្រតិបត្តិការពាក់ព័ន្ធទៅនឹងការអនុវត្តថវិកានៃឆ្នាំកន្លងទៅ ដែលទាមទារ អោយមានការធ្វើនិយ័តកម្មគណនេយ្យ នៅក្នុងរយៈពេលបន្ថែមនេះ ។

គោលដៅនៃរយៈពេលបន្ថែម គឺដើម្បីបង្ហាញនូវគណនីនៃការគ្រប់គ្រងរួមនៃប្រតិបត្តិការនៅក្នុងថវិកាតែមួយ ។ ការចុះបញ្ជីការចុងក្រោយនៃប្រតិបត្តិការនិយ័តភាពអាណត្តិបើកប្រាក់ នៅក្នុងរយៈពេលបន្ថែម ត្រូវដាក់ថ្ងៃនៃឆ្នាំមុន ដោយសារតែការអនុវត្តថវិកានេះប្រើប្រាស់នូវឥណទានថវិកានៃឆ្នាំមុន ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ជំពូកទី ៩

# ទិន្នភាពម៉ាក្រូសេដ្ឋកិច្ច និង រូបិយវត្ថុ

ឱនភាពថវិកា ជញ្ជីងពាណិជ្ជកម្ម ជញ្ជីងទូទាត់ចរន្ត ជញ្ជីងទូទាត់ អត្រាការប្រាក់ អតិផរណា អនីតិកម្ម គឺជាអញ្ញត្តិ ដែលមានការពាក់ព័ន្ធនឹងគ្នា និង ជាឧបករណ៍នៃគោលនយោបាយថវិកា សេដ្ឋកិច្ច និង រូបិយវត្ថុ ។

ទស្សនទានទាំងនេះ គឺជាប្រធានបទនៃគោលការណ៍ណែនាំរបស់ **មូលនិធិរូបិយវត្ថុអន្តរជាតិ** និង **អង្គការដើម្បីកិច្ចសហប្រតិបត្តិការ និងការអភិវឌ្ឍសេដ្ឋកិច្ច** (OECD) គោលការណ៍ណែនាំរបស់ **មូលនិធិរូបិយវត្ថុអន្តរជាតិ** ស្តីពីជញ្ជីងទូទាត់ ឆ្នាំ ២០០៨ ប្រព័ន្ធគណនេយ្យជាតិ ឆ្នាំ ១៩៩៣ និង គោលការណ៍ណែនាំរបស់ **មូលនិធិរូបិយវត្ថុអន្តរជាតិ** ស្តីពីស្ថិតិហិរញ្ញវត្ថុសាធារណៈ ឆ្នាំ ២០០១ (GFS 2001) ។

## ១. ជញ្ជីងពាណិជ្ជកម្ម

**ជញ្ជីងពាណិជ្ជកម្ម** កត់ត្រានូវការផ្លាស់ប្តូរខាងផ្នែកពាណិជ្ជកម្ម រវាងប្រទេស និង ដៃគូពាណិជ្ជកម្មរបស់ខ្លួន (ពាណិជ្ជកម្មក្រៅប្រទេស) ។ ជញ្ជីងពាណិជ្ជកម្មមិនរាប់បញ្ចូលនូវការផ្ទេរសេវា និង មូលធន ដែលជាផ្នែកមួយនៃបន្លាស់ប្តូរក្រៅប្រទេស តែខុសពីពាណិជ្ជកម្មក្រៅប្រទេស ។ ជញ្ជីងពាណិជ្ជកម្មត្រូវបានរៀបចំឡើង ដោយឈរលើមូលដ្ឋាននៃស្ថិតិរបស់អគ្គនាយកដ្ឋានគយ និង រដ្ឋាករ ។ រង្វាស់ពាណិជ្ជកម្មត្រូវធ្វើនៅព្រំដែននៃប្រទេសនាំចេញតាមនិយមន័យ **Free on Board (FOB)** ។ ទំនិញដែលនាំចូលជាបណ្តោះអាសន្ន (សម្រាប់ការជួសជុល ឬ សម្រាប់បម្លែង) ដោយមិនមានការផ្លាស់ប្តូរនូវម្ចាស់កម្មសិទ្ធិ នឹងមិនមានការកត់ត្រាឡើយ ។ ការកំណត់តម្លៃត្រូវធ្វើឡើង តាមនិយមន័យ **Cost Insurance Freight (CIF)** បន្ទាប់ពីបូកបញ្ចូលនូវថ្លៃ ធានារ៉ាប់រង និង ដឹកជញ្ជូនរួចមក ទៅលើថ្លៃដើមតាមនិយមន័យ **FOB** ។

តម្លៃ **CIF =** តម្លៃ **FOB +** ការធានារ៉ាប់រង **+** ការដឹកជញ្ជូន

- យើងត្រូវចាប់ផ្តើមពីការប្រមូលព័ត៌មានពីអគ្គនាយកដ្ឋានគយ និង រដ្ឋាករ (តាមនិយមន័យ **FOB** សម្រាប់ការនាំចេញ និង តាមនិយមន័យ **CIF** សម្រាប់ការនាំចូល) ។
- យើងដកចេញនូវថ្លៃ ធានារ៉ាប់រង និង ការដឹកជញ្ជូន ដើម្បីទទួលបាននូវថ្លៃការនាំចូលតាមនិយមន័យ **FOB** ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

- យើងដកចេញនូវការនាំចូលសម្រាប់ការជួសជុល ឬ សម្រាប់ការកែឆ្នៃ ។
- យើងបន្ថែមប្រតិបត្តិការដោយគ្មានការទូទាត់ ដែលនាំអោយមានការផ្ទេរនូវកម្មសិទ្ធិ ។
- យើងទទួលបាននូវទិន្នន័យគយកែតម្រូវ ដែលអាចដាក់ក្នុងជញ្ជីងទូទាត់បាន ។

ជញ្ជីងពាណិជ្ជកម្មនៃប្រទេសទាំងអស់ តាមការរៀបចំឡើង ត្រូវតែបូកចូលគ្នាស្មើនឹងសូន្យ (ការនាំចេញត្រូវស្មើនឹងការនាំចូល) ។

## ២. ជញ្ជីងទូទាត់ចរន្ត

**ជញ្ជីងទូទាត់ចរន្ត** ត្រូវស្មើនឹងជញ្ជីងពាណិជ្ជកម្ម បូកនឹងជញ្ជីងពាណិជ្ជកម្មសេវា ប្រាក់ចំណូល និង ការផ្ទេរចរន្ត ។

### ២.១. សេវាកម្ម

- ការនាំចេញសេវា ដូចជាការធានារ៉ាប់រង ការដឹកជញ្ជូន និង ទេសចរណ៍
- ការនាំចូលសេវា និង ការផ្ទេរជាឯកតោភាគី (ជំនួយ)

យើងអាចរៀបរាប់ដោយលម្អិតនូវ ÷

- សេវាក្រៅពីការធ្វើដំណើរ ÷

+ការដឹកជញ្ជូន

- ជើងទឹក
- ជើងអាកាស
- ផ្សេងៗ (ផ្លូវថ្នល់ ផ្លូវដែក និង តាមទន្លេ)

+សេវាគមនាគមន៍អេឡិចត្រូនិច

- ការទូទាត់តាមសេវាប្រៃសណីយ៍ តេឡេក្រាហ្វ និង ទូរស័ព្ទ
- ការប្រើប្រាស់បណ្តាញគមនាគមន៍អេឡិចត្រូនិច



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

- ការផ្ទេរទិន្នន័យ

+សេវាសាងសង់

- ថ្លៃដំណើរការ និង ប្រាក់ចំណេញនៃការដ្ឋាន
- ចំណាយលើការរុករករ៉ែ និង ការខួងអណ្តូងរ៉ែ ដោយអនិវាសនជន
- ការទិញទំនិញនៅក្នុងប្រទេសទីបីដើម្បីកិច្ចការនេះ

+ការធានារ៉ាប់រង

- ផ្តល់ដោយសហគ្រាសនិវាសនជនដល់ អនិវាសនជន និង ការវិនិយោគ
- ការធានារ៉ាប់រងដោយផ្ទាល់ (ការដឹកជញ្ជូន ការខូចខាត ឧប្បត្តិហេតុ ការទទួលខុសត្រូវក្នុងការសាងសង់ ការធានារ៉ាប់រងបន្ត)
- ការធានារាប៉រងអន្តរជាតិ

+សេវាហិរញ្ញវត្ថុ

- កំរៃជើងសារ និង កំរៃធនាគារ សម្រាប់ប្រតិបត្តិការប្តូរប្រាក់ ការជួញដូរតម្លៃចលនវត្ថុ

+សេវាព័ត៌មានវិទ្យា និង ព័តិមាន

- ពន្ធលើការប្រើប្រាស់កម្មវិធីព័ត៌មានវិទ្យា

+ច្បាប់ និង អាជ្ញាប័ណ្ណសម្រាប់

- ការប្រើប្រាស់ម៉ាក វិញ្ញាបនប័ត្រ គំរូ
- ច្បាប់និពន្ធ និង ច្បាប់កម្មសិទ្ធិផ្ទេរដោយអនិវាសនជន ជូនដល់និវាសនជន និង ពីនិវាសនជនជូនដល់អនិវាសនជន

+សេវាផ្សេងៗផ្តល់អោយសហគ្រាស

- ពាណិជ្ជកម្មអន្តរជាតិ

- កម្រៃជើងសារពាណិជ្ជកម្ម

- សេវាផ្សេងៗ (កម្រៃសិក្សា ស្រាវជ្រាវ ជំនួយបច្ចេកទេស)

+សេវាបុគ្គលិក វប្បធម៌ និង កំសាន្ត

- ពន្ធលើផលិតផលកុន

- ការទិញ ការលក់ ការជួយកម្មវិធីវិទ្យុ និង ទូរទស្សន៍

+សេវានៃរដ្ឋបាលសាធារណៈ

- កិច្ចដំណើរការស្ថានទូតនៅបរទេស

- សេវាធ្វើដំណើរ

+ចំណាយអនិវាសនជន

## ២.២. ប្រាក់ចំណូល

ប្រាក់ចំណូលបានមកពី÷

- ប្រាក់បៀវត្សរ៍អនិវាសនជនផ្តល់ដោយនិវាសនជន និង ប្រាក់បៀវត្សរ៍និវាសនជនផ្តល់ដោយអនិវាសនជន
- ការវិនិយោគ (ការទូទាត់ពាក់ពន្ធនឹងទ្រព្យសម្បត្តិហិរញ្ញវត្ថុក្រៅប្រទេស)

## ២.៣. ការផ្ទេរចរន្ត

ការផ្ទេរចរន្ត គឺជាការផ្ទេរដែលពាក់ព័ន្ធនឹងទំនិញ សេវា និង មូលធនដែលនាំចេញដោយគ្មានបដិការ (ដោយគ្មានការទូទាត់ជាសាច់ប្រាក់ ឬ ទំនិញ) ÷

- ការផ្ទេរចរន្តនៃរដ្ឋបាលសាធារណៈ (ការចូលរួមវិភាគទានចំពោះអង្គការអន្តរជាតិ)
- ការផ្ទេរប្រាក់ចំណូលរបស់ពលករ (ពីបរទេសមកកម្ពុជា និង ពីកម្ពុជាទៅបរទេស)
- ជំនួយ និង ជំនួយមនុស្សធម៌
- ការឧបត្ថម្ភកធន


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

**វិបត្តិជញ្ជីងទូទាត់ចរន្ត** អនុញ្ញាតអោយវាស់វែងនូវសមត្ថភាព (ឬ តម្រូវការ) ហិរញ្ញប្បទានរបស់ប្រទេស ។ និនភាពដ៏វ៉ារ៉ៃនៃជញ្ជីងទូទាត់ចរន្តអាចនាំអោយមានបំណុលក្រៅប្រទេស និង ប៉ះពាល់ជាអវិជ្ជមានដល់អត្រាប្តូរប្រាក់ ។

## ៣. គណនីមូលធន

**គណនីមូលធន** កត់ត្រានូវប្រតិបត្តិការដែលនាំអោយមានការផ្ទេរកម្មសិទ្ធិពីទ្រព្យសកម្មថេរ ឬ ការបំពេញកាតព្វកិច្ចដោយឥណទាយិក ដោយគ្មានបដិការ (ដូចជាការផ្ទេរមូលធន) និង ការទិញ ឬ ការលក់ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុអរូបិយ ។

### ៣.១. ការផ្ទេរជាមូលធន

ការផ្ទេរជាមូលធនបែងចែកជាៈ

- ការសងបំណុល និង
- ការផ្ទេរផ្សេងទៀត ។

### ៣.២. ការទិញ ឬ ការលក់ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុអរូបិយ

ការទិញ ឬ ការលក់ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុអរូបិយ ផ្តោតទៅលើទ្រព្យអរូបិយ (វិញ្ញាបនប័ត្រ ច្បាប់អ្នកនិពន្ធ អាជ្ញាប័ណ្ណ ម៉ាក ។ល។) ដែលទិញ ឬ លក់ដោយនិវាសនជន ទៅអោយនិវាសនជន ។

## ៤. គណនីហិរញ្ញវត្ថុ

**គណនីហិរញ្ញវត្ថុ** ត្រូវបានរៀបចំឡើងទៅតាមសារជាតិនៃមូលធន (វិនិយោគដោយផ្ទាល់ វិនិយោគជាភាគហ៊ុន ផលិតផលហិរញ្ញវត្ថុ ទុនបម្រុង)

### ៤.១. ការវិនិយោគដោយផ្ទាល់

ការវិយោគដោយផ្ទាល់ផ្តោតទៅលើ ការវិនិយោគដោយផ្ទាល់ (ពីបរទេស) នៅកម្ពុជា និង ការវិនិយោគរបស់កម្ពុជានៅបរទេស ។ ការវិនិយោគនេះអាចពាក់ព័ន្ធនឹងសហគ្រាស ឬ ទ្រព្យអចលនវត្ថុ ។ យើងចាត់ទុកថាមានការវិនិយោគដោយផ្ទាល់ នៅពេលដែលចំណែកមូលធន ឬ សិទ្ធិក្នុងការបោះឆ្នោតស្មើយ៉ាងហោចណាស់ ១០% ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ៤.២. ការវិនិយោគភាគហ៊ុន

ការវិនិយោគភាគហ៊ុន គឺជាប្រតិបត្តិការលើភាគហ៊ុនដែលអាចទិញ- លក់បានរវាងនិវាសនជន និង អនិវាសនជន ។

## ៤.៣. ផលិតផលហិរញ្ញវត្ថុដេរីវេ

ផ្នែកនេះពាក់ព័ន្ធនឹងលាភការជាភាគហ៊ុន អត្រាការប្រាក់នៃផលិតផល ស្វប់ ដែលពីពេលមុនត្រូវបានចាត់ថ្នាក់ជាការវិនិយោគភាគហ៊ុន ។

## ៤.៤. ការវិនិយោគដទៃទៀត

ការវិនិយោគឯកទៀតមាន ÷

- ឥណទានពាណិជ្ជកម្មផ្តល់ដោយអនិវាសនជន ដល់អតិថិជនជានិវាសនជន (និងដោយនិវាសនជន ដល់អតិថិជនជាអនិវាសនជន) ។
- កម្ចី និង បញ្ញើ
- ទុនបម្រុងដែលជាទុនបម្រុងអន្តរជាតិ ដែលអាចទទួលបានភ្លាម ឬ ដែលស្ថិតទៅក្រោមការគ្រប់គ្រងរបស់ធនាគារជាតិនៃកម្ពុជា ដើម្បីអាចធ្វើហិរញ្ញប្បទាននូវអតុល្យភាពនៃការទូទាត់ ឬ អន្តរាគមន៍ដើម្បីកាត់បន្ថយអតុល្យភាពនោះ ។

**ទុនបម្រុងអន្តរជាតិដុល** មានសមាសធាតុដូចតទៅ÷

- មាស
- ទុនបម្រុងជា **សិទ្ធិបោះផ្សាយពិសេស** (SDR)
- ស្ថានភាពទុនបម្រុងនៅ មូលនិធិរូបិយវត្ថុអន្តរជាតិ
- រូបិយប័ណ្ណនៅបរទេស

**ទុនបម្រុងអន្តរជាតិផ្លូវការ** គឺជាកំណើននៃទុនបម្រុងដុល÷

- រូបិយប័ណ្ណនៅក្នុងប្រទេស


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

**ទុនបម្រុងសុទ្ធជារូបិយប័ណ្ណ** គឺជាកំណើននៃទុនបម្រុងផ្លូវការ ÷

- ការសន្យា

តាមការរៀបចំ ជញ្ជីងទូទាត់ត្រូវមានសមតុល្យ ស្មើនឹងសូន្យ ។

## ៥. គោលនយោបាយសេដ្ឋកិច្ច

គោលដៅនៃកំណើនសេដ្ឋកិច្ចអាចសង្ខេបជា «**ចតុរង្គសំភ្ជីសិទ្ធិ**» ដូចខាងក្រោម ÷

- ស្ថេរភាពថ្លៃ
- តុល្យភាពថវិកា
- តុល្យភាពខាងក្រៅ
- កំណើនប្រកបដោយសមធម៌ (ការកាត់បន្ថយភាពក្រីក្រ និង វិសមភាព) និង ការបង្កើតការងារពេញលេញ។

យើងនឹងពិភាក្សាផងដែរនៅផ្នែកខាងក្រោយ ពីការតាមដានត្រួតពិនិត្យសេដ្ឋកិច្ច ។

## ៦. គោលនយោបាយរូបិយវត្ថុ

**គោលនយោបាយរូបិយវត្ថុ** គឺជាអន្តរាគមន៍ (នៃធនាគារជាតិនៃកម្ពុជា) ទៅលើអញ្ញត្តិរូបិយវត្ថុនៃការប្រើប្រាស់ ការវិនិយោគ និង ផលិតកម្ម ក្នុងគោលដៅធានានូវស្ថិរភាពថ្លៃ អត្រាប្តូរប្រាក់ អនិកម្មភាព កំណើនការអភិវឌ្ឍន៍សេដ្ឋកិច្ច ការកាត់បន្ថយភាពក្រីក្រ និង វិសមភាព ។ បធ្យោបាយត្រួតពិនិត្យមានដូចតទៅ÷

- ការកំណត់អត្រាការប្រាក់គោលនយោបាយ (Policy rate)
- ទុនបម្រុងកាតព្វកិច្ចសម្រាប់ធនាគារពាណិជ្ជ
- សកម្មភាពលើការផ្គត់ផ្គង់រូបិយវត្ថុ

## ៧. គោលនយោបាយថវិកា

**គោលនយោបាយថវិកា** គឺជាការអនុវត្តថវិកា តាមរយៈការប្រមូលចំណូល ការអនុវត្តចំណាយ និង ការធានាអោយបាននូវតុល្យភាពរវាងចំណូល និង ចំណាយ ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

### ៧.១. ចំណូល

រាល់ការយកពន្ធជាកាតព្វកិច្ចធ្វើអោយអានុភាពនៃការទិញរបស់ភ្នាក់ងារសេដ្ឋកិច្ចដែលពាក់ព័ន្ធធ្លាក់ចុះ ។ ក៏ប៉ុន្តែ ការប្រមូលពន្ធបង្កើតឡើងនូវលទ្ធភាពអោយរដ្ឋអនុវត្តចំណាយ ក្នុងគោលដៅអភិវឌ្ឍន៍ ។

### ៧.២. ចំណាយ

ចំណាយនៃថវិការដ្ឋផ្តើមចេញពីមុខងាររបស់រដ្ឋដើម្បីធានាបូណិភាព (យុត្តិធម៌ សន្តិសុខ ការទូត បំណុលសាធារណៈ) និង មុខងារសេដ្ឋកិច្ច និង សង្គមរបស់រដ្ឋ ។ រដ្ឋត្រូវទទួលរ៉ាប់រងនូវសេវាសាធារណៈ ដែលត្រូវផ្តល់ជូនប្រជាពលរដ្ឋ៖ សុខាភិបាល អប់រំ បរិស្ថាន ហេដ្ឋារចនាសម្ព័ន្ធ ។ល។ រដ្ឋត្រូវកែតម្រូវនូវផលប៉ះពាល់ជាអវិជ្ជមាននៃកំណើនសេដ្ឋកិច្ច (ការបំពុលបរិស្ថាន ការបំពុលសម្លេង) និង ការបែងចែកធនធានឡើងវិញ ដើម្បីកែតម្រូវវិសមភាព ។ រដ្ឋត្រូវអនុវត្តនូវគោលនយោបាយសាធារណៈ ។

### ៧.៣. តុល្យភាពថវិកា

ឱនភាពថវិកានៅក្នុងប្រព័ន្ធគ្រប់គ្រង គឺជាផលដករវាងចំណូល និង ចំណាយថវិកា ។ នៅក្នុងគម្រោងច្បាប់ស្តីពីហិរញ្ញវត្ថុប្រចាំឆ្នាំ និង នៅក្នុងតារាង **TOFE** បណ្តោះអាសន្ន ឱនភាពថវិកា ដែលត្រូវធ្វើអោយមានតុល្យភាពឡើងវិញតាមរយៈ ការធ្វើហិរញ្ញប្បទានពីក្រៅប្រទេស ។ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវគោលនយោបាយយ៉ាងហ្មឹងម៉ាត់ ដើម្បីធ្វើហិរញ្ញប្បទាននៃឱនភាពថវិកា តាមរយៈជំនួយ និង កម្ចីដែលមានលក្ខណៈសម្បទានប៉ុណ្ណោះ ក្នុងគោលដៅធានាអោយបាននូវការគ្រប់គ្រងបំណុលក្រៅប្រទេស អោយមានចីរភាព ។

នៅពេលដែលស្ថានភាពថវិកា ជាពិសេសស្ថានភាពចំណូលថវិកាកើនឡើងដល់កម្រិតមួយយ៉ាងខ្ពស់នៅពេលអនាគត ឱនភាពថវិកាអាចធ្វើហិរញ្ញប្បទានតាមរយៈការបោះផ្សាយបំណុលក្នុងប្រទេស ដូចជា ប័ណ្ណរតនាគារ ឬ សញ្ញាប័ណ្ណរដ្ឋជាដើម ។

## ៨. ការតាមដានត្រួតពិនិត្យសេដ្ឋកិច្ច

ការតាមដានត្រួតពិនិត្យគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចត្រូវបានអនុវត្ត ដោយដាក់ចេញនូវគោលដៅច្បាស់លាស់ និង ត្រួតពិនិត្យការអនុវត្ត ។ ការតាមដានត្រួតពិនិត្យនេះអាចអនុវត្ត ទាំងនៅក្នុងក្របខ័ណ្ឌជាតិ ទាំងនៅក្នុងក្របខ័ណ្ឌតំបន់ ដូចជាក្នុងក្របខ័ណ្ឌអាស៊ាន អាស៊ានបូកបី ឬ ក្នុងក្របខ័ណ្ឌស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ ដូចជា មូលនិធិរូបិយវត្ថុអន្តរជាតិជាដើម ។


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

## ៨.១. សូចនាករតាមដាន

សូចនាករតាមដានមានដូចតទៅ៖

- អនុបាតឱនភាពថវិកាគ្មានជំនួយ លើផលិតផលសរុបក្នុងស្រុក (ផសស) តាមថ្លៃបច្ចុប្បន្ន
- អនុបាតលទ្ធផលបឋម (ឱនភាព ឬ អតិរេកថវិកាចរន្ត) លើចំណូលសារពើពន្ធ
- អត្រាកំណើនសេដ្ឋកិច្ចពិត
- អត្រាកំណើនប្រជាជន
- អត្រាវិនិយោគ (ផលចែកនៃវិនិយោគដុល និង ផសស)
- អត្រាវិនិយោគសាធារណៈ
- អត្រាសព្វយក្នុងស្រុក
- អនុបាតសេវាបំណុលលើចំណូលថវិកា
- អនុបាតសេវាបំណុលក្រៅប្រទេសលើការនាំចេញ
- អនុបាតសមតុល្យថវិកាសរុបគ្មានជំនួយលើចំណូលសារពើពន្ធ
- អនុបាតសមតុល្យថវិកាសរុបដោយមានជំនួយលើចំណូលសារពើពន្ធ
- អនុបាតសមតុល្យថវិកាសរុបដោយមានជំនួយលើផលិតផលសរុបក្នុងស្រុកតាមថ្លៃបច្ចុប្បន្ន
- អនុបាតសមតុល្យថវិកាចរន្តលើផលិតផលសរុបក្នុងស្រុកតាមថ្លៃបច្ចុប្បន្ន
- ទុនបម្រុងអន្តរជាតិសុទ្ធ
- អត្រាជម្រៅហិរញ្ញវត្ថុ (រូបិយវត្ថុទូទៅលើផសស)
- អត្រាឥណទានមិនដំណើរការ
- អត្រានៃការបើកទូលាយសេដ្ឋកិច្ចៈ ការនាំចូល និង នាំចេញលើផសសតាមថ្លៃបច្ចុប្បន្ន
- អត្រាការនាំចេញលើការនាំចូល


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

- កម្រិតនៃសមាហរណកម្មៈ ការនាំចូលរបស់ប្រទេសអាស៊ានមួយពីប្រទេសអាស៊ានមួយទៀត និង ការនាំចេញរបស់ប្រទេសអាស៊ានមួយទៅកាន់ប្រទេសអាស៊ានមួយទៀត
- ចលនភាពនៃកត្តាផលិតកម្ម
- អត្រាសិស្សចូលរៀន
- ចំនួយវេជ្ជបណ្ឌិតក្នុងប្រជាជនម្នាក់ៗ
- ដង់ស៊ីតេនៃហេដ្ឋារចនាសម្ព័ន្ធ
- ចលនាដោយសេរីរបស់ប្រជាជន
- អត្រាអន្តោប្រវេសន៍

## ៨.២. លក្ខណៈវិនិច្ឆ័យទីមួយ

- អនុបាទលទ្ធផលថវិកាលើ ផសស តាមថ្លៃបច្ចុប្បន្ន ដែលត្រូវលើសពី ០,៣%
- អត្រាអតិផរណាជាមធ្យម ដែលត្រូវតែទាបជាង ៣%
- អត្រាបំណុលក្នុងប្រទេស និង ក្រៅប្រទេសលើ ផសស តាមថ្លៃបច្ចុប្បន្ន ដែលត្រូវទាបជាង ៧០%
- បំណុលថវិកាក្នុងស្រុក (មិនត្រូវអោយកើនឡើង) និង បំណុលក្រៅប្រទេស (មិនត្រូវអោយកើនឡើង)

## ៨.៣. លក្ខណៈវិនិច្ឆ័យទីពីរ

- អត្រាបន្ទុកបុគ្គលិកលើចំណូលសារពើពន្ធៈ ជាធម្មតាត្រូវស្មើនឹង ៣៥%
- អនុបាទវិនិយោគសាធារណៈធ្វើហិរញ្ញប្បទានដោយធនធានក្នុងស្រុក ដោយធៀបនឹងចំណូលសារពើពន្ធៈ គោលដៅត្រូវអោយស្មើ យ៉ាងហោចណាស់ក៏ ២០% ។
- អនុបាទជញ្ជីងទូទាត់ចរន្តដោយមិនគិតការផ្ទេរសាធារណៈលើ ផសស តាមថ្លៃបច្ចុប្បន្នៈ គោលដៅត្រូវស្មើនឹង -៥% ។
- អត្រាសម្ពាធសារពើពន្ធ (ចំណូលសារពើពន្ធចែកនឹង ផសស)ៈ គោលដៅត្រូវសម្រេចអោយបាន ១៧%



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ដើម្បីសម្រេចបាននូវសម្ពាធសារពើពន្ធខ្ពស់ ការប្រមូលកៀងគរ និង កត់ត្រាអោយអស់នូវចំណូលសារពើពន្ធគ្រប់ប្រភេទ ដោយគ្មានការកាត់កងនឹងអនុញ្ញាតអោយយើងវាស់បានល្អប្រសើនូវអត្រា និង អនុបាទទាំងនេះ ។ ចំណូលដែលមិនបានប្រមូល ឬ ដែលកាត់កងនឹងចំណាយបណ្តាលអោយមានការគណនាអត្រាសម្ពាធសារពើពន្ធមិនបានត្រឹមត្រូវ ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ជំពូកទី ១០

# ការត្រួតពិនិត្យថវិកាក្រោយចំណាយ

មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ និង គណនេយ្យករសាធារណៈមានភារៈកិច្ចធានានូវការត្រួតពិនិត្យការអនុវត្ត ចំណាយថវិកាដោយអាណាប័ក ។ ការត្រួតពិនិត្យចំណាយថវិកា ដោយមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ និង ដោយ គណនេយ្យករសាធារណៈ គឺជា **ការត្រួតពិនិត្យមុនចំណាយ** (Pre-audit) ។

ដោយឡែក អគ្គាធិការដ្ឋាននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គាធិការបច្ចេកទេសតាមវិស័យ នាយកដ្ឋាន សវនកម្មផ្ទៃក្នុង អាជ្ញាធរសវនកម្មជាតិ និង រដ្ឋសភា គឺជាស្ថាប័នដែលអនុវត្ត **ការត្រួតពិនិត្យក្រោយចំណាយ** (Post-audit) លើថវិកាជាតិ ។ ស្ថាប័នដែលអនុវត្តនូវការត្រួតពិនិត្យក្រោយចំណាយត្រូវសម្របសម្រួលគ្នាអោយ បានល្អ ដើម្បីបំពេញភារកិច្ច ធ្វើអន្តរាគមន៍ និង រៀបចំរបាយការណ៍ កុំអោយជាន់គ្នា ។

## ១. អគ្គាធិការដ្ឋាននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**អគ្គាធិការដ្ឋាន** នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវបានបង្កើតដោយ ***អនុក្រឹត្យលេខ ០៤ អនក្រ/បក ចុះថ្ងៃទី ២០ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ*** ។

ដើម្បីជៀសវាងការអនុវត្តការងារស្ទួនគ្នារវាងអគ្គាធិការដ្ឋាន និង នាយកដ្ឋានសវនកម្មផ្ទៃក្នុង ការងារ ត្រួតពិនិត្យត្រូវបានបែងចែក ដូចតទៅ៖

- អគ្គាធិការដ្ឋានមានតួនាទីធ្វើអធិការកិច្ចក្រសួង ស្ថាប័ន ខេត្ត ក្រុងនានា ។

- នាយកដ្ឋានសវនកម្មផ្ទៃក្នុងធ្វើអធិការកិច្ចផ្ទៃក្នុងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

អគ្គាធិការដ្ឋានមានតួនាទី៖

- ធ្វើអធិការកិច្ចទូទៅលើគ្រប់ក្រសួង ស្ថាប័ន ខេត្ត ក្រុង ពីវិន័យក្នុងកិច្ចប្រតិបត្តិការចំណូល- ចំណាយ ថវិកាជាតិ និង ពីការទទួលខុសត្រូវរបស់អ្នកគ្រប់គ្រងប្រាក់កាសសាធារណៈ ។

- ធ្វើអធិការកិច្ចលើរាល់កិច្ចប្រតិបត្តិការហិរញ្ញវត្ថុរបស់បណ្តាគ្រឹះស្ថានសាធារណៈ ដែលមានលក្ខណៈ រដ្ឋបាល និង គ្រឹះស្ថានសាធារណៈដែលមានលក្ខណៈសេដ្ឋកិច្ច ក្រុមហ៊ុនរដ្ឋ ក្រុមហ៊ុនចម្រុះ អង្គការនានា និង



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ក្រុមហ៊ុនឯកជន ដែលបានទទួលផលប្រយោជន៍ពីហិរញ្ញវត្ថុសាធារណៈ ទោះជាតាមរូបភាពណាក៏ដោយ ។

– ចុះត្រួតពិនិត្យពាក្យបណ្តឹងតវ៉ា និង បរិហាររបស់ពលរដ្ឋដែលទាក់ទងការគ្រប់គ្រងសេដ្ឋកិច្ច ដើម្បីកសាងសំណុំរឿងបញ្ជូនទៅតុលាការ ។

– អគ្គាធិការដ្ឋានមានតួនាទីក្នុងការត្រួតពិនិត្យគណនេយ្យករសាធារណៈ អាណាប័កនៅក្នុងគ្រប់ក្រសួង ស្ថាប័ន ខេត្ត ក្រុង (មាត្រា ៧) ។

«ការគ្រប់គ្រងរបស់អាណាប័កដើមខ្សែលើគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវស្ថិតក្រោមការត្រួតពិនិត្យរបស់អធិការដ្ឋានហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ» (មាត្រា ៣៧ នៃ **ព្រះរាជក្រឹត្យ** លេខនស/រកក/១២៩៧/៩១ ចុះថ្ងៃទី ៣១ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពី **លក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល**) ។

«គណនីគ្រប់គ្រងរបស់គណនេយ្យរដ្ឋ ត្រូវបានផ្ញើជូនរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដែលដាក់អោយអធិការកិច្ចហិរញ្ញវត្ថុពិនិត្យមុនថ្ងៃទី ៣០ ខែ មិថុនា នៃឆ្នាំបន្ទាប់» (មាត្រា ១១៥ នៃ **អនុក្រឹត្យ** លេខ ៨២ អកក្រ.បក ស្តីពី **បទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ**) ។

«ការត្រួតពិនិត្យលើការគ្រប់គ្រងរបស់អាណាប័ក ត្រូវបានធានាដោយរដ្ឋសភា អង្គការ និង គណៈកម្មការត្រួតពិនិត្យដែលមានសមត្ថកិច្ច និងដោយរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ» (មាត្រា ១១៥ នៃ **អនុក្រឹត្យ** លេខ ៨២) ។

«រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ធ្វើការត្រួតពិនិត្យដែលបានគ្រោងទុកក្នុងមាត្រាមុន តាមរយៈអធិការកិច្ចហិរញ្ញវត្ថុ និង អ្នកត្រួតពិនិត្យហិរញ្ញវត្ថុ» (មាត្រា ១១៥ នៃ **អនុក្រឹត្យ** លេខ ៨២) ។

«ការត្រួតពិនិត្យការគ្រប់គ្រងរបស់គណនេយ្យករ ត្រូវបានធានាក្រោមអំណាចរបស់រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយឋានានុក្រមថ្នាក់លើរបស់គណនេយ្យករ និង ដោយអធិការកិច្ចហិរញ្ញវត្ថុ» (មាត្រា ១១៥ នៃ **អនុក្រឹត្យ** លេខ ៨២) ។

នៅពេលដែលមកដល់នាយកដ្ឋានគណនេយ្យ និង ហិរញ្ញវត្ថុ ដែលត្រូវត្រួតពិនិត្យភ្លាម អធិការហិរញ្ញវត្ថុត្រូវបញ្ឈប់ជាបន្ទាន់នូវរាល់សកម្មភាព បញ្ឈប់សកម្មភាពបេឡា (ដោយធ្វើការរាប់សាច់ប្រាក់ក្នុងបេឡា) បញ្ឈប់ការចុះបញ្ជីការគណនី ហើយផ្ទៀងផ្ទាត់បេឡា ជាមួយនឹងបញ្ជីការគណនី ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ២. អគ្គាធិការបច្ចេកទេសតាមវិស័យ

ក្រសួង ស្ថាប័ននីមួយៗត្រូវមាននាយកដ្ឋានអធិការកិច្ច ដែលមានតួនាទី និង ភារៈកិច្ចក្នុងការត្រួតពិនិត្យគុណភាពសេវានៅក្នុងវិស័យនោះ ។ ឧទាហរណ៍ នាយកដ្ឋានអធិការកិច្ចរបស់ក្រសួងអប់រំ យុវជន និង កីឡា មានតួនាទីត្រួតពិនិត្យគុណភាពអប់រំនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

## ៣. នាយកដ្ឋានសវនកម្មផ្ទៃក្នុងរបស់ក្រសួង - ស្ថាប័ន

**សវនកម្មផ្ទៃក្នុង** មានភារកិច្ចធ្វើការពិនិត្យវាយតម្លៃដោយឯករាជ្យ លើប្រសិទ្ធភាពក្នុងការអនុវត្តនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់បណ្ដាក្រសួង ស្ថាប័ន និង សហគ្រាសសាធារណៈ ។

«រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័ន ប្រធានគ្រប់អង្គភាពសាធារណៈប្រហាក់ប្រហែល ប្រធានសហគ្រាសសាធារណៈ និង អភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ មានកាតព្វកិច្ចទទួលខុសត្រូវក្នុងការរៀបចំក្របខ័ណ្ឌ និង គ្រប់គ្រងកិច្ចប្រតិបត្តិការការត្រួតពិនិត្យផ្ទៃក្នុងរបស់ខ្លួន ដើម្បីធានាភាពត្រឹមត្រូវ និង ស្របតាមបទដ្ឋាន បទប្បញ្ញត្តិ និង សេចក្ដីណែនាំរបស់រាជរដ្ឋាភិបាល ។

ដោយឡែក រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានកាតព្វកិច្ចទទួលខុសត្រូវក្នុងការណែនាំអំពីការរៀបចំក្របខ័ណ្ឌ កិច្ចប្រតិបត្តិការត្រួតពិនិត្យផ្ទៃក្នុងរបស់ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល សហគ្រាសសាធារណៈ និង រដ្ឋបាលថ្នាក់ក្រោមជាតិ និងមានភារកិច្ចធ្វើអធិការកិច្ចហិរញ្ញវត្ថុ នៅតាមក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល សហគ្រាសសាធារណៈ និងរដ្ឋបាលថ្នាក់ក្រោមជាតិ» (មាត្រា ៧២ នៃច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ) ។

«សវនកម្មផ្ទៃក្នុងត្រូវបង្កើតឡើងនៅតាមបណ្ដាស្ថាប័ន ក្រសួង និង សហគ្រាសសាធារណៈ ។ សវនកម្មផ្ទៃក្នុងត្រូវធ្វើរបាយការណ៍ទៅប្រធានស្ថាប័ន ក្រសួង និងសហគ្រាសសាធារណៈរបស់ខ្លួន ហើយត្រូវធ្វើរបាយការណ៍ និង សេចក្ដីសន្និដ្ឋាននៃការធ្វើសវនកម្មនេះ ទៅ **អាជ្ញាធរសវនកម្មជាតិ**» (មាត្រា ៤១ នៃច្បាប់ស្ដីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា) ។

«**ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង** គឺជាដំណើរការរបស់រាជរដ្ឋាភិបាល ដែលធ្វើឡើងដោយថ្នាក់ដឹកនាំស្ថាប័ន ក្រសួង និង សហគ្រាសសាធារណៈ ដើម្បីផ្ដល់នូវការធានាភាពសមស្របលើសមិទ្ធកម្មនៃកម្មវត្ថុ តាមបណ្ដាផ្នែកខាងក្រោម ÷

ក- ប្រសិទ្ធភាពនៃកិច្ចប្រតិបត្តិការ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ខ- ភាពទទួលខុសត្រូវលើរបាយការណ៍ហិរញ្ញវត្ថុ

គ- ភាពសមស្របតាមបណ្តាច្បាប់ បទបញ្ញា គោលនយោបាយ នីតិវិធី និងការចាត់ចែងដែលត្រូវអនុវត្ត» (មាត្រា ៤៣ នៃច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា) ។

មុខងារ និងការទទួលខុសត្រូវរបស់សវនកម្មផ្ទៃក្នុងត្រូវបានកំណត់ដោយអនុក្រឹត្យលេខ ៤០ ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៦ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃសវនកម្មផ្ទៃក្នុងនៅតាមបណ្តាស្ថាប័ន ក្រសួង និង សហគ្រាសសាធារណៈ ។ គោលបំណងចម្បងនៃសវនកម្មផ្ទៃក្នុង គឺផ្តល់អោយស្ថាប័ន ក្រសួង និងសហគ្រាស សាធារណៈ នូវការវិភាគ ការវាយតម្លៃ អនុសាសន៍ មតិយោបល់ និង ព័ត៌មានទាក់ទងនឹងសកម្មភាព ដែលបាន ត្រួតពិនិត្យ និង ពិនិត្យឡើងវិញ ។

**នាយកដ្ឋានសវនកម្មផ្ទៃក្នុង** របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុមានភារកិច្ចធ្វើជាសេនាធិការអោយ ក្រសួងលើការងារ៖

- ពិនិត្យលើមុខងារ សកម្មភាព កម្មវិធី និង ប្រតិបត្តិការនានារបស់ស្ថាប័ន និង អង្គភាពក្រោមឱវាទ ក្រសួង ក្នុងការិយបរិច្ឆេទសមស្របដើម្បីកំណត់ការអនុវត្តអោយបានសមស្របនូវការរៀបចំផែនការ ការចេញ បទបញ្ញា ការចាត់តាំងការងារ និង ការត្រួតពិនិត្យ ដោយផ្អែកតាមគោលនយោបាយ ការណែនាំរបស់ថ្នាក់ដឹកនាំ និង វិធានការជាធរមាន និង ស្របតាមគោលដៅរបស់ក្រសួង ។

- កំណត់ភាពសមស្រប និងប្រសិទ្ធភាពប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងផ្នែកគណនេយ្យ រដ្ឋបាល និង កិច្ច ប្រតិបត្តិការរបស់ស្ថាប័ន និង អង្គភាពនៅក្រោមឱវាទក្រសួង ។

- ពិនិត្យលើភាពអាចជឿជាក់បាន ការិយបរិច្ឆេទ និង ភាពពេញលេញនៃព័ត៌មាន និង ទិន្នន័យ និងលើ វិធីសាស្ត្រនៃការរៀបចំរបាយការណ៍ពីព័ត៌មាន និងទិន្នន័យទាំងនេះ ។

- ពិនិត្យលើប្រព័ន្ធដែលបានបង្កើតរួច ដើម្បីធានាភាពត្រឹមត្រូវតាមគោលនយោបាយ ផែនការ នីតិវិធី ច្បាប់ និង បទប្បញ្ញត្តិនានា ហើយលើកសំណើកែតម្រូវ និង កែលម្អ ប្រសិនបើមានកំហុស ។

- ពិនិត្យលើមធ្យោបាយ ក្នុងការថែរក្សាសម្បត្តិរដ្ឋ ។

- វាយតម្លៃភាពសន្សំសំចៃ និង ប្រសិទ្ធភាពសេដ្ឋកិច្ចនៃការប្រើប្រាស់ធនធានរដ្ឋ ហើយលើកសំណើដោះ ស្រាយ និងកែលម្អការអនុវត្តប្រតិបត្តិការ ។

- ធ្វើសវនកម្មលើកិច្ចប្រតិបត្តិការចំណូល ចំណាយថវិការដ្ឋ ដើម្បីបញ្ជាក់ពីភាពត្រឹមត្រូវនៃរបាយការណ៍


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ហិរញ្ញវត្ថុរបស់មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុខេត្ត- ក្រុង និង បណ្តាអង្គភាពផ្សេងៗនៅក្រោមឱវាទក្រសួង

- សម្របសម្រួលការងារសវនកម្មផ្ទៃក្នុងជាមួយអគ្គាធិការដ្ឋាន និង អាជ្ញាធរសវនកម្មជាតិ ដើម្បីធានាដំណើការអោយបានគ្រប់គ្រាន់ និង សមស្រប ជាពិសេសកាត់បន្ថយការងារស្ទួនគ្នា

- ធ្វើរបាយការណ៍ជូនរដ្ឋមន្ត្រីក្រសួង អំពីការប្រព្រឹត្តទៅរបស់អង្គភាព ដែលបានធ្វើសវនកម្មរួចហើយ ។ ទន្ទឹមនឹងនេះ ត្រូវធ្វើរបាយការណ៍អំពីសកម្មភាពការងាររបស់ខ្លួន ប្រចាំត្រីមាស និង ប្រចាំឆ្នាំ ដើម្បីផ្ញើជូនរដ្ឋមន្ត្រីពិនិត្យ និង ផ្តល់ការណែនាំ

- ផ្តល់អនុសាសន៍ ដើម្បីកែលម្អការអនុវត្តអោយមានប្រសិទ្ធភាពខ្ពស់ និង តាមដានការអនុវត្តកែលម្អរបស់នាយកដ្ឋាន មន្ទីរខេត្ត- ក្រុង និង បណ្តាអង្គភាពក្រោមឱវាទក្រសួង

- រៀបចំផែនការសវនកម្មផ្ទៃក្នុងប្រចាំឆ្នាំ ដើម្បីដាក់ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ពិនិត្យ និង សម្រេច ។

តាមការផ្តល់សិទ្ធិពីអនុក្រឹត្យលេខ ៤០ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០០៥ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានដាក់អោយប្រើប្រាស់នូវលិខិតបទដ្ឋានសវនកម្មផ្ទៃក្នុងគន្លឹះមួយចំនួន គឺ៖ **គោលនយោបាយស្តីពីការគ្រប់គ្រងផ្ទៃក្នុង ក្រមសីលធម៌សម្រាប់សវនករផ្ទៃក្នុង** និង **ស្តង់ដារវិជ្ជាជីវៈសវនកម្មផ្ទៃក្នុង** ។

**ការគ្រប់គ្រងផ្ទៃក្នុង** គឺជាសំណុំរួមនៃផែនការរបស់អង្គភាព កម្មវិធីប្រតិបត្តិ ប្រព័ន្ធគោលនយោបាយ នីតិវិធី ដំណើរការចាត់ចែង និងអនុវត្ត ព្រមទាំងជំហរ និងឥរិយាបថរបស់ថ្នាក់ដឹកនាំប្រតិបត្តិ និងមន្ត្រីផ្សេងទៀត ដែលបង្កើត និង សំដែងឡើងដោយថ្នាក់ដឹកនាំប្រតិបត្តិ ដើម្បីសម្រេចនូវគោលបំណងចម្បងរបស់អង្គភាព ជាមួយនឹងការធានាបាននូវប្រសិទ្ធភាព និង ជំនាញនិយាយជារួម ។

**ការគ្រប់គ្រងផ្ទៃក្នុង** មាន ៣ ប្រភេទ៖

- **ការគ្រប់គ្រងផ្ទៃក្នុងផ្នែកគណនី** គឺទាក់ទងនឹងការកត់ត្រា ការគណនា ការបូកសរុប និង ការរាយការណ៍អំពីប្រតិបត្តិការណ៍ហិរញ្ញវត្ថុប្រចាំថ្ងៃ ។
- **ការគ្រប់គ្រងផ្ទៃក្នុងផ្នែករដ្ឋបាល** គឺជាការគ្រប់គ្រងកម្រិតខ្ពស់របស់ថ្នាក់ដឹកនាំ ។
- **ការគ្រប់គ្រងផ្ទៃក្នុងផ្នែកប្រតិបត្តិការ** គឺជាការគ្រប់គ្រងដែលទាក់ទងនឹងសកម្មភាពផ្សេងពីកិច្ចការហិរញ្ញវត្ថុ ដែលបំពេញដោយមន្ត្រីមិនមែនថ្នាក់ដឹកនាំ ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

**សវនកម្មផ្ទៃក្នុង** គឺជាសមាសភាគមួយនៃប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង ។ **សវនកម្មផ្ទៃក្នុង** ផ្ដោតទៅលើ៖

- សវនកម្មផ្នែកហិរញ្ញវត្ថុ
- សវនកម្មប្រតិបត្តិការ និង
- សវនកម្មលើភាពអនុលោមតាមច្បាប់ បទប្បញ្ញត្តិ និង នីតិវិធី

ដើម្បីអោយសវនកម្មផ្ទៃក្នុងប្រព្រឹត្តទៅដោយឯករាជ្យ និង មិនលំអៀង សវនករផ្ទៃក្នុងត្រូវគោរពតាមក្រមសីលធមិ ដែលទាមទារអោយសវនករត្រូវគោរពតាមគោលការណ៍ ÷ ភាពសុចរិត ភាពមិនលំអៀង ការសម្ងាត់ និង មានសមត្ថភាព ។

គោលដៅនៃសវនកម្មផ្ទៃក្នុង គឺជួយអង្គភាពក្នុងការបំពេញការទទួលខុសត្រូវរបស់ខ្លួនអោយមានប្រសិទ្ធភាព ផ្ដល់អោយនូវការវិភាគ ការវាយតម្លៃ អនុសាសន៍ មតិយោបល់ និងព័ត៌មានទាក់ទងនឹងសកម្មភាពដែលបានពិនិត្យ ។ ដើម្បីសម្រេចបានតាមគោលដៅនេះ សវនកម្មផ្ទៃក្នុងត្រូវឈរលើមូលដ្ឋាននៃស្តង់ដារដូចតទៅ៖

- **ឯករាជ្យភាព**- ការបំពេញភារកិច្ចដោយសេរី និង មិនលំអៀង
- **ភាពស្ទាត់ជំនាញ និងលក្ខការណ៍វិជ្ជាជីវៈ**:- មានចំណេះដឹង ប៉ិនប្រសប់ និង មានជំនាញច្បាស់លាស់
- **វិសាលភាពការងារ**- ការពិនិត្យ និង ការវាយតម្លៃលើភាពគ្រប់គ្រាន់ និងសមិទ្ធកម្មនៃប្រព័ន្ធគ្រប់គ្រងហានិភ័យ ដំណើរការអភិបាលកិច្ច ប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង និង គុណភាពនៃការអនុវត្តភារកិច្ចរបស់អង្គភាព ។
- **ការអនុវត្តការងារសវនកម្ម**- ការរៀបចំផែនការសវនកម្ម ការពិនិត្យ និងការវាយតម្លៃព័ត៌មាន របាយការណ៍លទ្ធផល និងការតាមដាន ។
- **ការគ្រប់គ្រងអង្គភាពសវនកម្មផ្ទៃក្នុង**- សិទ្ធិអំណាច និងការទទួលខុសត្រូវ ការរៀបចំផែនការ គោលការណ៍ និងនីតិវិធី ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស និងការធានាគុណភាព ។

ចាប់តាំងពីឆ្នាំ ២០០៩ មក នាយកដ្ឋានសវនកម្មផ្ទៃក្នុងត្រូវបានបង្កើត និង ដាក់អោយដំណើរការនៅក្នុងគ្រប់ក្រសួងទាំង ២៥ របស់រាជរដ្ឋាភិបាល ដែលក្នុងនោះ នាយកដ្ឋានសវនកម្មផ្ទៃក្នុងចំនួន ១១ ដំណើរការបានល្អ ។

## ៤. សវនកម្មផ្ទៃក្រៅ និង អាជ្ញាធរសវនកម្មជាតិ

«ក្របខ័ណ្ឌ និង កិច្ចដំណើរការនៃ **សវនកម្មផ្ទៃក្រៅ** ត្រូវអនុវត្តតាមច្បាប់ស្តីពីសវនកម្មនៃព្រះរាជា



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ណាចក្រកម្ពុជា» (មាត្រា ៧៩ នៃ ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ) ។

**អាជ្ញាធរសវនកម្មជាតិ** ជាស្ថាប័នមួយឯករាជ្យ ដែលត្រូវបានបង្កើតឡើង ដើម្បីអនុវត្តមុខងារសវនកម្មផ្ទៃក្រៅរបស់រាជរដ្ឋាភិបាល ដោយអនុលោមតាមច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា ដែលដាក់អោយប្រើប្រាស់ដោយព្រះរាជក្រមលេខ ជស/រកម/០៣០០/១០ ចុះថ្ងៃទី ៣ ខែ មិនា ឆ្នាំ ២០០០ ។ អាជ្ញាធរសវនកម្មជាតិត្រូវផ្ញើរបាយការណ៍នៃសវនកម្មជូនទៅរដ្ឋសភា ព្រឹទ្ធសភាដោយផ្ទាល់ និងជូនដល់រាជរដ្ឋាភិបាល ដើម្បីជ្រាបជាព័ត៌មាន (មាត្រា ១៤ នៃច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា) ។ មន្ត្រីរាជការនៃអាជ្ញាធរសវនកម្មជាតិមានលក្ខន្តិកៈដោយឡែក ។ អាជ្ញាធរសវនកម្មជាតិមានថវិកាដោយឡែករបស់ខ្លួន ផ្តល់ដោយថវិកាជាតិ (មាត្រា ១៧) ។ របាយការណ៍ដែលធ្វើដោយអគ្គសវនករ ត្រូវបានចាត់ទុកជាឯកសារសាធារណៈ (មាត្រា ២៩)។

**អាជ្ញាធរសវនកម្មជាតិ** អាចធ្វើសវនកម្មផ្ទៃក្រៅលើ៖

- បណ្តាក្រសួង ស្ថាប័ន និងភ្នាក់ងារ
- អាជ្ញាធរធនាគារជាតិ
- ស្ថាប័នហិរញ្ញវត្ថុរដ្ឋ និង ស្ថាប័នហិរញ្ញវត្ថុរដ្ឋចម្រុះឯកជន
- សហគ្រាសសាធារណៈ និង គ្រឹះស្ថានសាធារណៈ
- រដ្ឋបាលខេត្ត ក្រុង
- រដ្ឋបាលមូលដ្ឋាន
- អ្នកម៉ៅការ អ្នកផ្គត់ផ្គង់ទំនិញ និង សេវាកម្មចំពោះរាជរដ្ឋាភិបាលតាមកិច្ចសន្យា
- បណ្តាអង្គការផ្សេងៗ ដែលរាជរដ្ឋាភិបាលផ្តល់ជំនួយហិរញ្ញវត្ថុបន្ថែមលើទុនផ្ទាល់ និង ឥណទាន រួមមានការលើកលែងពន្ធអាករគ្រប់ប្រភេទ ព្រមទាំងសម្បទានផ្សេងៗទៀត ទៅអង្គការដែលមិនរកប្រាក់ចំណេញ និងសហគ្រាសឯកជនផងដែរ (មាត្រា ២ នៃច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា) ។

«**សវនកម្មផ្ទៃក្រៅ** គឺជាការពិនិត្យពិចារណា ឬ ការពិនិត្យឡើងវិញលើកិច្ចបញ្ជីកាគណនេយ្យ ប្រព័ន្ធគ្រប់គ្រងកិច្ចប្រតិបត្តិការ និងការត្រួតពិនិត្យស្ថាប័នគ្រប់គ្រងដោយអនុលោមតាមស្តង់ដារនៃការធ្វើសវនកម្មទូទៅ និងតាមស្តង់ដារនៃការធ្វើសវនកម្មរបស់រាជរដ្ឋាភិបាលដើម្បីផ្តល់ការធានាថា៖

ក- បណ្តាសកម្មភាពហិរញ្ញវត្ថុ និងសេដ្ឋកិច្ចត្រូវបានបង្ហាញយ៉ាងត្រឹមត្រូវ តាមរយៈសេចក្តីថ្លែងការណ៍


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

និង តាមរបាយការណ៍ ។

ខ- បណ្តាសកម្មភាពទាំងនេះត្រូវបានអនុវត្ត ដោយអនុលោមតាមគោលការណ៍គណនេយ្យទូទៅ ។

គ- ការត្រួតពិនិត្យនីតិវិធី និងការអនុវត្តដោយអនុលោមតាមច្បាប់ បទបញ្ញា កិច្ចព្រមព្រៀង ប្រព័ន្ធគ្រប់គ្រង កិច្ចសន្យា កម្មវិធី និង លក្ខណៈវិនិច្ឆ័យផ្សេងទៀត ដែលទាក់ទងដល់ចំណូល ចំណាយ និងការប្រើប្រាស់ប្រភពធនធានរបស់រាជរដ្ឋាភិបាល» (មាត្រា ៤ នៃច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា) ។

សវនកម្មផ្ទៃក្រៅរាប់បញ្ចូលការអនុវត្តប្រភេទសវនកម្មដូចតទៅ៖

- សវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ ។
- សវនកម្មលើការគ្រប់គ្រងកម្មវិធីគម្រោងឥណទាន ដែលបានទទួលពីមូលនិធិក្រៅប្រទេស ។
- សវនកម្មលើប្រព័ន្ធគ្រប់គ្រង និង ការប្រព្រឹត្តទៅលើបណ្តាស្ថាប័ន ។
- សវនកម្មលើការវាយតម្លៃ ការផ្តល់លទ្ធផលល្អ និង ប្រសិទ្ធភាពក្នុងការអនុវត្ត ។
- សវនកម្មលើអង្គការដែលមិនរកប្រាក់ចំណេញ សមាគម គណបក្សនយោបាយ និង សវនកម្មលើសហគ្រាសវិនិយោគឯកជន ដែលបានទទួលការលើកលែងពន្ធអាករគ្រប់ប្រភេទ ព្រមទាំងសម្បទានផ្សេងៗទៀត (មាត្រា ៣)។

អាជ្ញាធរសវនកម្មជាតិធ្វើ **សវនកម្ម** លើ៖

- ***សេចក្តីថ្លែងការណ៍*** និង***របាយការណ៍ហិរញ្ញវត្ថុ*** របស់ក្រសួង ស្ថាប័ន ដែលជាមូលដ្ឋានសម្រាប់ធ្វើរបាយការណ៍ហិរញ្ញវត្ថុសរុបរបស់រាជរដ្ឋាភិបាល នៅដំណាច់ឆ្នាំនៃការិយបរិច្ឆេទដែលរៀបចំដោយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មុនពេលដាក់ជូនទៅអង្គការនីតិប្បញ្ញត្តិ ។
- ***ភាពត្រឹមត្រូវ*** ភាពពិតប្រាកដ ការយល់ព្រម ការធ្វើអោយមានសុពលភាព និងស្របតាមទិន្នន័យហិរញ្ញវត្ថុដូចមានបង្ហាញលើរបាយការណ៍របស់បណ្តាក្រសួង ស្ថាប័ន និង របាយការណ៍ហិរញ្ញវត្ថុសរុបរបស់រាជរដ្ឋាភិបាល ។
- ***របាយការណ៍ហិរញ្ញវត្ថុ***របស់សហគ្រាសសាធារណៈ អាជ្ញាធរ រួមមាន តារាងតុល្យការ របាយការណ៍អំពីប្រាក់ចំណេញ ការខាតបង់ និង ការវិភាគគណនី ដែលជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុ ។


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

- **របាយការណ៍ហិរញ្ញវត្ថុ** និង របាយការណ៍ផ្សេងៗទៀត ដែលសំណូមពរដោយបណ្តាភ្នាក់ងារផ្តល់ជំនួយអន្តរជាតិ និង បណ្តា **ឥណទាយក** (Creditor) នៅក្នុងគម្រោងផ្តល់មូលនិធិពីក្រៅប្រទេស ។
- **ប្រព័ន្ធត្រួតពិនិត្យនានា** ដើម្បីរៀបចំមតិលើភាពសមស្របគ្រប់ជ្រុងជ្រោយ ក្នុងការចាត់ចែងប្រព័ន្ធគ្រប់គ្រង និងការប្រព្រឹត្តទៅនៃស្ថាប័នទាំងនោះ ។
- **មុខងារ ឬ កិច្ចការកំពុងអនុវត្ត** រវាងស្ថាប័នគ្រប់គ្រង និង ស្ថាប័នគ្រប់គ្រង ដើម្បីធានាសកម្មភាពកិច្ចប្រតិបត្តិការ ដែលទាក់ទងដល់មុខងារនៅក្នុងបណ្តាស្ថាប័នគ្រប់គ្រង អោយអនុវត្តគោរពតាមច្បាប់ បទបញ្ញា និងគោលការណ៍ទាំងឡាយដែលកំពុងអនុវត្ត ។
- **ការសន្សំសំចៃ ការផ្តល់អោយនូវផលល្អ ប្រសិទ្ធភាព**នៃកិច្ចប្រតិបត្តិការចំណាយ និង លទ្ធផលនៃកម្មវិធីរបស់រាជរដ្ឋាភិបាល ។

### ៥. រដ្ឋសភា

ការត្រួតពិនិត្យរបស់រដ្ឋសភាលើការអនុវត្តថវិកាប្រព្រឹត្តទៅ តាមរយៈការអនុម័តច្បាប់ទូទាត់ថវិកា ។ «សេចក្តីព្រាងច្បាប់ទូទាត់ថវិកា ពិនិត្យកត់ត្រានូវចំនួនទឹកប្រាក់ជាស្ថាពរនៃចំណូលដែលបានបង់ចូលគណនីទោលរបស់រតនាគារជាតិ និង អាណាប័ណ្ណចំណាយដែលបានប្រព្រឹត្ត នៅក្នុងការិយបរិច្ឆេទនៃឆ្នាំថវិកា ។ សេចក្តីព្រាងច្បាប់នេះទុកជាមោឃៈនូវឥណទានដែលមិនបានប្រើប្រាស់ ហើយលើកឡើងអោយឃើញនូវលទ្ធផលហិរញ្ញវត្ថុពិតនៃឆ្នាំ ដោយធ្វើការកត់ត្រាទៅក្នុង គណនីលទ្ធផលរបស់រតនាគារជាតិ» (មាត្រា ៧៧ នៃ ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ) ។

«សេចក្តីព្រាងច្បាប់ទូទាត់ថវិកា ត្រូវរៀបចំដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ទៅតាមមាតិកាថវិកានីមួយៗ ដោយផ្អែកលើទិន្នន័យចំណូល ចំណាយ ដែលរាយការណ៍ដោយគណនេយ្យករសាធារណៈ ក្រោយពីបានធ្វើការផ្ទៀងផ្ទាត់ត្រឹមត្រូវជាមួយអាណាប័កពាក់ព័ន្ធ» (មាត្រា ៧៨ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ) ។

ការវិភាជន៍ពិសេស គឺជាថវិកាឧបសម្ព័ន្ធ និង គណនីពិសេសរតនាគារ ។ ក៏ប៉ុន្តែ ថវិកាឧបសម្ព័ន្ធមិនទាន់បានប្រើប្រាស់អោយបានទូលំទូលាយនៅឡើយនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ គណនីពិសេសរតនាគារមានសមតុល្យ ដែលអាចផ្ទេរពីមួយឆ្នាំ ទៅមួយឆ្នាំទៀតបាន លើកលែងតែមានចែងក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុប្រចាំឆ្នាំ ។

ច្បាប់ទូទាត់ថវិកាត្រូវបានរៀបចំឡើង តាមរចនាសម្ព័ន្ធ និង មាត្រាថវិកា ដូចច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ ដោយគ្រាន់តែថែមនូវជួរបន្ទាត់ ដើម្បីទទួលបាននូវច្បាប់ទូទាត់ថវិកា ដែលមានវិភាជន៍



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

នូវឥណទានថវិកាដែលបានអនុម័ត ការធ្វើវិសោធនកម្ម (ការបន្ថែម ឬ បន្ថយឥណទានថវិកា) ទាយជ្ជទានក្រោយពីធ្វើវិសោធនកម្មរួច ការធានាចំណាយ ចំណាយតាមអាណត្តិបើកប្រាក់ និង ចំណាយថវិកាដែលបានទូទាត់រួច ។

«ប្រតិបត្តិការ ដែលបង្ហាញនៅក្នុងសេចក្តីព្រាងច្បាប់ទូទាត់ថវិកា ត្រូវឆ្លុះបញ្ចាំងនូវវិធានគណនេយ្យសាធារណៈតាមលំនាំដូចខាងក្រោម៖

១- ចំពោះចំណូលៈ ការគ្រោងទុកដើមគ្រា ព្រមទាំងការកែប្រែ និង ចំណូលជាក់ស្តែង ដែលបែងចែកតាមក្រុម ប្រភេទ ជំពូក គណនី និង អនុគណនី ។

២- ចំពោះចំណាយៈ ការគ្រោងទុកដើមគ្រា ការអនុញ្ញាតថ្មី និង ចំណាយជាក់ស្តែងនៅតាមក្រសួង ស្ថាប័ន ឬ អង្គភាពសាធារណៈប្រហាក់ប្រហែល និង រដ្ឋបាលថ្នាក់ក្រោមជាតិទៅតាមមាតិកាថវិកា ។

៣- ការប្រៀបធៀបទឹកប្រាក់សរុបនៃការគ្រោងទុកនៃចំណូល និង ចំណាយ និង ការកែប្រែដែលបានធ្វើប្រសិនបើមានជាមួយនឹងលទ្ធផលចុងក្រោយនៃថវិការបស់រដ្ឋបាលសាធារណៈនីមួយៗ ។

ប្រតិបត្តិការ ដែលបង្ហាញនៅក្នុងសេចក្តីព្រាងច្បាប់ទូទាត់ថវិកា ទាំងថវិការដ្ឋ និង ទាំងគណនីពិសេសរបស់រតនាគារជាតិ ត្រូវបង្ហាញជាលម្អិតនូវឥណទានដែលបានអនុម័តដើមឆ្នាំ និងឥណទានកែតម្រូវទៅតាមមាតិកាថវិកា» (មាត្រា ៧៨ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ) ។

«សេចក្តីព្រាងច្បាប់ទូទាត់ថវិកា ដែលត្រូវដាក់ជូនរដ្ឋសភាសុំការអនុម័ត និង ព្រឹទ្ធសភាសុំការពិនិត្យ ត្រូវភ្ជាប់ជាមួយនូវ៖

១- របាយការណ៍វិភាគស្តីពីលទ្ធផលនៃការប្រមូលចំណូល និង ស្ថានភាពនៃការអនុវត្តចំណាយថវិកា ។

២- របាយការណ៍ស្តីពីស្ថានភាពទូទៅនៃសេដ្ឋកិច្ច និង ហិរញ្ញវត្ថុនៅក្នុងឆ្នាំអនុវត្ត និង ស្តីពីស្ថានភាពនៃការសម្រេចបាននូវតុល្យភាពម៉ាក្រូសេដ្ឋកិច្ច ។

៣- តារាងតុល្យការរបស់រាជរដ្ឋាភិបាល» (មាត្រា ៧៨ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ) ។


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

# ជំពូកទី ១១

# ការគ្រប់គ្រងបំណុល

## ១. និយមន័យ

### ១.១. បំណុលរដ្ឋ

បំណុលរដ្ឋត្រូវបានចែកចេញជា ÷

- តាមនិយមន័យចង្អៀត÷

- កម្ចីក្នុង និង ក្រៅប្រទេសរបស់រដ្ឋ

- កម្ចីក្នុង និង ក្រៅប្រទេសដែលរដ្ឋធានា

- ប័ណ្ណរតនាគារ (និងសញ្ញាប័ណ្ណរដ្ឋឯទៀត)

- បំណុលរតនាគារចំពោះធនាគារជាតិនៃកម្ពុជា

- តាមនិយមន័យទូលាយ÷

- បញ្ញើនៅរតនាគារ (បញ្ញើតតិយជន ក្រុមហ៊ុន និង ស្ថាប័នដែលត្រូវបានអនុញ្ញាតអោយដាក់ប្រាក់បញ្ញើនៅរតនាគារ)

- បំណុលចំណាយកកស្ទះ ។

ការគ្រប់គ្រងបំណុលនៅព្រះរាជាណាចក្រកម្ពុជាត្រូវបានបែងចែកតាមផ្នែកដូចតទៅ÷

**- អគ្គនាយកដ្ឋានរតនាគារជាតិ** ទទួលខុសត្រូវចំពោះបំណុលក្នុងស្រុក លើកលែងតែបំណុលជារូបិយប័ណ្ណ ដែលគ្រប់គ្រងដោយនាយកដ្ឋានវិនិយោគ និង សហប្រតិបត្តិការអន្តរជាតិ

**- អង្គភាពគ្រប់គ្រងបំណុល** នៃនាយកដ្ឋានវិនិយោគ និងសហប្រតិបត្តិការអន្តរជាតិ ទទួលបន្ទុកគ្រប់គ្រងបំណុលក្រៅប្រទេស ដោយរួមទាំងបំណុលក្នុងស្រុកជារូបិយប័ណ្ណ

-**ធនាគារជាតិនៃកម្ពុជា** - ទទួលខុសត្រូវចំពោះកម្មវិធីនៃមូលនិធិរូបិយវត្ថុអន្តរជាតិ ។

## ១.២. បំណុលក្រៅប្រទេស

**បំណុលក្រៅប្រទេស** គឺជាសំណុំនៃបំណុលរយៈពេលវែង ដែលនិវាសនជននៃប្រទេសមួយជំពាក់អនិវាសនជន ។ និយមន័យនេះ គឺជានិយមន័យបំណុលរបស់ធនាគារពិភពលោក ។ និយមន័យនេះមានសារសំខាន់ណាស់ ដោយសារទិន្នន័យស្តីពីបំណុលអនុញ្ញាតអោយយើងវាយតម្លៃ ពីសមត្ថភាព **ឥណពំន្ធ** (Indebtedness) របស់ប្រទេសមួយ និង ដែលជាទិន្នន័យចាំបាច់សម្រាប់ការគណនាជញ្ជីងទូទាត់ ។

បំណុលរយៈពេលវែង គឺជាបំណុលដែលមានរយៈពេលសងលើសពីមួយឆ្នាំ ។ ការគណនារយៈពេលសងបំណុល គឺជារយៈពេលរវាងកាលបរិច្ឆេទនៃកិច្ចសន្យាផ្តល់កម្ចី (កាលបរិច្ឆេទសន្យា) និង កាលបរិច្ឆេទនៃការទារការទូទាត់បំណុលចុងក្រោយ ។

ប្រទេសមួយចំនួនចាត់ថ្នាក់បំណុលរយៈពេលខ្លី ជាបំណុលដែលរយៈពេលសងដំបូងមិនលើសពី ២ ឆ្នាំ ដែលខុសពីប្រទេសខ្លះ ដែលចាត់ទុកថាបំណុលរយៈពេលខ្លី គឺបំណុលដែលមានរយៈពេលសងតិចជាង ១ ឆ្នាំ ។ ក៏ប៉ុន្តែ និយមន័យរបស់ធនាគារពិភពលោក ដែលចាត់ទុកថា «បំណុលរយៈពេលវែង គឺជាបំណុលដែលមានរយៈពេលសងលើសពីមួយឆ្នាំ» គឺជានិយមន័យ ដែលប្រើប្រាស់សម្រាប់រៀបចំនូវស្ថិតិអន្តរជាតិ ។

អនិវាសនជន គឺជាបុគ្គល ឬ អង្គការដែលគ្មានវត្តមានជាក់ស្តែងនៅក្នុងប្រទេសនោះ ដូចជា រូបវន្តបុគ្គលអនិវាសនជន ក្រុមហ៊ុនបរទេស (លើកលែងតែសាខារបស់ក្រុមហ៊ុននៅក្នុងប្រទេសមួយចំនួន) និង អង្គការអន្តរជាតិ ។ និយមន័យនេះមានសង្គតិភាពជាមួយសៀវភៅណែនាំរបស់មូលនិធិរូបិយវត្ថុអន្តរជាតិស្តីពីជញ្ជីងទូទាត់។

បំណុលក្រៅប្រទេសរយៈពេលវែងត្រូវបានចែកចេញជាពីរប្រភេទ គឺ ÷ បំណុលសាធារណៈ និង បំណុលឯកជន ។

បំណុលសាធារណៈក្រៅប្រទេសចែកចេញជា ÷

- បំណុលក្រៅប្រទេសនៃផ្នែកសាធារណៈ និង
- បំណុលក្រៅប្រទេសនៃផ្នែកឯកជន ដែលរដ្ឋធានា ។

បំណុលទាំងនេះត្រូវបានត្រួតពិនិត្យយ៉ាងយកចិត្តទុកដាក់ ដោយអង្គភាពគ្រប់គ្រងបំណុលរបស់នាយកដ្ឋានវិនិយោគ និង សហប្រតិបត្តិការអន្តរជាតិនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ចាប់តាំងពីពេលករកើត



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

បំណុល រហូតដល់ពេលបំណុលទាំងនេះត្រូវបានសងរួច ។ បំណុលនីមួយៗមានតារាងឯកសារតាមដានរបស់ខ្លួន ។

បំណុលក្រៅប្រទេសរបស់ផ្នែកឯកជនមិនអាចអោយយើងតាមដានបានគ្រប់ជ្រុងជ្រោយបានឡើយ ។ ដូច្នេះហើយ ចាំបាច់យើងត្រូវអោយនិយមន័យអោយចំនួវផ្នែកសាធារណៈ ។

**ផ្នែកសាធារណៈ**: រួមមាន ៖

ក- **រដ្ឋ**: រដ្ឋាភិបាល ដែលមានក្រសួង និង ស្ថាប័ន ។ បំណុលក្រៅប្រទេសរបស់រដ្ឋងាយស្រួលនឹងស្រង់ និង ត្រួតពិនិត្យ ដោយសារតែបំណុលទាំងនេះត្រូវបានកត់ត្រាទុក នៅក្នុងចំណូលថវិកានៅពេលខ្ចី និង កត់ត្រាជាចំណាយថវិកាសម្រាប់សេវាការប្រាក់ និង ការសងដើមបំណុល ។

ខ- **ខេត្ត- ក្រុង**: បន្ទាប់ពីការដាក់អោយអនុវត្តនូវច្បាប់អង្គការស្តីពីការគ្រប់គ្រងរដ្ឋបាលខេត្ត ស្រុក ខ័ណ្ឌ ខេត្ត- ក្រុង គឺជានីតិបុគ្គលនៃនីតិសាធារណៈ ។ ក៏ប៉ុន្តែ ដោយអនុលោមតាមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ខេត្ត- ក្រុង មិនអាចជាភាគីមួយនៃកម្ចីបានឡើយ ។

គ- **ធនាគារកណ្តាល**: ធនាគារជាតិនៃកម្ពុជា ។

ឃ- **ស្ថាប័នសាធារណៈស្វយ័ត**: ដូចជា គ្រឹះស្ថានសាធារណៈ ។

ង- **សហគ្រាសសាធារណៈ**: ដូចជា គ្រឹះស្ថានសាធារណៈដែលមានលក្ខណៈសេដ្ឋកិច្ច ក្រុមហ៊ុនរដ្ឋ និង ក្រុមហ៊ុនចម្រុះដែលក្នុងនោះរដ្ឋកាន់កាប់ដោយផ្ទាល់ ឬ ដោយប្រយោលលើសពី ៥១%នៃដើមទុនក្រុមហ៊ុន ឬ សិទ្ធិបោះឆ្នោត ។

**បំណុលដែលរដ្ឋធានា** គឺជាបំណុលនៃក្រុមហ៊ុនឯកជន ដែលរដ្ឋ ឬ ស្ថាប័នសាធារណៈបានធ្វើការធានាថានឹងធ្វើការទូទាត់ការប្រាក់ និង សងដើមបំណុលប្រសិនបើ **ឥណទាយិក** (Debtor) មិនអាចសងបំណុលនេះបាន ។ រដ្ឋត្រូវ មានការប្រយ័ត្នប្រយែង ក្នុងការធានាបំណុលឯកជន បើពុំនោះសោត ការធានានេះមានន័យថា ធានាអោយក្រុមហ៊ុនឯកជនតែម្តង ។

ការធានារបស់រដ្ឋច្រើនតែអនុវត្តចំពោះកម្ចីរបស់សហគ្រាសសាធារណៈ ជាពិសេសក្រុមហ៊ុនរដ្ឋ និង ក្រុមហ៊ុនចម្រុះរដ្ឋ- ឯកជន នៅពេលដែល **ឥណទាយក** (Creditor) ទាមទារអោយរដ្ឋផ្តល់នូវការធានានេះ ក្នុងគោលដៅកាត់បន្ថយអត្រាការប្រាក់អោយនៅទាប ។

នៅក្នុងព្រះរាជាណាចក្រកម្ពុជា បំណុលទាំងអស់ គឺជាបំណុលដែលដៃគូអភិវឌ្ឍន៍ពហុភាគី និង



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ទូទាត់ផ្តល់ជូនរដ្ឋដោយផ្ទាល់ ។ ដោយអនុលោមតាមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និង ច្បាប់ស្តីពីថវិកាប្រចាំឆ្នាំ មានតែរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុតែម្នាក់គត់ ដែលមានសម្បទានអាចចុះកិច្ចព្រមព្រៀងកម្ចីបានតាមការប្រទានសិទ្ធិរបស់នាយករដ្ឋមន្ត្រី ដោយមិនអោយលើសពី ២០០ លាន SDR ក្នុងមួយឆ្នាំ ។ ក៏ប៉ុន្តែរដ្ឋសភាបានអនុម័តធានាការវិនិយោគរបស់ក្រុមហ៊ុនឯកជនរបស់សាធារណៈរដ្ឋប្រជាមានិតចិន ដែលដាក់ទុនវិនិយោគក្នុងការសាងសង់ស្ថានីយវារីអគ្គិសនី ដូចជា ស្ថានីយវារីអគ្គិសនីគីរីរម្យ និង ស្ថានីយវារីអគ្គិសនីកំចាយជាដើម ។

## ២. ការគ្រប់គ្រងបំណុលក្រៅប្រទេស

### ២.១. អង្គភាពគ្រប់គ្រងបំណុល

**អង្គភាពគ្រប់គ្រងបំណុល** គឺជាអង្គភាពមួយនៃនាយកដ្ឋានវិនិយោគ និង សហប្រតិបត្តិការអន្តរជាតិនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលទទួលបន្ទុកខាងផ្នែកគ្រប់គ្រងបំណុលក្រៅប្រទេស ។ ការគ្រប់គ្រងបំណុលក្រៅប្រទេស គឺជាការងារដែលមានបច្ចេកទេសជំនាញពិសេស ដែលទាមទារអោយមន្ត្រីដែលទទួលបន្ទុកត្រូវឆ្លងកាត់នូវវគ្គបណ្តុះបណ្តាលពិសេស ។

អង្គភាពនេះត្រូវតែស្ថិតនៅក្រោមឱវាទរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្នុងគោលដៅធានាអោយបាននូវការគ្រប់គ្រងបំណុលប្រកបដោយប្រសិទ្ធភាព ។ ជារួម ថវិកាជាតិគ្រោងទៅក្នុងចំណាយចរន្ត នូវចំណាយសម្រាប់សងការប្រាក់ និង នៅក្នុងចំណាយមូលធន នូវចំណាយសម្រាប់សងដើមកម្ចី ។

ថ្វីត្បិតតែអង្គភាពគ្រប់គ្រងបំណុល ជាអង្គភាពមួយមានឯកទេសពិសេស អង្គភាពនេះត្រូវទំនាក់ទំនង និង សហការយ៉ាងជិតស្និទ្ធជាមួយគ្រប់ស្ថាប័ន និង នាយកដ្ឋានទាំងអស់ដែលទទួលបន្ទុកខាងគ្រប់គ្រងបំណុល ដូចជា នាយកដ្ឋានថវិកា អគ្គនាយកដ្ឋានរតនាគារជាតិ និង ធនាគារជាតិនៃកម្ពុជា ។

ការទទួលខុសត្រូវរបស់អង្គភាពគ្រប់គ្រងបំណុលអាចចែកចេញជាមុខងារបីសំខាន់ៗ គឺ៖ មុខងាររដ្ឋបាល មុខងារគណនេយ្យ និង មុខងារស្ថិតិ ។

#### ២.១.១. មុខងាររដ្ឋបាល

ការទទួលខុសត្រូវចំពោះមុខរបស់អង្គភាពគ្រប់គ្រងបំណុល គឺការតាមដាន និង ត្រួតពិនិត្យការសងការប្រាក់ និង ប្រាក់ដើម ទៅតាមកាលបរិច្ឆេទ ដើម្បីជៀសវាងការយឺតយ៉ាវនាំអោយមានពិន័យ ។ ដើម្បីបំពេញមុខងារនេះ ÷



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ទីមួយ- អង្គភាពគ្រប់គ្រងបំណុលត្រូវដឹងទាំងអស់ពីកិច្ចសន្យាកម្ចី ដែលរាជរដ្ឋាភិបាលបានចុះហត្ថលេខា។

ទីពីរ- មន្ត្រីរៀបចំថវិកាត្រូវគ្រោងចំណាយសងបំណុលនៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុប្រចាំឆ្នាំ

ទីបី- រតនាគារជាតិ និង ធនាគារជាតិនៃកម្ពុជាត្រូវពិនិត្យអោយបានហ្មត់ចត់ ដើម្បីធានានូវការទូទាត់បំណុល និង ការផ្ទេរប្រាក់ទៅឥណទាយក ។

### ២.១.២. មុខងារគណនេយ្យ

អង្គភាពគ្រប់គ្រងបំណុលត្រូវបើកគណនីសម្រាប់រាល់កម្ចីទាំងអស់ និង កត់ត្រារាល់ប្រតិបត្តិការទាំងអស់ដែលពាក់ព័ន្ធនឹងកម្ចី ។

ដំណាក់កាលទី ១ គឺ ត្រូវកត់ត្រានូវបរិមាណនៃកម្ចីដែលបានចុះកិច្ចសន្យា ការប៉ាន់ស្មានបើកផ្តល់ក្នុងឆ្នាំកាលបរិច្ឆេទដែលត្រូវសងដើម និង ការប្រាក់ ។ បន្ទាប់មក ត្រូវកត់ត្រានូវការអនុវត្តបើកផ្តល់សាច់ប្រាក់បំណុល ។ នៅពេលដែល កាលបរិច្ឆេទសងការប្រាក់ ឬ សងដើមកម្ចីបានមកដល់ ត្រូវកត់ត្រាទុកនូវនីតិវិធីទូទាត់សងនៅក្នុងគណនីកម្ចី ។ ហើយចុងបញ្ចប់ ប្រសិនបើមានការយឺតយ៉ាវក្នុងការសងការប្រាក់ក្តី ឬ ក្នុងការសងដើមបំណុលក្តី ទំហំទឹកប្រាក់នៃការយឺតយ៉ាវនេះ ត្រូវតែចុះកិច្ចបញ្ជីកា និង តាមដានដោយផ្ទាល់ នៅក្នុងគណនីកម្ចី ។

### ២.១.៣. មុខងារស្ថិតិ

ស្ថិតិបំណុលរៀបចំឡើង ដោយឈរលើមូលដ្ឋាននៃការចុះបញ្ជីកាគណនេយ្យ ។ កាលបរិច្ឆេទស្ថិតិនេះមានថេរវេលាចំនួនមួយឆ្នាំ យ៉ាងច្រើនបំផុត ។ ទិន្នន័យស្ថិតិសាមញ្ញអាចបោះផ្សាយក្នុងមួយត្រីមាសម្តង ។

ដោយសារការដាក់អោយអនុវត្តនូវកម្មវិធីព័ត៌មានវិទ្យា ការគ្រប់គ្រងបំណុលដែលធ្លាប់តែជាការងារមួយទាមទារនូវពេលវេលាច្រើន និង មានលក្ខណៈស្មុគស្មាញ ឥឡូវនេះអាចអនុវត្តបានយ៉ាងភ្លាមៗតែម្តង ។

## ២.២. ការគ្រប់គ្រងរដ្ឋបាលនៃបំណុល

### ២.២.១. ការតាមដានត្រួតពិនិត្យការសន្យាបើកផ្តល់កម្ចី

ដំណាក់កាលទីមួយ គឺត្រូវរៀបចំនូវតារាងកត់ត្រាកម្ចីទាំងអស់ ដែលឆ្លើយតបទៅនឹងនិយមន័យនៃបំណុលសាធារណៈ ។ បន្ទាប់មក អង្គភាពគ្រប់គ្រងបំណុលត្រូវសហការអោយបានជិតស្និទ្ធជាមួយការិយាល័យ ដែលទទួលបន្ទុកចរចាយកកម្ចីថ្មី និង ត្រូវធ្វើបច្ចុប្បន្នភាពជាប្រចាំនូវតារាងបំណុលនេះ ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ក. ការបង់លេខ

កម្ចីនីមួយៗត្រូវមានលេខកូដសម្គាល់ ដើម្បីងាយស្រួលនឹងគ្រប់គ្រង ។ គេអាចដាក់អោយអនុវត្តនូវប្រព័ន្ធលេខកូដ សម្រាប់បញ្ជូនព័ត៌មានទៅធនាគារពិភពលោក (ដែលទាមទារអោយមានប្រព័ន្ធលេខកូដតែមួយ) ឬ អាចអនុវត្តនូវប្រព័ន្ធលេខកូដផ្សេងទៀត ។

## ខ. ការបង្កើតបញ្ជីកម្ចី

កម្ចីនីមួយៗត្រូវមានបញ្ជីរបស់វា ដែលត្រូវបែងចែកជាឯកសារពីរផ្នែក ÷

ទីមួយ- បញ្ជីឯកសារទីមួយត្រូវមានច្បាប់ដើមនៃកិច្ចសន្យាកម្ចី ឬ យ៉ាងហោចណាស់ក៏ច្បាប់ចម្លងនៃកិច្ចសន្យានេះដែរ និង ឯកសារ និងសក្ខីប័ត្រផ្សេងៗទៀត ដែលបញ្ជាក់ បំពេញបន្ថែម ឬ បំភ្លឺពីលក្ខខណ្ឌនៃកម្ចី ។ ឯកសារទាំងនេះត្រូវរក្សាទុកជាប្រចាំ ឬ យ៉ាងហោចណាស់ក៏រហូតដល់ពេលដែលការទូទាត់សងបំណុលត្រូវបានចប់សព្វគ្រប់ (រយៈពេលសងកម្ចីរបស់ធនាគារពិភពលោក និង ធនាគារអភិវឌ្ឍន៍អាស៊ី មានថេរៈវេលាចំនួន ៤០ ឆ្នាំ)។

ទីពីរ- បញ្ជីឯកសារទីពីរ គឺសំណុំលិខិតឆ្លងឆ្លើយ របាយការណ៍ស្តីពីស្ថានភាពបំណុល លិខិតជូនព័ត៌មានពីកាលបរិច្ឆេទត្រូវសងបំណុល ។ល។ ឯកសារទាំងនេះត្រូវមានចំណាត់ថ្នាក់ជាកម្រងឯកសារប្រចាំឆ្នាំ ដែលត្រូវមានប័ណ្ណសារសម្រាប់រយៈពេល ៣ ទៅ ៤ ឆ្នាំ ។

## គ. កម្ចីឯកជនធានាដោយរដ្ឋ

កម្ចីឯកជនដែលរដ្ឋធានាត្រូវតែតាមដានត្រួតពិនិត្យដោយអង្គភាពគ្រប់គ្រងបំណុល ដូចកម្ចីធម្មតាដែរ÷ ដោយមានលេខកូដ និង មានឯកសារសម្រាប់កម្ចីនីមួយៗ ។ ក៏ប៉ុន្តែ ព័ត៌មានពាក់ព័ន្ធនឹងកម្ចីនេះ (ការបើកផ្តល់កម្ចី ការទូទាត់សងការប្រាក់ ឬ ដើមបំណុល) មិនត្រូវបានផ្តល់អោយអង្គភាពដោយផ្ទាល់ទេ ។ ព័ត៌មានទាំងនេះត្រូវទទួលយកពីសហគ្រាស ដែលទទួលកម្ចីទាំងនេះផ្ទាល់ ។

## ឃ. ការតាមដានការបើកផ្តល់កម្ចី

អង្គភាពត្រូវតាមដានការបើកផ្តល់កម្ចីជារៀងរាល់ថ្ងៃ ឬ យ៉ាងហោចណាស់ក៏ជារៀងរាល់ខែដែរ។ អង្គភាពគ្រប់គ្រងបំណុលត្រូវកំណត់នូវទឹកប្រាក់សរុបដែលនៅសល់សម្រាប់កម្ចីនីមួយៗ (កម្ចីដែលសន្យា- ការបើកផ្តល់) ។ ទឹកប្រាក់ និង កាលបរិច្ឆេទនៃការបើកផ្តល់កម្ចីមានសារសំខាន់ណាស់ ដើម្បីគណនារកការប្រាក់ដែលត្រូវសងទៅឥណទាយក ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ការតាមដានការបើកផ្តល់កម្ចី គឺជាភារកិច្ចមួយដ៏សំខាន់ និង ដ៏លំបាកផងដែររបស់អង្គភាព ដោយសារតែបញ្ហាអាចខុសៗគ្នាចំពោះប្រភេទកម្ចីនីមួយៗ ÷

### 1. កម្ចីបើកផ្តល់ជាសាច់ប្រាក់

កម្ចីបើកផ្តល់ជាសាច់ប្រាក់ងាយស្រួលនឹងគ្រប់គ្រង ដោយសារតែការបើកផ្តល់ត្រូវបានធនាគារបានកត់ត្រាទុកយ៉ាងលម្អិត និង មានព័ត៌មានច្បាស់លាស់ (ឧទាហរណ៍ ឥណទានរបស់**មូលនិធិរូបិយវត្ថុអន្តរជាតិ**)។

### 2. ឥណទានសម្រាប់ការនាំចេញ

ធនាគារបរទេសផ្តល់ឥណទានដល់អ្នកទិញកម្ពុជា ដើម្បីអោយអ្នកទិញនោះអាចសងជាសាច់ប្រាក់ដល់អ្នកផ្គត់ផ្គង់របស់ខ្លួន (ជាទូទៅ គឺជាក្រុមហ៊ុននៃប្រទេសដែលធនាគារនោះស្ថិតនៅ) ។ ប្រការនេះគេហៅថា **ឥណទានអ្នកទិញ** (Buyer credit)។ ការប្រមូលទិន្នន័យមានលក្ខណៈស្មុគ្រស្មាញ ។ កាលបរិច្ឆេទនៃការបើកផ្តល់កម្ចី គឺជាកាលបរិច្ឆេទនៃផ្គត់ផ្គង់ទំនិញ ឬ សេវា ។ ជាញឹកញយ អង្គភាពគ្រប់គ្រងបំណុលមិនបានទទួលព័ត៌មានអំពីការផ្គត់ផ្គង់នេះទេ ។ អង្គភាពត្រូវទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយក្រុមហ៊ុន ដែលទទួលបាននូវការផ្គត់ផ្គង់ទំនិញ និង សេវានេះ ។ អ្នកផ្គត់ផ្គង់បរទេសអាចស្នើសុំដោយផ្ទាល់ អោយធនាគារផ្តល់ឥណទានអោយខ្លួន ដែលក្នុងករណីនេះ ហៅថា **ឥណទានអ្នកលក់** (Seller credit)។ អ្នកផ្គត់ផ្គង់ត្រូវកំណត់នូវលក្ខខណ្ឌទូទាត់ដល់អ្នកទិញកម្ពុជាដែលត្រូវទូទាត់នៅពេលក្រោយ ។ អ្នកផ្គត់ផ្គង់ខ្លួនឯងក៏អាចផ្តល់អោយអ្នកទិញកម្ពុជា នូវលទ្ធភាពទូទាត់នៅពេលក្រោយ ដោយមិនចាំបាច់ទៅរកឥណទានពីធនាគារ ។

### 3. ឥណទានតាមរយៈការនាំចូលទំនិញ

ជាញឹកញយ ឥណទាយកផ្តល់ឥណទានជាទំនិញ ដែលត្រូវនាំចូលយកមកលក់នៅក្នុងប្រទេសកម្ពុជា ។ ការលក់នេះទទួលបានជាសាច់ប្រាក់បដិភាគ ត្រូវត្រូវបានយកមកធ្វើជាជំនួយទ្រទ្រង់ថវិកាសម្រាប់រាជរដ្ឋាភិបាល ។ អង្គភាពគ្រប់គ្រងបំណុលត្រូវទំនាក់ទំនងយ៉ាងជិតស្និទ្ធ ជាមួយស្ថាប័នទទួលបន្ទុកអនុវត្តនូវការធ្វើហិរញ្ញប្បទានបែបនេះ ។

### 4. ឥណទានគម្រោង

ជាទូទៅ អង្គភាពគ្រប់គ្រងបំណុលអាចប្រមូលទិន្នន័យពីការបើកផ្តល់កម្ចីពី **អង្គភាពគ្រប់គ្រងគម្រោង** ឬ **អង្គភាពអនុវត្តគម្រោង** ដែលត្រូវបានបង្កើតនៅតាមក្រសួង ដែលទទួលនូវគម្រោងទាំងនោះ ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ចំពោះកម្ចីរបៀបនេះ មាននីតិវិធីចំនួន ៣ ប្រភេទ ក្នុងការបើកផ្តល់កម្ចី ។ ចាំបាច់ត្រូវបញ្ជាក់អោយបានច្បាស់ ក្នុងករណីនីមួយៗ នូវកាលបរិច្ឆេទនៃការបើកផ្តល់កម្ចី ដែលត្រូវកត់ត្រាទុកក្នុងតារាងគ្រប់គ្រងបំណុលៈ

- ក្នុងករណីនៃការអនុវត្តនូវ **នីតិវិធីទូទាត់ដោយផ្ទាល់** ឥណទាយកទូទាត់ត្រង់ ដោយផ្ទាល់អោយអ្នកផ្គត់ផ្គង់ ហើយការទូទាត់នេះត្រូវបានចាត់ទុកថា ជាការបើកផ្តល់កម្ចី ។

- ក្នុងករណីនៃការអនុវត្តនូវ **នីតិវិធីបុរេប្រទាន** ឥណទាយកបើកផ្តល់បុរេប្រទានដល់អ្នកផ្គត់ផ្គង់ ក្នុងគណនីដែលគ្រប់គ្រងដោយ **អង្គភាពអនុវត្តគម្រោង** ។ **អង្គភាពអនុវត្តគម្រោង** ចាប់ផ្តើមបញ្ជាទិញ ទូទាត់អ្នកផ្គត់ផ្គង់ ហើយបន្ទាប់មកទើបទាមទារអោយទូទាត់បុរេប្រទាន ។ ការបើកផ្តល់កម្ចី គឺជាកាលបរិច្ឆេទនៃការទូទាត់បុរេប្រទាន ។

ជារួម ការបើកផ្តល់កម្ចី គឺជាកាលបរិច្ឆេទបើកផ្តល់កម្ចី ក្នុងនាមឥណាយិក ។ ឥណទាយករៀបចំតារាងស្ថានភាពបើកផ្តល់កម្ចីជារៀងរាល់ខែ ដើម្បីផ្ញើទៅអោយអង្គភាពគ្រប់គ្រងបំណុល ។

### ២.២.២. ការតាមដានត្រួតពិនិត្យការទូទាត់សេវាបំណុល

ការទទួលខុសត្រូវមួយដ៏សំខាន់របស់អង្គភាពគ្រប់គ្រងបំណុល គឺការធានានូវការទូទាត់សេវាបំណុល (ការប្រាក់ និង ប្រាក់ដើម) អោយបានទាន់ពេលវេលា ។

- ឥណទាយកត្រូវផ្តល់ព័ត៌មានស្តីពីកាលបរិច្ឆេទសងបំណុល ទៅអោយអង្គភាពគ្រប់គ្រងបំណុល ។

- ទោះបីជាឥណទាយកមានភារកិច្ចក្នុងការផ្តល់ព័ត៌មានស្តីពីកាលបរិច្ឆេទសងបំណុលក្តី ក៏អង្គភាពគ្រប់គ្រងបំណុល នៅតែមានកាតព្វកិច្ចក្នុងការត្រួតពិនិត្យកាលបរិច្ឆេទសងបំណុលដដែល ។ អង្គភាពត្រូវទំនាក់ទំនងជាមួយឥណទាយក ប្រសិនបើគេមិនបានទទួលព័ត៌មានស្តីពីកាលបរិច្ឆេទសងបំណុលទេនោះ យ៉ាងហោចណាស់ មួយខែមុនពេលដែលត្រូវទូទាត់ ។

- អង្គភាពគ្រប់គ្រងបំណុលទទួលខុសត្រូវក្នុងការរៀបចំអាណត្តិបើកប្រាក់ ដាក់អាណត្តិបើកប្រាក់ឆ្លងថ្នាក់ដឹកនាំ និង អនុវត្តនូវនីតិវិធីដើម្បីផ្ទេរប្រាក់ទៅអោយធនាគារជាតិនៃកម្ពុជា ។

- អង្គភាពគ្រប់គ្រងបំណុលត្រូវកត់ត្រានូវប្រតិបត្តិការខាងលើនេះ នៅក្នុងប្រព័ន្ធគណនេយ្យរបស់ខ្លួន ពីពេលចេញអាណត្តិបើកប្រាស់ ដល់ពេលទូទាត់ ។

- អង្គភាពត្រូវផ្ទៀងផ្ទាត់ជាប្រចាំនូវការកត់ត្រាបញ្ជីគណនេយ្យនៃកម្ចីនីមួយៗ ជាមួយនឹងព័ត៌មានដែលទទួលបាន


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ពីឥណទាយក ។

នីតិវិធីថវិកាក្នុងការទូទាត់សេវាបំណុល គឺជានីតិវិធីសាមញ្ញ ។ នៅក្នុងនីតិវិធីធម្មតានៃការត្រួតពិនិត្យចំណាយថវិកា គេត្រូវឆ្លងឯកសារពីរដងដើម្បីអោយមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុផ្តល់ទិដ្ឋាការ ÷ លើកទីមួយ មុនពេលធានាចំណាយ ដើម្បីបញ្ជាក់ពីភាពទំនេរនៃឥណទានថវិកា និង លើកទីពីរ នៅពេលផ្តល់ទិដ្ឋាការលើអាណត្តិបើកប្រាក់ ។

ចំពោះនីតិវិធីនៃការទូទាត់សេវាបំណុលវិញ មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុផ្តល់ទិដ្ឋាការលើអាណត្តិតែមួយលើកប៉ុណ្ណោះ ។ ជាការពិត ឥណទានថវិកាសម្រាប់ការទូទាត់សេវាបំណុល គឺជាប្រភេទឥណទានដែលវាយតម្លៃបាន គឺមិនមែនជាឥណទានមានកំហិតដូចឥណទានថវិកាចរន្តទូទៅឡើយ ។ ទោះបីជាគ្មានឥណទានថវិកាក៏ដោយ ក៏គេត្រូវតែទូទាត់បំណុលដែរ នៅពេលដែលបំណុលនោះដល់ពេលត្រូវសង ដោយសារតែចំណាយនេះ ជាប្រភេទចំណាយចាំបាច់ ។ ដូច្នេះ ការទូទាត់សេវាបំណុលអាចអនុវត្តលើសពីឥណទានថវិកាដែលមាន ។ ក៏ប៉ុន្តែ ដើម្បីអោយការ-អនុវត្តថវិកាប្រព្រឹត្តទៅប្រកបដោយតុល្យភាព នៅពេលដែលអស់ឥណទាន ចាំបាច់ត្រូវផ្ទេរឥណទានថវិកាពីមុខសញ្ញាចំណាយផ្សេង ដើម្បីយកមកបំពេញឥណទានថវិកាសម្រាប់សេវាបំណុល ។

មូលហេតុមួយទៀត គឺការទូទាត់ចំណាយការប្រាក់ និង ចំណាយទូទាត់ប្រាក់ដើម មិនមែនជាការធានាចំណាយថ្មីឡើយ ។ តាមទិដ្ឋភាពគតិយុត្តិ ការធានាចំណាយចាប់ផ្តើមនៅពេលដែលក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុចុះហត្ថលេខាលើកិច្ចព្រមព្រៀងកម្ចី ។ ដូច្នេះ កាតព្វកិច្ចដែលបង្កើតឡើងដោយកិច្ចសន្យាកម្ចី មិនមែនការធានាចំណាយថ្មីឡើយ ។

ទោះបីជាចំណាយទូទាត់សេវាការប្រាក់ និង ទូទាត់ប្រាក់ដើម អាចអនុវត្តលើសពីឥណទានដែលមានក៏ដោយ ឥណទានថវិកាសម្រាប់ការទូទាត់បំណុលត្រូវតែប្រើប្រាស់ ដោយប្រុងប្រយ័ត្ន និង ដោយយកចិត្តទុកដាក់បំផុត ។

ជាបឋម ឥណទាននេះត្រូវតែប៉ាន់ស្មានអោយបានត្រឹមត្រូវ និង ជាក់លាក់នៅពេលរៀបចំថវិកា ។ អង្គភាពគ្រប់គ្រងបំណុលជាអ្នកទទួលខុសត្រូវដោយផ្ទាល់ ក្នុងការប៉ាន់ស្មានឥណទានថវិកាសម្រាប់ទូទាត់បំណុល ដោយសារអង្គភាពមានទិន្នន័យគណនេយ្យទាំងអស់ សម្រាប់ការប៉ាន់ស្មានចំណាយប្រភេទនេះអោយបានត្រឹមត្រូវ ។

ទោះបីជាឥណទានថវិកាសម្រាប់ទូទាត់បំណុលមិនគ្រប់គ្រាន់ក៏ដោយ ការទូទាត់បំណុលត្រូវតែអនុវត្ត ។ ក៏ប៉ុន្តែ ការអនុវត្តលើសពីឥណទានថវិកាដែលមាន នាំអោយថវិកាបាត់បង់នូវតុល្យភាព ។ ក្នុងករណីនេះ អង្គភាពត្រូវស្នើសុំរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុបង្កើនឥណទានថវិកាសម្រាប់ទូទាត់បំណុល តាមរយៈការផ្ទេរ


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ឥណទានថវិកាពីជំពូកផ្សេង ឬ ត្រូវពិនិត្យឡើងវិញនូវចំណាយថវិកា តាមរយៈការរៀបចំ និង ការអនុម័តនូវច្បាប់ស្តីពីហិរញ្ញវត្ថុកែតម្រូវ ។

អង្គភាពគ្រប់គ្រងបំណុលមិនត្រូវចាត់ទុកថាភារកិច្ចរបស់ខ្លួនចប់សព្វគ្រប់ នៅពេលដែលរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុចុះហត្ថលេខាលើអាណត្តិបើកប្រាក់ហើយនោះទេ ។ អង្គភាពត្រូវតាមដានឯកសារនោះរហូតដល់ពេលដែលធនាគារជាតិនៃកម្ពុជាធ្វើការទូទាត់ តាមបញ្ជារបស់រតនាគារជាតិ (ឬ តាមបញ្ជារបស់នាយកដ្ឋានវិនិយោគ និង សហប្រតិបត្តិការអន្តរជាតិ) ។ អគ្គនាយកដ្ឋានរតនាគារជាតិ និង នាយកដ្ឋានវិនិយោគ និង សហប្រតិបត្តិការអន្តរជាតិ ត្រូវចាត់ទុកថាការទូទាត់សេវាបំណុល គឺជាអាទិភាពធំជាងគេបំផុត បើប្រៀបធៀបទៅនឹងចំណាយផ្សេងៗទៀត ។

ការទូទាត់សេវាបំណុលអោយបានទាន់ពេលវេលានឹងជួយពង្រឹងកិត្យានុភាព និង ភាពគួរអោយទុកចិត្តបានរបស់ប្រទេសដែលខ្ចីប្រាក់ នៅចំពោះមុខដៃគូអភិវឌ្ឍន៍ ។ ផ្ទុយទៅវិញ ការទូទាត់បំណុលដោយយឺតយ៉ាវនឹងធ្វើអោយដៃគូអភិវឌ្ឍន៍បាត់ជំនឿ និង ធ្វើអោយការចរចាដើម្បីទទួលបាននូវបំណុលថ្មីនឹងមានភាពស្មុគស្មាញជាងមុន។ ការយឺតយ៉ាវក្នុងការទូទាត់បំណុលអាចនាំអោយឥណទាយកព្យួរការបើកផ្តល់កម្ចី ។ ប្រការនេះនឹងត្រូវធ្វើអោយការអនុវត្តគម្រោងមានការយឺតយ៉ាវ ។

## ២.៣. មុខងារគណនេយ្យនៃអង្គភាពគ្រប់គ្រងបំណុល

មុខងារគណនេយ្យពាក់ព័ន្ធទៅនឹងមុខងាររដ្ឋបាល ដែលយើងបានសិក្សាពីពេលមុនមក ។ មុខងារគណនេយ្យទាមទារអោយកត់ត្រានូវទិន្នន័យមួយចំនួន តាមលំដាប់លំដោយនៃកាលបរិច្ឆេទ លើឯកសារកម្ចីនីមួយៗ ដើម្បីអាចអោយអង្គភាពបូកសរុបនូវស្ថានភាពបំណុល ដែលឥណាយិកជំពាក់ឥណទាយក ក៏ដូចជាស្ថានភាពនៃការអនុវត្តនីតិវិធីទូទាត់ការប្រាក់ និង/ ឬ ប្រាក់ដើមនៃបំណុល ។

ការកត់ត្រានេះ មិនមែនជាការចុះកិច្ចបញ្ជីកាគណនី តាមវិធានគណនីទ្វេភាគឡើយ ដោយគ្រាន់តែចុះកិច្ចបញ្ជីកាគណនី តាមវិធានគណនីឯកកត្តភាគ ជាការស្រេច ។ ឯកសារកម្ចីអាចជាឯកសារក្រដាស ដែលអាចបំពេញដោយដៃ ឬ មួយជាឯកសារគ្រប់គ្រងតាមប្រព័ន្ធព័តិមានវិទ្យា ។

នៅលើកដំបូង នៅពេលដែលកម្ចីមានចំនួនតិច យើងអាចប្រើវិធីកត់ត្រាដោយដៃ លើឯកសារកម្ចីនីមួយៗ ដោយមិនចាំបាច់ប្រើប្រាស់នូវកម្មវិធីកុំព្យូទ័រស្មុគស្មាញ ។ ការកត់ត្រាដោយដៃ ក៏ជាវិធីមួយដែលគួរអនុវត្តនៅពេលដែលអង្គភាពចាំផ្តើមដាក់អោយអនុវត្តសាកល្បងនូវប្រព័ន្ធគ្រប់គ្រងបំណុល តាមប្រព័ន្ធព័តិមានវិទ្យា ។ ជារួមការងារគ្រប់គ្រងបំណុល គឺជាការងារដែលត្រូវធ្វើបណ្តើរ រៀនសូត្របណ្តើរ ។ ការកត់ត្រាលើឯកសារកម្ចីនីមួយៗ


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ទោះបីជាប្រើប្រាស់របៀបកត់ត្រាដោយដៃ ឬ ប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងដោយព័តិមានវិទ្យាក៏ដោយ ក៏អាចជួយសម្រួលដល់ការរៀបចំរបាយការណ៍ស្ដីពីស្ថានភាពបំណុលរបស់ប្រទេសផងដែរ ។

## ២.៤. មុខងារស្ថិតិនៃអង្គភាពគ្រប់គ្រងបំណុល

ការត្រួតពិនិត្យតាមដានការបំណុលយ៉ាងលម្អិត និង មានលក្ខណៈខ្ជាប់ខ្ជួនអាចអោយអង្គភាពគ្រប់គ្រងបំណុលរៀបចំបានយ៉ាងងាយស្រួល នូវទិន្នន័យ និង ស្ថិតិស្ដីពីស្ថានភាពបំណុលរបស់ព្រះរាជាណាចក្រកម្ពុជា ដោយមានការវិភាគជាអនុបាទ ឬ ក្រាហ្វិកផ្សេងៗ ។

## ៣. ក្លឹបទីក្រុងប៉ារីស និង ការចរចាបំណុលឡើងវិញ

វិបត្តិបំណុលនៅក្នុងប្រទេសកំពុងអភិវឌ្ឍ ជាពិសេសនៅក្នុងប្រទេសដែលមានប្រាក់ចំណូលទាប គឺជាបញ្ហាមួយដ៏សំខាន់នៃការអភិវឌ្ឍសេដ្ឋកិច្ចនៅក្នុងពិភពលោក នៅក្នុងអំឡុងពេលប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ ។ ដើម្បីប្រឈមមុខនឹងវិបត្តិបំណុល ដែលតែងតែកើតឡើងជារឿយៗនៅក្នុងប្រទេសឥណាយិក ប្រទេសឥណទាយកបានរៀបចំនូវវេទិកាសំខាន់ៗចំនួនពីរ គឺ៖

ទីមួយ- **ក្លឹបទីក្រុងប៉ារីស** ដែលប្រមូលផ្ដុំឥណទាយកសាធារណៈ (រដ្ឋ និង នីតិបុគ្គលនៃនីតិសាធារណៈ) ដែលបានផ្ដល់កម្ចីអោយរដ្ឋ ឬ អោយនីតិបុគ្គលនៃនីតិសាធារណៈ ឬ អោយសហគ្រាសឯកជន ដោយមានការធានារបស់រដ្ឋ ។

ទីមួយ- **ក្លឹបទីក្រុងឡុងដ៍** ដែលប្រមូលផ្ដុំឥណទាយកឯកជន (ធនាគារពាណិជ្ជ) ដែលផ្ដល់កម្ចីអោយរដ្ឋ ឬ អោយនីតិបុគ្គលនៃនីតិសាធារណៈ ឬ អោយសហគ្រាសឯកជន ដោយមានការធានារបស់រដ្ឋ ។

ក្លឹបទាំងពីរនេះ ដែលជាឥណទាយកសាធារណៈ និង ឯកជន ទាមទារអោយប្រទេសឥណាយិកចុះកិច្ចព្រមព្រៀងជាបឋមជាមួយ **មូលនិធិរូបិយវត្ថុអន្តរជាតិ** ។

**ក្លឹបទីក្រុងប៉ារីស** មិនមែនជាអង្គការផ្លូវការទេ តែជាក្រុមក្រៅផ្លូវការនៃប្រទេសឥណទាយក ដែលជួបជុំគ្នានៅទីក្រុងប៉ារីសមួយដង ក្នុងមួយខែជាមធ្យម ដើម្បីពិនិត្យបញ្ហាចរចាឡើងវិញនូវបំណុលក្រៅប្រទេសរបស់ប្រទេសឥណាយិក ដែលដាក់ពាក្យស្នើសុំធ្វើការចរចាបំណុលឡើងវិញ ។

**ក្លឹបទីក្រុងប៉ារីស** គ្មានមូលដ្ឋានគតិយុត្តិ ឬ វិធានសម្រាប់ទទួលសមាជិក ហើយក៏គ្មានរចនាសម្ព័ន្ធស្ថាប័ន ឬ គ្មានបុគ្គលិកអ្វីឡើយ ។ ក្លឹបទីក្រុងប៉ារីសជួបប្រជុំក្រោមអធិបតីភាពរបស់អគ្គនាយករតនាគារបារាំង ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ការិយាល័យនៃធនាគារបារាំងត្រូវបានតែងតាំង ជាលេខាធិការដ្ឋាននៃក្លឹបប៉ារីស ។ ប្រទេសឥណាយិកជាច្រើនបានមកក្លឹបប៉ារីសជាច្រើនដង ។ ក្លឹបប៉ារីសបានធ្វើការចរចាឡើងវិញនូវបំណុល ដែលធ្លាប់ចរចាឡើងវិញរួចមកហើយ ។

សមាជិកអចិន្ត្រៃយ៍នៃ **ក្លឹបទីក្រុងប៉ារីស** មានប្រទេស អាឡឺម៉ាញ អូស្ត្រាលី អូទ្រីស បែលហ្ស៊ិក កាណាដា ដាណឺម៉ាក អេស្ប៉ាញ សហរដ្ឋអាមេរិក ហ្វាំងឡង់ បារាំង អៀរឡង់ អ៊ីតាលី ជប៉ុន ន័រវេ ហូឡង់ អង់គ្លេស ស៊ុយអែត និង ស្វីស ។ **ក្លឹបទីក្រុងប៉ារីស** មិនមែនបិទទ្វារមិនទទួលសមាជិកថ្មីឡើយ ហើយសមាជិកមិនមែនសុទ្ធតែជាប្រទេសឧស្សាហកម្មជឿនលឿនទេ ។ ប្រទេសកំពុងអភិវឌ្ឍខ្លះ ដែលជាឥណទាយកធ្លាប់បានចូលរួមក្នុងអង្គប្រជុំនៃ**ក្លឹបទីក្រុងប៉ារីស** រួចមកហើយ ។ ប្រទេសរុស្ស៊ីបានចូលជាសមាជិកនៃ**ក្លឹបទីក្រុងប៉ារីស** នៅក្នុងឆ្នាំ ១៩៩៧ ជាប្រទេសឥណទាយក បន្ទាប់ពីបានចូលរួមការចរចា ក្នុងឋានជាប្រទេសឥណាយិករួចមក ។

ម្យ៉ាងវិញទៀត **ក្លឹបទីក្រុងប៉ារីស** បើកទ្វារសម្រាប់ស្ថាប័នរូបិយវត្ថុពហុភាគី ដែលមានការពាក់ព័ន្ធ ។ ដូចជា មូលនិធិរូបិយវត្ថុអន្តរជាតិបានធ្វើការវិភាគពីកម្មវិធីកំណែតម្រូវរចនាសម្ព័ន្ធ និង ទស្សនវិស័យម៉ាក្រូសេដ្ឋកិច្ចនៃ ប្រទេសឥណាយិក ។ ធនាគារពិភពលោកបានវាយតម្លៃពីប្រសិទ្ធភាពនៃគោលនយោបាយវិនិយោគ វិធានការតាមផ្នែក និង ទស្សនវិស័យរយៈពេលមធ្យម និង រយៈពេលវែង ។ ធនាគារក្នុងតំបន់ដើម្បីអភិវឌ្ឍន៍ អង្គការដើម្បីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចនៅអ៊ឺរ៉ុប គណៈកម្មាធិការនៃសហគមន៍អ៊ឺរ៉ុប និង សន្និសិទអង្គការសហប្រជាជាតិដើម្បីពាណិជ្ជកម្ម និង ការអភិវឌ្ឍ អាចចូលរួមក្នុងអង្គប្រជុំបាន និង ផ្តល់នូវមតិយោបល់របស់គេ ។

ប្រទេសឥណាយិកតែងតែចាត់តាំងរដ្ឋមន្ត្រី ក្រសួងហិរញ្ញវត្ថុរបស់គេ អមដោយមន្ត្រីជំនាញ អោយចូលរួមប្រជុំជាតំណាង ដើម្បីពិភាក្សាករណីរបស់ប្រទេសនោះ ។ កិច្ចប្រជុំត្រូវបានរៀបចំឡើងនៅទីក្រុងប៉ារីស តាមការអញ្ជើញរបស់លេខាធិការដ្ឋាននៃ**ក្លឹបទីក្រុងប៉ារីស** ។ កិច្ចប្រជុំប្រព្រឹត្តទៅជាភាសាបារាំង និង អង់គ្លេស ដែលមានអ្នកបកប្រែភ្លាមៗពីភាសាមួយ ទៅភាសាមួយទៀត ។

## ៤. បំណុលក្រៅប្រទេសរបស់កម្ពុជា

**ក្លឹបទីក្រុងប៉ារីស** បានជជែកពិភាក្សាលើករណីបំណុលក្រៅប្រទេសរបស់កម្ពុជា នៅថ្ងៃទី ២៦ មករា ឆ្នាំ ១៩៩៥ ។

### ៤.១. គោលការណ៍គន្លឹះ

- **គោលការណ៍ករណីមួយៗ៖** រាល់សេចក្តីសម្រេចចិត្តត្រូវធ្វើឡើងជាឯកច្ឆ័ន្ទ ដែលមានន័យថា ត្រូវមានការខិត



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ខំប្រឹងប្រែងយ៉ាងខ្លាំង និង ត្រូវមានសុច្ឆន្ទៈពីគ្រប់អ្នកចូលរួម ដើម្បីសម្រេចបញ្ហាបាន ។ ជាញឹកញយ កិច្ចព្រមព្រៀងស្តីពីលក្ខខណ្ឌនៃការចរចាបំណុលឡើងវិញត្រូវបានចុះហត្ថលេខានៅពេលថ្ងៃ ។

- **គោលការណ៍ប្រព្រឹត្តិកម្មដូចៗគ្នា**៖ ការខិតខំប្រឹងប្រែងរបស់ប្រទេសឥណទាយក ដើម្បីចរចាបំណុលឡើងវិញ មិនត្រូវប្រើប្រាស់ ដើម្បីកេងយកចំណេញពីឥណទាយកផ្សេងទៀតឡើយ ។ ការខិតខំប្រឹងប្រែងនៃឥណទាយកទាំងអស់ត្រូវធ្វើឡើងប្រហាក់ប្រហែលគ្នា ។

## ៤.២. វិធាននៃកិច្ចដំណើរការ

វិធាននៃកិច្ចដំណើរការ គឺជាវិធានជាក់ស្តែង ដែលងាយស្រួលអនុវត្ត និង សម្របសម្រួលទៅតាមសេចក្តីត្រូវការនៃករណីនីមួយៗ មានសភាពហ្នឹងម៉ាត់ តែមានការវិវត្តឥតឈប់ឈរ ។ ពីមួយឆ្នាំ ទៅមួយឆ្នាំ យើងសង្កេតឃើញថា វិធានទាំងនេះមានការវិវត្តជាវិជ្ជមានសម្រាប់ប្រទេសឥណាយិក ។

### ៤.២.១. ទំហំនៃការកែតម្រូវរចនាសម្ព័ន្ធបំណុល

ការកែតម្រូវរចនាសម្ព័ន្ធបំណុលមិនគ្របដណ្តប់លើបំណុលទាំងអស់របស់ប្រទេសឥណទាយកឡើយ ។ ក្លឹបនៃទីក្រុងប៉ារីសពិនិត្យតែសេវាបំណុលមួយផ្នែក ដែលប្រទេសមួយមិនអាចដោះស្រាយ នៅក្នុងដំណាក់កាលណាមួយនោះ ដែលហៅថា ដំណាក់កាលកែតម្រូវរចនាសម្ព័ន្ធបំណុល ។ ការកែតម្រូវរចនាសម្ព័ន្ធបំណុលត្រូវបានអនុវត្តតែចំពោះដើមបំណុល ហើយប្រសិនបើចាំបាច់ ចំពោះការប្រាក់ដែលត្រូវសងនៅក្នុងរយៈពេលនោះ ។ ដំណាក់កាលកែតម្រូវរចនាសម្ព័ន្ធបំណុល គឺជាដំណាក់កាលដែលត្រូវបើក ដោយមានកិច្ចព្រមព្រៀងជាមួយ មូលនិធិរូបិយវត្ថុអន្តរជាតិ និង មានតែដំណាក់កាលនេះទេ ដែលមានការប្រែប្រួល ÷ មួយឆ្នាំ ពីរឆ្នាំ ឬ លើសពីនេះ ។ នៅក្នុងករណីនៃប្រទេសកម្ពុជា ដំណាក់កាលកែតម្រូវរចនាសម្ព័ន្ធបំណុលមានថេរវេលាចំនួន ពីរឆ្នាំកន្លះ គឺចាប់តាំងពីថ្ងៃទី ១ ខែ មករា ឆ្នាំ ១៩៩៥ ដល់ ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០០៥ ។

គេអាចយកបំណុលរ៉ាំរ៉ៃដែលមានស្រាប់ នៅពេលចាប់ផ្តើមនៃដំណាក់កាលកែតម្រូវរចនាសម្ព័ន្ធបំណុល ដើម្បីយកមកចរចាឡើងវិញបាន ។ ចំពោះករណីកម្ពុជា បំណុលដែលមិនទាន់បានសងទាំងអស់នៅត្រឹមថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ ត្រូវបានយកមកចរចាឡើងវិញ ។

អត្រានៃការចរចាឡើងវិញតែងតែខុសគ្នា ពីប្រទេសមួយទៅប្រទេសមួយទៀត ដែលឆ្លុះបញ្ចាំងពីតម្រូវការជាក់ស្តែងក្នុងការធ្វើហិរញ្ញប្បទាន និង សមត្ថភាពសងរបស់ប្រទេសឥណទាយកដែលមានការពាក់ព័ន្ធ ។

ការទូទាត់នៃបំណុលរយៈពេលខ្លីមិនត្រូវបានបញ្ចូលក្នុងការចរចាឡើងវិញទេ ដើម្បីទុកលទ្ធភាពអោយ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ប្រទេសនោះ អាចស្វែងរកហិរញ្ញប្បទានថ្មីរយៈពេលខ្លី ។ គោលការណ៍នេះត្រូវបានយកមកអនុវត្តផងដែរ ចំពោះបំណុលរយៈពេលវែង (ដែលមានរយៈពេលច្រើនជាងមួយឆ្នាំ) ហើយដែលកើតមានឡើងក្រោយ **កាលបរិច្ឆេទបិទបញ្ចី** (Cut off date or date butoir)។ ឥណទានដែលផ្តល់មុន **កាលបរិច្ឆេទបិទបញ្ចី** នឹងត្រូវចរចាឡើងវិញទៅតាមលក្ខខណ្ឌនៃ **ក្លឹបទីក្រុងប៉ារីស** (ដែលមានលក្ខខណ្ឌសងសម្បទាន គឺរយៈពេលសងវែង ហើយការប្រាក់ទាប) ។ ចំណែកឯ ឥណទានដែលផ្តល់ក្រោយ **កាលបរិច្ឆេទបិទបញ្ចី** នឹងត្រូវចរចាឡើងវិញតាមលក្ខខណ្ឌរបស់ **ក្លឹបទីក្រុងប៉ារីស** ដែលមានអត្រាការប្រាក់ទីផ្សារ និង ទៅតាមតារាងសងប្រាក់ដែលបានកំណត់ ។

គួរគូសបញ្ជាក់ថា មានតែបំណុលទ្វេភាគីប៉ុណ្ណោះ ដែលអាចចរចាឡើងវិញបាន ។ ចំណែកឯឥណទានពហុភាគីដែលជាឥណទានផ្តល់ដោយមូលនិធិហិរញ្ញវត្ថុអន្តរជាតិ ឥណទានផ្តល់ដោយធនាគារពិភពលោក និង ធនាគារអភិវឌ្ឍន៍អាស៊ី មិនអាចយកមកចរចាឡើងវិញបានឡើយ ។

### ៤.២.២. ប្រព្រឹត្តកម្មនៃបំណុលដែលត្រូវចរចាឡើងវិញ

ប្រមុខរដ្ឋនៃប្រទេសអភិវឌ្ឍន៍ជឿនលឿនបានកំណត់នូវគោលការណ៍ធំៗនៃការចរចាឡើងវិញ ដែលរៀបចំឡើងនៅក្នុងឱកាសនៃជំនួបកំពូលជាច្រើនលើកមកហើយ ។ នៅក្នុងឱកាសជំនួបកំពូលនៅទីក្រុងតូរ៉ុនតូនៅក្នុងឆ្នាំ ១៩៩៨ ប្រមុខរដ្ឋទាំងនោះបានអនុម័តនូវប្រព្រឹត្តកម្មមួយសម្រាប់ **ប្រទេសអភិវឌ្ឍយឺតបំផុត** (ដែលជាប្រទេសដែលទទួលនូវកម្ចីសម្បទានពីធនាគារពិភពលោក) ។ ប្រទេសឥណទាយកអាចជ្រើសរើសជម្រើសមួយក្នុងចំណោមប្រព្រឹត្តកម្មចំនួន ៣ ដើម្បីដាក់នៅក្នុងកិច្ចព្រមព្រៀងទ្វេភាគី ÷

- ការលុបចោលមួយភាគបីនៃបំណុលដែលត្រូវចរចាឡើងវិញ
- ការកាត់បន្ថយអត្រាការប្រាក់
- ការបង្កើន **រយៈពេលសងសេវាបំណុល** រហូតដល់ ២៥ ឆ្នាំ ដែលក្នុងនោះ **រយៈពេលអនុគ្រោះ** (Grace period) មានចំនួន ១៤ ឆ្នាំ ។

ជម្រើសខាងលើនេះត្រូវបានកែលម្អជាបន្តបន្ទាប់ តាមរយៈការអនុម័តនូវ **លក្ខខណ្ឌឡុងដ៍** និង **លក្ខខណ្ឌទ្រីនីដាត** នៅក្នុងឆ្នាំ ១៩៩១ និង **លក្ខខណ្ឌណាពើល** (Naples Terms) នៅក្នុងឆ្នាំ ១៩៩៤ ។

**ព្រះរាជាណាចក្រកម្ពុជា** គឺជាប្រទេសទីមួយដែលទទួលបាននូវប្រព្រឹត្តកម្មបំណុលតាម **លក្ខខណ្ឌណាពើល** ដែលផ្តល់នូវ÷ ការលុបចោលបំណុលចំនួន ៧០% និង ការអនុវត្ត **រយៈពេលសងសេវាបំណុល** ៤០



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ឆ្នាំ ។

## ៥. ការពិពណ៌នាពីបំណុលសាធារណៈក្រៅប្រទេសរបស់កម្ពុជា

ទស្សនវិស័យនៃការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជាអាស្រ័យ ក្នុងចំណែកមួយយ៉ាងធំ លើសមត្ថភាពរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការកៀងគរនូវធនធានក្នុង និង ក្រៅប្រទេស ដើម្បីធ្វើហិរញ្ញប្បទានការអភិវឌ្ឍ ។ ការកៀងគរធនធានក្រៅប្រទេសត្រូវបានផ្តោតកាន់តែខ្លាំងឡើង លើកម្ចី ។ ដូច្នេះហើយ ទើបរាជរដ្ឋាភិបាលកម្ពុជាបង្កើនការយកចិត្តទុកដាក់លើការវាយតម្លៃនៃសមត្ថភាពសងបំណុលរបស់កម្ពុជា ដោយឈរលើមូលដ្ឋាននៃទំហំបំណុល និង សមត្ថភាពសេវាបំណុល ។ ម៉្យាងវិញទៀត សមត្ថភាពសងបំណុលរបស់កម្ពុជាអាស្រ័យលើលទ្ធផលនៃការចរចាដើម្បីដោះស្រាយបំណុលជាមួយសហព័ន្ធរុស្ស៊ី និង សហរដ្ឋអាមេរិក ជាពិសេស លក្ខខណ្ឌនៃការចរចាឡើងវិញ ដូចជា **អត្រាការប្រាក់ រយៈពេលអនុគ្រោះ** និង **រយៈពេលសងសេវាបំណុល** ។

### ៥.១. ការវិភាគរចនាសម្ព័ន្ធបំណុល

នៅត្រឹមថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៦ ទំហំនៃបំណុលសរុបរបស់កម្ពុជា ដោយរួមទាំង **ការប្រាក់ទោសទំណង** ស្មើនឹង ៣,១៥ ពាន់លានដុល្លារ ឬ ៤៣,៣%នៃ ផលិតផលសរុបក្នុងស្រុក (ផសស) ។ ឥណទាយកសំខាន់ពីររបស់កម្ពុជា គឺ សហព័ន្ធរុស្ស៊ី និង សហរដ្ឋអាមេរិក ។ ក្រោយពីការចរចាឡើងវិញជាមួយឥណទាយកទាំងពីរ បំណុលក្រៅប្រទេសរបស់កម្ពុជានឹងត្រូវស្មើនឹង ២,១ ពាន់លានដុល្លារ ឬ ២៩%នៃ ផសស ។

### ៥.២. បំណុលពហុភាគី

បំណុលដែលកម្ពុជាជំពាក់ឥណទាយកពហុភាគី (ធនាគារពិភពលោក ធនាគារអភិវឌ្ឍន៍អាស៊ី មូលនិធិអន្តរជាតិដើម្បីការអភិវឌ្ឍកសិកម្ម និង អង្គការនៃប្រទេសនាំចេញប្រេង) មានចំនួន ១,១ ពាន់លានដុល្លារ ឬ ៥២% នៃបំណុលសរុប ។ បំណុលទាំងនេះ ជាប្រភេទបំណុលសម្បទានដែលកម្ពុជាចាប់ផ្តើមខ្ចីចាប់តាំងពីឆ្នាំ ១៩៩៣ មកហើយចេះតែកើនឡើងជាលំដាប់ ។

បំណុលដែលកម្ពុជាជំពាក់ **មូលនិធិរូបិយវត្ថុអន្តរជាតិ** មិនបានគិតបញ្ចូលក្នុងការគិតគូខាងលើទេ ។ កម្ចីរបស់ **មូលនិធិរូបិយវត្ថុអន្តរជាតិ** គឺសម្រាប់ទ្រទ្រង់ជញ្ជីងទូទាត់ ។ កម្ពុជាធ្លាប់អនុវត្តនូវកម្មវិធីជាមួយ នឹង **មូលនិធិរូបិយវត្ថុអន្តរជាតិ** ចំនួនបីលើក ដើម្បីទទួលបាននូវកម្ចី ដែលមានទឹកប្រាក់សរុបចំនួន ១០៣ លានដុល្លារ នៅក្នុងឆ្នាំ ២០០៣ ដែលជាឆ្នាំចុងក្រោយនៃការអនុវត្តគម្រោងជាមួយនឹងស្ថាប័ននេះ ។

- **កម្ចីដើម្បីបំប្លែងប្រព័ន្ធសេដ្ឋកិច្ច** (Systemic Transformation Facility-STE) - ដែលអនុម័តនៅក្នុង



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ខែ តុលា ឆ្នាំ ១៩៩៣ ដែលមានទឹកប្រាក់ចំនួន ៦,២៥ លាន **SDR** ដែលមានការប្រាក់ចំនួន ៥,៧២%។

- **កម្ចីដើម្បីពង្រីកកំណែតម្រូវរចនាសម្ព័ន្ធសេដ្ឋកិច្ច** (Enhanced Structural Adjustment Facility-ESAF)- ដែលអនុម័តនៅក្នុង ខែ ឧសភា ឆ្នាំ ១៩៩៤ ដែលមានទឹកប្រាក់ចំនួន ៨៤ លាន **SDR (**ប្រមាណជា ១២០ លានដុល្លារអាមេរិក) ដើម្បីគាំទ្រដល់ការអនុវត្តកម្មវិធីកំណែតម្រូវរចនាសម្ព័ន្ធ និង កំណែទម្រង់សេដ្ឋកិច្ចក្នុងរយៈពេល ៣ ឆ្នាំ ។ កម្ចីនេះត្រូវបានចែកចេញជាបីដុំប្រចាំឆ្នាំ ដែលមានទឹកប្រាក់ ក្នុងមួយឆ្នាំចំនួន ២៨ លាន **SDR** ។ មកទល់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៦ មូលនិធិរូបិយវត្ថុអន្តរជាតិបានបើកផ្តល់នូវទឹកប្រាក់ជាងពាក់កណ្តាលស្មើនឹង ៤២ លាន **SDR (**ប្រមាណ ជា ៦០ លានដុល្លារអាមេរិក) ។ ដោយសារតែមានបញ្ហាក្នុងកំណែទម្រង់វិស័យព្រៃឈើ កម្ចីដែលនៅសល់ត្រូវបានលុបចោល ។ លក្ខខណ្ឌនៃកម្ចីនេះ គឺ អត្រាការប្រាក់សម្បទាន ០,៥% រយៈពេលសងសេវាបំណុលចំនួន ១០ ឆ្នាំ និង រយៈពេលអនុគ្រោះចំនួន ៥,៥ ឆ្នាំ ។
- **កម្ចីដើម្បីកាត់បន្ថយភាពក្រីក្រ និង កំណើន** (Poverty Reduction and Growth Facility-PRGF) - ដែលអនុម័តនៅក្នុង ឆ្នាំ ១៩៩៩ ដើម្បីគាំទ្រដល់ការអនុវត្តកម្មវិធីកំណែទម្រង់ សម្រាប់ឆ្នាំ ១៩៩៩-២០០៣ ដោយមានអត្រាការប្រាក់សម្បទាន ០,៥% រយៈពេលសងសេវាបំណុលចំនួន ១០ ឆ្នាំ និង រយៈពេលអនុគ្រោះចំនួន ៥,៥ ឆ្នាំ ។ កម្ពុជាបានឆ្លងកាត់នូវការពិនិត្យឡើងវិញនៃកម្មវិធី **កម្ចីដើម្បីកាត់បន្ថយភាពក្រីក្រ និង កំណើន** នេះចំនួន ៦ លើក ហើយទទួលបានកម្ចីចំនួន ៥៨,៥ លាន **SDR (**៨០ លានដុល្លារអាមេរិក) ។

ដោយសារតែកម្ចីនេះមានគោលដៅទ្រទ្រង់ជញ្ជីងទូទាត់ **ធនាគារជាតិនៃកម្ពុជា** ជាស្ថាប័នដែលគ្រប់គ្រងកម្ចីនេះ ក្នុងគោលដៅពង្រឹងស្ថានភាពទុនបម្រុង ដើម្បីប្រើប្រាស់ជាមធ្យោបាយទូទាត់ជាមួយបរទេស ។ **ធនាគារជាតិនៃកម្ពុជា** ទទួលខុសត្រូវក្នុងការសងសេវាបំណុល និង ការប្រាក់ ។ ដូច្នេះ ចំណាយសេវាបំណុលដែលកម្ពុជាជំពាក់មូលនិធិរូបិយវត្ថុអន្តរជាតិ មិនបានបញ្ចូលក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុប្រចាំឆ្នាំឡើយ តែទិន្នន័យនេះត្រូវបានបញ្ចូលទៅក្នុងទិន្នន័យស្ថិតិបំណុល ។

នៅក្នុងខែ មិថុនា ឆ្នាំ ២០០៥ ក្រុមប្រទេសឧស្សាហកម្មចម្រើនជឿនលឿនចំនួន ៨ **(G-8)** បានដាក់ចេញនូវសំណើរអោយស្ថាប័នរូបិយវត្ថុអន្តរជាតិចំនួនបី គឺ **មូលនិធិរូបិយវត្ថុអន្តរជាតិ សមាគមអន្តរជាតិដើម្បីអភិវឌ្ឍន៍** នៃធនាគារពិភពលោក និង **ធនាគារអភិវឌ្ឍន៍អាហ្វ្រិក** លុបចោលទាំងស្រុងនូវបំណុលរបស់ប្រទេសដែលបានបំពេញតាមលក្ខខណ្ឌ ឬ ដែលនឹងបំពេញតាមលក្ខខណ្ឌនៃ «**ការផ្តួចផ្តើមគំនិតប្រទេសក្រីក្រដែលជំពាក់បំណុលខ្លាំង**» (Heavily Indebted Poor Country (HIPC) Initiative) ដែលគ្រប់គ្រងរួមគ្នាដោយមូលនិធិរូបិយវត្ថុអន្តរជាតិ និង ធនាគារពិភពលោក ។ «**ការផ្តួចផ្តើមគំនិតប្រទេសក្រីក្រដែលជំពាក់បំណុល**



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

| តារាងលេខ - បំណុលក្រៅប្រទេសនៃព្រះរាជាណាចក្រកម្ពុជា (លានដុល្លារ) | | | | | |
|---|---|---|---|---|---|
| | | ខែ ធ្នូ ឆ្នាំ ២០០៦ | %នៃផសស | ក្រោយពីចរចា | %នៃផសស |
| I | **បំណុលពហុភាគី** | **1,083,512,063** | **14.91%** | **1,083,512,063** | **14.91%** |
| | ធនាគារអភិវឌ្ឍន៍អាស៊ី | 579,956,046 | 7.98% | 579,956,046 | 7.98% |
| | ធនាគារពិភពលោក | 461,704,631 | 6.36% | 461,704,631 | 6.36% |
| | IFAD | 26,532,450 | 0.37% | 26,532,450 | 0.37% |
| | OPEC | 15,318,936 | 0.21% | 15,318,936 | 0.21% |
| II | **បំណុលទ្វេភាគី** | **253,140,147** | **3.48%** | **253,140,147** | **3.48%** |
| | បារាំង | 21,156,485 | 0.29% | 21,156,485 | 0.29% |
| | អាឡឺម៉ាញ | 2,074,306 | 0.03% | 2,074,306 | 0.03% |
| | ជប៉ុន | 43,237,398 | 0.60% | 43,237,398 | 0.60% |
| | ស្វ៊ីតឺ | 268,259 | 0.00% | 268,259 | 0.00% |
| | ដែក | 766,518 | 0.01% | 766,518 | 0.01% |
| | ម៉ាឡេស៊ី | 7,000,000 | 0.10% | 7,000,000 | 0.10% |
| | ចិន | 102,576,554 | 1.41% | 102,576,554 | 1.41% |
| | កូរ៉េ | 57,674,436 | 0.79% | 57,674,436 | 0.79% |
| | ឥណ្ឌា | 4,771,185 | 0.07% | 4,771,185 | 0.07% |
| | ថៃឡង់ | 13,062,181 | 0.18% | 13,062,181 | 0.18% |
| | មូលនិធិអភិវឌ្ឍន៍ន៍ឌីក | - | | - | |
| | វៀតណាម | 552,825 | 0.01% | 552,825 | 0.01% |
| | **បំណុលរុស្ស៊ី- អាមេរិក** | **1,812,865,620** | **24.95%** | **749,585,751** | **10.32%** |
| | សហព័ន្ធរុស្ស៊ី | 1,525,000,000 | 20.99% | 457,585,751 | 6.30% |
| | Russian pre-cut-off | | 0.00% | 210,788,538 | 2.90% |
| | Russian post-cut-off | | 0.00% | 246,797,213 | 3.40% |
| | សហរដ្ឋអាមេរិក | 287,865,620 | 3.96% | 292,000,000 | 4.02% |
| | **បំណុលជាប្រូបរុស្ស៊ី** | **2,044,005** | **0.03%** | **2,044,005** | **0.03%** |
| | ប៉ូឡូញ | 1,564,655 | 0.02% | 1,564,655 | 0.02% |
| | អ៊ីតាលី | 479,350 | 0.01% | 479,350 | 0.01% |
| III | **បំណុលសរុប** | **3,151,561,835** | **43.38%** | **2,088,281,966** | **28.74%** |
| *ប្រភព: ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ខែ ឧសភា ឆ្នាំ ២០០៧* | | | | | |

**ខ្លាំង»** ត្រូវអនុវត្តដោយឈរលើមូលដ្ឋាននៃការអនុវត្តផែនកាសកម្មភាពរួមគ្នារវាងប្រទេសពាក់ព័ន្ធ និង ស្ថាប័នរូបិយវត្ថុអន្តរជាតិ ដើម្បីអោយបំណុលនៃប្រទេសក្រីក្រដែលជំពាក់បំណុលខ្លាំងឈានទៅរកកម្រិតមួយ ដែលមានចីរភាព ។ «**ការផ្តួចផ្តើមគំនិតលុបចោលបំណុលពហុភាគី**» (Multilateral Debt Relief Initiative - MDRI) គឺជាការផ្តួចផ្តើមគំនិត ដែលកាន់តែឈានមុខជាងគេ ដោយស្នើសុំអោយលប់ចោលនូវបំណុលទាំងស្រុង ដើម្បីអោយប្រទេសក្រីក្រអាចយកធនធានពីការលុបបំណុលនេះ ទៅវិនិយោគដើម្បីសម្រេចបាននូវ «**គោលដៅ**



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

**អភិវឌ្ឍន៍សហស្សវត្សរ៍»** (MDG) ។

ដើម្បីទទួលបាននូវការលុបចោលបំណុលនេះ តាមការសម្រេចរបស់ក្រុមប្រឹក្សាភិបាលនៃមូលនិធិរូបិយវត្ថុអន្តរជាតិ ប្រទេសក្រីក្រនោះត្រូវមានកម្មវិធីជាមួយមូលនិធិរូបិយវត្ថុអន្តរជាតិ និង សម្រេចបាននូវសមិទ្ធផលល្អក្នុងវិស័យបីដូចខាងក្រោម៖ (១) គោលនយោបាយម៉ាក្រូសេដ្ឋកិច្ច (២) ការអនុវត្តយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ និង (៣) ការគ្រប់គ្រងចំណាយថវិកា ។ ក្រុមប្រឹក្សាភិបាលនៃមូលនិធិរូបិយវត្ថុអន្តរជាតិបានសម្រេចថា ប្រទេសក្រីក្រចំនួន ១៩ អាចទទួលបាននូវការលុបបំណុលចោលភ្លាមៗ ក្នុងក្របខ័ណ្ឌនៃ «**ការផ្តួចផ្តើមគំនិតលុបចោលបំណុលពហុភាគី**» ។

នៅក្នុងខែ ធ្នូ ឆ្នាំ ២០០៥ មន្ត្រីរបស់មូលនិធិរូបិយវត្ថុអន្តរជាតិបានសម្រេចថាកម្ពុជាបានបំពេញតាមគ្រប់លក្ខណៈវិនិច្ឆ័យ ដូចបានថែងខាងលើ ហើយអាចទទួលបាននូវការលុបបំណុលក្នុងក្របខ័ណ្ឌនៃ «**ការផ្តួចផ្តើមគំនិតលុបចោលបំណុលពហុភាគី**» ។ ចាប់តាំងពីឆ្នាំ ១៩៩៩ មក កម្ពុជាសម្រេចបាននូវកំណើនសេដ្ឋកិច្ចខ្ពស់អតិផរណាទាប វឌ្ឍនភាពក្នុងការកាត់បន្ថយភាពក្រីក្រ កែលម្អការគ្រប់គ្រងចំណាយថវិកា និង បានអនុវត្តការប្តេជ្ញាចិត្តរបស់ខ្លួន ក្នុងការអនុវត្តនូវយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ ។

នៅក្នុងខែ មករា ឆ្នាំ ២០០៦ ដោយអនុលោមតាម «**ការផ្តួចផ្តើមគំនិតលុបចោលបំណុលពហុភាគី**» មូលនិធិរូបិយវត្ថុអន្តរជាតិបានអនុម័តលុបចោលបំណុលដែលកម្ពុជាជំពាក់ខ្លួនមុនថ្ងៃទី ១ ខែ មករា ឆ្នាំ ២០០៥ ទាំង ១០០ ភាគរយ ។ បំណុលទាំងអស់នេះដែលមានទឹកប្រាក់សរុបចំនួន ៨២ លានដុល្លារអាមេរិក នឹងត្រូវផ្តល់ជូនរាជរដ្ឋាភិបាលកម្ពុជា ដើម្បីបង្កើនការវិនិយោគក្នុងគោលដៅសម្រេចអោយបាននូវ «**គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍**» (MDG) ។

## ៥.៣. បំណុលទ្វេភាគី

បំណុលទ្វេភាគីភាគច្រើនជាបំណុលចាស់ ដែលរាជរដ្ឋាភិបាលកម្ពុជាកំពុងចរចាឡើងវិញជាមួយឥណទាយកចំនួនពីរ គឺ៖ សហព័ន្ធរុស្ស៊ី និង សហរដ្ឋអាមេរិក ។ បំណុលទ្វេភាគីត្រូវបានចែកចេញជា៖

- បំណុលចាស់ ដែលភាគច្រើនកំពុងតែចរចា៖ បំណុលដែលជំពាក់មុនឆ្នាំ ១៩៧៥ ជារូបិយប័ណ្ណ និង បំណុលដែលខ្ចីនៅក្នុងអំឡុងទស្សវត្សទី ៨០ ជាលុយរូបដែលអាចប្តូរបាន (Convertible rouble) ។
- បំណុលទ្វេភាគីថ្មី ដែលកម្ពុជាខ្ចីក្រោយពេលចុះកិច្ចព្រមព្រៀងទីក្រុងប៉ារីស នៅក្នុងឆ្នាំ ១៩៩១ ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

### ៥.៣.១. ឥណទាយកនៃក្លឹបទីក្រុងប៉ារីស

បំណុលជារូបិយប័ណ្ណដែលខ្ចីមុនឆ្នាំ ១៩៧៥ ត្រូវបានរាជរដ្ឋាភិបាលកម្ពុជាសិក្សា និង ស្រង់ជាតារាងយ៉ាងម៉ត់ចត់នៅក្នុងឆ្នាំ ១៩៩៤ ។ ដោយសារតែឯកសារបំណុលទាំងនេះត្រូវបានបំផ្លាញ នៅពេលដែលស្រុកមានសង្គ្រាម ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុបានស្នើសុំអោយឥណទាយកធំៗផ្តល់នូវឯកសារ ដើម្បីបញ្ជាក់ពីបំណុលទាំងនេះ ។ ប្រទេសចំនួនប្រាំបានឆ្លើយតបទៅនឹងសំណើរនេះ មាន សហរដ្ឋអាមេរិក បារាំង អាឡឺម៉ាញ ជប៉ុន និង អ៊ីតាលី ។

នៅថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ១៩៩៤ រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជាបានផ្ញើលិខិតទៅប្រធានក្លឹទីក្រុងប៉ារីស ដើម្បីស្នើសុំការកាត់បន្ថយបំណុលរបស់កម្ពុជា ។ តំណាងនៃប្រទេសទាំងប្រាំខាងលើបានឆ្លើយតបទៅនឹងសំណើរនេះ និង បានកោះប្រជុំ នៅថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩៥ (តំណាងកម្ពុជាមិនបានចូលរួមប្រជុំទេ) ហើយបានសម្រេចថានឹងផ្តល់អនុសាសន៍ដល់ប្រទេសរបស់ខ្លួន ដើម្បីលុបចោលនូវបំណុលរបស់កម្ពុជា តាមរយៈការចរចាបំណុលឡើងវិញ ឬ តាមរយៈបុនហិរញ្ញប្បទាន តាមលក្ខខណ្ឌដូចតទៅ ÷

**ទីមួយ - ដែនអនុវត្តនៃការចរចាបំណុលឡើងវិញ:**

រាល់ការសងនូវដើមបំណុល ឬ ការប្រាក់នៃឥណទានពាណិជ្ជកម្ម ឬ ឥណទានរដ្ឋាភិបាល ដែលមានរយៈពេលជាងមួយឆ្នាំ ដែលផ្តល់ជូនរាជរដ្ឋាភិបាលកម្ពុជា ឬ ផ្នែកសាធារណៈកម្ពុជា ឬ ដែលត្រូវបានផ្តល់ការធានារបស់រដ្ឋ មុនថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៨៥ (កាលបរិច្ឆេទ បិទបញ្ជី- Cut off date) ÷

- បំណុលចំនួន ១០០ ភាគរយ ទាំងដើមបំណុល ទាំងការប្រាក់ មុនថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ ។

- បំណុលចំនួន ១០០ ភាគរយ ទាំងដើមបំណុល ទាំងការប្រាក់ ដែលត្រូវសងពីថ្ងៃទី ១ ខែ មករា ឆ្នាំ ១៩៩៥ ដល់ ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩៧ ។

ដូច្នេះ ផែនអនុវត្តនៃការចរចាបំណុលឡើងវិញនេះគ្របដណ្តប់នូវបំណុលទ្វេភាគីជារូបិយប័ណ្ណទាំងអស់របស់កម្ពុជា លើកលែងតែបំណុលដែលពាក់ព័ន្ធនឹងឥណទានបីនៃសហរដ្ឋអាមេរិក ។

**ទីពីរ - លក្ខខណ្ឌនៃការចរចាបំណុលឡើងវិញ:**

- **បំណុលពាណិជ្ជកម្ម** (ឥណទាយកពាក់ព័ន្ធ គឺ បារាំង និង អាឡឺម៉ាញ) ចំនួន ៦៧% ត្រូវបានលុបចោល និង ៣៣% ទៀតត្រូវសងក្នុងរយៈពេល ៨៦ ឆមាស (២៣ ឆ្នាំ) ដោយមានរយៈពេលអនុគ្រោះចំនួន ៦ ឆ្នាំ និង អនុលោមតាមតារាងសងបំណុលដែលមានអត្រាកើនឡើង ពី ០,១២% នៃដើម សម្រាប់កាលបរិច្ឆេទទីមួយ និង ៧,៩៦% នៃដើម សម្រាប់កាលបរិច្ឆេទចុងក្រោយ ។ អត្រាការប្រាក់លើទឹកប្រាក់ដែលចរចាឡើងវិញនឹងត្រូវចរចា


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ជាទ្វេភាគី ដោយឈរលើមូលដ្ឋាននៃអត្រាទីផ្សារ ។

- កម្ពុជា «**ជំនួយសាធារណៈដើម្បីអភិវឌ្ឍន៍**» (ឥណទាយកៈ សហរដ្ឋអាមេរិក បារាំង អាឡឺម៉ាញ និង ជប៉ុន) ។ រយៈពេលសងសេវាបំណុលនៃបំណុលទាំងអស់ស្មើនឹង ៨០ ឆមាស (៤០ ឆ្នាំ) ដោយមានរយៈពេលអនុគ្រោះ ១៦ ឆ្នាំ និង អនុលោមតាមតារាងសងបំណុលដែលមានអត្រាកើនឡើង ពី ០,៥៣%នៃដើម សម្រាប់កាលបរិច្ឆេទទីមួយ និង ៥,២៦%នៃដើម សម្រាប់កាលបរិច្ឆេទចុងក្រោយ ។ អត្រាការប្រាក់លើទឹកប្រាក់ដែលចរចាឡើងវិញនឹងត្រូវចរចា ជាទ្វេភាគី ក៏ប៉ុន្តែ យ៉ាងហោចណាស់ត្រូវតែមានលក្ខណៈអំណោយផល ដូចអត្រាការប្រាក់សម្បទានផងដែរ ។

លក្ខខណ្ឌនៃការចរចាបំណុលឡើងវិញនេះគឺជាការអនុវត្តលើកទី ១ នូវ**លក្ខខណ្ឌណាពើល** (Naples Terms) ដែលប្រមុខរដ្ឋនៃប្រទេសឧស្សាហកម្មចម្រើនជឿនលឿន បានអនុម័តទៅទីក្រុង **ណាពើល** នៅក្នុងឆ្នាំ ១៩៩៤ ដើម្បីលប់បំណុលប្រទេសកំពុងអភិវឌ្ឍ ហើយនៅពេលនោះត្រូវបានគេចាត់ទុកថា ជាលក្ខខណ្ឌលុបចោលបំណុលដែលអនុគ្រោះជាងគេ ។

**ក្លឹបទីក្រុងប៉ារីស** បានកំណត់នូវ **កាលបរិច្ឆេទបិទបញ្ចី** ដើម្បីធានាអោយបាននូវការធានាការសងបំណុល នៅថ្ងៃអនាគត ។ សម្រាប់កម្ពុជា **កាលបរិច្ឆេទបិទបញ្ជី** នេះត្រូវបានកំណត់យក ខែ ធ្នូ ឆ្នាំ ១៩៨៥ ។

បន្ទាប់ពីរដ្ឋាភិបាលទទួលយកនូវសំណើររបស់ឥណទាយកនៃក្លឹបទីក្រុងប៉ារីស ការចរចាទ្វេភាគីអាចចាប់ផ្តើមជាមួយប្រទេសឥណទាយកបាន ។

### ៥.៣.១.១. បារាំង

បំណុលសាធារណៈដែលកម្ពុជាជំពាក់បារាំងមានប្រភពមកពីបារាំងបានផ្តល់ហិរញ្ញប្បទាន ដើម្បីសាងសង់នូវគម្រោងហេដ្ឋារចនាសម្ព័ន្ធនៅក្នុងអំឡុងទស្សវត្សទី ៦០ ដូចជាការសាងសង់កំពង់ផែក្រុងព្រះសីហនុ ផ្លូវដែកពីភ្នំពេញទៅខេត្តព្រះសីហនុ និង ឧបករណ៍បំពាក់ផ្លូវដែកនោះ ការសាងសង់រោងចក្រចម្រាញ់ប្រេងកាតនៅខេត្តព្រះសីហនុ និង ការសាងសង់ទំនប់ព្រែកត្នោត ។ល។

ចាប់តាំងពីឆ្នាំ ១៩៧៥ មកដល់ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ ដែលជាកាលបរិច្ឆេទចុងក្រោយដែលកំណត់ដោយក្លឹបទីក្រុងបារីស កម្ពុជាមិនបានទូទាត់បំណុលឡើយ ទាំងឥណទានអ្នកទិញ ទាំងឥណទានរដ្ឋាភិបាលបារាំង ដោយរួមទាំងកិច្ចព្រមព្រៀងចំនួន ៣ ដើម្បីចរចាបំណុលឡើងវិញ ។ បំណុលទាំងអស់ដែលត្រូវចរចាឡើងវិញ សុទ្ធសឹងតែជាបំណុលដែលមិនបានសងទាំងអស់ ។


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

បន្ទាប់ពីគណប្រតិភូកម្ពុជាដែលបានទៅបំពេញបេកសកម្មនៅប្រទេសបារាំង បានពិនិត្យឯកសារដើមយ៉ាងល្អិតល្អន់រួចមក ការចរចាបានចាប់ផ្ដើម និង ឈានដល់ការចុះហត្ថលេខាលើកិច្ចព្រមព្រៀងនៅថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៥ ។ ភាគីបារាំងក៏បានសម្រេចលប់ចោលនូវបំណុលពាណិជ្ជកម្មចំនួន ៦៧% ស្មើនឹង ១០៧ លានហ្វ្រង់ ប្រមាណជា ២១ លានដុល្លារ ។ ទឹកប្រាក់សរុបនៃបំណុលដែលកម្ពុជាជំពាក់បារាំងមានចំនួន ២១ លានដុល្លារ មកទល់នឹងចុងឆ្នាំ ២០០៦ នេះ ។

### ៥.៣.១.២. អាឡឺម៉ាញ

បំណុលដែលកម្ពុជាជំពាក់អតីត **សហព័ន្ធអាឡឺម៉ង់** (អាឡឺម៉ាញខាងលិច) ត្រូវបានលុបចោលទាំងស្រុងក្នុងក្របខ័ណ្ឌនៃកិច្ចព្រមព្រៀងចុះថ្ងៃទី ៦ ខែ ឧសភា ឆ្នាំ ១៩៩៤ មុនកិច្ចប្រជុំនៃក្លឹបទីក្រុងប៉ារីស ។ បំណុលទាំងនេះកើតឡើងដោយធនាគារ **KfW** បានផ្ដល់ឥណទានចំនួន ២ ÷ ឥណទានទីមួយផ្ដល់ជូនធនាគារជាតិនៃកម្ពុជា និង ឥណទានទីពីរ ផ្ដល់ជូនព្រះរាជអាយស្ម័យានកម្ពុជា ដោយមានការធានារបស់រដ្ឋ ។

បំណុលដែលកម្ពុជាជំពាក់អតីតសាធារណរដ្ឋប្រជាធិបតេយ្យអាឡឺម៉ង់ ដែលជាឥណទានប្រភេទពាណិជ្ជកម្ម ត្រូវបានកាត់បន្ថយ និង ចរចាឡើងវិញ ក្នុងក្របខ័ណ្ឌនៃកិច្ចព្រមព្រៀងចុះថ្ងៃទី ៧ ខែ មិនា ឆ្នាំ ១៩៩៦ ដោយមានលក្ខខណ្ឌដូចតទៅ ÷

- ការផ្ទេរពីបំណុលជារូបប្លរបាន (Convertible rouble) ចំនួន ១៥,៩ លានរូប អោយទៅជាបំណុលជាម៉ាក អាឡឺម៉ង់ ចំនួន ១០៨ ម៉ាក តាមអត្រា ១ ម៉ាក = ០,៦៨ រូប ។
- ការលប់ចោលបំណុលចំនួន ៦៧% ។
- ការកំណត់បំណុលឡើងវិញ (Rescheduling) នៃចំនួន ៣៣% ដែលនៅសល់ ដោយអនុលោមតាលក្ខខណ្ឌនៃក្លឹបប៉ារីស ។
- អត្រាការប្រាក់ចំនួន ៤% ។

ទឹកប្រាក់សរុបនៃបំណុលដែលកម្ពុជាជំពាក់សាធារណៈរដ្ឋសហព័ន្ធអាឡឺម៉ាញ មានចំនួន ២១ លានដុល្លារ មកទល់នឹងចុងឆ្នាំ ២០០៦ នេះ ។

### ៥.៣.១.៣. ជប៉ុន

បំណុលដែលកម្ពុជាជំពាក់ជប៉ុនមានប្រភពមកពីការចុះកិច្ចព្រមព្រៀងកម្ចីពីរ លេខ **CP-1** ចុះថ្ងៃទី ៦ ខែ



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

តុលា ឆ្នាំ ១៩៦៩ និង **CP-2** ចុះថ្ងៃទី ១ ខែ កុម្ភៈ ឆ្នាំ ១៩៧១ ដោយ Overseas Economic Cooperation Fund (OECF) ដើម្បីធ្វើហិរញ្ញប្បទានសាងសង់គម្រោងទំនប់វារីអគ្គិសនី និង ទំនប់ធារាសាស្ត្រព្រែកត្នោត ។

ទឹកប្រាក់សរុបដែលកម្ពុជាជំពាក់ OECF គឺសុទ្ធសឹងតែជាបំណុលរ៉ាំរ៉ៃ៖

- បំណុលជាប្រាក់ដើម និង ជាការប្រាក់ ពីថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ១៩៧៥ ដល់ ថ្ងៃទី ២០ ខែ សីហា ឆ្នាំ ១៩៩០ ដែលជាកាលបរិច្ឆេទចុងក្រោយ ស្មើនឹងទឹកប្រាក់សរុបចំនួន ១.៦១២,៦ លានយ៉េន
- ការប្រាក់ទោសទំណួដោយសារការខកខានមិនបានសងបំណុលខាងលើមានចំនួន ៨០៣,៣ លានយ៉េន
- ដូច្នេះទឹកប្រាក់សរុបនៃបំណុលដែលកម្ពុជាជំពាក់ជប៉ុន មានចំនួន ២.៤១៥,៩ លានយ៉េន ដែលស្មើនឹង ២៤ លានដុល្លារ ។

បំណុលទាំងអស់ត្រូវបានដោះស្រាយរួចរាល់តាមរយៈកិច្ចព្រមព្រៀង ចំនួនពីរលើក នៅខែ មេសា និង ខែ ឧសភា ឆ្នាំ ១៩៩៦ ដែលមានទឹកប្រាក់សរុបចំនួន ១៥,២ លានយ៉េន ឬ ១.៦១២,៦ លានយ៉េន ។ ការទូទាត់នេះធ្វើឡើងតាមរយៈមូលនិធិថវិកាជាតិនៃព្រះរាជាណាចក្រកម្ពុជា ដែលធ្វើហិរញ្ញប្បទានដោយជំនួយឥតសំណងរបស់ប្រទេសជប៉ុន (ជំនួយជាទំនិញ) ។

ការប្រាក់ទោសទណ្ឌចំពោះការយឺតយ៉ាវមិនបានសងបំណុលចំនួន ៨០៣,៣ លានយ៉េន ត្រូវបានចរចាឡើងវិញ (Consolidation) និង ត្រូវបានកំណត់ឡើងវិញ (Rescheduling) ក្នុងក្របខ័ណ្ឌនៃកិច្ចព្រមព្រៀងខែ តុលា ឆ្នាំ ១៩៩៦ តាមលក្ខខណ្ឌដូចតទៅ៖

- រយៈពេលសងសេវាបំណុលចំនួន ១៥ ឆ្នាំ ដែលមានរយៈពេលអនុគ្រោះចំនួន ៧ ឆ្នាំ ។
- អត្រាការប្រាក់ ចំនួន ៣,៥%។

ទឹកប្រាក់សរុបនៃបំណុលទ្វេភាគីដែលកម្ពុជាជំពាក់ជប៉ុន ដែលសុទ្ធសឹងតែឥណទានផ្តល់ក្រោយកិច្ចព្រមព្រៀងទីក្រុងប៉ារីសឆ្នាំ ១៩៩១ មានចំនួន ៤៣ លានដុល្លារ មកទល់ នឹងចុងឆ្នាំ ២០០៦ នេះ ។

### ៥.៣.១.៤. អ៊ីតាលី

បំណុលដែលកម្ពុជាជំពាក់អ៊ីតាលីត្រូវបានដោះស្រាយក្នុងក្របខ័ណ្ឌនៃកិច្ចព្រមព្រៀងស្តីពីការកាត់បន្ថយ និង ការចរចាបំណុលឡើងវិញ តាមលក្ខខណ្ឌដូចតទៅ÷

- ការលុបចោលបំណុលចំនួន ៧០% ឬ ១,៥ លានដុល្លារ ។


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

- ការកំណត់បំណុលឡើងវិញនូវទឹកប្រាក់ដែលនៅសល់ចំនួន ៣០% ដោយប្រើអត្រាការប្រាក់ចំនួន ០% ។

ក្រោយពីបានកំណត់បំណុលឡើងវិញ បំណុលដែលកម្ពុជាជំពាក់អ៊ីតាលីទាំងអស់ស្មើនឹង ០,៥ លានដុល្លារ។

### ៥.៣.២. បំណុលជារូបម្លូរបាន

បំណុលជា **រូបម្លូរបាន** (Convertible rouble) គឺជាប្រភេទបំណុលដែលកើតមកពីឥណទាន ដែលអតីតសហភាពសូវៀត និង ប្រទេសប្លុកខាងកើតបានផ្តល់អោយកម្ពុជានៅក្នុងអំឡុងទស្សវត្សទី ៨០ ។ រាជរដ្ឋាភិបាលកម្ពុជាបាន និង កំពុងចរចាដោះស្រាយបំណុលដែលកម្ពុជាជំពាក់ប្រទេសនៃអតីតប្លុកលោកខាងកើត ។

#### ៥.៣.២.១. សាធារណៈរដ្ឋស្លូវ៉ាគី

បំណុលដែលបរទេសជំពាក់អតីតសាធារណរដ្ឋសង្គមនិយមឆេកូស្លូវ៉ាគីត្រូវបានបែងចែកជាពីរ៖ មួយភាគបីត្រូវបានបែងចែកអោយសាធារណរដ្ឋស្លូវ៉ាគី និង ពីរភាគបីត្រូវបានបែងចែកអោយសាធារណរដ្ឋឆែក ។ ទឹកប្រាក់សរុបនៃបំណុលដែលកម្ពុជាជំពាក់សាធារណរដ្ឋស្លូវ៉ាគីស្មើនឹង ២៦៨.២៥៩ ដុល្លារ ។

#### ៥.៣.២.២. សាធារណៈរដ្ឋឆែក

ទឹកប្រាក់សរុបនៃបំណុលដែលកម្ពុជាជំពាក់សាធារណរដ្ឋឆែកត្រូវបានចរចាឡើងវិញ ហើយស្មើនឹង ៧៦៦.៥១៨ ដុល្លារ ។

#### ៥.៣.២.៣. ប៉ូឡូញ

ទឹកប្រាក់សរុបនៃបំណុលដែលកម្ពុជាជំពាក់ប៉ូឡូញត្រូវបានចរចាឡើងវិញ ហើយស្មើនឹង ១.៩៥៥.៨១៩ រូប ឬ ១,៦ លានដុល្លារ តាមអត្រាប្តូរប្រាក់ ១ រូប = ០,៨ ដុល្លារ ។ ប្រទេសប៉ូឡូញបានសម្រេចបង្វែរបំណុលនេះអោយទៅជាជំនួយដើម្បីជួសជុលព្រះបរមរាជវាំង ។ រដ្ឋាភិបាលទាំងពីរបានចុះកិច្ចព្រមព្រៀងដើម្បីប្រគល់ការងារអោយក្រុមហ៊ុនប៉ូឡូញមួយបំពេញការងារជួសជុលព្រះបរមរាជវាំង ។

### ៥.៣.៣. បំណុលកំពុងចរចា

#### ៥.៣.៣.១. សហព័ន្ធរុស្សី

បំណុលដែលកម្ពុជាជំពាក់រុស្ស៊ីមានប្រភពមកពីកិច្ចព្រមព្រៀងផ្តល់ឥណទានចំនួន ១៥ ដែលកម្ពុជាបានចុះជាមួយអតីតសហភាពសូវៀតចាប់តាំងពីឆ្នាំ ១៩៨០ ដល់ ឆ្នាំ ១៩៩០ ដែលត្រូវបានចរចាឡើងវិញក្នុងក្របខ័ណ្ឌនៃកិច្ចព្រមព្រៀងចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ១៩៩១ រវាងធនាគារពាណិជ្ជកម្មក្រៅប្រទេសនៃសហភាពសូវៀត និងធនាគារពាណិជ្ជកម្មក្រៅប្រទេសកម្ពុជា ។ លក្ខខណ្ឌនៃការចរចាឡើងវិញមានដូចតទៅ ÷

- ការទូទាត់ក្រោមរូបភាពជាការផ្គត់ផ្គង់ទំនិញ តាមការព្រមព្រៀងរវាងភាគីទាំងពីរ ។ កម្ពុជាអាចជ្រើសរើសយកការទូទាត់ផ្សេងទៀត តាមការព្រមព្រៀងរវាងភាគីទាំងពីរ ។
- រយៈពេលសងសេវាបំណុលមានចំនួន ២០ ឆ្នាំ ÷

  - ឆ្នាំ ១៩៩១ ចំនួន ៦២ លានរូប

  - ឆ្នាំ ១៩៩២ ចំនួន ៦៦ លានរូប

  - ពីឆ្នាំ ១៩៩៣ ដល់ ឆ្នាំ ២០០០ ចំនួន ៦៥ លានរូប

  - ពីឆ្នាំ ២០០០ ដល់ ឆ្នាំ ២០១១ ចំនួនពី ១៦ ដល់ ៤ លានរូប

- កិច្ចព្រមព្រៀងបានកំណត់ថាកាលបរិច្ឆេទឆ្នាំ ១៩៩១ អាចនឹងត្រូវចរចាឡើងវិញតាមការព្រមព្រៀងរវាងភាគីទាំងពីរ ។
- កម្ចីនេះគ្មានការប្រាក់ឡើយ ។

ក្រៅពីបំណុលដែលចរចាឡើងវិញនៅក្នុងឆ្នាំ ១៩៩១ រុស្ស៊ីបានផ្តល់ឥណទានពីរទៀតអោយកម្ពុជា៖

- បំណុលដែលមានប្រភពពីឥណទានក្នុងក្របខ័ណ្ឌនៃកិច្ចព្រមព្រៀងស្តីពីការអភិវឌ្ឍកិច្ចសហប្រតិបត្តិការក្នុងវិស័យផលិតផលកៅស៊ូធម្មជាតិ ចុះថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ១៩៨៣ ។
- ការប្រាក់ជំពាក់នៅក្នុងក្របខ័ណ្ឌនៃកិច្ចព្រមព្រៀងចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ១៩៨៥ ។ បំណុលនេះត្រូវបានចរចាឡើងវិញរហូតដល់ឆ្នាំ ១៩៩១ ហើយត្រូវសងវិញជាការផ្គត់ផ្គង់កៅស៊ូធម្មជាតិ ។

កម្ពុជា និង រុស្ស៊ីបានព្រមព្រៀងគ្នាថា ទឹកប្រាក់សរុបនៃបំណុលចរចាឡើងវិញស្មើនឹង ៩១៤,៧ លានរូប ។ បំណុលនេះត្រូវបានភាគីទាំងពីលើកយកមកពិភាក្សា ក្នុងគោលដៅកាត់បន្ថយ និង កំណត់ឡើងវិញ ដោយអនុលោមតាម **លក្ខខណ្ឌណាភើល** (Naples Terms) នៃក្លឹបប៉ារីស ដែលមានលក្ខខណ្ឌដូចតទៅ៖



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ទីមួយ- គណនាឡើងវិញនូវបំណុលជាប្រាក់រូប ដែលមានទឹកប្រាក់សរុបចំនួន ៩១៤,៧ លានរូប អោយទៅជាបំណុលជាប្រាក់ដុល្លារ ដែលមានទឹកប្រាក់សរុបចំនួន ១.៥២៥ លានដុល្លារ (តាមអត្រាប្តូរប្រាក់ ១ ដុល្លារ = ០,៨១២៩ រូប) ។ បន្ទាប់មក បំណុលជាប្រាក់ដុល្លារចំនួន ៧០%នឹងត្រូវបានលុបចោល ហើយទឹកប្រាក់បំណុលដែលនៅសល់មានចំនួន ៤៥៧ លានដុល្លារ ។

ទីពីរ- ដោយអនុលោមតាមសៀវភៅបន្ទុកនៃក្លឹបប៉ារីស ទឹកប្រាក់បំណុលដែលនៅសល់ចំនួន ៤៥៧ លានដុល្លារនឹងត្រូវបែងចែកជាពីរផ្នែក ÷ ផ្នែកទីមួយ គឺជាឥណទានដែលផ្តល់មុន **កាលបរិច្ឆេទបិទបញ្ជី** និង ផ្នែកទីពីរ គឺ ឥណទានដែលផ្តល់ក្រោយ **កាលបរិច្ឆេទបិទបញ្ជី** (Post cut off date)។

ទីបី- ឥណទានដែលផ្តល់មុន **កាលបរិច្ឆេទបិទបញ្ជី** នឹងត្រូវបានកំណត់ឡើងវិញតាមលក្ខខណ្ឌសម្បទានដូចតទៅ÷ អត្រាការប្រាក់ ០,៨១២៩% **រយៈពេលសងសេវាបំណុល** ៣៣ ឆ្នាំ ដោយគ្មាន រយៈពេលអនុគ្រោះ ។

ទីបួន- ឥណទានដែលផ្តល់ក្រោយ **កាលបរិច្ឆេទបិទបញ្ជី** នឹងត្រូវចរចាជាទ្វេភាគីក្រៅក្របខ័ណ្ឌនៃក្លឹបប៉ារីស ដែលផ្តល់លទ្ធភាពអោយកម្ពុជាអាចចរចាជាមួយសហព័ន្ធរុស្ស៊ី ដើម្បីទទួលបាននូវលក្ខខណ្ឌកំណត់បំណុលឡើងវិញដែលមានភាពអនុគ្រោះ ។

**លក្ខខណ្ឌណាភើលនៃក្លឹបប៉ារីស**

នៅក្នុងខែធ្នូ ឆ្នាំ ១៩៩៤ ដោយប្រឈមមុខនឹងវិបត្តិបំណុលដែលកាន់តែរាលដាលខ្លាំងឡើង ប្រទេសឥណទាយកបានព្រមព្រៀងគ្នាយ៉ាងប្រញាប់ប្រញាល់ ដើម្បីអនុម័តនូវ **លក្ខខណ្ឌណាភើល** (Naples Terms) ។ ប្រទេសដែលអាចទទួលនូវ **លក្ខខណ្ឌណាភើល** នេះបានទាល់តែជាប្រទេសដែលសមស្របទៅនឹងលក្ខណៈវិនិច្ឆ័យ ក្នុងការទទួលយកហិរញ្ញប្បទានសម្បទានពីធនាគារពិភពលោក និង ត្រូវមានប្រាក់ចំណូលទាប (ចំណូលក្នុងប្រជាជនម្នាក់ តិចជាង ៧៥៥ ដុល្លារ) ។ ប្រសិនបើប្រទេសនោះអាចបំពេញតាមលក្ខណៈវិនិច្ឆ័យនេះហើយ នោះឥណទានដែលមិនមានជា **ជំនួយផ្លូវការដើម្បីអភិវឌ្ឍន៍** នឹងត្រូវលុបចោលក្នុងកម្រិតពី ៥០% ទៅ ៦៧% (ជាធម្មតាការលុបចោលស្មើនឹង ៦៧%ចាប់តាំងពីខែ កញ្ញា ឆ្នាំ ១៩៩៩ មកម្លេះ) ។ ចំពោះ ឥណទានដែលជា **ជំនួយផ្លូវការដើម្បីអភិវឌ្ឍន៍** នឹងត្រូវកំណត់ឡើងវិញដោយមានរយៈពេលសងសេវាបំណុលចំនួន ៤០ ឆ្នាំ និង រយៈពេលអនុគ្រោះចំនួន ១៦ ឆ្នាំ ។

ក៏ប៉ុន្តែ កម្ពុជា និង រុស្ស៊ីនៅមិនទាន់ព្រមព្រៀងគ្នាលើចំណុចសំខាន់ដូចខាងក្រោម÷

- លក្ខខណ្ឌនៃការកំណត់បំណុលឡើងវិញចំពោះឥណទានដែលផ្តល់ក្រោយ **កាលបរិច្ឆេទបិទបញ្ជី** ជាពិសេស **រយៈពេលសងសេវាបំណុល** រយៈពេលអនុគ្រោះ និង អត្រាការប្រាក់ ។ រាជរដ្ឋាភិបាលកម្ពុជាចង់បាននូវ


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

អត្រាការប្រាក់ទាប រយៈពេលសងសេវាបំណុលវែង និង មានរយៈពេលអនុគ្រោះ ដើម្បីកាត់បន្ថយនូវ «តម្លៃបច្ចុប្បន្នសុទ្ធ» (Net Present Value) នៃបំណុល ។

- ការចុះបំណុលចំនួន ៤០ លានដុល្លារ ដែលភាគីកម្ពុជាយល់ឃើញថា ជាឥណទានមុន **កាលបរិច្ឆេទបិទបញ្ជី** ដែលត្រូវអនុវត្តតាមលក្ខខណ្ឌអនុគ្រោះ ។

### ៥.៣.៣.២. សហរដ្ឋអាមេរិក

បំណុលដែលព្រះរាជាណាចក្រកម្ពុជាជំពាក់សហរដ្ឋអាមេរិក មានដើមកំណើតមកពីកិច្ចព្រមព្រៀងស្តីពីកម្ចីចំនួន ៣ ដើម្បីទិញកសិផលពីសហរដ្ឋអាមេរិក (កប្បាស ថ្នាំជក់ អង្ករ ប្រេងឆា និង ស្រូវសាឡី) នៅក្នុងឆ្នាំ ១៩៧២ ក្នុងឆ្នាំ ១៩៧៣ និង ក្នុងឆ្នាំ ១៩៧៤ ។ តាមប្រភពនៃក្រសួងកសិកម្មរបស់សហរដ្ឋអាមេរិកបានអោយដឹងថា សហរដ្ឋអាមេរិកបានបញ្ចេញថវិកាចំនួន ២៧៧ លានដុល្លារនៃទឹកប្រាក់តាមកិច្ចព្រមព្រៀងចំនួន ៣២២ លានដុល្លារ ។

ដោយអនុលោមតាមលក្ខខណ្ឌនៃកម្ចី រដ្ឋាភិបាលកម្ពុជាត្រូវយកប្រាក់ចំណូលបានមកពីការលក់ផលិតផលទាំងនោះ ដើម្បីយកទៅកែលម្អផលិតកម្ម ការរក្សាទុក និង ការលក់កសិផលនៅកម្ពុជា ។ លក្ខខណ្ឌនៃឥណទាននេះមានលក្ខណៈសម្បទាន ÷

- អត្រាការប្រាក់ចំនួន ២% ក្នុងរយៈពេលអនុគ្រោះ និង ៣% នៅពេលបន្ទាប់ ។
- រយៈពេលសងសេវាបំណុលចំនួន ៣១ ឆ្នាំ ក្រោយពីរយៈពេលអនុគ្រោះចំនួន ១០ ឆ្នាំ ។

កម្ពុជាមិនបានសងបំណុលនេះ ទាំងការប្រាក់ ទាំងប្រាក់ដើម ចាប់តាំងពីឆ្នាំ ១៩៧៥ មកម្ល៉េះ ។ ដោយសារតែគ្មានឯកសារជាភស្តុតាង ដើម្បីកំណត់ចំនួនទឹកប្រាក់បំណុលសរុប រដ្ឋាភិបាលនៃប្រទេសទាំងពីរបានឯកភាពគ្នាកំណត់ដើមបំណុលចំនួន ១៦២ លានដុល្លារ ។ ដោយបូកនឹងការប្រាក់ផង បំណុលដែលកម្ពុជាជំពាក់សហរដ្ឋអាមេរិកប្រហែលអាចស្មើនឹង ២៩២ ទៅ ៣០០ លានដុល្លារ ។ កម្ពុជានៅមិនទាន់បានព្រមព្រៀងជាមួយសហរដ្ឋអាមេរិក នូវចំនួនទឹកប្រាក់សរុបនៃបំណុល និង អត្រាការប្រាក់នៅឡើយទេ ។

## ៥.៤. បំណុលទ្វេភាគីថ្មីដែលផ្តល់ក្រោយឆ្នាំ ១៩៩៣

ចាប់តាំងពីឆ្នាំ ១៩៩៣ មក រាជរដ្ឋាភិបាលកម្ពុជាបានចុះហត្ថលេខាស្តីពីកម្ចីទ្វេភាគីជាមួយប្រទេសមួយចំនួន ដូចជា ចិន ម៉ាឡេស៊ី សាធារណៈរដ្ឋកូរ៉េ ឥណ្ឌា ថៃឡង់ វៀតណាម និង មូលនិធិអភិវឌ្ឍន៍ណ័រឌីក ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

### ៥.៤.១. ចិន

ចិនបានលុបចោលនូវបំណុលដែលកម្ពុជាខ្ចី មុនឆ្នាំ ១៩៩១ ដែលមានទឹកប្រាក់សរុបចំនួន ៥៨ លានដុល្លារ ។ ចំនួនទឹកប្រាក់នៃបំណុលសរុបដែលកម្ពុជាជំពាក់ចិនមានចំនួន ១០២ លានដុល្លារ នៅចុងឆ្នាំ ២០០៦ ។

### ៥.៤.២. ម៉ាឡេស៊ី

ម៉ាឡេស៊ីបានផ្តល់ឥណទាន នៅថ្ងៃទី ២១ ខែ សីហា ឆ្នាំ ១៩៩៥ ចំនួន ៣៥ លាន រីងហ្គីត (ប្រមាណជា ១៤ លានដុល្លារ) តាមរយៈធនាគារនីហារ៍ណ អាហារ៍ណ ម៉ាឡេស៊ី ដើម្បីស្តារ និង កសាងឡើងវិញនូវអង្គភាពនៃកងនាវាចរណ៍នៃកងយោធពលខេមរភូមិន្ទ ។ រយៈពេលសងសេវាបំណុលមានចំនួន ១០ ឆ្នាំ រយៈពេលអនុគ្រោះ ៥ ឆ្នាំ និង អត្រាការប្រាក់ចំនួន ៣% ។

## ៦. សមត្ថភាពសងបំណុលរបស់កម្ពុជា

នៅក្នុងប្រទេសកំពុងអភិវឌ្ឍ ការអនុវត្តនូវតុល្យភាពរវាងសញ្ច័យ និង វិនិយោគអាចសម្រេចបានយ៉ាងកម្រណាស់ ដោយសារតែកង្វះខាតនូវសញ្ច័យ ។ ទន្ទឹមនឹងនេះ ប្រទេសកំពុងអភិវឌ្ឍត្រូវការនូវទំហំវិនិយោគយ៉ាងច្រើន ។ ឱនភាពថវិកា ដែលជាផលដករវាងចំណូល និង ចំណាយ ដាក់សម្ពាធលើសមត្ថភាពវិនិយោគរបស់រាជរដ្ឋាភិបាល ។ ឱនភាពនេះអាចធ្វើហិរញ្ញប្បទានបានបួនយ៉ាង ÷

- ការបោះផ្សាយក្រដាសប្រាក់ ដែលនាំអោយមានអតិផរណា ។
- ការបង្កើនសញ្ច័យក្នុងស្រុក (គ្រួសារ និង សហគ្រាស) ក៏ប៉ុន្តែ សមត្ថភាពសញ្ច័យនៅទាប នៅក្នុងប្រទេសកំពុងអភិវឌ្ឍ ។
- ហិរញ្ញប្បទានពីក្រៅប្រទេស ក្រោមរូបភាពជាជំនួយឥតសំណង តែនៅមានកម្រិត ។
- កម្ចីក្រៅប្រទេស ។

ការបង្កើនបំណុលក្រៅប្រទេស គឺជាសមាសធាតុយ៉ាងសំខាន់នៃគោលនយោបាយអភិវឌ្ឍ ដែលអនុញ្ញាតអោយរដ្ឋទិញនូវទំនិញ និង សេវាពីក្រៅប្រទេស ទោះបីជាទុនបម្រុងអន្តរជាតិជារូបិយប័ណ្ណបរទេសរបស់ប្រទេសនៅមានកម្រិតនៅឡើយ ។ ក៏ប៉ុន្តែ ឥណទាយកតែងតែចង់គ្រប់គ្រងអោយបាននូវហានិភ័យ ដោយវាយតម្លៃយ៉ាងម៉ត់ចត់នូវស្ថានភាពរបស់ឥណាយិក ។ ការវាយតម្លៃនូវសមត្ថភាពរបស់ឥណាយិក ក្នុងការសងបំណុល គឺជាកត្តា កំណត់ក្នុងការសម្រេចចិត្តអោយខ្ចី ។


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ដើម្បីវាយតម្លៃពីសមត្ថភាពរបស់ប្រទេសក្នុងការខ្ចីឥណទាន សេដ្ឋវិទូបានបង្កើតឡើងនូវអនុបាទ ឬសូចនាករជាច្រើន ។ អនុបាទដែលត្រូវបានប្រើប្រាស់ជាអន្តរជាតិទាំងនេះអនុញ្ញាតអោយយើងប្រៀបធៀបស្ថានភាពនៃប្រទេសផ្សេងៗ ។

## ៦.១. បំណុលចែកនឹងផលិតផលសរុបក្នុងស្រុក

អនុបាទនេះមានគោលដៅបញ្ជាក់ពីសមត្ថភាពក្នុងការសង ទោះបីជាយើងមិនឃើញពីទំនាក់ទំនងដោយផ្ទាល់រវាងសមត្ថភាពក្នុងការសង និង បំណុលចែកនឹងផលិតផលសរុបក្នុងស្រុក (ផសស) ក៏ដោយ ។ ចំពោះប្រទេសកម្ពុជា ទឹកប្រាក់បំណុលសរុបនៃផ្នែកសាធារណៈថយចុះពី ៣៣%នៃផសស នៅចុងឆ្នាំ ២០០៦ មកនៅត្រឹម ៣០%នៃផសស នៅចុងឆ្នាំ ២០០៧ ។ «តម្លៃបច្ចុប្បន្នសុទ្ធ» (Net Present Value) នៃបំណុលផ្នែកសាធារណៈបានធ្លាក់ចុះពី ២៣%នៃផសស នៅក្នុងឆ្នាំ ២០០៧ មកនៅត្រឹម ៨%នៃផសស នៅក្នុងឆ្នាំ ២០២៦ ដែលឆ្លុះបញ្ចាំងពីភាពសម្បទាននៃបំណុលនាពេលបច្ចុប្បន្ន ។




## ៦.២. បំណុលចែកនឹងការនាំចេញនៃទំនិញ និង សេវា

អនុបាទ «បំណុល/ការនាំចេញនៃទំនិញ និង សេវា» គឺជារង្វាស់នៃសមត្ថភាពសងបំណុលរបស់ប្រទេសដោយយកសន្និទ្ធិបំណុល (បំណុលសរុប) មកចែកនឹងលំហូរ (ការនាំចេញ) ។ តម្លៃបច្ចុប្បន្នសុទ្ធនៃបំណុល/ការនាំចេញនៃទំនិញ និង សេវា- ស្មើនឹង ៣៤% ក្នុងឆ្នាំ ២០០៧- ស្ថិតនៅក្រោមសូចនាករគោលចំនួន ១០០% នៅឡើយ ។ ក៏ប៉ុន្តែ សមត្ថភាពសងបំណុលប្រកបដោយចីរភាពរបស់កម្ពុជាងាយនឹងរងគ្រោះ នៅពេលមានវិបត្តិ



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ពីក្រៅប្រទេស ។ ការធ្លាក់ចុះនៃកំណើនការនាំចេញអាចនាំអោយ «តម្លៃបច្ចុប្បន្នសុទ្ធ» នៃអនុបាទ បំណុល/ផសស កើនឡើងយ៉ាងខ្លាំង ។




## ៦.៣. សេវាបំណុលធៀបនឹងការនាំចេញទំនិញ និង សេវា

អនុបាទសេវាបំណុលធៀបនឹងការនាំចេញវាស់សមត្ថភាពរបស់ប្រទេស ក្នុងការស្វែងរកថវិកាបំណុលដើម្បីទូទាត់បំណុល ។ សេវាបំណុលស្ថិតនៅក្នុងកម្រិត ១%នៃការនាំចេញនៃទំនិញ និង សេវា ។






fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

## ៦.៤. សេទាអត្រាការប្រាក់/បំណុល

អនុបាទនេះអនុញ្ញាតអោយយើងវាយតម្លៃពីកម្រិតនៃសម្បទានរបស់បំណុល ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ជំពូកទី ១២

## ការវិនិយោគសាធារណៈ

ចំណាយមូលធនសម្រាប់វិនិយោគសាធារណៈបានកើនឡើងពី ៥,៥%នៃផសស ក្នុងឆ្នាំ ១៩៩៤ ដល់ ៦,១%នៃផសស ក្នុងឆ្នាំ ២០០៨ ដែលស្មើនឹង ១.៧៨៥ ពាន់លានរៀល ឬ ៥,៧៣%នៃផសស ដែលមានចំនួន ៣១.១៣៧ ពាន់លានរៀល ក្នុងឆ្នាំ ២០០៧ ពោលសម្រេចបានកំណើនចំនួន ៦,៥% តាមថ្លៃថេរ ។ គិតជាភាគរយនៃចំណាយសរុប ចំណាយមូលធនកើនឡើងពី ៣៣,៦%នៃចំណាយថវិកាសរុប នៅក្នុងឆ្នាំ ១៩៩៤ ដល់ ៣៧,៦%នៃចំណាយថវិកាសរុប នៅក្នុងឆ្នាំ ២០០៥ និងដល់ ៣៨,៦២%នៃចំណាយថវិកាសរុប នៅក្នុងឆ្នាំ ២០០៧ ។ ដូច្នេះ បន្តិចម្តងៗ ចំណាយវិនិយោគសាធារណៈបានក្លាយទៅជាសមាសភាគមួយយ៉ាងសំខាន់នៃចំណាយថវិកាជាពិសេសក្នុងការបង្កើនកំណើនសេដ្ឋកិច្ច និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ថ្វីត្បិតតែនៅក្នុងពេលបច្ចុប្បន្ន និង នៅពេលខាងមុខតទៅទៀត ធនធានថវិកាក្នុងស្រុកសម្រាប់ហិរញ្ញប្បទាននៃការវិនិយោគសាធារណៈ នៅមានសមាមាត្រទាបនៅឡើយ បើប្រៀបធៀបនឹងហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍អន្តរជាតិក្រោមរូបភាពជាជំនួយជាគម្រោង ។ **ជំនួយជាគម្រោង** មានសមាមាត្រស្មើនឹង ៧៧%នៃចំណាយវិនិយោគនៃថវិកាឆ្នាំ ១៩៩៤ ហើយថយចុះមកនៅត្រឹម ៧៣% នៅក្នុងឆ្នាំ ២០០៥ តែកើនដល់ ៨០% វិញនៅក្នុងឆ្នាំ ២០០៧ ។

### ១. ហិរញ្ញប្បទានក្រៅប្រទេសដោយផ្ទាល់

ការបញ្ចូលនៅក្នុងថវិកាជាតិនៃព្រះរាជាណាចក្រកម្ពុជា នូវវិនិយោគសាធារណៈដោយហិរញ្ញប្បទានដោយផ្ទាល់ពីក្រៅប្រទេស ធ្វើឡើងដោយកត់ត្រានៅក្នុងថវិកាជាតិ នូវការព្យាករណ៍នៃទឹកប្រាក់សរុបនៃហិរញ្ញ-ប្បទានដោយផ្ទាល់ពីក្រៅប្រទេស ។ ការព្យាករណ៍នេះមិនមែនជាឥណទានថវិកា ដែលត្រូវអនុវត្តតាមនីតិវិធីចំណាយតាមច្បាប់ជាធរមានឡើយ ។ ការកត់ត្រានូវវិនិយោគសាធារណៈដោយហិរញ្ញប្បទានដោយផ្ទាល់ពីក្រៅប្រទេសមិនទាមទារអោយមានទិដ្ឋាការពីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុឡើយ ដោយសារទឹកប្រាក់នេះគ្រាន់តែជាការព្យាករណ៍នៃចំណាយដែលអាចនឹងត្រូវអនុវត្ត តាមប្រភពនៃហិរញ្ញប្បទានក្រៅប្រទេសនៅក្នុងឆ្នាំថវិកាតែប៉ុណ្ណោះ ។

ដៃគូអភិវឌ្ឍន៍ផ្តល់ការសន្យាប្រចាំឆ្នាំនូវជំនួយផ្លូវការដើម្បីអភិវឌ្ឍន៍ នៅក្នុងឱកាស **វេទិកាអភិវឌ្ឍន៍កម្ពុជា** ដែលជាវេទិកាផ្លាស់ប្តូរយោបល់រវាងរាជរដ្ឋាភិបាលកម្ពុជា និង ដៃគូអភិវឌ្ឍន៍លើគោលនយោបាយ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

សំខាន់ៗនៃ **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ** ។ បន្ទាប់មកដៃគូអភិវឌ្ឍន៍មួយចំនួនធ្វើការពិគោះយោបល់ជាមួយរាជរដ្ឋាភិបាលកម្ពុជា ពីគោលនយោបាយតាមវិស័យ និង បែងចែកការផ្តល់ហិរញ្ញប្បទានអភិវឌ្ឍន៍តាមវិស័យ ដែលខ្លួនមានឧត្តមភាពប្រៀបធៀប ។ ដៃគូអភិវឌ្ឍន៍ចុះហត្ថលេខាជាមួយរាជរដ្ឋាភិបាលលើអនុស្សារណៈស្តីពីការផ្តល់ហិរញ្ញប្បទាន ។ ដោយឈរលើមូលដ្ឋាននៃទិន្នន័យខាងលើនេះ ក៏ដូចជាការអនុវត្តនូវគម្រោងនៅក្នុងឆ្នាំកន្លងទៅ យើងធ្វើការប៉ាន់ស្មាននូវជំនួយជាគម្រោងតាមវិធីដូតទៅ៖

ទីមួយ- គម្រោងដែលធ្វើហិរញ្ញប្បទានដោយ **ធនាគារអភិវឌ្ឍន៍អាស៊ី** និង **ធនាគារពិភពលោក** ។ ថ្វីត្បិតតែគម្រោងទាំងនេះអនុវត្តក្រៅប្រព័ន្ធរតនាគារ នាយកដ្ឋានវិនិយោគ និង សហប្រតិបត្តិការអន្តរជាតិនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុជាស្ថាប័នគ្រប់គ្រងគម្រោងទាំងនេះផ្ទាល់ រួមគ្នាជាមួយនឹង **ធនាគារអភិវឌ្ឍន៍អាស៊ី** និង **ធនាគារពិភពលោក** ។ ហើយគណនីគម្រោងត្រូវបានបើកនៅធនាគារជាតិនៃកម្ពុជា និង ធនាគារពាណិជ្ជដើម្បីអនុវត្តគម្រោងទាំងនេះ ។ ការព្យាករណ៍ចំណាយចរិកាក្នុងក្របខ័ណ្ឌគម្រោងដែលធ្វើហិរញ្ញប្បទានដោយ **ធនាគារអភិវឌ្ឍន៍អាស៊ី** និង **ធនាគារពិភពលោក** មានលក្ខណៈសុក្រឹត ដោយឈរលើមូលដ្ឋាននៃកិច្ចព្រមព្រៀងដែលបានចុះរួចហើយ ឬ ដែលបានគ្រោងទុកជាមុន ។

ទីពីរ- គម្រោងដែលធ្វើហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍ដ៏ទៃទៀត អង្គការអន្តរជាតិ និង អង្គការក្រៅ-រដ្ឋាភិបាល ។ ដោយសារតែគម្រោងទាំងនេះមានទាំងចំណាយចរន្ត (ចំណាយដំណើរការគម្រោង ប្រាក់បៀវត្ស) និង ចំណាយមូលធន ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបញ្ចូលក្នុងចំណាយវិនិយោគដែលធ្វើហិរញ្ញប្បទានពីក្រៅប្រទេស តែជំនួយបច្ចេកទេសដែលពាក់ព័ន្ធនឹងវិនិយោគ (ឧទាហរណ៍ ការសិក្សាលើកគម្រោង) និង ចំណាយវិនិយោគតែប៉ុណ្ណោះ ។ ប្រាក់បៀវត្ស ចំណាយដំណើរការ ចំណាយលើការផ្តល់សៀង ការផ្សព្វផ្សាយបច្ចេកទេសកសិកម្ម ។ល។ មិនត្រូវបានបញ្ចូលក្នុងចំណាយវិនិយោគនៃថវិកាជាតិឡើយ ។ ក៏ប៉ុន្តែ រាជរដ្ឋាភិបាលកម្ពុជាបានប្តេជ្ញាចិត្តនឹងបញ្ចូលហិរញ្ញប្បទានអភិវឌ្ឍន៍ទាំងអស់ ចូលក្នុងថវិកាជាតិនៅពេលអនាគត នៅពេលដែលព័ត៌មានដែលទទួលបានមានលក្ខណៈសុក្រិត និង សមស្របតាមចំណាត់ថ្នាក់សេដ្ឋកិច្ច ដែលអាចចុះបញ្ជីកាបានក្នុងគណនីរតនាគារជាតិ ។

ដូច្នេះ ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៧ បានព្យាករណ៍ចំណាយវិនិយោគដោយហិរញ្ញ-ប្បទានពីក្រៅប្រទេសសរុបចំនួន ១.១១០ ពាន់លានរៀល ដែលជា **ជំនួយជាគម្រោង** ។ បន្ទាប់ពីការព្យាករណ៍ស្តីពីចំណាយវិនិយោគត្រូវបានដាក់បញ្ចូលក្នុងថវិកាប្រចាំឆ្នាំ និង ការអនុម័តថវិកាដោយរដ្ឋសភាព និង ពិនិត្យដោយព្រឹទ្ធសភា គម្រោងទាំងនេះនឹងត្រូវអនុវត្តដោយដៃគូអភិវឌ្ឍន៍ទាំងអស់ ។ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុតាមដានត្រួតពិនិត្យការអនុវត្តគម្រោងវិនិយោគដោយហិរញ្ញប្បទានក្រៅប្រទេស ដោយប្រើប្រាស់យន្តការនៃ **តារាង**


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

**ប្រតិបត្តិការហិរញ្ញវត្ថុសាធារណៈ** (TOFE) ។ នៅក្នុងរបាយការណ៍ប្រចាំខែ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុផ្ដល់នូវព័ត៌មានស្ដីពីការអនុវត្តគម្រោងដោយ **ធនាគារអភិវឌ្ឍន៍អាស៊ី** និង **ធនាគារពិភពលោក** ដោយឈរលើមូលដ្ឋាននៃទិន្នន័យបើកផ្ដល់ជាក់ស្ដែង ។ ក៏ប៉ុន្ដែ ទិន្នន័យស្ដីពីការអនុវត្តគម្រោងដោយដៃគូអភិវឌ្ឍផ្សេងទៀតត្រូវឈរលើមូលដ្ឋាននៃការប៉ាន់ស្មាន ដោយយកការព្យាករណ៍សម្រាប់មួយឆ្នាំ ចែកនឹង ១២ ហើយដាក់ចូលក្នុងរបាយការណ៍ TOFE ប្រចាំខែ ។ នៅពេលដែលរៀបចំធ្វើរបាយការណ៍នៅក្នុងខែ ឧសភា ឬ មិថុនានៃឆ្នាំនីមួយៗ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុស្រង់យកទិន្នន័យនៃការបើកផ្ដល់ហិរញ្ញប្បទានសម្រាប់អភិវឌ្ឍន៍ជាក់ស្ដែង ហើយបញ្ចូលទិន្នន័យនៃការអនុវត្តថវិកាសរុប ចូលទៅក្នុងសេចក្ដីព្រាងច្បាប់ស្ដីពីការអនុវត្តថវិកាប្រចាំឆ្នាំ ហើយដាក់ជូនគណៈរដ្ឋមន្ត្រីអនុម័ត បន្ទាប់មកដាក់ជូនរដ្ឋសភាអនុម័ត និង ព្រឹទ្ធសភាពិនិត្យ ។

## ២. វិនិយោគដោយហិរញ្ញប្បទានក្នុងប្រទេស

ចំណាយវិនិយោគដោយហិរញ្ញប្បទានក្នុងប្រទេស ត្រូវបានចែកចេញជាពីរផ្នែក ÷

ទីមួយ- ចំណាយវិនិយោគដែលធ្វើហិរញ្ញប្បទានដោយថវិកាជាតិដោយផ្ទាល់ ដោយប្រើប្រាស់នូវធនធានក្នុងស្រុក ដែលជាអតិរេកនៃថវិកាចរន្ត ដើម្បីយកទៅបង្កើននូវការអនុវត្តគម្រោងវិនិយោគសំខាន់ៗមួយចំនួន ដែលជាអាទិភាពនៃគោលនយោបាយរបស់រាជរដ្ឋាភិបាល ។

ទីពីរ- ចំណាយវិនិយោគថវិកា ដែលជាមូលនិធិបដិភាគរបស់រាជរដ្ឋាភិបាល ដើម្បីចូលរួមអនុវត្តនូវគម្រោងរបស់ **ធនាគារអភិវឌ្ឍន៍អាស៊ី** និង **ធនាគារពិភពលោក** ដែលទាមទារអោយមានការចូលរួមរបស់រាជរដ្ឋាភិបាលកម្ពុជា ទោះបីជាទឹកប្រាក់ទាំងនោះនៅមានកម្រិតជានិមិត្តរូបក៏ដោយ ដើម្បីបង្ហាញជាភាពជាម្ចាស់របស់កម្ពុជា លើការងារអភិវឌ្ឍប្រទេសជាតិ ។ នៅក្នុងអំឡុងទស្សវត្សទី ៩០ និង ដើមទស្សវត្សទី ២០០០ នៅពេលដែលកម្ពុជាប្រមូលចំណូលបានតិច «**ជំនួយជាទំនិញ**» ដែលដៃគូអភិវឌ្ឍន៍ខ្លះបានផ្ដល់ជូនរាជរដ្ឋាភិបាលកម្ពុជាត្រូវ បានយកទៅលក់នៅលើទីផ្សារ រួចមកយកទៅចូលជាមូលនិធិបដិភាគរបស់រាជរដ្ឋាភិបាល នៅក្នុងគម្រោងសំខាន់ៗ ។

ជាការពិតណាស់ ទំហំទឹកប្រាក់វិនិយោគដោយហិរញ្ញប្បទានក្នុងប្រទេសនៅមានកម្រិតនៅឡើយ ដោយសារតែចំណាយចរន្តចេះតែកើនជាលំដាប់ ថ្វីត្បិតតែចំណូលសរុបបានកើនឡើងដល់ ១២,១%នៃផសស នៅក្នុងឆ្នាំ ២០០៨ កន្លងទៅនេះក៏ដោយ ។ ក៏ប៉ុន្ដែ ចំណាយវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេសបានកើនឡើងយ៉ាងខ្លាំង ពី --,១%នៃផសស នៅក្នុងឆ្នាំ ១៩៩៤ ដល់ --,១%នៃផសស ឬ ស្មើនឹង ---- ពាន់លានរៀល នៅក្នុងឆ្នាំ ២០០៨ ។



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

វិនិយោគដោយហិរញ្ញប្បទានក្នុងស្រុកដើរតួនាទីយ៉ាងសំខាន់ ក្នុងការអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ដោយសារតែថវិកាជាតិមានភាពទន់ភ្លន់ អាចអោយរាជរដ្ឋាភិបាលអាចមានភាពទន់ភ្លន់ក្នុងការអនុវត្តនូវយុទ្ធសាស្រ្តចតុកោណ ផែនការយុទ្ធសាស្រ្តអភិវឌ្ឍជាតិ និងរៀបចំផែនការវិនិយោគសាធារណៈ ដែលឆ្លុះបញ្ចាំងទាំងស្រុងនូវអាទិភាពរបស់ខ្លួន តាមរយៈការប្រមូលផ្តុំចំណាយវិនិយោគដោយហិរញ្ញប្បទានក្នុងស្រុកទៅលើវិស័យហេដ្ឋារចនាសម្ព័ន្ធ ជាពិសេសផ្លូវខេត្ត ផ្លូវលំ និង ផ្លូវជនបទ ការថែទាំខួប ឬ ប្រចាំ ការជួសជុលធំ ឬ ការជួសជុលឡើងវិញនូវផ្លូវជាតិ ការសាងសង់ផ្លូវថ្មី ការសាងសង់ និង ជួសជុលនូវប្រព័ន្ធធារាសាស្រ្តជាដើម ។

ចាប់តាំងពីអាណត្តិទីពីរនៃរដ្ឋសភាក្នុងឆ្នាំ ១៩៩៩ មក រាជរដ្ឋាភិបាលកម្ពុជាបានផ្តោតអាទិភាពទៅលើការសាងសង់ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ជាពិសេសផ្លូវថ្នល់ និង ប្រព័ន្ធធារាសាស្រ្ត ដែលចូលរួមវិភាគទានយ៉ាងសំខាន់ក្នុងការផ្សារភ្ជាប់សេដ្ឋកិច្ចជាតិ អោយក្លាយជាសរីរាង្គតែមួយ ពង្រីកទីផ្សារក្នុងស្រុក បង្កើនផលិតភាពកសិកម្ម និង ដោះស្រាយបានយ៉ាងស័ក្តិសិទ្ធិនូវហានិភ័យនៃគ្រោះរាំងស្ងួត ។ ប្រការនេះបានចូលរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនកម្ពុជា ចំនួន ១% ក្នុងមួយឆ្នាំ ។

ការបង្កើនថវិកាវិនិយោគដោយហិរញ្ញប្បទានក្នុងស្រុកបានចូលរួមយ៉ាងសំខាន់ ក្នុងការអនុវត្តគម្រោងដែលផ្តល់ហិរញ្ញប្បទានដោយ**ធនាគារអភិវឌ្ឍន៍អាស៊ី** និង **ធនាគារពិភពលោក** ជាពិសេស គម្រោងហេដ្ឋា-រចនាសម្ព័ន្ធ ដែលបង្កើតនូវសមត្ថភាពផលិតរបស់សេដ្ឋកិច្ចជាតិ និង ទាក់ទាញនូវ **វិនិយោគផ្ទាល់ពីបរទេស** ។ ការអនុវត្តគម្រោងសំខាន់ៗទាំងនេះ ដូចជាការសាងសង់ស្ថានីយអគ្គិសនី ការសាងសង់បណ្តាញបញ្ជូនចែកចាយអគ្គិសនី ការសាងសង់ប្រព័ន្ធធារាសាស្រ្ត ការសាងសង់ផ្លូវជាតិ និង ផ្លូវខេត្ត ការសាងសង់សាលារៀន មន្ទីរពេទ្យ មណ្ឌលសុខភាព ។ល។ និង ការកសាងសមត្ថភាពស្ថាប័ន បានបង្កើតនូវសក្តានុពលសម្រាប់ធានាបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ ក្នុងរយៈពេលមួយទស្សវត្សកន្លងទៅនេះ ។

ជារួម ថវិកាវិនិយោគដោយហិរញ្ញប្បទានក្នុងស្រុកបានក្លាយទៅជាសរសរទ្រូងនៃការអនុវត្តគោល-នយោបាយវិនិយោគជាតិ តាមរយៈការបង្កើត និង ការពង្រីកសញ្ច័យជាតិ និង ការកសាងសមត្ថភាពស្ថាប័នដើម្បីឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍប្រទេសជាតិ ។

ចំណាយថវិកាវិនិយោគដោយហិរញ្ញប្បទានក្នុងស្រុកត្រូវបានអនុវត្ត ដោយគោរពតាមនីតិវិធីថវិកាជាតិជាធរមាន ក្នុងក្របខ័ណ្ឌនៃការត្រួតពិនិត្យចំណាយសាធារណៈ តាមដំណាក់កាលនៃចំណាយ៖ ការធានាចំណាយ ការជម្រះបញ្ជី អាណាប័ណ្ណ និង ការទូទាត់ ដោយមានការត្រួតពិនិត្យហិរញ្ញវត្ថុ និង ការត្រួតពិនិត្យរតនាគារ ។ ចំណាយថវិកាវិនិយោគដោយហិរញ្ញប្បទានក្នុងស្រុកគ្រប់គ្រងដោយនាយកដ្ឋានវិនិយោគ និង សហប្រតិបត្តិការអន្តរជាតិ ដោយសហការយ៉ាងជិតស្និទ្ធជាមួយក្រសួងចំណាយ ។ ឥណទានថវិកាត្រូវបានបែងចែកតាមគម្រោង និង



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

តាមក្រសួង ហើយអនុវត្តតាមគោលការណ៍ «**អគ្គបញ្ជាការតែមួយ - សេនាធិការតែមួយ**» ដោយគម្រោងវិនិយោគទាំងអស់ត្រូវឆ្លងការសម្រេចរបស់សម្តេចនាយករដ្ឋមន្ត្រី ដែលជាបញ្ជាការតែមួយគត់នៃចំណាយវិនិយោគ ដែលមានក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុជាសេនាធិការតែមួយគត់ ។ ឥណទានថវិកាត្រូវបានបែងចែក ជា **ឥណទានកម្មវិធី** សម្រាប់គម្រោងនីមួយៗ **ឥណទានភ្ជាប់សន្យា** សម្រាប់ឆ្នាំនីមួយៗ និង **ឥណទានទូទាត់** សម្រាប់ច្បាប់ថវិកាប្រចាំឆ្នាំ ។

## ៣. ការទ្រទ្រង់ថវិកា

ការទ្រទ្រង់ថវិកា គឺជារូបភាពមួយនៃការផ្តល់ហិរញ្ញប្បទានពីក្រៅប្រទេសដោយដៃគូអភិវឌ្ឍន៍ (ទាំងដៃគូពហុភាគី ដែលជាស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ ទាំងដៃគូទ្វេភាគី) ដោយផ្តល់ការគាំទ្រដោយផ្ទាល់ ជារូបិយប័ណ្ណ និង ជាទំនិញ ដល់ថវិការបស់ប្រទេស ដែលទទួលហិរញ្ញប្បទាននេះ ។ ការទ្រទ្រង់ថវិកាអាចជាជំនួយឥតសំណង ឬ ជាកម្ចី ។ គោលដៅនៃការទ្រទ្រង់ថវិកា គឺ៖

ទីមួយ- ការជួយពង្រឹង **សមត្ថភាពស្ថាប័ន**របស់រដ្ឋ ក្នុងការអនុវត្តនូវយុទ្ធសាស្ត្រ និង គោលនយោបាយក្នុងការអភិវឌ្ឍប្រទេស ។

ទីពីរ- ការអនុវត្តដោយផ្ទាល់នូវគោលនយោបាយរបស់រាជរដ្ឋាភិបាល តាមរយៈ **ការអនុវត្តនូវគម្រោងវិនិយោគសាធារណៈ** ។

ទីបី- ការជួយ **កាត់បន្ថយនូវភាពមិនប្រាកដប្រជា** នៃចំណូលថវិការដ្ឋ ។ នៅពេលមានវិបត្តិសេដ្ឋកិច្ច ដែលនាំអោយចំណូលធ្លាក់ចុះ ការទ្រទ្រង់ថវិកាគឺជាប្រភពចំណូលមួយដ៏សំខាន់ ដើម្បីធានាអោយបាននូវភាពទុកចិត្តនៃថវិការដ្ឋ ។ ប្រការនេះធានាអោយបាននូវការគោរពតាមគោលការណ៍តុល្យភាពថវិកា ដើម្បីរក្សានូវចំណាយជាអាទិភាព ជាពិសេសចំណាយក្នុងវិស័យសង្គមកិច្ច ដូចជាវិស័យអប់រំ សុខាភិបាល និង ចំណាយលើហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ចសំខាន់ៗ ។ ក្នុងករណីដែលគ្មានប្រភពចំណូលដើម្បីប៉ះប៉ូវដល់ការធ្លាក់ចុះនៃចំណាយ នោះចំណាយថវិកានឹងត្រូវកាត់បន្ថយ តាមសមាមាត្រនៃការធ្លាក់ចុះនៃចំណូល ដែលធ្វើអោយមានការលំបាកក្នុងការអនុវត្តនូវគោលនយោបាយរបស់រាជរដ្ឋាភិបាល ។

ទីបួន- ការលើកទឹកចិត្តដល់កម្មវិធីកំណែទម្រង់របស់រាជរដ្ឋាភិបាល ។ ជំនួយទ្រទ្រង់ថវិកាតែងតែភ្ជាប់ជាមួយនឹងលក្ខខណ្ឌកំណែទម្រង់តាមវិស័យ ។ ការបើកផ្តល់ថវិកាត្រូវឈរលើមូលដ្ឋាននៃលទ្ធផលដែលសម្រេចបាន ដែលកំណត់ដោយសូចនាករ ក្នុងក្របខ័ណ្ឌនៃសូចនាករតាមដានរួម រវាងរាជរដ្ឋាភិបាលកម្ពុជា និង ដៃគូអភិវឌ្ឍន៍ ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ៣.១. ជំនួយទ្រទ្រង់ថវិកាដោយផ្ទាល់

ដោយឈរលើមូលដ្ឋាននៃការគិតគូរខាងលើ រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់ក្នុងការអនុវត្តនូវជំនួយទ្រទ្រង់ថវិកា ។ **ជំនួយទ្រទ្រង់ថវិកាដោយផ្ទាល់** គឺជាការផ្តល់នូវថវិកាជាសាច់ប្រាក់ ចូលទៅក្នុងគណនីរបស់រាជរដ្ឋាភិបាលនៅក្នុងរតនាគារជាតិតែម្តង ហើយរាជរដ្ឋាភិបាលអាចយកមូលនិធិនេះ ទៅប្រើប្រាស់ ជាចំណាយចរន្ត ឬ ជាចំណាយជាមូលធន ដោយមិនភ្ជាប់ទៅនឹងគម្រោងណាមួយឡើយ ។ ជំនួយទ្រទ្រង់ថវិកាដោយផ្ទាល់មានលក្ខណៈជាកម្មវិធី ដូចជា «**ប្រតិបត្តិការកាត់បន្ថយភាពក្រីក្រ និងកំណើន**» **(PRGO)** ដែលមានដៃគូអភិវឌ្ឍន៍ចំនួនបួនចូលរួម គឺធនាគារពិភពលោក (១៥លានដុល្លារអាមេរិក) ទីភ្នាក់ងារ **DFID** របស់អង់គ្លេស (៣លានដុល្លារអាមេរិក) អង្គការ **JICA** របស់ ជប៉ុន (១០ លានដុល្លារអាមេរិក) និង សហគមន៍អ៊ឺរ៉ុប (២លានដុល្លារអាមេរិក) ។ កម្មវិធីកំណែទម្រង់ចែកចេញជាបីផ្នែក គឺ ៖ ទីមួយ- កំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ ទីពីរ- កំណែទម្រង់អភិវឌ្ឍន៍ផ្នែកឯកជន និង ទីបី- កំណែទម្រង់ការគ្រប់គ្រងដីធ្លី ។

## ៣.២. ជំនួយទ្រទ្រង់ថវិកាជាទំនិញ (ជំនួយជាទំនិញ)

ជំនួយទ្រទ្រង់ថវិកាជាទំនិញ គឺជាប្រភេទជំនួយមួយទៀត ដើម្បីបង្កើនចំណូលរបស់រាជរដ្ឋាភិបាល ។ ដៃគូអភិវឌ្ឍន៍ផ្តល់ជំនួយជាទំនិញ ដែលត្រូវលក់លើទីផ្សារក្នុងស្រុក ហើយយកថវិកាជាប្រាក់រៀល ដើម្បីដាក់ចូលជាចំណូលថវិកា ។ ប្រភេទនៃជំនួយទ្រទ្រង់ថវកានេះត្រូវបានអនុវត្តដោយប្រទេសជប៉ុន ក្នុងក្របខ័ណ្ឌនៃកម្មវិធីសង្គ្រោះបន្ទាន់ដើម្បីនីតិសម្បទាកម្ពុជា ។ ជប៉ុនផ្តល់ជំនួយជាជីគីមី ឬ ជាដែកថែប ដែលត្រូវបានយកទៅដេញថ្លៃលក់លើទីផ្សារក្នុងស្រុក ហើយប្រមូលចំណូលចូលថវិការរដ្ឋ ។ ជំនួយប្រភេទនេះជួយដល់រាជរដ្ឋាភិបាល ក្នុងការផ្គត់ផ្គង់ទំនិញយុទ្ធសាស្ត្រផង និង ប្រមូលប្រាក់រៀលចូលក្នុងរតនាគារជាតិផង ក្នុងទិសដៅគ្រប់គ្រងអតិផរណាអោយទៅទាប ។



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

# ជំពូកទី ១៣

# លទ្ធកម្មសាធារណៈ

## ១. ក្របខ័ណ្ឌគតិយុត្តិ

បន្ទាប់ពីចូលជាសមាជិកភាពរបស់ **អង្គការពាណិជ្ជកម្មពិភពលោក** កម្ពុជាមានកាតព្វកិច្ចគោរពតាមកិច្ចព្រមព្រៀងទីក្រុង **ម៉ារ៉ាកិច** ចុះថ្ងៃទី១៥ ខែមេសា ឆ្នាំ ១៩៩៤ ស្តីពីការបង្កើតអង្គការពាណិជ្ជកម្មពិភពលោក ដែលក្នុងនោះមានឧបសម្ព័ន្ធមួយចែងថា÷ «ប្រទេសសមាជិកត្រូវគោរពវិធានលទ្ធកម្មសាធារណៈ» (ឧបសម្ព័ន្ធទី ៤ នៃកិច្ចព្រមព្រៀង) ។ ក៏ប៉ុន្តែ ដើម្បីអោយច្បាប់នេះអាចអនុវត្តនៅព្រះរាជាណាចក្រកម្ពុជាបាន ទាល់តែរដ្ឋសភាធ្វើសច្ចាប័នលើសន្ធិសញ្ញាអន្តរជាតិ ឬ អនុម័តច្បាប់ជាតិដែលមានខ្លឹមសារដូចសន្ធិសញ្ញា ឬ កិច្ចព្រមពៀងអន្តរជាតិជាមុនសិន ។

លទ្ធកម្មសាធារណៈនៅព្រះរាជាណាចក្រត្រូវបានគ្រប់គ្រងតាមបថានានុក្រមនៃបទប្បញ្ញត្តិដូចខាងក្រោម ÷

- **អនុក្រឹត្យ** លេខ ១០៥ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០០៦ ស្តីពី **លទ្ធកម្មសាធារណៈ** (ជំនួសអនុក្រឹត្យ លេខ ៦០ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ១៩៩៥ ស្តីពីការគ្រប់គ្រងលទ្ធកម្មសាធារណៈ)

- **ប្រកាស** លេខ ១០៥ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០០៦ ស្តីពី **ការអនុវត្តវិធាន និង**

**ឧត្តមភាពនៃសន្ធិសញ្ញាលើនីតិក្នុងស្រុក**

កិច្ចព្រមព្រៀង ទីក្រុង **វីយែន** ចុះថ្ងៃទី ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ១៩៦៩ ស្តីពី **នីតិនៃសន្ធិសញ្ញា** បានចែងអំពីឧត្តមភាពនៃសន្ធិសញ្ញាលើនីតិក្នុងស្រុក ត្រង់មាត្រា ២៧ ថា : «*ភាគីមួយមិនអាចយកបទប្បញ្ញត្តិនៃនីតិក្នុងស្រុក មកធ្វើជាតឹកតាងនៃការមិនអនុវត្តសន្ធិសញ្ញាបានឡើយ*»។

«ព្រះមហាក្សត្រទ្រង់ឡាយព្រហស្តលេខាលើសន្ធិសញ្ញា និងអនុសញ្ញាអន្តរជាតិ ហើយទ្រង់ប្រទានសច្ចាប័នលើសន្ធិសញ្ញា អនុសញ្ញាទាំងនេះ ក្រោយបានទទួលការអនុម័តយល់ព្រមពីរដ្ឋសភា ជាតិ និងព្រឹទ្ធសភា» (មាត្រា ២៦ ថ្មីនៃ **រដ្ឋធម្មនុញ្ញ** នៃព្រះរាជាណាចក្រកម្ពុជា) ។

កិច្ចព្រមព្រៀងនៃអង្គការពាណិជ្ជកម្មពិភពលោក ព្រមទាំងឧបសម្ព័ន្ធស្តីពីលទ្ធកម្មសាធារណៈ ដាក់កំហិតលើនីតិក្នុងស្រុក ។ ប្រការនេះដូចគ្នាផងដែរនឹងកិច្ចព្រមព្រៀងដែលចុះហត្ថលេខាជាមួយដៃគូអភិវឌ្ឍន៍ និងដែលតម្រូវអោយអនុវត្តនូវនីតិវិធីអនុម័តដោយរដ្ឋសភា ពិនិត្យដោយព្រឹទ្ធសភា និងផ្តល់សច្ចាប័នដោយ ព្រះមហាក្សត្រ ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

**បទប្បញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈ** (ជំនួសប្រកាសលេខ ៣១៩ សហវ.ម.ប្រក. ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ១៩៩៥ ស្តីពី **ការអនុវត្តវិធាន និង បទប្បញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈ**)

-**ប្រកាស** លេខ ០៤៥ សហវ.ប្រក. ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៥ ស្តីពី **ការអនុវត្តវិសហ-មជ្ឈការកិច្ចលទ្ធកម្មសាធារណៈ**

-**ប្រកាស** របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លេខ ៥៨៧ ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០៥ ដែលប្រកាសអោយប្រើសៀវភៅស្តីពី **លទ្ធកម្មរបស់ធនាគារពិភពលោក និង ធនាគារអភិវឌ្ឍអាស៊ី** (៤៩០ ទំព័រ)

-**ប្រកាស** លេខ ៤០១ ចុះថ្ងៃទី ៣០ ឧសភា ឆ្នាំ ២០០៦ ដែលកែសំរួលលើមាត្រា ២ នៃ ប្រកាសលេខ ០៤៥ ចុះថ្ងៃទី ៣១ មករា ឆ្នាំ ២០០៥ **ជាពិសេសចំពោះទំហំនៃលទ្ធកម្ម**

-**សារាចរណែនាំ** លេខ ០០៦ ហសវ ចុះថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០០៧ **ស្តីពីការរៀបចំផែនការលទ្ធកម្មឆ្នាំ ២០០៨ និង ឆ្នាំបន្តបន្ទាប់** ។

***ឋានានុក្រមនៃអត្ថបទច្បាប់នៅព្រះរាជាណាចក្រកម្ពុជា***

អត្ថបទច្បាប់នៅព្រះរាជាណាចក្រកម្ពុជា តាមឋានានុក្រមមាន៖

-**រដ្ឋធម្មនុញ្ញ**

-**ច្បាប់** ដែលមានធម្មនុញ្ញភាព

-**សន្ធិសញ្ញា** ឬ កិច្ចព្រមព្រៀង ឬ អនុសញ្ញាអន្តរជាតិ ដែលផ្តល់សច្ចាប័នដោយរដ្ឋសភា និងឡាយព្រហស្តលេខាដោយព្រះមហាក្សត្រ ។ ក្នុងករណីចាំបាច់ ត្រូវធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញជាមុនសិន ដើម្បីផ្តល់សច្ចាប័នលើសន្ធិសញ្ញា ឬ កិច្ចព្រមព្រៀង ដោយអនុលោមតាមរដ្ឋធម្មនុញ្ញ ។

-**ច្បាប់អន្តរការ**

-**ច្បាប់** ទូទៅ (ដាក់អោយប្រើប្រាស់ដោយ **ព្រះរាជក្រម**)

-**ព្រះរាជក្រឹត្យ** ដែលឆ្លងតាមសំណើរបស់គណៈរដ្ឋមន្ត្រី ឬ នាយករដ្ឋមន្ត្រី តាមរយៈច្បាប់ ដែលរៀបចំសេចក្តីព្រាងដោយទីស្តីការគណៈរដ្ឋមន្ត្រី

-**អនុក្រឹត្យ** របស់គណៈរដ្ឋមន្ត្រី

-**ប្រកាស**របស់រដ្ឋមន្ត្រីក្រសួង

**សេចក្តីណែនាំ** និង **សារាចរ** មិនមានអានុភាពគតិយុត្តិទេ គឺមានគោលដៅសម្រាប់ពន្យល់ការអនុវត្តតែប៉ុណ្ណោះ ។



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

***ការទិញជាសាធារណៈ ឬ លទ្ធកម្មសាធារណៈ***

លទ្ធកម្មទំនិញ អាចអនុវត្តក្រោមរូបភាពផ្សេងៗ៖ ការទិញ ការធ្វើ **តតិសន្យា** ការជួល ការជួល-លក់ សម្រាប់ការអនុវត្តលទ្ធកម្មសាធារណៈ ។ គេអាចអនុវត្តលទ្ធកម្មផងដែរសម្រាប់អំណោយ ការឧបត្ថម្ភ ជាអំណោយស្នាដៃសិល្បៈ ឬ បេតិកភ័ណ្ឌនានា ។

រាល់លទ្ធកម្មត្រូវអនុវត្តតាម **កិច្ចសន្យា** ផ្ទាល់មាត់ ឬ ជាលាយលក្ខណ៍អក្សរ ។ កិច្ចសន្យាធ្វើឡើងដោយរដ្ឋ និង អង្គភាពពាក់ព័ន្ធ ដែលមានគុណសម្បត្តិជា «រដ្ឋបាល» ។

**កិច្ចសន្យារដ្ឋបាល** ភាគច្រើន ជាលទ្ធកម្មសាធារណៈ សម្បទាន និងកិច្ចសន្យាការងារនៃភ្នាក់ងាររដ្ឋ ។

គ្រប់កិច្ចសន្យាដែលចុះដោយរដ្ឋ ពុំមែនសុទ្ធតែជាកិច្ចសន្យារដ្ឋបាលនោះទេ ។ ការវិនិច្ឆ័យលើកិច្ចសន្យាត្រូវកំណត់ជាដំបូងនូវភ្នាក់ងាររដ្ឋដែលចុះកិច្ចសន្យា (ពេលខ្លះភ្នាក់ងាររបស់រដ្ឋអាច មានប្រភពពីនីតិឯកជន) ។

**លទ្ធកម្មសាធារណៈ** ជាកិច្ចសន្យារដ្ឋបាល (ប៉ុន្តែ លទ្ធកម្មរដ្ឋមួយចំនួន អាចធ្វើតាមកិច្ចសន្យាឯកជនបាន) ។ កិច្ចសន្យាទាំងនេះអាចកើតឡើងរវាងនីតិបុគ្គលសាធារណៈ និងរូបវ័ន្តបុគ្គល ឬ រវាងនីតិបុគ្គលសាធារណៈពីរភាគី (និង ពេលខ្លះរវាងរូបវ័ន្តបុគ្គល តែក្នុងនោះ ភាគីមួយត្រូវអនុវត្តនូវបទប្បញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈ) ។

លក្ខណៈសម្បត្តិនៃកិច្ចសន្យារដ្ឋបាល គឺ **អសមប្បមាណ** (Dissymétrie) រវាងភាគីនៃកិច្ចសន្យា ។ ពេលខ្លះគេនិយាយថា ភាគីឯកជនស្ថិតនៅក្នុងស្ថានភាពពាក់កណ្តាលកិច្ចសន្យា ពាក់កណ្តាលបទប្បញ្ញត្តិ ។ បទប្បញ្ញត្តិដោយឡែក (មិនស្ថិតនៅក្រោមនីតិរួម) ត្រូវបានអនុវត្ត ដូចជា ៖ ប្រធានសក្តិ ដែលអនុញ្ញាតអោយអ្នកទិញមានសិទ្ធិបដិសេធកិច្ចសន្យា ។ ចំណែកឯភាគីឯកជនមានកាតព្វកិច្ចអនុវត្តព្រោះគេបានចូលរួមសហការជាមួយស្ថាប័នសាធារណៈ ។

## ២. ក្របខ័ណ្ឌនៃកិច្ចព្រមព្រៀងម៉ារ៉ាកិច

កិច្ចព្រមព្រៀងទីក្រុង **ម៉ារ៉ាកិច** ទាមទារអោយរាល់ភាគីនៃកិច្ចព្រមព្រៀងកំណត់បញ្ជីអង្គភាព (អាជ្ញាធរដែលជាភាគីនៃកិច្ចសន្យា) ដែលត្រូវចូលក្នុងដែនប្រតិបត្តិនៃកិច្ចព្រមព្រៀងនេះ (ឧបសម្ព័ន្ធ ១) ។

មាត្រា ២ កំណត់អំពីវិធីវាយតម្លៃ និងទំហំទឹកប្រាក់នៃកិច្ចសន្យា សម្រាប់ការអនុវត្តកម្រិតទឹកប្រាក់ដែល កំណត់ដោយកិច្ចព្រមព្រៀងនេះ ។ កម្រិតទឹកប្រាក់នេះត្រូវកំណត់ដោយភាគីទាំងអស់ នៅក្នុងឧបសម្ព័ន្ធ ។

គោលការណ៍ចម្បងនៃមាត្រា ៣ គឺ **គោលការណ៍នៃការមិនរើសអើង** រវាងផលិតផល សេវា និង រវាងអ្នកផ្គត់ផ្គង់ក្នុងស្រុក និងអ្នកផ្គត់ផ្គង់ក្រៅស្រុក ។ ប៉ុន្តែពេលខ្លះ ការអនុវត្តដោយឡែកត្រូវបានគេបង្កើតឡើង សម្រាប់ប្រទេសកំពុងអភិវឌ្ឍ (មាត្រា ៤) ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ២.១. នីតិវិធីនៃលទ្ធកម្មសាធារណៈ

នីតិវិធីនៃលទ្ធកម្មសាធារណៈមានដូចជា ៖

- **ការដេញថ្លៃដោយប្រកួតប្រជែង** ដោយចំហ សម្រាប់គ្រប់អ្នកផ្គត់ផ្គង់ដែលអាចចូលរួមដេញថ្លៃ
- **ការដេញថ្លៃដោយប្រកួតប្រជែង** ដោយជ្រើសរើស ដោយស្ថាប័នដែលរៀបចំការដេញថ្លៃអញ្ជើញតែក្រុមហ៊ុនដែលមានបុរេលក្ខណៈសម្បត្តិអោយចូលរួមដេញថ្លៃ
- **ការដេញថ្លៃដោយប្រកួតប្រជែង** ដោយចង្អៀត ដោយស្ថាប័នដែលរៀបចំការដេញថ្លៃទំនាក់ទំនងដោយផ្ទាល់ ក្នុងករណីតិចតួចប៉ុណ្ណោះ តែជាមួយក្រុមហ៊ុនមួយៗតែម្តង (មាត្រា ១៥) ។

នីតិវិធីនៃការជ្រើសរើសអ្នកផ្គត់ផ្គង់ ត្រូវបានពិពណ៌នានៅក្នុងមាត្រា ៨ នៃកិច្ចព្រមព្រៀងនេះ ហើយនីតិវិធីនេះមិនត្រូវមានការរើសអើងឡើយ ។

ការផ្សព្វផ្សាយដាក់ពាក្យ ឬ ជ្រើសរើស ត្រូវតែផ្សព្វផ្សាយជាសាធារណៈ ហើយភាគីនីមួយៗត្រូវមានបញ្ជីសារពតិមានដែលត្រូវផ្សព្វផ្សាយពីការដេញថ្លៃ (ឧបសម្ព័ន្ធ ៣) ។ បញ្ជីឈ្មោះនៃអ្នកផ្គត់ផ្គង់ដែលមានបុរេ-លក្ខណៈសម្បត្តិអោយចូលរួមដេញថ្លៃត្រូវតែកំណត់ និង ផ្សព្វផ្សាយជារៀងរាល់ឆ្នាំ (មាត្រា ៩) ។ អ្នកដេញថ្លៃដែលគ្មានបុរេលក្ខណៈសម្បត្តិអោយចូលរួមដេញថ្លៃត្រូវតែខិតខំ ដើម្បីទទួលបាននូវបុរេលក្ខណៈសម្បត្តិ និងទាមទារអោយចុះឈ្មោះរបស់គេក្នុងបញ្ជី នៅពេលដែលបំពេញលក្ខណៈសម្បត្តិរួចរាល់ (មាត្រា ១០) ។

មាត្រា ១១ កំណត់រយៈ ពេលអប្បបរមាសំរាប់អ្នកផ្គត់ផ្គង់ ដើម្បីរៀបចំតម្រូវការ ឬ ការស្នើសុំផ្គង់ផ្គង់៖

- ២៥ ថ្ងៃ សម្រាប់រៀបចំឯកសារចូលរួមដេញថ្លៃ និង
- ៤០ ថ្ងៃសម្រាប់ដាក់ពាក្យចូលរួមដេញថ្លៃឡើងវិញ ។

កាលបរិច្ឆេទនេះអាចនឹងត្រូវកាត់បន្ថយ (ក្នុងករណីដែលមានការផ្សព្វផ្សាយពីការដេញថ្លៃតាំងពីយូរយារណាស់មកហើយ ការពិគ្រោះយោបល់លើកទី ២ បន្ទាប់ពីមានការពិគ្រោះថ្លៃលើកទី ១ មិនបានសម្រេចលទ្ធផល ឬក្នុង ករណីដែលបន្ទាន់) ។ កាលបរិច្ឆេទអប្បបរមា គឺមានចំនួន ១០ ថ្ងៃ ។

ខ្លឹមសារនៃឯកសារដេញថ្លៃ ឬ ឯកសារពិគ្រោះ មានលម្អិតនៅក្នុងមាត្រា ១២ ដែលរួមមាន ៖

- អាស័យដ្ឋាននៃអង្គភាពដែលទទួលពាក្យសុំចូលរួមដេញថ្លៃ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

- អាស័យដ្ឋាននៃអង្គភាពដែលអាចសុំព័ត៌មានបន្ថែម

- ភាសាដែលត្រូវប្រើប្រាស់ក្នុងពាក្យដាក់សុំដេញថ្លៃ ឬ ក្នុងឯកសារ

- កាលបរិច្ឆេទឈប់ទទួលពាក្យ ថេរវេលាសុពលភាព

- បុគ្គលដែលអនុញ្ញាតចូលរួមពេលបើកឯកសារដេញថ្លៃ កាលបរិច្ឆេទ ទីកន្លែង និងពេលវេលា

- លក្ខខណ្ឌសេដ្ឋកិច្ច បច្ចេកទេស និងហិរញ្ញវត្ថុ ព័ត៌មានឬ ឯកសារពាក់ព័ន្ធចាំបាច់

- សៀវភៅបន្ទុកនៃផលិតផល ឬ សេវាដែលត្រូវការ

- លក្ខណៈវិនិច្ឆ័យនៃការប្រគល់លទ្ធកម្មសាធារណៈ និងសមាសភាគនៃថ្លៃដែលអាចទទួលយក (មធ្យោបាយដឹកជញ្ជូន អធិការកិច្ច ថ្លៃចូលរួមដេញថ្លៃ រូបិយវត្ថុ...)

- លក្ខខណ្ឌនៃការទូទាត់

- រាល់បែបបទ និងលក្ខខណ្ឌផ្សេងៗទៀត

ការប្រគល់កិច្ចលទ្ធកម្មទៅអោយអ្នកផ្គត់ផ្គង់ត្រូវធ្វើឡើង ទៅតាមលក្ខណៈដែលបានរៀបរាប់ខាងលើ (មាត្រា ១៣) ។ ការចរចាអាចអនុវត្តបាន ដើម្បីជ្រើសរើសអ្នកផ្គត់ផ្គង់ ប្រសិនបើមានករណីពីរដូចគ្នា ។

កិច្ចសន្យាដែលដេញថ្លៃបាន ត្រូវតែមានការផ្សព្វផ្សាយយ៉ាងយូរត្រឹម ៧២ ថ្ងៃបន្ទាប់ពីការដេញបាន (មាត្រា ១៨) ដោយបញ្ជាក់ពី ប្រភេទ និង បរិមាណនៃទំនិញ ឬ សេវាដែលដេញថ្លៃបាន ឈ្មោះ និង អាស័យដ្ឋាននៃអង្គភាពដែលធ្វើកិច្ចលទ្ធកម្ម (អាជ្ញាធរចុះកិច្ចសន្យា) កាលបរិច្ឆេទដេញថ្លៃបាន ឈ្មោះ និង អាស័យដ្ឋានអ្នកទទួលតំលៃដេញដែលខ្ពស់បំផុត និង ទាបបំផុត និងនីតិវិធីដែលបានប្រើប្រាស់ ។

ម្យ៉ាងវិញទៀត ភាគីនីមួយៗ (នៃកិច្ចព្រមព្រៀង) នឹងផ្សព្វផ្សាយច្បាប់ និងបទប្បញ្ញត្តិ សេចក្ដីសំរេចរបស់តុលាការ បទប្បញ្ញត្តិរដ្ឋបាលដែលអនុវត្តជាទូទៅ ប្រការនៃកិច្ចសន្យាគំរូពាក់ព័ន្ធនឹងកិច្ចលទ្ធកម្ម (មាត្រា ១៩) ។ ប្រទេសនីមួយៗត្រូវរៀបចំបោះពុម្ពផ្សាយស្ថិតិប្រចាំឆ្នាំ ។

នីតិវិធីនៃការប្ដឹងតវ៉ា (ឬ ជំទាស់) ត្រូវតែលំអិត និងផ្សព្វផ្សាយជាសាធារណៈ (មាត្រា ២០) ។



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

## ២.២. ការប្រគល់កិច្ចសន្យានៅក្នុងលទ្ធកម្មសាធារណៈ

### ២.២.១. កិច្ចព្រមព្រៀងនីត្រូវម៉ារ៉ាកិច

វាក្យស័ព្ទដែលប្រើប្រាស់ក្នុងកិច្ចព្រមព្រៀង **ម៉ារ៉ាកិច** គឺជាវាក្យស័ព្ទនៃការសំរេចប្រគល់កិច្ចសន្យា (Adjudication) ដែលជាវាក្យស័ព្ទបារាំងជំនាន់មុន ។

កាលពីពេលមុន **ការប្រគល់កិច្ចសន្យា** (Adjudication) សំដៅដល់ការទទួលយកសំណើនៃការដេញថ្លៃដែលទាបជាងគេ ដែលសំណើនេះគឺជាឯកសារចូលរួមដេញថ្លៃ (Soumission) ។

បន្ទាប់មក គេចាប់ផ្តើមអនុវត្តនូវនីតិវិធី **ដេញថ្លៃប្រកួតប្រជែង** (Appel d'offres) ពីការផ្សព្វផ្សាយស្នើសុំអោយបេក្ខជនផ្តល់ **សំណើបច្ចេកទេស និង ហិរញ្ញវត្ថុ** ហើយកិច្ចសន្យាលទ្ធកម្មនឹងប្រគល់ទៅអោយ **សំណើ** ដែលល្អប្រសើជាងគេ ដែលមិនចាំបាច់ត្រូវតែមានតំលៃទាបជាងគេនោះទេ ។

### ២.២.២. វាក្យស័ព្ទរបស់សហគមន៍អឺរ៉ុប

**សេចក្តីណែនាំ** របស់សហគមន៍អ៊ឺរ៉ុប លេខ ២០០៤/១៨/CE ចុះថ្ងៃទី ៣១ ខែមីនា ឆ្នាំ ២០០៤ ស្តីពីកិច្ចសម្របសម្រួលនីតិវិធីលទ្ធកម្មសាធារណៈលើការងារសាងសង់ ការផ្គត់ផ្គង់សម្ភារៈ និងសេវា តម្រូវអោយប្រើប្រាស់វាក្យស័ព្ទរបស់សហគមន៍អ៊ឺរ៉ុប ។

**លទ្ធកម្មសាធារណៈ** គឺជាកិច្ចសន្យាមានលក្ខណៈជាទឹកប្រាក់ ជាលាយលក្ខណ៍អក្សរ រវាងប្រតិបត្តិករសេដ្ឋកិច្ចម្នាក់ ឬ ច្រើននាក់ ជាមួយនឹងអាជ្ញាធរមានសិទ្ធិដាក់ដេញថ្លៃមួយ ឬ ច្រើន ដើម្បីអនុវត្តការសាងសង់ ឬ ការផ្គត់ផ្គង់សម្ភារៈ ឬ ការផ្គត់ផ្គង់សេវាណាមួយ ។

**លទ្ធកម្មសំណង់** គឺជាការអនុវត្តនូវការសាងសង់ ឬ ការអនុវត្តដោយរួមនូវការរៀបចំសិក្សា និងការអនុវត្តនូវការសាងសង់ ឬ ការបំពេញអោយបានសម្រេចនូវការងារណាមួយ ។

**ការងារ** (Ouvrage) គឺជាលទ្ធផលនៃការសាងសង់អាគារ ឬសំណង់ស៊ីវិល សំដៅបម្រើមុខងារសេដ្ឋកិច្ច ឬ បច្ចេកទេស ។

**លទ្ធកម្មទំនិញ** គឺជាការទិញ ការធ្វើភតិសន្យា ការជួល ឬ ជួល- លក់ ដោយមាន ឬ គ្មានជម្រើសនៃការទិញផលិតផល ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

**លទ្ធកម្មសេវា** សំដៅដល់ការផ្គត់ផ្គង់សេវា ។

**សម្បទានការងារសាធារណៈការ** គឺជាកិច្ចសន្យាដែលមានលក្ខណៈដូចគ្នានឹងលទ្ធកម្មសេវាដែរ លើកលែងត្រង់ថា បដិភាគីនៃការបំពេញការងារសាធារណៈការ គឺការទទួលបាននូវបុព្វសិទ្ធិក្នុងការធ្វើអាជីវកម្មលើលទ្ធផលការងារ ឬ ទទួលបាននូវកម្រៃពីការអនុវត្តការងារនោះ ។

**សម្បទានសេវា** គឺជាកិច្ចសន្យាដែលមានលក្ខណៈដូចគ្នានឹងលទ្ធកម្មសេវាដែរ លើកលែងត្រង់ថា បដិភាគីនៃការងារ គឺការទទួលបាននូវបុព្វសិទ្ធិក្នុងការធ្វើអាជីវកម្មលើលទ្ធផលការងារ ឬ ទទួលបាននូវកម្រៃពីការអនុវត្តការងារនោះ ។

**កិច្ចព្រមព្រៀងក្របខ័ណ្ឌ** (Accord-Cadre) គឺជាកិច្ចព្រមព្រៀងរវាងអាជ្ញាធរមានសិទ្ធិដាក់ដេញថ្លៃមួយ ឬ ច្រើន ជាមួយនឹងប្រតិបត្តិករសេដ្ឋកិច្ចមួយ ឬ ច្រើន ដើម្បីកំណត់លក្ខខណ្ឌអនុវត្តការងារក្នុងអំឡុងពេលណាមួយ ជាពិសេសពាក់ព័ន្ធនឹងថ្លៃ ជាពិសេស បរិមាណដែលត្រូវផ្គត់ផ្គង់ ។

**ប្រតិបត្តិករសេដ្ឋកិច្ច** មានន័យថាជា សហគ្រិន (ដែលអនុវត្តការងារសំណង់ ឬ ការងារណាមួយ) អ្នកផ្គត់ផ្គង់ (ទំនិញ) និង អ្នកផ្គត់ផ្គង់សេវា (សេវា)។

**អ្នកដាក់ពាក្យដេញថ្លៃ** (Soumissionnaire) ជាប្រតិបត្តិករដែលបានដាក់ពាក្យ (ជាបេក្ខជនដែលចូលរួមក្នុង **នីតិវិធីចន្លៀត ចរចាផ្ទាល់** ឬ **ការពិភាក្សាថ្លៃ** ។

**អាជ្ញាធររៀបចំការដេញថ្លៃ** (Pouvoirs adjudicataires) ជារដ្ឋ អាជ្ញារធរដែនដី អង្គភាពនៃនីតិសាធារណៈ និង សមាគមដែលបង្កើតឡើងដោយសហគមន៍មួយ ឬ ច្រើន ឬ ដោយអង្គភាពនៃនីតិសាធារណៈមួយ ឬ ច្រើន ។

**អង្គភាពនៃនីតិសាធារណៈ** ជាអង្គភាពដែលបង្កើតឡើងដើម្បីបំពេញអត្ថប្រយោជន៍ទូទៅ មានលក្ខណៈផ្សេងពីឧស្សាហកម្ម ឬ ពាណិជ្ជកម្ម ដែលមានលក្ខណៈជា **នីតិបុគ្គល** ដែលសកម្មភាពត្រូវផ្តល់ហិរញ្ញប្បទានភាគច្រើនដោយរដ្ឋ ដោយអាជ្ញាធរមូលដ្ឋាន ឬ ដោយអង្គភាពនៃនីតិសាធារណៈផ្សេងទៀត ដែលការគ្រប់គ្រងស្ថិតនៅក្រោមអាជ្ញាធរខាងលើ ឬ អង្គភាពរដ្ឋបាល គណៈកម្មការគ្រប់គ្រង ឬ ក្រុមប្រឹក្សាភិបាល ដែលសមាជិកច្រើនជាងពាក់កណ្តាលត្រូវបានតែងតាំងដោយរដ្ឋ ដោយអាជ្ញាធរមូលដ្ឋាន ឬ ដោយអង្គភាពនៃនីតិសាធារណៈផ្សេងទៀត ។

**នីតិវិធីចំហ** (Procédures ouvertes) ជានីតិវិធីដែលក្នុងនោះ រាល់ប្រតិបត្តិករសេដ្ឋកិច្ចទាំងអស់


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

អាចដាក់ពាក្យចូលដេញថ្លៃបាន ។

**នីតិវិធីចង្អៀត** (Procédures restreintes) គឺជានីតិវិធីដែលក្នុងនោះ រាល់ប្រតិបត្តិករសេដ្ឋកិច្ចអាចសុំចូលរួមបាន ក៏ប៉ុន្តែ មានតែប្រតិបត្តិករដែលត្រូវបាន **អាជ្ញាធររៀបចំការដេញថ្លៃ** អញ្ជើញតែប៉ុណ្ណោះ ដែលអាចដាក់ពាក្យដេញថ្លៃបាន ។

**ការពិគ្រោះថ្លៃ** (Dialogue compétitif) គឺជានីតិវិធី ដែលក្នុងនោះរាល់ប្រតិបត្តិករសេដ្ឋកិច្ចអាចសុំចូលរួមបាន ហើយអាជ្ញាធររៀបចំការដេញថ្លៃត្រូវធ្វើការពិភាក្សាជាមួយបេក្ខជន ដែលមានបុរេលក្ខណៈសម្បត្តិ ដើម្បីពិភាក្សាលម្អិតលើដំណោះស្រាយសមស្រប ក្នុងការឆ្លើយតបទៅនឹងតម្រូវការ និង ដើម្បីកំណត់មូលដ្ឋាននៃការដាក់សំណើ ។

**នីតិវិធីចរចាផ្ទាល់** (Procédures négociées) គឺជានីតិវិធី ដែលអាជ្ញាធររៀបចំការដេញថ្លៃចរចាដោយផ្ទាល់ជាមួយប្រតិបត្តិករសេដ្ឋកិច្ចដែលខ្លួនបានជ្រើសរើស និងពិភាក្សាពីលក្ខខណ្ឌនៃការប្រគល់កិច្ចសន្យាលទ្ធកម្មជាមួយប្រតិបត្តិករទាំងនោះ ។

**ការប្រលងប្រណាំង** (Concours) គឺជានីតិវិធី ដែលអនុញ្ញាតអោយអាជ្ញាធររៀបចំការដេញថ្លៃទទួលបានគម្រោង ដែលជ្រើសរើសដោយគណៈកម្មការមួយ បន្ទាប់ពីការប្រកួតប្រជែង ដោយមាន ឬគ្មានប្រាក់លាភការ ។

## ៣. ក្របខ័ណ្ឌគតិយុត្តិនៃព្រះរាជាណាចក្រកម្ពុជា

វិធាន និងបទប្បញ្ញត្តិដែលគ្រប់គ្រងនូវរាល់កិច្ចការលទ្ធកម្មសាធារណៈ នៅក្នុងព្រះរាជាណាចក្រកម្ពុជាត្រូវបានកំណត់ដោយ **អនុក្រឹត្យ** លេខ ១០៥ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០០៦ ស្ដីពី **លទ្ធកម្មសាធារណៈ** និង បំពេញបន្ថែមដោយ **ប្រកាស** ស្ដីពី **ការអនុវត្តវិធាន និង បទប្បញ្ញត្តិស្ដីពីលទ្ធកម្មសាធារណៈ** ។

### ៣.១. វាក្យស័ព្ទ

**ប្រកាស** ស្ដីពី **ការអនុវត្តវិធាន និង បទប្បញ្ញត្តិស្ដីពីលទ្ធកម្មសាធារណៈ** បានកំណត់នូវវាក្យស័ព្ទ និង និយមន័យពាក្យបច្ចេកទេសក្នុងកិច្ចលទ្ធកម្ម ដូចតទៅ÷

**លទ្ធកម្ម:** គឺជាការរកបាននូវទំនិញ និងសេវាកម្មពាក់ព័ន្ធ ឬជាការជួលអ្នកទទួលម៉ៅការសម្រាប់ការ


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

សាងសង់ ជួសជុល តាមរយៈវិធីសាស្ត្រដែលបានរៀបរាប់ក្នុងវិធាន និងបទប្បញ្ញត្តិលទ្ធកម្មសាធារណៈ ។

**លទ្ធកម្មសាធារណៈ:** គឺជាលទ្ធកម្មដែលធ្វើឡើងដោយក្រសួង ស្ថាប័នខេត្ត-ក្រុង ស្រុក ខណ្ឌ ឃុំ-សង្កាត់ និងសហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល ។

**ទំនិញ:** គឺជាវត្ថុរាវ រឹង ឬ ជាឧស្ម័ន ដែលមានតម្លៃ ឬ ផលប្រយោជន៍សេដ្ឋកិច្ច ដូចជាគ្រឿងចក្រ ឧបករណ៍ សម្ភារៈ បរិក្ខា គ្រឿងឧបភោគបរិភោគ ឱសថ និងផលិតផលផ្សេងៗ រួមទាំងអគ្គិសនីផងដែរ ។

**សំណង់:** គឺរាល់សកម្មភាព ដែលពាក់ព័ន្ធដល់ការងារសាងសង់ ការជួសជុល ការធ្វើឡើងជាថ្មី ការដំឡើង ការជីក ការបូម និងការងារប្រហាក់ប្រហែល ដែលបង្កើតអោយមានការប្រើប្រាស់កម្លាំងពលកម្ម គ្រឿងម៉ាស៊ីន បរិក្ខារ និងបច្ចេកវិទ្យា ។

**ឡូត៍លទ្ធកម្ម:** គឺជាការប្រមូលផ្តុំទំនិញ ឬ សំណង់ ដែលមានលក្ខណៈបច្ចេកទេសដូចគ្នា ឬ ស្រដៀងគ្នា ដាក់ចូលក្នុងក្រុមតែមួយសម្រាប់ធ្វើលទ្ធកម្មតែមួយលើក ។

**កញ្ចប់លទ្ធកម្ម:** គឺជាការប្រមូលឡូត៍លទ្ធកម្ម ដែលមានភាពប្រហាក់ប្រហែលគ្នា ឬ ស្រដៀងគ្នា បញ្ចូលជាកញ្ចប់ធំតែមួយសម្រាប់ធ្វើលទ្ធកម្មតែមួយលើក ។

**សេវាកម្ម:** គឺជាសកម្មភាពដែលពាក់ព័ន្ធដល់ការប្រើប្រាស់កម្លាំងមនុស្ស គ្រឿងបរិក្ខារ ឬ បច្ចេកវិទ្យា ដែលនាំមកនូវផលប្រយោជន៍ដល់ស្ថាប័នសាធារណៈ ប៉ុន្តែមិនរាប់បញ្ចូលការងារសាងសង់ និង មុខរបរសេវាវិជ្ជាជីវៈប្រឹក្សាទេ ។

**សេវាប្រឹក្សា:** គឺជាសេវាជំនាញការ ដែលផ្តល់ដោយក្រុមហ៊ុនទីប្រឹក្សា ឬ ក៏ទីប្រឹក្សាឯកត្តជនដែលពាក់ព័ន្ធទៅនឹងគម្រោងណាមួយ ឬ ក៏ការពង្រឹងស្ថាប័ន ។

**ទីប្រឹក្សា:** ជាក្រុមហ៊ុនទីប្រឹក្សា ឬ ទីប្រឹក្សាឯកត្តជន ដែលមានមុខរបរផ្តល់នូវសេវាទីប្រឹក្សា ។

**អ្នកម្ចាស់ការ:** គឺជាស្ថាប័នសាធារណៈ ដែលចុះកិច្ចសន្យាស្តីពីការសាងសង់ ឬ សេវាជួលជាមួយអ្នកទទួលម៉ៅការ ។

**អ្នកទទួលការ:** គឺជា ឯកត្តជន ឬ ក្រុមហ៊ុនដែលចុះកិច្ចសន្យាលើការសាងសង់ ឬ សេវាជួលជាមួយអ្នកម្ចាស់ការ ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

**អ្នកទិញ**: គឺជាស្ថាប័នសាធារណៈ ដែលបានចុះកិច្ចសន្យាទិញទំនិញជាមួយអ្នកផ្គត់ផ្គង់ ។

**អ្នកផ្គត់ផ្គង់**: គឺជាបុគ្គល ឬក្រុមហ៊ុនដែលចុះកិច្ចសន្យាលក់ទំនិញជាមួយអ្នកទិញ ។

**ការសន្សំសំចៃ**: ជាការសម្រេចបាននូវតម្លៃល្អបំផុត ឆ្លងតាមរយៈការប្រកួតប្រជែងដោយយុត្តិធម៌ ។

**តម្លាភាព**: ជាការបំពេញករណីយកិច្ចអោយបានត្រឹមត្រូវ និង ស្មោះត្រង់ ក្នុងដំណើរការអនុវត្តកិច្ចលទ្ធកម្ម ។

**គណនេយ្យភាព**: ជាការធានាអោយមានការទទួលខុសត្រូវទាំងឡាយណា ដែលជាប់ពាក់ព័ន្ធជាមួយនឹងដំណើរការអនុវត្តកិច្ចលទ្ធកម្ម ។

**សមភាព**: ផ្អែកតាមទម្រង់ឯកភាពតែមួយលើគោលនយោបាយ និងនីតិវិធីលទ្ធកម្ម បង្កើតអោយមានភាពស្មើគ្នាសម្រាប់ការប្រកួតប្រជែង ។

**ប្រសិទ្ធភាព**: មានន័យថា ដំណើរការនៃកិច្ចលទ្ធកម្មទំនិញ សំណង់ និង សេវា ត្រូវប្រព្រឹត្តទៅក្នុងភាពរលូនតាមវិធីសាស្ត្រ និងនីតិវិធីលទ្ធកម្មសាធារណៈ ហើយឆ្លើយតបពេញលេញតាមតម្រូវការនៃលក្ខខណ្ឌបច្ចេកទេស បរិមាណ គុណភាព ពេលវេលា សេវា និង តម្លៃ ។

**សុចរិតភាព**: ជាកការជម្រុញអោយដំណើរការអនុវត្តកិច្ចលទ្ធកម្ម ប្រកបដោយតម្លាភាព ស្មើភាព និង មានការទុកចិត្តពីសាធារណៈជន ។

**ក្រមសីលធម៌វិជ្ជាជីវៈ**:: មានន័យថា អ្នកចូលរួមពាក់ព័ន្ធនឹងកិច្ចលទ្ធកម្មត្រូវយល់ដឹង និងអនុវត្តដោយស្មោះត្រង់តាមបទប្បញ្ញត្តិគតិយុត្តិជាធរមាន (ច្បាប់ អនុក្រឹត្យ ប្រកាស សារាចរណែនាំ) និងអនុវត្តអោយបានត្រឹមត្រូវតាមតួនាទី និង មុខងាររបស់ខ្លួន ។

**អំពើពុករលួយ**: សំដៅដល់ការសូក ឬ ការទទួលវត្ថុមានតម្លៃ ដើម្បីធ្វើអោយមានឥទ្ធិពលលើសកម្មភាពមន្ត្រីសាធារណៈ នៅក្នុងដំណើរការជ្រើសរើស ប្រគល់កិច្ចសន្យា ឬ ក្នុងការអនុវត្តកិច្ចសន្យា ។

**អំពើបន្លំ**: គឺជាការបកស្រាយបំភ្លៃហេតុការណ៍ ដើម្បីធ្វើអោយមានឥទ្ធិពលលើដំណើរការវាយតម្លៃប្រគល់កិច្ចសន្យា ឬ ដំណើរការអនុវត្តកិច្ចសន្យា និង ការចូលរួមចំណែកក្នុងអំពើឃុបឃិតជាមួយអ្នកដេញថ្លៃ និង ទីប្រឹក្សា (មុន ឬ ក្រោយពេលដាក់សំណើសុំដេញថ្លៃ) ធ្វើអោយខូចប្រយោជន៍របស់រាជរដ្ឋាភិបាល ។

**អំពើឃុបឃិត**: សំដៅដល់ផែនការ ឬ ជាការរៀបចំឡើងរវាងអ្នកដេញថ្លៃពីរ ឬ ច្រើននាក់ ដើម្បីបង្កើតតម្លៃដេញថ្លៃសិប្បនិម្មិត និងថ្លៃគ្មានលក្ខណៈប្រកួតប្រជែង ឬ ធ្វើអោយមានឥទ្ធិពលលើការអនុវត្តកិច្ចសន្យា ។

**អំពើបង្ខិតបង្ខំ**: សំដៅដល់ការហាមឃាត់ ឬ ការគម្រាមកំហែងដោយផ្ទាល់ ឬ ដោយប្រយោល ធ្វើអោយមានគ្រោះថ្នាក់ដល់បុគ្គល ឬ ទ្រព្យសម្បត្តិរបស់បុគ្គលដើម្បីធ្វើអោយមានឥទ្ធិពលក្នុងការចូលរួម ក្នុងដំណើរការលទ្ធកម្មរបស់បុគ្គល ឬ ធ្វើអោយមានការជះឥទ្ធិពលលើការអនុវត្តកិច្ចសន្យា ។

**សំណើរដេញថ្លៃ**: (Bid or tender) គឺជាការដាក់ឯកសារដេញថ្លៃ ដើម្បីផ្គត់ផ្គង់ទំនិញ សេវា ឬ ធ្វើការសាងសង់ ជួសជុល ដែលធ្វើឡើងតាមលក្ខខណ្ឌកំណត់ដោយអ្នកទិញ ឬ អ្នកម្ចាស់ការ ។

**ការពិគ្រោះថ្លៃ** : គឺជានីតិវិធី ដែលដាក់ឱ្យមានការប្រកួតប្រជែងការផ្គត់ផ្គង់ទំនិញ សេវា ឬ ការងារ ។

**ការដេញថ្លៃ** : គឺជាសំណើមួយ ដែលអ្នកផ្គត់ផ្គង់ទំនិញ ឬសេវា ឬសាធារណៈការធ្វើឡើង ដោយគោរពតាមការកំណត់ និង លក្ខខណ្ឌនៃស្ថាប័នអនុវត្តលទ្ធកម្ម ឬដោយនិយោជក ។

**បុរេលក្ខណៈសម្បត្តិ** (Prequalification): គឺជាការវាយតម្លៃលើលក្ខណៈសម្បត្តិ និង សមត្ថភាពរបស់អ្នកផ្គត់ផ្គង់/អ្នកទទួលការ ក្នុងគោលបំណងជ្រើសរើសអ្នក ដែលអាចអញ្ជើញអោយចូលក្នុងការដេញថ្លៃបាន ។

**លក្ខណៈសម្បត្តិតាមក្រោយ** : (Post qualification) គឺជាសកម្មភាពវាយតម្លៃឡើងវិញនូវលក្ខណៈសម្បត្តិ បច្ចេកទេស និងហិរញ្ញវត្ថុ របស់អ្នកដែលដាក់ថ្លៃថោកជាងគេបំផុត ដើម្បីបញ្ជាក់អោយដឹងថាតើគេមានសមត្ថភាពអនុវត្តកិច្ចសន្យាដែរ ឬ ទេ? ។

**កិច្ចសន្យា**: គឺជាកិច្ចព្រមព្រៀងរវាងអ្នកទិញ និង អ្នកផ្គត់ផ្គង់ ដើម្បីផ្តល់នូវទំនិញ ឬ ក៏រវាងអ្នកម្ចាស់ការ និង អ្នកទទួលការ ដើម្បីអនុវត្តការងារសាងសង់ ជួសជុល ឬ ជួលសេវាក្នុងល័ក្ខខ័ណ្ឌ ដែលព្រមព្រៀងដោយភាគីទាំងពីរ ។

**ការកំណត់ថ្លៃឯកតា**: (Unit pricing) គឺជាវិធីសាស្ត្រកំណត់ថ្លៃថេរដោយឈរលើមូលដ្ឋាន នៃទំហំទឹកប្រាក់ណាមួយ ឬ ក៏ចំនួនណាមួយធ្វើជាខ្នាតរង្វាស់ ។

**ការកំណត់ថ្លៃសរុប**: (Lump-sum pricing) គឺជាវិធីសាស្ត្រកំណត់ថ្លៃ ដែលឈរលើមូលដ្ឋាននៃថ្លៃសរុបដែលមានចែងនៅក្នុងកិច្ចសន្យា ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

### ៣.២. នីតិវិធីបើកចំហ

លទ្ធកម្មមានបួនប្រភេទ៖ លទ្ធកម្មទំនិញ លទ្ធកម្មសំណង់ លទ្ធកម្មសេវាកម្ម និង លទ្ធកម្មសេវាទីប្រឹក្សា ។

លទ្ធកម្មទំនិញ សេវា ការងារសាងសង់ ធ្វើឡើងដោយក្រសួង ស្ថាប័ន ឬ អង្គភាពសាធារណៈ ត្រូវអនុវត្តតាមរបៀបពីរយ៉ាង គឺ៖

**ទីមួយ**- ការដេញថ្លៃដោយប្រកួតប្រជែងបើកចំហ ។

**ទីពីរ**-វិធីផ្សេងទៀត ដែលមិនមែនជាការដេញថ្លៃ ដោយប្រកួតប្រជែងបើកចំហ ។

នីតិវិធីដេញថ្លៃដោយប្រកួតប្រជែងបើកចំហត្រូវបានយកមកប្រើប្រាស់ នៅពេលដែលប្រតិបត្តិករសេដ្ឋកិច្ចមានចំនួនគ្រប់គ្រាន់ ដែលអាចមានលទ្ធភាពគ្រប់គ្រាន់ ដែលអាចផ្គត់ផ្គង់ទំនិញ សេវា ឬ អនុវត្តការងារ ។ នីតិវិធីដេញថ្លៃដោយប្រកួតប្រជែងបើកចំហនឹងផ្តល់ជាអត្ថប្រយោជន៍ដល់រាជរដ្ឋាភិបាល ប្រសិនបើការប្រកួតប្រជែងនឹងនាំទៅដល់ការជ្រើសរើសអ្នកផ្គត់ផ្គង់ និង អ្នកទទួលការណាមួយ ដែលផ្តល់នូវសំណើ ដែលមានលក្ខណៈសន្សំសំចៃ និង អត្ថប្រយោជន៍ជាងគេនោះ ។ ការដេញថ្លៃដោយប្រកួតប្រជែងជាចំហ អាចធ្វើឡើងជាលក្ខណៈជាតិ ឬ ជាលក្ខណៈអន្តរជាតិ ។

#### ៣.២.១. ការដេញថ្លៃដោយប្រកួតប្រជែងជាលក្ខណៈអន្តរជាតិ

**ការដេញថ្លៃដោយប្រកួតប្រជែងជាលក្ខណៈអន្តរជាតិ** (International Competitive Bidding-ICB) គឺជាវិធីសាស្ត្រលទ្ធកម្មដែលផ្តល់ដល់អ្នកប្រើប្រាស់ នូវការជ្រើសរើសយ៉ាងទូលំទូលាយពីក្នុងចំណោយអ្នកផ្គត់ផ្គង់ដែលប្រកួតប្រជែង ហើយផ្តល់ដល់អ្នកផ្គត់ផ្គង់នូវឱកាសគ្រប់គ្រាន់ យុត្តិធម៌ និង ស្មើភាពគ្នា ។ វិធីសាស្ត្រនេះត្រូវប្រើសម្រាប់គម្រោងចំណាយដែលមានទឹកប្រាក់ធំ ។ ដោយអនុលោមតាម **សារាចរណែនាំ** លេខ ០០៦ ហសវ ចុះថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ស្តីពីការរៀបចំផែនការលទ្ធកម្មឆ្នាំ ២០០៨ និង ឆ្នាំបន្តបន្ទាប់ **ការដេញថ្លៃដោយប្រកួតប្រជែងជាលក្ខណៈអន្តរជាតិ** ត្រូវអនុវត្ត ចំពោះទំនិញចាប់ពីតម្លៃ ១.០០០ លានរៀលឡើងទៅ ចំពោះសំណង់ ចាប់ពី ១.២០០ លានរៀលឡើងទៅ ចំពោះសេវា ចាប់ពី ៨០០ លានរៀលឡើងទៅ ។ ចំពោះការដេញថ្លៃជាលក្ខណៈអន្តរជាតិសម្រាប់គម្រោង ដែលផ្តល់ហិរញ្ញប្បទានដោយធនាគារពិភពលោក និង ធនាគារអភិវឌ្ឍន៍អាស៊ី : សម្រាប់ទំនិញ គឺចាប់ពី ១០០.០០០ ដុល្លារឡើងទៅ និងសម្រាប់ផ្នែកការងារសាងសង់ គឺចាប់ពី ៣០០.០០០ ដុល្លារឡើងទៅ (ឧបសម្ព័ន្ធទី ៥) ។

ការប្រកាសផ្សព្វផ្សាយត្រូវធ្វើឡើងយ៉ាងតិចបំផុតក្នុងសាព័ត៌មាន មួយជាភាសាជាតិ និង ជាភាសាបរទេស



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ដោយអ្នកដែលអាចចូលដេញថ្លៃក្នុងវិធីសាស្ត្រនេះត្រូវមានប្រាក់កក់ធានាការដេញថ្លៃយ៉ាងតិច ២%នៃតម្លៃសរុបដាក់អោយដេញថ្លៃ ។

### ៣.២.២. ការដេញថ្លៃដោយប្រកួតប្រជែងជាលក្ខណៈជាតិ

**ការដេញថ្លៃដោយប្រកួតប្រជែងក្នុងស្រុក** (Domestic Competitive Bidding-DCB) គឺជាវិធីសាស្ត្រលទ្ធកម្មដែលត្រូវអនុវត្តក្នុងករណីដែលក្រុមហ៊ុនក្នុងស្រុកមានលទ្ធភាពផ្គត់ផ្គង់គ្រប់គ្រាន់ ហើយត្រូវអនុវត្តសម្រាប់គម្រោងចំណាយដែលមានទំហំទឹកប្រាក់ ចំពោះទំនិញចាប់ពីតម្លៃ ១០០លានរៀល ដល់ក្រោម ១០០០ លានរៀល ចំពោះសំណង់ ចាប់ពី ១០០ លានរៀល ដល់ក្រោម ១.២០០ លានរៀល ចំពោះសេវា ចាប់ពី ១០០ លានរៀល ដល់ក្រោម ៨០០ លានរៀល។ វិធីសាស្ត្រនេះត្រូវមានលិខិតប្រាក់កក់ធានា ការដេញថ្លៃមិនតិចជាង ២%នៃតម្លៃសរុបដាក់ដេញថ្លៃ ។

## ៣.៣. នីតិវិធីផ្សេងទៀត

### ៣.៣.១. វិធីសាស្ត្រពិគ្រោះថ្លៃ

**វិធីសាស្ត្រពិគ្រោះថ្លៃ** (Shopping) គឺជាវិធីសាស្ត្រលទ្ធកម្មដែលតម្រូវ អោយមានតារាងថ្លៃដាក់ក្នុងសំបុត្របិទជិត និង បោះត្រាពីលើ ។ អ្នកផ្គត់ផ្គង់យ៉ាងហោចណាស់ក៏មានចំនួនបី ដែលស្ថិតនៅក្នុងបញ្ជីជ្រើសរើសត្រូវបានទទួលលិខិតអញ្ជើញអោយចូលរួមពិគ្រោះថ្លៃដោយផ្ទាល់ ។ យោងតាម **សារាចរណែនាំ** លេខ ០០៦ ហសវ ចុះថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ស្តីពីការរៀបចំផែនការលទ្ធកម្មឆ្នាំ ២០០៨ និង ឆ្នាំបន្តបន្ទាប់ វិធីសាស្ត្រនេះត្រូវបានប្រើនៅពេលដែលគម្រោងចំណាយមានទឹកប្រាក់ ចំពោះទំនិញចាប់ពីតម្លៃ ២០លានរៀល ដល់ក្រោម ១០០ លានរៀល ចំពោះសំណង់ ចាប់ពី ២០ លានរៀល ដល់ក្រោម ១០០ លានរៀល ចំពោះសេវា ចាប់ពីក្រោម ១០០ លានរៀល ។

សម្រាប់ធនាគារពិភពលោក និងធនាគារអភិវឌ្ឍន៍អាស៊ី ការពិគ្រោះថ្លៃ គឺធ្វើតាមរយៈការផ្សព្វផ្សាយតម្លៃចាប់ពីចំនួនទឹកប្រាក់ពី ៥.០០០ ដុល្លារ ទៅ ២០.០០០ ដុល្លារ ចំពោះការផ្គត់ផ្គង់ទំនិញ និងចាប់ពី ៥.០០០ ដុល្លារ ដល់ ៤០.០០០ ដុល្លារ ចំពោះផ្នែកការងារសាធារណៈការ ។ នៅក្នុងករណី ដែលគម្រោងចំណាយមានទឹកប្រាក់ក្រោម ៥.០០០ ដុល្លារ គេអាចធ្វើការពិគ្រោះថ្លៃដោយពុំចាំបាច់ធ្វើការចុះផ្សាយ (ឧបសម្ព័ន្ធទី៥) ។

### ៣.៣.២. វិធីសាស្ត្រស្ទង់តម្លៃ

**វិធីសាស្ត្រស្ទង់តម្លៃ** (Canvassing) គឺជាវិធីសាស្ត្រលទ្ធកម្មដែលមិនតម្រូវអោយធ្វើការប្រកាសផ្សាយ


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ទេ ។ ក្នុងករណីនេះ មន្ត្រីលទ្ធកម្មត្រូវសាកសួរក្រុមហ៊ុនល្បីឈ្មោះផ្សេងគ្នា ដោយផ្ទាល់ ឬ តាមរយៈទូរស័ព្ទអោយបានច្រើន តាមលទ្ធភាពដែលអាចធ្វើបាន យ៉ាងហោចណាស់អោយបានចំនួនបីក្រុមហ៊ុនដែរ ហើយត្រូវធានាថា តារាងថ្លៃដែលទទួលបានពីអ្នកផ្គត់ផ្គង់ផ្សេងគ្នានោះ បានដាក់ក្នុងស្រោមសំបុត្របិទជិត ហើយត្រូវកត់ត្រាថ្លៃ ឈ្មោះ និង អាស័យដ្ឋានរបស់ក្រុមហ៊ុននីមួយៗ ដើម្បីជ្រើសរើសក្រុមហ៊ុនដែលដាក់ថ្លៃលក់សមស្របបំផុត ។ យោងតាម **សារាចរណែនាំ** លេខ ០០៦ ហសវ ចុះថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ស្តីពីការរៀបចំផែនការលទ្ធកម្មឆ្នាំ ២០០៨ និង ឆ្នាំបន្តបន្ទាប់ វិធីសាស្ត្រនេះត្រូវប្រើនៅពេលដែលគម្រោងចំណាយ មានតម្លៃក្នុងកម្រិតទឹកប្រាក់ ចំពោះទំនិញ ចំពោះតម្លៃក្រោម ២០ លានរៀល និង ចំពោះសំណង់ ក្រោម ២០ លាន រៀល ។

សម្រាប់គម្រោងដែលផ្តល់ហិរញ្ញប្បទានដោយធនាគារពិភពលោក និង ធនាគារអភិវឌ្ឍន៍អាស៊ី វិធីសាស្ត្រនេះត្រូវអនុវត្តតាមការបញ្ជាទិញ ឬ ទិញដោយប្រាក់សុទ្ធ ទៅតាមតារាងចំណាយសម្រាប់តម្លៃក្រោម ៥ ពាន់ដុល្លារ (ឧបសម្ព័ន្ធទី៥) ។

សៀវភៅលទ្ធកម្មធនាគារពិភពលោក និងធនាគារអភិវឌ្ឍន៍អាស៊ីចាត់ទុកពាក្យ **វិធីសាស្ត្រពិគ្រោះថ្លៃ** និង ពាក្យ **វិធីសាស្ត្រស្ទង់តម្លៃ** ប្រហាក់ប្រហែលគ្នា (មាត្រា ១០.២.៤ នៃសៀវភៅលទ្ធកម្មសាធារណៈ) ។

### ៣.៣.៣. វិធីសាស្ត្រលទ្ធកម្មដោយឡែក

**វិធីសាស្ត្រលទ្ធកម្មដោយឡែក** គឺជាវិធីសាស្ត្រដែលត្រូវអនុវត្តតែក្នុងកាលៈទេសៈពិសេស ដោយមានការយល់ព្រមជាមុនពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ដោយស្របតាមបញ្ញត្តិនៃគោលការណ៍ណែនាំរបស់សៀវភៅលទ្ធកម្ម និង ស្របតាមផែនការលទ្ធកម្ម ។ វិធីសាស្ត្រលទ្ធកម្មដោយឡែកមិនពាក់ព័ន្ធនឹងការកំណត់ទឹកប្រាក់ឡើយ ។ វិធីសាស្ត្រនេះមាន ÷

- **ការចុះកិច្ចសន្យាផ្ទាល់** (Direct contracting)

- **ការចុះកិច្ចសន្យាជាមួយអង្គភាពជំនាញនៃស្ថាប័នអនុវត្តលទ្ធកម្ម**

- **លទ្ធកម្មភាគកម្មសហគមន៍**

#### ៣.៣.៣.១. ការចុះកិច្ចសន្យាផ្ទាល់

**ការចុះកិច្ចសន្យាផ្ទាល់** ដែលពាក្យស័ព្ទចំណាស់របស់បារាំងហៅថា Marché de gré à gré ឬ **លទ្ធកម្មតថ្លៃ** (Marché négocié) (វាក្យស័ព្ទថ្មីរបស់បារាំង និង អ៊ឺរ៉ុប) សំដៅលើកិច្ចព្រមព្រៀង ឬ ការចរចារ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ជាមួយអ្នកផ្គត់ផ្គង់តែម្នាក់គត់ ។ វិធីសាស្ត្រនេះត្រូវបានប្រើប្រាស់ក្នុងករណីពិសេសដូចខាងក្រោម ÷

- ឧបករណ៍ និង លក្ខខណ្ឌបច្ចេកទេសដែលត្រូវមានប្រភពតែមួយគត់
- ករណីចាំបាច់សម្រាប់ឆ្លើយតបនៅពេលមានគ្រោះមហន្តរាយធម្មជាតិកើតឡើង និង/ឬ តម្រូវការចាំបាច់បន្ទាន់រយៈពេលខ្លី មិនណាចរង់ចាំអោយប្រើវិធីសាស្ត្រផ្សេងទៀតបាន
- សម្រាប់គោលបំណងសិក្សាស្រាវជ្រាវដកយកបទពិសោធន៍ ឬ អភិវឌ្ឍន៍
- ការប្រកួតប្រជែងដេញថ្លៃត្រូវខកខានយ៉ាងហោចណាស់ពីរដងរួចមកហើយ ដោយមូលហេតុមកពីខ្វះអ្នកចូលរួមដេញថ្លៃ ឬពុំមានការឆ្លើយតបក្នុងការដេញថ្លៃ ។

សម្រាប់ធនាគារទាំងពីរ ការអនុវត្តវិធីសាស្ត្រនេះត្រូវមានលក្ខណៈពិសេសដោយឡែក និងត្រូវមានការអនុញ្ញាតជាមុន ចំពោះការទិញទំនិញ ផ្នែកការងារសាធារណៈការពុំចាំបាច់មានការអនុញ្ញាតទេ ។

### ៣.៣.៣.២. ការចុះកិច្ចសន្យាជាមួយអង្គភាពជំនាញនៃស្ថាប័នអនុវត្តលទ្ធកម្ម

**ការចុះកិច្ចសន្យាជាមួយអង្គភាពជំនាញនៃស្ថាប័នអនុវត្តលទ្ធកម្ម** ត្រូវអនុវត្តជាមួយអង្គភាពជំនាញរបស់រដ្ឋដែលមានស្រាប់នូវធនធាន កម្លាំងពលកម្ម បច្ចេកទេសជំនាញ និង ឧបករណ៍សម្រាប់បំពេញការងារក្នុងគម្រោងនេះ ។ វិធីសាស្ត្រនេះអាចអនុវត្តក្នុងករណីដែល ÷

- បរិមាណការងារមិនអាចកំណត់បានជាមុន
- ការងារមានទំហំតូច ឬ ទីកន្លែងមិនអំណោយផល ហើយមានភូមិសាស្ត្រដាច់ស្រយាល ដែលមិនអាចទាក់ទាញក្រុមហ៊ុនសាងសង់អោយចូលរួមដេញថ្លៃ
- ការងារដែលត្រូវធ្វើបន្ថែម ដើម្បីជៀសវាងការខកខានដល់ការងារដែលកំពុងដំណើរការ
- ហានិភ័យនៃការពន្យារពេលដែលកើតឡើងជាបន្ទុករបស់រាជរដ្ឋាភិបាល ជាជាងបន្ទុករបស់អ្នកម៉ៅការឯកជន
- មានគ្រោះមហន្តរាយធម្មជាតិ ឬ តម្រូវការបន្ទាន់ដែលត្រូវយកចិត្តទុកដាក់ ។

### ៣.៣.៣.៣. លទ្ធកម្មភាគកម្មសហគមន៍

**លទ្ធកម្មភាគកម្មសហគមន៍** ត្រូវបានប្រើប្រាស់ ដើម្បីសម្រេចបាននូវគោលដៅរបស់សង្គមដ៏ជាក់លាក់នៅពេលណាមានការជ្រើសរើសសមាសភាគនៃគម្រោងចំពោះគម្រោងដូចខាងក្រោម ÷



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

- ការអំពាវនាវអោយមានការចូលរួមពីសហគមន៍ក្នុងស្រុក ឬ អង្គការក្រៅរដ្ឋាភិបាល ក្នុងការផ្តល់សេវា
- បង្កើនការប្រើប្រាស់ចំណេះដឹង និង សម្ភារៈក្នុងស្រុក
- ការប្រមូលផ្តុំប្រើប្រាស់ពលកម្ម និងសម្ភារៈបច្ចេកទេសសមស្របជាមួយសេដ្ឋកិច្ចក្នុងស្រុក ។

## ៣.៤. ការរៀបចំនីតិវិធី (សម្រាប់ការផ្គត់ផ្គង់ ការសាងសង់ និង គម្រោងសាធារណៈការ)

### ៣.៤.១. ការរៀបចំផែនការលទ្ធកម្ម

នៅក្នុង **សារាចរណែនាំ** លេខ ០០៦ ហសវ ចុះថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០០៧ **ស្តីពីការរៀបចំផែនការលទ្ធកម្មឆ្នាំ ២០០៨ និង ឆ្នាំបន្តបន្ទាប់** ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុតម្រូវអោយក្រសួង- ស្ថាប័ន និង ខេត្ត- ក្រុងទាំងអស់រៀបចំធ្វើផែនការលទ្ធកម្ម ដើម្បីដាក់ជូនក្រសួងអនុម័តនៅដើមឆ្នាំនីមួយៗ ក្នុងគោលដៅលើកកំពស់ពង្រឹងយន្តការគ្រប់គ្រងចំណាយថវិការដ្ឋ អោយមានតម្លាភាព គណនេយ្យភាព និង ប្រសិទ្ធភាពខ្ពស់ ។ ផែនការលទ្ធកម្មផ្តល់នូវអត្ថប្រយោជន៍ដូចតទៅ ÷

- ជម្រុញការគ្រប់គ្រង ការតាមដាន និង លើកកំពស់ការអនុវត្តកិច្ចលទ្ធកម្មអោយកាន់តែមានប្រសិទ្ធភាពខ្ពស់
- បង្ហាញអោយដឹងពីតម្រូវការទំនិញ សំណង់ សេវា ទាំងបរិមាណ និង តម្លៃសរុបប្រចាំឆ្នាំរបស់ស្ថាប័ននីមួយៗ
- ដឹងចំនួនកិច្ចលទ្ធកម្ម តម្លៃគម្រោងនីមួយៗ តាមវិធីសាស្ត្រ និង តាមមុខសញ្ញា និង តាមប្រភេទលទ្ធកម្ម

ការរៀបចំធ្វើផែនការលទ្ធកម្មត្រូវបានបែងចែកជាដំណាក់កាល ដូចខាងក្រោម÷

ទីមួយ- **បុរេលក្ខណៈសម្បត្តិ (ករណីចាំបាច់)**

- ការរៀបចំយថាប្រភេទ និងការប៉ាន់ស្មានតម្លៃគម្រោង

- ការរៀបចំឯកសារបុរេលក្ខណៈសម្បត្តិ

- ការរៀបចំលិខិតជូនដំណឹង ដើម្បីផ្សព្វផ្សាយ

- ការផ្សព្វផ្សាយ លក់ ទទួល បើកឯកសារបុរេលក្ខណៈសម្បត្តិ

- ការវាយតម្លៃជ្រើសរើសក្រុមហ៊ុន ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់

ទីពីរ- **ដំណាក់កាលរៀបចំឯកសារដេញថ្លៃ**



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

- ការរៀបចំឯកសារដេញថ្លៃ

- ការអនុម័តលើឯកសារដេញថ្លៃ (ក្រោមសិទ្ធិសម្រេច)

- ការផ្តល់ទិដ្ឋាការយល់ព្រមលើឯកសារដេញថ្លៃ ដោយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ (ករណីលើសសិទ្ធិសម្រេច)

ទីបី- **ដំណាក់កាលផ្សព្វផ្សាយ និង បើកឯកសារដេញថ្លៃ**

- ការរៀបចំលិខិតជូនដំណឹងស្តីពីដំណើរការកិច្ចលទ្ធកម្ម

- ការផ្សព្វផ្សាយ (លក់ ទទួល បើកឯកសារដេញថ្លៃ)

- ការចែកកំណត់ហេតុបើកឯកសារដេញថ្លៃ

ទីបួន- **ដំណាក់កាលវាយតម្លៃ**

- ការរៀបចំវាយតម្លៃលើសំណើដេញថ្លៃ

- ការពិនិត្យ និង ផ្តល់អនុសាសន៍របស់ **គណៈកម្មាធិការកំណត់បុរេលក្ខណៈសម្បត្តិ វាយតម្លៃ និង ប្រគល់កិច្ចសន្យា**

- ការពិនិត្យឡើងវិញ និងផ្តល់អនុសាសន៍របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (ករណីលើសសិទ្ធិសម្រេច)

ទីប្រាំ- **ដំណាក់កាលចុះកិច្ចសន្យា**

- ការធ្វើលិខិតជូនដំណឹងស្តីពីការសម្រេចប្រគល់កិច្ចសន្យា

- ការរៀបចំកិច្ចសន្យា

- ការចុះហត្ថលេខាលើកិច្ចសន្យា

ទីប្រាំមួយ- **ដំណាក់កាលប្រគល់ - ទទួល**

- រយៈពេលប្រគល់- ទទួល (ពេលចាប់ផ្តើម- ពេលបញ្ចប់)

- ចំនួនលើកដែលត្រូវប្រគល់- ទទួល



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

- រយៈពេលធានាគុណភាព

ទីប្រាំពីរ- **ដំណាក់កាលទូទាត់**

- រយៈពេលទូទាត់ (ពេលចាប់ផ្តើម- ពេលបញ្ចប់)

- តម្លៃដែលត្រូវទូទាត់ ក្នុងត្រីមាសនីមួយៗ ។

### ៣.៤.២. ការអនុវត្តវិសហមជ្ឈការកិច្ចលទ្ធកម្មសាធារណៈ

ដោយអនុលោមតាមប្រកាសលេខ ០៤៥ សហវ.ប្រក. ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៥ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុប្រគល់សិទ្ធិសម្រេចទទួលខុសត្រូវលើកិច្ចលទ្ធកម្មសាធារណៈ ជូនក្រសួង ស្ថាប័ន ខេត្ត-ក្រុង និង សហគ្រាសសាធារណៈ ក្នុងកម្រិតទឹកប្រាក់ធានាចំណាយ ដូចខាងក្រោម÷

- ក្រោមទឹកប្រាក់ ២០០ លានរៀល សម្រាប់ថវិកាមន្ទីរជំនាញខេត្ត- ក្រុង
- ក្រោមទឹកប្រាក់ ៣០០ លានរៀល សម្រាប់ថវិកាសាលាខេត្ត- ក្រុង
- ក្រោមទឹកប្រាក់ ៥០០ លានរៀល សម្រាប់ថវិកាក្រសួង- ស្ថាប័ន និង សហគ្រាសាធារណៈលក្ខណៈរដ្ឋបាល
- ក្រោមទឹកប្រាក់ ១.០០០ លានរៀល សម្រាប់ថវិកាក្រសួងអប់រំ យុវជន និង កីឡា ក្រសួងសុខាភិបាល និង សហគ្រាសសាធារណៈលក្ខណៈសេដ្ឋកិច្ច ។

ចំពោះកិច្ចលទ្ធកម្មដែលទឹកប្រាក់លើសពីទឹកប្រាក់កម្រិតសិទ្ធិសម្រេច ក្រសួង- ស្ថាប័ន ខេត្ត- ក្រុង សហគ្រាសសាធារណៈ ត្រូវរក្សាការអនុវត្តវិធីសាស្ត្រ និងនីតិវិធីជាធរមាន ដោយត្រូវបញ្ជូនឯកសារដេញថ្លៃ ឯកសារវាយតម្លៃប្រគល់កិច្ចសន្យា និង កិច្ចសន្យា ដើម្បីសុំការពិនិត្យ ផ្តល់ទិដ្ឋាការ និង ការសម្រេចយល់ព្រមពីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ តាមរយៈនាយកដ្ឋានលទ្ធកម្មសាធារណៈ ។ ការបើកឯកសារដេញថ្លៃ និង ការប្រគល់- ទទួល ត្រូវមានការចូលរួមពីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

### ៣.៤.៣. វិធីសាស្ត្រលទ្ធកម្ម

ជាទូទៅលទ្ធកម្មមានបួនប្រភេទគឺ៖ លទ្ធកម្មទំនិញ លទ្ធកម្មសំណង់ លទ្ធកម្មសេវាកម្ម លទ្ធកម្មទីប្រឹក្សា ។ លទ្ធកម្មទាំងនេះមានវិធីសាស្ត្រអនុវត្ត ៤ ធំៗ គឺ ការដេញថ្លៃដោយប្រកួតប្រជែងជាលក្ខណៈអន្តរជាតិ ការដេញថ្លៃដោយប្រកួតប្រជែងក្នុងស្រុក ការពិគ្រោះថ្លៃ និង ការស្នងតម្លៃ ។


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ក្នុងករណីការប្រកាសដេញថ្លៃចំហ (ការដេញថ្លៃដោយប្រកួតប្រជែងជាលក្ខណៈអន្តរជាតិ និង ការដេញថ្លៃដោយប្រកួតប្រជែងក្នុងស្រុក) គឺអនុវត្តវិធានសម្រាប់លទ្ធកម្មសាធារណៈធម្មតា ។ សេចក្តីប្រកាសដេញថ្លៃត្រូវចុះផ្សាយក្នុងទំព័រសារព័ត៌មាន ។

ក្នុងករណីការប្រកាសឱ្យដេញថ្លៃជាលក្ខណៈមិនចំហ គឺមានតែបេក្ខជនត្រូវបានជ្រើសរើសប៉ុណ្ណោះដែលអនុញ្ញាត (យ៉ាងហោចណាស់ក៏ត្រូវមានបេក្ខជនបីនាក់ ប៉ុន្តែបេក្ខជនទាំងអស់ត្រូវតាមដានកិច្ចពិគ្រោះដែលអាចធ្វើឡើងដោយលទ្ធកម្ម មាត្រា ៣ នៃវិធាន និងបទប្បញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈ) ដែលអាចទទួលបាន (ដោយផ្ទាល់) នូវការកោះអញ្ជើញចូលរួមដេញថ្លៃដោយសាមញ្ញបំផុត ប៉ុន្តែត្រូវតែបញ្ជាក់អោយច្បាស់លាស់អំពីលក្ខខណ្ឌនៃការចុះកិច្ចសន្យារួមគ្នា ។

នៅពេលអនុវត្តនីតិវិធី **ការពិគ្រោះថ្លៃ** ត្រូវអញ្ជើញអ្នកផ្គត់ផ្គង់ ឬ អ្នកទទួលការអោយដាក់តម្លៃដែលបិទជិត ហើយការបើកសំណើពិគ្រោះថ្លៃត្រូវធ្វើឡើងជាសាធារណៈ ។ លិខិតអញ្ជើញត្រូវបានផ្ញើអោយអ្នកផ្គត់ផ្គង់ ឬ អ្នកទទួលការចំនួនមិនតិចជាងបី ហើយត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈនៅថ្នាក់ជាតិ ឬ ថ្នាក់ខេត្ត និង ត្រូវបើកចំហសម្រាប់អ្នកដេញថ្លៃទាំងអស់ ដែលចង់ចូលរួម (មាត្រា ៨ នៃអនុក្រឹត្យ ឆ្នាំ ២០០៦) ។

ក្នុងករណី **ការស្ទង់តម្លៃ** ត្រូវទទួល និង ធ្វើការកត់ត្រាយ៉ាងតិចបំផុតចំនួនបីនាក់ តាមរយៈទូរស័ព្ទ និង ការសួរផ្ទាល់មាត់ពីក្រុមហ៊ុន ឬ ពីប្រភពណាមួយ ដោយធ្វើកំណត់ហេតុ និង ត្រូវចុះកិច្ចសន្យា ជាមួយក្រុមហ៊ុន ឬ បុគ្គលដែលផ្តលវិក័យប័ត្រជាទម្រង់ ឬ បញ្ជីប៉ាន់តម្លៃទាបសមស្របជាងគេបំផុត (មាត្រា ៨ នៃអនុក្រឹត្យ ឆ្នាំ ២០០៦) ។

ការរៀបចំឯកសារពិគ្រោះ ព័ត៌មានអ្នកដេញថ្លៃ និងបេក្ខភាព ត្រូវស្ថិតនៅក្រោមការទទួលខុសត្រូវរបស់អង្គភាពលទ្ធកម្មសាធារណៈ ដែលបង្កើតឡើងដោយស្ថាប័នអនុវត្តលទ្ធកម្មផ្ទាល់ (មាត្រា ២១ នៃអនុក្រឹត្យ និង មាត្រា ១៩ នៃបទប្បញ្ញត្តិ និងវិធានស្តីពីលទ្ធកម្មសាធារណៈ) ។

ចំពោះកិច្ចលទ្ធកម្មដែលត្រូវអនុវត្តតាមវិធីសាស្រ្តដោយឡែក រួមមានៈ ការចុះកិច្ចសន្យាផ្ទាល់ លទ្ធកម្មភាគកម្មសហគមន៍ និងការចុះកិច្ចសន្យាជាមួយអង្គភាពជំនាញនៃស្ថាប័នអនុវត្តលទ្ធកម្ម ស្ថាប័នអនុវត្តលទ្ធកម្មត្រូវសុំការយល់ព្រមជាមុនពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមរយៈនាយកដ្ឋានលទ្ធកម្មសាធារណៈ (មាត្រា ៧.៣.៤ នៃបទប្បញ្ញត្តិ និងវិធានស្តីពីលទ្ធកម្មសាធារណៈ) ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

### ៣.៤.៤. ការកំណត់បុរេលក្ខណៈសម្បត្តិ

**ការកំណត់បុរេលក្ខណៈសម្បត្តិ** របស់អ្នកដេញថ្លៃ អ្នកផ្គត់ផ្គង់ ឬ អ្នកទទួលការដែលមានសក្តានុពល មិនត្រូវធ្វើឡើងសម្រាប់គ្រប់កិច្ចលទ្ធកម្មទំនិញ និង ការងារសាងសង់ទាំងអស់ទេ ។ ការកំណត់បុរេលក្ខណៈសម្បត្តិត្រូវធ្វើឡើងចំពោះតែកិច្ចលទ្ធកម្មដែលមានទឹកប្រាក់ធំ ហើយមានលក្ខណៈស្មុគ្រស្មាញ ឬ ក្នុងកាលៈទេសៈដែលការរៀបចំសំណើដេញថ្លៃត្រូវចំណាយថវិកាច្រើន ដូចជាការផ្គត់ផ្គង់បរិក្ខារតាមបញ្ជាអ្នកទិញ សំណង់រោងចក្រឧស្សាហកម្ម សេវាកម្មពិសេស បច្ចេកវិទ្យា និងព័ត៌មានវិទ្យាស្មុគ្រស្មាញ និង កិច្ចសន្យាមានលក្ខណៈស្មុគ្រស្មាញ ។ ចំពោះការងារនេះ ការអញ្ជើញអោយចូលរួមដេញថ្លៃ ធ្វើឡើងតែចំពោះអ្នកដេញថ្លៃទាំងឡាយណាដែលមានសមត្ថភាព និងធនធានគ្រប់គ្រាន់ប៉ុណ្ណោះ ដើម្បីធានាថា អ្នកទាំងនោះអាចអនុវត្តបានត្រឹមត្រូវតាមកិច្ចសន្យា ។

**ក- បុរេលក្ខណៈសម្បត្តិក្នុងការផ្តល់វិញ្ញាបនប័ត្រ** : ដើម្បីមានសិទ្ធិចូលរួមក្នុងគម្រោងដេញថ្លៃការសាងសង់ណាមួយ អ្នកទទួលការសាងសង់ត្រូវតែទទួលការចុះបញ្ជីបែងចែកប្រភេទការងារសាងសង់ និង ចំណាត់ថ្នាក់តូច មធ្យម ធំ ដោយយោងតាមសមត្ថភាពអនុវត្តរបស់ក្រុមហ៊ុនក្នុងរយៈពេល ៣ ឆ្នាំចុងក្រោយ ។ ការបែងចែកប្រភេទ និងចំណាត់ថ្នាក់នេះ ត្រូវធ្វើឡើងដោយគណៈកម្មការមួយដែលតែងតាំងឡើងដោយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ តាមសំណើរបស់ក្រសួង- ស្ថាប័នជំនាញដែលចូលរួម ។ ការកំណត់បុរេលក្ខណៈសម្បត្តិត្រូវពិនិត្យ ពិចារណាទៅលើៈ ទី១- បទពិសោធន៍ និង អតីតភាពការងារ ទី២- សមត្ថភាព (បុគ្គលិក ឧបករណ៍មធ្យោបាយសម្រាប់ផលិតកម្ម ឬ មធ្យោបាយសម្រាប់ការងារសាងសង់) និង ទី៣- ស្ថានភាពហិរញ្ញវត្ថុ ។ វិញ្ញាបនប័ត្រដែលផ្តល់ជូនក្រុមហ៊ុនមានសុពលភាពតែក្នុងរយៈពេលមួយជាកំណត់ និងអាចបន្តសារជាថ្មីបាន ។

**ខ- បុរេលក្ខណៈសម្បត្តិមុនការដេញថ្លៃ:** ចំពោះលទ្ធកម្មទំនិញ ឬ សំណង់ធំៗ ដែលមានលក្ខណៈស្មុគ្រស្មាញ ហើយត្រូវចំណាយថវិកាច្រើន ត្រូវធ្វើការផ្សព្វផ្សាយអញ្ជើញអោយក្រុមហ៊ុនចូលរួម ដើម្បីធ្វើបុរេលក្ខណៈសម្បត្តិ ។ ការផ្សព្វផ្សាយត្រូវបានធ្វើឡើងនៅក្នុងទំព័រសារព័ត៌មាន ជាភាសាខ្មែរ និង អង់គ្លេស ដោយមានសេចក្តីចម្លងផ្ញើទៅស្ថានទូត ស្ថានកុងស៊ុល និង ភ្នាក់ងារពាណិជ្ជកម្មអន្តរជាតិនៃបណ្តាប្រទេស ដែលមានសក្តានុពលពាក់ព័ន្ធ (កិច្ចសន្យាអន្តរជាតិ មាត្រា ៨.៣.២. នៃវិធាន និង បទប្បញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈ) ។ គ្រប់អ្នកដាក់ពាក្យសុំទាំងអស់ដែលបានបំពេញតាមលក្ខខណ្ឌវិនិច្ឆ័យកំណត់ ត្រូវបានទទួលការអនុញ្ញាតអោយចូលរួមដេញថ្លៃ ហើយឯកសារដេញថ្លៃក៏ត្រូវជូនទៅអ្នកដេញថ្លៃ ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ។

ម្យ៉ាងទៀត **បុរេលក្ខណៈសម្បត្តិ**ជាសមត្ថកិច្ចនៃ **គណៈកម្មាធិការកំណត់បុរេលក្ខណៈសម្បត្តិ វាយតម្លៃ និង ប្រគល់កិច្ចសន្យា** (មាត្រា ២០ នៃអនុក្រឹត្យស្តីពីលទ្ធកម្មសាធារណៈ ឆ្នាំ ២០០៦) ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

**សៀវភៅបន្ទុក**

នៅប្រទេសបារាំង ឯកសារដេញថ្លៃត្រូវបានរៀបចំឡើង តាមលំដាប់លំដោយឯកសារជាអាទិភាព ពីធំទៅតូចៈ

- លិខិតធានាអះអាង (នៃអ្នកដេញថ្លៃ ក្នុងការអនុវត្តសៀវភៅបន្ទុក) ។
- ការបញ្ជាក់លក្ខណៈរដ្ឋបាលពិសេស ដែលជាការមិនអនុវត្តតាមសៀវភៅបន្ទុក សម្រាប់ការអនុវត្តកិច្ចលទ្ធកម្ម ។
- ការបញ្ជាក់លក្ខណៈបច្ចេកទេស ដែលបញ្ជាក់អំពីលក្ខណៈលម្អិតនៃទំនិញ សំណង់ និង សេវា ដែលស្ថាប័នអនុវត្តលទ្ធកម្មចង់បាន ។
- ចំពោះគម្រោងសាងសង់ដែលមានលក្ខណៈស្មុគស្មាញ ត្រូវមានគំនូសប្លង់ ការគណនាបច្ចេកទេស បទដ្ឋានបច្ចេកទេស បទដ្ឋានបច្ចេកទេសភូគព្ភសាស្ត្រ ។
- ប្រសិនបើកិច្ចសន្យានេះមិនបានបញ្ជាក់ពីការទូទាត់សរុប ហើយការផ្គត់ផ្គង់ត្រូវប្រើប្រាស់នូវថ្លៃសរុបពិសេស ត្រូវមានបញ្ជាក់ពីថ្លៃសរុប តារាងបញ្ជីថ្លៃឯកតាតាមរាយមុខទំនិញ ។
- ត្រូវមានតារាងប៉ាន់ស្មាននៃថ្លៃតាមបញ្ជីលម្អិតសម្រាប់ទំនិញ ។

## ៣.៤.៥. ការរៀបចំលក្ខណៈបច្ចេកទេស

ជំហានដំបូង នៃនីតិវិធីលទ្ធកម្មសាធារណៈ គឺការបញ្ជាក់លក្ខណៈបច្ចេកទេសលម្អិតនៃទំនិញ សំណង់ និង សេវា ដែលស្ថាប័នអនុវត្តលទ្ធកម្មចង់បាន ។ ការបញ្ជាក់លក្ខណៈបច្ចេកទេស គឺជារបាយការណ៍ស្តីពីគុណភាព ឬ លក្ខណៈចាំបាច់ពិសេសទាំងអស់នៃផលិតផល ឬ សេវា ព័ត៌មានស្តីពីសេចក្តីត្រូវការ មធ្យោបាយសម្រាប់ប្រៀបធៀបសំណើដេញថ្លៃ ការពិពណ៌នាអំពីសមត្ថភាពអនុវត្តដែលចង់បាន ។ ចំពោះទំនិញខ្លះ ត្រូវមានប៉ាន់គំរូទំនិញ រូបគំនូរដែលត្រូវធ្វើលទ្ធកម្ម ។ ចំពោះកិច្ចសន្យាសំណង់ត្រូវមានបទដ្ឋាន ដូចជាបទដ្ឋានទឹកដៃ បទដ្ឋានសម្ភារៈវត្ថុធាតុដើម និង បទដ្ឋាននៃការអនុវត្តការងារ ។

## ៣.៤.៦. នីតិវិធីនៃការរៀបចំឯកសារដេញថ្លៃ

ឯកសារដេញថ្លៃត្រូវរៀបរាប់អំពីការធ្វើតេស្តអំពីបទដ្ឋាន និង វិធីសាស្ត្រត្រួតពិនិត្យ និង វាយតម្លៃ ដែលជាឧបករណ៍ប្រើសម្រាប់វិនិច្ឆ័យពីភាពឆ្លើយតបនៃទំនិញដែលទទួលបាន ឬ ការងារសាងសង់ដែលត្រូវអនុវត្ត ។

### ៣.៤.៦.១. សេចក្តីណែនាំចំពោះអ្នកដេញថ្លៃ

សេចក្តីណែនាំត្រូវមានព័ត៌មានសំខាន់ៗដូចជា ពិពណ៌នាទូទៅអំពីទំនិញ បរិក្ខារ និងសេវាដែលត្រូវការ ទំហំនៃសំណើដេញថ្លៃ ឬ សំណើទីប្រឹក្សា សេចក្តីណែនាំសម្រាប់បំពេញឯកសារដេញថ្លៃ ទីកន្លែង ពេលវេលា និង កាលបរិច្ឆេទសម្រាប់សន្និសីទមុនដេញថ្លៃ នីតិវិធីដាក់សំណើដេញថ្លៃ នីតិវិធីបើកសំណើដេញថ្លៃ កាលបរិច្ឆេទ


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ពេលវេលា និងទីកន្លែងសម្រាប់ទទួលសំណើ និងបើកសំណើដេញថ្លៃ រយៈពេលសុពលភាព ការរៀបរាប់លម្អិតអំពីការកែតម្រូវសំណើដេញថ្លៃ នីតិវិធីសម្រាប់រៀបចំបង្កើតកិច្ចសន្យា សិទ្ធិក្នុងការកែប្រែបរិមាណទំនិញ រូបិយប័ណ្ណដែលទទួលស្គាល់ ឯកសារផ្សេងៗដែលត្រូវភ្ជាប់ ។

### ៣.៤.៦.២. លក្ខខណ្ឌទូទៅ និង លក្ខខណ្ឌពិសេសនៃកិច្ចសន្យា

លក្ខខណ្ឌទូទៅនៃកិច្ចសន្យាត្រូវភ្ជាប់ជានិច្ចជាមួយឯកសារដេញថ្លៃ ដូចជាៈ សិទ្ធិ និងកាតព្វកិច្ចរបស់ភាគីហត្ថលេខី ប្រភពដើមនៃទំនិញ សំណង់ និងសេវា ប្រាក់កក់ធានាការអនុវត្ត ការសាកល្បង និងការត្រួតពិនិត្យការវេចខ្ចប់ រយៈពេលប្រគល់- ទទួល ការធានាគុណភាព លក្ខខណ្ឌទូទាត់ តម្លៃនៃកិច្ចសន្យា ការយឺតយ៉ាវក្នុងការអនុវត្ត ការបញ្ចប់កិច្ចសន្យា ករណីប្រធានស័ក្តិ ពន្ធដារ និង ពន្ធគយ ។

លក្ខខណ្ឌទូទៅមិនអាចកែប្រែបានទេ ។ តែកិច្ចលទ្ធកម្មនីមួយៗខុសប្លែកពីគ្នា ដែលទាមទារអោយមានលក្ខខណ្ឌពិសេស ដែលនឹងត្រូវអនុវត្តបានតែកិច្ចសន្យាមួយប៉ុណ្ណោះ ។

ប្រាក់កក់ធានាការដេញថ្លៃត្រូវមានយ៉ាងតិចពី ២% នៃតម្លៃដាក់ដេញថ្លៃ ។ ប្រាក់កក់ធានាការអនុវត្តកិច្ចសន្យាត្រូវស្មើ ១០% នៃតម្លៃសរុបនៃកិច្ចសន្យា ។

## ៣.៤.៧. ដំណើរការដេញថ្លៃ

### ៣.៤.៧.១. រយៈពេលផ្សព្វផ្សាយលក់ និង ទទួលឯកសារ

អ្នកដេញថ្លៃត្រូវមានថិរវេលាគ្រប់គ្រាន់ សម្រាប់រៀបចំឯកសារដេញថ្លៃរបស់ខ្លួន ។ បទប្បញ្ញត្តិ និងវិធានស្តីពីលទ្ធកម្មសាធារណៈកំណត់រយៈពេលផ្សព្វផ្សាយ និងទទួលឯកសារយ៉ាងតិច ៦០ថ្ងៃ ប្រសិនកិច្ចការនោះមានលក្ខណៈស្មុគស្មាញ សម្រាប់ការប្រកាសដេញថ្លៃប្រកួតប្រជែងលក្ខណៈអន្តរជាតិ និង ៣០ ថ្ងៃ សម្រាប់ការដេញថ្លៃដោយប្រកួតប្រជែងក្នុងស្រុក និង ១៥ ថ្ងៃ សម្រាប់វិធីសាស្ត្រពិគ្រោះថ្លៃ ។ ថិរវេលានេះចាប់គិតចាប់ពីកាលបរិច្ឆេទនៃការផ្សព្វផ្សាយអញ្ជើញក្រុមហ៊ុន អោយចូលរួមដេញថ្លៃ (មាត្រា ៣.១០.២.នៃវិធាន និង បទប្បញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈ)។

ថិរវេលាដែលខ្លីពេក គឺមិនអាចអោយមានការរៀបចំការដេញថ្លៃ ដែលប្រសើរបានឡើយជាពិសេសលក្ខណៈបច្ចេកទេស និង ការរៀបចំហិរញ្ញវត្ថុអោយបានត្រឹមត្រូវ ។ ការរៀបចំដែលឆាប់រហ័សពេកចុងក្រោយ គឺប៉ះពាល់ធ្ងន់ធ្ងរ ដល់អ្នកទិញសាធារណៈ ។


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

### ថ្លៃលក់ឯកសារដេញថ្លៃ

ឯកសារដេញថ្លៃត្រូវលក់អោយអ្នកដែលមានបំណងចូលរួមដេញថ្លៃ ដើម្បីទូទាត់ថ្លៃផលិត និង ថ្លៃផ្សព្វផ្សាយ និង ចំណាយពាក់ព័ន្ធផ្សេងទៀត ។ ចំពោះឯកសារដេញថ្លៃសម្រាប់ជ្រើសរើសទីប្រឹក្សា ត្រូវផ្តល់អោយក្រុមហ៊ុនដែលមាននៅក្នុងបញ្ជីជ្រើសរើស ដោយឥតគិតថ្លៃ ។ ថ្លៃលក់ឯកសារមានដូចតទៅ ÷

- ឯកសារដេញថ្លៃដោយប្រកួតប្រជែងក្នុងស្រុក: ២.០០០ រៀល ក្នុងមួយទំព័រ បូកថែម ២៤០.០០០ រៀល ក្នុងមួយឯកសារ ។
- ឯកសារដេញថ្លៃដោយប្រកួតប្រជែងជាលក្ខណៈអន្តរជាតិ: ២.០០០ រៀល ក្នុងមួយទំព័រ បូកថែម ៦៤០.០០០ រៀល ក្នុងមួយឯកសារ ។
- ថ្លៃលក់ឯកសារនេះអាចនឹងប្រែប្រួលតាមការជាក់ស្តែង ។

### ៣.៤.៧.២. ការទទួល និងការរក្សាទុកសំណើរដេញថ្លៃ

នៅពេលទទួលសំណើដេញថ្លៃរួម អង្គភាពលទ្ធកម្មត្រូវមានភារកិច្ចទុកដាក់ឯកសារទាំងនេះ នៅទីតាំងដែលមានសុវត្ថិភាព និង ត្រូវរក្សាទុកនៅក្នុងប្រអប់ចាក់សោ ។ នៅពេលបើកសំណើដេញថ្លៃ ប្រអប់ដេញថ្លៃដែលនៅបិទជិតនោះត្រូវបានបញ្ជូនទៅទីតាំងបើកឯកសារដេញថ្លៃ (មាត្រា ៣.១០. នៃវិធាន និង បទប្បញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈ) ។

### ៣.៤.៨. នីតិវិធីបើកសំណើរដេញថ្លៃ

ការបើកឯកសារដេញថ្លៃត្រូវធ្វើឡើងភ្លាមៗ ក្រោយកាលបរិច្ឆេទបញ្ចប់ការទទួលឯកសារដេញថ្លៃ និង ត្រូវធ្វើឡើងជាសាធារណៈ ដើម្បីអោយសាធារណៈជនអាចដឹងថា ស្ថាប័នអនុវត្តលទ្ធកម្មអនុវត្តបានត្រឹមត្រូវ ដោយសេរី និងមានការប្រកួតប្រជែងដោយយុត្តិធម៌ (មាត្រា ១២ នៃអនុក្រឹត្យ ឆ្នាំ ២០០៦ និង មាត្រា ៣.១១. នៃបទប្បញ្ញត្តិ និងវិធានស្តីពីលទ្ធកម្មសាធារណៈ) ។

ការបើកឯកសារដេញថ្លៃត្រូវធ្វើកំណត់ហេតុ និង ត្រូវផ្តល់កំណត់ហេតុនោះ អោយក្រុមហ៊ុនទាំងអស់ដែលបានដាក់សំណើសុំដេញថ្លៃ ។ កំណត់ហេតុបើកឯកសារដេញថ្លៃ ត្រូវកត់ត្រាយ៉ាងហោចណាស់ ÷ ឈ្មោះ និង សញ្ជាតិអ្នកដេញថ្លៃ តម្លៃដាក់ដេញថ្លៃ សុពលភាពឯកសារដេញថ្លៃ វត្តមានអ្នកចូលរួម ចំនួនប្រាក់កក់ដេញថ្លៃ និង សុពលភាពប្រាក់កក់ធានាការដេញថ្លៃ (មាត្រា ១១ នៃអនុក្រឹត្យ ឆ្នាំ ២០០៦ និងមាត្រា ៣.១១. នៃបទប្បញ្ញត្តិ និងវិធានស្តីពីលទ្ធកម្មសាធារណៈ) ។ អ្នកដេញថ្លៃ ឬ បេក្ខជនត្រូវមានវត្តមាន ចុះហត្ថលេខាក្នុងបញ្ជីចូលរួមបើកឯកសារដេញថ្លៃ (មាត្រា ៣.១១. នៃវិធាន និងបទប្បញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈ) ។

ការងារបើកឯកសារដេញថ្លៃ ស្ថិតក្រោមការទទួលខុសត្រូវរបស់ប្រធាន **គណៈកម្មាធិការកំណត់**



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

***ដំណើរការដេញថ្លៃ***

នៅពេលទទួលសំណើដេញថ្លៃរួច អង្គភាពលទ្ធកម្មត្រូវរក្សាទុកឯកសារទាំងនោះនៅក្នុងប្រអប់ចាក់សោរ ។ នៅពេលបើកសំណើដេញថ្លៃ ប្រអប់ដេញថ្លៃដែលនៅបិទជិតនោះ ត្រូវបញ្ជូនទៅទីតាំង ដែលបានជ្រើសរើសសម្រាប់ការបើកសំណើដេញថ្លៃ ។

ការបើកសំណើដេញថ្លៃត្រូវធ្វើឡើងជាសាធារណៈ ដើម្បីធានាថា ដំណើរការលទ្ធកម្មប្រព្រឹត្តទៅ ដោយសេរី និងយុត្តិធម៌ ដោយផ្តល់អោយអ្នកចូលរួមដេញថ្លៃនូវឱកាសស្មើៗគ្នា ក្នុងការទទួលបាននូវកិច្ចសន្យា និង មានការប្រកួតប្រជែងបានពេញលេញ ។

អ្នកចូលរួមត្រូវបានអញ្ជើញអោយពិនិត្យមើលប្រអប់ដាក់សំណើរដេញថ្លៃរបស់ខ្លួន ដើម្បីប្រាកដថាសំណើទាំងនោះមិនត្រូវបានគេលួចបើកមើល ។ នៅពេលអ្នកចូលរួមបានពិនិត្យគ្រប់សព្វហើយ ប្រធានគណកម្មការបើកឯកសារដេញថ្លៃ ត្រូវប្រកាសចាប់ផ្តើមបើកសំណើដេញថ្លៃ ហើយកាត់ឃ្លុំបេ និងចាក់សោរបើកប្រអប់ដាក់សំណើដេញថ្លៃនីមួយៗ ។

នៅពេលដែលសំណើដេញថ្លៃត្រូវបានបើកមើល ហើយខ្លឹមសាររបស់វាត្រូវបានប្រកាស អ្នកចូលរួមអាចចោទសួរក្នុងរយៈពេលខ្លី ។

**លក្ខណៈសម្បត្តិ វាយតម្លៃ និង ប្រគល់កិច្ចសន្យា** (PEAC) (មាត្រា ៣.១១. នៃបទប្បញ្ញត្តិ និងវិធានស្តីពីលទ្ធកម្មសាធារណៈ) ។

### ៣.៤.៩. ការវាយតម្លៃឯកសារដេញថ្លៃ

ការវាយតម្លៃឯកសារដេញថ្លៃត្រូវផ្អែកលើមូលដ្ឋាននៃលក្ខខណ្ឌវិនិច្ឆ័យ ដែលបានបញ្ជាក់នៅក្នុងឯកសារដេញថ្លៃ ។ មានវិធីសាស្ត្រក្នុងការវាយតម្លៃបីប្រភេទដែលអាចយកមកប្រើប្រាស់ ៖

- **ការអនុលោមតាម**- សម្រាប់ការវាយតម្លៃលទ្ធកម្មទំនិញ ឬ សំណង់
- **ការប្រតិបត្តិ**- សម្រាប់ការវាយតម្លៃលទ្ធកម្មទំនិញ ឬ សំណង់
- **ពិន្ទុគុណសម្បត្តិ**- សម្រាប់វាយតម្លៃលទ្ធកម្មនៃរោងចក្រឧស្សាហកម្មប្រមូលផ្តុំ ដែលមានភាពស្មុគស្មាញខ្ពស់ ឬ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដែលមានភាពស្មុគស្មាញ ។

**ដំណើរការវាយតម្លៃ** គួរចាប់ផ្តើមជាបន្ទាន់ បន្ទាប់ពីពិធីបើកឯកសារដេញថ្លៃ ។ គោលបំណងនៃការត្រួតពិនិត្យជាបឋម គឺដើម្បីកំណត់ និងបដិសេធឯកសារដេញថ្លៃដែលមិនគ្រប់គ្រាន់ អសុពលភាព ឬ មិនឆ្លើយតបពេញលេញទៅនឹងលក្ខខណ្ឌនៃឯកសារដេញថ្លៃ ហើយសំណើដេញថ្លៃទាំងនេះ មិនត្រូវបានយកមកពិចារណាបន្ថែមទៀតទេ ។



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

**ចំណុចសំខាន់ៗកិច្ចសន្យា**

កិច្ចសន្យាត្រូវមានចំណុចសំខាន់ៗដូចតទៅ៖

- ប្រសិទ្ធភាពនៃកិច្ចសន្យា
- ការប្រគល់ និងការផ្ទេរអធិការកិច្ចលើទំនិញ
- ការទាមទារសំណងធានារ៉ាប់រង
- ការទូទាត់អោយអ្នកផ្គត់ផ្គង់ ឬ អ្នកទទួលម៉ៅការ
- ការត្រួតពិនិត្យការអនុវត្តសម្រាប់សេវាកម្ម និង សំណង់
- វិវាទនៃកិច្ចសន្យា
- ការយឺតយ៉ាវក្នុងការអនុវត្ត
- ការទាមទារសំណងសម្រាប់ការខូចខាត
- ការចូលកាន់កាប់ជាបឋម និង ជាស្ថាពរលើសំណង់
- ការដំឡើង និង ការចាប់ផ្តើមការប្រើប្រាស់គ្រឿងបរិក្ខារ
- ការទទួលយកនូវលទ្ធផលការងាររបស់ទីប្រឹក្សា
- ការបង្វិលប្រាក់កក់ធានាការអនុវត្ត និង ប្រាក់បង្កកទុក
- ការបញ្ចប់កិច្ចសន្យា

ប្រសិនបើសំណើដេញថ្លៃមិនមានការឆ្លើយតបពេញលេញ មានន័យថាសំណើដេញថ្លៃនោះមានការខុសគ្នាច្រើនរវាង យថាប្រភេទ លក្ខខណ្ឌ និង លក្ខណៈបច្ចេកទេសនៅក្នុងឯកសារដេញថ្លៃ ។ ដូច្នេះ សំណើដេញថ្លៃនោះមិនត្រូវយកមកពិចារណាបន្ថែមទៀតទេ ។ អ្នកវាយតម្លៃត្រូវពិនិត្យអោយឃើញថាសំណើដេញថ្លៃ គឺជាសំណើដែលមានលក្ខណៈគ្រប់គ្រាន់ ហើយអ្នកដេញថ្លៃនោះមានសមត្ថភាពអនុវត្តតាមលក្ខខណ្ឌនៃដំណើរការដេញថ្លៃ និងលក្ខខណ្ឌនៃកិច្ចសន្យា ។ អ្នកវាយតម្លៃត្រូវពិនិត្យថា ក្រុមហ៊ុន ឬ បុគ្គលដែលចូលរួមប្រកួតប្រជែង មិនមានឈ្មោះនៅក្នុងបញ្ជីហាមឃាត់របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។ លិខិតធានាប្រាក់កក់ធានាការដេញថ្លៃ ត្រូវតែមាន ។ ប្រសិនបើអ្នកដេញថ្លៃមិនបានផ្តល់ឱ្យ សំណើដេញថ្លៃនោះត្រូវបានបដិសេធ ។ ការខុសគ្នាច្រើនពេកពីលក្ខខណ្ឌពាណិជ្ជកម្ម និងលក្ខខណ្ឌបច្ចេកទេស គឺជាមូលដ្ឋាននៃការបដិសេធសំណើដេញថ្លៃ ។ សំណើដេញថ្លៃមានការឆ្លើយតបពេញលេញនឹងត្រូវបានធ្វើការប្រៀបធៀប និង វាយតម្លៃ ។ (មាត្រា ៣.១២. នៃវិធាន និងបទប្បញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈ) ។

រូបិយប័ណ្ណប្រើប្រាស់ក្នុងការវាយតម្លៃសម្រាប់សំណើដេញថ្លៃដោយប្រកួតប្រជែងក្នុងស្រុក ត្រូវតែជាប្រាក់រៀល ។ ក៏ប៉ុន្តែ សំណើដេញថ្លៃដែលអនុវត្តវិធីសាស្រ្តដេញថ្លៃដោយប្រកួតប្រជែងជាលក្ខណៈអន្តរជាតិ អាចជារូបិយប័ណ្ណមួយចំនួន (រហូតដល់បី)។ ក្នុងករណីតម្លៃដាក់ដេញជារូបិយប័ណ្ណបរទេស ត្រូវប្តូរជាប្រាក់រៀល



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

តាមអត្រាប្តូរប្រាក់របស់ធនាគារជាតិនៅថ្ងៃបើកឯកសារដេញថ្លៃ ។

**ការវាយតម្លៃលក្ខណៈសម្បត្តិតាមក្រោយ** នឹងត្រូវអនុវត្តតែលើសំណើដេញថ្លៃ ដែលត្រូវបានកំណត់ថាជាសំណើដេញថ្លៃឆ្លើយតបច្រើនបំផុត និងមានតម្លៃទាបជាងគេបំផុត បន្ទាប់ពីការកែតម្រូវទាំងអស់ ។ បន្ទាប់ពីសំណើនេះត្រូវបានពិនិត្យឡើងវិញ ដោយផ្អែកលើលក្ខខណ្ឌវិនិច្ឆ័យលក្ខណៈសម្បត្តិ ដូចមានបញ្ជាក់នៅក្នុងឯកសារដេញថ្លៃ ។ ក្នុងករណីអ្នកដេញថ្លៃបំពេញបានតាមលក្ខខណ្ឌវិនិច្ឆ័យលក្ខណៈសម្បត្តិ អ្នកដេញថ្លៃនោះនឹងត្រូវស្នើសុំការសម្រេច (មាត្រា ៣.១២. នៃបទប្បញ្ញត្តិ និងវិធានស្តីពីលទ្ធកម្មសាធារណៈ)។

ប្រសិនបើលទ្ធផលទទួលឯកសារដេញថ្លៃមានចំនួនតិចជាងបី ឯកសារដេញថ្លៃមិនត្រូវបើក ហើយបញ្ជូនឯកសារទាំងនោះ ត្រឡប់ទៅកាន់អ្នកដេញថ្លៃវិញ បន្ទាប់មកត្រូវធ្វើការពិនិត្យកែលម្អឯកសារដេញថ្លៃឡើងវិញ ដើម្បីបង្កើនកម្រិតនៃការប្រកួតប្រជែងជាសាធារណៈលើទីពីរ ។ ក្រោយការផ្សព្វផ្សាយជាសាធារណៈលើកទីពីរ ទោះបីលទ្ធផលទទួលបានឯកសារដេញថ្លៃចំនួនប៉ុន្មាន ក៏ត្រូវតែធ្វើការបើកឯកសារទាំងនោះជាសាធារណៈ និងធ្វើការវាយតម្លៃដែរ ។ ប្រសិនបើការដេញថ្លៃត្រូវខកខានយ៉ាងហោចណាស់ពីរដងរួចមកហើយ ដោយហេតុមកពីតម្លៃពុំមានការឆ្លើយតបនឹងការដេញថ្លៃ ត្រូវទិញផ្ទាល់ ឬ ចុះកិច្ចសន្យាផ្ទាល់ (មាត្រា ១១ នៃអនុក្រឹត្យ ឆ្នាំ ២០០៦)។

### ៣.៤.១០. ការសម្រេចប្រគល់កិច្ចសន្យា

ស្ថាប័នអនុវត្តលទ្ធកម្មនឹងសម្រេចប្រគល់កិច្ចសន្យាអោយអ្នកដេញថ្លៃណា ដែលមានសំណើដេញថ្លៃដែលៈ

- មានការឆ្លើយតបពេញលេញ
- មានតម្លៃដែលបានវាយតម្លៃថាទាបសមស្រប
- មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការអនុវត្តកិច្ចសន្យា ។

**គណៈកម្មាធិការ កំណត់បុរេលក្ខណៈសម្បត្តិ វាយតម្លៃ និង ប្រគល់កិច្ចសន្យា** មានភារកិច្ចត្រួតពិនិត្យលើសកម្មភាពលទ្ធកម្ម និង ត្រូវធ្វើការសម្រេចជាឯកច្ឆន្ទចំពោះរបាយការណ៍វាយតម្លៃ និងផ្តល់អនុសាសន៍ ដើម្បីប្រគល់កិច្ចសន្យា (មាត្រា ២៧ នៃអនុក្រឹត្យ ឆ្នាំ ២០០៦) ។

ស្ថាប័នអនុវត្តលទ្ធកម្មត្រូវជូនដំណឹងអំពីការសម្រេចប្រគល់កិច្ចសន្យា ជូនអ្នកដេញថ្លៃជោគជ័យមុននឹងផុតកំណត់រយៈពេលសុពលភាពនៃសំណើដេញថ្លៃ ។ បេក្ខជនត្រូវតែបានទទួលព័ត៌មាន ត្រូវទទួលក្នុងរយៈពេលសុពលភាពនៃប្រាក់កក់ធានាការដេញថ្លៃរបស់ខ្លួន ។ ការពន្យាពេលនៃចិរវេលានៃសុពលភាពនៃប្រាក់កក់ធានាការដេញថ្លៃអាចស្នើសុំបាន ប្រសិនបើមានការចាំបាច់ចំពោះបេក្ខជន ដែលបានជ្រើសរើស ។ ប្រសិនបើ


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

### ការកែប្រែកិច្ចសន្យា ប្រាក់កក់ធានាការអនុវត្ត ការទូទាត់មុន ការយឺតយ៉ាវក្នុងការអនុវត្តកិច្ចសន្យា និង ការបញ្ចប់កិច្ចសន្យា

***ការកែប្រែកិច្ចសន្យា***

ការកែប្រែកិច្ចសន្យាអាចជាការចាំបាច់ ដោយសារការអនុវត្តមានការប្រែប្រួល ដោយការពន្យាកាលវិភាគ ពេលវេលាប្រគល់-ទទួល ។ គណៈកម្មាធិការកំណត់បុរេលក្ខណៈសម្បត្តិ វាយតម្លៃ និង ប្រគល់កិច្ចសន្យាត្រូវពិនិត្យសំណើកែប្រែ ហើយដាក់ជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុពិនិត្យ និង ចុះហត្ថលេខាលើឯកសារកែប្រែកិច្ចសន្យា ។

***លិខិតធានាប្រាក់កក់ធានាការអនុវត្ត***

ជាទូទៅ ការធ្វើលទ្ធកម្មទំនិញ សំណង់ និង សេវាកម្មតម្រូវអោយអ្នកផ្គត់ផ្គង់ និង អ្នកទទួលការផ្តល់នូវលិខិតប្រាក់កក់ធានាការអនុវត្តតាមគំរូ និង ចំនួនទឹកប្រាក់ ដូចមាននៅក្នុងឯកសារដេញថ្លៃ ។ ប្រាក់កក់ធានាការអនុវត្តត្រូវកំណត់ចំនួន ១០%នៃតម្លៃកិច្ចសន្យា ដែលនឹងត្រូវដកយកសម្រាប់ទូទាត់សងការខូចខាត ឬ ការយឺតយ៉ាវ ។

***ការទូទាត់មុន***

ក្នុងករណីចាំបាច់ កិច្ចសន្យានឹងអនុញ្ញាតអោយមានការទូទាត់មុន ទៅអោយអ្នកផ្គត់ផ្គង់ ឬ អ្នកទទួលការ ។ ការទូទាត់មុនមិនអាចធ្វើបានទេ ប្រសិនបើគ្មានលិខិតធានាការទូទាត់មុន ដែលចេញដោយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

***ការយឺតយ៉ាវក្នុងការអនុវត្តកិច្ចសន្យា***

អ្នកផ្គត់ផ្គង់ ឬ អ្នកទទួលការត្រូវបញ្ចប់អោយបានសព្វគ្រប់នូវការប្រគល់ទំនិញ សំណង់ និង សេវាកម្ម ដោយអនុលោមតាមតារាងកម្មវិធីការងារ ។ ការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ចរបស់ខ្លួន នឹងបណ្តាលអោយ អ្នកផ្គត់ផ្គង់ ឬ អ្នកទទួលការទទួលខុសត្រូវលើសំណងខូចខាត លើកលែងតែការយឺតយ៉ាវនោះបណ្តាលមកពីប្រធានស័ក្តិ ។

***ការបញ្ចប់កិច្ចសន្យា***

ជាទូទៅ អ្នកទិញអាចបញ្ចប់កិច្ចសន្យាបាន ដោយផ្អែកលើមូលដ្ឋាន៖ អ្នកផ្គត់ផ្គង់ខកខានមិនបានប្រគល់ទំនិញណាមួយ អ្នកផ្គត់ផ្គង់ខកខានមិនបានបំពេញកាតព្វកិច្ច ។

បេក្ខជនបដិសេធ ប្រាក់កក់ធានាការដេញថ្លៃត្រូវបង្វិលឱ្យវិញ អ្នកដេញថ្លៃល្អបន្ទាប់ត្រូវបានពិចារណា ។ សេចក្តីជូនដំណឹងពីការសម្រេចប្រគល់កិច្ចសន្យា ជាមូលដ្ឋានសម្រាប់បង្កើតកិច្ចសន្យា ។ កាលបរិច្ឆេទដែលអ្នកផ្គង់ផ្គង់ ឬ អ្នកទទួលការទទួលបាននូវលិខិតជូនដំណឹងអំពីការសម្រេចយល់ព្រមប្រគល់កិច្ចសន្យា គឺជាកាលបរិច្ឆេទចាប់ផ្តើមនៃកិច្ចសន្យា ហើយភាគីចុះកិច្ចសន្យាមានកាតព្វកិច្ចទទួលយកកាលបរិច្ឆេទនេះ សម្រាប់ចាប់ផ្តើមក្នុងការប្រគល់ទំនិញ ។

## ៣.៤.១១. កិច្ចសន្យា

ទម្រង់ឯកសារដែលបានបញ្ចូលទៅក្នុងឯកសារដេញថ្លៃ ជានិច្ចជាកាលត្រូវធ្វើជាមូលដ្ឋានក្នុងការរៀបចំ


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

កិច្ចសន្យាជាក់ស្តែង ព្រោះថាអ្នកដេញថ្លៃបានរៀបចំសំណើដេញថ្លៃរបស់ពួកគេ ដោយផ្អែកលើទម្រង់ឯកសារនោះ (មាត្រា ៣.១៣. នៃបទប្បញ្ញត្តិ និងវិធានស្តីពីលទ្ធកម្មសាធារណៈ) ។

កិច្ចសន្យានីមួយៗ ត្រូវចុះហត្ថលេខាដោយប្រធាន **គណៈកម្មាធិការកំណត់មុខលក្ខណៈសម្បត្តិ វាយតម្លៃ និង ប្រគល់កិច្ចសន្យា** ឬ បុគ្គលដែលទទួលការផ្ទេរសិទ្ធិពីប្រធាន ។

ជាទូទៅ ការធ្វើលទ្ធកម្មទំនិញ សំណង់ និងសេវាកម្ម តម្រូវអោយអ្នកផ្គត់ផ្គង់ និង អ្នកទទួលការផ្តល់នូវលិខិតប្រាក់កក់ធានាការអនុវត្ត ដែលចំនួនប្រាក់កក់ត្រូវបានកំណត់ ១០%នៃតម្លៃកិច្ចសន្យា ។ ការខកខានរបស់អ្នកដេញថ្លៃឈ្នះ ក្នុងការបញ្ជូនត្រឡប់មកវិញនូវកិច្ចសន្យាដែលត្រូវចុះហត្ថលេខា ឬ មិនបានផ្តល់នូវលិខិតធានាប្រាក់កក់ធានាការអនុវត្ត បង្កើតជាមូលដ្ឋានគ្រប់គ្រាន់សម្រាប់ការទុកជាមោឃៈនៃការសម្រេចប្រគល់កិច្ចសន្យា និងការរឹបអូសប្រាក់កក់ធានាការដេញថ្លៃ ។

ក្នុងករណីចាំបាច់ កិច្ចសន្យានឹងអនុញ្ញាតអោយមានការទូទាត់មុន ទៅអោយអ្នកផ្គត់ផ្គង់ ឬ អ្នកទទួលការ ។ ការទូទាត់មុនមិនអាចធ្វើឡើងបានទេ ប្រសិនបើគ្មានលិខិតធានាការទូទាត់មុន ដែលចេញដោយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

### ៣.៤.១២. ការប្តឹងតវ៉ា

អ្នកដេញថ្លៃ ឬ ទីប្រឹក្សា ដែលវាយតម្លៃថាវិធានដែលអនុវត្ត (អនុក្រឹត្យ ឆ្នាំ ២០០៦ និង បទប្បញ្ញត្តិ និងវិធានស្តីពីលទ្ធកម្មសាធារណៈ) មិនត្រូវបានគោរព មានសិទ្ធិដាក់ពាក្យប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរ នៅគ្រប់ដំណាក់កាលនៃដំណើរការធ្វើលទ្ធកម្ម (មាត្រា ៣៨ នៃអនុក្រឹត្យ ឆ្នាំ ២០០៦)។

ពាក្យប្តឹងតវ៉ានេះ ត្រូវដាក់ជូនសាមីស្ថាប័នអនុវត្តលទ្ធកម្ម ហើយត្រូវចម្លងពាក្យបណ្តឹងនេះ បញ្ជូនទៅក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។ ស្ថាប័នអនុវត្តលទ្ធកម្មត្រូវធ្វើការពិនិត្យពាក្យបណ្តឹង និង ផ្តល់ចម្លើយនៅក្នុងរយៈពេល ១៥ ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃដាក់ពាក្យប្តឹងតវ៉ា ។ អ្នកដេញថ្លៃ ឬ ទីប្រឹក្សាដែលមិនពេញចិត្តនឹងចម្លើយរបស់ស្ថាប័នអនុវត្តលទ្ធកម្ម មានសិទ្ធិប្តឹងបន្តបន្ថែម ក្នុងរយៈពេល ១៥ ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃដែលស្ថាប័នអនុវត្តលទ្ធកម្មបានផ្តល់ចម្លើយ និង សុំអោយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុពិនិត្យឡើងវិញលើសេចក្តីសម្រេចរបស់ស្ថាប័នអនុវត្តលទ្ធកម្ម ។ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុត្រូវផ្តល់ចម្លើយក្នុងរយៈពេល ១៥ ថ្ងៃ (មាត្រា ៣៩ នៃអនុក្រឹត្យ ឆ្នាំ ២០០៦)។

### ៣.៤.១៣. ការគ្រប់គ្រងកិច្ចសន្យា

ស្ថាប័នអនុវត្តលទ្ធកម្មត្រូវត្រួតពិនិត្យជាប្រចាំលើរាល់កិច្ចសន្យា ហើយត្រូវធានាថារាល់បញ្ហាកើតឡើង ត្រូវបានដោះស្រាយភ្លាមៗ ឬ អនុវត្តវិធានការការពារមុនពេលបញ្ហាកើតឡើង ។ ក្រោយកិច្ចសន្យាចូលជាធរមាន មានបញ្ហាជាច្រើនដែលចាំបាច់ត្រូវត្រួតពិនិត្យ និង ដោះស្រាយមុនកិច្ចសន្យាឈានដល់ការបញ្ចប់ រួមមាន÷ ប្រសិទ្ធភាពនៃកិច្ចសន្យា ការប្រគល់ និង ការធ្វើអធិការកិច្ចលើទំនិញ ការទាមទារសំណងធានារ៉ាប់រង ការទូទាត់ អោយអ្នកផ្គត់ផ្គង់ ឬ អ្នកទទួលការ ការត្រួតពិនិត្យការអនុវត្តសម្រាប់សេវាកម្ម និង សំណង់ វិវាទនៃកិច្ចសន្យា ការយឺតយ៉ាវក្នុងការអនុវត្ត ការទាមទារសំណងសម្រាប់ការខូចខាត ការចូលកាន់កាប់ជាបឋម និងជាស្ថាពរលើ សំណង់ ការតម្លើង និង ការចាប់ផ្ដើមប្រើប្រាស់គ្រឿងបរិក្ខារ ការទទួលយកនូវលទ្ធផលការងាររបស់ទីប្រឹក្សា ការបង្វិលប្រាក់កក់ធានាការអនុវត្ត និង ប្រាក់បង្កទុក និង ការបញ្ចប់កិច្ចសន្យា ។

### ៣.៤.១៤. ទោសប្បញ្ញត្តិ

អ្នកដេញថ្លៃដែលមិនគោរពវិធាន ដែលទាក់ទងនឹងលទ្ធកម្ម (ឧទាហរណ៍ អំពើពុករលួយ) អាចទទួល ទោស គឺហាមឃាត់ក្រុមហ៊ុន ឬ បុគ្គលទាំងនោះ មិនអោយចូលរួមកិច្ចលទ្ធកម្មសាធារណៈ ពោលគឺក្នុងរយៈពេល មិនតិចជាងបីឆ្នាំ ឬ ជាអចិន្ត្រៃយ៍ (មាត្រា ៨៥ នៃអនុក្រឹត្យ ឆ្នាំ ២០០៦ និង មាត្រា ៩.១. នៃបទប្បញ្ញត្តិ និងវិធាន ស្ដីពីលទ្ធកម្មសាធារណៈ) ។

## ៤. នីតិវិធីដោយឡែកក្នុងកិច្ចលទ្ធកម្មសេវាទីប្រឹក្សា

### ៤.១. ការជ្រើសរើសទីប្រឹក្សាឯកត្តជន ឬ ក្រុមហ៊ុន

**ទីប្រឹក្សា** អាចត្រូវត្រូវបានជ្រើសរើសមក ដើម្បីផ្ដល់សេវាឯកទេស ក្នុងការអនុវត្តគម្រោង កិច្ចសន្យា សំខាន់ៗ ឬ ផ្ដល់ជាយោបល់បច្ចេកទេស ឬ ជាជំនួយក្នុងការពង្រឹងសមត្ថភាពឯកជន ឬ ស្ថាប័ន ។ ទីប្រឹក្សាអាចជា ឯកត្តបុគ្គល ឬ ជាក្រុមហ៊ុនទីប្រឹក្សា (មាត្រា ១៣ នៃអនុក្រឹត្យ ឆ្នាំ ២០០៦) ។

នីតិវិធីក្នុងការជ្រើសរើសទីប្រឹក្សា និងវិធីសាស្ត្រវាយតម្លៃត្រូវបានកំណត់ក្នុងក្នុងបទប្បញ្ញត្តិ និងវិធាន ស្ដីពីលទ្ធកម្មសាធារណៈ ហើយនីតិវិធីទាំងនេះចាំបាច់ត្រូវអនុវត្តសម្រាប់គ្រប់ករណីទាំងអស់ ។ ម៉្យាងវិញទៀត គំរូ ឯកសារដេញថ្លៃ និង ទម្រង់កិច្ចសន្យាត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធនៃបទប្បញ្ញត្តិ និង វិធានស្ដីពីលទ្ធកម្ម សាធារណៈ។ ឯកសារគំរូទាំងនេះ ត្រូវប្រើប្រាស់នៅក្នុងគ្រប់ករណីទាំងអស់ (មាត្រា ១៤ នៃអនុក្រឹត្យ ឆ្នាំ ២០០៦)។

**សេចក្ដីណែនាំចំពោះទីប្រឹក្សា** មានគោលបំណងផ្ដល់នូវព័ត៌មានទាំងឡាយដែលទីប្រឹក្សាត្រូវការចាំបាច់

ដើម្បីរៀបចំនូវ **សំណើឆ្លើយតប** ទៅតាមសេចក្តីត្រូវការនៃគម្រោង ។ **ឯកសារសំណើផ្តល់សេវាទីប្រឹក្សា** គឺជាឯកសារសំខាន់បំផុត នៅក្នុងដំណើរការនៃកិច្ចលទ្ធកម្ម ។ វិធីសាស្រ្តលទ្ធកម្មសេវាទីប្រឹក្សា មានដូចខាងក្រោម÷

- ការជ្រើសរើសផ្អែកលើគុណភាព
- ការជ្រើសរើសផ្អែកលើគុណភាព និង តម្លៃ
- ការជ្រើសរើសផ្អែកលើថវិកាកំណត់
- ការជ្រើសរើសផ្អែកលើតម្លៃទាបបំផុត
- ការជ្រើសរើសផ្អែកលើលក្ខណៈសម្បត្តិរបស់ទីប្រឹក្សា
- ការជ្រើសរើសលើមូលដ្ឋានប្រភពតែមួយ និង
- ការជ្រើសរើសទីប្រឹក្សាឯកត្តជន ។

ក្នុងករណី តម្លៃប៉ាន់ស្មាននៃសេវាទីប្រឹក្សាខ្ពស់ជាងកម្រិតកំណត់ ការផ្សព្វផ្សាយជ្រើសរើសទីប្រឹក្សាត្រូវធ្វើឡើងជាភាសាខ្មែរ និង ភាសាអន្តរជាតិ ដែលពាក់ព័ន្ធនឹងការងារនេះ (មាត្រា ១៥ នៃអនុក្រឹត្យ ឆ្នាំ ២០០៦) ។ ក្នុងការជ្រើសរើសទីប្រឹក្សា គេមិនប្រើការបញ្ជាក់លក្ខណៈបច្ចេកទេសទេ គេប្រើ **លក្ខខណ្ឌការងារ** ជំនួយវិញ ។

នៅពេលបើកឯកសារ អង្គភាពលទ្ធកម្មធ្វើការបើកតែស្រោមសំបុត្រផ្អែកបច្ចេកទេសនៃសំណើរបស់ទីប្រឹក្សាប៉ុណ្ណោះនៅក្នុងពិធីបើកដំបូង ។ ស្រោមសំបុត្រផ្អែកហិរញ្ញវត្ថុត្រូវរក្សាទុកបិទជិតដដែល ។ នៅពេលបញ្ចប់ការវាយតម្លៃផ្អែកបច្ចេកទេស ស្រោមសំបុត្រផ្អែកហិរញ្ញវត្ថុនឹងត្រូវបានយកមកបើក ហើយទីប្រឹក្សាទាំងអស់ត្រូវបានអញ្ជើញអោយចូលរួមនៅក្នុងពិធីបើកស្រោមសំបុត្រផ្អែកហិរញ្ញវត្ថុ ជាសាធារណៈ ។

ការជ្រើសរើសទីប្រឹក្សាឯកត្តជន ត្រូវធ្វើឡើងដោយផ្អែកលើមូលដ្ឋាននៃលក្ខណៈសម្បត្តិ និងបទពិសោធន៍របស់ឯកកត្តជនទាក់ទងនឹងទីកន្លែងការងារដែលធ្លាប់បានបំពេញ ។ ការអញ្ជើញចំណាប់អារម្មណ៍ ត្រូវផ្សព្វផ្សាយជាសាធារណៈទូទាំងប្រទេស ហើយនៅពេលតម្លៃប៉ាន់ស្មាននៃការងារត្រូវបំពេញលើសពីកម្រិតទឹកប្រាក់ដែលបានកំណត់ នោះការផ្សព្វផ្សាយជ្រើសរើសទីប្រឹក្សាឯកត្តជន ត្រូវធ្វើឡើងជាភាសាខ្មែរ និង ភាសាអន្តរជាតិ ផ្អែកតាមការងារដែលត្រូវបំពេញ (មាត្រា ១៦ នៃអនុក្រឹត្យ ឆ្នាំ ២០០៦) ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ៤.២. ប្រភេទនៃកិច្ចសន្យា

### ៤.២.១. កិច្ចសន្យាមធ្យោបាយ

ការផ្តល់បៀរវត្សត្រូវធ្វើតាមថិរវេលាធ្វើការ ទៅតាមអត្រាដែលព្រមព្រៀង (ជាម៉ោង ជាខែ) ។ រាល់ការចំណាយ ដែលអាចសងហើយមានចែងក្នុងកិច្ចសន្យាត្រូវសងមកវិញ ។ ចំនួនទឹកប្រាក់សរុបត្រូវមានកំណត់ក្នុងកិច្ចសន្យា អ្នកផ្តល់ប្រឹក្សាមានកាតព្វកិច្ចបង្ហើយការងារ តាមស្រោមសំបុត្រហិរញ្ញវត្ថុនៃកិច្ចសន្យា ។

### ៤.២.២. កិច្ចសន្យាតាមតម្លៃសរុប

តម្លៃទាំងអស់ត្រូវចរចារ និងការសងប្រាក់ត្រូវធ្វើជាទៀងទាត់ពេលវេលា ទៅតាមកម្រិតរីកចម្រើននៃការងារ ។ ចំនួនទឹកប្រាក់នៃកិច្ចសន្យាសន្មតដោយឈរលើចំនួនបុគ្គលិកក្នុងមួយខែ និងការចំណាយដែលអាចសងវិញ ។

### ៤.២.៣. កិច្ចសន្យាតាមភាគរយ

ប្រភេទនៃកិច្ចសន្យានេះប្រើប្រាស់ក្នុងគម្រោងសំណង់ និងសាធារណការ ។ បៀរវត្សនៃអ្នកផ្តល់គំនិត និង ឬ ការិយាល័យស្រាវជ្រាវត្រូវធ្វើដោយគិតទៅតាមភាគរយនៃតម្លៃ (ដើម ឬ សើរើ ដោយរាប់បញ្ចូល ទាំងកិច្ចសន្យាបន្ថែម) នៃគម្រោង ។

សម្រាប់ធនាគារពិភពលោក និងធនាគារអភិវឌ្ឍន៍អាស៊ី ប្រភេទ និង ចំនួនកម្រិតនៃនីតិវិធីមួយចំនួនខុសគ្នាច្រើនគឺ ÷

- ការជ្រើសរើសដោយផ្ទាល់ : ករណីលើកលែង និងតាមរយៈការព្រមព្រៀងជាមុនរបស់ធនាគារ ដែលបានផ្តល់ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។
- ការជ្រើសរើសជាលក្ខណៈអន្តរជាតិ តាមវិធីសាស្ត្រផ្អែកលើតម្លៃ និងគុណភាព ។
- សម្រាប់កិច្ចសន្យា ដែលមានទឹកប្រាក់ចាប់ពី ១០ម៉ឺនដុល្លារឡើងទៅ ។
- ការជ្រើសរើសថ្នាក់ជាតិ ទៅតាមវិធីសាស្ត្រផ្អែកលើតម្លៃ និងគុណភាព រវាងតម្លៃចាប់ពី ៥ម៉ឺន ដុល្លារ ទៅ ១០ ម៉ឺន ដុល្លារ ។
- ការជ្រើសរើសផ្អែកលើគុណភាព អ្នកផ្តល់ប្រឹក្សា ចំពោះកិច្ចសន្យា ដែលលើសពី៥ម៉ឺនដុល្លារឡើងទៅ ។

- ទីប្រឹក្សាឯកជនៈ ឈរលើកិច្ចព្រមព្រៀងធនាគារពិភពលោកដែលផ្តល់ហិរញ្ញប្បទាន (ឧបសម្ព័ន្ធ ៥) ។

## ៥. ស្ថាប័នគ្រប់គ្រងលទ្ធកម្មសាធារណៈ

### ៥.១. ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

អនុក្រឹត្យលេខ ៤ អនុក្រ.បក្រ. ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានចែងថាក្រសួងមានការទទួលខុសត្រូវជាពិសេស លើការគ្រប់គ្រងតាមដានកិច្ចលទ្ធកម្មសាធារណៈនៃក្រសួងស្ថាប័ននានា ទាំងនៅថ្នាក់ខេត្ត- ក្រុង និងស្ថាប័នកណ្តាល ឬស្ថាប័នស្វយ័ត ។

លើសពីនេះទៅទៀត ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជា «ស្ថាប័នគ្រប់គ្រងលទ្ធកម្មសាធារណៈ» ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុកំណត់ទឹកប្រាក់សម្រាប់អនុវត្តវិធីសាស្ត្រលទ្ធកម្ម រៀបចំគោលនយោបាយលទ្ធកម្ម និងនីតិវិធីលម្អិតនៃលទ្ធកម្ម សម្រាប់អនុវត្តស្របទៅតាមបទប្បញ្ញត្តិដែលមានស្រាប់ និងអនុវត្តអំណាចដទៃទៀតតាមការចាំបាច់ ដើម្បីធានាអោយមុខងារ និង ការអនុវត្តដំណើរការបានល្អ (មាត្រា ១៧ នៃអនុក្រឹត្យ ឆ្នាំ ២០០៦)។

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុមានភារកិច្ចធ្វើការកែលម្អ និង បំពេញបន្ថែមលើវិធាន និងបទប្បញ្ញត្តិស្តីពីវិធានលទ្ធកម្មសាធារណៈ (មាត្រា ១៨ នៃអនុក្រឹត្យ ឆ្នាំ ២០០៦) ។

### ៥.២. នាយកដ្ឋាន លទ្ធកម្មសាធារណៈ

នាយកដ្ឋានលទ្ធកម្មសាធារណៈនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាសេនាធិការអោយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុលើការងារគ្រប់គ្រងលទ្ធកម្មសាធារណៈនៅតាមបណ្តាក្រសួង ស្ថាប័ន ខេត្ត- ក្រុង ឃុំ សង្កាត់ សហគ្រាសសាធារណៈ និង គ្រឹះស្ថានសាធារណៈលក្ខណៈរដ្ឋបាលទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជា ដោយមិនគិតពីប្រភពមូលនិធិ (មាត្រា ១៩ នៃអនុក្រឹត្យ ឆ្នាំ ២០០៦) ។

### ៥.៣. ការទទួលខុសត្រូវរបស់ស្ថាប័នអនុវត្តលទ្ធកម្ម

ការទទួលខុសត្រូវក្នុងការដាក់អោយអនុវត្តបទបញ្ញត្តិ និងវិធានស្តីពីលទ្ធកម្មសាធារណៈ ជាបន្ទុករបស់ស្ថាប័នអនុវត្តលទ្ធកម្ម ក្នុងការធ្វើកិច្ចលទ្ធកម្មសាធារណៈ ។

ស្ថាប័នអនុវត្តលទ្ធកម្មមានភារកិច្ចគ្រប់គ្រង និងត្រួតពិនិត្យជាប្រចាំរាល់កិច្ចលទ្ធកម្មសាធារណៈរបស់ស្ថាប័នខ្លួន និងតាមដានរាល់ការអនុវត្តគ្រប់អនុសាសន៍ ដែលផ្តល់ដោយនាយកដ្ឋានលទ្ធកម្មសាធារណៈ (មាត្រា ២០ នៃអនុក្រឹត្យ ឆ្នាំ ២០០៦) ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ៥.៤. អង្គភាពលទ្ធកម្មសាធារណៈ

ដើម្បីបង្កលក្ខណៈងាយស្រួលដល់ដំណើរការប្រកបដោយប្រសិទ្ធភាពនៃលទ្ធកម្មសាធារណៈ ស្ថាប័នអនុវត្តលទ្ធកម្មនីមួយៗត្រូវបង្កើតនូវ **អង្គភាពលទ្ធកម្មសាធារណៈ** របស់ខ្លួន ។ **អង្គភាពលទ្ធកម្មសាធារណៈ** ត្រូវទទួលរ៉ាប់រងលើរាល់កិច្ចលទ្ធកម្មទាំងអស់ នៅក្នុងស្ថាប័នរបស់ខ្លួន ។ តួនាទីលម្អិត និងការទទួលខុសត្រូវនៃ **អង្គភាពលទ្ធកម្មសាធារណៈ** ត្រូវបានកំណត់ក្នុងបទប្បញ្ញត្តិ និងវិធានស្តីពីលទ្ធកម្មសាធារណៈ (មាត្រា ២៧ នៃអនុក្រឹត្យ ឆ្នាំ ២០០៦) ។

អង្គភាពលទ្ធកម្មសាធារណៈ រៀបចំឯកសារពិគ្រោះ រៀបចំបោះពុម្ពផ្សាយឯកសារទាក់ទងទៅនឹងការពិគ្រោះយោបល់ ផ្តត់ផ្គង់ឯកសារពិគ្រោះដល់ភាគីពាក់ព័ន្ធនឹងការទទួលខុសត្រូវនូវការដាក់លទ្ធកម្ម និង តាមដាននូវភាពត្រឹមត្រូវនៃឯកសារពិគ្រោះ និងបញ្ជូនសំណួរ ដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់នាយកដ្ឋានលទ្ធកម្ម ស្គាល់អាស័យដ្ឋាន ទាក់ទងឱ្យអ្នកចូលរួមដេញថ្លៃ និងបេក្ខជនដែលជ្រើសរើស រួចហើយរៀបចំអោយចុះហត្ថលេខាលើលទ្ធកម្មដែលឯកភាព និងជាចុងក្រោយ ទទួលទំនិញ បញ្ជាក់អំពីការបង់ថ្លៃ រួចបញ្ជូនទៅ **គណកម្មធិការកំណត់មុរលេក្ខណ:សម្បត្តិ វាយតម្លៃ និង ប្រគល់កិច្ចសន្យា** ។

អង្គភាពលទ្ធកម្មសាធារណៈ ស្ថិតនៅក្រោមការដឹកនាំរបស់ប្រធាន **គណកម្មធិការកំណត់មុរលេក្ខណ: សម្បត្តិ វាយតម្លៃ និង ប្រគល់កិច្ចសន្យា** ។

## ៥.៥. គណ:កម្មាធិការកំណត់មុរលេក្ខណ:សម្បត្តិ វាយតម្លៃ និង ប្រគល់កិច្ចសន្យា

ក្រសួងនីមួយៗ រដ្ឋបាលខេត្ត-ក្រុងនីមួយៗ ក្រុមហ៊ុនចម្រុះរដ្ឋនីមួយៗ ឬ ស្ថាប័ន ដែលស្ថិតនៅក្រោមការត្រួតពិនិត្យនីមួយៗ ត្រូវបង្កើត**គណ:កម្មាធិការកំណត់មុរលេក្ខណ:សម្បត្តិ វាយតម្លៃ និង ប្រគល់កិច្ចសន្យា** ដែលទទួលខុសត្រូវពិនិត្យ តាមដានឡើងវិញ នូវរាល់កម្មវិធីលទ្ធកម្មសាធារណៈ ឯកសារពិគ្រោះ និងអនុសាសន៍សម្រាប់ធ្វើការជ្រើសរើស និងព្រមទាំងការតវ៉ា ។ លទ្ធកម្មនៃអាជ្ញាធរខេត្ត-ក្រុងមានចែងក្នុងបទប្បញ្ញត្តិ និងវិធានស្តីពីលទ្ធកម្មសាធារណៈ ។

ក្រៅពីប្រធាន **គណ:កម្មាធិការកំណត់មុរលេក្ខណ:សម្បត្តិ វាយតម្លៃ និង ប្រគល់កិច្ចសន្យា** ត្រូវតែងតាំងតាមមាត្រា ២៥ សមាជិកនៃគណៈកម្មាធិការនេះ រៀងរាល់ ២ ឆ្នាំ ម្តង ដោយប្រធាន ។

សមាជិកនេះ អាចធ្វើការតែងតាំង ១ ឆ្នាំ ម្តងបន្ថែមទៀត ប៉ុន្តែ អាណត្តិសរុបរបស់គេ គឺមិនអាចលើសពី ៣ ឆ្នាំជាប់ៗគ្នាបានឡើយ ។ អតីតសមាជិកដែលតែងតាំងក្រោយពេល ក្នុងរយៈពេល ១ ឆ្នាំយ៉ាងតិច បន្ទាប់ពីការ


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

បញ្ចប់អាណត្តិ ៣ ឆ្នាំ ខាងដើម ។ ប្រធានស្ថាប័នអនុវត្តលទ្ធកម្មអាចធ្វើការតែងតាំងសមាជិកអចិន្ត្រៃយ៍ ពី ៤នាក់ ទៅ ៦នាក់ ។

ស្ថាប័នអនុវត្តលទ្ធកម្មអាចតែងតាំងសមាជិកបម្រុងបន្ថែមទៀត សម្រាប់លទ្ធកម្មសាធារណៈ ក្នុងពេលដ៏ចាំបាច់មួយ ប្រសិនបើត្រូវការយល់ដឹងបន្ថែម ឬ ត្រូវការសមត្ថភាពអ្នកបច្ចេកទេស ។

យ៉ាងហោចណាស់ ក៏មានសមាជិកម្នាក់ត្រូវមានជំនាញ និងទទួលការបណ្តុះបណ្តាលផ្នែកហិរញ្ញវត្ថុ និង ម្នាក់ទៀត យ៉ាងហោចណាស់ក៏ត្រូវតែមានជំនាញបច្ចេកទេស ដូចជាវិស្វករគ្រឿងយន្តមេកានិក និង ទេពកោសល្យសំណង់ស៊ីវិលដែរ ។

នាយកដ្ឋានលទ្ធកម្មសាធារណៈនឹងត្រូវបានស្ថាប័នអនុវត្តលទ្ធកម្មអញ្ជើញអោយចូលរួម និងមានសិទ្ធិចូលរួមគ្រប់ការពិភាក្សារបស់ **គណៈកម្មាធិការកំណត់បុរេលក្ខណៈសម្បត្តិ វាយតម្លៃ និង ប្រគល់កិច្ចសន្យា** ជាអ្នកសង្កេតការណ៍ (មាត្រា ២៥ នៃអនុក្រឹត្យ ឆ្នាំ ២០០៦) ។

**គណៈកម្មាធិការកំណត់បុរេលក្ខណៈសម្បត្តិ វាយតម្លៃ និង ប្រគល់កិច្ចសន្យា** ត្រូវមានរចនាសម្ព័ន្ធអចិន្ត្រៃយ៍ ។ លេខាធិការនៃគណៈកម្មាធិការនេះ គឺជាប្រធាននៃ **គណៈកម្មាធិការកំណត់បុរេលក្ខណៈសម្បត្តិ វាយតម្លៃ និង ប្រគល់កិច្ចសន្យា** ។ **គណៈកម្មាធិការកំណត់បុរេលក្ខណៈសម្បត្តិ វាយតម្លៃ និង ប្រគល់កិច្ចសន្យា** ត្រូវមានប្រធាន មួយរូប និង អនុប្រធានទី ២ មួយរូប ។ សិទ្ធិដឹកនាំរបស់ **គណៈកម្មាធិការកំណត់បុរេលក្ខណៈសម្បត្តិ វាយតម្លៃ និង ប្រគល់កិច្ចសន្យា** ត្រូវបានកំណត់ដូចខាងក្រោម៖

- លទ្ធកម្មកម្រិតខ្ពស់ ត្រូវដឹកនាំដោយប្រធាន **គណៈកម្មាធិការកំណត់បុរេលក្ខណៈសម្បត្តិ វាយតម្លៃ និង ប្រគល់កិច្ចសន្យា** ដែលជាប្រធានស្ថាប័ន
- លទ្ធកម្មកម្រិតមធ្យម ត្រូវដឹកនាំដោយអនុប្រធានទី ១ **គណៈកម្មាធិការកំណត់បុរេលក្ខណៈសម្បត្តិ វាយតម្លៃ និង ប្រគល់កិច្ចសន្យា**
- លទ្ធកម្មកម្រិតទាប ត្រូវដឹកនាំដោយអនុប្រធានទី ២ **គណៈកម្មាធិការកំណត់បុរេលក្ខណៈសម្បត្តិ វាយតម្លៃ និង ប្រគល់កិច្ចសន្យា**

អនុប្រធានទី ១ និង អនុប្រធានទី ២ របស់ **គណៈកម្មាធិការកំណត់បុរេលក្ខណៈសម្បត្តិ វាយតម្លៃ និង ប្រគល់កិច្ចសន្យា** ត្រូវបានតែងតាំងដោយប្រធានស្ថាប័ន និង ត្រូវប្រគល់សិទ្ធិពេញលេញអោយធ្វើជាផ្នែកមួយ


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

| ប្រភេទ | លេខ | ទឹកប្រាក់ធានាចំណាយ | តម្លៃកិច្ចសន្យា | សំចៃ |
|---|---|---|---|---|
| **ក. ផ្គត់ផ្គង់** | | | | |
| ការិយាល័យ ២ | ៣៧ | 194 481 706 171 | 192 188 031 269 | 2 293 674 902 |
| ការិយាល័យ ៣ | ២២ | 46 501 209 950 | 45 178 582 639 | 1 322 627 311 |
| ការិយាល័យ ជុំវិញខេត្ត-ក្រុង | ៧ | 5 340 488 400 | 5 202 792 250 | 137 696 150 |
| **សរុប ផ្នែក (ក)** | ៦៦ | 246 323 404 521 | 242 569 406 158 | 3 753 998 363 |
| **ខ. ការសាងសង់** | | | | |
| ការិយាល័យ ១ | ៥២ | 97 726 789 600 | 97 141 500 000 | 585 289 600 |
| ការិយាល័យ ៣ | ៤៤ | 37 395 217 200 | 37 118 986 572 | 276 230 628 |
| ការិយាល័យ ជុំវិញខេត្ត-ក្រុង | ៣១ | 52 208 823 000 | 51 455 324 400 | 753 498 600 |
| **សរុប ផ្នែក (ខ)** | ១២៧ | 187 330 829 800 | 185 715 810 972 | 1 615 018 828 |
| **សរុប ផ្នែក (ក + ខ)** | ១៩៣ | 433 654 234 321 | 428 285 217 130 | 5 369 017 191 |

របស់ **គណៈកម្មាធិការកំណត់មុខលេខគុណៈសម្បត្តិ វាយតម្លៃ និង ប្រគល់កិច្ចសន្យា** ក្នុងការអនុម័តយល់ព្រមលើរបាយការណ៍វាយតម្លៃ និងចុះកិច្ចសន្យា តាមកម្រិតទឹកប្រាក់ដែលស្ថិតក្នុងសិទ្ធិសម្រេចរបស់ខ្លួន ។ អនុប្រធានទី ១ និង អនុប្រធានទី ២ ត្រូវបានផ្តល់សិទ្ធិដើម្បីចុះហត្ថលេខាក្នុងនាមស្ថាប័ន ដោយមិនចាំបាច់មានការយល់ព្រមបន្ថែមពីប្រធានស្ថាប័នឡើយ ។ អនុប្រធានទី ១ និង អនុប្រធានទី ២ ត្រូវធ្វើរបាយការណ៍ស្តីពីការអនុវត្តគ្រប់កិច្ចលទ្ធកម្មក្រោមសិទ្ធិអំណាចរបស់ខ្លួន ជូនប្រធាន **គណៈកម្មាធិការកំណត់មុខលេខគុណៈសម្បត្តិ វាយតម្លៃ និង ប្រគល់កិច្ចសន្យា** ដែលជាប្រធានស្ថាប័ន ។

អំណាចរបស់ **គណៈកម្មាធិការកំណត់មុខលេខគុណៈសម្បត្តិ វាយតម្លៃ និង ប្រគល់កិច្ចសន្យា**មានអំណាចរិះគន់សកម្មភាពលទ្ធកម្មសាធារណៈ ផ្តល់របាយការណ៍វាយតម្លៃ និងផ្តល់អនុសាសន៍ ក្នុងការជ្រើសរើសបេក្ខជន ។

សេចក្តីសម្រេចនៃ **គណៈកម្មាធិការកំណត់មុខលេខគុណៈសម្បត្តិ វាយតម្លៃ និង ប្រគល់កិច្ចសន្យា** ត្រូវតែមានសំលេងជាឯកច្ឆ័ន្ទ សម្រាប់ផ្តល់ការវាយតម្លៃចំពោះរបាយការណ៍វាយតម្លៃ និងជ្រើសរើសបេក្ខជន ក្នុងករណីដែល **គណៈកម្មាធិការកំណត់មុខលេខគុណៈសម្បត្តិ វាយតម្លៃ និង ប្រគល់កិច្ចសន្យា** បង្កើតឡើងដ៏សមស្រប និង បានវាយតម្លៃលើលទ្ធកម្មសាធារណៈត្រឹមត្រូវ ឯស្ថាប័នអនុវត្តលទ្ធកម្មផ្សេងទៀត មិនអាច


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

បដិសេធលើសេចក្តីសម្រេចនេះបានឡើយ ។

ប្រធាននៃ **គណៈកម្មាធិការកំណត់ប្រលេក្ខណៈសម្បត្តិ វាយតម្លៃ និង ប្រគល់កិច្ចសន្យា** មាន ភារកិច្ចចុះហត្ថលេខាលើកិច្ចសន្យា ក្នុងនាមស្ថាប័នអនុវត្តលទ្ធកម្ម ដោយពុំចាំបាច់មានការឯកភាពពីអ្នកផ្សេងទៀតឡើយ ។

លើកលែងតែករណីដូចតទៅ ÷

- សម្រាប់លទ្ធកម្មសាធារណៈ ដែលមានទឹកប្រាក់លើសពីកាលកំណត់ ។ ក្នុងករណីនេះ ប្រធាននៃ**គណៈកម្មាធិការកំណត់ប្រលេក្ខណៈសម្បត្តិ វាយតម្លៃ និង ប្រគល់កិច្ចសន្យា**ត្រូវមានការឯកភាពពីក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមរយៈនាយកដ្ឋានលទ្ធកម្មសាធារណៈ ជាមុនសិន ។
- សម្រាប់លទ្ធកម្មសាធារណៈ ដែលមានភាពរសើបខាងផ្នែកនយោបាយ ឬ មានទម្ងន់ផ្នែកសង្គម ឬ សីលធម៌ធ្ងន់ធ្ងរ ឬ អាចប៉ះពាល់ដល់បរិស្ថាន ត្រូវមានការឯកភាពពីទីស្តីការគណៈរដ្ឋមន្ត្រី តាមរយៈក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជាមុនសិន ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ជំពូកទី ១៤

# ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ

ការគ្រប់គ្រងទ្រព្យសម្បត្តិឯកជន និងទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ គឺស្ថិតនៅក្នុងការទទួលខុសត្រូវរបស់រដ្ឋ ។ **រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា** ផ្តល់កិច្ចការពារជាពិសេស ដល់បេតិកភ័ណ្ឌវប្បធម៌ និងបេតិកភ័ណ្ឌសិល្បៈរបស់រដ្ឋ (មាត្រា ៧០) ។

**ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ** ដែលប្រកាសអោយប្រើប្រាស់ដោយព្រះរាជក្រមលេខ ន.ស./រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ បានចែងត្រង់មាត្រា ១៧ ថា ៖«ទ្រព្យសម្បត្តិរដ្ឋ ដែលរួមមាន ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ និង ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ត្រូវចាត់ចែង និង គ្រប់គ្រងយ៉ាងត្រឹមត្រូវទៅតាមបទប្បញ្ញត្តិនៃច្បាប់ជាធរមាន ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាសេនាធិការរបស់រាជរដ្ឋាភិបាល ក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋលើការលក់ ការជួល ការផ្ទេរ និង ការចាត់ចែងដទៃទៀតលើទ្រព្យសម្បត្តិរដ្ឋ ការផ្តល់សម្បទានផ្សេងៗរបស់រដ្ឋ ព្រមទាំងការធ្វើបញ្ជីសារពើភ័ណ្ឌ ។ រាល់ការចុះកិច្ចសន្យាលើការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ និង ផ្តល់សម្បទានផ្សេងៗរបស់រដ្ឋ ដែលមានការពាក់ព័ន្ធនឹងហិរញ្ញវត្ថុសាធារណៈ ត្រូវស្ថិតក្រោមការត្រួតពិនិត្យ និង ការឯកភាពរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។ ... ចំណូលទាំងអស់ដែលបានពីការចាត់ចែង និង គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ត្រូវបង់ចូលគណនីទោលរបស់រតនាគារជាតិនៃថវិការដ្ឋ ដោយមិនអាចដកចំណូលនេះទៅកាត់កងដោយត្រង់ជាមួយចំណាយឡើយ» ។

**ច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និង ទ្រព្យសម្បត្តិខេត្ត-ក្រុង** ដែលប្រកាសអោយប្រើប្រាស់ដោយព្រះរាជក្រមលេខ ជស/រកម/០២៩៨/០៣ ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ បានចែងត្រង់មាត្រា ៩ ថា ៖ «រដ្ឋប្រគល់អោយខេត្ត ក្រុងនីមួយៗនូវសិទ្ធិកាន់កាប់ និងសិទ្ធិប្រើប្រាស់ទ្រព្យសម្បត្តិសាធារណៈ អចលនវត្ថុមួយចំនួន ដែលស្ថិតនៅក្នុងមណ្ឌលដែនដីនៃខេត្ត ក្រុងទៅតាមការកំណត់របស់រដ្ឋ ...។ ...ការប្រគល់ត្រូវបានប្រតិបត្តិក្នុងលក្ខណៈ ដែលអាចដកហូតយកវិញបាន ។ អភិបាលខេត្ត ក្រុងដែលជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ ត្រូវទទួលបន្ទុកថែរក្សា និងជួសជុលនូវទ្រព្យសម្បត្តិរដ្ឋទាំងនោះ ។ អភិបាលខេត្ត ក្រុងត្រូវធានានូវការគ្រប់គ្រង និង អាចទទួលបាននូវផលទុន ដែលបានមកពីទ្រព្យសម្បត្តិទាំងនោះ បន្ទាប់ពីមានការយល់ព្រមរបស់រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង តាមយោបល់ឯកភាពពីក្រសួងមហាផ្ទៃ ។ អភិបាលខេត្ត ក្រុងមិនអាចជួល ផ្ទេរការប្រើប្រាស់ទ្រព្យសម្បត្តិទាំងនោះដោយគ្មានការយល់ព្រមជាមុនពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បន្ទាប់ពីមាន



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

យោបល់ឯកភាពពីក្រសួងមហាផ្ទៃឡើយ» ។

មាត្រា ១១ បានចែងថា÷«ទ្រព្យសម្បត្តិអចលវត្ថុ និង ចលនវត្ថុសម្រាប់សេវាសាធារណៈ ដែលខេត្ត ក្រុង រកបានដោយខ្លួនឯក គឺជាកម្មសិទ្ធិរបស់ខេត្ត ក្រុងផ្ទាល់» ។

**អនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ៧ ខែ តុលា ឆ្នាំ ២០០៥ ស្តីពីវិធាន និង នីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ** បានចែងនៅត្រង់មាត្រា ២ ថា : «រាជរដ្ឋាភិបាល គឺជាអ្នកគ្រប់គ្រងរាល់ទ្រព្យសម្បត្តិរបស់រដ្ឋ ដែលស្ថិតនៅក្រោមការកាន់កាប់ ការប្រើប្រាស់ ការថែរក្សា ការធ្វើអាជីវកម្មរបស់ក្រសួង ស្ថាប័ន ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និង របស់នីតិបុគ្គលសាធារណៈ ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គឺជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ។ អាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ជាសេនាធិការអោយរាជរដ្ឋាភិបាល លើការលក់ ការដូរ និងការជួល នូវទ្រព្យសម្បត្តិរបស់រដ្ឋ» ។

មាត្រា ៣ បានចែងថា ÷ «ទ្រព្យសម្បត្តិរដ្ឋ រួមមានទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ។ ទ្រព្យសម្បត្តិទាំងនេះអាចជាចលនទ្រព្យ និងអចលនទ្រព្យ ។ ទ្រព្យសម្បត្តិរបស់រដ្ឋ សំដៅលើទ្រព្យសម្បត្តិទាំងឡាយ ដែលកំពុងស្ថិតនៅក្រោមការកាន់កាប់ ការប្រើប្រាស់ ការថែរក្សា ការធ្វើអាជីវកម្មរបស់ក្រសួង ស្ថាប័ន ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ព្រមទាំងទ្រព្យសម្បត្តិទាំងឡាយ ដែលរដ្ឋប្រគល់ទៅអោយនីតិបុគ្គលសាធារណៈដទៃទៀត កាន់កាប់ ប្រើប្រាស់ ថែរក្សា និងធ្វើអាជីវកម្ម» ។

មាត្រា ៤ ចែងថា ÷ «ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋទាំងអស់ រួមទាំងទ្រព្យសម្បត្តិ ដែលកំពុងស្ថិតនៅក្រោមការកាន់កាប់របស់រដ្ឋ របស់នីតិបុគ្គលសាធារណៈដ៏ទៃទៀត អាចជាកម្មវត្ថុនៃការជួល ការលក់ និងការដូរបាន ស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ » ។

**អនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី ៧ ខែ តុលា ឆ្នាំ ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ** បានចែងនៅត្រង់មាត្រា ៣ ថា : «ជាទូទៅ រដ្ឋគឺជាម្ចាស់នៃដីទាំងអស់ដែលមិនស្ថិតនៅក្រោមការកាន់កាប់ជាភោគៈស្របច្បាប់ ឬ ជាកម្មសិទ្ធិដោយបុគ្គលឯកជន ឬ ដោយសមូហភាព ស្របតាមច្បាប់ភូមិបាលឆ្នាំ ២០០១ ។ ដីរដ្ឋមានដីសាធារណៈរបស់រដ្ឋ និងដីឯកជនរបស់រដ្ឋ ...។ ដីរដ្ឋអាចផ្តល់ជាសម្បទានដីសង្គមកិច្ច ជាសម្បទានដីសេដ្ឋកិច្ចឬជាសម្បទានផ្សេងៗទៀតបាន លុះត្រាតែដីនោះត្រូវបានចុះបញ្ជីថា ជាដីសាធារណៈរបស់រដ្ឋ ឬ ជាដីឯកជនរបស់រដ្ឋនឹងត្រូវអនុវត្តតាមនីតិវិធីច្បាប់» ។

**អនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ** បានចែងនៅត្រង់មាត្រា ១៣ ថា : «នាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

មានភារៈកិច្ចធ្វើជាសេនាធិការ អោយក្រសួងលើការងារ ÷

- គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ផ្អែកលើមូលដ្ឋានច្បាប់ និង បទបញ្ញាជាធរមាន
- ពិនិត្យ រៀបចំបញ្ជី និងគ្រប់គ្រងសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ
- ស្រាវជ្រាវ និង គ្រប់គ្រងទ្រព្យឥតម្ចាស់ និង មរតកឥតបណ្តឹង
- ទទួលខុសត្រូវក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ
- គ្រប់គ្រងភាគហ៊ុនរបស់រដ្ឋ និង ដើមទុនរបស់រដ្ឋ
- គ្រប់គ្រងគ្រឹះស្ថានសាធារណៈរដ្ឋបាល និង សហគ្រាសសាធារណៈ
- ប្រមូលផ្តុំព័តិមានពាក់ព័ន្ធទៅនឹងការងារឯកជនភាវូបនីយកម្ម និង ការជំរះបញ្ជីសហគ្រាសសាធារណៈ
- រៀបចំសេចក្តីព្រាងច្បាប់ និង បទបញ្ញានានាដែលទាក់ទងទៅនឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ
- រៀបចំបញ្ជីសម្បទានដី ព្រៃឈើ រ៉ែ ទ្រព្យសម្បត្តិរដ្ឋដទៃទៀតអោយផ្នែកឯកជន
- រៀបចំនីតិវិធី វាយតម្លៃការដាក់ជួល លក់ ផ្ទេរសិទ្ធិ ទ្រព្យសម្បត្តិរដ្ឋ
- ចូលរួមរៀបចំគម្រោងថវិកាជាតិប្រចាំឆ្នាំ ដើម្បីបញ្ចូលទៅក្នុងសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំនីមួយៗ» ។

**អនុក្រឹត្យលេខ ៨២ ចុះថ្ងៃទី ខែ ឆ្នាំ ១៩៩៥ ស្តីពីគណនេយ្យសាធារណៈ** បានចែងនៅត្រង់មាត្រា ១៣ ថា ÷«គណនេយ្យករសាធារណៈមានភារៈកិច្ច ÷

...

**គ.** ក្នុងវិស័យបេតិកភ័ណ្ឌ ត្រួតពិនិត្យៈ

- ការរក្សានូវសិទ្ធិ បុព្វសិទ្ធិ និង ទ្រព្យបញ្ចាំ
- ការរក្សាទុកដាក់ទ្រព្យសម្បត្តិដែលមានចែងក្នុង **គណនេយ្យរូបធាតុ**» ។

នៅក្នុងប្រទេសមួយចំនួន អាណាប័កមានភារៈកិច្ចគ្រប់គ្រងគណនេយ្យរូបធាតុ ។ នៅប្រទេសផ្សេងៗទៀត គណនេយ្យករដាច់ដោយឡែកជាអ្នកគ្រប់គ្រងគណនេយ្យករូបធាតុ ។ គណនេយ្យករជាអ្នកទទួលទំនិញ ការងារ និង សេវា និងបញ្ជាក់ពីទំនិញ ការងារ និង សេវាដែលបានផ្គត់ផ្គង់ ។

នៅពេលដែលគំរោងត្រូវបានផ្តល់ហិរញ្ញប្បទានដោយដៃគូរអភិវឌ្ឍន៍ ដោយការអនុវត្តថវិកាមិនបាន


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ឆ្លងកាត់ប្រព័ន្ធរតនាគារ នៅពេលដែលគម្រោងនេះចប់ ការងារ ឬ សំណង់អាគារត្រូវផ្ទេរជាកម្មសិទ្ធិរបស់រដ្ឋ តាមរយៈការគ្រប់គ្រងដោយអង្គភាព ឬ ស្ថាប័នដែលទទួលបន្ទុក ។ ដូច្នេះ ដើម្បីធានានូវការពង្រឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ សមិទ្ធិផលទាំងនេះ ជាការងារ ឬ សំណង់អាគារត្រូវចុះបញ្ជីជាទ្រព្យសម្បត្តិរដ្ឋនៅក្នុងគណនេយ្យរូបធាតុ និង គណនេយ្យទូទៅរបស់រដ្ឋ ។

ការដាក់អោយអនុវត្តនូវប្រព័ន្ធគណនេយ្យបង្គរ ដែលជាផ្នែកមួយនៃកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បង្កើតនូវលក្ខខណ្ឌចាំបាច់ដើម្បីពង្រឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ដោយមានបង្កើតនូវ **ថ្នាក់គណនេយ្យ- អចលនទ្រព្យ** ។ ចំពោះការផ្គត់ផ្គង់ទំនិញ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងកំណត់កម្រិតថ្លៃទំនិញដែលចាត់ទុកថាជាវិនិយោគ ហើយដែលត្រូវចុះបញ្ជីនៅក្នុងបញ្ជីសារពើភ័ណ្ឌរបស់រដ្ឋ និង នៅក្នុងគណនីនៃរតនាគារជាតិ ។ ដូចគ្នានេះដែរ បន្ទាប់ពីការងារ និង សំណង់អាគារ ដែលត្រូវបានហិរញ្ញប្បទានដោយថវិការដ្ឋត្រូវបានប្រគល់ជូនក្រសួង ស្ថាប័ន ឬ សហគ្រាសសាធារណៈពីក្រុមហ៊ុនដែលជាអ្នកផ្គត់ផ្គង់ ឬ អ្នកទទួលការ ទំនិញ ការងារ ឬ សំណង់ទាំងនេះត្រូវចុះក្នុងបញ្ជីសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិរដ្ឋ និង នៅក្នុងគណនីនៃទ្រព្យសម្បត្តិរដ្ឋនៅរតនាគារជាតិ ។

# ជំពូកទី ១៥

# វិមជ្ឈការ វិសហមជ្ឈការ ឯកជនភាវូបនីយកម្ម

## ១. និយមន័យរបស់ «រដ្ឋ»

តាមទស្សនៈច្បាប់ **រដ្ឋ** ជានីតិបុគ្គលនៃអធិបតេយ្យភាពមួយ ។ គេធ្វើការបែងចែកជា រដ្ឋបាលកណ្តាល និង អង្គភាព- ស្ថាប័នរបស់រដ្ឋ (គ្រឹះស្ថានសាធារណៈរដ្ឋបាល អាជ្ញាធរដែនដី- ដែលគេអាចហៅផងដែរថាជាអាជ្ញាធរតំបន់) ។ រដ្ឋបាលកណ្តាល និង អង្គភាពផ្សេងៗទៀតជា នីតិបុគ្គលនៃនីតិសាធារណៈ ដែលគេអាចហៅថាជា «**បុគ្គលសាធារណៈ**» ។ តាមន័យចង្អៀត អំណាចរបស់រដ្ឋ គឺជា «**អំណាចអធិបតេយ្យ**»: ដូចជាអំណាចក្នុងវិស័យ នយោបាយក្រៅប្រទេស នគរបាលជាតិ ការពារជាតិ យុត្តិធម៌ ពន្ធ ។

នៅព្រះរាជាណាចក្រកម្ពុជា ជាបឋម «**រដ្ឋ**» រួមមានស្ថាប័ន ដែលកំណត់ដោយរដ្ឋធម្មនុញ្ញៈ ព្រះមហាក្សត្រ (ជំពូក ២ នៃរដ្ឋធម្មនុញ្ញ) និង ព្រះបរមរាជវាំង រដ្ឋសភា (ជំពូក ៧) និង ព្រឹទ្ធសភា (ជំពូក ៨) រាជរដ្ឋាភិបាល (ជំពូក ១០) ដែលជាគណៈរដ្ឋមន្ត្រី (មាត្រា ១១៨ ថ្មីនៃរដ្ឋធម្មនុញ្ញ) អំណាចនីតិបញ្ញត្តិ (តំណាង ដោយតុលាការកំពូល និង សាលាក្តីគ្រប់កម្រិត ជំពូក ១១) ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម (មាត្រា ១៣២ ថ្មី) ក្រុមប្រឹក្សាជាន់ខ្ពស់ការពារជាតិ (មាត្រា ២៤ ថ្មី) និងជាចុងក្រោយ ក្រុមប្រឹក្សារដ្ឋធម្មនុញ្ញ (ជំពូក ១២) ។

ដោយអនុលោមតាម **ច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី** (ចុះថ្ងៃទី ១៩ ខែកក្កដា ឆ្នាំ ១៩៩៤) បានអោយនិយមន័យរបស់ «**ស្ថាប័ន**» ថាជា «ក្រសួង ឬ រដ្ឋលេខាធិការដ្ឋាន» ដែលយើងប្រើប្រាស់សព្វថ្ងៃ ។

ទស្សនទាន «**រដ្ឋ**» នេះបូកបញ្ចូលផងដែរនូវ **រដ្ឋបាលសាធារណៈ** ដែលស្ថិតនៅក្រោមឱវាទនៃក្រសួងមួយ (ឬច្រើន) ឬ រដ្ឋបាលសាធារណៈស្វយ័ត ដូចជា **អាជ្ញាធរសវនកម្មជាតិ** ឬ **ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា** (ដែលស្ថិតក្រោមការគ្រប់គ្រងរបស់នាយករដ្ឋមន្ត្រី) ។ ស្ថាប័នទាំងនេះអាចមាននៅកម្រិតជាតិ ឬ នៅក្នុងកម្រិតវិមជ្ឈការនៅក្នុងប្រទេស ។

**គ្រឹះស្ថានសាធារណៈរដ្ឋបាល** ជានីតិបុគ្គល នៃនីតិសាធារណៈ ដែលទទួលបន្ទុកចម្បងនូវបេសកកម្មផ្នែកសេវាសាធារណៈជាលក្ខណៈ រដ្ឋបាល សង្គម សុខាភិបាល វប្បធម៌ វិទ្យាសាស្ត្រ ឬ បច្ចេកទេស (ព្រះរាជក្រឹត្យ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

លេខ នស/រកក/១២៩៧/៩១ ស្តីពីលក្ខន្តិកៈគតិយុត្តិនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល មាត្រា ១)។ គ្រឹះស្ថានសាធារណៈរដ្ឋបាល មានស្វ័យភាពហិរញ្ញវត្ថុ ។

**សហគ្រាសសាធារណៈ** គឺជាសហគ្រាសដែលមានដើមទុនទាំងអស់ ឬ ភាគច្រើនជារបស់រដ្ឋ ។ សហគ្រាសសាធារណៈមានបេសកកម្មបង្កលក្ខណៈដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកិច្ច ជាអាទិ៍ ក្នុងការបង្កើនតម្លៃធនធានធម្មជាតិ និង ការបង្កើនអាជីព (ច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ ដែលប្រកាសអោយប្រើដោយ ព្រះរាជក្រម ជស/រកម/០៦៩៦/០៣ មាត្រា ២) ។ សហគ្រាសសាធារណៈ គឺជានីតិបុគ្គលដែលមានដែលមានស្វ័យភាពហិរញ្ញវត្ថុ ។

**សហគ្រាសសាធារណៈ** មានទម្រង់ជា៖

- គ្រឹះស្ថានសាធារណៈដែលមានលក្ខណៈសេដ្ឋកិច្ច
- ក្រុមហ៊ុនរដ្ឋ
- ក្រុមហ៊ុនចម្រុះដែលក្នុងនោះរដ្ឋកាន់កាប់ដោយផ្ទាល់ ឬ ដោយប្រយោលលើសពី ៥១%នៃដើមទុនក្រុមហ៊ុន ឬ សិទ្ធិបោះឆ្នោត ។

សហគ្រាសសាធារណៈត្រូវអនុវត្តតាមគោលការណ៍ និង បែបបទនៃនីតិក្រុមហ៊ុនពាណិជ្ជកម្មក្នុងទំនាក់ទំនងរបស់ខ្លួនជាមួយតតិយជន (អនុក្រឹត្យលេខ ៤១ អនក្របក ចុះថ្ងៃទី ៦ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការអនុវត្តព្រះរាជក្រមលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ មាត្រា ៤) ។ សហគ្រាសសាធារណៈត្រូវកាន់កាប់បញ្ជីគណនេយ្យតាមទម្រង់ប្លង់គណនេយ្យជាតិ និង អនុលោមតាមគោលការណ៍គណនេយ្យទូទៅសម្រាប់ក្រុមហ៊ុនពាណិជ្ជកម្ម (មាត្រា ៥) ។ បុគ្គលិកនៃសហគ្រាសសាធារណៈត្រូវស្ថិតនៅក្រោមលក្ខន្តិកៈដោយឡែក ដែលសម្រេចដោយក្រុមប្រឹក្សាភិបាល និង ក្រោមអំណាចនៃច្បាប់ឯកជន លើកលែងតែមន្ត្រីរាជការដែលត្រូវបានតែងតាំងអោយកាន់កាប់តំណែងជាអ្នកដឹកនាំសហគ្រាសសាធារណៈ ។

ជាគោលការណ៍ ទស្សនទាន «**សហគ្រាសសាធារណៈ**» មិនសំដៅដល់ទម្រង់គតិយុត្តិឡើយ ក៏ប៉ុន្តែផ្តោតលើអង្គភាពឧស្សាហកម្ម និង ពាណិជ្ជកម្ម អង្គភាពសាធារណៈ និង សហគ្រាស ដែលមានកម្មសិទ្ធិរបស់រដ្ឋ ។

**គ្រឹះស្ថានសាធារណៈដែលមានលក្ខណៈសេដ្ឋកិច្ច** ជានីតិបុគ្គលនៃនីតិសាធារណៈ ដែលមានស្វ័យភាពហិរញ្ញវត្ថុ (មាត្រា ២៦ ច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ជស/រកម/០៦៩៦/០៣) ។ របបហិរញ្ញវត្ថុរបស់ **គ្រឹះស្ថានសាធារណៈដែលមានលក្ខណៈសេដ្ឋកិច្ច**


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ត្រូវបានកំណត់ដោយលក្ខន្តិកៈរបស់គ្រឹះស្ថាននោះ ។

**ក្រុមហ៊ុនរដ្ឋ** ត្រូវបានបង្កើតឡើងដោយអនុក្រឹត្យ តាមការស្នើរួមគ្នារបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ក្រសួងអាណាព្យាបាល ឬ អាជ្ញាធរអាណាព្យាបាល ។ អនុក្រឹត្យនេះកំណត់ជាអាទិ៍អំពីកម្មវត្ថុរបស់ក្រុមហ៊ុន ទម្រង់គតិយុត្តិ ក្រសួងអាណាព្យាបាល ឬ អាជ្ញាធរអាណាព្យាបាល របបត្រួតពិនិត្យដែលត្រូវអនុវត្ត សមាសភាពរបស់ក្រុមប្រឹក្សាភិបាល ។ លក្ខន្តិកៈរបស់ក្រុមហ៊ុនរដ្ឋកំណត់ជាអាទិ៍អំពីចំនួនទឹកប្រាក់ និង ប្រភេទនៃភាគទុន ការរៀបចំរដ្ឋបាល និង ហិរញ្ញវត្ថុ វិធាននៃការប្រព្រឹត្តទៅរបស់ក្រុមហ៊ុន ។

**ក្រុមហ៊ុនចម្រុះ** គឺជាក្រុមហ៊ុនដែលត្រូវបានបង្កើតឡើងតាមគោលការណ៍ និង តាមបែបបទទាំងឡាយនៃនីតិក្រុមហ៊ុនពាណិជ្ជកម្ម ហើយដែលដើមទុនត្រូវបានកាន់កាប់រួមគ្នាដោយនីតិបុគ្គល ឬ រូបវន្តបុគ្គលឯកជន និង នីតិបុគ្គលរដ្ឋ ។ កាលណាភាគកម្មសាធារណៈលើសពី ៥១%នៃដើមទុន ឬ សិទ្ធបោះឆ្នោត ក្រុមហ៊ុនចម្រុះត្រូវបានចាត់ទុកជាសហគ្រាសសាធារណៈ ។

## ២. វិមជ្ឈការ «បច្ចេកទេស» និង គ្រឹះស្ថានសាធារណៈ

នៅក្នុងព្រះរាជាណាចក្រកម្ពុជា មានគ្រឹះស្ថានសាធារណៈ ២ ប្រភេទ៖

- **គ្រឹះស្ថានសាធារណៈរដ្ឋបាល** និង
- **គ្រឹះស្ថានសាធារណៈដែលមានលក្ខណៈសេដ្ឋកិច្ច**

គ្រឹះស្ថានទាំងនេះជានីតិបុគ្គលនៃនីតិសាធារណៈ ។ គ្រឹះស្ថានសាធារណៈប្រភេទពិសេសអាចត្រូវបានបង្កើតឡើងដោយព្រះរាជក្រម ដូចជាការបង្កើតឡើងនៃ **ធនាគារជាតិនៃកម្ពុជា** ។

### ២.១. គ្រឹះស្ថានសាធារណៈរដ្ឋបាល

ព្រះរាជក្រឹត្យ លេខ នស/រកក/១២៩៧/៩១ ស្តីពីលក្ខន្តិកៈគតិយុត្តិនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល បានចែងថា ÷ «**គ្រឹះស្ថានសាធារណៈរដ្ឋបាល** ត្រូវបានបង្កើតឡើងដោយអនុក្រឹត្យ តាមសំណើរួម របស់ក្រសួង ឬ អាជ្ញាធរអាណាព្យាបាលបច្ចេកទេស និង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។ អនុក្រឹត្យស្តីពីការបង្កើតគ្រឹះស្ថាននេះត្រូវកំណត់ជាពិសេស នូវបេសកកម្ម បុព្វសិទ្ធិ ភាតព្វកិច្ច សមាសភាពនៃក្រុមប្រឹក្សាភិបាល ព្រមទាំងវិធានពិសេសសម្រាប់អនុវត្តក្នុងការគ្រប់គ្រង និង ការត្រួតពិនិត្យលើគ្រឹះស្ថាន ។ អនុក្រឹត្យនេះ ត្រូវបញ្ជាក់ផងដែរនូវក្រសួង និង អាជ្ញាធរអាណាព្យាបាល ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ការប្រព្រឹត្តទៅរបស់គ្រឹះស្ថានត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុង ដែលរៀបចំ និងស្នើឡើងដោយប្រធានស្ថាប័ន ឬ អាជ្ញាធរអាណាព្យាបាលបច្ចេកទេស និង រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ» (មាត្រា ៣) ។

### ២.១.១. ក្រុមប្រឹក្សាភិបាល

**គ្រឹះស្ថានសាធារណៈរដ្ឋបាល** ត្រូវដឹកនាំដោយក្រុមប្រឹក្សាភិបាលមួយ ដែលត្រូវមានសមាជិកយ៉ាងតិច ៥ រូប និងយ៉ាងច្រើន ១១ រូប ដែលក្នុងនោះជាចាំបាច់ត្រូវមានតំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តំណាងក្រសួងអាណាព្យាបាលបច្ចេកទេស និង តំណាងទីស្តីការគណៈរដ្ឋមន្ត្រី ។ ក្រុមប្រឹក្សាត្រូវ៖

- សម្រេចលើចំណូល និង ចំណាយប្រចាំឆ្នាំ និង លើថវិកាប្រចាំឆ្នាំរបស់គ្រឹះស្ថាន
- ពិនិត្យសម្រេចលើរបាយការណ៍គ្រប់គ្រង និង លើគណនីហិរញ្ញវត្ថុប្រចាំឆ្នាំ
- កំណត់ការរៀបចំរចនាសម្ព័ន្ធ និងភារកិច្ចទូទៅរបស់អង្គភាពចំណុះផ្សេងៗទៀត
- ជម្រុញដំណើរការរបស់គណៈកម្មាធិការ និង គណៈកម្មការដែលមានគ្រោងក្នុងអនុក្រឹត្យស្តីពីការបង្កើតគ្រឹះស្ថាន ឬ ក្នុងបទបញ្ជាផ្ទៃក្នុងហើយចាត់ការបង្កើតគណៈកម្មាធិការ និង គណៈកម្មការប្រសិនបើមានការ ចាំបាច់
- កំណត់នូវបែបបទធ្វើការជ្រើសរើស ការតម្លើងឋានន្តរសក្តិ ឬ ការផ្តល់លាភការ ដោយពុំប៉ះពាល់ដល់បទប្បញ្ញត្តិនៃច្បាប់ ឬ បទបញ្ជាពាក់ព័ន្ធដល់ប្រយោជន៍បុគ្គលិករបស់គ្រឹះស្ថាន
- សម្រេចលើក្របខ័ណ្ឌចំនួនបុគ្គលិកដែលអនុញ្ញាតសម្រាប់គ្រឹះស្ថាន
- សម្រេចលើកិច្ចសន្យាស្តីពីលទ្ធកម្ម
- ធ្វើការវាយតម្លៃតាមចន្លោះពេលទៀងទាត់ នូវលទ្ធផលសម្រេចបាន និង លើវិធានការកែតម្រូវសម្រាប់អនុវត្ត

ក្រុមប្រឹក្សាភិបាល «អាចផ្ទេរអំណាចចាំបាច់ សំរាប់ដំណើរការប្រចាំថ្ងៃរបស់គ្រឹះស្ថាន ទៅអោយប្រធាន ឬ នាយករបស់គ្រឹះស្ថាន តែការផ្ទេរអំណាចនេះ ពុំមែនជាការផ្ទេរការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលឡើយ» (មាត្រា ៩)។

ក្រុមប្រឹក្សាភិបាលត្រូវរួមប្រជុំរាល់ពេលដែលផលប្រយោជន៍របស់គ្រឹះស្ថានតម្រូវ និង យ៉ាងតិចបីខែម្តង ។ នាយកត្រូវចូលរួមក្នុងការប្រជុំរបស់ក្រុមប្រឹក្សាភិបាល តែគ្មានសិទ្ធិបោះឆ្នោតទេ (មាត្រា ១០) ។



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

«ក្នុងរយៈពេល ១៥ បន្ទាប់ពីការប្រជុំក្រុមប្រឹក្សាភិបាល ប្រធាន ឬ នាយក ត្រូវផ្ញើជូនប្រធានស្ថាប័ន ឬ អាជ្ញាធរអាណាព្យាបាលបច្ចេកទេស និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នូវកម្មវិធីអភិវឌ្ឍន៍ និងគម្រោងថវិកា ដើម្បីសុំការយល់ព្រម ។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មានរយៈពេល ១ខែ គិតចាប់ពីថ្ងៃដែលបានទទួលឯកសារ ដើម្បីរៀបចំយោបល់របស់ខ្លួនជូនរដ្ឋមន្ត្រីក្រសួងអាណាព្យាបាលបច្ចេកទេស ។ ប្រធានស្ថាប័ន ឬ អាជ្ញាធរអាណាព្យាបាលបច្ចេកទេសមានពេល ២ ខែ គិតចាប់ពីថ្ងៃដែលបានទទួលឯកសារដែលបញ្ជូនដោយប្រធាន ឬ នាយកដើម្បីសម្រេចផ្តល់ការយល់ព្រមលើឯកសារទាំងនោះ ។

ក្នុងករណីប្រធានស្ថាប័ន ឬ អាជ្ញាធរអាណាព្យាបាលបច្ចេកទេស មិនបានឆ្លើយតបតាមរយៈពេលកំណត់ទេនោះ កម្មវិធីអភិវឌ្ឍន៍ ឬ គម្រោងថវិកា ត្រូវចាត់ទុកថាបានទទួលការឯកភាព» (មាត្រា ២៩) ។ បទបញ្ញត្តិដូចគ្នានេះត្រូវអនុវត្តផងដែរចំពោះរបាយការណ៍លើការគ្រប់គ្រង និងលើគណនីហិរញ្ញវត្ថុប្រចាំឆ្នាំ ។

### ២.១.២. អាណាប័ក

ប្រធានក្រុមប្រឹក្សាភិបាល ឬ នាយកជាអាណាប័កដើមខ្សែរបស់គ្រឹះស្ថាន ។ ក្នុងន័យនេះ ប្រធាន ឬ នាយកត្រូវមានភារកិច្ចពិនិត្យប្រាក់ និង ទូទាត់ចំណូល ចាត់ចែងធ្វើការទូទាត់ និង ចេញបញ្ជាចំណាយ (មាត្រា១៧) ។ គ្រឹះស្ថានត្រូវស្ថិតនៅក្រោមគោលការណ៍នៃគណនេយ្យសាធារណៈ លើការគ្រប់គ្រងផ្នែកហិរញ្ញវត្ថុ និង គណនេយ្យ (មាត្រា ១៦) ។

### ២.១.៣. ការត្រួតពិនិត្យហិរញ្ញវត្ថុ

គ្រឹះស្ថានសាធារណៈរដ្ឋបាលត្រូវស្ថិតក្រោមការត្រួតពិនិត្យជាមុន និងជាក្រោយលើគ្រឹះស្ថាន ដោយមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុមួយរូប ដែលតែងតាំងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ (មាត្រា ៣៦) ។

### ២.១.៤. គណនេយ្យករ

«គ្រឹះស្ថានសាធារណៈរដ្ឋបាលមានគណនេយ្យករម្នាក់ ដែលតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ» (មាត្រា ១៨)។ «ប្រតិបត្តិការហិរញ្ញវត្ថុ និង ការកាន់កាប់គណនេយ្យត្រូវអនុវត្តដោយអនុលោមតាមបទបញ្ញាផ្ទៃក្នុងរបស់គ្រឹះស្ថាន ក្រោមការទទួលខុសត្រូវផ្ទាល់របស់គណនេយ្យករ» (មាត្រា ១៨) ។

### ២.១.៥. ប្រភពធនធាន

ប្រភពធនធានរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលរួមមានធនធានតំបូងដែលរដ្ឋផ្តល់អោយ ការផ្ទេរក្នុង

លក្ខណៈជាអន្តរាគមន៍សាធារណៈ អាករដែលសហគ្រាសមានសិទ្ធិទទួលដោយផ្ទាល់ ហើយត្រូវបានគ្រោងទុកក្នុងថវិកាប្រចាំឆ្នាំរបស់គ្រឹះស្ថាន ការផ្ទេរពន្ធ និងអាករចូលក្នុងប្រាក់ចំណេញរបស់គ្រឹះស្ថាន អំណោយ កម្រៃនៃទ្រព្យសម្បត្តិរបស់គ្រឹះស្ថាន (មាត្រា ១៩) ។

### ២.១.៦. ថវិកា

«ចំណូល និងចំណាយចរន្ត និងជាមូលធនរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលត្រូវបានគ្រោងទុកក្នុងថវិកាប្រចាំឆ្នាំ ។ ក្រុមប្រឹក្សាភិបាលរបស់គ្រឹះស្ថាន ត្រូវចែងអំពីបែបបទនៃការរៀបចំ ការចាត់ចែង និងអនុវត្តថវិកា ។ សេចក្តីសំរេចទាំងឡាយរបស់ក្រុមប្រឹក្សាភិបាលទាក់ទងនឹងទម្រង់បែបបទនៃការរៀបចំ ការចាត់ចែង និងអនុវត្តថវិកា ត្រូវមានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ» (មាត្រា ១៩) ។

### ២.១.៧. គណនេយ្យ

«ការងារគណនេយ្យរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលមួយរួមមាន៖

- គណនេយ្យទូទៅ កាន់កាប់ជាគណនេយ្យទ្វេភាគ ដែលចែងអំពីប្រតិបត្តិការថវិកា រតនាគារ និងប្រតិបត្តិការដែលអនុវត្តជាមួយតតិយជន
- គណនេយ្យអចលនទ្រព្យ រូបធាតុ និងមូលប័ត្រ
- គណនេយ្យវិភាគ ប្រសិនបើជាការចាំបាច់

គណនេយ្យរបស់គ្រឹះស្ថានត្រូវ ÷

- ស្របតាមវិធានដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- គោរពតាមប្លង់គណនេយ្យរបស់គ្រឹះស្ថាន ដែលសម្រេចដោយក្រុមប្រឹក្សាភិបាល (ប្លង់នេះត្រូវតែទទួលការយល់ព្រមពីរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ» (មាត្រា ២០) ។

### ២.១.៨. មូលនិធិ

«មូលនិធិរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល គឺជាមូលនិធិសាធារណៈដែលត្រូវដាក់ចូលក្នុងគណនីមួយនៅរតនាគារជាចាំបាច់ លើកលែងមានបដិប្បញ្ញត្តិដែលត្រូវមានការយល់ព្រម តាមប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ» (មាត្រា ២១)។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

### ២.១.៩. បុព្វសិទ្ធិ

«អនុក្រឹត្យស្ដីពីការបង្កើតគ្រឹះស្ថានសាធារណៈរដ្ឋបាល អាចចែងនូវការ ផ្ដល់បុព្វសិទ្ធិ នៃអំណាចសាធារណៈ ក្នុងការប្រមូលចំណូល ការសងបំណុល និងការការពារទ្រព្យសម្បត្តិ» (មាត្រា ២៣) ។

### ២.១.១០. របបសារពើពន្ធ

«លើកលែងមានបដិប្បញ្ញត្តិដែលចែងដោយច្បាប់ គ្រឹះស្ថានសាធារណៈរដ្ឋបាលត្រូវស្ថិតក្រោមនីតិរបបចំពោះរបបសារពើពន្ធ ដូចដែលត្រូវបានអនុវត្តលើអង្គភាពនានារបស់រដ្ឋ» (មាត្រា ២៤) ។

### ២.១.១១. លទ្ធកម្ម

«ការសំរេច ការអនុវត្ត និងការត្រួតពិនិត្យលើលទ្ធកម្ម ក្នុងគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវគ្រប់គ្រងដោយបទប្បញ្ញត្តិនៃលទ្ធកម្មសាធារណៈ...» (មាត្រា ២៥) ។

«ការគ្រប់គ្រងរបស់អាណាប័កដើមខ្សែលើគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវស្ថិតក្រោមការត្រួតពិនិត្យរបស់អគ្គាធិការដ្ឋានហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ» (មាត្រា ៣៧) ។

### ២.១.១២. ការត្រួតពិនិត្យតាមក្រោយ ឬ ក្នុងពេលដំណាលគ្នា

«ការគ្រប់គ្រងរបស់គណនេយ្យករ ត្រូវស្ថិតក្រោមការត្រួតពិនិត្យរបស់គណនេយ្យករកណ្ដាលនៃរតនាគារជាតិ និង ក្រោមការត្រួតពិនិត្យរបស់អគ្គាធិការដ្ឋាននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ» (មាត្រា ៣៧) ។

### ២.១.១៣. បុគ្គលិក

«បុគ្គលិកអចិន្ត្រៃយ៍របស់គ្រឹះស្ថានសាធារណៈរដ្ឋបាល រួមមានមន្ត្រីរាជការដែលត្រូវបានតែងតាំង ឬ ផ្ទេរបញ្ជូនមកបម្រើការងារនៅក្នុងគ្រឹះស្ថាន ដោយអនុលោមតាមបទបញ្ញាទាំងឡាយនៃច្បាប់ និងអត្ថបទពាក់ព័ន្ធដទៃទៀតរបស់មុខងារសាធារណៈ និងអនុក្រឹត្យស្ដីពីការបង្កើតគ្រឹះស្ថាន» (មាត្រា ១៣) ។

«អនុក្រឹត្យស្ដីពីការបង្កើតគ្រឹះស្ថាន អាចអនុញ្ញាតឱ្យជ្រើសរើសបុគ្គលិកក្រៅក្របខ័ណ្ឌនៃមុខងារសាធារណៈតាមរយៈកិច្ចសន្យា ដើម្បីបំពេញការងារពិសេសណាមួយ ។ បុគ្គលិកទាំងនេះត្រូវស្ថិតក្រោមការគ្រប់គ្រងនៃបទបញ្ជាផ្ទៃក្នុង និងការសំរេចរបស់ក្រុមប្រឹក្សាភិបាល ស្របតាមច្បាប់ស្ដីពីការងារ» (មាត្រា ១៣) ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

### ២.១.១៤. បេតិកភណ្ឌ

«គ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវទទួលគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ហើយមានសិទ្ធិពេញលេញលើទ្រព្យនោះ ។ គ្រឹះស្ថានសាធារណៈរដ្ឋបាលអាចមានទ្រព្យផ្ទាល់ខ្លួន ដែលស្ថិតជាកម្មសិទ្ធិឯកជន ហើយដែលអាចទទួលយក និង គ្រប់គ្រងបាន ដោយអនុលោមទៅតាមបទបញ្ញត្តិនៃបទបញ្ជាផ្ទៃក្នុង» (មាត្រា ១៥) ។

ទ្រព្យសម្បត្តិរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល មិនអាចរឹបអូសបានទេ ប្រសិនបើលក្ខន្តិកៈបង្កើតគ្រឹះស្ថានមិនបានចែង ។

### ២.១.១៥. សវនកម្ម

«របាយការណ៍ហិរញ្ញវត្ថុ...ដោយរួមបញ្ចូលតារាងតុល្យការ របាយការណ៍ចំណេញ-ខាត និងការវិភាគគណនី...» ត្រូវបានធ្វើសវនកម្មដោយអាជ្ញាធរសវនកម្មជាតិ (មាត្រា ៥ នៃច្បាប់លេខ ១០ ចុះថ្ងៃ ៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា) ។

## ២.២. គ្រឹះស្ថានសាធារណៈដែលមានលក្ខណៈសេដ្ឋកិច្ច

**ច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ** ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៦ កំណត់នូវប្រភេទគតិយុត្តិនៃសហគ្រាសសាធារណៈដែលមានទម្រង់ជា «គ្រឹះស្ថានសាធារណៈដែលមានលក្ខណៈសេដ្ឋកិច្ច» ក្រុមហ៊ុនរដ្ឋ និងក្រុមហ៊ុនចម្រុះ ។

**គ្រឹះស្ថានសាធារណៈដែលមានលក្ខណៈសេដ្ឋកិច្ច** «ជានីតិបុគ្គលនៃនីតិសាធារណៈ ដែលមានស្វ័យភាពហិរញ្ញវត្ថុ» (មាត្រា ៣) ។

### ២.២.១. ក្រុមប្រឹក្សាភិបាល

**គ្រឹះស្ថានសាធារណៈដែលមានលក្ខណៈសេដ្ឋកិច្ច** ត្រូវបានគ្រប់គ្រងដោយក្រុមប្រឹក្សាភិបាលមួយ ដែលមានសមាជិកយ៉ាងច្រើនបំផុតត្រឹម ៧ នាក់ ។ ការគ្រប់គ្រង «ត្រូវអនុលោមតាមគោលការណ៍ និងបែបបទទាំងឡាយនៃនីតិក្រុមហ៊ុនពាណិជ្ជកម្ម» ។ ក្នុងចំណោមសមាជិកក្រុមប្រឹក្សាភិបាលត្រូវមានអាសនៈមួយកន្លែងសម្រាប់តំណាងនិយោជិត (មាត្រា ៩) ។

«សមាជិកក្រុមប្រឹក្សាភិបាលទាំងអស់ លើកលែងតែអ្នកតំណាងនិយោជិត មិនមានលក្ខណៈជាបុគ្គលិករបស់សហគ្រាសឡើយ ដូចនេះមិនអាចទទួលប្រាក់បៀវត្សឡើយ ។ តាមសំណើរបស់ក្រុមប្រឹក្សាភិបាល



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

រដ្ឋមន្ត្រីអាណាព្យាបាលបច្ចេកទេស និង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជាអ្នកសម្រេចរួម ជាគោលការណ៍ចំពោះលាភការសម្រាប់មុខងារជា សមាជិកក្រុមប្រឹក្សាភិបាល និងកំណត់ទឹកប្រាក់នៃលាភការដែលត្រូវផ្តល់ជូន» (មាត្រា ១១.២ អនុក្រឹត្យ ៤១ ឆ្នាំ ១៩៩៧ ស្តីពីការអនុវត្តច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ) ។

ក្រុមប្រឹក្សាភិបាលមានភារកិច្ចជាអាទិ៍៖

- សម្រេចគម្រោងអភិវឌ្ឍន៍សហគ្រាស
- វាយតម្លៃនូវលទ្ធផលសម្រេចបាន និងលើកវិធានការកែតម្រូវសម្រាប់អនុវត្ត
- សម្រេចគម្រោងថវិកាសម្រាប់ការប្រព្រឹត្តទៅ និងការវិនិយោគ ព្រមទាំងហិរញ្ញប្បទាន
- អនុម័តតារាងតុល្យការ និង គណនីគ្រប់គ្រងទាំងឡាយរបស់គ្រឹះស្ថាន
- កំណត់រចនាសម្ព័ន្ធរបស់សហគ្រាស លក្ខន្តិកៈបុគ្គលិក និងរបបបៀវត្ស
- អនុម័តកិច្ចលទ្ធកម្មសាធារណៈ ។

### ២.២.២. នាយកប្រតិបត្តិ: ប្រធានអគ្គនាយក ឬ អគ្គនាយក

«ក្រុមប្រឹក្សាភិបាលប្រគល់អោយប្រធានអគ្គនាយក ឬ អគ្គនាយកនូវអំណាចចាំបាច់សម្រាប់ដំណើរការសហគ្រាសប្រចាំថ្ងៃ ។ ប៉ុន្តែការប្រគល់សិទ្ធិនេះ មិនមែនជាការផ្ទេរការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលឡើយ» (មា ត្រា ១០) ។

### ២.២.៣. ដំណើរការហិរញ្ញវត្ថុ

គ្រឹះស្ថាននេះ ត្រូវស្ថិតក្រោមបទប្បញ្ញត្តិនៃការបែងចែករវាងអាណាប័ក និងគណនេយ្យករ និងបទប្បញ្ញត្តិផ្សេងៗទៀតនៃគណនេយ្យសាធារណៈ (មាត្រា ៥.២ នៃអនុក្រឹត្យលេខ ៤១ ចុះថ្ងៃ ៦ សីហា ឆ្នាំ ១៩៩៧ ស្តីពីការអនុវត្តច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ) ។

### ២.២.៤. អាណាព្យាបាល

សហគ្រាសសាធារណៈដែលមានលក្ខណៈសេដ្ឋកិច្ចត្រូវផ្តល់ជូនទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រួមនឹងក្រសួងអាណាព្យាបាល ឬ អាជ្ញាធរអាណាព្យាបាលបច្ចេកទេស នូវឯកសារដូចតទៅ៖ កំណត់ហេតុប្រជុំក្រុមប្រឹក្សាភិបាល ថវិកាសម្រាប់ដំណើរការ និង ការវិនិយោគ របាយការណ៍លម្អិតស្តីពីសកម្មភាព


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

តារាងតុល្យការ និងគណនី និង របាយការណ៍ពាក់ព័ន្ធនឹងការត្រួតពិនិត្យគណនី នៅក្នុងរយៈពេលមួយដែលមិនលើសពី ១៥ ថ្ងៃ (មាត្រា ១៦) ។

### ២.២.៥. ការត្រួតពិនិត្យ និងសវនកម្ម

សហគ្រាសសាធារណៈត្រូវស្ថិតក្រោមការត្រួតពិនិត្យរបស់រដ្ឋ (មាត្រា ៧ និង មាត្រា ២១ ដល់ ២៥) ។ «មន្ត្រីត្រួតពិនិត្យរដ្ឋ ដែលនៅអមសហគ្រាសសាធារណៈដែលមានលក្ខណៈសេដ្ឋកិច្ចទទួលបន្ទុកការងារត្រួតពិនិត្យជាអាទិ៍លើ÷

- ការបំពេញកាតព្វកិច្ចរបស់សហគ្រាសសាធារណៈ ដែលបានចែងក្នុងច្បាប់និងបទបញ្ញាទាំងឡាយជាធរមាន
- ការអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល
- ការតាមដានការប្រព្រឹត្តទៅ និងការវិវឌ្ឍរបស់សហគ្រាស
- ប្រក្រតីភាពនៃសកម្មភាពទាំងឡាយ ដែលអាចជះឥទ្ធិពលដល់ស្ថានភាពហិរញ្ញវត្ថុរបស់សហគ្រាស»(មាត្រា ២១) ។

«មន្ត្រីត្រួតពិនិត្យរដ្ឋត្រូវចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាភិបាល មានសិទ្ធិផ្តល់យោបល់ពិគ្រោះ ហើយអាចជំទាស់លើការចាត់វិធានការទាំងឡាយដែលខ្លួនយល់ឃើញថាផ្ទុយនឹងច្បាប់ និងដែលប៉ះពាល់ដល់សិទ្ធិ និងផលប្រយោជន៍របស់សហគ្រាស ឬ របស់រដ្ឋ ឬ ពុំសមស្របនឹងគោលដៅរបស់សហគ្រាស» (មាត្រា ២៤) ។

«គណនីប្រចាំឆ្នាំរបស់សហគ្រាសសាធារណៈ ត្រូវជាកម្មវត្ថុនៃការផ្ទៀងផ្ទាត់និងការបញ្ជាក់របស់ស្នងការគណនី» (មាត្រា ១៤ អនុក្រឹត្យ ៤១) ។ ស្នងការគណនីត្រូវបានបង្កើតឡើងតាមដោយអនុលោមតាមអនុក្រឹត្យលេខ ៤២ អនក្របក ចុះថ្ងៃទី ៦ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីស្នងការគណនីនៃសហគ្រាសសាធារណៈ ។ «របាយការណ៍ហិរញ្ញវត្ថុ...រួមមានតារាងតុល្យការ របាយការណ៍ចំណេញ- ខាត និងការវិភាគគណនី...» ត្រូវបានធ្វើសវនកម្មដោយអាជ្ញាធរសវនកម្មជាតិ (មាត្រា ៥ នៃច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា» ។

### ២.២.៦. បុគ្គលិក

«បុគ្គលិក...ត្រូវស្ថិតក្រោមលក្ខន្តិកៈដោយឡែកដែលសម្រេចដោយក្រុមប្រឹក្សាភិបាល និង ក្រោមអំណាចនៃច្បាប់ឯកជន លើកលែងតែតែមន្ត្រីរាជការដែលត្រូវបានតែងតាំង អោយកាន់កាប់តំណែងជាអ្នកដឹកនាំសហគ្រាស» (មាត្រា ៦ អនុក្រឹត្យ ៤១) ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

### ២.២.៧. បេតិកភ័ណ្ឌ

បេតិកភ័ណ្ឌត្រូវស្ថិតក្រោមច្បាប់ពាណិជ្ជកម្ម ។

## ៣. ទិមដ្ឋការ «ដែនដី» និង រដ្ឋបាលថ្នាក់ក្រោមជាតិ

### ៣.១. ថវិកាខេត្ត-ក្រុង

ច្បាប់លេខ ២៩៨ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ស្តីពីរបបហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិខេត្ត-ក្រុង បានចែងក្នុងមាត្រា ទី ២ ថា «ខេត្ត និងក្រុង ជានីតិបុគ្គលនៃច្បាប់សាធារណៈ ។ ខេត្ត-ក្រុង...មានថវិកា និងទ្រព្យសម្បត្តិទាំងឡាយដែលកំណត់ដោយច្បាប់» ។

#### ៣.១.១. អង្គភាពពិគ្រោះយោបល់

នៅថ្នាក់ខេត្ត-ក្រុងគ្មានអង្គភាពពិគ្រោះឡើយ ។

#### ៣.១.២. អំណាចនីតិប្រតិបត្តិ

អភិបាលខេត្ត និង អភិបាលក្រុងជាអំណាចនីតិប្រតិបត្តិ នៅក្នុងខេត្ត និង ក្រុង (មាត្រា ៦ នៃច្បាប់ឆ្នាំ ១៩៩៨) ។

#### ៣.១.៣. គណនេយ្យករ

«មុខងារគណនេយ្យករខេត្ត-ក្រុង ត្រូវកាន់កាប់ដោយគណនេយ្យកររបស់រតនាគារដែលតែងតាំងដោយរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ» (មាត្រា ២៣) ។

#### ៣.១.៤. ថវិកា

«ថវិកាស្វយ័តត្រូវបំពេញដោយចំណូលសារពើពន្ធ និង មិនមែនសារពើពន្ធ» (មាត្រា ៧) ។ «គម្រោងថវិកាខេត្ត-ក្រុង...ត្រូវបញ្ជូនមកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ...យ៉ាងយូរបំផុតត្រឹមថ្ងៃទី ១ ខែ កញ្ញា នៃឆ្នាំនីមួយៗ...។ គម្រោងថវិកាខេត្ត-ក្រុងទាំងអស់ ជាកញ្ចប់រួមដែលត្រួតពិនិត្យ និងអនុម័តដោយសភាជាតិក្នុងក្របខ័ណ្ឌនៃថវិកាទូទៅរបស់រដ្ឋ ។ កញ្ចប់នេះ ត្រូវបានកំណត់ដោយផ្អែកលើមូលដ្ឋានតុល្យភាពសេដ្ឋកិច្ច ។ កញ្ចប់នេះ ត្រូវបានបែងចែករវាងខេត្ត-ក្រុង តាមរយៈប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បន្ទាប់ពីបានទទួលយោបល់ឯកភាពពីក្រសួងមហាផ្ទៃ» (មាត្រា ១៨) ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

«ឥណទានដែលបានបម្រុងដោយរដ្ឋ សម្រាប់កម្មវិធីអភិវឌ្ឍន៍...និងគម្រោងថ្នាក់ខេត្ត... ត្រូវបានផ្ទេរទៅអោយថវិកាខេត្ត-ក្រុង និងត្រូវចាត់ទុកជាប្រភពធនធាន និងចំណាយផ្ទាល់ ដោយអនុលោមតាមច្បាប់ស្តីពីហិរញ្ញវត្ថុ» (មាត្រា ១៩) ។

### ៣.១.៥. ធនធាន

«ត្រូវបានបង្វែរពីថវិការដ្ឋ ចូលទៅថវិកាខេត្ត-ក្រុង នូវចំណូលសារពើពន្ធ និងមិនមែនសារពើពន្ធដូចខាងក្រោម៖

*ចំណូលសារពើពន្ធ :*

- ពន្ធលើដី-ធ្លី ដែលមិនបានប្រើប្រាស់
- ពន្ធប្រថាប់ត្រា
- ពន្ធប៉ាតង់
- ពន្ធលើសត្តឃាតដ្ឋាន
- ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ

*ចំណូលមិនមែនសារពើពន្ធ :*

- ការផ្គត់ផ្គង់អគ្គិសនី និងទឹកស្អាតនៅក្នុងខេត្ត
- ផលទុននៃរដ្ឋាករទឹកនៅខេត្ត-ក្រុង
- ចំណូលពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ (ផ្សារ ចំណតរថយន្ត កំពង់ចំលង-សាឡាង កន្លែងលក់ដេញថ្លៃ)
- ចំណូលមិនមែនសារពើពន្ធផ្សេងៗទៀតរបស់ខេត្ត...

*ចំណូលមិនមែនសារពើពន្ធសំរាប់ជាគុណប្រយោជន៍ខេត្ត-ក្រុង :*

- ចំណូលសម្រាប់ទំរង់ការរដ្ឋបាល...
- ចំណូលសម្រាប់ការអនុញ្ញាតរដ្ឋបាល...



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

- ចំណូលសម្រាប់សេវាកម្មសាធារណៈ...» (មាត្រា ១៧) ។

### ៣.១.៦. បេតិកភណ្ឌ

«រដ្ឋប្រគល់អោយខេត្ត- ក្រុងនីមួយៗ នូវសិទ្ធិកាន់កាប់ទ្រព្យសម្បត្តិសាធារណៈអចលនៈវត្ថុមួយចំនួន ដែលស្ថិតនៅក្នុងមណ្ឌលដែនដីនៃខេត្ត- ក្រុង...» (មាត្រា ៩) ។

### ៣.១.៧. របបហិរញ្ញវត្ថុ

«ការអនុវត្តថវិការបស់ខេត្ត- ក្រុង ស្ថិតនៅក្រោមបទបញ្ញត្តទូទៅនៃគណនេយ្យសាធារណៈ ការត្រួតពិនិត្យហិរញ្ញវត្ថុ និង លទ្ធកម្មសាធារណៈ» (មាត្រា ២៣) ។

### ៣.១.៨. គ្រឹះស្ថានសាធារណៈ និងសហគ្រាសសាធារណៈថ្នាក់ក្រោមជាតិ

«ខេត្ត- ក្រុងអាចបង្កើតសហគ្រាសសាធារណៈ ដើម្បីគ្រប់គ្រងសេវាសាធារណៈមានលក្ខណៈឧស្សាហកម្ម និង ពាណិជ្ជកម្មនៅក្នុងដែនមណ្ឌលដែនដីរបស់ខ្លួន ។ ការរៀបចំ និងការប្រព្រឹត្តទៅនៃសហគ្រាសសាធារណៈទាំងនោះ ត្រូវអនុវត្តតាមច្បាប់ និងបទបញ្ញាជាធរមាន » (មាត្រា ២៦)។

### ៣.១.៩. បុគ្គលិក

«បុគ្គលិករបស់ខេត្ត- ក្រុង ស្ថិតក្រោមលក្ខន្តិកៈទូទៅរបស់មន្ត្រីរាជការស៊ីវិល...» (មាត្រា ២៧) ។

## ៣.២. ឃុំ- សង្កាត់

ការគ្រប់គ្រងរដ្ឋបាលឃុំ- សង្កាត់ ត្រូវរៀបចំឡើងដោយច្បាប់ចុះថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០០១ ស្ដីពីរដ្ឋបាលឃុំ- សង្កាត់ ។

### ៣.២.១. បុគ្គលិកលក្ខណៈ

ច្បាប់ឆ្នាំ ២០០១ បានលើកឡើងពីបុគ្គលិកលក្ខណៈរបស់ឃុំ- សង្កាត់ ក៏ប៉ុន្តែពុំបានបញ្ជាក់ច្បាស់ថា ឃុំ- សង្កាត់ ជានីតិបុគ្គលនៃនីតិសាធារណៈឡើយ ។

### ៣.២.២. ស្ថាប័នពិគ្រោះយោបល់

ឃុំ និង សង្កាត់ ជាអង្គការពិគ្រោះយោបល់មួយ (មាត្រា ៩) ដែលត្រូវបានជ្រើសតាំងដោយប្រជារាស្ត្រ


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

នៅក្នុងមណ្ឌលដែនដីរបស់ខ្លួន ។

ក្រុមប្រឹក្សានេះគ្រប់គ្រងដោយ ប្រធានមួយរូប (មាត្រា ២៥) ដែលជាអ្នកទទួលបានសម្លេងគាំទ្រច្រើនជាងគេនៅក្នុងការបោះឆ្នោត (មាត្រា ៣២) ។ ប្រធានជាអ្នកអនុម័តលើផែនការអភិវឌ្ឍន៍ និងថវិការបស់ឃុំក៏ដូចជាថ្លៃសេវាសង្គមនានា (មាត្រា ២២) ។ ឃុំ-សង្កាត់គ្មានសមត្ថកិច្ចលើគោលនយោបាយសារពើពន្ធឡើយ (មាត្រា ៤៥) ។ អំណាចនីតិប្រតិបត្តិរបស់ឃុំ ត្រូវអនុវត្តតាមរយៈដីកា ដែលត្រូវតែផ្សព្វផ្សាយអោយសាធារណៈជនបានដឹង (មាត្រា ៤៨) ។

### ៣.២.៣. អំណាចនីតិប្រតិបត្តិ

ប្រធានឃុំ ជាប្រធានក្រុមប្រឹក្សា ។ គាត់អាចទទួលការផ្ទេរសិទ្ធិពីក្រុមប្រឹក្សា លើកលែងតែលើការអនុម័តថវិកា និងផែនការអភិវឌ្ឍន៍ ការកំណត់តម្លៃចំណូលសារពើពន្ធ និង មិនមែនសារពើពន្ធ និងការកំណត់ថ្លៃសេវាសង្គមនានា (មាត្រា ៥១) ។ អំណាចនេះមិនអាចផ្ទេរអោយថ្នាក់ក្រោមបានឡើយ ។

### ៣.២.៤. អាណាព្យាបាល

ការត្រួតពិនិត្យភាពស្របច្បាប់នៃការការគ្រប់គ្រង និង ការតាមដានលើវឌ្ឍនភាពរបស់ឃុំនីមួយៗ ត្រូវអនុវត្តដោយក្រសួងមហាផ្ទៃ ។

### ៣.២.៥. បុគ្គលិក

ឃុំនីមួយៗមានលេខាម្នាក់ ដែលផ្តល់ដោយក្រសួងមហាផ្ទៃ ។ លេខានេះ ជាភ្នាក់ងារមុខងារសាធារណៈ (មាត្រា ២៨) ។ ឃុំអាចជ្រើសរើសបុគ្គលិក ក្រៅក្របខ័ណ្ឌរដ្ឋ (មាត្រា ២៩) ។

### ៣.២.៦. ថវិកា

«ឃុំមានធនធានហិរញ្ញវត្ថុផ្ទាល់ ថវិកា និង បេតិកភ័ណ្ឌ» (មាត្រា ៧៣) ។ «ឃុំ-សង្កាត់ មានសិទ្ធិទទួលចំណូលផ្ទាល់ ចំណូលសារពើពន្ធ និង មិនមែនសារពើពន្ធ និង ចំណូលផ្សេងៗសម្រាប់សេវាដែលបានផ្តល់ ។

ចំណូលទាំងនេះនឹងត្រូវទទួលបាន ក្នុងពេលជាមួយគ្នានឹងការទទួលពន្ធលើដី-ធ្លី ពន្ធលើអចលនទ្រព្យ និងពន្ធលើការជួល ។

នៅពេលដែលក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុប្រមូលចំណូលផ្ទាល់ពី ឃុំ-សង្កាត់ ការប្រមូលនេះត្រូវធ្វើឡើងក្នុងនាមឃុំ-សង្កាត់ ។ ប្រភេទនៃចំណូលសារពើពន្ធ និងមិនមែនសារពើពន្ធ ទំហំទឹកប្រាក់ របៀបទទួល



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

និងចំណូលផ្សេងៗទៀតលើសេវាដែលបានផ្តល់ ត្រូវតែកំណត់ដោយច្បាប់» (មាត្រា ៧៤) ។

«ឃុំ- សង្កាត់អាចទទួលការវិភាជន៍បន្ថែមពីរដ្ឋ ។ ការវិភាជន៍នេះមានប្រភពមកពីៈ

- ការបង្វែរដោយផ្នែកនៃចំណូលសារពើពន្ធ និង មិនមែនសារពើពន្ធរបស់រដ្ឋ
- ទាយជ្ជទាន និង ឧបត្ថម្ភកធន ឬ ឧបត្ថម្ភកររដ្ឋ
- ធនធាន ដែលបានបញ្ជាក់ខាងលើ ត្រូវបង្វែរទៅឃុំ- សង្កាត់ តាមរយៈរតនាគារខេត្ត ។
- ការរៀបចំ និងនីតិវិធីនៃការបង្វែរធនធាន ត្រូវកំណត់ដោយអនុក្រឹត្យ» (មាត្រា ៧៥) ។

«ឃុំ- សង្កាត់នីមួយៗមានសិទ្ធិទទួលធនធានសំរាប់ការប្រតិបត្តិលើបេសកកម្ម ដែលបានប្រគល់អោយដោយរដ្ឋ ឬស្ថាប័នរបស់រាជរដ្ឋាភិបាល ក្នុងនាមការភ្នាក់ងាររដ្ឋ ។ ចំណូលនេះជាការធនធានបន្ថែម ដែលបំពេញលើការវិភាជន៍ដែលឃុំបានទទួលពីរដ្ឋ ។ រដ្ឋាភិបាល និង ក្រសួង ឬ ស្ថានប័ននានា ដែលប្រើប្រាស់សេវារបស់ឃុំ - សង្កាត់ ត្រូវផ្តល់កម្រៃសមស្របសំរាប់ការអនុវត្តបេសកកម្មដែលបានពោលខាងលើ ។ ក្នុងករណីដែលការផ្ទេរភារកិច្ចពីរដ្ឋមានលក្ខណៈអចិន្ត្រៃយ៍ រដ្ឋាភិបាលត្រូវលៃទុកធនធានហិរញ្ញវត្ថុដើម្បីធានាការបង្វែរជូនឃុំ- សង្កាត់សម្រាប់រយៈពេលវែង ។ របៀបនៃការទូទាត់ ត្រូវបានចែងតាមរយៈអនុក្រឹត្យ » (មាត្រា ៧៦) ។

«ជារៀងរាល់ឆ្នាំ ឃុំ- សង្កាត់ត្រូវរៀបចំ និង អនុម័តថវិការបស់ខ្លួន ។ ថវិកាឃុំ- សង្កាត់ត្រូវតែរៀបចំ និងអនុម័ត ដោយស្របតាមប្រព័ន្ធថវិកាជាតិ ។ ថវិកាឃុំ- សង្កាត់ត្រូវឈរលើតុល្យភាពទូទៅ ។ ឃុំ- សង្កាត់អាចបង្កើនចំណាយរបស់ខ្លួន តែត្រូវបង្កើនផងដែរនូវចំណូល ដើម្បីប៉ះប៉ូវគ្នា ។ ថវិកាឃុំ- សង្កាត់ត្រូវឆ្លុះបញ្ចាំងពីអាទិភាព និងតំរូវការនៃផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគរបស់ឃុំ ។ នីតិវិធីនៃការរៀបចំ និងការអនុម័តថវិកាឃុំ- សង្កាត់ ត្រូវកំណត់ដោយអនុក្រឹត្យ» (មាត្រា ៧៩) ។

### ៣.២.៧. មូលនិធិឃុំ- សង្កាត់

...«មូលនិធិនេះជាកម្មវត្ថុនៃការបង្វែរចំណូលជាតិ ឬប្រភពធនធានផ្សេងទៀត ចូលទៅថវិកាឃុំ - សង្កាត់...» (មាត្រា ៧៧ ) ។

«**មូលនិធិឃុំ- សង្កាត់** ត្រូវបំពេញដោយ ÷

- ការវិភាជន៍មួយផ្នែកផ្ទាល់ពីថវិកាប្រចាំរបស់រដ្ឋ ដែលកំណត់ដោយអនុក្រឹត្យ
- ទាយជ្ជទាន និងការសុំខ្ចីក្នុងស្រុក ឬក្រៅស្រុក


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

- ការបែងចែកធនធានប្រចាំឆ្នាំដល់ឃុំ- សង្កាត់ តាមរយៈមូលនិធិឃុំ- សង្កាត់ ត្រូវធ្វើឡើងតាមរបៀបមួយ ដែលកំណត់ដោយអនុក្រឹត្យ ។

«របបគ្រប់គ្រង បទប្បញ្ញត្តិប្រើប្រាស់ និងនីតិវិធីទូទាត់ចំណាយរបស់មូលនិធិឃុំ- សង្កាត់ ត្រូវកំណត់ដោយអនុក្រឹត្យ» (មាត្រា ៧៨) ។

### ៣.២.៨. បេតិកភ័ណ្ឌ

«ឃុំ- សង្កាត់អាចទទួលការបង្វែរទ្រព្យមួយផ្នែកពីរដ្ឋ...ឃុំ- សង្កាត់អាចប្រើផលពីទ្រព្យដែលរដ្ឋប្រគល់អោយជាធនធាន ។ ...ឃុំ- សង្កាត់មិនមានសិទ្ធិលក់ ឬផ្ទេរសិទ្ធិលើការប្រើប្រាស់ទ្រព្យទាំងនេះ ដោយមិនមានការយល់ព្រមជាមុនពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុឡើយ បន្ទាប់ពីបានទទួលយោបល់ឯកភាពពីក្រសួងមហាផ្ទៃ» (មាត្រា ៨៣) ។

«ឃុំ- សង្កាត់មិនអាចធ្វើការសុំខ្ចីបានឡើយ ។ ឃុំ- សង្កាត់មិនអាចធានាការខ្ចី ឬ សញ្ញាប័ណ្ណហិរញ្ញវត្ថុដែលមានលក្ខណៈកម្ចីបានឡើយ » (មាត្រា ៨០) ។

### ៣.២.៩. លទ្ធកម្ម

«លទ្ធកម្មរបស់ឃុំ- សង្កាត់ត្រូវស្ថិតក្រោមបទប្បញ្ញត្តិលទ្ធកម្មសាធារណៈ» (មាត្រា ៣ អនុក្រឹត្យ ១០៥ ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០០៦ ស្តីពីលទ្ធកម្មសាធារណៈ) ។

## ៤. វិស័យឯកជនរបស់រដ្ឋ : ក្រុមហ៊ុនរដ្ឋ ឬ ចម្រុះ

### ៤.១. ក្រុមហ៊ុនរដ្ឋ

«ក្រុមហ៊ុនរដ្ឋ គឺជាក្រុមហ៊ុនដែលមានដើមទុនទាំងអស់ជារបស់រដ្ឋ» (ច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ មាត្រា ៣០) ។

បទបញ្ញត្តិទូទៅនេះក៏ត្រូវបានអនុវត្តផងដែរ លើគ្រឹះស្ថានសាធារណៈដែលមានលក្ខណៈសេដ្ឋកិច្ចៈ ក្រុមប្រឹក្សាភិបាល ប្រធានអគ្គនាយក អគ្គនាយកជាដើម ។

«ក្រសួងអាណាព្យាបាល ឬអាជ្ញាធរអាណាព្យាបាលបច្ចេកទេសទទួលខុសត្រូវបំពេញទម្រង់បែបបទនៃការបង្កើតក្រុមហ៊ុនដោយ÷

- រៀបចំលក្ខន្តិកៈរបស់ក្រុមហ៊ុន ដោយមានការព្រមព្រៀងជាមួយនឹងក្រសួងសេដ្ឋកិច្ចនិង ហិរញ្ញវត្ថុ


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

- ចាត់ចែងចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង
- បំពេញទម្រង់បែបបទទាំងអស់តាមគោលការណ៍ និងបែបបទទាំងឡាយនៃនីតិក្រុមហ៊ុនពាណិជ្ជកម្ម» (មាត្រា ៣២) ។

«តាមបដិបញ្ញត្តិលើគោលការណ៍ និងបែបបទទាំងឡាយនៃនីតិក្រុមហ៊ុនពាណិជ្ជកម្ម អំណាចនៃមហាសន្និបាតរបស់ក្រុមហ៊ុន ត្រូវបានប្រគល់ឱ្យក្រុមប្រឹក្សាភិបាល» (មាត្រា ៣៤) ។

ក្រុមហ៊ុនរដ្ឋត្រូវស្ថិតក្រោមការត្រួតពិនិត្យពីស្នងការគណនី ដូចជាគ្រឹះស្ថានសាធារណៈដែលមានលក្ខណៈសេដ្ឋកិច្ច និង ក្រុមហ៊ុនចម្រុះដែរ ។

«របាយការណ៍ហិរញ្ញវត្ថុ...រួមមានតារាងតុល្យការ របាយការណ៍ចំនេញ-ខាត និងការវិភាគណេនី...» ត្រូវបានធ្វើសវនកម្មដោយ **អាជ្ញាធរសវនកម្មជាតិ**» (មាត្រា ៥ នៃច្បាប់លេខ ១០ ចុះថ្ងៃទី៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា ។

## ៤.២. ក្រុមហ៊ុនចម្រុះ

**ក្រុមហ៊ុនចម្រុះ** គឺជាក្រុមហ៊ុនដែលត្រូវបានបង្កើតឡើងតាមគោលការណ៍ និង តាមបែបបទទាំងឡាយនៃនីតិក្រុមហ៊ុនពាណិជ្ជកម្ម ហើយដែលដើមទុនត្រូវបានកាន់កាប់រួមគ្នាដោយនីតិបុគ្គល ឬ រូបវន្តបុគ្គលឯកជន និងនីតិបុគ្គលរដ្ឋ (ច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ មាត្រា ៣៨) ។ ចំណែកនៃដើមទុនរបស់ក្រុមហ៊ុនចម្រុះ ដែលកាន់កាប់ដោយរដ្ឋ ដោយគ្រឹះស្ថានសាធារណៈ ឬ ដោយក្រុមហ៊ុនរដ្ឋ គឺជា «**ភាគកម្មសាធារណៈ**» (មាត្រា ៣៧) ។ ភាគកម្មនេះអាចច្រើន (លើសពី ៥១%) ឬ តិច ។ ក្រុមហ៊ុនមួយត្រូវបានចាត់ទុកថាជា **សហគ្រាសសាធារណៈ** កាលណា **ភាគកម្មសាធារណៈ** មានលើសពី ៥១% នៃដើមទុន ឬ សិទ្ធិបោះឆ្នោត (មាត្រា ៣៨) ។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាអ្នកទទួលបន្ទុកខាងផ្នែករដ្ឋបាលលើភាគកម្មសាធារណៈ (មាត្រា ៣៩)។ ប្រតិបត្តិការហិរញ្ញវត្ថុពាក់ព័ន្ធនឹងភាគកម្មសាធារណៈ ត្រូវបានអនុវត្ត ដោយអនុលោមតាមបទប្បញ្ញត្តិដែលមានចែកក្នុងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និង ច្បាប់ហិរញ្ញវត្ថុជាធរមាន ។

តំណាងរបស់រដ្ឋ របស់គ្រឹះស្ថានសាធារណៈ និងរបស់ក្រុមហ៊ុនរដ្ឋ នៅក្នុងក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុនចម្រុះ ត្រូវបានតែងតាំងដោយអនុក្រឹត្យតាមសំណើរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។ ការទទួលខុសត្រូវផ្នែករដ្ឋប្បវេណី របស់តំណាងរដ្ឋទាំងនោះក្នុងការបំពេញភារកិច្ចរបស់ខ្លួននៅក្នុងក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុនចម្រុះរដ្ឋ


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ត្រូវធ្លាក់លើរដ្ឋ លើគ្រឹះស្ថានសាធារណៈ ឬលើក្រុមហ៊ុនរដ្ឋ តែតំណាងត្រូវទទួលខុសត្រូវខាងផ្នែកព្រហ្មទណ្ឌ (មាត្រា ៤៤) ។

«រដ្ឋត្រូវតំណាងដោយអាណត្តិគាហកៈពិសេស នៅក្នុងមហាសន្និបាតសាមញ្ញ និងវិសាមញ្ញ និង មានសិទ្ធិបោះឆ្នោត ក្នុងនាមរដ្ឋ» (មាត្រា ៤៧) ។

ក្រុមហ៊ុនចម្រុះត្រូវស្ថិតក្រោមការត្រួតពិនិត្យពីស្នងការគណនី ដូចជាសហគ្រាសសាធារណៈមានលក្ខណៈសេដ្ឋកិច្ច និង សហគ្រាសរដ្ឋដែរ ។

«របាយការណ៍ហិរញ្ញវត្ថុ...រួមមានតារាងតុល្យការ របាយការណ៍លទ្ធផល និងការវិភាគគណនី...» ត្រូវធ្វើសវនកម្មដោយអាជ្ញាធរសវនកម្មជាតិ (មាត្រា ៥ នៃច្បាប់ លេខ ១០ ចុះថ្ងៃទី ៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីការធ្វើសវនកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា) (អនុក្រឹត្យលេខ ៩៧-៤១ និង ៤២ ប្រកាសលេខ លេខ ៥ ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧) ។

## ៥. ឯកជនភាវូបនីយកម្ម

ឯកជនភាវូបនីយកម្ម ត្រូវបានគ្រប់គ្រងដោយ **ច្បាប់ស្តីពីច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥** (មាត្រាលេខ ៨១) **អនុក្រឹត្យ** លេខ ៣៨ អនក្រ ចុះថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ១៩៩៥ **ស្តីពីបែបបទនៃឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ** និង **ប្រកាស** លេខ ២៨០ ប្រក.កសហវ.ទរ ចុះថ្ងៃទី ៣ ខែ សីហា ឆ្នាំ ១៩៩៥ **ណែនាំអនុវត្តការងារឯកជនភាវូបនីយកម្ម សហគ្រាសសាធារណៈ** ។

ឯកជនភាវូបនីយកម្មរួមមានការផ្ទេរទ្រព្យសម្បត្តិសាធារណៈ ទៅអោយវិស័យឯកជន (មាត្រា ៨១ នៃច្បាប់ហិរញ្ញវត្ថុ ឆ្នាំ ១៩៩៥) ។

### ៥.១. ដែនអនុវត្ត

ទ្រព្យសម្បត្តិសកម្មសាធារណៈទាំងឡាយដែលជាកម្មសិទ្ធិ ឬ ការប្រើប្រាស់ អាចធ្វើជាកម្មវត្ថុនៃការផ្ទេរទៅអោយផ្នែកឯកជនទាំងអស់ រួមមាន ÷

**ក- សហគ្រាសសាធារណៈ**: - ទោះជាមានសកម្មភាពក្នុងវិស័យណាក៏ដោយ (ឧស្សាហកម្ម ពាណិជ្ជកម្ម សេវាកម្ម) ឬ អាជ្ញាធរអាណាព្យាបាល ដែលស្ថិតនៅក្រោមបង្គាប់ (ក្រសួង ខេត្ត- ក្រុង) ។


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

| | ឈ្មោះសហគ្រាស | ទ្រព្យសកម្ម | មូលធនផ្ទាល់ | បុគ្គលិក | ឆ្នាំសារពើពន្ធ ២០០៦ | | |
|---|---|---|---|---|---|---|---|
| | | | | | ចំណូលសរុប | ចំណាយសរុប | ចំណេញ |
| 1 | ចំការកៅស៊ូ ជប់ | 169,969 | 163,058 | 4,414 | 84,622 | 63,639 | 20,983 |
| 2 | ចំការកៅស៊ូ ក្រែក | 69,674 | 65,330 | 1,170 | 27,232 | 16,575 | 10,657 |
| 3 | ចំការកៅស៊ូ មេមត់ | 81,553 | 74,518 | 1,549 | 25,595 | 24,436 | 1,159 |
| 4 | ចំការកៅស៊ូ ពាមជាំង | 45,072 | 42,698 | 1,168 | 25,154 | 19,111 | 6,043 |
| 5 | ចំការកៅស៊ូ ចំការអណ្ដូង | 74,231 | 73,307 | 1,779 | 14,323 | 13,252 | 1,071 |
| 6 | ចំការកៅស៊ូ ស្នួល | 27,621 | 21,939 | 785 | 11,622 | 8,970 | 2,652 |
| 7 | ចំការកៅស៊ូ បឹងកេត | 41,521 | 39,348 | 1,144 | 4,847 | 5,706 | -859 |
| | **សរុប ចំការកៅស៊ូ** | **509,641** | **480,198** | **12,009** | **193,395** | **151,689** | **41,706** |
| 8 | ក្រុមហ៊ុនធាតុចូលកសិកម្ម | 21,948 | 21,278 | 49 | 2,827 | 2,773 | 54 |
| 9 | កំពង់ផែក្រុងព្រះស៊ីហនុ | 473,187 | 467,094 | 1,032 | 97,015 | 87,181 | 9,834 |
| 10 | កំពង់ផែក្រុងភ្នំពេញ | 108,473 | 105,017 | 465 | 18,469 | 12,772 | 5,697 |
| 11 | កាំសាប | 24,387 | 22,574 | 148 | 9,090 | 4,630 | 4,460 |
| 12 | ក្រុមហ៊ុន ហ្គ្រីនត្រេត | 45,272 | 41,850 | 194 | 7,152 | 7,184 | -32 |
| 13 | ក្រុមហ៊ុនធានារ៉ាប់រងជាតិនៃកម្ពុជា | 31,933 | 29,470 | 60 | 4,547 | 4,045 | 502 |
| 14 | ក្រុមហ៊ុនបោះពុម្ពផ្សាយ | 29,367 | 29,154 | 145 | 11,046 | 10,130 | 916 |
| 15 | ទូរគមនាគមន៍កម្ពុជា | 228,633 | 185,937 | 617 | 81,982 | 55,947 | 26,035 |
| 16 | ក្រុមហ៊ុនអយស្ម័យាន | 3,951,329 | 3,948,159 | 1,609 | 7,830 | 9,294 | -1,464 |
| 17 | មន្ទីរពិសោធន៍សំណង់និងការងារសាធារណៈ | 1,717 | 1,283 | 24 | 422 | 502 | -80 |
| 18 | រដ្ឋាករទឹកក្រុងភ្នំពេញ | 555,218 | 434,609 | 568 | 78,512 | 58,650 | 19,862 |
| 19 | អគ្គិសនីកម្ពុជា | 589,404 | 348,297 | 2,180 | 613,600 | 601,259 | 12,341 |
| 20 | ធនាគារអភិវឌ្ឍន៍ជនបទ | 65,057 | 30,416 | 49 | 4,043 | 2,708 | 1,335 |
| | **សរុបរួម** | **6,635,566** | **6,145,336** | **19,149** | **1,129,930** | **1,008,764** | **121,166** |

**ខ- ភាគកម្មសាធារណៈ:-** ចំណែកដើមទុនដែលរដ្ឋ សម្ព័ហភាពសាធារណៈក្នុងស្រុក និង សហគ្រាសសាធារណៈត្រូវរក្សាទុកក្នុងដើមទុនរបស់ក្រុមហ៊ុនចម្រុះ ។

**គ- សកម្មភាពឧស្សាហកម្ម ឬ ពាណិជ្ជកម្ម ដែលអនុវត្តដោយរដ្ឋបាលសាធារណៈ:-** សកម្មភាពអាជីវកម្មដែលអនុវត្តដោយអង្គភាពសាធារណៈ ដូចជាការដឹកជញ្ជូន សកម្មភាពពាណិជ្ជកម្ម ឧស្សាហកម្ម អាជីវកម្មក្នុងវិស័យទូរគមនាគមន៍ ការគ្រប់គ្រងអាកាសយានដ្ឋាន ការនេសាទ អាជីវកម្មព្រៃឈើ និង ទេសចរណ៍ ។ល។

**ឃ- ទ្រព្យសកម្មសាធារណៈរូបីយ៍ផ្សេងៗ** (អាគារ ដី ថេបនកម្ម សម្ភារៈ) ដែលជាកម្មសិទ្ធិរដ្ឋ សម្ព័ហភាពសាធារណៈក្នុងស្រុក ឬ របស់សហគ្រាសសាធារណៈ ។ ទ្រព្យសកម្មទាំងនេះអាចត្រូវបានកាត់ផ្ដាច់ចេញពីសហគ្រាសសាធារណៈ (ដោយត្រូវធ្វើអនុបយោគនូវទ្រព្យសម្បត្តិនេះ ពីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋមកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ) ។

### ទ្រព្យសម្បត្តិសាធារណៈ និង ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ

ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋរួមមាន ទ្រព្យសម្បត្តិសាធារណៈធម្មជាតិ និងទ្រព្យសម្បត្តិកែច្នៃ («ជាពិសេសដី ក្រោមដី ធនធានក្រោមសមុទ្រ ឆ្នេរ លំហរអាកាស កោះ ទន្លេ ព្រែកជីក ស្ទឹង បឹង ព្រៃ ធនធានធម្មជាតិ មជ្ឈមណ្ឌលសេដ្ឋកិច្ច និង វប្បធម៌ មូលដ្ឋានការពារជាតិ និងសំណង់នានាដែលជាកម្មសិទ្ធិរដ្ឋ ។ ការគ្រប់គ្រង ការប្រើប្រាស់ និងការប្រគល់នូវទ្រព្យរបស់រដ្ឋ ត្រូវកំណត់ដោយច្បាប់» មាត្រា ៥៨ នៃរដ្ឋធម្មនុញ្ញ ។)

ទ្រព្យសម្បត្តិទាំងនេះគ្មានអាជ្ញាយុកាល មិនអាចរឹបអូស និងមិនអាចលក់ ។

ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ជាផ្នែកមួយនៃបេតិកភ័ណ្ឌ ដែលត្រូវគ្រប់គ្រងដោយនីតិឯកជន ។

រាល់នីតិបុគ្គលនៃនីតិសាធារណៈអាចជាអគ្គគាហកៈនៃទ្រព្យសម្បត្តិសាធារណៈ និង មានសិទ្ធិលើទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ។

មានតែទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ និងរបស់នីតិបុគ្គលនៃនីតិសាធារណៈប៉ុណ្ណោះ ដែលអាចលក់ដូរទៅអោយវិស័យឯកជនបាន ។

ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ត្រូវតែធ្វើ **អនុបយោគ** ជាមុនសិន មុននឹងអាចលក់ដូរបាន ។ ការកែប្រែនេះត្រូវអនុវត្តតាមនីតិវិធី ដែលចាត់ថ្នាក់ទ្រព្យសម្បត្តិសាធារណៈ ÷ ច្បាប់ ឬ វិធានច្បាប់ ។ ឧទាហរណ៍ រដ្ឋធម្មនុញ្ញបានចែងថា (មាត្រា ៤៤) **អស្សាមិករណ៍** ត្រូវទុកជាសម្បត្តិរដ្ឋ ។ ដី ឬ អាគារ ដែលចូលជាសម្បត្តិរដ្ឋ តាមរយៈការធ្វើអស្សាមិករណ៍ អាចលក់ដូរបាន បន្ទាប់ពីមានការផ្លាស់ប្ដូរចំណាត់ថ្នាក់ តាមនីតិវិធីច្បាប់ ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

**ខ- ទ្រព្យសកម្មអរូបីយ៍-** ដូចជា សម្បទានអាជីវកម្មលើធនធានធម្មជាតិ ។

**ច- សកម្មភាពដែលមិនមានលក្ខណ:ជាសេវាសាធារណ:** ។

**ជ- ទ្រព្យសកម្មហិរញ្ញវត្ថុ** (ភាគហ៊ុន ចំណែកភាគកម្ម សិទ្ធិលើមូលធនក្រុមហ៊ុនចម្រុះ) ។

## ៥.២. គណ:កម្មាធិការឯកជនភាវូបនីយកម្ម

**គណ:កម្មាធិការឯកជនភាវូបនីយកម្ម** (បង្កើតឡើងដោយអនុលោមតាមច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៥) ជាស្ថាប័នដែលទទួលបន្ទុកអនុវត្តកម្មវិធីឯកជនភាវូបនីយកម្មរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលមានសមាសភាពដូចតទៅ៖

| | |
|---|---|
| • រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬ តំណាង | ប្រធាន |
| • រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណ:រដ្ឋមន្ត្រី ឬ តំណាង | សមាជិក |
| • រដ្ឋមន្ត្រីក្រសួងផែនការ ឬ តំណាង | សមាជិក |
| • រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ឬ តំណាង | សមាជិក |
| • រដ្ឋមន្ត្រីក្រសួងសាធារណ:ការ និង ដឹកជញ្ជូន ឬ តំណាង | សមាជិក |
| • រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ឬ តំណាង | សមាជិក |
| • រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ឬ តំណាង | សមាជិក |
| • រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច និងអតីតយុទ្ធជន ឬ តំណាង | សមាជិក |
| • រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ឬ តំណាង | សមាជិក |
| • ទេសាភិបាលធនាគារជាតិនៃកម្ពុជា ឬ តំណាង | សមាជិក |
| • រដ្ឋមន្ត្រីអាណាព្យាបាល ឬ តំណាង | សមាជិក |
| • ប្រធានសហគ្រាសពាក់ព័ន្ធ និង រាល់ភាគីពាក់ព័ន្ធ តាមការចាំបាច់ ។ | |

**គណ:កម្មាធិការឯកជនភាវូបនីយកម្ម** ត្រូវរៀបចំកម្មវិធីឯកជនភាវូបនីយកម្ម ដោយផ្អែកលើសំណើ



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីអាណាព្យាបាលផ្សេងៗ ។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបញ្ជូនកម្មវិធីឯកជនភាវូបនីយកម្មនេះទៅនាយករដ្ឋមន្ត្រី ដើម្បីអនុម័ត ។

គណៈកម្មាធិការឯកជនភាវូបនីយកម្មពិនិត្យលើប្រតិបត្តិការរៀបចំឯកជនភាវូបនីយកម្ម ជាពិសេសការវាយតម្លៃទ្រព្យសកម្ម ការបញ្ជាក់ពីលក្ខន្តិកៈរបស់សហគ្រាស ការជម្រះបញ្ជីអតិថិជន និងអ្នកផ្គត់ផ្គង់ និងជាយថាហេតុ ការកាត់បន្ថយចំនួនបុគ្គលិក ។ ភារកិច្ចទាំងនេះ ជារបស់រដ្ឋមន្ត្រីអាណាព្យាបាល ។

## ៥.៣. សំណុំឯកសារឯកជនភាវូបនីយកម្ម

សំណុំឯកសារឯកជនភាវូបនីយកម្ម ត្រូវបានរៀបចំក្រោមការទទួលខុសត្រូវពីអាណាព្យាបាលសហគ្រាស បន្ទាប់មកដាក់ជូនគណៈកម្មាធិការ ។ សំណុំឯកសារនេះរួមមាន ÷

- កំណត់បង្ហាញសហគ្រាស ដែលរំលេចអោយឃើញនូវបេតិកភ័ណ្ឌ លក្ខខណ្ឌទូទៅនៃសកម្មភាព ស្ថានភាពហិរញ្ញវត្ថុក្នុងរយៈពេល ៣ ឆ្នាំចុងក្រោយ និង ទស្សនៈវិស័យនៃការអភិវឌ្ឍរបស់សហគ្រាស
- គំនូសបំព្រួញនៃឯកជនភាវូបនីយកម្ម
- គំរោងសៀវភៅបន្ទុក ប្រសិនបើចាំបាច់

## ៥.៤. គំនូសបំព្រួញនៃឯកជនភាវូបនីយកម្ម

គំនូសបំព្រួញ គឺជារូបមន្តនៃឯកជនភាវូបនីយកម្ម ដែលរៀបចំឡើងក្នុងគោលដៅសម្រេចបាននូវគោលបំណងនៃឯកជនភាវូបនីយកម្ម ។ ឯកជនភាវូបនីយកម្មអាចអនុវត្ត តាមរូបភាពជាច្រើនប្រភេទ ÷

- **ឯកជនភាវូបនីយកម្មទាំងស្រុង**- ការផ្ទេរទ្រព្យសកម្មទាំងស្រុងទៅឱ្យអ្នកទិញ
- **ឯកជនភាវូបនីយកម្មដោយផ្នែក**- ការបើកចំហមូលធននៃសហគ្រាសសាធារណៈសំរាប់វិនិយោគិនឯកជន
- **ការជួលទ្រព្យសកម្មមួយចំនួន**- អាទិ៍អាគារ និង ដីធ្លី
- **សម្បទាន**- ការផ្តល់ជូនប្រតិបត្តិករឯកជន នូវសិទ្ធិធ្វើអាជីវកម្មលើសកម្មភាពណាមួយដែលស្ថិតក្រោមអំណាចនៃផ្នែកសាធារណៈ ឧទាហរណ៍ សេវាសាធារណៈ ធនធានធម្មជាតិ
- **ការលក់ទ្រព្យសកម្មដោយឡែកៗពីគ្នា**- ការលក់ទ្រព្យសកម្មខ្លះនៃសហគ្រាសសាធារណៈ ដើម្បីអោយក្លាយជាទ្រព្យសកម្មដាច់ដោយឡែក ដោយសារតែរដ្ឋមិនចង់ធ្វើឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ៥.៥. សៀវភៅបន្ទុក និង ការដាក់អោយប្រកួតប្រជែង

**សៀវភៅបន្ទុក** កំណត់នូវលក្ខខណ្ឌនៃការធ្វើឯកជនភាវូបនីយកម្ម ដែលត្រូវដាក់ជូនគណៈកម្មាធិការឯកជនភាវូបនីយកម្មអនុម័តជាមុនសិន មុននឹងប្រកាសផ្សព្វផ្សាយដេញថ្លៃ ឬ សន្យាអំពីនីតិវិធីពិគ្រោះជ្រើសរើសជាមួយអ្នកទិញ ។ សៀវភៅបន្ទុកនេះបញ្ជាក់ពីៈ

- គំនូសបំព្រួញនៃឯកជនភាវូបនីយកម្ម
- បញ្ជីលម្អិតនៃទ្រព្យសកម្ម (រូបីយ៍ និងអរូបីយ៍) ដែលជាទ្រព្យសម្បត្តិរបស់សហគ្រាស
- លក្ខខណ្ឌនៃការទូទាត់
- ឯកសារយោង ផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ
- ទំហំទឹកប្រាក់ និងនីតិវិធីក្នុងកាគ្រប់គ្រងប្រាក់កក់
- ចំនួនបុគ្គលិកដែលត្រូវរក្សាទុក (ជាយថាហេតុ)
- លក្ខខណ្ឌធានាសកម្មភាព និងការវិនិយោគដែលត្រូវអនុវត្ត

ម៉្យាងទៀត ក្នុងករណីដែលសហគ្រាសមានសកម្មភាពផ្តាច់មុខ ឬ ផ្តល់នូវសេវាសាធារណៈ សៀវភៅបន្ទុកត្រូវចែងអោយច្បាស់ពីលក្ខខណ្ឌនៃសកម្មភាពអាជីវកម្ម និងការកំណត់ថ្លៃ ក្នុងគោលដៅការពារនូវផលប្រយោជន៍រួម ។

នៅពេលដែលត្រូវធ្វើការវាយតម្លៃ ដោយប្រើប្រាស់នូវអ្នកជំនាញការឯករាជ្យដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ១ រូប ឬ ច្រើនរូប ជាទូទៅ គេប្រើនូវវិធីសាស្ត្រផ្សេងៗ ដូចជាវិធីសាស្ត្រ លៃលឈរលើមូលដ្ឋាននៃតម្លៃភាគហ៊ុន តម្លៃទ្រព្យសម្បត្តិ ការធ្វើបច្ចុប្បន្នកម្មនៃប្រាក់ចំណេញ ក្នុងរយៈពេល ១០ ឆ្នាំខាងមុខ ដោយយកតម្លៃអប្បបរមា និងអតិបរមា (តម្លៃមធ្យម) ។

ការដាក់អោយប្រកួតប្រជែង ត្រូវគោរពតាមបទបញ្ជា លើកលែងករណីលក់អោយបុគ្គលិកក្រុមហ៊ុន ។ បទបញ្ជាពាក់ព័ន្ធនឹងលទ្ធកម្មសាធារណៈ ត្រូវអនុវត្តចំពោះការប្រកួតប្រជែងនេះ ។

## ៥.៦. ការជ្រើសរើសអ្នកទិញ

ការប្រកាសជ្រើសរើសអ្នកទិញ ត្រូវធ្វើដោយបើកចំហ និងត្រូវវិភាគដោយគណៈកម្មការមួយ


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ដែលសមាជិកត្រូវបានតែងតាំងដោយ ប្រកាសក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងត្រូវគ្រប់គ្រងដោយរដ្ឋលេខាធិការម្នាក់ និង មានសមាសភាពជាតំណាងទីស្ដីការគណៈរដ្ឋមន្ត្រី តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តំណាងក្រសួងអាណាព្យាបាល និង តំណាងប្រធានក្រុមហ៊ុនពាក់ព័ន្ធ ។

អ្នកទិញត្រូវជ្រើសរើសដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្នុងករណីដែលទំហំទឹកប្រាក់លើសកម្រិតកំណត់ ឬ លើសពីលក្ខណៈវិនិច្ឆ័យមួយចំនួន ត្រូវទទួលការឯកភាពពីនាយករដ្ឋមន្ត្រី ។

បុគ្គលិករបស់សហគ្រាសមានសិទ្ធិជាអាទិភាព ដើម្បីទិញក្រុមហ៊ុនរបស់ខ្លួន ឬ ទ្រព្យសកម្មមួយចំនួនរបស់ក្រុមហ៊ុន ។ ការលើកទឹកចិត្តទាំងនេះត្រូវកំណត់ដោយទីស្ដីការគណៈរដ្ឋមន្ត្រី តាមសំណើរបស់គណៈកម្មាធិការឯកជនភាវូបនីយកម្ម ។

វិនិយោគិនខាងក្រៅអាចចូលរួម ជាម្ចាស់ភាគហ៊ុនភាគតិច ជាមួយរូបវ័ន្តបុគ្គល ឬ នីតិបុគ្គលកម្ពុជាដើម្បីចូលរួមក្នុងការទិញនេះ ។ ប្រតិបត្តិការឯកជនភាវូបនីយកម្ម អាចអនុវត្តដោយផ្ដល់ការលើកទឹកចិត្ត ដូចជាការផ្ដល់ការលើកទឹកចិត្តដូចនីតិវិធីនៃការវិនិយោគទុនដែរ ។

## ៥.៧. ចំណូលពីឯកជនភាវូបនីយកម្ម

ប្រតិបត្តិការឯកជនភាវូបនីយកម្ម ត្រូវធ្វើការទូទាត់ដោយឆ្លងតាមគណនីពិសេសរបស់រតនាគារ ដែលបង្កើតឡើងដោយច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៥ ដែលគ្រប់ដណ្ដប់លើ÷

- ចំណាយរៀបចំ សហគ្រាសដែលជាមុខសញ្ញានៃឯកជនភាវូបនីយកម្ម
- ហិរញ្ញប្បទានកម្មវិធីនៃកម្មវិធីរំសាយបុគ្គលិកដែលលើស នៅក្នុងសហគ្រាសសាធារណៈ
- ការយល់ព្រមលើទាយជ្ជទានជាមូលធន ជាប្រយោជន៍ដល់សហគ្រាសសាធារណៈ ដែលត្រូវរក្សាទុកក្នុងវិស័យសាធារណៈ ។

## ៥.៨. ការធ្វើឯកជនភាវូបនីយកម្មក្រុមហ៊ុនចំការកៅស៊ូរដ្ឋ

**គណៈកម្មការជាតិអវិនិយោគ** ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ទីស្ដីការគណៈរដ្ឋមន្ត្រីត្រូវបានរៀបចំធ្វើឯកជនភាវូបនីយកម្មនៃចំការកៅស៊ូចំនួន ៧ ដោយធ្វើសារពើភ័ណ្ឌ និង វាយតម្លៃដើមកៅស៊ូកំពុងចៀរជ័រ កូនកៅស៊ូមិនទាន់អោយផល គ្រឿងម៉ាស៊ីនសម្ភារៈបរិក្ខាររោងចក្រ ខ្សែសង្វាក់ផលិតកម្ម ផលិតផលសម្រេច មធ្យោបាយដឹកជញ្ជូន អាគាររដ្ឋបាល ផ្ទះកម្មករ និងសំណង់ផ្សេងៗ ។ ការធ្វើឯកជនភាវូបនីយកម្មបានរៀបចំ


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

| លរ | ចំការកៅស៊ូ | ទឹកប្រាក់ដេញថ្លៃបាន |
|---|---|---|
| ១ | ចំការកៅស៊ូមេមត់ | ១១.៥០០.០០០ ដុល្លារ |
| ២ | ចំការកៅស៊ូបឹងកេត | ៩. ៣៦៧.២៥៥ ដុល្លារ |
| ៣ | ចំការកៅស៊ូចំការអណ្តូង | ១១.៦០០.០០០ ដុល្លារ |
| ៤ | ចំការកៅស៊ូស្នួល | ៧.៥១០.០០០ ដុល្លារ |
| ៥ | ចំការកៅស៊ូពាមជាំង | ៨.០០០.០០០ ដុល្លារ |
| ៦ | ចំការកៅស៊ូក្រែក | ១៥.៥២១.៦៩៥ ដុល្លារ |
| ៧ | ចំការកៅស៊ូជុប | ៣៩.៨៨៨.១៦៨ ដុល្លារ |
| | | ១០៣. ៣៨៧.១១៨ ដុល្លារ |

ឡើងដោយឈរលើលក្ខខណ្ឌដូចតទៅ ÷

- ដី ស្ថិតនៅក្រោមកិច្ចសន្យាជួល
- ដើមកៅស៊ូចាស់ៗអស់ប្រសិទ្ធភាពសេដ្ឋកិច្ចបានស្ថិតនៅក្រោមកិច្ចសន្យាកាប់រួចមកហើយ ជាមួយក្រុមហ៊ុនកែឆ្នៃដើមកៅស៊ូ ចំណូលពីការកាប់ដើមកៅស៊ូចាស់ត្រូវបង់ចូលថវិការដ្ឋ ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ផ្នែកទី ២

## គណនេយ្យសាធារណៈ

### (អនុក្រឹត្យ ៨២-៩៥ ប្រកាស ៩៦-៤)

នីតិសាធារណៈមានតួនាទីគ្រប់គ្រងការរៀបចំរដ្ឋ និងស្ថាប័ន និង ទំនាក់ទំនងជាមួយប្រជាពលរដ្ឋ ។ នីតិសាធារណៈរួមមាន ច្បាប់រដ្ឋធម្មនុញ្ញ ច្បាប់រដ្ឋបាល និង ហិរញ្ញវត្ថុសាធារណៈ ដែលគេអាចហៅផងដែរថាជាច្បាប់ថវិកា ឬ ច្បាប់ហិរញ្ញវត្ថុ ។

**ច្បាប់រដ្ឋធម្មនុញ្ញ** កំណត់បទប្បញ្ញត្តិនៃការរៀបចំនៃអំណាចសាធារណៈ ឬ អំណាចរដ្ឋ ។

**ច្បាប់រដ្ឋបាល** កំណត់បទប្បញ្ញត្តិស្ដីពីទំនាក់ទំនងរវាងរដ្ឋបាល និងប្រជាពលរដ្ឋដែលស្ថិតក្រោមអំណាចនៃច្បាប់នេះ ។

**ហិរញ្ញវត្ថុសាធារណៈ** កំណត់បទប្បញ្ញត្តិគ្រឹះដែលក្រសួង ស្ថាប័នត្រូវអនុវត្ត និង នីតិវិធីសម្រាប់ស្ថាប័នសាធារណៈអនុវត្តនូវភារកិច្ចរបស់ខ្លួនពាក់ព័ន្ធនឹងធនធានហិរញ្ញវត្ថុ ។ ហិរញ្ញវត្ថុសាធារណៈរួមមាន ច្បាប់ថវិកា (ដែលចែងពីវិធានស្ដីពីថវិកា) ច្បាប់សារពើពន្ធ (ដែលគ្រប់គ្រងចំណូលសារពើពន្ធ) និងគណនេយ្យសាធារណៈ ។

**វិធានគណនេយ្យសាធារណៈ** សម្រាប់ប្រទេសកម្ពុជាដំបូងគេបង្អស់ ត្រូវបានអនុម័ត ក្នុងក្របខ័ណ្ឌនៃអនុក្រឹត្យ លេខ ៨២ ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្ដីពី **បទបញ្ញាត្តទូទៅនៃគណនេយ្យសាធារណៈ** ។

អនុក្រឹត្យនេះកំណត់វិធានទាំងឡាយ «សម្រាប់អនុវត្តកិច្ចប្រតិបត្តិការហិរញ្ញវត្ថុ និងគណនេយ្យ ដែលជាលទ្ធផលនៃកិច្ចប្រតិបត្តិការថវិការដ្ឋ» (មាត្រាទី ១) ។

អនុក្រឹត្យខាងលើកំណត់កាតព្វកិច្ច និងការទទួលខុសត្រូវរបស់អាណាប័ក និងគណនេយ្យករសាធារណៈពាក់ព័ន្ធនឹងចំណូល និង ចំណាយថវិកា ។

តាមគោលការណ៍ដែលគេទទួលស្គាល់ជាទូទៅនៅក្នុងប្រព័ន្ធដែលមានប្រភពពីប្រព័ន្ធបារាំង «តួនាទីរបស់អាណាប័ក និង គណនេយ្យករ មានវិសមិតភាពនឹងគ្នា» (មាត្រាទី ១៧ នៃអនុក្រឹត្យ ៨២) ។ ប្ដី ឬ ប្រពន្ធរបស់អាណាប័កមិនអាចជាធ្វើជាគណនេយ្យករ អោយអង្គភាពសាធារណៈ ដែលសាមីខ្លួនជាអាណាប័កបំពេញមុខងារនៅទីនោះឡើយ (មាត្រាទី ១៧) ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ការបែងចែកខាងលើ គឺ មានលក្ខណៈជាប្រព័ន្ធផង និងជាប្រតិបត្តិការផង ។ ប៉ុន្តែ ក៏មានករណីលើកលែង ដែលអនុវត្តផងដែរ ដូចជា ការលើកលែងដែលជាលក្ខណៈធម្មតា (បុរេប្រទាន) ឬ ការលើកលែងជាពិសេស (ការគ្រប់គ្រងតាមសភាពការណ៍ជាក់ស្តែង) ។

យើងនឹងពិនិត្យជាបន្តទៀតនូវប្រតិបត្តិការរតនាគារ និងការកត់ត្រាគណនេយ្យនៃប្រតិបត្តិការទាំងនេះ និងជាចុងក្រោយការត្រួតពិនិត្យលើអាណាប័ក និងគណនេយ្យករ ។



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

# ជំពូកទី ១

# អាណាប័ក និង គណនេយ្យករ

## ១. វិសមិតភាពរវាងអាណាប័ក និង គណនេយ្យករ

### ១.១. វិសមិតភាពមុខងារ

អាណាប័ក និងគណនេយ្យករ ជាមុខងារពីរ ដែលចូលរួមក្នុងការអនុវត្តថវិកា ។ គោលការណ៍នៃវិសមិតភាពនេះត្រូវបានលើកលែងក្នុងករណីខ្លះនៅពេលអនុវត្ត ដែលជាការលើកលែងជាបទប្បញ្ញត្តិ ដូចជាក្នុងការអនុវត្ត **រេជ្ជនេយ្យ** និង ការលើកលែងជាក់ស្តែង ដូចជាក្នុងករណី ការគ្រប់គ្រងតាមព្រឹត្តិការណ៍ ។ ទំនាក់ទំនងរវាងអាណាប័ក និង គណនេយ្យករត្រូវបានកំណត់ដោយ **អនុក្រឹត្យ លេខ ៨១** អនក្រ.បក ចុះថ្ងៃទី ១៦ វិច្ឆិកា ឆ្នាំ ១៩៩៩ **ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុ លើការចំណាយថវិការដ្ឋ នៅតាមក្រសួង ខេត្ត-ក្រុង ក្រុងស្វយ័ត -រាជធានីភ្នំពេញ និង អង្គភាពសាធារណៈរដ្ឋបាល** និង **អនុក្រឹត្យ លេខ ៨២** អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ **ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ** ។

#### ១.១.១. អាណាប័ក

**អាណាប័ក** អាចជាអាណាប័កដើមខ្សែ ឬ អាណាប័កតាមការប្រទានសិទ្ធ ហើយអាចប្រគល់សិទ្ធអំណាចរបស់ខ្លួន ឬ រកអ្នកជំនួសក្នុងករណីអាណាប័កអវត្តមាន ឬ មានធុរៈ (មាត្រាទី ៤ អនុក្រឹត្យលេខ ៨២) ។

**ការប្រគល់សិទ្ធិអំណាច និងសិទ្ធិចុះហត្ថលេខា**

អាណាប័កដែលប្រគល់សិទ្ធិអំណាច មិនអាចប្រើប្រាស់អំណាចនេះបានទេ ។ ក៏ប៉ុន្តែ អាណាប័កដែលប្រគល់សិទ្ធិចុះហត្ថលេខា អាចបន្តអនុវត្តភារកិច្ចរបស់ខ្លួន នៅក្នុងពេលជាមួយគ្នានឹងអ្នកទទួលសិទ្ធិដែរ ។

ការប្រគល់សិទ្ធិអំណាចនឹងបន្តទៀត ទោះបីជាបុគ្គលដែលបានប្រគល់សិទ្ធិ ឬ អ្នកទទួលសិទ្ធិនោះត្រូវបានផ្លាស់ប្តូរក៏ដោយ (ដោយសារតែការប្រគល់សិទ្ធិនេះ មិនមែនជាការប្រគល់សិទ្ធិជូនដល់បុគ្គលទេ គឺការប្រគល់សិទ្ធិដល់មន្ត្រីដែលកាន់តួនាទីនៅក្នុងក្រសួង ស្ថាប័នរដ្ឋ) ។

ផ្ទុយទៅវិញ ការប្រគល់សិទ្ធចុះហត្ថលេខានឹងត្រូវបញ្ចប់ ប្រសិនបើអ្នកប្រគល់សិទ្ធិ ឬ អ្នកទទួលសិទ្ធិត្រូវបានផ្លាស់ប្តូរ (ក៏ប៉ុន្តែ ក្នុងពេលថ្មីៗនេះ បទប្បញ្ញត្តិបារាំងត្រូវបានផ្លាស់ប្តូរៈ អនុក្រឹត្យ ២០០៥-៨៥០ ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៥ ស្តីពីការប្រគល់សិទ្ធចុះហត្ថលេខាជំនួសរដ្ឋមន្ត្រី និង សារាចរអនុវត្ត ក្នុងគោលដៅចៀសវាងការប្រគល់សិទ្ធិចុះហត្ថលេខាជាន់គ្នា នៅពេលដែលមានការដោះដូរគណៈរដ្ឋមន្ត្រី និង នៅពេលដែលការងាររាជការមានការជាប់គាំង ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

**អភិបាល អាណាប័កតាមការប្រទានសិទ្ធនៃថវិការដ្ឋ អាណាប័កដើមខ្សែនៃថវិកាខេត្ត- ក្រុង**

អភិបាលខេត្ត- ក្រុងពាក់មួកពីរ ÷

- ជាបឋម **អភិបាលខេត្ត- ក្រុង** ជាតំណាងអោយរដ្ឋបាលកណ្តាលនៅក្នុងមណ្ឌលគ្រប់គ្រងរបស់ខ្លួន និងជាអាណាប័កផ្ទេរសិទ្ធ (ក្រោមការទទួលខុសត្រូវនៃរដ្ឋមន្ត្រីក្រសួងពាក់ព័ន្ធ) សម្រាប់មន្ទីរខេត្ត (អភិបាលខេត្ត- ក្រុង គឺជាអាណាប័កតាមការប្រទានសិទ្ធ សម្រាប់គ្រប់គ្រងរដ្ឋបាលស៊ីវិល លើមណ្ឌលទឹកដីខេត្ត- ក្រុងរបស់ខ្លួន- មាត្រា ៦ នៃអនុក្រឹត្យ ៨២ ស្តីពីវិធានទូទៅនៃគណនេយ្យសាធារណៈ) ។ ក្នុងន័យនេះ អភិបាលខេត្ត- ក្រុង ជាអាណាប័កតាមការប្រទានសិទ្ធលើថវិកានៃមន្ទីរខេត្ត- ក្រុង (ប្រធានមន្ទីរខេត្ត- ក្រុង ក៏អាចជាអាណាប័កតាមការប្រទានសិទ្ធបានដែរ) ។

- ទន្ទឹមនឹងនេះ អភិបាលខេត្ត- ក្រុងអាចជាអាណាប័កដើមខ្សែនៃថវិកាស្វ័យយ័ត នៅលើមណ្ឌលទឹកដីខេត្ត- ក្រុងរបស់ខ្លួន (ច្បាប់ លេខ ២៩៨-០៣ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិខេត្ត - ក្រុង មាត្រា ៦)។ ខេត្ត ជានីតិបុគ្គលនៃនីតិសាធារណៈ យោងតាមមាត្រាទី ២ នៃច្បាប់នេះ ។

អាណាប័កតាមការប្រទានសិទ្ធ ឬ តាមការជំនួស អនុវត្តតាមការផ្ទេរសិទ្ធដោយមានការចុះហត្ថលេខា មិនមែនផ្អែកលើសមត្ថភាព (ឬអំណាច) ឡើយ ។ អាណាប័ក ដែលអនុវត្តតាមការផ្ទេរសិទ្ធ ដែលផ្អែកលើសមត្ថភាពមានឈ្មោះថា **អាណាប័កទីពីរ** (Ordonnateur secondaire) ។ ការអនុវត្តបែបនេះមិនអាចធ្វើបានឡើយ ក្នុងក្របខ័ណ្ឌនៃអនុក្រឹត្យ លេខ ៨២ ស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ ក៏ប៉ុន្តែ មាត្រា ៤៨ ថ្មីនៃច្បាប់ ៩៣-១ ចុះថ្ងៃទី ២៨ ខែ ធ្នូ ស្តីពីច្បាប់ហិរញ្ញវត្ថុ និងប្រព័ន្ធថវិកា ដែលបានកែសម្រួលដោយច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង ឆ្នាំ ២០០០ មាត្រា ៨ បានចែងថា ÷ «រដ្ឋមន្ត្រី ប្រធានស្ថាប័ន និងប្រធានអង្គភាពសាធារណៈប្រហាក់ប្រហែល អាណាប័កដើមខ្សែនៃថវិការបស់ខ្លួន អាចប្រគល់សិទ្ធិជូនអភិបាលរដ្ឋបាលថ្នាក់ក្រោមជាតិជាអាណាប័កផ្ទេរសិទ្ធិសម្រាប់កិច្ចប្រតិបត្តិការនៃថវិកា ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។ រដ្ឋមន្ត្រី ប្រធានស្ថាប័ន និងប្រធានអង្គភាពសាធារណៈប្រហាក់ប្រហែល ដែលជាអាណាប័កដើមខ្សែនៃថវិការបស់ខ្លួន អាចប្រគល់សិទ្ធិជូនប្រធានអង្គភាពក្រោមឱវាទ ប្រធានមន្ទីជំនាញ ខេត្ត និងរាជធានី ជាអាណាប័កផ្ទេរសិទ្ធិសម្រាប់កិច្ចប្រតិបត្តិការហិរញ្ញវត្ថុនៃថវិកា បន្ទាប់ពីមានការយល់ព្រមជាមុនពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ» ។

**អាណាប័កដើមខ្សែ** អាចជាមន្ត្រីគ្រប់គ្រងថវិការដ្ឋ (រដ្ឋមន្ត្រី ប្រធានរដ្ឋបាលសាធារណៈស្វ័យត ឬប្រធានស្ថាប័ន) ឬ មន្ត្រីគ្រប់គ្រងថវិកាវិមជ្ឈការៈ ថវិការបស់គ្រឹះស្ថានសាធារណៈ ថវិកាខេត្ត- ក្រុង (អភិបាល) ថវិកាឃុំ- សង្កាត់ (មេឃុំ ឬ ចៅសង្កាត់) ។

**អាណាប័កតាមការប្រទានសិទ្ធិ** អាចជាមន្ត្រីគ្រប់គ្រងថវិការដ្ឋ (ប្រធានរដ្ឋបាលកណ្តាល ឬ រដ្ឋបាលវិមជ្ឈការ អភិបាលខេត្ត- ក្រុង ដែលទទួលបន្ទុកខាងផ្នែកហិរញ្ញវត្ថុនៅក្នុងរដ្ឋបាលខេត្ត- ក្រុង) ។



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

**ចុះអភិបាលក្រុងវិញ ?**

ច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិខេត្ត- ក្រុង ត្រូវបានអនុវត្តចំពោះអភិបាលក្រុង នៅក្នុងមណ្ឌលគ្រប់គ្រងរបស់ខ្លួន ។

អភិបាលក្រុង គឺជាតំណាងរបស់រដ្ឋ នៅក្នុងមណ្ឌលគ្រប់គ្រងរបស់ខ្លួន ។ អភិបាលក្រុង ជាអាណាប័កដើមខ្សែនៃថវិកាខេត្ត- ក្រុង ដែលជានីតិបុគ្គលនៃនីតិសាធារណៈ ។

### ១.១.២. គណនេយ្យករសាធារណៈ

«គណនេយ្យករសាធារណៈទទួលភារកិច្ចដឹកនាំប៉ុស្តិ៍គណនេយ្យ ។ ប៉ុស្តិ៍គណនេយ្យត្រូវបានគ្រប់គ្រងដោយគណនេយ្យករតែមួយគត់ ។ គណនេយ្យករអាចប្រគល់សិទ្ធិទៅអោយអាជ្ញានុករិមួយរូប ឬ ច្រើនរូប ដែលមាន លក្ខណៈសម្បត្តិធ្វើការក្នុងការនាមខ្លួន និងក្រោមការទទួលខុសត្រូវរបស់ខ្លួន» (មាត្រា ១៤ អនុក្រឹត្យលេខ ៨២) ។

«គណនេយ្យករសាធារណៈ ត្រូវបានតែងតាំងដោយមានសេចក្តីយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាចាំបាច់ ។ លិខិតតែងតាំងត្រូវបានផ្សព្វផ្សាយ ។ មុននឹងចូលបំពេញការងារ គណនេយ្យករសាធារណៈត្រូវធ្វើសច្ចាប្រណិធាន ។ គណនេយ្យករទាំងនេះតែងតាំងឡើងសំរាប់អមអាណាប័ក ហើយក្នុងករណីខ្លះអមគណនេយ្យករសាធារណៈដ៏ទៃទៀតដែលខ្លួនមានការទាក់ទង ។ គណនេយ្យករសាធារណៈត្រូវផ្តល់របាយការណ៍យ៉ាងតិចមួយឆ្នាំម្តង» (មាត្រា ១៥ អនុក្រឹត្យលេខ ៨២) ។

«ប្រភេទគណនេយ្យករសាធារណៈរដ្ឋ មានដូចតទៅ ÷

- គណនេយ្យករផ្ទាល់របស់រតនាគារ
- គណនេយ្យករ រដ្ឋបាលហិរញ្ញវត្ថុ» (មាត្រា ១៨ អនុក្រឹត្យលេខ ៨២) ។

#### ១.១.២.១. គណនេយ្យករផ្ទាល់របស់រតនាគារ

«ក្រោមអំណាចនៃរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គណនេយ្យករផ្ទាល់របស់រតនាគារដើមខ្សែ ឬរង ត្រូវអនុវត្តរាល់ប្រតិបត្តិការចំណូល ឬ ចំណាយថវិកាទូទៅ និងគណនីពិសេសនៃរតនាគារ (និង ថវិកាឧបសម្ព័ន្ធ) ។ ក្នុងន័យនេះ រាល់ប្រតិបត្តិការរតនាគារ និង ជាទូទៅ រាល់កិច្ចប្រតិបត្តិការហិរញ្ញវត្ថុសាធារណៈលើកលែងតែប្រតិបត្តិការណា ដែលការអនុវត្តត្រូវបានប្រគល់អោយគណនេយ្យករសាធារណៈផ្សេងទៀត» (មាត្រា ១៩ អនុក្រឹត្យលេខ ៨២) ។



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

**គណនេយ្យករដើមខ្សែ និង គណនេយ្យករទេ**

«**គណនេយ្យករដើមខ្សែ** គឺជាគណនេយ្យករដែលអនុវត្តកិច្ចប្រតិបត្តិការ (ចំណូល និង ចំណាយ) របស់អាណាប័កដើមខ្សែ ។ គណនេយ្យកររតនាគារជាតិ ដែលជាគណនេយ្យករកណ្ដាលនៅភ្នំពេញ មានលក្ខណៈសម្បត្តិជាគណនេយ្យករដើមខ្សែ ។ គណនេយ្យករនេះអនុវត្តកិច្ចប្រត្តិបត្តិការរបស់អាណាប័កដើមខ្សែ និងប្រមូលផ្តុំនូវរាល់កិច្ចប្រតិបត្តិការដែលធ្វើឡើងដោយគណនេយ្យកររតនាគារខេត្ត-ក្រុង និងគណនេយ្យករនៃអង្គភាពរដ្ឋបាលហិរញ្ញវត្ថុ ។ គណនេយ្យករដើមខ្សែនេះអនុវត្ត ឬ ប្រមូលផ្តុំកិច្ចប្រត្តិបត្តិការរតនាគាររបស់រដ្ឋជាមួយវិទ្យាស្ថានបោះប្រាក់ និក្ខិត្តកររបស់រតនាគារ ដែលមានលក្ខណៈជាតិ និងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ ។ គណនេយ្យករនេះ បង្កើតឡើងនូវគណនីប្រចាំឆ្នាំរបស់រដ្ឋក្រោយពេលប្រមូលផ្តុំកិច្ចប្រតិបត្តិការថវិកាទូទៅ និងគណនីពិសេស» មាត្រា ២០ អនុក្រឹត្យលេខ ៨២ ។

«**គណនេយ្យករទេ** គឺជាគណនេយ្យកររបស់រតនាគារខេត្ត-ក្រុង ដែលអនុវត្តប្រតិបត្តិការរបស់អាណាប័កតាមការប្រទានសិទ្ធ (ព្រោះថាអាណាប័កមានតែ ២ ប្រភេទប៉ុណ្ណោះនៅប្រទេសកម្ពុជា) ។ គណនេយ្យករទាំងនេះ ជាគណនេយ្យករនៅតាមមណ្ឌលខេត្ត-ក្រុងរបស់ខ្លួន» (មាត្រា ២១ អនុក្រឹត្យលេខ ៨២) ។

### ១.១.២.២. គណនេយ្យកររដ្ឋបាលហិរញ្ញវត្ថុ

«**គណនេយ្យកររដ្ឋបាលហិរញ្ញវត្ថុ**មានភារៈកិច្ចប្រមូលពន្ធដារ ពន្ធគយ បំណុលពន្ធ ផលិតផលនៃទ្រព្យរដ្ឋ និងចំណូលផ្សេងៗ ព្រមទាំងការពិន័យសារពើពន្ធ និងសោហ៊ុយទារប្រាក់ពន្ធ និងសោហ៊ុយតុលាការដែលពាក់ព័ន្ធក្នុងលក្ខខណ្ឌកំណត់ច្បាប់ និងបទបញ្ញា ។ គណនេយ្យករនោះត្រូវបង់ចូលទៅរតនាគារជាតិនូវប្រាក់ចំណូល ដែលខ្លួនប្រមូលបាន» មាត្រា ២២ អនុក្រឹត្យលេខ ៨២ ។

## ១.២. ការបែងចែកមុខងារ

### ១.២.១. កម្រិតអាណាប័ក: ដំណាក់កាលរដ្ឋបាល

«**អាណាប័ក** បញ្ជានូវការអនុវត្តចំណូល និងចំណាយថវិកា» (មាត្រា ៣ អនុក្រឹត្យលេខ ៨២) ។ ខាងផ្នែកចំណូល អាណាប័ក (នៅក្នុងដំណាក់កាលរដ្ឋបាល) **កំណត់ចំណូល** ហើយបន្ទាប់មកដាក់ចេញនូវវិធានការដើម្បីប្រមូលចំណូល ។ ខាងផ្នែកចំណាយ អាណាប័ក **ធានាចំណាយ ជម្រះបញ្ជីចំណាយ** និង ចេញ**អាណត្តិបើកប្រាក់** ។

#### ១.២.១.១. ចំណូល

«ចំណូលរបស់រដ្ឋរួមមានពន្ធអាករ សិទ្ធិ និងចំណូលប្រហាក់ប្រហែលផ្សេងៗទៀត ផលិតផលនៃទ្រព្យសម្បត្តិរដ្ឋ ការផាកពិន័យ ទោសទណ្ឌជាប្រាក់កាសផ្សេងៗ និងផលិតផលផ្សេងៗទៀតដែលអនុញ្ញាត



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

***មាតិកាចំណូល***

**មាតិកាចំណូល**ត្រូវបានកំណត់ដោយប្រកាសក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ) ។ ប៉ុន្តែ មាតិកានេះត្រូវអនុលោមតាមនិយាមអន្តរជាតិ ដែលប្រើប្រាស់ជាផ្លូវការក្នុងសៀវភៅស្ថិតិស្តីពីហិរញ្ញវត្ថុសាធារណៈ (GFS 2001) របស់ **មូលនិធិរូបិយវត្ថុអន្តរជាតិ** ដែលរួមមាន៖

**ពន្ធ និង អាករ**

- ពន្ធលើចំណូល លើប្រាក់ចំណេញ និងលើប្រាក់ចំណេញជាមូលធន
- ពន្ធលើប្រាក់បៀវត្សរ៍ និងលើកម្មករ
- ពន្ធលើបេតិកភ័ណ្ឌ
  - . ពន្ធលើអចលនទ្រព្យ
  - . ពន្ធលើបេតិកភ័ណ្ឌសុទ្ធ
  - . ពន្ធលើការផ្ទេរ ដោយសារមរណៈភាព ការផ្ទេរមរតក អំណោយរវាងអ្នកនៅរស់ ពន្ធលើប្រតិបត្តិការហិរញ្ញវត្ថុ និងមូលធន
  - . ពន្ធផ្សេងៗទៀតដែលមិនគិតតាមពេលវេលាលើបេតិកភ័ណ្ឌ
  - . ពន្ធផ្សេងទៀតលើបេតិកភ័ណ្ឌ
- ពន្ធលើទំនិញ និងសេវា
  - . អាករលើតម្លៃបន្ថែម
  - . ពន្ធលើការលក់
  - . ពន្ធលើផលរបរ និងពន្ធផ្សេងៗទៀតលើទំនិញ និងសេវា
  - . ប្រាក់ចំណេញ
  - . ពន្ធលើសេវាដែលបានកំណត់
  - . ពន្ធលើយានយន្ត
  - . ពន្ធផ្សេងៗលើការប្រើប្រាស់ ឬ អនុញ្ញាតប្រើប្រាស់ទ្រព្យ ឬ ប្រតិបត្តិសកម្មភាពអ្វីមួយ
  - . ពន្ធផ្សេងៗលើទ្រព្យ និងសេវា
- ពន្ធលើពាណិជ្ជកម្មក្រៅប្រទេស និងប្រតិបត្តិការអន្តរជាតិ
  - . ពន្ធគយ និងពន្ធផ្សេងៗលើការនាំចូល
  - . ពន្ធនាំចេញ
  - . ចំណេញលើការផ្តាច់មុខនាំចូល ឬ នាំចេញ
  - . ចំណេញពីអត្រាប្តូរប្រាក់
  - . ពន្ធលើប្រតិបត្តិការប្តូរប្រាក់
  - . ពន្ធផ្សេងៗទៀតលើពាណិជ្ជកម្មក្រៅប្រទេស និងប្រតិបត្តិការអន្តរជាតិ
- ចំណូលសារពើពន្ធផ្សេងៗ

**<u>វិភាគទានសង្គម</u>**

**<u>អំណោយ</u>**

**<u>ចំណូលលើកម្មសិទ្ធិ</u>**

**<u>ការលក់ទំនិញ និងសេវា</u>**

**<u>ការពិន័យ ការដាក់ទណ្ឌកម្ម ការរឹបអូស</u>**

**<u>ការផ្ទេរដោយឆន្ទៈ ក្រៅពីអំណោយ</u>**

**<u>ចំណូលផ្សេងទៀត ដែលបានចែងខាងលើ</u>**

សៀវភៅ GFS 2001 ដែលបានរៀបរាប់ខាងលើ ផ្តល់នូវទំនាក់ទំនងជាមួយ *ប្រព័ន្ធគណនេយ្យជាតិ ៩៣* ។



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ដោយច្បាប់» (មាត្រា ២៦ អនុក្រឹត្យលេខ ៨២) ។

«ចំណូលត្រូវកត់ត្រាចូលទាំងស្រុងនូវពន្ធ អាករ និង ផលិតផលឯទៀត ដោយគ្មានការកាត់កងរវាងចំណូល និង ចំណាយឡើយ» (មាត្រា ២៧ អនុក្រឹត្យលេខ ៨២) ។ ប្រការនេះ គឺជាការអនុវត្តនូវគោលការណ៍ **សកលភាព** ថវិកា ។

«ក្នុងលក្ខខណ្ឌដែលបានចែងសំរាប់ចំណូលនីមួយៗ ចំណូលត្រូវបានជម្រះបញ្ជីជាមុនសិន មុននឹងត្រូវបានប្រមូល ...។ ឥណទេយ្យដែលបានជម្រះបញ្ជីហើយ ត្រូវចេញ **ដីកាចំណូល** ។ **ការជម្រះបញ្ជី** គឺ ការកំណត់ចំនួនទឹកប្រាក់នៃបំណុលរបស់អ្នកជាប់អាករ» (មាត្រា ២៧ អនុក្រឹត្យលេខ ៨២) ។

ការបញ្ជូនដីកាចំណូលទៅអោយគណនេយ្យករទទួលបន្ទុកប្រមូលចំណូល គឺជាការរៀបចំប្រមូលចំណូល។ ជាធម្មតា ការបញ្ជូនដីការចំណូលត្រូវភ្ជាប់មកជាមួយនូវ **ដីការអមមួយ** ដែលត្រូវបានប្រើប្រាស់ដើម្បីចុះបញ្ជីការក្នុង **គណនេយ្យរដ្ឋបាល** (ដោយ អាណាប័ក) ដែលនឹងបញ្ជូនបន្តទៅអោយគណនេយ្យករនៃរតនាគារជាតិដើម្បីចុះបញ្ជីការ ។ ដីការអមនេះត្រូវមាន **លិខិតយុត្តិការ** ភ្ជាប់មកជាមួយ ។

### ១.២.១.២. ចំណាយ

«**ចំណាយ**ថវិការដ្ឋ ត្រូវតែគ្រោងនៅក្នុងថវិកា ហើយត្រូវអនុលោមតាមច្បាប់ និងបទបញ្ញាជាធរមាន» (មាត្រា ៤៥ អនុក្រឹត្យលេខ ៨២) ។

***តើវាក្យស័ព្ទ ចំណាយ បន្ទុក ប្រតិបត្តិការ ចំណូល ផលិតផល ការប្រើប្រាស់ ប្រភព មានភាពខុសគ្នា យ៉ាងដូចម្ដេច?***

ថវិកាត្រូវបានបង្កើតឡើង ជាដំបូង ដោយ **ការទទួលសាច់ប្រាក់** និង **ការបញ្ចេញសាច់ប្រាក់** (មូលដ្ឋានបេឡា) ឬ និយាយម្យ៉ាងទៀត គឺជា **ចំណូល** និង **ចំណាយ** ដែលជាវាក្យស័ព្ទប្រើប្រាស់ក្នុងការបកប្រែ **នីតិហិរញ្ញវត្ថុសាធារណៈ** កម្ពុជា ។ ក៏ប៉ុន្តែ វាក្យស័ព្ទទាំងនេះមិនមានន័យដូចគ្នាឡើយ ។

នៅពេលដែលខ្ញុំទូទាត់ចំណាយលើការហូបចុកនៅភោជនីយដ្ឋាន ប្រាក់នៅក្នុងហោប៉ៅរបស់ខ្ញុំនឹងថយចុះក្នុងទំហំទឹកប្រាក់ដូចគ្នា ។ ឧទាហរណ៍ នៅពេលដែលខ្ញុំទិញរថយន្តមួយតម្លៃ ៣០.០០០ ដុល្លារ ទ្រព្យសម្បត្តិរបស់ខ្ញុំនៅដដែលៈ ៣០.០០០ ដុល្លារ បានឆ្លងពីគណនីរបសខ្ញុំនៅធនាគារ ទៅជាអចលនទ្រព្យ ។ រថយន្ត ដែលនឹងថយចុះតម្លៃតាមពេលវេលា ត្រូវបានកត់ត្រាជាចំណាយលើការរំលស់ ។ ទ្រព្យសម្បត្តិរបស់ខ្ញុំនឹងថយចុះតាមពេលវេលានៃការកាន់កាប់រថយន្តនេះ រហូតដល់ពេលលក់ចេញ ឬ ខ្ញុំអាចប្រើប្រាស់តម្លៃសំណល់ ដើម្បីគណនាទំហំទឹកប្រាក់នៃការថយចុះទ្រព្យសម្បត្តិរបស់ខ្ញុំ (ទ្រព្យសកម្ម) ។ ខ្ញុំក៏ត្រូវមានបន្ទុកលើចំណាយប្រតិបត្តិការៈ បៀវត្សរ៍អ្នកបើកបរ ការធានារ៉ាប់រងប្រចាំឆ្នាំ ប្រេងឥន្ធនៈ និងការជួសជុល- ថែទាំជាប្រចាំ ។

សៀវភៅ GFS 2001 កំណត់ថា ចំណាយវិនិយោគជា «ប្រតិបត្តិការលើទ្រព្យសកម្ម » ។ ការសងបំណុលធ្វើឡើងច្រើនឆ្នាំ ។ ដូចគ្នាដែរ គេនិយាយពី «បន្ទុកបំណុល» ដែលមួយផ្នែក ត្រូវបានចាត់ទុកថា ជាចំណាយថវិកា ។

ខាងផ្នែក **ចំណូល** វាក្យស័ព្ទដែលត្រូវគ្នានឹងពាក្យចំណូលនេះ គឺ **ផល** ។ ចំពោះពាក្យ «**ប្រភព**» ដែលប្រើប្រាស់នៅក្នុងតារាងតុល្យការ សំដៅដល់ «**ប្រភពនៃសាច់ប្រាក់**» ។ ចំណែកឯពាក្យ «**ការប្រើប្រាស់**» សំដៅដល់ «ទិសដៅដែលសាច់ប្រាក់ត្រូវទៅដល់» ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

***មាតិកាចំណាយ : (ចំណាត់ថ្នាក់សេដ្ឋកិច្ច)***

ដូចគ្នានឹងចំណូលដែរ **មាតិកាចំណាយ** ត្រូវបានកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ (ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ) ។ មាតិកានេះត្រូវអនុលោមតាមនិយាមអន្តរជាតិ ដែលប្រើប្រាស់ជាផ្លូវការក្នុងសៀវភៅស្ថិតិស្តីពីហិរញ្ញវត្ថុសាធារណៈ (GFS 2001) របស់ **មូលនិធិរូបិយវត្ថុអន្តរជាតិ** ដែលរួមមាន៖

**បន្ទុក:**

- បៀវត្សរ៍បុគ្គលិក
- ការប្រើប្រាស់ទ្រព្យ និងសេវា
- ការប្រើប្រាស់មូលធន
- ការប្រាក់
- ឧបត្ថម្ភកធន
- អំណោយ
- សន្តិសុខសង្គម
- បន្ទុកផ្សេងៗ

**ប្រតិបត្តិការលើទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ**

- លទ្ធកម្មសុទ្ធនៃទ្រព្យសកម្មថេរ
- ការប្រើប្រាស់មូលធន
- បម្រែបម្រួលសន្និធិ
- ការទិញវត្ថុដែលមានតម្លៃ
- ការទិញទ្រព្យ ដែលមិនមែនជាផលិតផល

**ប្រតិបត្តិការលើទ្រព្យសកម្មហិរញ្ញវត្ថុ និងអកម្ម**

- មាសជារូបិយវត្ថុ និង SDR
- សាច់ប្រាក់ និង ប្រាក់បញ្ញើ
- មូលបត្រ ក្រៅពីភាគហ៊ុន
- ឥណទាន
- ភាគហ៊ុន និង ភាគកម្ម
- ទុនបម្រុងបច្ចេកទេសសម្រាប់វិស័យធានារ៉ាប់រង
- ផលិតផលហិរញ្ញវត្ថុនានា
- គណនីផ្សេងៗ ដែលត្រូវទទួល ឬ ត្រូវទូទាត់

«មុនពេលធ្វើ **ការទូទាត់** ចំណាយត្រូវតែបានធ្វើ **ធានាចំណាយ ជម្រះបញ្ជី** និង ចេញ **អាណត្តិបើកប្រាក់** » (មាត្រា ៨៦ អនុក្រឹត្យ ៨២) ។

## ១.២.១.២.១. ការធានាចំណាយ

«**ការធានាចំណាយ** គឺជាប្រតិបត្តិការដែលរដ្ឋបង្កើត ឬ ទទួលស្គាល់កាតព្វកិច្ចរបស់ខ្លួន ដែលនឹងនាំអោយមាន **ចំណាយថវិកា**» (មាត្រា ៨៧ អនុក្រឹត្យលេខ ៨២) ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

**ការធានាចំណាយគតិយុត្ត និង ការធានាចំណាយគណនេយ្យ**

ការធានាចំណាយមានពីរប្រភេទ គឺៈ **ការធានាចំណាយគតិយុត្ត** និង **ការធានាចំណាយគណនេយ្យ** ។ ការធានាចំណាយគតិយុត្ត គឺជាប្រតិបត្តិការដែលរដ្ឋបង្កើត ឬ ទទួលស្គាល់កាតព្វកិច្ចរបស់ខ្លួន ដែលនឹងនាំអោយមានចំណាយថវិកាៈ កិច្ចសន្យាជ្រើសរើសភ្នាក់ងារ លទ្ធកម្មសាធារណៈ កិច្ចសន្យាទិញ ឬ ជួសជុលកុំព្យូទ័រ ។ល។

ដើម្បីអាចធ្វើការធានាចំណាយគតិយុត្តិបាន អាណាប័កត្រូវបង្ហាញថាខ្លួនមានឥណទានគ្រប់គ្រាន់ នៅក្នុងថវិកាទូទៅដែលខ្លួនគ្រប់គ្រង ។ អាណាប័កត្រូវ កាត់ចេញពីស្តុកនៃឥណទានថវិកាដែលខ្លួនគ្រប់គ្រង នូវចំណាយដែលបានគ្រោងទុក និងបញ្ជូនសំណើជាលាយលក្ខអក្សរ ទៅអោយមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ។ មកដល់ត្រង់នេះ គឺជាការធានាចំណាយហិរញ្ញវត្ថុ ឬ **ការធានាចំណាយគណនេយ្យ** ។ មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុត្រូវពិនិត្យថាសំណើដែលបញ្ជូនដោយអាណាប័ក ត្រឹមត្រូវតាមខ្ទង់ចំណាយថវិកាដែលមាន និង ត្រូវពិនិត្យមើលឥណទានដែលមាន ។

ប្រសិនបើចំណាយត្រឹមត្រូវតាមខ្ទង់ថវិកា និង មានឥណទានថវិកាគ្រប់គ្រាន (ដោយត្រូវពិនិត្យ **នីតិភាព** នៃចំណាយ និង **ប្រក្រតីភាព**នៃសំណើ) មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុនឹងផ្តល់ទិដ្ឋាការលើសំណើសុំធានាចំណាយនោះ ។

មន្ត្រីត្រួតពិនិត្យហិរញ្ញត្ថុ កាត់ចេញពីស្តុកនៃឥណទានទំនេរ នូវទំហំទឹកប្រាក់ធានាចំណាយ ដើម្បីអោយគណនេយ្យនៃការធានាចំណាយហិរញ្ញវត្ថុរបស់ខ្លួន ត្រូវគ្នានឹងគណនេយ្យរបស់អាណាប័ក ។

ប្រសិនបើ **ការធានាចំណាយហិរញ្ញវត្ថុ** (ឬ **គណនេយ្យ**) ត្រូវបានបដិសេធដោយ មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ អាណាប័កត្រូវ «ដកចេញ» ទំហំទឹកប្រាក់ខាងលើពីគណនេយ្យរបស់ខ្លួនដោយចុះបញ្ជីការ (សរសេរពណ៌ក្រហម ប្រសិនបើកត់ត្រាដោយដៃ) ដែលជាការកត់ត្រាបញ្ច្រាសទិស ពីការកត់ត្រាសម្រាប់ការធានាចំណាយ ដើម្បីបង្កើតឥណទានឡើងវិញ ។

«គ្មានចំណាយសាធារណៈណាមួយក្នុងថវិកាជាតិ ឬ ក្នុងគណនីពិសេសរបស់រតនាគារ អាចយល់ព្រម ឬ ទទួលឱ្យចាប់ផ្តើមអនុវត្តបាន ដោយអាណាប័កដើមខ្សែ ឬ អាណាប័កផ្ទេរសិទ្ធិ បើគ្មានការស្នើសុំជាលាយលក្ខអក្សរ និងមានទិដ្ឋាការយល់ព្រម ពីមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ» (មាត្រា ៣ អនុក្រឹត្យ លេខ ៨១) ។

គេតែងតែចោទសួរជារឿយៗថាៈ «តើទំហំទឹកប្រាក់ដែលត្រូវធានាចំណាយមានប៉ុន្មាន ដើម្បីអោយគណនេយ្យនៃការធានាចំណាយឆ្លុះបញ្ចាំង អោយបានត្រឹមត្រូវនូវ **ការធានាចំណាយគតិយុត្ត** ?

គោលការណ៍ទាំងឡាយនៃ **ការធានាចំណាយ** និង **ការចុះបញ្ជីការគណនេយ្យ** បង្កើតជាសំណួរថាៈ តើគេអាចធ្វើការកែតម្រូវសាច់ប្រាក់ តាមរយៈការធានាចំណាយបានដែរឬទេ ?

បទប្បញ្ញត្តិនៃមាត្រា ៤៩ នៃអនុក្រឹត្យលេខ ៨២ បានចែងថាៈ «សង្វាក់នៃការធានាចំណាយប្រចាំខែត្រូវសម្រេចដោយរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទៅតាមស្ថានភាពនៃការប្រមូលចំណូលថវិកា» អាចយកទៅបំភ្លឺបញ្ហាដែលបានលើកឡើងខាងលើ ។



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

*តើទំហំទឹកប្រាក់ចំនួនប៉ុន្មាន ដែលត្រូវបានអនុញ្ញាតអោយធានាចំណាយគណនេយ្យ?*

**គណនេយ្យហិរញ្ញវត្ថុ**នៃការធានាចំណាយត្រូវឆ្លុះបញ្ចាំងនូវតថភាពនៃ **ការធានាចំណាយគតិយុត្តិ** ដើម្បីអោយឥណទានដែលនៅសល់ទំនេរ ពិតជានៅទំនេរអាចប្រើប្រាស់ពិតមែន និងអនុញ្ញាតអោយការគ្រប់គ្រងថវិកា និងការព្យាករណ៍អាចអនុវត្តបានដោយរលូន ទាំងសម្រាប់ការធានាចំណាយលើកក្រោយទៀត ទាំងសម្រាប់ការរក្សាទុកឥណទានសម្រាប់ចំណាយផ្សេងទៀត ។

ជាការពិតទៅ ប្រសិនបើគណនេយ្យនៃ **ការធានាចំណាយហិរញ្ញវត្ថុ** ប៉ាន់ស្មានទាបជាង **ការធានាចំណាយគតិយុត្តិ** ការអនុវត្តថវិកាអាចធ្វើអោយលើសពីឥណទានដែលត្រូវបានអនុញ្ញាតអោយប្រើប្រាស់ ។

ឧទាហរណ៍ កិច្ចសន្យាភតិសន្យាសំរាប់រយៈពេលមួយឆ្នាំ មិនអាចធ្វើកិច្ចសន្យាតាមត្រីមាសបានទេ ។ គេត្រូវចុះកិច្ចសន្យាលើទំហំទឹកប្រាក់សម្រាប់រយៈពេលមួយឆ្នាំ ។ ប្រសិនបើច្បាប់អនុញ្ញាតអោយធានាចំណាយច្រើនឆ្នាំ គេត្រូវធានាចំណាយសម្រាប់ទំហំទឹកប្រាក់ទាំងស្រុង សំរាប់រយៈពេលច្រើនឆ្នាំ ។ បន្ទាប់មកការទូទាត់ត្រូវអនុវត្តតាមរយៈ **ឥណទានទូទាត់** ប្រចាំឆ្នាំ ។

កិច្ចសន្យាជួសជុលដែលត្រូវទូទាត់មួយត្រីមាសម្តង ប៉ុន្តែកត់ត្រាប្រចាំឆ្នាំ ត្រូវតែធានាចំណាយក្នុងទំហំទឹកប្រាក់ប្រចាំឆ្នាំ ឬ សម្រាប់រយៈពេលនៃកិច្ចសន្យា ប្រសិនបើរយៈពេលកិច្ចសន្យានេះតិចជាងមួយឆ្នាំ ។

ចំណាយបុគ្គលិកត្រូវតែធានាចំណាយប្រចាំឆ្នាំដូចគ្នាដែរ ឬ សំរាប់រយៈពេលនៃកិច្ចសន្យា ប្រសិនបើរយៈពេលនៃកិច្ចសន្យានេះតិចជាងមួយឆ្នាំ ។

ចំណាយច្បាស់លាស់ ឬចំណាយកាតព្វកិច្ចទាំងអស់ ត្រូវតែធានាចំណាយនៅដើមឆ្នាំ (សូមអានមាត្រា ១២ អនុក្រឹត្យលេខ ៨១) ។

### ១.២.១.២.២. ការជម្រះបញ្ជី

«មុននឹងធ្វើ **ការទូទាត់** ចំណាយត្រូវតែ មានការធានាចំណាយ **ការជម្រះបញ្ជី** និង ចេញអាណត្តិបើកប្រាក់ ជាមុនសិន» (មាត្រា ៨៦ អនុក្រឹត្យលេខ ៨២) ។

«**ការជម្រះបញ្ជី** មានគោលដៅផ្ទៀងផ្ទាត់ភាពពិតប្រាកដនៃបំណុល និងបញ្ឈប់ទឹកប្រាក់ចំណាយ ។ ការជម្រះបញ្ជីនេះត្រូវធ្វើឡើង ក្រោយពីបានឃើញមូលបត្រ បញ្ជាក់ពីសិទ្ធិរបស់ឥណទាយក» (មាត្រា ៥១ អនុក្រឹត្យលេខ ៨២) ។

ចំណុចសំខាន់នៃការជម្រះបញ្ជី គឺ ការបញ្ជាក់ពី «សេវាដែលបានផ្គត់ផ្គង់» : គោលការណ៍ទូទៅ គឺថាការទូទាត់អាចអនុវត្តបាន បន្ទាប់ពីសេវាត្រូវបានផ្គត់ផ្គង់ (បៀវត្សរ៍ ការផ្គត់ផ្គង់ទំនិញ និងសេវា ។ល។) ។ នៅក្នុងពេលជម្រះបញ្ជី អាណាប័កដើមខ្សែ ឬ អាណាប័កផ្ទេរសិទ្ធិ ត្រូវផ្ទៀងផ្ទាត់ថា ឥណទាយក (អ្នកផ្គត់ផ្គង់) បានបំពេញកាតព្វកិច្ចទាំងឡាយរបស់ខ្លួន ដូចដែលបានចែងនៅក្នុងបញ្ជាចំណាយ: បរិមាណផ្តល់ គុណភាព ការគោរពពេលវេលា ។ បន្ទាប់មក អាណាប័កកំណត់ទំហំទឹកប្រាក់ចំណាយ ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

***ការគ្រប់គ្រងសាច់ប្រាក់***

ការប្រមូលចំណូលថវិកាប្រភេទខ្លះតែងតែមានភាពមិនទៀងទាត់ ÷ ដោយសារកត្តាកាលបរិច្ឆេទតែមួយ ការបង់ប្រាក់រំដោះពន្ធ តាមកាលបរិច្ឆេទកំណត់តែមួយ ។

ក្នុងន័យនេះ ចំណាយក៏ត្រូវតែគ្រប់គ្រង អោយស៊ីសង្វាក់ទៅតាមភាពមិនទៀងទាត់នៃការប្រមូលចំណូល និងទៅតាមការប៉ាន់ប្រមាណលើសនៃចំណូលមួយចំនួន ។

ការព្យាករណ៍ស្តីពីការប្រមូលចំណូលត្រូវតែធ្វើឡើង ដោយស្របទៅតាមប្រភេទចំណូលដែលបានលម្អិត និងទៅតាមរយៈពេលនៃការប្រមូលចំណូល (សប្តាហ៍ ខែ ឬ ត្រីមាស) ដើម្បីអោយអ្នកទទួលខុសត្រូវអាចតាមដានការអនុវត្តថវិកាបាន ។

ខាងផ្នែកចំណាយ ចំណាយមួយចំនួនមានលក្ខណៈច្បាស់លាស់ និងមានកាលបរិច្ឆេទជាក់លាក់ (ឧទាហរណ៍ ប្រាក់ខែ ប្រាក់ឈ្នួល កិច្ចសន្យាថែទាំ) ។ ចំណាយមួយចំនួនទៀតច្បាស់លាស់ តែគ្មានកាលបរិច្ឆេទច្បាស់លាស់ឡើយ (ឧទាហរណ៍ បំណុល) ។

ចាប់តាំងពីដើមឆ្នាំ ការធានាចំណាយដែលច្បាស់លាស់ និងមានកាលបរិច្ឆេទច្បាស់លាស់ និងមិនច្បាស់លាស់ អាចអោយគេដឹង ពីឥណទានទំនេរពិតប្រាកដ តាមរយៈគណនេយ្យធានាចំណាយ ។

ដូច្នេះ មន្ត្រីគ្រប់គ្រងថវិកាអាចគ្រប់គ្រងបានតែឥណទានទំនេរប៉ុណ្ណោះ ទើបគេអាចគ្រប់គ្រងការធានាចំណាយ និង គ្រប់គ្រងចំណាយលើសឥណទានថវិកា (ក្នុងករណីបន្ទាន់ និងចាំបាច់) ។

### ១.២.១.២.៣. ការចេញអាណត្តិបើកប្រាក់

«មុននឹងធ្វើ **ការទូទាត់** ចំណាយត្រូវតែ មានការធានាចំណាយ ការជម្រះបញ្ជី និង ចេញ **អាណត្តិបើកប្រាក់** ជាមុនសិន» (មាត្រា ៥៦ អនុក្រឹត្យលេខ ៨២) ។

«**ការចេញអាណត្តិបើកប្រាក់** គឺជាប្រតិបត្តិការរដ្ឋបាល ដែលបញ្ជាអោយរដ្ឋសងបំណុលរបស់ខ្លួន ដោយស្របតាមលទ្ធផលនៃការជម្រះបញ្ជី» (មាត្រា ៥៣ អនុក្រឹត្យលេខ ៨២) ។

«ចំណាយថវិកាត្រូវតែមាន **អាណត្តិបើកប្រាក់** ដែលចេញដោយអាណាប័ក ។ ក្នុងន័យនេះ អាណាប័កត្រូវចេញ **អាណត្តិបើកប្រាក់** ដើម្បីទូទាត់ចំណាយថវិកា ។ អាណត្តិបើកប្រាក់ដែលចេញដោយអាណាប័កដើមខ្សែត្រូវកត់ត្រាតាមប្រភេទនៃឥណទាន ដែលបានផ្តល់ជូនតាមខ្ទង់ថវិកា ។ អាណត្តិចេញដោយអាណាប័កផ្ទេរសិទ្ធិត្រូវកត់ត្រាតាមប្រភេទនៃឥណទាន ដែលប្រគល់ដោយអាណាប័កដើមខ្សែ តាមរយៈប្រកាសផ្ទេរសិទ្ធិ» (មាត្រា ៥៤ អនុក្រឹត្យលេខ ៨២) ។

«អាណត្តិ និង ប្រកាសផ្ទេរសិទ្ធិលើឥណទាន ត្រូវឆ្លងទិដ្ឋាការជាមុនពីមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ...» (មាត្រា ៥៥ អនុក្រឹត្យលេខ ៨២) ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

***តើ បញ្ជាចំណាយ និង អាណត្តិបើកប្រាក់ មានភាពខុសគ្នាយ៉ាងដូចម្តេច?***

នៅព្រះរាជាណាចក្រកម្ពុជា អាណាប័កចេញអាណត្តិបើកប្រាក់ (បើទោះជា មាត្រា ៦៦ នៃអនុក្រឹត្យ ៨២ ហៅថា «**បញ្ជាចំណាយ**» ។ នៅប្រទេសបារាំង អាណាប័កដើមខ្សែនៅរដ្ឋបាលកណ្តាលចេញ **បញ្ជាចំណាយ** (Ordonnance de paiement) និង សិទ្ធិប្រទាន ។ អាណាប័ករង និងអាណាប័កផ្ទេរសិទ្ធិចេញ **អាណត្តិបើកប្រាក់** ។ អាណាប័កដើមខ្សែនៃស្ថាប័នសាធារណៈចេញ **បញ្ជាចំណាយ** (Ordre de paiement)។

«អាណត្តិចេញដោយរដ្ឋមន្ត្រីក្នុងនាមជាអាណាប័កដើមខ្សែ និង ចេញដោយប្រធាននៃរដ្ឋបាលកណ្តាលក្នុងនាមជាអាណាប័កផ្ទេរសិទ្ធិ ត្រូវបានចាត់ចែងដោយគណនេយ្យករមុខការរបស់រតនាគារជាតិ ។ អាណត្តិចេញដោយអភិបាលខេត្ត- ក្រុង ក្នុងនាមអាណាប័កផ្ទេរសិទ្ធិ ត្រូវបានចាត់ចែងដោយគណនេយ្យកររងរបស់រតនាគារខេត្ត- ក្រុង ដែលជាមណ្ឌលរបស់អភិបាលខេត្ត- ក្រុងនោះ» (មាត្រា ៥៦ អនុក្រឹត្យលេខ ៨២) ។

ដើម្បីងាយស្រួលតាមដានការចេញ **អាណត្តិបើកប្រាក់** ជាទូទៅ អាណត្តិទាំងនេះត្រូវបញ្ជូនទៅគណនេយ្យករ ដោយមាន **កំណត់ហេតុ** និង **លិខិតយុត្តិការ** ភ្ជាប់ជាមួយ ។ គណនេយ្យករទទួលអាណត្តិបើកប្រាក់ទាំងនេះ ដើម្បីធ្វើការទូទាត់ ។

### ១.២.២. តម្រិតគណនេយ្យករ: ដំណាក់កាលគណនេយ្យ

«គណនេយ្យករសាធារណៈ ជាអ្នកទទួលបន្ទុកៈ

- ការទទួលខុសត្រូវក្នុងការប្រមូលចំណូល ដែលអាណាប័កបានប្រគល់អោយប្រមូលឥណទេយ្យ តាមកិច្ចសន្យាមូលបត្រកម្មសិទ្ធិ ឬ មូលបត្រផ្សេងៗទៀត ដែលគណនេយ្យករត្រូវធានារក្សាទុកដាក់ ព្រមទាំងបញ្ចូលក្នុងបេឡា នូវប្រាក់ពន្ធបង់ដល់ដៃ និងចំណូលគ្រប់ប្រភេទទាំងអស់ ដែលរដ្ឋមាននីតិសម្បទាទទួល
- ទូទាត់ចំណាយ តាមបញ្ជាអាណាប័ក
- ការពារ និងរក្សាទុកនូវមូលនិធិ ទ្រព្យសម្បត្តិនានារបស់រដ្ឋ និងរបស់គ្រឹះស្ថានសាធារណៈផ្សេងៗទៀត
- កាន់កាប់មូលនិធិ និងចលនាគណនីប្រាក់ទំនេរ
- រក្សាទុកដាក់លិខិតយុត្តិការនៃប្រតិបត្តិការចំណូល- ចំណាយ និងឯកសារគណនេយ្យ
- កាន់បញ្ជីគណនី តាមដំណែងរបស់ខ្លួន (មាត្រា ១២ អនុក្រឹត្យលេខ ៨២) ។


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

**ឥណទាយក និង ឥណាយិក**

ឥណទាយក (Créancier) គឺជាអ្នកដែលរដ្ឋជំពាក់អ្វីមួយៈ ឥណទេយ្យ ។ ឥណទាយក គឺជាអ្នកផ្គត់ផ្គង់ ។ ចំណែកឯឥណាយិក (Débiteur) ជាអ្នកដែលជំពាក់រដ្ឋ ។ អ្នកជំពាក់ពន្ធ (Redevable) សំដៅលើឥណាយិកដែលជំពាក់ពន្ធ ។

ខាងផ្នែកចំណូល និងចំណាយ គណនេយ្យករទទួលបន្ទុកចុះកិច្ចបញ្ជីការប្រតិបត្តិការ បន្ទាប់មក ចាត់ការប្រមូលចំណូល ឬ ទូទាត់ចំណាយ បន្ទាប់ពីបានធ្វើការត្រួតពិនិត្យតាមសមត្ថកិច្ចរបស់ខ្លួន ។

### ១.២.២.១. ចំណូល

#### ១.២.២.១.១. ការកំណត់ចំណូល

បន្ទាប់ពីបានទទួល **ដីកាចំណូល** គណនេយ្យករត្រួតពិនិត្យអត្តសញ្ញាណរបស់ឥណាយិក ពិនិត្យមើលលិខិតយុត្តិការ និង «ពិនិត្យភាពត្រឹមត្រូវនៃ **ដីកាចំណូល**» (មាត្រា ១៣ នៃអនុក្រឹត្យ ៨២)។

#### ១.២.២.១.២. ការប្រមូលចំណូល

គណនេយ្យករសាធារណៈត្រូវអោយដំណឹងទៅអោយឥណាយិក នូវទំហំទឹកប្រាក់ដែលត្រូវទូទាត់ និងទទួលសាច់ប្រាក់នៅពេលទូទាត់ ។

«ប្រសិនបើការប្រមូលចំណូលមិនអាចធ្វើទៅបានដោយស្រុះស្រួលទេ ឥណទេយ្យនឹងត្រូវប្រមូលដោយចាប់បង្ខំ ទៅតាមផ្លូវច្បាប់ ទៅតាមដីកាដែលចាប់បង្ខំអោយធ្វើ» (មាត្រា ៣០ អនុក្រឹត្យ លេខ ៨២) ។

នៅពេលខ្លះ ការបង់ប្រាក់ និង ការកត់ត្រាចំណូលអាចធ្វើឡើងខុសពេលគ្នា ។ ក្នុងករណីនេះ គណនេយ្យករសាធារណៈទទួលសាច់ប្រាក់ចំណូល ហើយដាក់ចូលក្នុងបេឡា បន្ទាប់មកទើបផ្តល់ព័ត៌មានទៅអោយអាណាប័ក និង ស្នើសុំអោយអាណាប័កចេញដីកាចំណូលដើម្បីធ្វើនិយ័តភាពជាក្រោយ ។

### ១.២.២.២. ចំណាយ

#### ១.២.២.២.១. ការកំណត់ចំណាយ

គណនេយ្យករសាធារណៈមានមុខងារពីរ ÷

- **មុខងារជាអ្នកទូទាត់** : ជាអ្នកត្រួតពិនិត្យ និង



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

***ការត្រួតពិនិត្យប្រក្រតីភាព នីតិភាព និងការត្រួតពិនិត្យកាលានុវត្តភាព?***

តើសារជាតិនៃការត្រួតពិនិត្យរបស់គណនេយ្យករមានដូចម្តេច? **យុត្តិសាស្ត្របារាំង**បានបែងចែក ដូចតទៅ៖

- **ការត្រួតពិនិត្យប្រក្រតីភាព** ជាភារកិច្ចរបស់គណនេយ្យករ ក៏ប៉ុន្តែ គណនេយ្យករមិនទទួលបន្ទុកពិនិត្យលើការមិនអនុលោមតាមច្បាប់ និងការទូទាត់របស់អាណាប័កឡើយ (Marillier et Balme, Cours des Comptes ចុះថ្ងៃ ២៨ ខែ ឧសភា ឆ្នាំ ១៩៩៥) ។
- **ការត្រួតពិនិត្យនីតិភាព** ជាធម្មតា នីតិភាពត្រូវត្រួតពិនិត្យដោយមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ (ប៉ុន្តែច្បាប់ខ្មែរមិនប្រគល់តួនាទីនេះ ទៅអោយមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុឡើយ) និង ដោយអភិបាលដែនដី (Préfet) ឬ រដ្ឋបាលតំបន់ ។
- **ការត្រួតពិនិត្យកាលានុវត្តភាព** ជាទូទៅ ជាការទទួលខុសត្រូវរបស់អាណាប័ក ។

- **មុខងារជាបេឡាករ:** គឺជាអ្នកធ្វើការទូទាត់បំណុលរបស់រដ្ឋ ដោយទូទាត់អោយម្ចាស់បំណុល ដើម្បីអោយរួចផុតពីកាតព្វកិច្ចរបស់រដ្ឋ ដែលជំពាក់បំណុល ។

ផ្ទុយពីការអនុវត្តខាងផ្នែកចំណូល អនុក្រឹត្យលេខ ៨២ មិនបានចែងជាផ្លូវការពីការកំណត់ចំណាយទេ ។ ក៏ប៉ុន្តែ អនុក្រឹត្យនេះហាក់ដូចជាបានសង្កត់ថា : គណនេយ្យករ ដែលទទួលអាណត្តិពីអាណាប័ក ត្រូវត្រួតពិនិត្យ និង សម្រេចថាបដិសេធ (បញ្ជូនត្រលប់ទៅវិញ) ឬ ចុះកិច្ចបញ្ជីការចំណាយ ។

«គណនេយ្យករសាធារណៈមានភារៈកិច្ច... ខាងផ្នែកចំណាយ ត្រួតពិនិត្យ ÷

- លក្ខណៈសម្បត្តិរបស់អាណាប័ក ឬ អាណាប័កផ្ទេរសិទ្ធ
- សំណល់ទំនេរនៃឥណទាន
- ការកំណត់ត្រឹមត្រូវពិតប្រាកដខ្ទង់ចំណាយតាមជំពូក ដែលពាក់ព័ន្ធដល់រូបធាតុ និងមុខសញ្ញារបស់វា
- ការបញ្ជាក់ត្រឹមត្រូវអំពីសេវា ដែលបានធ្វើហើយ និងភាពប្រាកដប្រជានៃការគណនាជម្រះឥណទេយ្យ
- ការបញ្ជាក់ទិដ្ឋាការរបស់អភិបាលហិរញ្ញវត្ថុ លើកិច្ចសន្យា និងអាណត្តិ
- ផលិតកម្មលិខិតយុត្តិការនៃឥណទេយ្យ
- ការអនុវត្តវិធានស្តីពីអាជ្ញាយុកាល និងឥណទេយ្យដែលផុតកាលកំណត់ (មាត្រា ១៣ អនុក្រឹត្យលេខ ៨២) ។

### ១.២.២.២.២. ការទូទាត់

បន្ទាប់ពីបានពិនិត្យភាពប្រក្រតីនៃអាណត្តិបើកប្រាក់ គណនេយ្យករសាធារណៈ ក្នុងនាមជាបេឡាករ

**ការប្រឆាំងជំទាស់ការទូទាត់**

«រាល់ការជំទាស់ ឬ ការអោយដំណឹងផ្សេងៗដែលមានកម្មវត្ថុបញ្ឈប់ការទូទាត់ ត្រូវធ្វើឡើងដោយផ្ទាល់ដៃរបស់គណនេយ្យករសាធារណៈមុខការចំណាយ» (មាត្រា ៦២ អនុក្រឹត្យលេខ ៨២) ។

ចាប់ផ្តើមទូទាត់ «**ការទូទាត់** គឺជាប្រតិបត្តិការ ដែលរដ្ឋបានសងបំណុលរបស់ខ្លួន» (មាត្រា ៥៧ អនុក្រឹត្យ ៨២) ។

«លើកលែងតែក្នុងករណីដែលបានចែងដោយច្បាប់ និងលិខិតបទដ្ឋានផ្សេងៗ ការទូទាត់មិនអាចឡើងមុនរយៈពេលត្រូវសងបំណុល ឬ មុនការផ្គត់ផ្គង់សេវាឡើយ ។ ក៏ប៉ុន្តែ គេអាចផ្តល់នូវការទូទាត់រំដោះ ឬ ផ្តល់បុរេប្រទានអោយសហគ្រិន ឬអ្នកផ្គត់ផ្គង់បាន ក្នុងលក្ខខណ្ឌដែលចែងដោយលិខិតបទដ្ឋានជាធរមាន» (មាត្រា ៥៧ អនុក្រឹត្យលេខ ៨២) ។

**ឥណនេយ្យរបស់រដ្ឋមានអាយុកាលស្ថិតស្ថេរហួតឬ ?**

វិធានស្តីពីអាជ្ញាយុកាលត្រូវបានអនុវត្ត ដូចខាងក្រោម៖

«លក្ខខណ្ឌ ដែលឥណនេយ្យមិនបានទូទាត់ត្រូវបានផុតរលត់ជាស្ថាពរ ហើយក្លាយជាប្រយោជន៍រដ្ឋ ត្រូវកំណត់ដោយច្បាប់» (មាត្រា ៦៣ អនុក្រឹត្យលេខ ៨២) ។

«ឥណទាយិករបស់រដ្ឋត្រូវបានរួចខ្លួន...ប្រសិនបើឥណទាយិកនោះមានសំអាងលើអាជ្ញាយុកាល...» (មាត្រា ៣២ អនុក្រឹត្យលេខ ៨២) ។

រយៈពេលអាជ្ញាយុកាល គឺ ៣ ឆ្នាំ ។

«សេចក្តីជូនដំណឹងស្តីពីការទារបំណុល ផ្អាកអាជ្ញាយុកាលបច្ចុប្បន្ន និងផ្តល់អាជ្ញាយុកាលថ្មី ៣ ឆ្នាំ ទៀត» (មាត្រា ៧៤ នៃច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ១៩៩៦) ។

«គណនេយ្យករមុខការ...ចាប់ផ្តើមរៀបចំទូទាត់អាណត្តិបើកប្រាក់ ។ ការទូទាត់ត្រូវធ្វើឡើងដោយប្រគល់សាច់ប្រាក់ប្រាក់ មូលប្បទានប័ត្រ ឬ ដោយបង្វែរ » (មាត្រា ៥៨ អនុក្រឹត្យលេខ ៨២) ។

«...រាល់ការបើកផ្តល់ដែលមានទឹកប្រាក់លើសពី ២,៥ លានរៀលឡើងទៅ អាចធ្វើការទូទាត់តាមរយៈធនាគារ ឬ មូលប្បទានប័ត្រ» ប្រកា ៨ ប្រកាសលេខ ៤ សហវ.មប្រក ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការអនុវត្តបទបញ្ញត្តិទូទៅនៃគណនេយ្យសាធារណៈ ។

«នៅពេលអនុវត្តការត្រួតពិនិត្យ...បើកត់សម្គាល់ឃើញភាពមិនត្រឹមត្រូវ នោះគណនេយ្យករសាធារណៈត្រូវព្យួរទុកការទូទាត់ ហើយត្រូវផ្តល់ព័ត៌មានដល់អាណាប័ក ។ ការទូទាត់ក៏អាចព្យួរទុកបានដែរ កាលណាគណនេយ្យករសាធារណៈបានពិនិត្យឃើញសេចក្តីបញ្ជាក់ (សេវាដែលបានផ្គត់ផ្គង់) ពុំមានភាពត្រឹមត្រូវ» (មាត្រា


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

៥៩ អនុក្រឹត្យលេខ ៨២) ។

## ២. ការអនុវត្តផ្ទុយនឹងគោលការណ៍វិសមិតភាពរវាងអាណាប័ក និងគណនេយ្យករ

ការអនុវត្តផ្ទុយនឹងគោលការណ៍វិសមិតភាពរវាងអាណាប័ក និងគណនេយ្យករគឺ ÷ ទី ១ ការចាប់បង្ខំ និង ទី ២ វដ្តទេយ្យករ ។ ករណីទាំងពីរនេះសុទ្ធតែត្រូវទទួលការអនុញ្ញាត តែករណីទី ២ គឺជាការគ្រប់គ្រងតាមសភាពការណ៍ជាក់ស្តែង (ករណីពិសេស) ។

### ២.១. ការចាប់បង្ខំ

តើមានអ្វីកើតឡើងបើគណនេយ្យករបដិសេធមិនទូទាត់ ?

«...នៅពេលដែលគណនេយ្យករព្យួរទុកការទូទាត់ចំណាយណាមួយ...អាណាប័កអាចចាប់បង្ខំជាលាយល័ក្ខអក្សរ...អោយគណនេយ្យករធ្វើការទូទាត់ក្រោមការទទួលខុសត្រូវរបស់ខ្លួន» (មាត្រា ៨ អនុក្រឹត្យលេខ ៨២) ។

«...នៅពេលដែលអាណាប័កទាមទារបង្ខំអោយគណនេយ្យករធ្វើការទូទាត់នោះ គណនេយ្យករព្រមអនុវត្តតាមបទបញ្ជា រួចហើយរាយការណ៍ជូនរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។ បញ្ជាចាប់បង្ខំអោយទូទាត់ចេញដោយអាណាប័ក នឹងត្រូវបានបញ្ជូនទៅតុលាការគណនី (អាជ្ញាធរសវនកម្មជាតិ) ដោយរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ» (មាត្រា ៦០ អនុក្រឹត្យលេខ ៨២) ។

«...គណនេយ្យករត្រូវបដិសេធបញ្ជាចាប់បង្ខំអោយទូទាត់ នៅពេលដែលការព្យួរទុកនៃការទូទាត់នោះបណ្តាលមកពីមូលហេតុ ដូចខាងក្រោម ÷

- ភាពមិនទំនេរនៃឥណទាន
- ពុំមានទិដ្ឋាការលើអាណត្តិ ដោយមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ
- ពុំមានលិខិតយុត្តិការ (ការបញ្ជាក់) ពីសេវាដែលបានផ្តត់ផ្គង់
- ការទូទាត់ដែលមានលក្ខណៈមិនអោយរួចបំណុល

ក្នុងករណីបដិសេធបញ្ជាចាប់បង្ខំអោយទូទាត់ គណនេយ្យករត្រូវរាយការណ៍ភ្លាមជូនរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីធ្វើការសម្របសម្រួលជាមួយរដ្ឋមន្ត្រីដែលពាក់ព័ន្ធ» (មាត្រា ៦១ អនុក្រឹត្យលេខ ៨២) ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

**ការពិគ្រោះសាមញ្ញ និង ការពិគ្រោះអនុលោម**

**ការពិគ្រោះ** (Avis) គឺជាលទ្ធផលនៃការពិភាក្សា ដោយស្ម័គ្រចិត្ត ឬ ដោយកាតព្វកិច្ច ។ នៅពេលដែល ការពិគ្រោះមានលក្ខណៈជាកាតព្វកិច្ច នៅក្នុងអត្ថន័យរបស់វា ដែលទាមទារអោយគេអនុវត្តតាម ការពិគ្រោះនេះ គឺជា ការពិគ្រោះអនុលោម (Avis conforme) ។ ក្នុងករណីផ្សេងទៀត គេនិយាយពី ការពិគ្រោះសាមញ្ញ (Avis simple) ឬ ការពិគ្រោះសុំយោបល់ (Avis consultatif)។

## ២.២. រដ្ឋទេយ្យ និង រដ្ឋទេយ្យករ

នៅពេលខ្លះ បុគ្គលតែម្នាក់អាចមានមុខងារជាអាណាប័កផង និងជាគណនេយ្យករផង: **រដ្ឋទេយ្យករ** គឺជា ភ្នាក់ងារដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់អាណាប័ក (ដែលផ្ទុយពីគណនេយ្យករសាធារណៈ ដែលស្ថិតក្រោម សមត្ថកិច្ចរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ) និងអាចអនុវត្តប្រតិបត្តិការប្រមូលចំណូល និងទូទាត់ចំណាយ ។

សម្រាប់ការបើកប្រាក់ គឺជា **រដ្ឋទេយ្យចំណូល** សម្រាប់ការទូទាត់ចំណាយ គឺជា **រដ្ឋទេយ្យបុរេប្រទាន** ។

«រដ្ឋទេយ្យចំណូល និងរដ្ឋទេយ្យបុរេប្រទាន ត្រូវបានបង្កើតឡើងដោយប្រកាសរួមរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និងក្រសួងពាក់ព័ន្ធ ។ គណនេយ្យករសាធារណៈរបស់រដ្ឋ ដែលរដ្ឋទេយ្យករធ្វើប្រតិបត្តិការជំនួស ហៅថា **គណនេយ្យករមុខការរបស់អាណាប័ក** ដែលរដ្ឋទេយ្យនោះនៅក្រោមចំណុះ» (មាត្រា ២៣ អនុក្រឹត្យ លេខ ៨២) ។

នៅព្រះរាជាណាចក្រកម្ពុជា រដ្ឋទេយ្យករត្រូវបានតែងតាំងដោយប្រកាសរួមរបស់ក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និងក្រសួងពាក់ព័ន្ធ ។ នៅប្រទេសបារាំង រដ្ឋទេយ្យករត្រូវបានតែងតាំងដោយប្រកាសរបស់អាណាប័ក ដោយផ្អែកលើការពិគ្រោះអនុលោម (Avis conforme) របស់គណនេយ្យករមុខការ ។

«រដ្ឋទេយ្យករចំណូល និង និងរដ្ឋទេយ្យករបុរេប្រទាន ស្ថិតក្រោមការត្រួតពិនិត្យរបស់អាណាប័ករបស់ខ្លួន និង គណនេយ្យករមុខការ» (មាត្រា ២៤ អនុក្រឹត្យលេខ ៨២) ។



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

## ***តើរដ្ឋទេយ្យដំណើរការយ៉ាងដូចម្ដេច?***

**រដ្ឋទេយ្យចំណូល**: រជ្ជទេយ្យករមានភារៈកិច្ចប្រមូលចំណូលចូលបេឡា ។ «ការពិន័យរបស់នគរបាលពីបទល្មើសចរាចរត្រូវប្រមូលដោយស្នងការនគរបាល ដែលត្រូវបង្កើតជារដ្ឋទេយ្យចំណូល តាមរយៈប្រកាសរួមរបស់ក្រសួងមហាផ្ទៃ និង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។ ភ្នាក់ងារនគរបាលត្រូវធ្វើកំណត់ហេតុ ផ្ដល់ទៅអ្នកប្រព្រឹត្តបទល្មើស ព្រមទាំងអញ្ជើញគេ អោយទៅស្នងការនគរបាលដើម្បីបង់ប្រាក់ពិន័យ» (ប្រការ ៣ ប្រកាសលេខ ០០៤/សហវ.មប្រក ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៩៦ ស្ដីពីការអនុវត្តបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ) ។

«...រជ្ជទេយ្យករចំណូល ត្រូវបង់ចំណូលដែលខ្លួនទទួលបានយ៉ាងតិចណាស់ក្នុងមួយខែម្ដង រៀងរាល់ថ្ងៃ ២៥ នៃខែនិមួយៗ និង ថ្ងៃទី ៣១ ខែ ធ្នូ និង រាល់ពេលវេលាដែលគណនេយ្យករមានប្រាក់លើសពីកម្រិតនៃចំនួនទឹកប្រាក់ ដែលបានកំណត់ដោយរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ» (ប្រការ ៤ ប្រកាសលេខ ៤) ។

**រដ្ឋទេយ្យបុរេប្រទាន (និងភ្នាក់ងារបើកផ្ដល់)**: «...សម្រាប់ប្រភេទចំណាយមួយចំនួន និងចំណាយសម្ភារៈព្រមទាំងការថែទាំ ដែលមានទឹកប្រាក់ទាបជាង ៥០០.០០០ រៀល អាចប្រព្រឹត្តទៅដោយប្រើរដ្ឋទេយ្យបុរេប្រទាន ។ ដោយឡែក ការចំណាយបៀវត្សរ៍ ចំណាយសន្តិសុខសង្គម និងពលីពិការ ត្រូវអនុវត្តតាមរយៈភ្នាក់ងារបើកផ្ដល់ (Agents payeurs)» (ប្រការ ៩ ប្រកាស ៤) ។ លើកលែងតែបដិប្បញ្ញត្តិដែលយល់ព្រមដោយ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបានទូទាត់តាមរយៈរដ្ឋទេយ្យនូវ៖

១- ចំណាយកំប៉ិកកំប៉ុកទិញសំភារៈក្នុងចំនួនទឹកប្រាក់ ដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

២- លាភការទាំងឡាយរបស់បុគ្គលិក

៣- សង្គ្រោះបន្ទាន់ និងពិសេស

៤- ចំណាយធ្វើដំណើរ និងប្រាក់បំណាច់បេសកកម្ម (មាត្រា ៦៤ អនុក្រឹត្យលេខ ៨២)

បេឡារបស់រដ្ឋទេយ្យករត្រូវបានបំពេញ ដោយគណនេយ្យករដែលនៅអម ។ «ត្រូវទុកអោយរដ្ឋទេយ្យករនីមួយៗនូវបុរេប្រទានដែលមានទឹកប្រាក់កំណត់ដោយប្រកាសដែលបានបង្កើតរដ្ឋទេយ្យ និងជាយថាហេតុ ប្រកាសនេះនឹងត្រូវពិនិត្យឡើងវិញក្រោមរូបភាពដូចគ្នា ។ លើកលែងតែបដិប្បញ្ញត្តិយល់ព្រមដោយរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចំនួនប្រាក់អតិបរិមានៃបុរេប្រទាននេះស្មើនឹង **មួយភាគប្រាំបី** នៃចំនួនទឹកប្រាក់គ្រោងចំណាយប្រចាំឆ្នាំ ដែលរដ្ឋទេយ្យករអាចទូទាត់បាន ។ បុរេប្រទានត្រូវបង់ដោយគណនេយ្យករសាធារណៈមុខការ ផ្អែកលើសំណើរបស់រដ្ឋទេយ្យករដែលមានចុះទិដ្ឋាការដោយអាណាប័ក» (មាត្រា ៦៥ អនុក្រឹត្យលេខ ៨២) ។

រដ្ឋទេយ្យករធ្វើប្រតិបត្តិការទូទាត់ចំណាយ ដែលប្រភេទនៃចំណាយនេះត្រូវកំណត់ដោយប្រកាសបង្កើតរដ្ឋទេយ្យ : «ក្នុងលក្ខខណ្ឌដូចគ្នានឹងគណនេយ្យសាធារណៈដែរ រដ្ឋទេយ្យករធ្វើប្រតិបត្តិការទូទាត់ចំណាយដោយបង្វែរ ឬ ដោយមូលប្បទានប័ត្រលើគណនីរបស់ខ្លួននៅរតនាគារ ឬមួយដោយសាច់ប្រាក់ក៏បាន» (មាត្រា ៦៦ អនុក្រឹត្យលេខ ៨២)។

រដ្ឋទេយ្យករអាចបើកប្រាក់ពីរតនាគារមួយភាគប្រាំបីម្ដង ដើម្បីចាយ ។ រដ្ឋទេយ្យករអាចទូទាត់ជាបណ្ដើរៗ ដើម្បីបំពេញឡើងវិញនូវទឹកប្រាក់ក្នុងរដ្ឋទេយ្យ ដោយរៀបចំអាណត្តិបើកប្រាក់ ដោយមានភ្ជាប់ជាមួយនូវលិខិតយុត្តិកានៃចំណាយ ។ បន្ទាប់ពីគណនេយ្យកររតនាគារអនុម័តលើអាណត្តិបើកប្រាក់ បុរេប្រទាននេះត្រូវបានបង្វែរទៅជាចំណាយ ហើយគណនេយ្យករអាចបំពេញទឹកប្រាក់នៃរដ្ឋទេយ្យ ដែលរដ្ឋទេយ្យករអាចបើកជាបុរេប្រទានយកមកចាយ ។

«រដ្ឋទេយ្យករប្រគល់លិខិតយុត្តិកាចំណាយដែលបានទូទាត់ដោយខ្លួនផ្ទាល់ជូនអាណាប័ក យ៉ាងយូរបំផុតក្នុងរយៈពេលមួយខែ ចាប់ពីកាលបរិច្ឆេទទូទាត់ចំណាយ ។ ចំពោះទឹកប្រាក់ចំណាយណា ដែលទទួលស្គាល់ថាត្រឹមត្រូវហើយ នោះអាណាប័កចេញអាណត្តិនិយ័តកម្មមួយ ដើម្បីជាគុណប្រយោជន៍ដល់រដ្ឋទេយ្យករ ។ ប្រាក់បុរេប្រទាន ត្រូវបានប្រមូលវិញដោយកត់ត្រាទឹកប្រាក់អាណត្តិនិយ័តកម្មនេះ ចុះខាងឥណទាននៃគណនីប្រាក់បញ្ញើរបស់រដ្ឋទេយ្យករ ក្នុងលេខនារបស់គណនេយ្យករមុខការ» (មាត្រា ៦៧ អនុក្រឹត្យលេខ ៨២) ។

**រដ្ឋទេយ្យចំណូល និងរដ្ឋទេយ្យបុរេប្រទាន**: រដ្ឋទេយ្យត្រូវគ្រប់គ្រង ចំណូលផ្សេង និងចំណាយផ្សេង ដោយមិនអោយកាត់កងគ្នាឡើយ ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ២.៣. ការមិនអនុវត្តផ្សេងៗទៀតនូវគោលការណ៍ធានាចំណាយជាមុន ការបង្វែរបញ្ជី និង ការចេញអាណត្តិបើកប្រាក់

### ២.៣.១. ការធានាចំណាយ: ការមិនអនុវត្តគោលការណ៍

«គ្មានចំណាយជាសាធារណៈណាមួយក្នុងថវិកាជាតិ ឬ ក្នុងគណនីពិសេសរបស់រតនាគារ (ឬក្នុងថវិកាឧបសម្ព័ន្ធ) អាចយល់ព្រម ឬ ទទួលឱ្យចាប់ផ្តើមអនុវត្តបានដោយអាណាប័កដើមខ្សែ ឬ ដោយអាណាប័កផ្ទេរសិទ្ធ បើគ្មានការស្នើសុំជាលាយលក្ខអក្សរ និងមានទិដ្ឋាការយល់ព្រម ពីមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុទេនោះ» (មាត្រា ៣ អនុក្រឹត្យលេខ ៨១) ។

ចំណាយជារជ្ជទេយ្យអាចចាត់ទុកថា ជាចំណាយដែលមិនបានអនុវត្តនូវគោលការណ៍ធានាចំណាយជាមុន។ ដូចគ្នានេះដែរ ការបញ្ជាដែលត្រូវបានធានាចំណាយ និង ចេញអាណត្តិក្នុងពេលជំណាលគ្នា (មានន័យថាការបញ្ជានេះ មិនមានការធានាចំណាយជាមុនទេ ហើយវិក្កយប័ត្រត្រូវបានទទួល) ។ អនុក្រឹត្យលេខ ៨១ បានចែងផងដែរពីការលើកលែងទិដ្ឋាការ ÷

«ត្រូវបានលើកលែងទិដ្ឋាការចំពោះ÷

ទីមួយ- ចំណាយដែលមានលក្ខណៈមិនទៀងទាត់ ដែលមានទឹកប្រាក់កំណត់ ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ ចាត់ទុកជាចំណាយមិនទៀងទាត់ គឺចំណាយមិនប្រក្រតី ហើយមិនអាចប្រមូលផ្ដុំទៅលើការងារផ្គត់ផ្គង់ ឬ សេវាកម្ម ។ ចំណាយទាំងនេះត្រូវបានកត់ត្រាទុកដោយមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុក្រោយពីបានចុះកិច្ចសន្យា ។

ទីពីរ- ចំណាយផ្តល់តាមបុរេប្រទាន ។

ទីបី- ចំណាយដែលទាក់ទងនឹងករណីដោយឡែក ដែលប៉ះពាល់ដល់វិស័យយោធា- សន្តិសុខជាតិ ហើយត្រូវរក្សាការសម្ងាត់» (មាត្រា ១១ អនុក្រឹត្យ ៨១) ។

«ចាប់ពីថ្ងៃទី ០១ ខែ ធ្នូ នៃឆ្នាំនីមួយៗ និងកម្រិត **មួយភាគដប់ពីរ** នៃឥណទានប្រចាំឆ្នាំកំពុងអនុវត្ត ការធានាចំណាយជាប្រក្រតីអាចធ្វើបាន ក្នុងករណីមានភាពប្រញាប់ដែលទាមទារអោយធ្វើការធានាចំណាយនៃឥណទាននៃឆ្នាំបន្ទាប់ ។ ការធានាចំណាយនេះមានន័យថា សេវាមិនអាចផ្គត់ផ្គង់មុនថ្ងៃទី ០១ មករា បានឡើយ» (មាត្រា ១១០ អនុក្រឹត្យលេខ ៨២) ។ ត្រង់ចំណុចនេះហើយ ដែលគោលការណ៍ថវិកាប្រចាំឆ្នាំ មិនត្រូវបានអនុវត្ត ។



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

### ការគ្រប់គ្រងតាមសភាពការណ៍ជាក់ស្តែង

ជាទូទៅ នៅក្នុងប្រទេសដែលអនុវត្តតាមនីតិហិរញ្ញវត្ថុសាធារណៈបារាំង ការគ្រប់គ្រងតាមសភាពការណ៍ជាក់ស្តែងត្រូវបានអនុវត្ត នៅពេលដែលបុគ្គលណាម្នាក់ដែលមិនមានលក្ខណៈសម្បត្តិជាគណនេយ្យករសាធារណៈ ឬ ដែលមិនស្ថិតក្រោមការគ្រប់គ្រង ឬ ក្នុងនាមអោយគណនេយ្យករសាធារណៈ ជ្រៀតជ្រែកចូលក្នុងការងារប្រមូលចំណូលចូលបេឡា ដែលជាការងាររបស់នីតិបុគ្គលនៃច្បាប់សាធារណៈ ដែលមានភារៈកិច្ចជាគណនេយ្យករ ឬ ដែលកាន់កាប់ប៉ុស្តិ៍គណនេយ្យ ។ បុគ្គលខាងលើត្រូវផ្តល់ព័ត៌មានដល់ **អាជ្ញាធរសវនកម្ម** ពីការប្រើប្រាស់មូលនិធិ និងមូលបត្រ ដែលខ្លួនបានកាន់កាប់ ឬ ប្រើប្រាស់ដោយមិនប្រក្រតី ។

ដូចគ្នាផងដែរ ចំពោះបុគ្គលដែលទទួល ឬ គ្រប់គ្រងដោយផ្ទាល់ ឬ ដោយប្រយោល នូវមូលនិធិ ឬ មូលបត្រដែលដកចេញដោយមិនប្រក្រតីពីបេឡារបស់នីតិបុគ្គលនៃនីតិសាធារណៈ និង ចំពោះបុគ្គលដែលមិនមានលក្ខណៈសម្បត្តិជាគណនេយ្យករសាធារណៈ ហើយអនុវត្តនូវប្រតិបត្តិការពាក់ព័ន្ធនឹងមូលនិធិ ឬ មូលបត្រ ដែលមិនមែនជារបស់នីតិបុគ្គលនៃនីតិសាធារណៈ ប៉ុន្តែជាភារៈកិច្ចផ្តាច់មុខរបស់គណនេយ្យករសាធារណៈដែល ត្រូវអនុវត្តតាមច្បាប់ជាធរមាន ។

ការគ្រប់គ្រងតាមសភាពការណ៍ជាក់ស្តែង ទាមទារអោយគណនេយ្យករតាមសភាពការណ៍ជាក់ស្តែង (Comptables de fait) ត្រូវមានកាតព្វកិច្ច និងការទទួលខុសត្រូវដូចគ្នានឹងក្នុងករណីការគ្រប់គ្រងជាក់ស្តែងដោយគណនេយ្យករសាធារណៈដែរ ។

តាមច្បាប់ព្រហ្មទណ្ឌ វាគឺជាការដណ្តើមយកមុខងារសាធារណៈ និងជាយថាហេតុ គឺជាការកេងបន្លំមូលនិធិសាធារណៈ និង ត្រូវទទួលការពិន័យច្បាប់ព្រហ្មទណ្ឌ ។

## ២.៣.២. ការជម្រះបញ្ជី: ការមិនអនុវត្តតាមគោលការណ៍

ការមិនអនុវត្តតាមគោលការណ៍ គឺនៅក្នុងករណីដែលមាន ការទូទាត់ជាមុនមុនពេលផ្គត់ផ្គង់ទំនិញ និង សេវា ឬ ការទូទាត់ជាដំណាក់កាល នៅក្នុងការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ (សូមអានផ្នែកលទ្ធកម្មសាធារណៈ) ។

## ២.៣.៣. ការចេញអាណត្តិបើកប្រាក់: ការមិនអនុវត្តតាមគោលការណ៍

ប្រទេសមួយចំនួនមិនអនុវត្តនូវនីតិវិធីចេញអាណត្តិបើកប្រាក់ នៅក្នុងករណីចំណាយលើសេវាបំណុល ចំណាយប្រាក់បៀវត្សរ៍ និង ប្រាក់សោធននិវត្តន៍ ។

ម៉្យាងវិញទៀត ចំណាយលើសោហ៊ុយធនាគារត្រូវបានកាត់ទុកដោយគ្មានការធានាចំណាយ និង ដោយមិនបានចេញអាណត្តិបើកប្រាក់ ។ ធនាគារត្រូវផ្តល់ព័ត៌មាននេះដល់អាណាប័ក ដើម្បីធ្វើ **និយ័តភាព** ។



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

### ២.៣.៤. ចំណូលទទួលបានផ្ទាល់ដៃ : ការមិនអនុវត្តតាមគោលការណ៍ជម្រះបញ្ជី និង ការទារចំណូល

ក្នុងករណីការទូទាត់ដោយឯកឯងពីសំណាក់អ្នកជាប់ពន្ធ គណនេយ្យករសាធារណៈចាប់ផ្ដើមប្រមូលសាច់ប្រាក់ចូលបេឡា ផ្ដល់ព័ត៌មានដល់អាណាប័ក ដែលនឹងចាត់នីតិវិធីក្នុងការធ្វើ **និយ័តភាព** (ការជម្រះបញ្ជី និង ការចេញដីកាចំណូល) ។

## ២.៤. ការគ្រប់គ្រងតាមសភាពការណ៍ជាក់ស្ដែង

ការគ្រប់គ្រងសភាពការណ៍តាមការជាក់ស្ដែង គឺជាការមិនអនុវត្តក្នុងពេលមួយដងមួយកាលនូវគោលការណ៍វិសមិត្តភាពជាស្ថាប័ន និងជាមុខងារ រវាងអាណាប័ក និង គណនេយ្យករ ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ជំពូកទី ២

# ការត្រួតពិនិត្យហិរញ្ញវត្ថុ

តួអង្គទីបីនៃការគ្រប់គ្រងចំណាយសាធារណៈ ដែលបានពិភាក្សារួចមកហើយនោះ គឺជា **ការត្រួតពិនិត្យហិរញ្ញវត្ថុ** ។ **អនុក្រឹត្យលេខ ៨១** អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ **ស្តីពី ការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើចំណាយថវិការដ្ឋ នៅតាមក្រសួង ខេត្ត-ក្រុង-ក្រុងស្វយ័ត-រាជធានីភ្នំពេញ និង អង្គការសាធារណៈរដ្ឋបាល** ចែងថា «...ការត្រួតពិនិត្យហិរញ្ញវត្ថុ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ» ។

«ការត្រួតពិនិត្យហិរញ្ញវត្ថុមានមុខងារសំខាន់ ក្នុងការត្រួតពិនិត្យជាមុន នូវសក្ខីប័ត្រចំណាយថវិកាជាតិ និង គណនីពិសេស ។ ម្យ៉ាងទៀត ការត្រួតពិនិត្យហិរញ្ញវត្ថុអាចជួយក្នុងការផ្ទៀងផ្ទាត់ពេលក្រោយ នៅនឹងកន្លែងលើការអនុវត្តចំណាយសាធារណៈ» (មាត្រា ១ អនុក្រឹត្យលេខ ៨១) ។

«ការត្រួតពិនិត្យហិរញ្ញវត្ថុ ត្រូវអនុវត្តដោយមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ដែលតែងតាំងដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅរដ្ឋបាលកណ្តាល និងអង្គភាពនានាក្នុងខេត្ត-ក្រុង ក្រុងស្វយ័ត-រាជធានីភ្នំពេញ និងនៅអង្គការសាធារណៈរដ្ឋបាល» (មាត្រា ២ អនុក្រឹត្យលេខ ៨១) ។

## ១. តួនាទីរបស់មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ

តួនាទីរបស់មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ គឺ ដើម្បីត្រួតពិនិត្យ និងចុះបញ្ជីកាគណនេយ្យ រាល់កិច្ចសន្យា និង អាណត្តិបើកប្រាក់ ផ្តល់ព័ត៌មានដល់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លើការគ្រប់គ្រងរដ្ឋបាល ដែលខ្លួនត្រួតពិនិត្យ និង ផ្តល់យោបល់ដល់អាណាប័កលើការគ្រប់គ្រងហិរញ្ញវត្ថុ និងបញ្ហានានាពាក់ព័ន្ធដល់ការសម្រេចចិត្ត ។

### ១.១. ការត្រួតពិនិត្យមុនចំណាយ

#### ១.១.១. និដ្ឋាការធានាចំណាយ

យើងបានឃើញរួចមកហើយនៅក្នុងផ្នែក **ធានាចំណាយ** ដែលបានចែងថា «គ្មានចំណាយសាធារណៈណាមួយក្នុងថវិកាជាតិ ឬ ក្នុងគណនីពិសេសរបស់រតនាគារ អាចយល់ព្រម ឬ ទទួលអោយចាប់ផ្តើមបានដោយ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

អាណាប័កដើមខ្សែ ឬ អាណាប័កផ្ទេរសិទ្ធ បើគ្មានការស្នើសុំជាលាយល័ក្ខអក្សរ និងមានទិដ្ឋាការយល់ព្រមពីមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុទេនោះ» (មាត្រា ៣ អនុក្រឹត្យលេខ ៨១) ។

«មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុពិនិត្យពីភាពត្រឹមត្រូវនៃការស្នើសុំចំណាយ ហើយការពិនិត្យនេះផ្អែកលើកត្តាដូចខាងក្រោមនេះ÷

- កម្មវត្ថុនៃចំណាយ
- បន្ទុកចំណាយនៃថវិកា ដែលត្រឹមត្រូវតាមបទបញ្ជាផ្សាយចេញពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រភេទនៃចំណាយស្របតាមការកំណត់នៃសៀវភៅថវិកា ដែលមានចែងជាឥណទានថវិកា
- ភាពត្រឹមត្រូវក្នុងការវាយតម្លៃនៃចំណាយ
- ភាពទំនេរនៃឥណទាន
- ការអនុវត្តត្រឹមត្រូវទៅតាមបទប្បញ្ញត្តិច្បាប់ហិរញ្ញវត្ថុ ព្រះរាជក្រឹត្យ ព្រះរាជក្រម និងបទបញ្ជាផ្សេងៗជាធរមាន
- ចំណាយត្រូវធ្វើអោយបានត្រឹមត្រូវទៅនឹងកិច្ចការរៀបចំថវិកា (មាត្រា ៤ អនុក្រឹត្យលេខ ៨១) ។

«មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុមានរយៈពេល ៤ ថ្ងៃធ្វើការដើម្បីរៀបចំយោបល់របស់ខ្លួន ។ ផុតរយៈពេលនេះ ចាត់ទុកថាមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុយល់ព្រមដោយស្វ័យប្រវត្តិ ហើយចំណាយត្រូវបានចាប់ផ្តើមអនុវត្ត» (មាត្រា ៧ អនុក្រឹត្យលេខ ៨១) ។

«ក៏ប៉ុន្តែ មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអាចសុំធ្វើការបំភ្លឺផ្តល់ព័ត៌មាន ឬ សេចក្តីបញ្ជាក់បន្ថែម បើយល់ថាជាការចាំបាច់ ។ ក្នុងករណីនេះ រយៈពេលកំណត់ខាងលើត្រូវផ្អាកជាបណ្តោះអាសន្ន រហូតដល់ពេលការផ្តល់

**ការគណនារយៈពេលកំណត់**

នៅពេលដែលរយៈពេលកំណត់ (Délai) ត្រូវបានគណនាជាពេលថ្ងៃធ្វើការ ថ្ងៃដែលជាចំណុចចាប់ផ្តើមពុំត្រូវបានរាប់បញ្ចូលឡើយ ។ ប្រសិនបើមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុបានទទួលសំណើសុំធានាចំណាយនៅថ្ងៃច័ន្ទ រយៈពេលកំណត់ត្រូវរាប់ចាប់ពីថ្ងៃអង្គារ៍ និងបញ្ចប់នាថ្ងៃសុក្រ ។ ដំណើរការប្រព្រឹត្តិទៅនៃសំណើសុំចំណាយ (តាមរយៈកិច្ចសន្យាព្រមព្រៀងដោយស្ងៀមស្ងាត់ (Accord tacite) នឹងប្រព្រឹត្តទៅ នៅថ្ងៃបន្ទាប់ពីចប់រយៈពេលកំណត់ ។ ថ្ងៃមិនធ្វើការ (សៅរ៍ អាទិត្យ ថ្ងៃបុណ្យ) មិនត្រូវបានរាប់បញ្ចូលទេ ។ ក្នុងឧទាហរណ៍ខាងលើ ដំណើរការប្រព្រឹត្តិទៅនៃសំណើសុំចំណាយ ចូលជាធរមានចាប់ពីថ្ងៃច័ន្ទ (អាទិត្យក្រោយ) ទៅ ។

ពេលដែលរយៈពេលកំណត់រាប់គ្រប់ថ្ងៃទាំងអស់ ដំណើរការប្រព្រឹត្តិទៅនៃសំណើសុំចំណាយ (តាមរយៈការព្រមព្រៀងដោយស្ងៀមស្ងាត់) ចាប់គិតពីថ្ងៃផុតកំណត់តែម្តង ។ ក្នុងករណីនេះ គឺ ថ្ងៃសុក្រ ។ រយៈពេលកំណត់ ត្រូវកំណត់ជាថ្ងៃប្រតិទិន (គ្រប់ថ្ងៃត្រូវរាប់បញ្ចូល) ឬជាថ្ងៃធ្វើការ (សៅរ៍ អាទិត្យ និងថ្ងៃបុណ្យ មិនត្រូវបានរាប់បញ្ចូលទេ) ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ឯកសារនានាបានទចប់សព្វគ្រប់ » (មាត្រា ៧ អនុក្រឹត្យលេខ ៨១) ។

«ក្នុងរយៈពេលនេះ គ្មានអន្តរាគមន៍ណាមួយដែលអាចរំលងទិដ្ឋាការរបស់មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុបានទេ ក្រៅពីសេចក្តីសំរេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ» មាត្រា ៨ អនុក្រឹត្យលេខ ៨១ ។

«ទិដ្ឋាការត្រូវបានផ្តល់ដោយផ្ទាល់ដោយរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ចំពោះចំណាយទាំងឡាយ ដែលមានទឹកប្រាក់លើសពីទឹកប្រាក់កំណត់ដោយអនុក្រឹត្យ» (មាត្រា ១០ អនុក្រឹត្យលេខ ៨១) ។

### ១.១.២. ទិដ្ឋាការលើអាណត្តិបើកប្រាក់ និងលើប្រកាសសិទ្ធិប្រទានឥណទាន

«អាណត្តិ និងប្រកាសសិទ្ធិប្រទានឥណទាន ត្រូវឆ្លងទិដ្ឋាការជាមុនពីអ្នកត្រួតពិនិត្យហិរញ្ញវត្ថុ» (មាត្រា ៥៥ អនុក្រឹត្យលេខ ៨២) ។

ទិដ្ឋាការនេះ អាចអោយមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុទទួលបានព័ត៌មានចាំបាច់ទាំងអស់ ដើម្បីគ្រប់គ្រងបញ្ជីគណនេយ្យ ការចេញអាណត្តិ ធៀបនឹងឥណទានដែលបានធានាចំណាយរួម និង អាចអោយចេញអាណត្តិដោយអនុលោមតាមការធានាចំណាយដែលនឹងត្រូវជម្រះ ទាំងស្រុង ឬ មួយផ្នែក ។ អនុក្រឹត្យលេខ ៨១ មិនបានចែងលម្អិតត្រង់ចំណុចនេះឡើយ ។

## ១.២. ការមិនអនុវត្តតាមគោលការណ៍

### ១.២.១. វិធានយុត្តិប្រទាន

យើងបានដឹងពីខាងលើរួចមកហើយ ក្នុងក្របខណ្ឌរដ្ឋទេយ្យ ដែលបានមិនបានអនុវត្តគោលការណ៍ **ធានាចំណាយជាមុន** (Engagement préalable) ។ ការមិនអនុវត្តផ្សេងៗទៀតតាមគោលការណ៍ មានការផ្តល់ **ការធានាចំណាយសរុប** (Engagement global) និង **ការធានាចំណាយបណ្តោះអាសន្ន** (Engagement prévisionnel) ។

#### ១.២.២.១. ការធានាចំណាយសរុប

«អាណាប័កដើមខ្សែ ឬ ផ្ទេរសិទ្ធិ អាចផ្តល់ **ការធានាចំណាយសរុប** ចំពោះចំណាយដែលមានលក្ខណៈដដែលៗ នៅដើមឆ្នាំថវិកា ឬ នៅពាក់កណ្តាលឆ្នាំថវិកា ។ ទិដ្ឋាការនៃការធានាចំណាយសរុប ដែលផ្តល់ដោយមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ គ្របដណ្តប់ទំហំទឹកប្រាក់សរុប និង គ្របដណ្តប់ចំណាយទាំងអស់នៃបន្ទាត់ថវិកាតែម្តង ហើយអាណាប័កមិនចាំបាច់ឆ្លងទិដ្ឋាការពីមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ដើម្បីទទួលបាននូវកាធានាចំណាយដាច់


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ដោយឡែក សម្រាប់ចំណាយមួយលើកៗឡើយ» (មាត្រា ១២ អនុក្រឹត្យលេខ ៨១) ។

«នីតិវិធីនៃការធានាចំណាយសរុប ត្រូវអនុវត្តជាអាទិ៍ចំពោះចំណាយដូចតទៅ ÷

- ចំណាយលើបៀវត្សរ៍ និងប្រាក់បំណាច់បន្ទាប់បន្សំ
- ចំណាយមានលក្ខណៈជាប្រក្រតី ហើយបានធានាចំណាយតាមការសម្រេចពីពេលមុនរួចមកហើយ ដ៏រាបណាពុំទាន់មានសេចក្តីសម្រេចថ្មីមកជំនួស
- ប្រាក់ឈ្នួល
- ប្រាក់ឧបត្ថម្ភ សំរាប់ដំណើរការអង្គការសាធារណៈរដ្ឋបាល
- ចំណាយសំរាប់សងបំណុលសាធារណៈ
- ការបងវិភាគទានអង្គការអន្តរជាតិ
- ចំណាយដែលត្រូវផ្តល់ក្នុងក្របខណ្ឌលទ្ធកម្មសាធារណៈ ឬ ក្នុងក្របខណ្ឌអោយខ្ចីមុន តាមការវាយតម្លៃសាច់ការដែលធ្វើបាន ហើយមានការយល់ព្រមពីគណៈកម្មការមានសមត្ថកិច្ច និង សាមីស្ថាប័នគ្រប់គ្រង (មាត្រា ១៣ អនុក្រឹត្យលេខ ៨១) ។

### ១.២.២.២. ការធានាចំណាយបណ្តោះអាសន្ន

«អាណាប័កដើមខ្សែ ឬ អាណាប័កផ្ទេរសិទ្ធិ អាចសុំចុះធានាចំណាយបណ្តោះអាសន្ន ចំពោះចំណាយ...÷

- ចំណាយលើសម្ភារៈ និង ការគ្រប់គ្រង
- ចំណាយលើការសងថ្លៃឈ្នួល
- ចំណាយអន្តរាគមន៍សាធារណៈក្នុងវិស័យសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌» (មាត្រា ១៥ អនុក្រឹត្យលេខ ៨១)

«ចំណាយបណ្តោះអាសន្នអនុញ្ញាតអោយអាណាប័កសុំតាមរយៈមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ក្នុងខ្ទង់ថវិកានីមួយៗ មួយចំណែកនៃឥណទាន កំណត់ដោយច្បាប់ហិរញ្ញវត្ថុ ជាគោលការណ៍ស្មើ **មួយភាគបួន** នៃថវិកាផ្តល់ប្រចាំឆ្នាំ ។ ចំនួននេះអាចបន្ថែម ឬ បន្ថយបានដោយរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទៅតាមប្រភេទចំណាយ និង ស្ថានភាពសាច់ប្រាក់របស់រដ្ឋ» (មាត្រា ១៦ អនុក្រឹត្យលេខ ៨១) ។ «សំណើតំបូង នៃធានាចំណាយបណ្តោះអាសន្ន មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុត្រូវតែផ្តល់ទិដ្ឋាការជូន ទោះបីជាអាណាប័កមិនបានភ្ជាប់មកជាមួយ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

នូវ **សក្ខីប័ត្រ** គ្រប់គ្រាន់ក៏ដោយ ។ សំណើបន្ទាប់នៃការធានាចំណាយបណ្តោះអាសន្ន ត្រូវភ្ជាប់មកជាមួយនូវសក្ខីប័ត្រនៃសំណើលើកមុន ហើយត្រូវបានចុះទិដ្ឋាការជូនត្រឹមចំនួនទឹកប្រាក់ដែលមានសក្ខីប័ត្រប៉ុណ្ណោះ» (មាត្រា ១៧ អនុក្រឹត្យលេខ ៨១) ។

## ១.៣. ការកែប្រែថវិកា

«សំណើសុំបង្វែរចំណាយ ផ្ទៃក្នុងនៃបន្ទាត់ថវិកា ឬ សំណើសុំផ្ទេរចេញពីជំពូកចំណាយមិនបានគ្រោងទុក ត្រូវតែមានចុះទិដ្ឋាការរបស់មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ មុនឆ្លងការពិនិត្យតាមដានការអនុវត្តថវិការបស់នាយកដ្ឋានជំនាញរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ» (មាត្រា ២៤ អនុក្រឹត្យលេខ ៨១) ។

## ១.៤. ការត្រួតពិនិត្យក្រោយចំណាយ

ការត្រួតពិនិត្យក្រោយចំណាយត្រូវបានចែង ក្នុងមាត្រាទី ១ និង មាត្រា ២២ នៃអនុក្រឹត្យលេខ ៨១ ដូចខាងក្រោមនេះ ÷

«ក្រោយពេលអនុវត្តចំណាយ មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ មាននីតិសម្បទាក្នុងការរកអោយឃើញ តាមគ្រប់រូបភាពស្របច្បាប់ ដែលយល់ថាចាំបាច់ នូវចំណាយថវិកាដែលបានធ្វើឡើងដោយមិនត្រឹមត្រូវៈ សេវាកម្ម ការរៀបចំគម្រោង ការទិញសម្ភារៈ ។ល។ ក្នុងន័យនេះ មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុមានសិទ្ធិចូលដោយគ្មានជូនដំណឹងជាមុន តាមបញ្ជាបេសកកម្មចេញអោយដោយរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ទៅកាន់ក្រសួង រដ្ឋលេខាធិការដ្ឋាន និងគ្រប់ខេត្ត-ក្រុង ក្រុងស្វយ័ត ព្រមទាំងអង្គភាពរដ្ឋបាលសាធារណៈនានា ដែលមានភារៈកិច្ចរាយការណ៍លម្អិតនៃការអនុវត្តចំណាយ ។

មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុត្រូវធ្វើរបាយការណ៍ផ្ញើជូនរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អំពីលក្ខណៈចំណាយដែលបានអនុវត្តរួចហើយ ។ ការខុសឆ្គងដែលមានក្នុងការអនុវត្ត និងភាពខុសគ្នាដែលបានស្រង់ចេញពីបញ្ជីកាគណនេយ្យ ជាសមត្ថកិច្ចដោះស្រាយរបស់រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងសំណើដាក់វិន័យដោយអនុលោមតាម **ច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា** ក្រោយទទួលបានយោបល់សម្រេចពីគណៈរដ្ឋមន្ត្រី ការអនុវត្តវិន័យខាងរដ្ឋបាល ឬ ប្តឹងទៅតុលាការ ត្រូវធ្វើទៅតាមករណីហេតុ» (មាត្រា ២២ អនុក្រឹត្យ ៨១)។

## ១.៥. គណនេយ្យចំណាយដែលបានធានាចំណាយ

«មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុត្រូវរួមចំណែកធានា ជាមួយផ្នែកទទួលបន្ទុកចំណាយនៃអាណាប័កដើមខ្សែ


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

និងអាណាប័កផ្ទេរសិទ្ធិ អំពីការខុសគ្នាក្នុងការចុះបញ្ជីគណនេយ្យ ការធានាចំណាយ និងតាមដានការប្រើប្រាស់ឥណទាន ។ របាយការណ៍ត្រូវធ្វើជារៀងរាល់ខែ ដើម្បីផ្ទៀងផ្ទាត់អំពីការធានាចំណាយ និងការបើកប្រាក់របស់អាណាប័ក ប្រៀបធៀបជាមួយបញ្ជីអនុវត្តចំណាយរបស់រតនាគារ» (មាត្រា ២១ អនុក្រឹត្យលេខ ៨១) ។

«សំណើចុះធានាចំណាយ ឬ លុបចោលធានាចំណាយ ត្រូវឆ្លងកាត់មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ដោយមានភ្ជាប់មកជាមួយនូវលិខិតបញ្ជាក់ និងលិខិតយោងចាំបាច់» (មាត្រា ១៩ អនុក្រឹត្យលេខ ៨១) ។

## ១.៦. តួនាទីផ្តល់យោបល់ដល់រដ្ឋមន្ត្រី

«មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ចាំបាច់ត្រូវចូលរួមយោបល់ ផ្នែកហិរញ្ញវត្ថុ លើសេចក្តីព្រាងច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស កិច្ចសន្យា ឬសេចក្តីសម្រេចដែលមានលក្ខណៈជាបទបញ្ជា និងមានផលប៉ះពាល់ដល់វិស័យហិរញ្ញវត្ថុ» (មាត្រា ១៩ អនុក្រឹត្យលេខ ៨១) ។

«មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ចូលរួមរាល់កិច្ចការរៀបចំថវិកា និងកសាងច្បាប់ស្តីពីហិរញ្ញវត្ថុ និងប្រព័ន្ធហិរញ្ញវត្ថុ» (មាត្រា ២៣ អនុក្រឹត្យលេខ ៨១) ។

«រៀងរាល់ឆ្នាំ មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុត្រូវធ្វើរបាយការណ៍សរុប អំពីការអនុវត្តថវិកាឆ្នាំកន្លងទៅ ដោយមានបញ្ជាក់អំពីលទ្ធផលនៃការត្រួតពិនិត្យ និងលើកសំណូមពរកែលម្អការអនុវត្តថវិកានៃឆ្នាំបន្ត ។ របាយការណ៍នេះត្រូវផ្ញើជូនរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅថ្ងៃទី ៣១ ខែ មីនា ឆ្នាំបន្ទាប់នៃឆ្នាំត្រួតពិនិត្យ» (មាត្រា ២៩ អនុក្រឹត្យលេខ ៨១) ។

## ១.៧. តួនាទីផ្តល់យោបល់ដល់អាណាប័កដែលត្រួតពិនិត្យ

មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុដែលមានចម្ងល់លើការគ្រប់គ្រងប្រចាំថ្ងៃរបស់អាណាប័ក នៅក្នុងក្រសួង ស្ថាប័នដែលខ្លួនគ្រប់គ្រង អាចស្នើសុំការបំភ្លឺលើការជ្រើសរើស និងការសម្រេចចិត្ត ដែលមានលក្ខណៈជាច្បាប់ និងបទបញ្ជាផ្នែកហិរញ្ញវត្ថុ ឬ ជាទូទៅ ។ ក្នុងន័យនេះ មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុត្រូវមានចំណេះដឹងយ៉ាងច្បាស់ជាពិសេសសំរាប់អ្វីដែលពាក់ព័ន្ធដល់ការទទួលខុសត្រូវរបស់ខ្លួន ។


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

# ជំពូកទី ៣

# ប្រតិបត្តិការរតនាគារ

## ១. រតនាគារ

**ប្រវត្តិរតនាគារ**

កាលពីយូរលង់មកហើយ រតនាគារជាប្រអប់ ឬ បន្ទប់ សំរាប់ប្រមូលប្រាក់ (pièces) ឬ លោហធាតុមានតម្លៃ (គេត្រូវការសត្វ ២៣.០០០ ក្បាល ដើម្បីដឹកជញ្ជូនមួយផ្នែកនៃទ្រព្យទាំងនេះពីដែលប្រមូលយកជាជ័យភ័ណ្ឌនៅ **ដារីយូស-៣** អោយទៅដល់ **អាឡិចសង់ដ្រ៍**) ។

នៅយុគសម័យកណ្ដាល ស្ដេចប្រទេសបារាំងបានប្រគល់ភារកិច្ចគ្រប់គ្រងរតនាគារទៅអោយពួក Templiers (ដែលជាមេបញ្ជាការសាសនា និង ទ័ព) ដែលដើរតួនាទី ជា **រតនាគារ** ។

បន្ទាប់ពីនោះមក គេយកឃ្លាំងស្ដេចធ្វើជា **រតនាគារ** មុននឹងបញ្ជូនជាចុងក្រោយទៅ **ធនាគារប្រទេសបារាំង** ។

នៅព្រះរាជាណាចក្រកម្ពុជា «ប្រាក់ទំនេររបស់គណនេយ្យករសាធារណៈនៃរតនាគារ ត្រូវរក្សាទុកក្រោមរូបភាពជា៖ សាច់ប្រាក់ក្នុងបេឡា ឬ សាច់ប្រាក់ក្នុងគណនីទោលនៃរតនាគារ ដែលបើកនៅធនាគារជាតិនៃកម្ពុជា» (មាត្រា ៧៤ អនុក្រឹត្យ ៨២) ។

«អង្គការសាធារណៈ ត្រូវដាក់ផ្ញើទុកមូលនិធិរបស់ខ្លួននៅរតនាគារ លើកលែងតែមានការអនុញ្ញាតពីរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ» (មាត្រា ៧១ អនុក្រឹត្យ ៨២) ។

«ធនាគារជាតិនៃកម្ពុជា ជាអ្នកទទួលរក្សាទុកផ្ដាច់មុខនូវមូលនិធិទាំងឡាយដែលកាន់កាប់ដោយគណនេយ្យករផ្ទាល់របស់រតនាគារ» (មាត្រា ៧៨ អនុក្រឹត្យ ៨២) ។

«មានតែគណនេយ្យករសាធារណៈទេ ដែលមាននីតិសម្បទាចាត់ចែងមូលនិធិរតនាគារ» (មាត្រា ៧២ អនុក្រឹត្យ ៨២) ។

«អាណាប័ក និងភ្នាក់ងាររដ្ឋផ្សេង ដែលគ្មានលក្ខណៈសម្បត្តិជាគណនេយ្យករសាធារណៈ មិនអាចបើកគណនីក្នុងធនាគារ ឬ គ្រឹះស្ថានឥណទានសាធារណៈ ឬ ឯកជនបានឡើយ ។ ក៏ប៉ុន្តែ អ្នកទទួលខុសត្រូវអង្គភាពគ្រប់គ្រងគម្រោង ដែលហិរញ្ញប្បទានដោយជំនួយក្រៅប្រទេស អាចបើកគណនីនៅធនាគារបានសម្រាប់តម្រូវការរបស់គម្រោង ក្នុងករណីណាដែលកិច្ចព្រមព្រៀងបានចុះហត្ថលេខាជាមួយអ្នកផ្ដល់មូលនិធិ ។ ការបើកគណនី


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

**គោលការណ៍នៃការមិនកាត់កងគ្នា**

បុគ្គលម្នាក់បានយកវិក្កយប័ត្រទៅគណនេយ្យករសាធារណៈ ដើម្បីបើកប្រាក់សម្រាប់ទូទាត់សេវា ដែលបានផ្គត់ផ្គង់រួច ។ ឧទាហរណ៍ សេវានេះថ្លៃ ១០.០០០ ដុល្លារ ហើយបុគ្គលនេះជំពាក់ពន្ធ ២.០០០ ដុល្លារ ។ កំណត់ត្រាគណនេយ្យត្រូវរំលេចអោយឃើញនូវការទូទាត់ចំនួន ១០.០០០ ដុល្លារ និង ការបង់ពន្ធចំនួន ២.០០០ ដុល្លារ ។ ប្រសិនបើបុគ្គលនោះកាត់កងរវាង ១០.០០០ និង ២.០០០ ដោយបង់ប្រាក់ជាក់ស្តែងតែ ៨.០០០ ដុល្លារ គឺជាការមិនត្រឹមត្រូវឡើយ ។

ទាំងនេះត្រូវឆ្លងកាត់ការអនុញ្ញាតជាមុនពីរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ» (មាត្រា ៧៣ អនុក្រឹត្យ ៨២) ។

ការបើកគណនីឯកជន និងការចាត់ចែងមូលនិធិ តាមរយៈនិក្ខិត្តករនៃគណនីទាំងនេះ (ឬការចាត់ចែងសាច់ប្រាក់) គឺជាការគ្រប់គ្រងតាមសភាពការណ៍ជាក់ស្តែង ដែលបានរៀបរាប់ខាងដើម ។

«គណនេយ្យករសាធារណៈរបស់រដ្ឋ មិនអាចបើកគណនីនៅធនាគារ ឬ គ្រឹះស្ថានឥណទាន ដែលមានលក្ខណៈឯកជនបានទេ វៀរលែងតែមានការយល់ព្រមពីរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ» (មាត្រា ៧៧ អនុក្រឹត្យ ៨២) ។

## ២. ប្រតិបត្តិការរតនាគារ

«**ប្រតិបត្តិការរតនាគារ** គឺជារាល់ចលនាសាច់ប្រាក់ មូលប័ត្រ គណនីនិក្ខិត្តភ័ណ្ឌ និងគណនីចរន្ត ហើយនិងប្រតិបត្តិការទាំងឡាយពាក់ព័ន្ធនឹងគណនីឥណទេយ្យ និងបំណុលរយៈពេលខ្លី» (មាត្រា ៦៨ អនុក្រឹត្យ ៨២) ។

«**ប្រតិបត្តិការរតនាគារ** ត្រូវបានពិពណ៌នាតាមប្រភេទទាំងស្រុង ដោយគ្មានការបំព្រួញឡើយ» (មាត្រា ៦៨ អនុក្រឹត្យ ៨២) ។

«បន្ទុក (ចំណាយ) និង ផល (ចំណូល) ដែលបណ្តាលមកពីការអនុវត្តប្រតិបត្តិការរតនាគារត្រូវបានកំណត់ក្នុងគណនីថវិកា» (មាត្រា ៦៩ អនុក្រឹត្យ ៨២) ។

«ក្រៅពីចលនាសាច់ប្រាក់ដែលចាំបាច់សម្រាប់ផ្គត់ផ្គង់ ឬ ការដកចេញពីបេឡារបស់គណនេយ្យករ

**បន្ទុក និង ផលនៃរតនាគារ**

រតនាគារអាចមានបន្ទុក (ចំណាយ) ដូចជា ការប្រាក់កម្ចី និង សោហ៊ុយលើការបោះផ្សាយ ឬ សោហ៊ុយធនាគារចំពោះមូលប្បទានប័ត្ររបស់អ្នកជាប់ពន្ធដែលគ្មានប្រាក់ ឬ លាភការរបស់និក្ខិត្តករ ។ រតនាគារអាចមាន ផល (ចំណូល) ដូចជា ផល លើប្រាក់បញ្ញើ ។ ចំណូល និងចំណាយទាំងនេះ ជាកម្មវត្ថុនៃការកែតម្រូវថវិកាលើគណនីពាក់ព័ន្ធ ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

រាល់ការទូទាត់ រវាងគណនេយ្យករសាធារណៈ ត្រូវធ្វើឡើងដោយការបង្វែរគណនី» (មាត្រា ៨០ អនុក្រឹត្យ ៨២) ។

### ៣. និក្ខិត្តករតេនាគារ

«ដោយអនុលោមតាមច្បាប់ និងបទបញ្ញាទាំងឡាយ ឬ ដោយអំណាចនៃអនុសញ្ញា **និក្ខិត្តករតេនាគារ** (Correspondants du Trésor) ជាអង្គការ និងឯកជននានា ដែលផ្ញើរទុកមូលនិធិនៅរតនាគារក្នុងនាមជាកាតព្វកិច្ច ឬ ដោយស្ម័គ្រចិត្ត ឬ ដែលត្រូវបានអនុញ្ញាតអោយធ្វើប្រតិបត្តិការចំណូល និងចំណាយតាមរយៈគណនេយ្យកររបស់រតនាគារ ។ វៀរលែងតែមានបានការអនុញ្ញាតពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ **និក្ខិត្តករ** ម្នាក់អាចបើកគណនីតែមួយគត់នៅរតនាគារ...» (មាត្រា ៨១ អនុក្រឹត្យ ៨២) ។

«គណនេយ្យករសាធារណៈនៃរតនាគារអាចទទួលបាននីតិសម្បទា ពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងការរ៉ាប់រងផ្នែកទទួលបន្ទុកមូលនិធិឯកជន» (មាត្រា ៨៣ អនុក្រឹត្យ ៨២) ។

«គណនីដែលបើកនៅរតនាគារក្នុងនាម **និក្ខិត្តករ** មិនត្រូវមាន **ឧបារូន៍** (découvert)(អាចដក ឬ ចាយប្រាក់លើសទឹកប្រាក់ដែលមាន)» (មាត្រា៨៤ អនុក្រឹត្យ ៨២)។

**ប្រាក់បញ្ញើតតិយជន**

នៅប្រទេសបារាំង ប្រាក់តំកល់មូលនិធិឯកជន (ប្រាក់បញ្ញើតតិយជន) ត្រូវបានបញ្ចប់ នៅចុងឆ្នាំ ២០០១ កន្លងនៅនេះ ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ជំពូកទី ៤

# ការទទួលខុសត្រូវរបស់តួអង្គផ្សេងៗ

## (អាណាប័ក មន្ត្រីត្រួតពិនិត្យ គណនេយ្យករ និង តួអង្គផ្សេងទៀត)

យើងបានពិភាក្សារួចមកហើយពីការទទួលខុសត្រូវរបស់អាណាប័ក និង បន្ទាប់មក ការទទួលខុសត្រូវរបស់មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ និង ជាចុងក្រោយ ការទទួលខុសត្រូវរបស់គណនេយ្យករ ។ យើងនឹងពិនិត្យជាបន្តលើការទទួលខុសត្រូវរបស់តួអង្គផ្សេងៗទៀត ដូចជា **សវនករផ្ទៃក្នុង** និង **សវនករផ្ទៃក្រៅ អធិការហិរញ្ញវត្ថុ** និង ភ្នាក់ងាររដ្ឋ និង ស្ថាប័ននានា ។

### ១. ការទទួលខុសត្រូវរបស់អាណាប័ក

យើងត្រូវបែងចែកអោយបានច្បាស់ នូវការទទួលខុសត្រូវរបស់សមាជិករាជរដ្ឋាភិបាល ពីអាណាប័កផ្សេងៗទៀត ។

### ១.១. ការទទួលខុសត្រូវរបស់រដ្ឋមន្ត្រី

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបានចែងថា ÷ «...រាល់សមាជិករបស់រាជរដ្ឋាភិបាលត្រូវទទួលខុសត្រូវជាថេរៗពីគ្នា នៅចំពោះមុខនាយករដ្ឋមន្ត្រី និងរដ្ឋសភា ចំពោះទង្វើដែលខ្លួនបានប្រព្រឹត្ត» (មាត្រា ១២៧ ថ្មី)។

«រាល់សមាជិករបស់រាជរដ្ឋាភិបាល ត្រូវទទួលការដាក់ទណ្ឌកម្មចំពោះឧក្រិដ្ឋកម្ម ឬ បទល្មើសដែលបានប្រព្រឹត្ត នៅក្នុងការអនុវត្តមុខងាររបស់ខ្លួន ។ ក្នុងករណីកំហុសធ្ងន់ធ្ងរ ប្រព្រឹត្តដោយសមាជិកណាម្នាក់នៃរាជរដ្ឋាភិបាល រដ្ឋសភាជាតិអាចធ្វើការប្តឹងទៅតុលាការមានសមត្ថកិច្ច ។ សភាចេញសេចក្តីសម្រេចនេះតាមរយៈការបោះឆ្នោតសម្ងាត់ភាគច្រើនពីសមាជិកទាំងឡាយ» (មាត្រា ១២៦ ថ្មី) ។

### ១.២. ការទទួលខុសត្រូវរបស់អាណាប័កផ្សេងៗទៀត

«ដោយមូលហេតុណាមួយក្នុងការអនុវត្តមុខការរបស់ខ្លួន អាណាប័កត្រូវទទួលការខុសត្រូវ ដូចបានចែងក្នុងច្បាប់ជាធរមាន ។ ការទទួលខុសត្រូវនេះ អាចដាក់ជាវិន័យព្រហ្មទណ្ឌ ឬ រដ្ឋប្បវេណី» (មាត្រា ១១ អនុក្រឹត្យ ៨២) ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ២ ការទទួលខុសត្រូវរបស់អ្នកត្រួតពិនិត្យហិរញ្ញវត្ថុ

ច្បាប់ពុំបានចែងជាបទប្បញ្ញត្តិពិសេសឡើយ ។ ក្នុងន័យនេះ ច្បាប់ទូទៅត្រូវបានយកមកអនុវត្ត ។

## ៣ ការទទួលខុសត្រូវរបស់គណនេយ្យករ (និងរដ្ឋនេយ្យករ)

«ក្នុងលក្ខខណ្ឌកំណត់ដោយច្បាប់ជាធរមាន គណនេយ្យករសាធារណៈទទួលខុសត្រូវ **ផ្ទាល់ខ្លួន** និង **ជាប្រាក់កាស** ពីកិច្ចប្រតិបត្តិដែលខ្លួនទទួលបន្ទុក...» (មាត្រា ១៦ អនុក្រឹត្យ ៨២) ។

«រដ្ឋទេយ្យករទទួលខុសត្រូវ **ផ្ទាល់ខ្លួន** និង **ជាប្រាក់កាស** នូវការរក្សាការពារមូលនិធិ ដែលខ្លួនទទួលបាន ឬ មូលនិធិទាំងឡាយណាដែលត្រូវបានបុរេប្រទានពីគណនេយ្យករមុខការ រក្សាទុកដាក់លិខិតយុត្តិការ ព្រមទាំងកាន់កាប់គណនេយ្យប្រតិបត្តិការទៀតផង» (មាត្រា ២៥ អនុក្រឹត្យ ៨២) ។

## ៤ ការទទួលខុសត្រូវរបស់តួអង្គផ្សេងៗទៀត

ការទទួលខុសត្រូវតួអង្គផ្សេងៗទៀត ដូចជាសវនករជាតិ សវនករតាមក្រសួង អធិការហិរញ្ញវត្ថុ អធិការតាមក្រសួង អ្នកទទួលខុសត្រូវលើកិច្ចលទ្ធកម្ម ។ល។ មិនមានលក្ខណៈខ្លាំងក្លា (ទទួលខុសត្រូវ ផ្ទាល់ខ្លួន និងជាប្រាក់កាស) ដូចតួអង្គសាធារណៈផ្សេងទៀតឡើយ ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ជំពូកទី ៥

# គណនេយ្យសាធារណៈ

តួអង្គក្នុងបណ្តាញចំណាយសាធារណៈ ទាំងអាណាប័ក មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ និង គណនេយ្យករ (និងរជ្ជទេយ្យករ) ត្រូវកាន់បញ្ជីគណនេយ្យសំរាប់ប្រតិបត្តិការរបស់ពួកគេ ។

- គណនេយ្យរដ្ឋបាលរបស់អាណាប័ក
- គណនេយ្យធានាចំណាយ (Comptabilité des engagements) និង គណនេយ្យចេញអាណត្តិរបស់មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ
- គណនេយ្យរដ្ឋ សម្រាប់គណនេយ្យករ និងរជ្ជទេយ្យករ

## ១. គណនេយ្យរដ្ឋបាលអាណាប័ក

***គណនេយ្យអាណាប័ក ឬ គណនេយ្យរដ្ឋបាល***

ជាបឋម អាណាប័កត្រូវការដឹងពីស្ថានភាពឥណទានរបស់ខ្លួន ដើម្បីប្រើប្រាស់អោយបានត្រឹមត្រូវ ។ នេះជាកម្មវត្ថុនៃគណនេយ្យធានាចំណាយ ដែលកាន់កាប់ក្នុងរបៀបផ្ទុយគ្នារវាងអាណាប័ក និង មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ។

អាណាប័កត្រូវដឹងផងដែរពីអាណត្តិ ដែលបានបញ្ជូនទៅគណនេយ្យករចាត់ចែង និងទូទាត់ ។ តារាងប្រតិបត្តិការហិរញ្ញវត្ថុសាធារណៈ (TOFE) ត្រូវបានរៀបចំផ្អែកលើអាណត្តិ (បោះចេញ អនុម័តដោយអាណាប័ក ឬ ចាត់ចែង និងអនុម័តដោយគណនេយ្យករ ។ ទឹកប្រាក់ត្រូវតែស្មើគ្នាចំពោះគណនេយ្យទាំងពីរនេះ) ។

លំអៀងត្រូវបញ្ចូលទៅក្នុង «ចំណាយបានធានាដែលមិនបានចេញអាណត្តិ (DENO)» ។

លំអៀងរវាងការចេញអាណត្តិ និង ការទូទាត់ មានឈ្មោះថា **ទឹកប្រាក់ត្រូវទូទាត់** (Reste à payer - RAP) ។ RAP ចាប់ពី ៣ ខែឡើងទៅ បង្កើតបានជា «**បំណុលជំពាក់**» តាមអត្ថន័យរបស់អង្គការរូបិយវត្ថុអន្តរជាតិ ។

លំអៀងរវាងដីកាចំណូល និងចំណូលប្រមូលបាន មានឈ្មោះថា «**ទឹកប្រាក់ត្រូវប្រមូល** (Reste à recouvrer – RAR)» ។ ផលបូកនៃ RAP និង RAR មានឈ្មោះថា «**ទឹកប្រាក់ត្រូវអនុវត្ត** (Reste à réaliser)» ។

ក្នុងប្រព័ន្ធ (ត្រូវបានរៀបចំអោយដំណើរការដោយស្វ័យប្រវត្តិ) នៃការគ្រប់គ្រងរួមនៃហិរញ្ញវត្ថុសាធារណៈ តួអង្គនីមួយៗ (អាណាប័ក មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ គណនេយ្យករ) អាចដឹងនៅគ្រប់ខណៈ ពីស្ថានភាពនៃចំណាយជាក់លាក់ណាមួយ និងស្ថានភាពឥណទានរួម និង លម្អិត ។



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

## ២. គណនេយ្យរបស់មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ

គណនេយ្យរបស់មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ត្រូវបានលើកយកមកពិភាក្សាលម្អិតនៅក្នុងជំពូកការត្រួតពិនិត្យហិរញ្ញវត្ថុ ។

## ៣. គណនេយ្យរដ្ឋទេយ្យ

«រដ្ឋទេយ្យករមានកាតព្វកិច្ចកាន់គណនេយ្យ ដែលទម្រង់គណនេយ្យនេះត្រូវបានកំណត់ ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ឬ ដោយមានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។ គណនេយ្យនេះ ត្រូវបង្ហាញអោយឃើញគ្រប់ពេលនូវ÷

- ស្ថានភាពប្រាក់ក្នុងបេឡា ចំពោះរដ្ឋទេយ្យចំណូល
- ស្ថានភាពបុរេប្រទានបានទទួល ចំពោះរដ្ឋទេយ្យបុរេប្រទាន» (មាត្រា ១០១ អនុក្រឹត្យ ៨២) ។

## ៤. គណនេយ្យរបស់រដ្ឋ

«គណនេយ្យទូទៅរបស់រដ្ឋបង្ហាញ ÷

- ប្រតិបត្តិការថវិកា
- ប្រតិបត្តិការរតនាគារ
- ប្រតិបត្តិការ ធ្វើជាមួយតតិយជន

គណនេយ្យទូទៅ បញ្ចេញអោយឃើញនូវលទ្ធផលនាដំណាច់ឆ្នាំ ។ គណនេយ្យទូទៅ ត្រូវបានកាន់កាប់តាមវិធីទ្វេភាគ» (មាត្រា ៩៨ អនុក្រឹត្យ ៨២) ។

«គណនេយ្យរបស់រដ្ឋ ត្រូវបានកាន់អនុលោមតាមប្លង់គណនេយ្យមួយ ដែលកំណត់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។ មាតិកាគណនី ដែលបើកក្នុងគណនេយ្យទូទៅកំណត់បែបបទនៃការប្រព្រឹត្តទៅនៃគណនីទាំងឡាយ ។ មាតិកាគណនីនេះ ត្រូវរៀបចំឡើងតាមលំនាំប្លង់គណនេយ្យទូទៅ» (មាត្រា ៩៩ អនុក្រឹត្យ ៨២) ។

«គណនេយ្យទូទៅរបស់រដ្ឋត្រូវបានកាន់ដោយគណនេយ្យករផ្ទាល់របស់រតនាគារ និងដោយគណនេយ្យករនៃរដ្ឋបាលហិរញ្ញវត្ថុ ។...គណនេយ្យនេះត្រូវប្រមូលផ្តុំដោយគណនេយ្យករកណ្តាលនៃរតនាគារ...» (មាត្រា ១០០



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ***មាតិកាថវិកាថ្មី និងគណនេយ្យតាមលក្ខណៈសេដ្ឋកិច្ចរបស់រដ្ឋ សំរាប់ឆ្នាំ ២០០៧***

**(មាតិកាសេដ្ឋកិច្ច)**

ក្នុងក្របខ័ណ្ឌនៃកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានដាក់អោយអនុវត្តក្នុងឆ្នាំ ២០០៧ នូវ **មាតិកាថវិកាថ្មី** ដើម្បីអោយមានសង្គតិភាពជាមួយ **ប្លង់គណនេយ្យថ្មី** ដែលឈរលើមូលដ្ឋាននៃ **គណនេយ្យបង្គរ** ។

**មាតិកាថវិការហូតដល់ឆ្នាំ ២០០៦** :

ថវិកាត្រូវបែងចែកជាជំពូក (ពីរខ្ទង់) មាត្រា (បីខ្ទង់) និងកថាខ័ណ្ឌ (ប្រាំខ្ទង់) ។

ឧទាហរណ៍ ជំពូក ១៣ ពាក់ព័ន្ធនឹង **កម្មវិធីសកម្មភាពអាទិភាព** (PAP) ដែលគោរពតាមនីតិវិធីចំណាយដាច់ដោយឡែក : ការបើកផ្តល់ជាលក្ខណៈបុរេប្រទាន ហើយការទូទាត់ដោយចេញអាណត្តិ តែមិនមានភ្ជាប់លិខិតយុត្តិការ ។

**មាតិកាថវិកា និងគណនេយ្យថ្មី** :

ចំណាត់ថ្នាក់ដូចគ្នាទាំងកម្រិតថវិកា និងគណនេយ្យ ។ មាតិស្រដៀងគ្នាបំផុតទៅនឹងគណនេយ្យផ្នែកឯកជន តែឆ្លុះបញ្ចាំងលក្ខណៈពិសេសរបស់រដ្ឋ ។ មាតិកានេះមានលក្ខណៈលំអិតជាងមាតិកាចាស់ (ដែលទាមទារការវិភាជន៍ថវិកា កិច្ចបញ្ជីកាថវិកា និង គណនេយ្យច្រើនជាងមុន) ។

គណនីបែងចែកតាម «**ថ្នាក់**» ដែលដូចគ្នានឹងគណនេយ្យឯកជនដែរ ÷

ថ្នាក់លេខ ១: **មូលធន**

ថ្នាក់លេខ ២: **អចលនទ្រព្យ**

. . .

ថ្នាក់លេខ ៦: **បន្ទុក**

ថ្នាក់លេខ ៧: **ផល**

. . .

(អ្វីដែលបានបង្ហាញខាងលើជា **ថ្នាក់** ដែលប្រើប្រាស់ទូទៅ ទាំងក្នុងថវិកា និងទាំងក្នុងគណនេយ្យ) ។

**ថ្នាក់** ត្រូវបានបែងចែកជាបន្តជា **គណនី** (៣ ខ្ទង់) និង **អនុគណនី** (៤ ខ្ទង់) ។ **អនុគណនី** អាចបែងចែកតទៅទៀតតាមតម្រូវការប្រើប្រាស់ ។ ឧទាហរណ៍

ជំពូក ៦០ : **ការទិញ**

គណនី ៦០១ **ការទិញសំភារៈផ្គត់ផ្គង់**

អនុគណនី ៦០១១ **ផលិតផលលាងសំអាត និង អនាម័យ**

អនុគណនី ៦០១២ **សំភារៈសំរាប់ថែទាំអាគារ**

អនុគណនី ៦០១៣ **សំភារៈសំរាប់ថែទាំផ្លូវ**

អនុគណនី ៦០១៤ **សំភារៈសំរាប់ថែទាំ ឧបករណ៍ផ្សេងៗ**

អនុគណនី ៦០១៥ **ប្រេងឥន្ធនៈ**

គណនីថវិកា និង គណនីនៃគណនេយ្យសាធារណៈមានលក្ខណៈដូចគ្នាបេះបិទ ។ **លក្ខណៈសេដ្ឋកិច្ច** ចំណាយ និង ចំណូលត្រូវកំណត់ចាប់តាំងពីការរៀបចំថវិកា អនុលោមតាមមាតិកាទូទៅសំរាប់អាណាប័ក និងគណនេយ្យករ ។

អនុក្រឹត្យ ៨២) ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

**មាតិកាចំណាត់ថ្នាក់ និង គណនេយ្យផ្សេងៗទៀត**

**មាតិកាចំណាត់ថ្នាក់តាមសេវា: ចំណាយថ្នាក់រដ្ឋបាល ឬ ចំណាត់ថ្នាក់មុខងារនៃចំណាយសាធារណៈ:**

ការរៀបចំស្ថាប័នរដ្ឋត្រូវបែងចែកជាស្ថាប័ន ក្រសួង រដ្ឋបាលសាធារណៈឯករាជ្យ គ្រឹះស្ថានសាធារណៈ សហគ្រាសរដ្ឋ និង សហគ្រាសចម្រុះ និងអាជ្ញាធរដែនដី ដែលបង្កើតជារចនាសម្ព័ន្ធគ្រប់គ្រង និង/ឬ **ទិសដៅ** នៃឥណទានថវិកា ។ រចនាសម្ព័ន្ធទាំងនេះបាន កំណត់អត្តសញ្ញាណនៅក្នុង «**បញ្ជីស្ថាប័នសាធារណៈ**» ។ ស្ថាប័នទាំងនេះ អាចមានតំណាងនៅតាមខេត្ត-ក្រុង ឬ អាចមានទីតាំង នៅក្នុងខេត្ត-ក្រុងតែម្តង ។

**ចំណាត់ថ្នាក់មុខងាររដ្ឋបាលសាធារណៈ:**

**ចំណាត់ថ្នាក់រដ្ឋបាល** ប្រែប្រួលពីរដ្ឋាភិបាលមួយទៅរដ្ឋាភិបាលមួយទៀត ពីប្រទេសមួយ ទៅប្រទេសមួយទៀត ។ ដើម្បីអាច ប្រៀបធៀបដោយឯករាជ្យ តាមពេលវេលា និងតាមលំហ **មូលនិធិរូបិយវត្ថុអន្តរជាតិ** បានបង្កើត «**ចំណាត់ថ្នាក់មុខងាររដ្ឋបាល សាធារណៈ**» ដែលរៀបចំដោយអង្គការសហប្រជាជាតិចំនួន ១៤ (អង្គការ) មានឈ្មោះថា COFOG (Classification of the Functions of Government) ។

**មាតិកាកម្មវិធី និងគម្រោង**

មាតិកានេះកំណត់ក្នុងបញ្ជីគម្រោង និងកម្មវិធី ។ វាអាចបំបែកចេញពី **មាតិការដ្ឋបាល** ឬ **មាតិកាមុខងារ** ឬ ដោយឯករាជ្យ ។

**ការកត់ត្រាក្នុងតារាងប្រតិបត្តិការហិរញ្ញវត្ថុសាធារណៈ** (TOFE)

ប្រតិបត្តិការហិរញ្ញវត្ថុសាធារណៈបង្កើតបានជាការកត់ត្រា ដែលរំលេចជាស្វ័យប្រវត្តិ នូវតារាង TOFE ។ ពេលជ្រើសរើស ម៉ូដែលតារាង TOFE (ដែលប្រែប្រួលពីប្រទេសមួយទៅមួយ) រួចរាល់ហើយ តារាងនោះនឹងក្លាយជាតារាងចុងក្រោយ ។

## ៥. គណនេយ្យពិសេស

«**គណនេយ្យពិសេសនៃរូបធាតុ** តម្លៃ និង មូលប័ត្រ មានកម្មវត្ថុពិពណ៌នាចំនួនដែលមានស្រាប់ និងចលនាដែលទាក់ទងនឹង៖

- សម្ភារៈ និងទ្រព្យសង្ហារឹម
- មូលប័ត្រមានចុះឈ្មោះ គ្មានឈ្មោះ និងតាមបញ្ជា រូបិយប័ណ្ណបរទេស និងមូលប័ត្រផ្សេងៗទៀតដែលជារបស់ រដ្ឋ ឬ ត្រូវបានផ្ញើរទុកនឹងរដ្ឋ
- រូបិយប័ណ្ណបរទេស...
- គំរូលិខិត មូលប័ត្រ ប័ណ្ណ តែមប្រិ៍ និងលតាប័ត្រទុកសំរាប់បោះផ្សាយ និងលក់

វិធានគណនេយ្យ ត្រូវបានកំណត់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ» (មាត្រា ១០២ អនុក្រឹត្យ ៨២) ។

គណនេយ្យតាមកម្មវិធីអាចត្រូវបានរៀបចំឡើង ដោយប្រកាសរបស់រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

### កំណែទម្រង់ពីប្រព័ន្ធគ្រប់គ្រង ទៅប្រព័ន្ធការិយបរិច្ឆេទ

ការគ្រប់គ្រងថវិកាមានប្រព័ន្ធពីរ គឺ **ប្រព័ន្ធគ្រប់គ្រង** និង **ប្រព័ន្ធការិយបរិច្ឆេទ** ដោយសារតែប្រព័ន្ធពីរនេះឈរលើមូលដ្ឋាននៃប្រព័ន្ធគណនេយ្យពីរខុសគ្នា ។ **ប្រព័ន្ធគ្រប់គ្រង** ប្រើប្រាស់ប្រព័ន្ធ **គណនេយ្យបេឡា** (Cash accounting) ចំណែកឯ **ប្រព័ន្ធការិយបរិច្ឆេទ** ប្រើប្រាស់ប្រព័ន្ធ **គណនេយ្យបង្គរ** (Accrual accounting) ។

ដូច្នេះ នៅពេលដែលក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុដាក់អោយអនុវត្តនូវប្រព័ន្ធ **គណនេយ្យបង្គរ** ប្រព័ន្ធថវិកាក៏ត្រូវផ្លាស់ប្តូរពី **ប្រព័ន្ធគ្រប់គ្រង** ទៅ **ប្រព័ន្ធការិយបរិច្ឆេទ** ផងដែរ ។

នៅក្នុង **ប្រព័ន្ធគ្រប់គ្រង** ប្រតិបត្តិការត្រូវចុះបញ្ជីការគណនេយ្យក្នុងកាលបរិច្ឆេទ ដែលធ្វើកំណត់ត្រា (ការប្រមូល និង ការទូទាត់ប្រាក់) ។ វាជាគណនេយ្យបេឡា (Cash accounting) ។ ក៏ប៉ុន្តែ ប្រព័ន្ធគណនីដែលអនុវត្តនៅក្នុងពេលកន្លងទៅ គឺជាប្រព័ន្ធបេឡាកែតម្រូវ (Modified cash) ដោយចំណូលត្រូវកត់ត្រាដោយឈរលើមូលដ្ឋានបេឡា ចំណែកឯចំណាយឈរលើមូលដ្ឋានអាណត្តិបើកប្រាក់ (Commitment) ។ នៅចុងការិយបរិច្ឆេទមាន **រយៈពេលបន្ថែម** (Complementary period) ចំនួន ពី មួយ ទៅ ពីរខែ តាមការកំណត់របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។ រយៈពេលបន្ថែមនេះចាំបាច់ ដោយសារនៅចុងឆ្នាំរតនាគារទទួលនូវអាណត្តបើកប្រាក់យ៉ាងច្រើនលើសលុប ដូច្នេះទើបមិនអាចបូកសរុបបាននៅត្រឹមនៅថ្ងៃទី ៣១ ខែធ្នូ នៃឆ្នាំនីមួយៗ ។

«រហូតដល់ថ្ងៃ ២៨ ខែកុម្ភៈ ប្រតិបត្តិការរតនាគារនិយ័តកម្មត្រូវពិនិត្យលេខនាបន្ថែមនៅថ្ងៃទី ៣១ ខែធ្នូ ។ ប្រតិបត្តិការនិយ័តកម្មនេះផ្តោតទៅលើ៖

- ការកត់ត្រាជាស្ថាពរនៃចំណូល ឬ នៃចំណាយ ដែលបានពិនិត្យកត់ត្រាជាលេខនា ថ្ងៃទី ៣១ ខែ ធ្នូ ជាអាទិ៍ចូលគណនីបណ្តោះអាសន្ន
- អាណត្តិនិយ័តកម្ម ដែលទាក់ទងដល់ចំណាយដែលបានទូទាត់ដោយរដ្ឋទេយ្យបុរេប្រទានមុនថ្ងៃទី ៣១ ខែធ្នូ
- ការកែប្រែលេខនាខុស
- ការបូកសរុបនៃប្រតិបត្តិការការគណនេយ្យរដ្ឋបាលហិរញ្ញវត្ថុ និងគណនេយ្យរងនៃរតនាគារខេត្ត-ក្រុង (មាត្រា ១១១ អនុក្រឹត្យ ៨២) ។

នៅក្នុង **ប្រព័ន្ធការិយបរិច្ឆេទ** ចំណូល និង ចំណាយ ត្រូវកត់ត្រាអោយត្រូវទៅនឹងការិយបរិច្ឆេទ (រយៈពេល) ដែលបានបង្កើតចំណូល និងចំណាយនេះឡើង ។ គេអាចហៅប្រព័ន្ធនេះផងដែរថាជា **ប្រព័ន្ធគណនេយ្យបង្គរ** ។ ការអនុវត្ត **រយៈពេលបន្ថែម** នាំអោយកាត់បន្ថយចំនួនលេខនាដែលផ្អាក ។

គណនេយ្យការិយបរិច្ឆេទនេះ គឺមានគោលបំណងផ្តល់នូវ «រូបភាពពិត និង ស្មោះត្រង់» ស្តីពីស្ថានភាពហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់រដ្ឋ ។ គណនេយ្យនេះស្រដៀងគ្នានឹងគណនេយ្យរបស់សហគ្រាសឯកជន ។ ប្រព័ន្ធគណនេយ្យនេះខុសពីឯកជនខ្លះ ដោយសារលក្ខណៈពិសេសរបស់រដ្ឋតែប៉ុណ្ណោះ ជាពិសេស សម្រាប់ចំណូល **«អធិបតេយ្យ»** ដែលជាការប្រមូលពន្ធ ដោយគ្មានការទូទាត់ជាបដិភាគ ។

ការកត់ត្រានូវ**បន្ទុក** ដែលត្រូវទូទាត់ និង **ផល** ដែលត្រូវទទួល ត្រូវកត់ត្រាក្នុងកាលិយបច្ឆេទ ដោយផ្អែកលើមូលដ្ឋាននៃសេវាដែលបានផ្គត់ផ្គង់ និង ការជម្រះបញ្ជី ។

យើងអាចរំលេចអោយឃើញនូវភាពខុសគ្នារវាង **គណនេយ្យការិយបរិច្ឆេទ** និង **គណនេយ្យបេតិកភណ្ឌ** ។ គណនេយ្យក្រោយនេះទាមទារការយល់ដឹងពីអចលនទ្រព្យ និង រំលស់ (ដូចដែលវិស័យឯកជនអនុវត្ត) ។ សារពើភ័ណ្ឌ និង ការវាយតម្លៃបេតិកភ័ណ្ឌរបស់រដ្ឋទាមទាររយៈពេលមួយយ៉ាងយូរ ឬ យ៉ាងខ្លី ដែលអាស្រ័យទៅតាមចំណាយរបស់រដ្ឋដើម្បីអនុវត្ត ។ ដំណោះស្រាយ គឺ ត្រូវកត់ត្រាចូលទៅក្នុងបញ្ជីសារពើភ័ណ្ឌ និង ចុះបញ្ជីកាគណនីបណ្តើរៗ ដើម្បីអាចអោយយើងស្វែងយល់អោយបានច្បាស់នូវបញ្ហាអចលនទ្រព្យ (សន្និធិ) និងតម្លៃរបស់វា ។

ដោយអនុវត្តតាមមាត្រា ៩៦ នៃអនុក្រឹត្យ ៨២ ។

## ៦. លទ្ធផលប្រចាំឆ្នាំ និង គណនីនៅចុងឆ្នាំ

ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈកំណត់ពីរបៀបគណនាលទ្ធផលពិតក្នុងឆ្នាំ (មាត្រា ៥៧) ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ចំណុចនេះ មានលម្អិតនៅក្នុងផ្នែកពាក់ព័ន្ធនឹងថវិកា ។

«គណនីលទ្ធផល ពិពណ៌នាពីអតិរេក និងឱនភាព ដែលរដ្ឋសំរេចបាន ក្នុងអំឡុងពេលនៃការគ្រប់គ្រងនីមួយៗ...» (មាត្រា ១១២ អនុក្រឹត្យ ៨២) ។

«គណនីទាំងឡាយរបស់រដ្ឋ ត្រូវបាន (រៀបចំ) ធ្វើឡើងរៀងរាល់ឆ្នាំដោយរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។ គណនីទូទៅនៃការគ្រប់គ្រងរដ្ឋបាលហិរញ្ញវត្ថុរួមមាន ÷

- តុល្យភាពទូទៅ នៃគណនីដែលបានសំយោគពីគណនីរបស់គណនេយ្យករសាធារណៈ
- អត្ថាធិប្បាយអំពី ចំណូលថវិកា
- អត្ថាធិប្បាយអំពី ចំណាយថវិកា ដោយរំលេចចេញសម្រាប់ក្រសួងនីមួយៗ នូវចំនួនទឹកប្រាក់ចំណាយតាមជំពូក ដែលបញ្ជាក់ដោយរដ្ឋមន្ត្រីនៃក្រសួងពាក់ព័ន្ធ
- អត្ថាធិប្បាយអំពី ប្រតិបត្តិការដែលបានពិនិត្យឃើញក្នុងគណនីពិសេសរបស់រតនាគារ
- អត្ថាធិប្បាយអំពី គណនីលទ្ធផល» (មាត្រា ១១៣ អនុក្រឹត្យ ៨២)

«រាល់ឆ្នាំរដ្ឋមន្ត្រីនីមួយៗធ្វើរបាយការណ៍ស្តីពីការគ្រប់គ្រង និងបញ្ជាក់សទិសភាព (Conformité) ដែលមានរវាងមុខងាររបស់សាម៉ីក្រសួង និងអត្ថាធិប្បាយអំពីចំណាយរបស់ក្រសួងនោះ ដែលរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានធ្វើជូន» (មាត្រា ១១៤ អនុក្រឹត្យ ៨២) ។

> នៅប្រទេសបារាំង ការបញ្ជាក់សទិសភាព រវាងលេខនារបស់អាណាប័ក និង គណនេយ្យករ ត្រូវបានផ្តល់ដោយតុលាការគណនី (Cour des comptes)។

«គណនីគ្រប់គ្រងរបស់គណនេយ្យរដ្ឋ ត្រូវបានធ្វើជូនរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលដាក់អោយអធិការកិច្ចហិរញ្ញវត្ថុពិនិត្យ មុនថ្ងៃ ៣០ ខែ មិថុនា នៃឆ្នាំបន្ទាប់» (មាត្រា ១១៥ អនុក្រឹត្យ ៨២) ។

«រដ្ឋសភាអនុម័តគណនីទាំងនោះ ហើយទូទាត់ថវិការដ្ឋជាស្ថាពរ ។ សេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិការដ្ឋ ត្រូវបានដាក់ជូនរដ្ឋសភាជាតិមុនដំណាច់ឆ្នាំ ។ សេចក្តីព្រាងច្បាប់នេះផ្អែកលើគណនីទូទៅនៃការគ្រប់គ្រងរដ្ឋបាលហិរញ្ញវត្ថុ និងរបាយការណ៍គ្រប់គ្រង ដែលរៀបចំដោយរដ្ឋមន្ត្រីក្រសួងនានា» (មាត្រា ១១៦ អនុក្រឹត្យ៨២)។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ផ្នែកទី ៣

# ការគ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យាលើវិស័យហិរញ្ញវត្ថុសាធារណៈ

**ការគ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យាលើវិស័យហិរញ្ញវត្ថុសាធារណៈ** (FMIS) មានគោលដៅធ្វើទំនើបភាវូបនីយកម្មនៃកាគ្រប់គ្រងរតនាគារ ដើម្បីកែលម្អការអនុវត្ត និង ការត្រួតពិនិត្យថវិកា ។ កម្មវិធីកំណែទម្រង់ផ្សេងៗទៀតមរួមមាន៖ (ក). ពិពណ៌នាយ៉ាងលំអិតនូវដំណើរការអនុវត្តថវិកា (ពីដំណាក់កាលធានាចំណាយការប្រគល់ទទួលទំនិញនិងសេវា ដល់ការរៀបចំអាណត្តិបើកប្រាក់ និង ការទូទាត់) ដោយបង្កើតឡើងនូវផែនការនៅក្នុងដំណាក់កាលអន្តរកាល មុននឹងអនុម័តនូវដំណើរការថវិកាថ្មីមួយ ដែលមានលក្ខណៈកាន់តែសាមញ្ញ និងកាន់តែមានប្រសិទ្ធភាព (ខ). បង្កើនការទូទាត់រវាងរដ្ឋាភិបាល ជាមួយនឹងតួអង្គដទៃទៀតតាមប្រព័ន្ធធនាគារដូចជា ការបង់ពន្ធការបើកប្រាក់បៀវត្សរ៍អោយមន្ត្រីរាជការ និង ការទូទាត់កិច្ចសន្យាជាមួយក្រុមហ៊ុនឯកជន (គ). រៀបចំ និង អនុវត្តវិធានការពង្រឹងវិន័យថវិកា ដោយកាត់បន្ថយនូវកំណើននៃបំណុលថវិកា (ឃ). រៀបចំលក្ខខណ្ឌបច្ចេកទេស ដើម្បីវាយតម្លៃអោយបានត្រឹមត្រូវនូវក្របខ័ណ្ឌ និង នីតិវិធីនៃ**ការគ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យាលើវិស័យហិរញ្ញវត្ថុសាធារណៈ** (FMIS) ដោយសង្កត់ធ្ងន់លើការកាត់បន្ថយ និង ការពង្រឹងតម្លាភាពនៃដំណើរការអនុវត្តការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ មុននឹងចាប់ផ្តើមអនុវត្តកម្មវិធីគ្រប់គ្រងតាមបែបកុំព្យូទ័រ (ង). ស្វែងរកការផ្តល់អនុសាសន៍ស្តីពីគោលនយោបាយប្រព័ន្ធរៀបចំល្អ និង ខ្លឹមសារ ដើម្បីដោះស្រាយបញ្ហាសមត្ថភាព និងបច្ចេកវិទ្យា ដោយរួមទាំងកម្មវិធីដាក់ឱ្យប្រើប្រាស់នូវកម្មវិធី និង សម្ភារៈប្រព័ន្ធព័ត៌មានវិទ្យា រួមទាំងការសាកល្បង និង ការធានារ៉ាប់រងគុណភាព (ឆ). កសាងសមត្ថភាពរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សម្រាប់កិច្ចដំណើរការ**គ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យាលើវិស័យហិរញ្ញវត្ថុសាធារណៈ** (FMIS) និងប្រើប្រាស់របាយការណ៍របស់ប្រព័ន្ធនេះ និង (ជ) បណ្តុះបណ្តាល និង កសាងសមត្ថភាពស្ថាប័នពាក់ព័ន្ធ ក្នុងការប្រើប្រាស់នូវប្រព័ន្ធដែលបានរៀបចំរួចស្រេច ។ សមាសភាពនេះតម្រូវឱ្យមានការចូលរួមការងារពីសំណាក់ក្រសួងនានា ដែលស្ថិតក្នុងភាពខុសគ្នានៃការអនុវត្តកម្មវិធីកំណែទម្រង់។

## ១. ដែនអនុវត្ត

ដើម្បីផ្តល់ទស្សនវិស័យគ្រប់ជ្រុងជ្រោយ និងប្រកបដោយសមាហរណកម្មនៃហិរញ្ញវត្ថុសាធារណៈ ប្រព័ន្ធព័ត៌មានវិទ្យាត្រូវគ្របដណ្តប់បន្តិចម្តងៗលើផ្នែកដូចខាងក្រោម ÷



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ១.១. នៅកម្រិតរដ្ឋបាលកណ្ដាល

- នៅកម្រិតរដ្ឋបាលកណ្ដាលនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
    - រតនាគារ
    - ថវិកា
    - ហិរញ្ញកិច្ច និង ការត្រួតពិនិត្យហិរញ្ញវត្ថុ
    - បំណុល
    - ទ្រព្យសម្បត្តិរដ្ឋ-(អចលនទ្រព្យប្រូបីយ៍ និងអរូបីយ៍)
    - បុគ្គលិក (ប្រាក់បៀវត្សរ៍)
    - បុគ្គលិក (ចំនួនមន្ត្រីរាជការ ឬ ប៉ុស្តិ៍ថវិកា)
    - ពន្ធ
    - គយ និងរដ្ឋាករ
- ក្រសួងផ្សេងទៀត និងអាណាប័កនៅកម្រិតកណ្ដាល
    - គណនេយ្យរដ្ឋបាល (ការធានាចំណាយ និងការបើកផ្តល់)
- មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុតាមខេត្ត- ក្រុង
- មន្ទីរខេត្ត- ក្រុងនៃក្រសួងផ្សេងៗ

## ១.២. នៅកម្រិតរដ្ឋបាលថ្នាក់ក្រោមជាតិ

- គ្រឹះស្ថានរដ្ឋបាលសាធារណៈ
- ថវិកាអភិបាលខេត្ត- ក្រុង
- ឃុំ



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

- អង្គភាពវិមជ្ឈការផ្សេងទៀតដែលនឹងត្រូវបង្កើត

## ២. ទម្រង់នៃប្រព័ន្ធគ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យាលើវិស័យហិរញ្ញវត្ថុសាធារណៈ

ទម្រង់នៃ **ប្រព័ន្ធគ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យាលើវិស័យហិរញ្ញវត្ថុសាធារណៈ** ត្រូវអនុលោមតាមផ្នែកនីមួយៗ ។

### ២.១. រតនាគារ

រតនាគារជាតិអាចអនុវត្តនូវប្រព័ន្ធព័ត៌មានវិទ្យាដោយឯករាជ្យ ប៉ុន្តែត្រូវស៊ីសង្វាក់ជាមួយនឹងការអនុវត្តនូវប្រព័ន្ធព័ត៌មានវិទ្យានៅក្នុងផ្នែកដទៃទៀត ដែលរតនាគារជាតិនឹងត្រូវធ្វើសមាហរណកម្មនៅថ្ងៃណាមួយ (មាតិកាគណនេយ្យ និងទម្រង់) ។

### ២.២. ចំណាយ

**ការកត់ត្រាអាណត្តិបើកប្រាក់:** ការកត់ត្រាអាណត្តិបើកប្រាក់ត្រូវធ្វើឡើងដោយឈរលើឯកសារក្រដាស់ពេលណាដែលប្រព័ន្ធព័ត៌មានវិទ្យារបស់អាណាប័ក មិនទាន់អាចបញ្ជូនអាណត្តិបើកប្រាក់ក្នុងទម្រង់អេឡិចត្រូនិច (ដូចជា USB ឌីស ឬ បណ្តាញ ក្នុងពេលភ្លាមៗ ឬនៅពេលក្រោយ) ។ ការកត់ត្រាតាមនីតិវិធីគតិយុត្តិនេះរួមមានការចុះទិដ្ឋាការរបស់រតនាគារលើអាណត្តិបើកប្រាក់ឬការបដិសេធ ។ យើងមិនត្រូវភ្លេចនូវដំណាក់កាលនេះឡើយនៅក្នុងការអនុវត្តជាក់ស្តែង ជាពិសេសសំរាប់បណ្តាញក្នុងពេលភ្លាមៗ ។ ក្រៅពីព័ត៌មានពាក់ព័ន្ធនឹងចំណាយ និងឥណទាយក អាណត្តិបើកប្រាក់ត្រូវមានកត់ត្រានូវព័ត៌មានដូចតទៅ ដើម្បីអោយយើងអាចចុះបញ្ជីកាគណនីបាន÷

- ចំណាត់ថ្នាក់រដ្ឋបាល (ក្រសួងគ្រប់គ្រងឥណទាន និងអ្នកទទួលឥណទាន)
- ចំណាត់ថ្នាក់សេដ្ឋកិច្ច (ឬ តាមមុខសញ្ញាចំណាយ): អាណត្តិបើកប្រាក់មួយអាចមុខសញ្ញាចំណាយ ដែលជាចំណាត់ថ្នាក់សេដ្ឋកិច្ចច្រើន
- ចំណាត់ថ្នាក់រដ្ឋបាល (ការកត់ត្រាដែលអាចអោយធ្វើការប្រៀបធៀបបាន រវាងការិយបរិច្ឆេទមួយទៅការិយបច្ឆេទមួយទៀត និងពីប្រទេសមួយទៅប្រទេសមួយទៀត)
- ចំណាត់ថ្នាក់តាមកម្មវិធី ឬគម្រោង
- ការកត់ត្រាតាមហិរញ្ញប្បទាន
- ការកត់ត្រាតាមភូមិសាស្ត្រ (ដើម្បីត្រួតពិនិត្យតាមដានចំណាយតាមខេត្ត- ក្រុង)

**ការឆ្លងទាត់អាណត្តិបើកប្រាក់**

- ***ការទូទាត់តាមដំណាក់កាលៈ*** ចំពោះគម្រោងដែលមានទឹកប្រាក់ធំ និង អនុវត្តជាច្រើនឆ្នាំ ការទូទាត់ត្រូវអនុវត្តតាមដំណាក់កាល ដោយអាណាប័កចេញអាណត្តិបើកប្រាក់ដើម្បីទូទាត់នូវការផ្គត់ផ្គង់ទំនិញ សេវា ឬ ការងារសាងសង់ ដែលប្រគល់- ទទួលតាមដំណាក់កាល ។

- ការទូទាត់បង្គ្រប់លើអាណត្តិបើកប្រាក់- សមតុល្យនៅសល់ៈ ក្នុងករណីដែលទំហំទឹកប្រាក់ត្រូវទូទាត់ចុងក្រោយ និងការទូទាត់មុនៗ ទាបជាងអាណត្តិបើកប្រាក់ លំអៀងថវិកាត្រូវបំបែកចេញ និងបញ្ចូលជាថ្មីលើឥណទានរបស់គណនេយ្យករ និងអាណាប័ក ។

- ការទាមទារនិយ័តភាពពីអាណាប័កៈ ចំពោះការទូទាត់ដែលបានធ្វើឡើងដោយមិនមានអាណត្តិបើកប្រាក់ (សេវាធនាគារ ។ល។) ទាមទារអោយមាននិយ័តភាព ដោយអាណាប័កត្រូវចេញអាណត្តិបើកប្រាក់ដើម្បីទូទាត់ចំណាយនោះ ។

- អាជ្ញាយុកាល ។

**ការចុះកិច្ចបញ្ជីកាគណនេយ្យៈ** ការចុះកិច្ចបញ្ជីកាគណនេយ្យ តាមមុខសញ្ញាចំណាយក្នុងក្របខ័ណ្ឌនៃគណនេយ្យទូទៅរបស់រដ្ឋ ការអនុវត្តនូវគណនេយ្យវិភាគផ្សេងៗ គណនេយ្យតាមកម្មវិធី ឬគំរោង និង តាមហិរញ្ញប្បទាន ។ល។

**ការតាមដានក្នុងពេលតែមួយ** នៅក្នុងការិយបរិច្ឆេទពីរ

**ប្រតិបត្តិការនៅចុងការិយបរិច្ឆេទ**

**ការលើកពីការិយបរិច្ឆេទមួយទៅការិយបរិច្ឆេទមួយទៀត**

## ២.៣. ផ្នែកចំណូល

- ការចុះកិច្ចបញ្ជីកានៃប័ណ្ណចំណូលដែលចេញដោយអាណាប័ក ។ ចំពោះចំណូលដែលប្រមូលដោយមិនទាន់មានលិខិតយុត្តិការត្រឹមត្រូវ ត្រូវធ្វើនិយ័តភាព ដោយទារប័ណ្ណចំណូលពីអាណាប័ក ។

- ការទារយកប័ណ្ណចំណូល ការប្រមូលចំណូលដោយមានការប្តឹងតវ៉ា អាជ្ញាយុកាល ការកត់ត្រាដោយគ្មានតម្លៃ

- ការចុះកិច្ចបញ្ជីកាគណនេយ្យ និងការតាមដាន



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

### ៣. ម៉ូឌុលផ្សេងៗទៀត

- **សំណុំឯកសារអ្នកផ្គត់ផ្គង់** (ដែលអាចកត់ត្រានៅអគ្គនាយកដ្ឋានពន្ធដារ អគ្គនាយកដ្ឋានគយ និងរដ្ឋាករ និង អាណាប័កៈ អ្នកផ្គត់ផ្គង់ក្នុងស្ថានភាពធម្មតា អ្នកផ្គត់ផ្គង់ត្រូវបានហាមឃាត់មិនអោយចូលរួមលទ្ធកម្មសាធារណៈ អ្នកផ្គត់ផ្គង់ជាប់បំណុលពន្ធ និងបំណុលគយ ការប្រឆាំងជំទាស់ ។ល។)

### ៣.១. អាណាប័ក

អាណាប័កត្រូវចុះកិច្ចបញ្ជីកាគណនេយ្យរដ្ឋបាលសំរាប់ប្រតិបត្តិការរបស់គេៈ ការធានាចំណាយ និង ការចេញអាណត្តិបើកប្រាក់។

**ថវិកាៈ** ជាដំបូង យើងអាចវាយលេខបញ្ចូលដោយដៃ ឬ មានម៉ូឌុលនៃការរៀបចំថវិកាដោយប្រព័ន្ធព័ត៌មានវិទ្យា ។

- ការកត់ត្រានូវឥណទានកម្មវិធី ឥណទានភ្ជាប់កិច្ចសន្យា និង ឥណទានទូទាត់ ។
- ការកែប្រែថវិកាៈ ការកែប្រែនេះត្រូវអនុវត្តដោយគោរពតាមនីតិវិធីច្បាប់ជាធរមាន ដូចជា ច្បាប់ហិរញ្ញវត្ថុកែតម្រូវ អនុក្រឹត្យ ប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ការសម្រេចរបស់អាណាប័កទៅតាមករណីជាក់ស្តែង ។ ត្រូវផ្តល់ឯកសារយោង ដែលត្រូវដាក់ចូលក្នុងប្រព័ន្ធ (ដោយមានដាក់លេខកូដ) ។
- ទាយជ្ជទានថវិកាខ្លះ ជាឥណទានអាចវាយតម្លៃបានៈ ទាយជ្ជទានទាំងនោះអាចត្រូវបានធានាចំណាយ លើសពីឥណទានថវិកាដែលមាន ។ ត្រូវផ្តល់ដំណឹងពីការលើសឥណទាននេះ ហើយត្រូវធ្វើនិយ័តភាពដោយផ្ទេរពីឥណទានដែលនៅទំនេរ ។ ទាយជ្ជទានភាគច្រើន គឺជាឥណទានថវិកាមានកំហិត ដែលមិនអាចប្រើប្រាស់លើសឥណទានបានឡើយ (ការធានាចំណាយត្រូវមានកម្រិត ការកែតម្រូវថវិកាត្រូវស្របតាមបន្ទាត់ថវិកានៃឥណទានទំនេរ ។
- ការកត់ត្រាឡើងវិញៈ នៅពេលដែលការធានាចំណាយត្រូវបានលុបចោលទាំងស្រុង ឬ ដោយផ្នែក ដោយអាណាប័ក ឬ គណនេយ្យករ ។

**ការធានាចំណាយៈ** ត្រូវតាមដានឥណទានកម្មវិធី ការធានាចំណាយ និងឥណទានទូទាត់

**ការចេញវិក្កយបត្រៈ** វិក្កយបត្រដែលទទួលបានត្រូវកត់ត្រាក្នុងបញ្ជីចាប់ពីពេលទទួល នៅក្នុងកុំព្យូទ័រនៃមជ្ឈមណ្ឌលកណ្តាល (ដែលជាការចុះកិច្ចបញ្ជីកាជាដាច់ខាតសម្រាប់ក្រុមហ៊ុនឯកជន) ។ ប្រការនេះអនុញ្ញាតអោយយើងអាចវាស់វែងទំហំនៃបំណុលផ្ទៃក្នុងនៅតាមស្ថាប័ននីមួយៗ ផ្ទៀងផ្ទាត់ភាពមិនប្រក្រតីមួយចំនួន

(វិក្កយប័ត្រចេញមុនពេលចេញអាណត្តិបើកប្រាក់ វិក្កយប័ត្រដោយគ្មានអាណត្តិបើកប្រាក់ បន្ទាប់ពីរយៈពេលកំណត់ណាមួយ) ។

**ការជម្រះបញ្ជីៈ** ទឹកប្រាក់ដែលបានយល់ព្រម (ទទួលស្គាល់) គឺជាទឹកប្រាក់ដែលនឹងត្រូវចេញអាណត្តិបើកប្រាក់ ។ ជាទូទៅ ប្រសិនបើទឹកប្រាក់ដែលបានទទួលស្គាល់ ខុសពីទឹកប្រាក់នៅក្នុងវិក្កយប័ត្រ (កំហុសគណនា កំហុសបរិមាណ កំហុសគុណភាព ឬ ថ្លៃឯកតា) ចាំបាច់ត្រូវមានការយល់ព្រមពីសំណាក់អ្នកផ្គត់ផ្គង់ ។ ការជម្រះបញ្ជីអាចមានច្រើនដង (ការប្រគល់-ទទួល និងការចេញវិក្កយប័ត្រជាដំណាក់ៗដោយមានការធានាចំណាយតែមួយលើកប៉ុណ្ណោះ) ។

**ការចេញអាណត្តិបើកប្រាក់ៈ** គឺជាការបញ្ជូនជាផ្លូវការអោយទៅគណនេយ្យករនូវអាណត្តិបើកប្រាក់ ។ នៅក្នុងប្រព័ន្ធកុំព្យូទ័រ ការចេញអាណត្តិបើកប្រាក់ គឺជាការភ្ជាប់រវាងការជម្រះបញ្ជីជាមួយការចេញអាណត្តិដោយចេញឯកសារបញ្ជាក់ ដោយមានដាក់លេខរៀងតៗគ្នា ។ ជាទូទៅ អាណត្តិបើកប្រាក់ ត្រូវបញ្ជូនទៅអោយគណនេយ្យករ ក្នុងទម្រង់ជាក្រដាស់ស្នាមមានដីការអម ចុះលេខរៀងតៗគ្នា ដោយអាណត្តិមួយត្រូវមានដីការអមមួយ ។ គេត្រូវបញ្ជាក់អោយច្បាស់ពីអាណត្តិបើកប្រាក់ណា ដែលទូទាត់ការធានាចំណាយ (ធៀបនឹងអាណត្តិបើកប្រាក់ដែលប្រើប្រាស់ឥណទានធានាចំណាយតែមួយផ្នែក) ។ ប្រសិនបើទំហំទឹកប្រាក់នៃអាណត្តិមិនប្រើអោយអស់នូវឥណទានធានាចំណាយទេនោះ ឥណទានដែលនៅសល់ត្រូវយកទៅប្រើប្រាស់ឡើងវិញ ។ អាណត្តិបើកប្រាក់មិនអាចលើសពីទឹកប្រាក់ធានាចំណាយបានឡើយ ។ ប្រសិនបើទឹកប្រាក់ធានាចំណាយមិនគ្រប់គ្រាន់ គេត្រូវផ្ទេរឥណទានដើម្បីធ្វើការធានាចំណាយបន្ថែម ។ ដូច្នេះ គេអាចចេញអាណត្តិបើកប្រាក់មួយ ដើម្បីប្រើប្រាស់នូវឥណទានដែលបានធានាចំណាយច្រើនដង ។ ទន្ទឹមនឹងនេះ គេក៏អាចចុះបញ្ជីកាគណនេយ្យច្រើនដង ដើម្បីកត់ត្រាអាណត្តិបើកប្រាក់មួយដែរ ។

- គេអាចបដិសេធអាណត្តិបើកប្រាក់បាន ។ គេអាចកែតម្រូវនូវដីកាអម ដែលផ្ញើមកជាមួយអាណត្តិបើកប្រាក់ ។ បន្ទាប់ពីកែតម្រូវនូវកំហុស គេបញ្ជូនអាណត្តិបើកប្រាក់ជាមួយនឹងដីកាអមមកម្តងទៀត ។
- អាណត្តិបើកប្រាក់ អាចជាកម្មវត្ថុនៃបណ្តឹងប្រសិនមានបទប្បញ្ញត្តិចែង ។ ប្រព័ន្ធព័ត៌មានវិទ្យាត្រូវគិតគូពីបញ្ហាអស់ទាំងនេះ ។

ការបញ្ចូលគ្នានូវម៉ូឌុលរបស់អាណាប័ក ការត្រួតពិនិត្យហិរញ្ញវត្ថុ និងគណនេយ្យ អាចអោយគ្រប់តួអង្គទាំងអស់បានដឹង នៅពេលណាក៏ដោយ នូវដំណាក់កាលនៃការប្រើប្រាស់ឥណទានដែលបានធានាចំណាយៈ ការចេញវិក្កយប័ត្រ ការចេញអាណត្តិបើកប្រាក់ ការជម្រះបញ្ជី និងការទូទាត់ ។ អ្នកផ្គត់ផ្គង់អាចដឹងថា តើវិក្កយប័ត្រ


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

របស់ខ្លួន បន្ទាប់ពីចេញពីអាណាប័កហើយ កំពុងស្ថិតនៅកន្លែងណា ដោយមិនចាំបាច់រត់តាមឯកសារឡើយ ។

## ៣.២. ការត្រួតពិនិត្យហិរញ្ញវត្ថុ

អនុលោមតាមបទប្បញ្ញត្តិ (ដែលប្រែប្រួលពីប្រទេសមួយទៅមួយ) ការត្រួតពិនិត្យហិរញ្ញវត្ថុត្រូវបានអនុវត្តលើការធានាចំណាយទាំងអស់ ឬ មួយចំនួន (តាមកម្រិតទឹកប្រាក់ធានាចំណាយ) និងលើអាណត្តិបើកប្រាក់ទាំងអស់ ឬលើអាណត្តិបើកប្រាក់មួយចំនួន (តាមកម្រិតទឹកប្រាក់នៃអាណត្តិបើកប្រាក់) ។

ការអនុវត្ត **ការគ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យាលើវិស័យហិរញ្ញវត្ថុសាធារណៈ** អាចអនុញ្ញាតអោយការត្រួតពិនិត្យហិរញ្ញវត្ថុ តាមដានការធានាចំណាយ និងការចេញអាណត្តិបើកប្រាក់ ដែលមិនមានទិដ្ឋាការពីដំបូង ។

ការត្រួតពិនិត្យហិរញ្ញវត្ថុត្រូវអាចតាមដានផងដែរ (បើក្នុងករណីមានការអនុញ្ញាត) នូវការកែប្រែថវិកា ។

ទិដ្ឋាការនៃការត្រួតពិនិត្យហិរញ្ញវត្ថុត្រូវផ្តល់តាមបែបអេឡិចត្រូនិច ស្របជាមួយនឹងសំណេរផ្ទាល់ដៃលើឯកសារ ។ ទិដ្ឋាការអេឡិចត្រូនិចត្រូវបានផ្តល់ដោយប្រព័ន្ធព័ត៌មានវិទ្យា និងបញ្ជូនពីម៉ូឌុលនៃការគ្រប់គ្រងហិរញ្ញវត្ថុ ទៅម៉ូឌុលអាណាប័ក និងបន្ទាប់មកពីម៉ូឌុលអាណាប័ក ទៅម៉ូឌុលគណនេយ្យ ។

## ៣.៣. ការគ្រប់គ្រងសាច់ប្រាក់

អ្នកទទួលខុសត្រូវខាងផ្នែកហិរញ្ញវត្ថុសាធារណៈ ជានិច្ចជាកាលតែងតែខិតខំគ្រប់គ្រងសាច់ប្រាក់តាមរយៈការគ្រប់គ្រងការធានាចំណាយ ដែលមិនដែលបានផ្តល់នូវលទ្ធផលល្អនោះទេ ។

គេអាចកាត់បន្ថយសកម្មភាពបាន ប៉ុន្តែគេមិនអាចកាត់បន្ថយថវិកាបានឡើយ ។ ជាទូទៅ មានតែការកាត់បន្ថយសកម្មភាពភាពប៉ុណ្ណោះ ដែលនឹងធ្វើអោយចំណាយធ្លាក់ចុះ ។

វិធីសាស្ត្រគ្រប់គ្រងសាច់ប្រាក់ដែលគេបានប្រើប្រាស់រួមមាន ការបង្កក «ឥណទាន» និង ការហាមឃាត់មិនអោយធានាចំណាយលើសពី X% នៃឥណទានថវិកា ។ ជាញឹកញាប់ ការបង្កកឥណទាននេះមិនបានឆ្លុះបញ្ចាំងនូវស្ថានភាពជាក់ស្តែងនៃការធានាចំណាយគតិយុត្តិឡើយ និង ឆ្លុះបញ្ចាំងមិនត្រឹមត្រូវលើការធានាចំណាយគណនេយ្យ ។ ឧទាហរណ៍ ភតិសន្យាដែលចុះហត្ថលេខាសម្រាប់រយៈពេល ១២ ខែ ឬលើសពីនេះ គឺមានបំណុលសម្រាប់ ១២ ខែ លើឥណទានទូទាត់ (និង សម្រាប់រយៈពេលច្រើនឆ្នាំ) ។ គេត្រូវរំលាយភតិសន្យានេះ ដើម្បីសន្សំសំចៃថវិកា ដែលត្រៀមទុកសម្រាប់ទូទាត់កិច្ចសន្យានេះ ។ ឧទាហរណ៍ កិច្ចសន្យាថែទាំប្រចាំលើកុំព្យូទ័រត្រូវបានចុះហត្ថលេខាសម្រាប់មួយឆ្នាំ ។ ដើម្បីសន្សំសំចៃ គេត្រូវរំលាយកិច្ចសន្យានេះចោល ឬ គិតគូរពីកិច្ចសន្យាប្រចាំត្រីមាស ដែលអាចចរចាជាថ្មី លើកលែងតែមានករណីបដិសេធ ។

**តើគេអាចគ្រប់គ្រងសាច់ប្រាក់តាមវិធីអ្វីទៀតក្រៅពីតាមរយៈការធានាចំណាយ?**

យើងអាចពង្រឹងការគ្រប់គ្រងសាច់ប្រាក់តាមរយៈការព្យាករណ៍ចំណូលប្រចាំខែ ឧទាហរណ៍ ការធានាចំណាយត្រូវកំណត់កាលបរិច្ឆេទទូទាត់ជាយថាហេតុ ដោយមានចេញវិក្កយប័ត្រសម្រាប់ជាសក្ខីប័ត្រ ។ នៅពេលចេញការធានាចំណាយ ប្រព័ន្ធនឹងផ្តល់ព័ត៌មានពីស្ថានភាពសាច់ប្រាក់ ដែលបណ្តាលមកពីការធានាចំណាយនេះ ដោយតាមដាន ដំណើរការនៃការផ្តល់ទិដ្ឋាការលើការធានាចំណាយ ការឯកភាព ការបដិសេធ ឬស្នើកាលបរិច្ឆេទថ្មីខាងមុខទៀត ជាដើម (ដែលធ្វើអោយសកម្មភាពថយចុះ ...) ។

ជាបឋម គេត្រូវផ្តល់អាទិភាពលើការធានាចំណាយជាកាតព្វកិច្ច (បៀវត្សរ៍ បំណុល ភតិសន្យា កិច្ចសន្យា និង លទ្ធកម្ម) ។ គេក៏ត្រូវគិតគូរផងដែរពីចំណាយមិនបានគ្រោងទុក និង ចំណាយមានលក្ខណៈបន្ទាន់ ។

## ៣.៤. ការរៀបចំថវិកា

ម៉ូឌុលនេះអាចអនុវត្តដោយឯករាជ្យ និង ផ្ទេរថវិកាដែលបានអនុម័តរួច ទៅក្នុងម៉ូឌុលរបស់អាណាប័កម៉ូឌុលការត្រួតពិនិត្យហិរញ្ញវត្ថុ និង ម៉ូឌុលរតនាគារ ។

គេអាចបញ្ចូលនិយាមថ្លៃដែលត្រូវធ្វើបច្ចុប្បន្នភាពជាប្រចាំ និង ប្រើប្រាស់ថ្លៃនេះដើម្បីរៀបចំថវិកា ។ គេអាចរៀបចំថវិកាតាមទម្រង់ចាស់ (រដ្ឋបាល) ឬ តាមកម្មវិធី ដោយមានម៉ាទ្រីសបម្លែងពីទម្រង់មួយទៅទម្រង់មួយទៀត ។ ការកត់ត្រាតាមចំណាត់ថ្នាក់មុខងារ តាមភូមិសាស្រ្ត និងតាមចំណាត់ថ្នាក់ផ្សេងៗទៀត ត្រូវមាននៅក្នុងម៉ូឌុលនេះ នឹងត្រូវផ្ទេរទៅម៉ូឌុលផ្សេងទៀត ជាមួយនឹងទាយជូទាន ។

## ៣.៥. ការគ្រប់គ្រងវិនិយោគ

វិនិយោគត្រូវបានរៀបចំឡើងជាគម្រោង ដែលហិរញ្ញប្បទានអាចជាថវិកាជាតិទាំងស្រុង ឬ មួយផ្នែក និងដោយមានហិរញ្ញប្បទានដោយបដិភាគជាមួយដៃគូរអភិវឌ្ឍន៍ទាំងស្រុង ឬ មួយផ្នែក (ស្វ័យហិរញ្ញប្បទាន សហហិរញ្ញប្បទាន ហិរញ្ញប្បទានពីក្រៅប្រទេស) ។

ប្រព័ន្ធព័ត៌មានវិទ្យាត្រូវផ្តល់លទ្ធភាពតាមដានករណីទាំង ៣ នេះ និង ក្នុងករណីស្មុគ្រស្មាញ ដែលមានដៃគូអភិវឌ្ឍន៍ចូលរួមការផ្តល់ហិរញ្ញប្បទាន ត្រូវមានការតាមដានការអនុវត្តនូវហិរញ្ញប្បទាននេះជារឿយៗ តាមរយៈបញ្ជីគិតតម្លៃរបស់ដៃគូអភិវឌ្ឍន៍ និងអនុលោមតាមមាតិកាហិរញ្ញប្បទាន ដើម្បីធានានូវសុខដុមនីយកម្ម ។

ប្រទេសមួយចំនួនបានរៀបចំនូវប្រព័ន្ធព័ត៌មានវិទ្យា រហូតដល់ការបោះផ្សាយជាស្វ័យប្រវត្តិនូវការស្នើដកមូលនិធិ ដែលប្រទេសទទួលជំនួយស្នើសុំដៃគូអភិវឌ្ឍន៍ ដើម្បីបំពេញគណនីដែលត្រូវទទួលមូលនិធិ


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ពីដៃគូអភិវឌ្ឍន៍ ។

## ៣.៦. ការគ្រប់គ្រងអចលនទ្រព្យ

មានប្រទេសកាន់តែច្រើនហើយដែលអនុវត្ត **គណនេយ្យបង្គរ** ដែលមានលក្ខណៈស្រដៀងគ្នាទៅនឹងគណនេយ្យរបស់សហគ្រាសឯកជន ដែលមាននូវការចុះកិច្ចបញ្ជីកាគណនេយ្យ និងការវាយតម្លៃអលចនទ្រព្យ ។

អចលនទ្រព្យអាចចុះកិច្ចបញ្ជីកាដោយដៃ (ការធ្វើសារពើភ័ណ្ឌអចិន្ត្រៃយ៍ ដើម្បីអាចយល់ដឹង និងគ្រប់គ្រងអចលនទ្រព្យ) និង ជាស្វ័យប្រវត្តិ ដោយចុះកិច្ចបញ្ជីកាគណនេយ្យនៅក្នុងគណនីថ្នាក់លេខ ២ និង ១ ។

គេមិនត្រូវបំភ្លេចអចលនទ្រព្យអរូបីយ៍ឡើយៈ ភាគកម្មរបស់រដ្ឋនៅក្នុងក្រុមហ៊ុនរដ្ឋ ឬ ក្រុមហ៊ុនចម្រុះ វិញ្ញាបនប័ត្រ និង អាជ្ញាប័ណ្ណ ។

## ៣.៧. ការទូទាត់

ផ្ទុយពីម៉ូដែលរបស់ប្រទេសបារាំង នៅក្នុងព្រះរាជាណាចក្រកម្ពុជា ចំណាយប្រាក់បៀវត្សរ៍ត្រូវបានគ្រប់គ្រងដោយ **ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល** ដោយមិនស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុឡើយ ។

ជាធម្មតា នៅពេលដែលមានប្រព័ន្ធព័ត៌មានវិទ្យាស្វ័យប្រវត្តិ ប្រព័ន្ធព័ត៌មានវិទ្យាសមាហរណកម្មត្រូវគិតគូរផងដែរដល់ **ប្រព័ន្ធតភ្ជាប់ប្រព័ន្ធព័ត៌មានវិទ្យា** (Interface) ដែលត្រូវទទួលព័ត៌មានសំយោគ ឬដែលអាចទទួលយកនូវព័ត៌មានលម្អិតដោយស្វ័យប្រវត្តិ តាមរយៈ **ប្រព័ន្ធព័ត៌មានវិទ្យាសមាហរណកម្ម** ។

## ៣.៨. ការគ្រប់គ្រងចំនួនមន្ត្រីរាជការ

ការគ្រប់គ្រងការចំនួនមន្ត្រីរាជការ ដែលជាទូទៅ ជាម៉ូឌុលដែលនៅពីលើម៉ូឌុលប្រាក់បៀវត្សរ៍ គឺជាម៉ូឌុលមួយដែលត្រូវបានប្រើប្រាស់សម្រាប់ការជ្រើសរើសបុគ្គលិក ។ ម៉ូឌុលប្រាក់បៀវត្សរ៍ចង្អុលបង្ហាញពីប៉ុស្តិ៍ថវិកាដែលតាមរយៈនេះ មន្ត្រីរាជការអាចបើកប្រាក់បៀវត្សរ៍របស់គេបាន ។ ម៉ូឌុលនៃការគ្រប់គ្រងចំនួនមន្ត្រីរាជការអាចត្រូវបានប្រើប្រាស់ដើម្បីធ្វើការព្យាករណ៍ចំណាយប្រាក់បៀវត្សរ៍សម្រាប់រយៈពេលមួយឆ្នាំ ឬច្រើនជាងនេះ ។

## ៣.៩. ការគ្រប់គ្រងគម្រោង (ធំ)

ការអនុវត្តគម្រោងធំៗទទួលបានជោគជ័យ ដោយសារគោលការណ៍ដូចខាងក្រោមនេះ ÷



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

**ការរៀបចំគម្រោង:** គម្រោងត្រូវបានរៀបចំឡើងក្រោមការត្រួតពិនិត្យរបស់ អ្នករៀបចំគម្រោងម្នាក់ ដែលផ្តល់ការធានាដល់ក្រុមការងារគម្រោងចំពោះភាគីខាងក្រៅ ។ គម្រោងមួយដែលរៀបចំមិនបានល្អ (សំណង់ស៊ីវិល ក៏ដូចជាគម្រោងព័ត៌មានវិទ្យា) នឹងត្រូវចំណាយអស់ប្រាក់ច្រើនដើម្បីសម្រេចគោលដៅ ព្រោះគេត្រូវពិភាក្សាជាប់ជានិច្ចជាមួយអ្នកផ្គត់ផ្គង់ដើម្បីធ្វើការកែប្រែផ្សេងៗ ។ លទ្ធផលនឹងសម្រេចបានដោយមានការយឺតយ៉ាវធៀបនឹងកាលបរិច្ឆេទដំបូង ហើយអាចជះឥទ្ធិពលអវិជ្ជមានដល់ទឹកចិត្តរបស់ក្រុមការងារ អត្ថគាហកៈចុងក្រោយ និង អ្នកប្រើប្រាស់ ។

**ក្រុមការងារគម្រោង:** ក្រុមការងារគម្រោងត្រូវដឹកនាំអោយប្រធានម្នាក់ ដែលដាក់ចេញនូវផែនការសកម្មភាពលម្អិត ផ្តល់ការលើកទឹកចិត្តដល់ក្រុមការងារ ផ្តល់ព័ត៌មានដល់ដៃគូ និងតាមដានវឌ្ឍនភាពនៃការអនុវត្តគម្រោង ។ សមាជិករបស់ក្រុមការងារមានការទទួលខុសត្រូវផ្សេងៗគ្នា តាមសកម្មភាព និង ថវិកាដែលបានគ្រោងទុក ។ ពួកគេត្រូវមានសមត្ថភាពបច្ចេកទេសគ្រប់គ្រាន់ ក្នុងការបំពេញការងាររបស់ពួកគេ ។

**ដៃគូ:** ត្រូវផ្តល់ព័ត៌មានពីវឌ្ឍនភាពគំរោង ការលំបាកដែលបានជួបប្រទះ និងដំណោះស្រាយ ដែលគួរអនុវត្ត ។

**អ្នកប្រើប្រាស់** : គេត្រូវដឹងពីអ្នកប្រើប្រាស់ចាប់តាំងពីពេលរៀបចំគម្រោង ដោយត្រូវយល់ពីកំហិត និងត្រូវសហការអោយបានជិតស្និទ្ធនៅក្នុងការអនុវត្តគម្រោង ។ ត្រូវរៀបចំវគ្គបណ្តុះបណ្តាលអោយបានសមស្រប ដើម្បីអោយអ្នកប្រើប្រាស់អាចប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យាបានភ្លាម បន្ទាប់ពីការប្រគល់- ទទួលផលិតផលពីគម្រោង ។

**អ្នកផ្គត់ផ្គង់** : គឺជាសហការីក្នុងការអនុវត្តសេវាសាធារណៈ ប៉ុន្តែមានសិទ្ធិទទួលបាននូវលាភការប្រកបដោយយុត្តិធម៌ ដែលអាចធានាសុវត្ថិភាពហិរញ្ញវត្ថុ និង ការរីកចម្រើនរបស់ពួកគេ ។

**ការធ្វើផែនការនីយកម្មគម្រោង** : គម្រោង (ធំ) តែងតែមានការចាប់ផ្តើម និង មានចុងបញ្ចប់ ។ ការរៀបចំធ្វើផែនការនីយកម្ម ត្រូវមានចំណុចចាប់ផ្តើម ការរីកដាលនូវសកម្មភាព និងការប្រមូលផ្តុំសកម្មភាពដើម្បីខិតទៅជិតចំណុចបញ្ចប់ (ការបញ្ចប់គម្រោង និង ការប្រគល់- ទទួល) ។ គម្រោងដែលរៀបចំមិនបានល្អអាចមើលឃើញភ្លាមៗតែម្តង ។ ចំនួនភារកិច្ចមិនត្រូវមានច្រើនពេកទេ: គឺត្រូវមានក្នុងរង្វង់ ៥០ ជាការល្អ ។ ដំណាក់កាលរៀបចំសកម្មភាពលម្អិតជាងផែនការ ដោយធានាអោយមានការបែងចែកភារកិច្ចអោយស៊ីចង្វាក់គ្នា និង ស្ថិតក្នុងលក្ខខណ្ឌដូចៗគ្នា ។ ធនធាន និងចំណាយត្រូវផ្សារភ្ជាប់ជាមួយនឹងភារកិច្ច ។ គេត្រូវកំណត់អោយច្បាស់នូវទិសដៅដែលត្រូវអនុវត្ត និង សកម្មភាពលម្អិតជាងនេះទៀត ។ ការសម្រេចបាននូវការអនុវត្តគម្រោងតាមកាលបរិច្ឆេទ គឺអាស្រ័យលើការរៀបចំផែនការសកម្មភាពលម្អិត និង ការអនុវត្តផែនការសកម្មភាពនេះ អោយបាន



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

សម្រេចតាមកាលបរិច្ឆេទនៃផែនការសកម្មភាពនីមួយៗ ។ ដើម្បីគ្រប់គ្រងនូវថ្លៃដើម និង ធនធាននៃគម្រោងមួយ គេអាចប្រើនូវកម្មវិធីព័ត៌មានវិទ្យាពិសេស ក្នុងគោលដៅធានាអោយបាននូវប្រសិទ្ធភាពការងារ ។

# ផ្នែកទី ៤

# កំណែទម្រង់ការគ្រប់គ្រងប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

## ១. ចក្ខុវិស័យនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

គោលដៅចំបង គឺសំដៅដាក់ចេញកម្រិតស្តង់ដារនៃការគ្រប់គ្រង និង គណនេយ្យភាពឱ្យកាន់តែខ្ពស់ថែមទៀត ក្នុងការកៀងគរពលប្រភពធនធានចរន្ត និង មូលធនរបស់រាជរដ្ឋាភិបាល (ចរន្ត និងជាមូលធន) ព្រមទាំងការប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិ នូវបណ្តាធនធានទាំងនេះ ក្នុងកិច្ចប្រតិបត្តិការអនុវត្តយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ និង កម្មវិធីជាអាទិភាពផ្សេងៗទៀតរបស់រាជរដ្ឋាភិបាល ។

ដូច្នេះ **កម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ** ដែលបានរៀបចំឡើងនេះ នឹងត្រូវកសាងឡើងជាជំហានៗយ៉ាងខ្ជាប់ខ្ជួន ដោយផ្អែកលើរបៀបវារៈសំខាន់ៗបួនដែលបានកំណត់អាទិភាព និង ដំណាក់កាលអនុវត្តន៍ច្បាស់លាស់ គឺ៖

***ទីមួយ-*** ថវិកាដែលកាន់តែអាចជឿទុកចិត្តបានច្រើនឡើង

***ទីពីរ-*** គណនេយ្យភាពហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាព

***ទីបី-*** របៀបវារៈគោលនយោបាយរបស់រាជរដ្ឋាភិបាលត្រូវបានកំណត់ជាអាទិភាពត្រឹមត្រូវ និងមានលទ្ធភាពពេញលេញ

***ទីបួន-*** មន្ត្រីគ្រប់គ្រងរបស់រាជរដ្ឋាភិបាល នឹងមានគណនេយ្យភាពពេញលេញចំពោះលទ្ធផលនៃការអនុវត្តន៍កម្មវិធី ។

ទន្ទឹមនឹងនោះ កម្មវិធីនេះ នឹងដំណើរការក្នុងដំណាក់កាលបួន៖

**ដំណាក់កាលទី ១**: គឺការអនុវត្តផែនការសកម្មភាពរយៈពេលខ្លី រួមមានគ្រប់សកម្មភាព និង វិធានការទាំងអស់ ដែលសំដៅសម្រេចឱ្យបាននូវគោលដៅនៃរបៀបវារៈទី ១ គួបផ្សំជាមួយនឹងសកម្មភាពផ្សេងៗទៀតសម្រាប់ត្រៀមលក្ខណៈអនុវត្តរបៀបវារៈក្រោយៗទៀតដែលត្រូវអនុវត្តក្នុងរយៈពេលវែង ។

**ដំណាក់កាលទី** ២ និង **ដំណាក់កាលទី** ៣: គឺជាផែនការសកម្មភាពរយៈ ពេលមធ្យមសម្រាប់អនុវត្តនៅក្រោយពេលបញ្ចប់ដំណាក់កាលទី ១ ហើយ

**ដំណាក់កាលទី** ៤ គឺជាផែនការសកម្មភាពរយៈពេលវែង ដែលជាដំណាក់កាលឈានទៅសម្រេចគោលដៅចុងក្រោយនៃចក្ខុវិស័យនេះ ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

និយាយជារួម **ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជា** ដែលចង់បាន គឺជាប្រព័ន្ធមួយបំពេញបាននូវចរិតលក្ខណៈសំខាន់ៗ មានសង្គតិភាពទៅនឹងនិយាម និងទំលាប់ប្រតិបត្តិល្អៗ ។ ប្រព័ន្ធរួមនេះនឹងមានអនុប្រព័ន្ធនានាពាក់ព័ន្ធនឹងប្រតិបត្តិការ ការពិនិត្យតាមដាន និង ការវាយតម្លៃ ។

## ១.១. ចរិតលក្ខណៈសំខាន់ៗនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់កម្ពុជា ត្រូវបង្កើតឡើងតាមរបៀបមួយដែលធ្វើឱ្យប្រព័ន្ធនេះមានរចនាសម្ព័ន្ធ និង លទ្ធភាពដំណើការល្អប្រសើរជាបណ្តើរៗ ទៅតាមលក្ខណៈដូចតទៅ ÷

***ទី១.*** ការបែងចែកតួនាទី និងអំណាចសារពើពន្ធ ស្របទៅតាមច្បាប់ សម្រាប់ថ្នាក់ជាតិ ថ្នាក់ខេត្ត និងថ្នាក់មូលដ្ឋាន ប៉ុន្តែត្រូវស្ថិតនៅក្រោមប្រព័ន្ធថវិកាឯកភាពមួយ ដែលគ្របដណ្តប់នៅគ្រប់ស្ថាប័នរបស់រាជរដ្ឋាភិបាល និង ទៅតាមមុខងារ កម្មវិធី និង គម្រោងនានា ។

***ទី២.*** ក្របខ័ណ្ឌការងារផែនការនីយកម្ម និង កម្មវិធីមួយ ដែលមានសង្គតិភាព ហើយមានវិសាលភាពគ្របដណ្តប់លើគ្រប់វិស័យ នៅក្នុងនោះ ប្រតិបត្តិការថវិកាត្រូវធ្វើចំណាត់ថ្នាក់លើមូលដ្ឋានកម្មវិធី មុខងាររដ្ឋបាល និង សេដ្ឋកិច្ច ដែលកំណត់ច្បាស់អំពីចំណាយផ្តោតលើការកាត់បន្ថយភាពក្រីក្រ និង ការគាំទ្រដល់ទិសដៅរួមនៃការគ្រប់គ្រងចំណាយសាធារណៈ ក្នុងគោលបំណងសម្រេចលទ្ធផលជាគោលនយោបាយនេះ ។

***ទី៣.*** ក្របខ័ណ្ឌការងារចំណាយរយៈពេលមធ្យម ដែលជាប្រតិបត្តិការមួយសម្រាប់គ្រប់គ្រងកម្មវិធីរយៈពេលច្រើនឆ្នាំ ។

***ទី៤.*** ថវិកាត្រូវគ្របដណ្តប់លើគ្រប់ទិដ្ឋភាពនៃប្រតិបត្តិការរបស់រាជរដ្ឋាភិបាល រួមទាំងហិរញ្ញប្បទានថវិការយៈពេលវែង និងផែនការគ្រប់គ្រងបំណុល ព្រមទាំងផែនការរកប្រភពធនធានផ្សេងទៀត ដែលបញ្ចូលគ្រប់ផ្នែកហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាល មានដូចជាអចលនៈទ្រព្យ និង ទ្រព្យសម្បត្តិផ្សេងៗ រួមទាំងបំណុលផងដែរ ។

***ទី៥.*** ការរៀបចំថវិកា មានឥទ្ធិពលលើសមាសធាតុលើកទឹកចិត្ត ទំហំការបណ្តុះបណ្តាល ការបែងចែកមន្ត្រីរាជការ និង មានឥទ្ធិពលផ្សេងៗទៀតទៅលើកម្មវិធី និងគោលនយោបាយរបស់រាជរដ្ឋាភិបាល ។

***ទី៦.*** ការទិញ ការបែងចែក ការប្រើប្រាស់ និងការទូទាត់បញ្ចេញរាល់ទ្រព្យសម្បត្តិ និង ធនធានរបស់រាជរដ្ឋាភិបាល រួមទាំងធនធានមនុស្សផងដែរ គឺត្រូវមានលក្ខណៈបើកចំហ ប្រកួតប្រជែង អព្យាក្រឹត្យ មិនប្រកាន់ពូជសាសន៍ និង មានតម្លាភាព ។ រាជរដ្ឋាភិបាលនឹងបង្កើត និង អនុវត្តវិធានច្បាប់យ៉ាងច្បាស់លាស់ដើម្បីលើកតម្កើង «តម្លៃនៃប្រាក់» សម្រាប់លទ្ធកម្មទំនិញ និងសេវា ។

***ទី៧.*** រាជរដ្ឋាភិបាលមានកាតព្វកិច្ចឆ្លើយតបយ៉ាងឆាប់រហ័ស ច្បាស់លាស់ និងជាសាធារណៈចំពោះគ្រប់បញ្ហាទាំងអស់ ដែលកើតមានឡើងក្នុងកំឡុងពេលអនុវត្តថវិកា ។

***ទី៨.*** ការដាក់ចេញប្រព័ន្ធគណនេយ្យ និងប្រព័ន្ធគ្រប់គ្រងព័ត៌មានថវិកា និង ហិរញ្ញវត្ថុមួយ ដោយប្រើប្រាស់កុំព្យូទ័រជាលក្ខណៈសមាហរណកម្ម និង គ្រប់ជ្រុងជ្រោយ ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

***ទី៩.*** ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នឹងរៀបចំស្តង់ដារណែនាំ និង ការពិនិត្យតាមដានលើការគ្រប់គ្រងហិរញ្ញវត្ថុនៅតាមបណ្តាក្រសួង- ស្ថាប័នពាក់ព័ន្ធ និង ទីភ្នាក់ងារចំណាយនានា ក្នុងនោះមានស្តង់ដារសវនកម្មផ្ទៃក្នុងផងដែរ ។

***ទី១០.*** ក្រសួង និងទីភ្នាក់ងារចំណាយនីមួយៗ ត្រូវបង្កើតគណៈកម្មាធិការសវនកម្មផ្ទៃក្នុងមួយ ដើម្បី (ក). ដឹកនាំការរៀបចំ និង គ្រប់គ្រងផែនការសវនកម្មផ្ទៃក្នុងប្រចាំឆ្នាំ (ខ). ត្រួតពិនិត្យ និង ផ្តល់ការគាំទ្រដល់ការអនុវត្តសវនកម្មនានា ។

***ទី១១.*** អាជ្ញាធរជាតិសវនកម្ម ត្រូវផ្តល់របាយការណ៍សវនកម្ម ដែលត្រូវប្រកាសផ្សាយជាសាធារណៈ ហើយ រាជរដ្ឋាភិបាលត្រូវធ្វើសកម្មភាព ឬ ចំណាត់ការជាបន្ទាន់ ទៅតាមអនុសាសន៍ ដែលលើកឡើងក្នុងរបាយការណ៍សវនកម្មទាំងនោះ ។

***ទី១២.*** ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវបានរៀបចំឡើង ដើម្បីស្វែងរកការអនុវត្តទាំងក្នុងការប្រើប្រាស់ធនធាន និង ការសម្រេចលទ្ធផលជាគោលនយោបាយ តាមរយៈការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឱ្យបានល្អប្រសើរ ។ ទន្ទឹមនឹងនោះ ជាបណ្តើៗប្រព័ន្ធនេះ ត្រូវស្វែករក ឬ ធានាតម្លៃនៃប្រាក់ជាអតិបរមាក្នុងរយៈពេលវែងចំពោះការប្រើប្រាស់ធនធាន ឬ ទ្រព្យសម្បត្តិរបស់រដ្ឋ ។

## ១.២. អនុប្រព័ន្ធប្រតិបត្តិការនានានៃប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

ដើម្បីស្ថាបនាប្រព័ន្ធហិរញ្ញវត្ថុសាធារណៈមួយមានលក្ខណៈល្អប្រសើរ ដូចដែលបានបរិយាយខាងលើ ប្រព័ន្ធនេះចាំបាច់ត្រូវគួបផ្សំជាមួយនឹងអនុប្រព័ន្ធប្រតិបត្តិការមួយចំនួនទៀត ។ អនុប្រព័ន្ធប្រតិបត្តិការទាំងនោះរួមមាន ÷

**ទី១. ប្រព័ន្ធនៃដំណើរប្រតិបត្តិការ និង គណនេយ្យ:** ជាការពិត អភិក្រមសង្គតិភាពនៃគណនេយ្យត្រូវបានប្រើប្រាស់នៅក្នុងគ្រប់ក្រសួង- ស្ថាប័នរាជរដ្ឋាភិបាល ដែលជាបឋមផ្អែកលើមូលដ្ឋាន «គណនេយ្យសាច់ប្រាក់» ក្នុងឆ្នាំសារពើពន្ធនីមួយៗ ។ ក្នុងពេលអនាគត នឹងមានការពិចារណាដល់ការផ្លាស់ប្តូរទៅរក «គណនេយ្យបង្គរ» នូវអ្វីដែលពាក់ព័ន្ធនឹងការប្រើប្រាស់ធនធានក្នុងមួយឆ្នាំៗ ដូចជាថ្លៃពលកម្ម ព្រមទាំងទំនិញ និងសេវា ។

**ទី២. ប្រព័ន្ធថវិកា:** ជាទូទៅ ថវិកាប្រចាំឆ្នាំរបស់អណាប័កទាំងអស់ ត្រូវរៀបចំក្នុងបរិការណ៍នៃការប៉ាន់ស្មានដោយប្រាកដនិយម សម្រាប់រយៈពេលច្រើនឆ្នាំ ហើយតួលេខនោះ ត្រូវបានផ្សព្វផ្សាយភ្ជាប់ជាមួយថវិកា ។ ការអនុវត្តដំណើររំកិល នៅក្នុងការប៉ាន់ស្មានថវិកាច្រើនឆ្នាំ មានន័យថាឆ្នាំទី ២ ក្នុងជុំនីមួយៗ គឺជាមូលដ្ឋានចាប់ផ្តើមសម្រាប់រៀបចំថវិកាឆ្នាំបន្ទាប់ ។

**ទី៣. ប្រព័ន្ធគៀងគរធនធាន:** *( ចំណូលសារពើពន្ធ និងមិនមែនសារពើពន្ធ ជំនួយខាងក្រៅ ហិរញ្ញប្បទាន និងបំណុល)* ការប្រើប្រាស់ប្រកបដោយប្រសិទ្ធភាពនូវសមត្ថភាពបង្កើនចំណូល តាមរយៈការអនុវត្តអភិក្រមតុល្យភាព ក្នុងការប្រមូលចំណូលពន្ធដារ (ពន្ធផ្ទាល់ និង ពន្ធប្រយោល) និង ការយកកម្រៃផ្សេងៗពីសាធារណៈជន ព្រមទាំងការគៀងគរចំណូលពីប្រភពហិរញ្ញប្បទានផ្សេងទៀត (រួមមានជំនួយពីក្រៅប្រទេស និងកម្ចីក្នុង និង ក្រៅស្រុក) ។


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

**ទី៤. ប្រព័ន្ធបច្ចេកវិទ្យា:** ពោល គឺការធានាឱ្យគ្រប់អ្នកពាក់ព័ន្ធអាច ទទួលបានទិន្នន័យដែលត្រឹមត្រូវ អាចទុកចិត្តបាន និង ទាន់ពេលវេលា តាមរយៈការប្រើប្រាស់ដោយមានលក្ខណៈសមាហរណកម្មនូវបច្ចេកវិទ្យាព័ត៌មានទំនើប ។ ក្នុងទិសដៅនេះ យើងត្រូវបើកចំហដល់គ្រប់ភាគីពាក់ព័ន្ធទាំងអស់ (ក្នុង និងក្រៅរដ្ឋាភិបាល) ដែលមានចំណាប់អារម្មណ៍ ចំពោះការពិនិត្យឡើងវិញនូវលទ្ធផល ការអនុវត្តថវិកា ដោយប្រៀបធៀបនឹងផែនការប្រចាំឆ្នាំ តាមរយៈតារាងទិន្នន័យមួយច្បាស់លាស់ និង មានតម្លាភាព ។

## ១.៣. អនុប្រព័ន្ធពិនិត្យតាមដាន និង វាយតម្លៃ

លក្ខណៈគន្លឹះនៃចក្ខុវិស័យសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គ្របដណ្តប់លើផ្នែកមួយចំនួនដូចខាងក្រោម៖

**ទី១. ភាពប្រាកដនិយមនៃថវិកា:** ថវិកា គឺត្រូវមានភាពប្រាកដនិយម និង អនុវត្តទៅបានជាលទ្ធផលដូចដែលគេរំពឹងទុកក្នុងរបៀបមួយដែលគេអាចទស្សទាយទុកជាមុន ។

**ទី២. ថវិកាពឹងផ្អែកលើគោលនយោបាយ និង ភាពគ្រប់ជ្រុងជ្រោយ:** ថវិកាប្រមូលផ្តុំរាល់ប្រតិបត្តិការសារពើពន្ធ ដែលពាក់ព័ន្ធនានា ។ ថវិកាក៏ត្រូវបានរៀបចំឡើង ក្នុងវិធីមួយដែលមានរបៀបរៀបរយដោយអនុវត្តទៅតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ។

**ទី៣. ការគ្រប់គ្រងសារពើពន្ធ:** ស្ថានភាពសារពើពន្ធសរុប និង ហានិភ័យ នឹងត្រូវបានពិនិត្យតាមដាន និង គ្រប់គ្រងយ៉ាងហ្មត់ចត់ ។

**ទី៤. ព័ត៌មាន:** ត្រូវមានកំណត់ត្រា និងព័ត៌មានគ្រប់គ្រាន់ស្តីពីសារពើពន្ធ ចំណូល និងចំណាយដែលត្រូវបានចងក្រងរក្សាទុក និង ផ្សព្វផ្សាយ ដើម្បីឆ្លើយតបទៅនឹងតម្រូវការសម្រេចចិត្ត ការត្រួតពិនិត្យ និង ការគ្រប់គ្រង ។

**ទី៥. ការត្រួតពិនិត្យ:** ត្រូវមានការត្រួតពិនិត្យ និង កាតព្វកិច្ចទទួលខុសត្រូវប្រកបដោយប្រសិទ្ធភាពក្នុងប្រតិបត្តិការប្រើប្រាស់មូលនិធិសាធារណៈ ។

**ទី៦. គណនេយ្យភាព និងតម្លាភាព:** ត្រូវមានយន្តការដែលមានលក្ខណៈប្រកបដោយគណនេយ្យភាព និង តម្លាភាព ។

**ទី៧. ភាពច្បាស់លាស់ និង គណនេយ្យភាព:** ត្រូវមានក្របខណ្ឌការងារច្បាប់ និង ស្ថាប័នប្រកបដោយភាពច្បាស់លាស់ សម្រាប់ទទួលខុសត្រូវលើមុខងារ និង ចំណាយនៅគ្រប់លំដាប់ថ្នាក់របស់រាជរដ្ឋាភិបាលព្រមទាំងការគ្រប់គ្រងរបស់អាណាប័កថវិកាប្រកបដោយគណនេយ្យភាព ។

**ទី៨. តម្លៃនៃប្រាក់** : ត្រូវធានាឱ្យបានក្នុងកំរិតអតិបរមាតម្លៃនៃប្រាក់ ក្នុងការប្រើប្រាស់ធនធានសាធារណៈ (ឧទាហរណ៍ ការកាត់បន្ថយតម្លៃសំភារៈផ្គត់ផ្គង់តាមរយៈការធ្វើលទ្ធកម្មជាប្រចាំ) ។

**ទី៩. ប្រតិកម្មឆ្លើយតប** : ការគ្រប់គ្រងសារពើពន្ធ និង ថវិកា ត្រូវមានលក្ខណៈរស់រវើក (ឧទាហរណ៍ ត្រូវមានការត្រួតពិនិត្យឡើងវិញ ក្នុងរយៈពេលពាក់កណ្តាលឆ្នាំដំបូងនូវការងាររបស់ស្ថាប័នស្តីពីលទ្ធផលអនុវត្តន៍


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ថវិកា ដែលនឹងត្រូវក្លាយជាមូលដ្ឋានសម្រាប់ពិចារណាក្នុងការអនុវត្តថវិកានៅពាក់កណ្តាលឆ្នាំបន្ទាប់ និង សម្រាប់ការរៀបចំថវិកានៅឆ្នាំក្រោយៗទៀត) ។

**ទី១០. វិជ្ជាជីវនិយម:** ត្រូវបង្កើតឱ្យមានវិជ្ជាជីវនិយម ក្នុងប្រព័ន្ធគ្រប់គ្រងមន្ត្រីរាជការ និង ការលើកទឹកចិត្ត (ឧទាហរណ៍ការកសាងក្រុមស្នូលនៃអ្នកជំនាញការផ្នែកបច្ចេកទេស) ។

## ១.៤. យុទ្ធសាស្ត្ររយៈពេលវែង

មានដំណាក់កាល ៤ នៃដំណើរការកំណែទម្រង់ដែលរដ្ឋាភិបាលត្រូវអនុវត្ត បន្ទាប់ពីគោលដៅដែលបានកំណត់រួចហើយទទួលបានជោគជ័យ មុននឹងបន្តឈានទៅអនុវត្តជំហានបន្តបន្ទាប់ទៀត ។ ដំណាក់កាលនីមួយៗត្រូវរៀបចំដើម្បីផ្លាស់ប្តូរមួយជំហានម្តងៗ ក្នុងការអនុវត្តឱ្យមានការផ្លាស់ប្តូរទាំងស្រុងក្នុងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង ផ្តល់របៀបវារៈ សម្រាប់ការអនុវត្តន៍ជំហានបន្តបន្ទាប់ទៀត ។

**ទី១. ថវិកាដែលកាន់តែអាចជឿទុកចិត្តបានច្រើនឡើង:** នៅដំណាក់កាលដំបូង រាជរដ្ឋាភិបាលនឹងប្រឹងប្រែងសម្រេចឱ្យបាននូវស្ថានភាពមួយ ដែលថវិកាទទួលបានជំនឿទុកចិត្តច្រើន ក្នុងន័យជាឧបករណ៍យុទ្ធ-សាស្ត្រមួយ សម្រាប់ការគ្រប់គ្រងធនធានសាធារណៈប្រចាំថ្ងៃ ពីព្រោះថវិកាផ្តល់ជាធនធាន ដែលអាចទស្សទាយទុកជាមុន និង មានការទទួលខុសត្រូវចំពោះមន្ត្រីគ្រប់គ្រងថវិកានីមួយៗ ។ ដូច្នេះគេអាចឈានទៅអនុវត្តជំហានបន្ត ដែលជម្រុញឱ្យមន្ត្រីគ្រប់គ្រងថវិកាមានគណនេយ្យភាពចំពោះការប្រើប្រាស់ធនធាន ដែលមានលក្ខណៈប្រកបដោយភាពត្រឹមត្រូវ ប្រសិទ្ធភាព និង ភាពស័ក្តិសិទ្ធិ ។

**ទី២. គណនេយ្យភាពហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាព:** ផ្លាស់ប្តូរទំលាប់ «និទណ្ឌភាព» ចំពោះការប្រព្រឹត្តិខុស ឬ ការមិនគោរពច្បាប់ដោយអាណាប័កថវិកា ។ រាជរដ្ឋាភិបាល នឹងរិតបន្តឹងការគ្រប់គ្រង ដើម្បីជម្រុញអាណាប័កថវិកាឱ្យមានការទទួលខុសត្រូវ និង ផ្តល់ការលើកទឹកចិត្តចំពោះការអនុវត្តការងារល្អ ។ ។

**ទី៣. . .របៀបវារៈគោលនយោបាយរបស់រាជរដ្ឋាភិបាល ត្រូវបានកំណត់ជាអាទិភាពត្រឹមត្រូវ និង មានលទ្ធភាពពេញលេញ:** ផ្អែកលើមូលដ្ឋានដែលបានរៀបចំឡើងក្នុងជំហានមុន ដែលក្នុងនោះ ថវិកាបានក្លាយទៅជាឧបករណ៍ដែលអាចទុកចិត្តបាន សម្រាប់ការអនុវត្តគោលនយោបាយរាជរដ្ឋាភិបាលនឹងផ្តោតលើការរៀបចំបច្ចេកទេស និងសមត្ថភាពសម្រាប់វិភាគអំពីផលប៉ះពាល់គោលនយោបាយថវិកា និងភ្ជាប់ទំនាក់ទំនងអាទិភាពគោលនយោបាយ និងគោលដៅសេវា ទៅនឹងផែនការ និងការអនុវត្តថវិកា ដែលធានាថាគោលនយោបាយរបស់រាជរដ្ឋាភិបាល នឹងត្រូវបានកំណត់អាទិភាពច្បាស់លាស់ និង មានលទ្ធភាពអាចអនុវត្តបានយ៉ាងពេញលេញ ។

**ទី៤. . .មន្ត្រីគ្រប់គ្រងរបស់រាជរដ្ឋាភិបាល នឹង មានគណនេយ្យភាពពេញលេញចំពោះលទ្ធផលនៃការអនុវត្តកម្មវិធី:** ដោយជម្រុញឱ្យមានស្ថិរភាព សុក្រឹតភាព និងគោលនយោបាយ ឈានឆ្ពោះទៅរកការអនុវត្តផែនការ និង ការគ្រប់គ្រងថវិកា រាជរដ្ឋាភិបាលអាចចាប់ផ្តើមជម្រុញឱ្យមន្ត្រីគ្រប់គ្រងថវិកាមានគណនេយ្យភាព និង លើកទឹកចិត្តពួកគេឱ្យសម្រេចគោលបំណងទៅតាមគោលដៅ និងស្តង់ដារអនុវត្តន៍


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ដែលបានគ្រោងទុក ។

## ២. កម្មវិធីសកម្មភាពកំណែទម្រង់

### ២.១. ការពិពណ៌នាជារួមអំពីបណ្តាសកម្មភាពនៃកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

បណ្តាសកម្មភាពនៃ **កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ** ត្រូវបានកំណត់ដោយលម្អិត សម្រាប់ការសម្រេចបានជំហានទីមួយ ។ ចំណែកឯបណ្តាសកម្មភាពទាំងឡាយ សម្រាប់ការសម្រេចបានបណ្តាជំហានបន្តបន្ទាប់ទៀត ក៏ត្រូវបានបង្ហាញផងដែរនូវគោលការណ៍សំខាន់ៗ ។ ខាងក្រោមនេះ គឺជាការពណ៌នាពីបណ្តាសកម្មភាពទាំងនេះ ដែលបណ្តាសកម្មភាពលំអិតត្រូវបានរៀបចំឡើង សម្រាប់ជំហានទីមួយ ហើយបណ្តាសកម្មភាពគោលៗជាមូលដ្ឋាន ត្រូវបានរៀបចំឡើងសម្រាប់ជំហានទីពីរ ទីបី និងទីបួន ។ ទន្ទឹមនឹងនេះ វឌ្ឍនភាពពីជំហានមួយទៅជំហានមួយទៀត ក៏ត្រូវបានបរិយាយយ៉ាងល្អិតល្អន់ផងដែរ ។

### ២.២. បណ្តាសកម្មភាពសម្រាប់ទ្រទ្រង់ជំហានទីមួយ

គោលដៅនៃជំហានទីមួយ គឺការសម្រេចឱ្យបាននូវស្ថានភាពនៃថវិកា ដែលអាចជឿទុកចិត្តបានជាងមុន និង ជាឧបករណ៍យុទ្ធសាស្ត្រសម្រាប់ការគ្រប់គ្រងធនធានសាធារណៈប្រចាំថ្ងៃ ដោយសារតែវាអាចផ្តត់ផ្គង់ធនធានដល់អណាប័កនៃថវិកា ប្រកបដោយភាពទុកចិត្តបាន និង ទស្សន៍ទាយទុកជាមុនបាន ។ បណ្តាសកម្មភាពដែលជាគន្លឹះ និង ចាំបាច់ ដើម្បីសម្រេចឱ្យបានបណ្តាគោលបំណង ទាំងនេះ មានដូចខាងក្រោម ÷

- *អនុវត្តភាពគ្រប់ជ្រុងជ្រោយ និង ការធ្វើសមាហរណកម្មនៃថវិកា (ការរៀបចំ និង ការប្រតិបត្តិ)*
- *អនុវត្តភាពប្រាកដនិយម និង ចីរភាពនៃថវិកា*
- *បង្កើនលទ្ធភាពដល់អណាប័កថវិកា ក្នុងចំណាយថវិកាទៅតាមការដែលបានអនុម័តផ្តល់*
- *បទប្បញ្ញត្តិដើម្បីទប់ស្កាត់ការបង្កើន ការកកស្ទះការបើកផ្តល់ការទូទាត់*
- *អនុវត្តការផ្តល់ការអនុម័តលើចំណាយឥណទាននៃថវិកាបន្ថែម*
- *កសាង និង កែលម្អនីតិវិធីលទ្ធកម្ម*
- *អនុវត្តបណ្តាវិធានការអភិវឌ្ឍន៍សមត្ថភាព*
- *វិធានការលើកទឹកចិត្តនៅក្នុងក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ*
- *វិធានការលើកទឹកចិត្តនៅក្នុងបណ្តាក្រសួងសាមី*
- *ការធ្វើសមាហរណកម្មដំបូងទៅលើ បណ្តាមុខងារនៅក្នុងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ*

លទ្ធផលសកម្មភាពទាំងនេះ នឹងធ្វើឱ្យមានកំណែលម្អលើការគ្រប់គ្រងម៉ាក្រូហិរញ្ញវត្ថុ និង ការព្យាករណ៍

ជាមួយនឹងការយកចិត្តទុកដាក់កែលំអលើក្របខ័ណ្ឌនៃការកៀងគរចំណូល ដើម្បីបង្កើនទំនុកចិត្តទៅលើលទ្ធភាពនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ ក្នុងការបើកផ្តល់សាច់ប្រាក់ទៅតាមគម្រោងថវិកា ។

អណាប័កនៃថវិកានឹងមានលទ្ធភាព ក្នុងការចុះកិច្ចសន្យាលើថវិការបស់ខ្លួន ដែលត្រូវបានផ្អែកទៅលើព័ត៌មានយ៉ាងពេញលេញ និង គ្រប់ជ្រុងជ្រោយអំពីលទ្ធភាពធនធាន ដែលត្រូវបានផ្តល់ឱ្យពួកគេ ក្នុងករណីដែលពួកគេបានបង្ហាញពីសមត្ថភាពក្នុងការអនុវត្តការត្រួតពិនិត្យផ្ទៃក្នុងរបស់ពួកគេ ក្នុងការបើកផ្តល់ដល់បុគ្គលិក និង អ្នកម៉ៅការ តាមរយៈការផ្ទេរតាមគណនី ផ្តល់ជាមូលប្បទានប័ត្រ សាច់ប្រាក់ ឬ រូបភាពនៃការផ្តល់សាច់ប្រាក់ណាផ្សេងទៀត នៅក្នុងថេរវេលាមួយសមស្រប និង អាចព្យាករណ៍បាន ដោយគ្រាន់តែស្ថិតក្នុងលក្ខខណ្ឌនៃការត្រួតពិនិត្យរួមនៅថ្នាក់ម៉ាក្រូតែប៉ុណ្ណោះ ។

## ២.៣. បណ្តាសកម្មភាពសម្រាប់ទ្រទ្រង់ជំហានទីពីរ

ជំហានទីពីរ មានគោលដៅសម្រេចឱ្យបាននូវភាពប្រសើរឡើង ជាដំបូងទៅលើការត្រួតពិនិត្យផ្ទៃក្នុង និង ការធ្វើឱ្យអណាប័កមានគណនេយ្យភាព ។ បណ្តាសកម្មភាព ដើម្បីសម្រេចឱ្យបានគោលដៅនេះ រួមមាន÷

**បង្កើនគណនេយ្យភាពនៅគ្រប់លំដាប់ថ្នាក់:** បែងចែកតួនាទី មុខនាទី និង ការទទួលខុសត្រូវ (រួមទាំងចំណាយ) អោយបានច្បាស់លាស់ នៅរាល់លំដាប់ថ្នាក់នៃរដ្ឋាភិបាល ។

**កែលម្អការងារគណនេយ្យ:** ពង្រឹងការកត់ត្រាទិន្នន័យ និង បញ្ជីគណនេយ្យ និងកែលំអនីតិវិធីផ្ទៀងផ្ទាត់ ។

**កែលំអការធ្វើរបាយការណ៍:** កែលំអការធ្វើរបាយការណ៍អំពីការអនុវត្តធៀបទៅនឹងគម្រោងថវិកា និងចាប់ផ្តើមការសិក្សាតាមដានការអនុវត្តថវិកា ។

**កែលម្អការធ្វើសវនកម្ម:** ពង្រឹងសមត្ថភាពទាំងការធ្វើសវនកម្មផ្ទៃក្នុង និង ផ្ទៃក្រៅ

**កែលម្អស្ថាប័ន:** បណ្តាវិធានការពង្រឹងសមត្ថភាពស្ថាប័ន និង វិធានការជម្រុញការលើកទឹកចិត្ត

## ២.៤. បណ្តាសកម្មភាពសម្រាប់ទ្រទ្រង់ជំហានទីបី

គោលបំណងនៃជំហានទីបី គឺការធ្វើឱ្យប្រសើរឡើងនូវទំនាក់ទំនងរវាងគោលដៅជាអាទិភាព និង សេវាទៅនឹងការធ្វើផែនការ និង ការអនុវត្ត ។ ជំហានទីបី មានគោលដៅកសាងបច្ចេកទេស និង សមត្ថភាពក្នុងការវិភាគលើប្រសិទ្ធភាពថវិកា លើគោលនយោបាយ និង ការផ្សារភ្ជាប់រវាងអាទិភាព និង ចំណាយថវិកា:

**កំណែទម្រង់ថវិកាស៊ីជម្រៅ:** ដំណើរការ **ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម** ការធ្វើថវិកាពហុឆ្នាំ ការអនុវត្តបច្ចេកទេស ក្នុងការកំណត់កញ្ចប់ធនធានតាមវិស័យ នីតិវិធីវិកលពីមួយឆ្នាំទៅមួយឆ្នាំ នៃវដ្តពហុឆ្នាំ ការផ្សារភ្ជាប់ទៅនឹងដំណើរការនៃការរៀបចំផែនការយុទ្ធសាស្ត្រ ការផ្សារភ្ជាប់ការកៀងគរ និង ការប្រើប្រាស់ធនធានទៅនឹងបណ្តាគោលនយោបាយជាអាទិភាព ជាពិសេស បណ្តាយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

**កែលម្អការវិភាគ និង ការវាយតម្លៃថវិកា:** ពង្រឹងលទ្ធភាពក្នុងការគណនា និង ការវាយតម្លៃលើការស្នើចំណាយ អនុវត្តការត្រួតពិនិត្យឡើងវិញលើចំណាយ បច្ចុប្បន្នកម្មជាប្រចាំលើរាល់និយាមចំណាយ ។

**ការធ្វើទំនើបកម្មប្រព័ន្ធលទ្ធកម្មសាធារណៈ:** បន្តពង្រីកការធ្វើវិសហមជ្ឈការថវិកា និង គណនេយ្យភាព និង បន្តកែលម្អការធ្វើវិមជ្ឈការសារពើពន្ធ ។

**ពង្រីកការចូលរួមនៃសេចក្តីសម្រេចចិត្តលើការប្រើប្រាស់ធនធាន:** កំណែលំអការផ្តល់កាលានុវត្តភាពជូនអ្នកនយោបាយ និង សង្គមស៊ីវិល ដើម្បីធ្វើទិស្សមានភាព (Visibility) និង រួមចំណែកធ្វើសេចក្តីសម្រេចក្នុងការវិភាជន៍ថវិកា ។

**កែលម្អស្ថាប័ន:** បណ្តុំវិធានការពង្រឹងសមត្ថភាពស្ថាប័ន និង វិធានការជម្រុញការលើកទឹកចិត្ត ។

## ២.៥. បណ្តាសកម្មភាពសម្រាប់ទ្រទ្រង់ជំហានទីបួន

ជំហានទីបួន គឺជាជំហាននៃការធ្វើសមាហរណកម្មគណនេយ្យភាព និង ដំណើរការត្រួតពិនិត្យឡើងវិញទាំងការគ្រប់គ្រងប្រតិបត្តិការ ទាំងការគ្រប់គ្រងហិរញ្ញវត្ថុ ។ សកម្មភាពមានដូចជា៖

**កែលំអព័ត៌មាននៃប្រតិបត្តិការហិរញ្ញវត្ថុ និងសេវា:** កុំព្យូទ័រូបនីយកម្មនៃការគ្រប់គ្រងហិរញ្ញវត្ថុតាមរយៈប្រព័ន្ធព័ត៌មាន កុំព្យូទ័រូបនីយកម្មការចុះបញ្ជីទ្រព្យសម្បត្តិរដ្ឋ កុំព្យូទ័រកម្មនៃការបញ្ចូលទិន្នន័យនៃការអនុវត្ត និង ប្រតិបត្តិការថវិកា និង ការប្តូរទៅប្រព័ន្ធ «គណនេយ្យអចលនវត្ថុ» ដើម្បីធ្វើឱ្យកាន់តែប្រសើរឡើងភាពស៊ីគ្នារវាងការប្រើប្រាស់ធនធាន និង លទ្ធផលដែលសម្រេចបាន ។

**បង្កើនការបង្ហាញលទ្ធផលដែលសម្រេចបាន:** ការធ្វើរបាយការណ៍ប្រចាំឆ្នាំអំពីប្រតិបត្តិការថវិកា និង សេវាដោយសាម៉ីក្រសួង ហើយធ្វើប្រឹក្សាជាមួយសាធារណៈជន និង អ្នកនយោបាយអំពីលទ្ធផលដែលសម្រេចបាន។

**ការទទួលអនុសាសន៍លើសេចក្តីសម្រេចចិត្តក្នុងការប្រើប្រាស់ធនធាន:** ត្រួតពិនិត្យឡើងវិញនូវលទ្ធផលដែលសម្រេចបាន និង បង្កើតនីតិវិធីក្នុងការបញ្ចូលបណ្តាមេរៀន និង បទពិសោធន៍ទាំងឡាយ និង ដើម្បីកែលម្អ លើសេចក្តីសម្រេចចិត្តប្រើប្រាស់ធនធាននៅក្នុងអនាគត ។

**កែលំអស្ថាប័ន:** បណ្តុំវិធានការពង្រឹងសមត្ថភាពស្ថាប័ន និង វិធានការជម្រុញការលើកទឹកចិត្ត ។

## ៣. យុទ្ធសាស្ត្រ: ការអនុវត្តន៍ជាដំណាក់កាល ដើម្បីកសាងមួយជំហានម្តងៗ

ដូចដែលបានគូសបញ្ជាក់ខាងលើ ដើម្បីកែលំអប្រព័ន្ធគ្រប់គ្រង និង ប្រតិបត្តិការហិរញ្ញវត្ថុសាធារណៈនៅកម្ពុជាទាមទារឱ្យមានដំណាក់កាលជាច្រើន ដើម្បីឆ្លើយតបទៅនឹងស្តង់ដារមូលដ្ឋាននៃប្រព័ន្ធទំនើបរបស់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ។ ដោយសារហេតុផលមួយចំនួន ដែលជំហានទាំងអស់នេះ មិនអាចយកមកអនុវត្តព្រមគ្នាតែម្តងបានទេ ប្រការនេះត្រូវធ្វើទៅតាមលំដាប់លំដោយសមស្រប និងទៅតាមជំហានទីមួយៗ ។ ហេតុផលទាំងនោះ រួមមាន: (ទី១). បណ្តាជំហានមួយចំនួន អាចអនុវត្តទៅបានលុះត្រាតែបណ្តាជំហានដទៃទៀត


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ត្រូវបានបញ្ចប់ដោយជោគជ័យ ។ (ទី២)• ការសម្រេចយកមកអនុវត្តនូវបណ្តាជំហាននីមួយៗត្រូវស្ថិតនៅក្នុងរង្វង់ដែលអាចគ្រប់គ្រង ជាពិសេស ចំពោះលទ្ធភាពគ្រប់គ្រងនៃមន្ត្រីសំខាន់ៗរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រួមទាំងមន្ត្រីជាន់ខ្ពស់ ដែលអាចផ្តល់ការដឹកនាំ និង ទិសដៅក្នុងការអនុវត្តប្រកបដោយប្រសិទ្ធភាព ។ (ទី៣)• ល្បឿននៃដំណើរការកម្មវិធីកំណែទម្រង់ក៏ជាកត្តាកំណត់ជោគជ័យកម្មវិធីនេះដែរ ។ (ទី៤)• វដ្តថវិកាប្រចាំឆ្នាំ ក៏អាចជាកត្តាកំណត់ល្បឿនដែលសមាសធាតុនៃគម្រោងកម្មវិធីអាចដំណើរការបាន មានន័យថា ប្រសិនបើពួកគេមិនបានចាប់អនុវត្តនៅត្រង់ចំណុចមួយសមស្របក្នុងវដ្តនៃឆ្នាំទេនោះ គេត្រូវរង់ចាំរហូតដល់ចំណុចត្រឹមត្រូវក្នុងវដ្តនៃឆ្នាំបន្ទាប់ ។

ជំហានទាំងបួន ត្រូវតែកសាងឡើងម្តងមួយៗ ដោយបន្ទុបពីលើគ្នា ។ ដើម្បីប្រសិទ្ធភាពក្នុងការអនុវត្តកម្មវិធីសកម្មភាពជំហានដំបូង គប្បីផ្តោតទៅលើការកែលំអបណ្តាផ្នែកសំខាន់ៗជាមូលដ្ឋាន ដែលមានលក្ខណៈទន់ខ្សោយ នៅក្នុងការប្រតិបត្តិ ។ លុះត្រាតែបណ្តាផ្នែកសំខាន់ជាមូលដ្ឋានទាំងនេះ ត្រូវបានកែលម្អត្រឹមត្រូវទើបបណ្តាជំហាន ដែលសំដៅកែលំអក្នុងកំរិតខ្ពស់ និងមានលក្ខណៈជាប្រព័ន្ធនោះ អាចត្រូវបានអនុវត្ត ។

ទស្សនាទាន ជាជំហានៗនេះ ត្រូវបានប្រើប្រាស់ដើម្បីជាជំនួយដល់ការកំណត់លំដាប់លំដោយនៃកំណែលម្អ ដែលមានលក្ខណៈជាប្រព័ន្ធនៃសកម្មភាពកំណែទម្រង់ ។ ដូច្នេះហើយ បានជាជំហានទីមួយ ត្រូវបានរៀបចំឡើងដោយផ្តោត ទៅលើការកែលម្អនូវមូលដ្ឋានប្រតិបត្តិការសំខាន់ៗ ដែលមានភាពទន់ខ្សោយ និង ដែលកំពុងរាំងស្ទះដល់ភាពដែលអាចជឿទុកចិត្តបាននៃថវិកា ។ លុះត្រាតែភាពខ្វះខាត និងទន់ខ្សោយនៃមូលដ្ឋានប្រតិបត្តិការសំខាន់ៗទាំងនេះ ត្រូវបានកែលម្អ និង ពង្រឹង ទើបបណ្តាជំហានដទៃទៀតអាចចាប់ផ្តើមកសាងមូលដ្ឋានដើម្បីបង្កើនកម្រិតប្រព័ន្ធការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលត្រូវបានកំណត់នៅក្នុងជំហានទីពីរ ជំហានទីបី និង ជំហានទីបួន ។

កម្មវិធីកំណែទម្រង់នេះ ត្រូវដំណើរការជាបួនដំណាក់កាល ។ ដំណាក់កាលទីមួយ រួមមានៈ (១)• បណ្តាសកម្មភាពចាំបាច់សម្រាប់កសាងជំហានទីមួយ ព្រមទាំង (២)• បណ្តាសកម្មភាពដែលបាន និងកំពុងបន្តកសាងលក្ខណៈពិសេសរបស់ **ប្រព័ន្ធការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ** សម្រាប់គាំទ្រដល់បណ្តាជំហានបន្តបន្ទាប់ ប៉ុន្តែត្រូវការចាប់ផ្តើមមុនពេលយ៉ាងយូរ ។ សកម្មភាពទាំងអស់នេះ រួមបញ្ចូលគ្នាបង្កើតបានជាបណ្តាសកម្មភាពសម្រាប់ដំណាក់កាលទីមួយនៃកម្មវិធីកំណែទម្រង់ ។ ដូច្នេះកម្មវិធីកំណែទម្រង់ រួមមានបួនដំណាក់កាលដែលដំណាក់កាលទីមួយ គឺជាដំណាក់កាលដែលមានរយៈពេលខ្លី ។ ដំណាក់កាលនីមួយៗនាំមកនូវការកសាងជំហានថ្មីនៃបណ្តាលក្ខណៈពិសេសរបស់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ហើយបូកបន្ថែមនូវបណ្តាសកម្មភាពកំពុងដំណើរការអភិវឌ្ឍលើបណ្តាលក្ខណៈពិសេសរបស់ **ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ** សម្រាប់គាំទ្រដល់ការកសាងជំហានបន្ទាប់ ។ ដូច្នេះ ដំណាក់កាលទីពីរ នឹងបន្តអនុវត្តបណ្តាសកម្មភាព ដែលបានចាប់ផ្តើមក្នុងដំណាក់កាលទីមួយ បូករួមទាំងបណ្តាសកម្មភាពថ្មី ដែលចាំបាច់ដើម្បីសម្រេចបានជំហានទីពីរ និង ជាបន្តបន្ទាប់ ដូចគ្នានេះនៅក្នុងដំណាក់កាលទីបី និង ទីបួន ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

### ៤. កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទីមួយ

ដំណាក់កាលទីមួយនៃ **កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ** ភាគច្រើន គឺជាបណ្តាសកម្មភាព ដើម្បីគាំទ្រដល់ការកសាងជំហានទីមួយ គឺៈ ការសម្រេចឱ្យបានភាពអាចជឿទុកចិត្តបាននៃថវិកា ។ ទោះបីជាយ៉ាងនេះក៏ដោយ ក៏ត្រូវតែបញ្ចូលនូវបណ្តាសកម្មភាពដទៃទៀតផងដែរ ដែលនឹងជួយធ្វើឱ្យជំហានទីមួយមានភាពរឹងមាំ និង ក្នុងគោលបំណងដ៏សំខាន់ គឺដើម្បីគាំទ្រដល់បណ្តាជំហានបន្តបន្ទាប់ទាំងបី ។ ទាំងនេះ រួមមានសកម្មភាពដូចខាងក្រោម÷

ទោះបីជាត្រូវការពេលវេលាយូរ ក្នុងការអនុវត្តប្រព័ន្ធចំណាត់ថ្នាក់ឯកភាពថ្មី និង **ការគ្រប់គ្រងហិរញ្ញវត្ថុតាមប្រព័ន្ធព័ត៌មានវិទ្យា** ដែលស្ថិតនៅក្នុងជំហានទីពីរ និង ជំហានទីបួនក៏ដោយ កិច្ចការសំខាន់ គឺត្រូវរៀបចំការងារនេះឱ្យបានមុន គឺយ៉ាងហោចក៏ត្រូវរៀបចំប្លង់ និង គម្រោងការងារឱ្យបានមុនដែរ ពីព្រោះទ្រង់ទ្រាយទាំងពីរនេះ នឹងមានឥទ្ធិពលទៅលើការកែលំអ *ដំណើរការគ្រប់គ្រងប្រតិបត្តិការឆ្លងកាត់* ការគ្រប់គ្រង ប្រតិបត្តិការដែលត្រូវបានកសាងនៅក្នុង ជំហានទីមួយ ។

ប្រការសំខាន់ផងដែរចំពោះការចាប់ផ្តើមការងារជាមូលដ្ឋាន សម្រាប់ការអភិវឌ្ឍសមត្ថភាព សវនកម្មផ្ទៃក្នុង ពីព្រោះការងារនេះ ត្រូវការពេលវេលាយូរ ហើយតួនាទីរបស់វាមានសារៈសំខាន់ចំពោះ *ប្រព័ន្ធដំណើរការសកម្មភាពឆ្លងកាត់* ដែលនឹងឆ្ពោះទៅរកការពឹងផ្អែកលើសវនកម្មក្រោយចំណាយ ។

ការចាប់ផ្តើមអនុវត្តការតាមដានចំណាយឱ្យបានឆាប់ នឹងផ្តល់លទ្ធភាពដល់ការអនុវត្តប្រកបដោយលក្ខណៈជាប្រព័ន្ធ ដែលជាចំណែកនៃក្របខ័ណ្ឌគណនេយ្យភាពក្នុងជំហានទីពីរ ។

ទោះបីជាកំណែប្រែជាមូលដ្ឋានក្នុងការអនុវត្តថវិកា មិនអាចធ្វើឱ្យមាននិរន្តភាពនៅមុនជំហាន ទីបីក៏ដោយ សំខាន់ត្រូវតែមានទស្សនៈយល់ដឹង និង កំណត់ឱ្យបានជាមុននូវទ្រង់ទ្រាយថ្មីនៃវដ្តថវិកា ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ ហើយអាចផ្តល់លទ្ធភាពដល់ជម្រើស និងអាទិភាព ដើម្បីជាមូលដ្ឋានសម្រាប់កែប្រែ *ការគ្រប់គ្រងប្រតិបត្តិការឆ្លងកាត់* ដែលត្រូវបានអនុវត្តនៅក្នុងជំហានទីមួយ ហើយនិងការចាប់ផ្តើមសាកល្បងយ៉ាងស៊ីជម្រៅនៃថវិកានីយកម្មកម្មវិធី ដើម្បីអាចដកបទពិសោធន៍សម្រាប់ការអនុវត្តជាទូទៅ និង ពេញលេញនៅក្នុងជំហានទីបី ។

ទោះជាការពង្រីកវិមជ្ឈការសារពើពន្ធ ត្រូវរង់ចាំការអនុមតិលើក្របខ័ណ្ឌជាតិ សម្រាប់ការគ្រប់គ្រងធនធាន និង គណនេយ្យភាពក៏ដោយ គប្បីត្រូវរៀបចំឱ្យបានរួចរាល់នូវចក្ខុវិស័យឱ្យបានច្បាស់លាស់អំពីថាតើវិមជ្ឈការសារពើពន្ធនឹងអាចសម្រេចបានតាមរបៀបណា ពីព្រោះវានឹងមានឥទ្ធិពលមកលើការរៀបចំប្រព័ន្ធ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

គ្រប់គ្រងសាច់ប្រាក់ *ប្រព័ន្ធគ្រប់គ្រងប្រតិបត្តិការឆ្លងកាត់* និង ប្រព័ន្ធលទ្ធកម្មក្នុងជំហានទីមួយ ។

ដោយហេតុថា **ការគ្រប់គ្រងហិរញ្ញវត្ថុតាមប្រព័ន្ធព័ត៌មានវិទ្យា** ជាប្រការសំខាន់ ក្នុងការបំពេញដល់ការផ្សារភ្ជាប់រវាងគណនេយ្យភាពការគ្រប់គ្រងហិរញ្ញវត្ថុ និង ការអនុវត្តការងារ ដែលគ្រោងសម្រេចឱ្យបាននៅក្នុងជំហានទីបួន ដូច្នេះ ការរៀបចំជាមុននូវចក្ខុវិស័យនៃគម្រោងព័ត៌មានវិទ្យានេះ ឱ្យបានច្បាស់លាស់មានសារៈសំខាន់ណាស់ ពីព្រោះ ដើម្បីអាចជាមូលដ្ឋានដល់ការរៀបចំឡើងវិញនូវ *ប្រព័ន្ធគ្រប់គ្រងប្រតិបត្តិការឆ្លងកាត់* ក្នុងជំហានទីមួយ និង ការពិចារណាទៅលើការរៀបចំផ្គត់ផ្គង់ជាបឋមនូវហេដ្ឋារចនាសម្ព័ន្ធរូបវន្តនៃប្រព័ន្ធកុំព្យូទ័រសម្រាប់គាំទ្រដល់ជំហានទីពីរ និង កសាងមូលដ្ឋានគ្រឹះសម្រាប់ប្រព័ន្ធទាំងមូលនៅក្នុងជំហានទីបួន ។

ដោយសារការអនុវត្តយ៉ាងពេញលេញនូវការគ្រប់គ្រងហិរញ្ញវត្ថុតាមរយៈប្រព័ន្ធព័ត៌មាន ក្នុងជំហានទីបួននឹងទាមទារដល់ការពង្រឹងកម្រិតសមត្ថភាពប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និង ការបង្កើនជាបណ្ដើរៗ ការប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យា នៅក្នុងគ្រប់ជំហានទាំងអស់ ដូច្នេះការពិចារណា និង កសាងផែនការយុទ្ធសាស្ត្រ ព័ត៌មានវិទ្យាអោយបានច្បាស់លាស់នាពេលបច្ចុប្បន្ននេះ នឹងអាចជាមូលដ្ឋានដល់ការរៀបចំគម្រោងការផ្គត់ផ្គង់ និង សេចក្តីសម្រេចចិត្តគ្រប់គ្រងចំពោះការអនុវត្តយ៉ាងពេញលេញការគ្រប់គ្រងហិរញ្ញវត្ថុ តាមរយៈប្រព័ន្ធព័ត៌មាននៅក្នុងជំហានទីបួន ។

ដូចគ្នានេះដែរ ចំពោះការបង្កើត និង ប្រើប្រាស់យ៉ាងពេញលេញនូវប្រព័ន្ធនៃការចុះបញ្ជីទ្រព្យសម្បត្តិរដ្ឋដែលអាចត្រូវរង់ចាំរហូតដល់ជំហានទីបួន ប៉ុន្តែ ការចាប់ផ្តើមរៀបចំប្លង់ និង គម្រោងការឱ្យបានជាមុនមានសារៈសំខាន់ណាស់ ពីព្រោះវាអាចជាមូលដ្ឋានក្នុងការផ្តល់ទិសដៅអំពីសេចក្តីសម្រេចនូវប្រព័ន្ធ ដែលត្រូវភ្ជាប់ និង យកមកសិក្សា ។

## ៥. ផែនការសកម្មភាពសម្រាប់ដំណាក់កាលទី ១

ចាប់តាំងពីខែមេសា ឆ្នាំ ២០០៤ មក ការងារជាច្រើនត្រូវសម្រេចបានពាក់ព័ន្ធនឹងការរៀបចំជាជំហានបន្ទាប់ និងលំអិតនៃផែនការសកម្មភាពរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រាប់ជំហ៊ានទី ១ នៃ កម្មវិធីកំណែទម្រង់ ។ គម្រោងផែនការសកម្មភាពត្រូវរៀបចំ និងផ្សព្វផ្សាយ ក្នុងរវាងខែមេសា និង មិថុនា ក្រោមជំនួយរបស់ក្រុមសម្រួលការងារ ។ នាខែសីហា ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុបានរៀបចំ *ផែនការសកម្មភាពរួម* (CAP) សម្រាប់ដំណាក់កាលទី ១ និង ដាក់ចេញសកម្មភាពចំបងនៃដំណាក់កាលបន្តបន្ទាប់ទៀត ។ CAP រួមមាន ៣ ផ្នែកៈ ១៣ សកម្មភាព (រួមនឹងអនុសកម្មភាព) ជាចាំបាច់ដើម្បីសម្រេចជំហានទី ១ ។ ១០ សកម្មភាព (រួមនឹងអនុសកម្មភាព) ជាចាំបាច់ដើម្បីសម្រេចដំណាក់កាលទី ១ (ឧទាហរណ៍ ការងារសម្រាប់ជំហានបន្ទាប់ដែលទាមទារត្រូវចាប់ផ្តើមភ្លាមៗ) និង ៤ សកម្មភាពចាំបាច់សំរាប់ពង្រឹងសមត្ថភាព និងកែលម្អការលើកទឹកចិត្ត ។

ផ្នែកនីមួយៗរួមមានការចង្អុលបង្ហាញពីកាលបរិច្ឆេទ (ការចាប់ផ្តើម និងរយៈពេល) នាយកដ្ឋានទទួលបន្ទុកជំនួយបច្ចេកទេសចាំបាច់ និងតម្រូវការធនធានមនុស្ស ។ ជំហានក្រោយៗមានសារៈសំខាន់សំរាប់កសាងកម្មវិធីតម្រូវការបុគ្គលិកនៅក្នុងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សម្រាប់កម្មវិធីកំណែទម្រង់ ។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានលើកសំណើសកម្មភាពភ្លាមៗ ដែលដកចេញពី CAP ដែលជួយបង្ហាញពីការចូលរួម ការកំណត់អ្នកទទួលខុសត្រូវលើសកម្មភាព និងផ្តល់ឱកាសសម្រាប់ ការទទួលបទពិសោធន៍អន្តរក្រសួង ។ ការផ្តល់អនុសាសន៍លើការងារអាទិភាព មិនមានបំណងធ្វើអោយប៉ះពាល់ដល់ផែនការសកម្មភាពនោះទេ គ្រាន់តែជាការជួយណែនាំពីការប្រមើលមើលសកម្មភាពមួយចំនួន ព្រោះថាបើសិនជាសកម្មភាពទាំងនោះសម្រេចបានឆាប់ នោះនឹងផ្តល់ជាមូលដ្ឋានយ៉ាងរឹងមាំសំរាប់ការងារបន្ទាប់ (សកម្មភាពទាំងនេះអាចត្រូវមើលឃើញថា ជាសកម្មភាពបំពេញបន្ថែមសកម្មភាពកំពុងដំណើរការ) ។ គោលដៅចម្បង គឺដើម្បីសម្រេចសកម្មភាពនាដើមឆ្នាំ ២០០៥ បើទោះបីជាមានសេសសល់ការងារបំពេញបន្ថែមត្រូវអនុវត្តក៏ដោយ ។

ចំណាយលម្អិតប៉ាន់ស្មានសំរាប់ដំណាក់កាលទី ១ និងការប៉ាន់ប្រមាណថវិកាសំរាប់កម្មវិធីទាំងមូលត្រូវបានអនុវត្ត ។ ដោយមិនគិតពីចំណាយលើលាភការតាមគុណសម្បត្តិ ចំណាយសំរាប់ដំណាក់កាលទី ១ មានប្រមាណជា ៤,២ លានដុល្លារ និងចំណាយសរុបសំរាប់កម្មវិធីកំណែទម្រង់ត្រូវប៉ាន់ប្រមាណក្នុងកម្រិត ១៩,១ លានដុល្លារ (សូមបញ្ជាក់ថា ចំណាយនេះមិនរាប់បញ្ចូលការចូលរួមរបស់រាជរដ្ឋាភិបាលជាហិរញ្ញប្បទាន ឬជាសម្ភារៈ) ។ រដ្ឋាភិបាលត្រូវការជំនួយបន្ទាន់ពីដៃគូអភិវឌ្ឍន៍បន្ទាប់ពីការចុះហត្ថលេខាជាផ្លូវការលើកម្មវិធី ។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ដៃគូអភិវឌ្ឍន៍ បានព្រមព្រៀងលើរបៀបវារៈកម្មវិធីដូចខាងក្រោម៖

- ដំណាក់កាលទី ១ : ១៥ ទៅ ២០ ខែ
- ដំណាក់កាលទី ២-៤ : ៦ ទៅ ៧ ខែ

ក្នុងខណៈដែលសកម្មភាពជាច្រើនដែលចេញពី **កម្មវិធីសម្របសម្រួលជំនួយបច្ចេកទេស** (TCAP) **ការសិក្សារួមនៃការវាយតម្លៃសាច់ប្រាក់ និង ការពិនិត្យចំណាយឡើងវិញ** (IFAPER) ជំនួយពហុភាគី និងទ្វេភាគី (ធនាគារអភិវឌ្ឍន៍អាស៊ី មូលនិធិរូបិយវត្ថុអន្តរជាតិ ធនាគារពិភពលោក ប្រទេសបារាំង ទីប្រឹក្សាជំនួយអន្តរជាតិរបស់អង់គ្លេស និង ទីប្រឹក្សាសហប្រតិបត្តិការអន្តរជាតិរបស់ជប៉ុន (JICA) កំពុងនៅដំណើរការ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុចាប់ផ្តើមអនុវត្តជាក់ស្តែងភ្លាមបន្ទាប់ពីការចុះហត្ថលេខាជាផ្លូវការលើ **កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ** នៅថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០០៤ ។ ក្នុងន័យនេះ ទាំង រដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ យល់ថាជំនួយជាបន្តដល់កម្មវិធី ស្ថិតលើវឌ្ឍនភាពជាបន្តបន្ទាប់ក្នុងក្របខណ្ឌប្រតិបត្តិការដែលបានកំណត់ទុក ។ ការប្រឈម គឺ ការកសាងទំនុកចិត្តបន្តបន្ទាប់ និងជំហរអចិន្ត្រៃយ៍ក្នុងអំឡុងពេលសម្រេចដំណាក់កាលទី ១ ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ៦. ក្របខ័ណ្ឌនៃការគ្រប់គ្រងការអនុវត្ត

ក្របខណ្ឌនៃការគ្រប់គ្រងការអនុវត្ត **កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ** រួមមាន៖

**ក) គំរោងក្របខ័ណ្ឌ:** សម្រាប់វាស់វែងការអនុវត្តកម្មវិធីក្នុងកម្រិតទស្សនវិស័យ និងដំណាក់កាលទី ១ និង **ខ)** CAP ដែល CAP នីមួយៗ កំណត់នូវសកម្មភាពប្រមាណ ២០០ ដាច់ៗពីគ្នា ដើម្បីអនុវត្តក្នុងកម្រិតនាយកដ្ឋាន ក្នុងអំឡុងពេល ១៥ ខែ ផ្តល់ការផ្សារភ្ជាប់គ្នារវាងការវាស់វែងការអនុវត្តដំណាក់កាលទី ១ និង ការទទួលខុសត្រូវរបស់នាយកដ្ឋានដែលត្រូវប្រគល់ទៅអោយបុគ្គល ឬ ក្រុមផ្សេងៗ ។ ធាតុទី ៣ ក្របខ័ណ្ឌគ្រប់គ្រងការអនុវត្ត និង ការវាយតម្លៃការអនុវត្តរបស់បុគ្គលិក ដែលភ្ជាប់ការអនុវត្តរបស់បុគ្គលម្នាក់ៗ ទៅនឹងផែនការសកម្មភាពរបស់នាយកដ្ឋានដែលបានរៀបចំក្នុង CAP ។ ការរៀបចំគោលការណ៍នៃប្រព័ន្ធវាយតម្លៃការអនុវត្តបុគ្គលិកត្រូវបានបញ្ចូលក្នុងសៀវភៅបន្ទុកនៃបេសកកម្មទី ៣ នៃ «ការពិគ្រោះដើម្បីជម្រុញ និងការផ្លាស់ប្តូររចនាសម្ព័ន្ធ» នាខែសីហា ឆ្នាំ ២០០៤ ។

វិធានទូទៅនៃការសម្រេចជំហានទី ១ គឺ ត្រូវធានាថាកម្មវត្ថុនៃជំហានទី ១ អាចសំរេចបាន មានន័យថាភាពជឿទុកចិត្តលើថវិកាត្រូវសម្រេចបាន និងដៃគូអភិវឌ្ឍន៍ចាត់ទុកវាជាឧបករណ៍ជំនួយ ព្រោះវាជាឧបករណ៍ជាក់ស្តែងនៃការកំណត់អាទិភាពគោលនយោបាយ ។ វិធានចំនួន ១៤ ពាក់ព័ន្ធនឹងជំហានទាំងឡាយ ដែលភ្ជាប់វិធាន ៤ នៃទស្សនៈទូទៅត្រូវបានរៀបចំ ។ វិធានដាច់ដោយឡែកពាក់ព័ន្ធនឹងការអនុវត្តត្រូវបានកំណត់ សម្រាប់វិធានទាំង ១៤ ជំហានទាំងឡាយ ។ លើសពីនេះទៅទៀត វិធានពីរក្រុមត្រូវបានកំណត់ ÷

**គ)** វិធានទូទៅនៃការសំរេចជំហានទី ១ : សកម្មភាពសំរេចបានជាលទ្ធផលនៃការកសាងមូលដ្ឋានគ្រឹះដែលអាចអោយឆ្លងទៅកាន់ជំហានបន្ទាប់ ។

**ឃ)** វិធានវឌ្ឍនភាពអន្តរកាល សំរាប់ធានាថាសកម្មភាពនៃកម្មវិធីហុចជាលទ្ធផល ។

គំរោងក្របខ័ណ្ឌត្រូវចាត់ទុកជានិយមន័យ១ នៃការគ្រប់គ្រងដែលបានកែសម្រួល និងជាឧបករណ៍ដឹកនាំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីត្រួតពិនិត្យជាប្រចាំលើ **កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ** ធៀបនឹងទស្សនៈវិស័យឆ្នាំ ២០១៥ និង ជំហានទី ១ ។ វាជាបេសសកម្មដែលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុព្យាយាមអនុវត្តការងារមូលដ្ឋានសម្រាប់កំណត់ការអនុវត្តបច្ចុប្បន្ន ដោយភ្ជាប់ទៅនឹងក្របខ័ណ្ឌ ដែលបានស្នើ ។ ដោយឈរលើលទ្ធផលនៃការងារមូលដ្ឋានគ្រឹះ បេសសកម្មមានរួមទាំងការដែល ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវពិនិត្យឡើងវិញនូវវិធានដែលបានលើកឡើង ។ លទ្ធផលនៃការងារមូលដ្ឋានត្រូវចែករំលែកជាមួយក្រុមគោលដៅមួយរួមមាន មន្ត្រីនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អ្នកធ្វើសេចក្តីសម្រេចចិត្តគោល-នយោបាយ បុគ្គលិកថ្នាក់ខេត្ត មន្ត្រី និង អ្នកធ្វើសេចក្តីសម្រេចចិត្តគោលនយោបាយនៃរចនាសម្ព័ន្ធវិមជ្ឈការ ។ ការងារនេះមានសារៈសំខាន់សំរាប់ការបែងចែកការទទួលខុសត្រូវសំរាប់ការអនុវត្ត និង វឌ្ឍនភាពចុងក្រោយធៀបនឹងលទ្ធផលរំពឹងទុកក្នុងកម្មវិធី ។

វាជាការចាំបាច់ក្នុងការកំណត់ការទទួលខុសត្រូវអោយបានច្បាស់លាស់ ចំពោះការដឹកនាំរួម និងការ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ត្រួតពិនិត្យវឌ្ឍនភាពនៃកំណែទម្រង់ឡើងវិញ ។ ក្នុងន័យនេះ យន្តការដូចខាងក្រោមត្រូវបានស្នើឡើង ÷

**ង)** ការដឹកនាំរួមលើ **កម្មវិធីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ** និង យន្តការត្រួតពិនិត្យឡើងវិញ ផ្អែកលើការដឹកនាំផ្ទៃក្នុងរបស់រដ្ឋាភិបាល និងនីតិវិធីនៃការត្រួតពិនិត្យឡើងវិញ ក្រោមការចូលរួមពីសំណាក់ដៃគូអភិវឌ្ឍន៍ ។

**ច)** ដៃគូអភិវឌ្ឍន៍ព្យាយាមប្រើប្រាស់យន្តការរួម សម្រាប់ការត្រួតពិនិត្យឡើងវិញ និងការដឹកនាំដែលមានការចូលរួមចំណែករបស់ពួកគេ ។

**ឆ)** ការត្រួតពិនិត្យឡើងវិញ និង ការដឹកនាំរួម ត្រូវបានរៀបចំ អោយសមស្របតាមការចង់បានរបស់ដៃគូអភិវឌ្ឍន៍ រួមទាំងដៃគូអភិវឌ្ឍន៍ដែលមាននៅក្នុងមូលនិធិ ។

**ជ)** ការត្រួតពិនិត្យឡើងវិញ និង ការដឹកនាំរួម ត្រូវចែងអោយច្បាស់ពីកាលបរិច្ឆេទនៃសកម្មភាពដែលអាចផ្តល់ពេលវេលាអោយដៃគូអភិវឌ្ឍន៍ អាចកៀងគរការចូលរួម និង ការធ្វើបេសកកម្មត្រួតពិនិត្យឡើងវិញ និង មានភាពទន់ភ្លន់ដើម្បីអាចអនុវត្តអភិក្រមរំកិលនៃការធ្វើផែនការ ក្នុងបរិការណ៍ **អភិក្រមតាមវិស័យទូលាយ** (SWAP) ។

**ឈ)** យន្តការត្រួតពិនិត្យឡើងវិញ និង ការដឹកនាំរួម ត្រូវតែត្រួតពិនិត្យ និងកែសំរួលឡើងវិញជាប្រចាំផ្អែកលើមូលដ្ឋានការព្រមព្រៀងគ្នា ។

## ៧. ការអភិវឌ្ឍន៍ស្ថាប័ន និងរចនាសម្ព័ន្ធ

យុទ្ធសាស្ត្រពង្រឹងសមត្ថភាព និងការគ្រប់គ្រងការអនុវត្ត មានសារៈសំខាន់ណាស់សំរាប់ទ្រទ្រង់ ប្រកបដោយជោគជ័យ លើការសំរេចបាននូវកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ ការអភិវឌ្ឍយុទ្ធសាស្ត្រដើម្បីលើកទឹកចិត្ត ការកែលម្អរចនាសម្ព័ន្ធ និងអភិវឌ្ឍសមត្ថភាពយូរអង្វែង មានការពាក់ព័ន្ធគ្នាយ៉ាងជិតស្និទ្ធ ដូចនេះទាមទារអោយមានការសម្របសម្រួលយ៉ាងល្អ ។

បេសកកម្មពិគ្រោះយោបល់សម្រាប់ការលើកទឹកចិត្ត និងការកែប្រែរចនាសម្ព័ន្ធ ត្រូវបានប្រគល់ដើម្បីផ្តល់ជាអនុសាសន៍ដល់ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុលើៈ ការកែលំអររចនាសម្ព័ន្ធក្នុងរយៈពេលខ្លី និងមធ្យមដែលចាំបាច់សម្រាប់ការសម្រេចបាននូវជំហានទី ១ បទប្បញ្ញត្តិរយៈពេលខ្លី និងមធ្យមដើម្បីកែលម្អរចនាសម្ព័ន្ធនៃការលើកទឹកចិត្ត (ហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុ) ពេលមានការចូលរួមពីមន្ត្រីនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុការគ្រប់គ្រងការកែប្រែ ដែលចាំបាច់ដើម្បីកសាងការព្រមព្រៀងទាំងមូល និង សម្រេចបានកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

វាមានភាពចាំបាច់ណាស់ក្នុងការឈានទៅរក **ការផ្តល់លាភការផ្អែកលើគុណសម្បត្តិ** (MBPI) ដើម្បីជួយជម្រុញ និងសម្រេចបានកម្មវិធីកំណែទម្រង់ ។ ដោយកំណត់យកការចូលរួមដ៏សំខាន់នៃកំណែទម្រង់ការផ្តល់លាភការនៅក្នុងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សម្រាប់រដ្ឋាភិបាលទាំងមូល វាជាការចាំបាច់ក្នុងការ



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ទាក់ទាញចំណាប់អារម្មណ៍លើសារៈសំខាន់នៃធាតុនេះ ក្នុងកម្មវិធីដែលមានលក្ខណៈយូរអង្វែង មានតម្លាភាព និងចាក់ឬសគល់ក្នុងទស្សនៈរបស់រដ្ឋាភិបាល នូវកំណែទម្រង់លាភការដែលបានព្រមព្រៀង ក្នុងលក្ខណៈជាគំនិតផ្តួចផ្តើមរបស់រដ្ឋាភិបាល ។

សំណុំនៃគោលការណ៍ត្រូវបានរៀបចំឡើង ក្នុងលក្ខណៈមួយទ្រទ្រង់ប្រព័ន្ធលាភការផ្អែកលើគុណសម្បត្តិ ដែលជាជំនួយដល់កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ គោលការណ៍ទាំងនេះកំណត់នូវប៉ារ៉ាម៉ែត្រសំរាប់ការបែងចែកការទទួលខុសត្រូវ តម្លាភាព និរន្តភាព ប្រាក់ដុល និងមូលដ្ឋាននៃកំណែទម្រង់លាភការ ប៉ុន្តែមិនកំណត់ពីលក្ខណៈ ឬ កម្រិតនៃលាភការ បន្ទាប់ពីដំណាក់កាលបច្ចេកទេស ។

តាមការប្រមើលមើលការអភិវឌ្ឍ និងការដាក់អោយដំណើរការប្រព័ន្ធដែលដំណើរការឈរលើមូលដ្ឋានគុណសម្បត្តិ ដៃគូអភិវឌ្ឍន៍ចាត់ទុកថាជាផ្នែកបង្រួមនៃសកម្មភាពចាំបាច់ ជាជំហានដំបូងឆ្ពោះទៅរកការកៀងគរធនធាន ។ មុនរយៈពេល ៦ ខែនៃកម្មវិធី (ដំណាក់កាលទី ១) សកម្មភាពទាំងនេះរួមមាន ÷

- ការព្រមព្រៀងផ្លូវការលើប្រព័ន្ធកំណែទម្រង់លាភការផ្អែកលើគុណសម្បត្តិ ដោយនាយករដ្ឋមន្ត្រី
- ការព្រមព្រៀងលើការទូទាត់ដែល ដំបូងត្រូវធ្វើឡើងតាមរយៈបណ្តាញរដ្ឋាភិបាល និងចាប់ពីដើមឆ្នាំ ២០០៦ តាមរយៈប្រព័ន្ធសមតុល្យ
- ការដាក់អោយដំណើរការប្រព័ន្ធមូលដ្ឋានវាយតម្លៃការអនុវត្តភ្នាក់ងារ ផ្អែកលើគោលការណ៍ក្របខ័ណ្ឌ
- ប្រព័ន្ធដែលធានាតម្លាភាព លើការទូទាត់ និង សវនកម្មប្រត្តិបត្តិការរៀងរាល់ឆមាសលើធនធានកំណែទម្រង់លើលាភការផ្អែកលើគុណសម្បត្តិ
- កិច្ចព្រមព្រៀងដែលជាលទ្ធផលនៃគំនិតផ្តួចផ្តើមនៃលាភការផ្អែកលើគុណសម្បត្តិ នឹងត្រូវអនុវត្តក្នុងក្របខណ្ឌនៃគោលការណ៍

ចាប់ពីដើមដំណាក់កាលទី ២ រដ្ឋាភិបាល ផ្តល់ការចូលរួមចំណែក ២០%ដល់ **គំនិតផ្តួចផ្តើមផ្តល់លាភការតាមគុណសម្បត្តិ** (MBPI) សម្រាប់ឆ្នាំ ២០០៥ (ការចូលរួមចំណែកនេះត្រូវបានកត់ចូលថវិកាជាតិ) ។ ការចូលរួមចំណែករបស់រដ្ឋាភិបាលត្រូវបង្កើនតាមពេលវេលា រហូតដល់ហិរញ្ញប្បទានទាំងស្រុងលើកម្មវិធីគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

## ៨. ការសម្របសម្រួលរបស់ដៃគូអភិវឌ្ឍន៍ និងការប្រមូលជំនួយ

មានការព្រមព្រៀងជាច្រើនរវាងដៃគូអភិវឌ្ឍន៍ និងរាជរដ្ឋាភិបាល ដើម្បីអោយ **អភិក្រមតាមវិស័យទូលាយ** (SWAP) អាចដំណើរការ ដើម្បីដឹកនាំ **កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ** ដែលកសាងឡើងដោយឈរលើការសម្រេចបាន TCAP និង ការវិភាគ និងអនុសាសន៍របស់ IFAPER និងការងារ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

វិភាគផ្សេងៗទៀត ដូចជាការសិក្សារបស់ក្រុមការងារដៃគូលើជំនួយ និងការសម្របសម្រួល និង ការអនុវត្តការពង្រឹងសមត្ថភាព ។ កិច្ចព្រមព្រៀងសម្របសម្រួលរបស់ដៃគូអភិវឌ្ឍន៍ដែលស្នើឡើងក្នុងក្របខ័ណ្ឌ **កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ អភិក្រមតាមវិស័យទូលាយ** ផ្អែកលើភាពជាម្ចាស់ និង ការអនុវត្តរបស់រាជរដ្ឋាភិបាល ។ លក្ខណៈនេះឆ្លុះបញ្ចាំងពី «គោលការណ៍ភាពជាដៃគូ» ដែលចែងពីគោលការណ៍ចូលរួមចំណែករបស់ដៃគូអភិវឌ្ឍន៍ ដែលការជម្រុញត្រូវធានាដោយរាជរដ្ឋាភិបាលផង និងដៃគូអភិវឌ្ឍន៍ផង ។

ម្យ៉ាងវិញទៀត អនុក្រុមដៃគូអភិវឌ្ឍន៍ បានសំរេចចិត្តរួមគ្នាដាក់រាល់សំណុំមធ្យោបាយដើម្បីរំលេចនូវភាពជាក់ស្តែងនៃជំនួយបច្ចេកទេស ដោយមួយផ្នែកដើម្បីបន្ថយចំណាយប្រតិបត្តិការរបស់រដ្ឋាភិបាល និងដើម្បីបង្កើនឥទ្ធិពលជំនួយ ។ ជាចុងក្រោយ មូលនិធិពហុដៃគូនៃការគ្រប់គ្រងហិរញ្ញវត្ថុសារធាណៈ ដែលត្រូវដាក់ក្នុងធនាគារពិភពលោក ក្រោមកិច្ចសហប្រតិបត្តិការរបស់ ទីភ្នាក់ងារអូស្រ្តាលីដើម្បីកិច្ចអភិវឌ្ឍន៍អន្តរជាតិ និង ទីភ្នាក់ងារដើម្បីកិច្ចអភិវឌ្ឍន៍អន្តរជាតិរបស់អង់គ្លេស និង សហគមន៍អ៊ឺរ៉ុប ។ ដើម្បីអនុវត្តការងារកំណែទម្រង់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុបានបង្កើតឡើងនូវលេខាធិការដ្ឋានកំណែទម្រង់មួយ ដែលមានមុខងារដូចតទៅ៖

- គ្រប់គ្រងមូលនិធិពហុដៃគូ ដោយរួមមានការធ្វើការរួមគ្នាយ៉ាងជិតស្និទ្ធជាមួយលេខាធិការដ្ឋានកំណែទម្រង់ លើធាតុចូលប្រត្តិការ និងបច្ចេកទេស ។
- សម្របសម្រួលជាមួយម្ចាស់ជំនួយ (រួមមានការសម្រួលកិច្ចប្រជុំតាមពេលវេលា ការរៀបចំសកម្មភាពអចិន្ត្រៃយ៍ និងរបាយការណ៍សំយោគសំរាប់ម្ចាស់ជំនួយ ការធានាគុណភាពលើរបាយការណ៍ជំនួយបច្ចេកទេស ហិរញ្ញប្បទានដោយមូលនិធិ ។ល។)
- ធានាទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍន៍ ដែលមិនមែនសមាជិកមូលនិធិ ដើម្បីសម្របសម្រួល ទាំងភាគី និងមិនមែនភាគីដែលគាំទ្រកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (វាអាចដែលថាពេលដែលមូលនិធិត្រូវប្រតិបត្តិទាំងស្រុង លេខាធិការដ្ឋានមានការទទួលខុសត្រូវធំ ក្នុងវិស័យសម្របសម្រួលរួម ជាមួយដៃគូអភិវឌ្ឍន៍)
- ជួយដៃគូអភិវឌ្ឍន៍ ក្នុងយន្តការសម្របសម្រួលតាមតម្រូវការ និង ព្រមព្រៀង
- ផ្តល់យោបល់ដែលលេខាធិការដ្ឋានកំណែទម្រង់បានស្នើ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ឧបសម្ព័ន្ធទី ១

## ឯកសារស្រាវជ្រាវ


BALIVET Beatrice, Coordinator, *Introduction au droit cambodgien* [Introduction to Cambodian Law], Presses Universitaires du Cambodge, 2005.

BLOCH Bernard-Michel, *Code des marchés publics annoté 2004* [Annotated Public Procurement Code 2004], Berger-Levrault 2004.

CHAMBAS Gérard, *Afrique au Sud du Sahara : Mobiliser des ressources fiscales pour le développement* [Sub-Saharan Africa: mobilizing tax revenue for development], Economica, 2005.

CHHORN Sopheap, OUCH Channora, SOU Socheat, YAN Vandeluxe, CORNUT Etienne, *Droit constitutionnel cambodgien* [Cambodian Constitutional Law], Presses Universitaires du Cambodge, 2005.

European Commission, *Manuel de Gestion du Cycle de Projet* [Project Cycle Management Handbook], 2001

IMF, *Cambodia: Selected Issues and Statistical Appendix*, IMF Country Report 06/265, 2006.

GUILLIEN Raymond and VINCENT Jean, *Lexique des termes juridiques* [Glossary of French Legal Terms], Dalloz, 1999.

HANG CHUON NARON Dr., *L'Economie du Cambodge, la lutte pour le développement* [Cambodia's Economy, the Struggle for Development], Phnom Penh, 2005.

MAGNET Jacques, *La Cour des Comptes, les institutions associées et les Chambres des Comptes* [The Audit Court, associated institutions and Chambers of Accounts], Berger-Levrault, 1996.

MUCCHIELLI Jean-Louis, *Principes d'économie internationale* [Principles of




fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

International Economics], ERE, SA/AUPELF, 1989.

NONJON Alain, *Comprendre l'économie mondiale* [Understanding the World Economy], EDICEF/Ellipses, 1995.

RAFFINOT Marc, *Dette extérieure et ajustement structurel* [External Debt and Structural Adjustment], EDICEF/AUPELF, 1991.

STIGLITZ Joseph E., *Un autre monde, contre le fanatisme du marché* [Another World, Against Market Fanaticism], Fayard, 2006.



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ឧបសម្ព័ន្ធទី ២

# មាតិកាថវិកា និង មាតិកាគណនេយ្យឆ្នាំ ២០០៧

## ថ្នាក់ទី ១: គណនីមូលធន

**១០ គណនីមូលធន**

១០១ ទាយជ្ជទាន

១០២ ធនធានអចលកម្មដែលបានទទួលគ្រប់គ្រង ប្រើប្រាស់

១០៤ ធនធានដែលបានពីអំណោយ និងកេរ្តិ៍មរតក

១០៦ អតិរេកផ្នែកចរន្ត- ធនបំរុង

**១១ យោងជាថ្មី**

១១០ យោងជាថ្មី ឥណទាយី (អតិរេក)

១១៩ យោងជាថ្មី ឥណទាយិក (ឱនភាព)

**១២ លទ្ធផលនៃការិយបរិច្ឆេទ (អតិរេក- ឱនភាព)**

**១៣ ឧបត្ថម្ភកធនវិនិយោគ**

១៣១ ឧបត្ថម្ភកធនពីទ្វេភាគី

១៣១. ១ជប៉ុន

១៣១. ២បារាំង

១៣១. ៣ អាឡឺម៉ង់

១៣១. ៤ផ្សេងៗ

១៣២ ឧបត្ថម្ភកធនពីពហុភាគី

១៣២. ១ធនាគារពិភពលោក

១៣២. ២ធនាគារអភិវឌ្ឍន៍អាស៊ី



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

១៣២. ៣ អង្គការអាយហ្វាត

១៣២. ៤ អង្គការអូប៉ិច

១៣២. ៨អង្គការផ្សេងៗ

១៣៣ ឧបត្ថម្ភកធនសំរាប់ការរំលស់បំណុល

១៣៣. ១ ទ្វេភាគី

១៣៣. ២ អង្គការអន្តរជាតិផ្សេងៗ

១៣៩ ឧបត្ថម្ភកធនវិនិយោគផ្ទេរទៅគណនីលទ្ធផល

## ១៦ ការទូទាត់ប្រាក់ខ្ចី និងបំណុលប្រហាក់ប្រហែល

១៦១ ការខ្ចីក្នុងប្រទេស

១៦១. ១ ធនាគារជាតិ

១៦១. ២ ធនាគារពាណិជ្ជ

១៦១. ៨ ផ្សេងៗ

១៦២ ការខ្ចីក្រៅប្រទេសពីពហុភាគី- អង្គការអន្តរជាតិ

១៦២. ១ ឆ្លងកាត់រតនាគារ

១៦២. ១១ ប្រាក់ដើមខ្ចីបានទទួល (ពុំទាន់ត្រូវសង)

១៦២. ១២ ប្រាក់ដើមខ្ចីត្រូវសង

១៦៣ ការខ្ចី ក្រៅរតនាគារ

១៦៣. ១ឆ្លងកាត់រតនាគារ

១៦៣. ១១ ប្រាក់ដើមខ្ចីបានទទួល (ពុំទាន់ត្រូវសង)

១៦៣. ១២ ប្រាក់ដើមខ្ចីត្រូវសង

១៦៤ ប្រាក់តំកល់ធានាបានទទួល

១៦៤. ១ រតនាគារកណ្តាល



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

១៦៤.១១ ប្រាក់រៀល

១៦៤.១២ ជាដុល្លារ

១៦៥ បរិវិសករ ប័ណ្ណរតនាគារ

១៦៥.១ សន្លឹកប័ណ្ណ

១៦៥.២ គណនីចរន្ត

១៦៦ សញ្ញាប័ណ្ណ

១៦៧ ការប្រាក់បានគិតទុកមុនពេលពុំទាន់បានបង់ (ប្រាក់ខ្ចី)

## ថ្នាក់លេខ ២: គណនី អចលកម្ម

### ២០ អចលកម្មអរូបី

២០៣ សោហ៊ុយសិក្សាស្រាវជ្រាវ និងអភិវឌ្ឍន៍

២០៣.១សោហ៊ុយសិក្សា

២០៣.២សោហ៊ុយស្រាវជ្រាវ និង អភិវឌ្ឍន៍

២០៥ ប្រកាសនីយប័ត្រ អាជ្ញាប័ណ្ណ និងសិទ្ធិប្រហាក់ប្រហែល

២០៥.១ ប្រកាសនីយប័ត្រ

២០៥.២ អាជ្ញាប័ណ្ណ

២០៥.៣សិទ្ធិប្រហាក់ប្រហែល

### ២១ អចលកម្មរូបី

២១១ ដីធ្លី ដីរ៉ែ និងសម្បត្តិធម្មជាតិ

២១១.១ ដីធ្លី

២១១.២ ដីរ៉ែ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

២១១. ៨ សម្បត្តិធម្មជាតិផ្សេងៗ

២១២ ការរៀបចំកែលម្អ ដីធ្លី និងសម្បត្តិធម្មជាតិផ្សេងៗ

២១២. ១ ការរៀបចំកែលម្អដីធ្លី

២១២. ២ ការរៀបចំកែលម្អដីរ៉ែ

២១២. ៣ការរៀបចំកែលម្អសម្បត្តិធម្មជាតិផ្សេងៗ

២១៣ សំណង់ និងការរៀបចំកែលម្អអាគារ

២១៣. ១ អាគារ

២១៣. ២ ការរៀបចំកែលម្អអាគារ

២១៣. ៨សំណង់ផ្សេងៗ

២១៤ ហេដ្ឋារចនាសម្ព័ន្ធ

២១៤. ១ ផ្លូវថ្នល់

២១៤. ២ ធារាសាស្ត្រ

២១៤. ៣អាយស្ម័យាន

២ ១៤. ៤ អាកាសយានដ្ឋាន

២១៤. ៥ ទូរគមនាគមន៍

២១៤. ៦ អគ្គិសនី

២១៤. ៨ ផ្សេងៗ

២១៥ ថបនកម្មបច្ចេកទេស សម្ភារៈ និងហត្ថូបករណ៍

២១៥. ១ ថបនកម្មបច្ចេកទេស

២១៥. ២ សម្ភារៈ

២១៥. ៣គ្រឿងឧបករណ៍ (ហត្ថូបករណ៍)

២១៦ ស្នាដៃសិល្បៈ និងការប្រមូល (សន្សំ)

២១៧ អចលកម្មដែលបានទទួលគ្រប់គ្រងប្រើប្រាស់

២១៧.១ ដីធ្លី

២១៧.២ ការរៀបចំកែលម្អដីធ្លី

២១៧. ៣ អាគារ

២១៧.៥ ថបនកម្មបច្ចេកទេស សម្ភារៈ ហត្ថបករណ៍

២១៧.៨ ផ្សេងៗ

២១៨ អចលកម្មរូបីផ្សេងៗ

២១៨.១ សម្ភារៈឧបករណ៍ដឹកជញ្ជូន

២១៨.២ សម្ភារៈឧបករណ៍ការិយាល័យ

២១៨. ៣សម្ភារៈព័ត៌មានវិទ្យា និងទូរគមនាគមន៍

២១៨.៤ សង្ហារឹម

២១៨.៨ ផ្សេងៗ

## ២៣ អចលកម្មកំពុងដំណើរការ

២៣១ អចលកម្មរូបីកំពុងដំណើរការ

២៣១.២ការកែលម្អដីធ្លី

២៣១. ៣ អាគារ

២៣១.៤ហេដ្ឋារចនាសម្ព័ន្ធ

២៣១.៥ថបនកម្មបច្ចេកទេស

២៣២ អចលកម្មអរូបីកំពុងដំណើរការ

២៣៨ ប្រាក់រំដោះលើការងារវិនិយោគ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

២៣៨.១អចលកម្មរូបី

២៣៨.២អចលកម្មអរូបី

## ២៤ អចលកម្មដែលបានបែងចែក ឬប្រគល់អោយប្រើប្រាស់

២៤១ អចលកម្មដែលបានធ្វើសម្បទាន ឬប្រវាស់

២៤២ អចលកម្មដែលបានបែងចែក ឬដាក់អោយប្រើប្រាស់

## ២៦ ភាគកម្ម និង ឥណទេយ្យពាក់ព័ន្ធ

២៦១ មូលប័ត្រនៃភាគកម្ម

## ២៧ អចលកម្មហិរញ្ញវត្ថុផ្សេងៗ

២៧១ ការអោយខ្ចី

២៧២ ប្រាក់តំកល់ធានាបានបង់

២៧៧ ការប្រាក់គិតទុកពុំទាន់បានទទួល (ប្រាក់អោយខ្ចី)

## ២៨ រំលស់អចលកម្ម

២៨០ រំលស់អចលកម្មអរូបី

២៨១ រំលស់អចលកម្មរូបី

## ថ្នាក់លេខ ៤ គណនី តតិយជន

## ៤០ អ្នកផ្គត់ផ្គង់

៤០១ អ្នកផ្គត់ផ្គង់ទំនិញ សេវា ការងារ

៤០១.១ នៅរតនាគារកណ្តាល

៤០១.១.១ ប្រាក់រៀល

*៤០១.១.១០ ឆ្នាំនេះ*

*៤០១.១.១១ ឆ្នាំមុន*



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

៤០១.១.២ ប្រាក់ដុល្លារ

*៤០១.១.២០ ឆ្នាំនេះ*

*៤០១.១.២១ ឆ្នាំមុន*

៤០១.២ នៅរតនាគារខេត្ត-ក្រុង

៤០១.២០ ឆ្នាំនេះ

៤០១.២១ ឆ្នាំមុន

៤០២ ប្រាក់ដើម ការប្រាក់ និងវិភាគទានត្រូវសង

៤០២.១ នៅរតនាគារកណ្តាល ជាប្រាក់រៀល

៤០២.១០ ឆ្នាំនេះ

៤០២.១១ ឆ្នាំមុន

៤០២.២ នៅរតនាគារកណ្តាល ជាប្រាក់ដុល្លារ

៤០២.២០ ឆ្នាំនេះ

៤០២.២១ ឆ្នាំមុន

៤០៤ អ្នកផ្គត់ផ្គង់អចលកម្ម

៤០៤.១ នៅរតនាគារកណ្តាល

៤០៤.១.១ ប្រាក់រៀល

*៤០៤.១.១០ ឆ្នាំនេះ*

*៤០៤.១.១១ ឆ្នាំមុន*

៤០៤.១.២ ប្រាក់ដុល្លារ

*៤០៤.១.២០ ឆ្នាំនេះ*

*៤០៤.១.២១ ឆ្នាំមុន*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

៤០៤. ២ នៅរតនាគារខេត្ត-ក្រុង

៤០៤. ២០ ឆ្នាំនេះ

៤០៤. ២១ ឆ្នាំមុន

៤០៧ ការកាត់ទុក ការជំទាស់

៤០៩ អ្នកផ្គត់ផ្គង់ឥណទាយិក

## ៤១ អ្នកជាប់ពន្ធ អតិថិជន

៤១១ អ្នកជាប់ពន្ធ (ពន្ធគយ)

៤១១. ១ នៅរតនាគារកណ្តាល

៤១១. ១០ ឆ្នាំនេះ

៤១១. ១១ ឆ្នាំមុន

៤១១. ២ នៅរតនាគារខេត្ត-ក្រុង

៤១១. ២០ ឆ្នាំនេះ

៤១១. ២១ ឆ្នាំមុន

៤១២ អ្នកជាប់ពន្ធ (ពន្ធដារ)

៤១២. ១ នៅរតនាគារកណ្តាល

៤១២. ១០ ឆ្នាំនេះ

៤១២. ១១ ឆ្នាំមុន

៤១២. ២ នៅរតនាគារខេត្ត-ក្រុង

៤១២. ២០ ឆ្នាំនេះ

៤១២. ២១ ឆ្នាំមុន

៤១៣ អតិថិជន (ចំណូលមិនមែនសារពើពន្ធ)



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

៤១៣.១ នៅរតនាគារកណ្ដាល

៤១៣.១.១ ប្រាក់រៀល

*៤១៣.១.១០ ឆ្នាំនេះ*

*៤១៣.១.១១ ឆ្នាំមុន*

៤១៣.១.២ ប្រាក់ដុល្លារ

*៤១៣.១.២០ ឆ្នាំនេះ*

*៤១៣.១.២១ ឆ្នាំមុន*

៤១៣.២នៅរតនាគារខេត្ត-ក្រុង

៤១៣.២០ ឆ្នាំនេះ

៤១៣.២១ ឆ្នាំមុន

## ៤២ បុគ្គលិក

៤២១ ប្រាក់បៀវត្ស និងលាភការត្រូវសង

៤២១.១ នៅរតនាគារកណ្ដាល

៤២១.១០ ឆ្នាំនេះ

៤២១.១១ ឆ្នាំមុន

៤២១.២ នៅរតនាគារខេត្ត-ក្រុង

៤២១.២០ ឆ្នាំនេះ

៤២១.២១ ឆ្នាំមុន

៤២២ សោហ៊ុយបេសកកម្ម និងសោហ៊ុយផ្សេងៗត្រូវសង

៤២២.១ នៅរតនាគារកណ្ដាល

៤២២.១.១ ប្រាក់រៀល



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

*៤២២.១.១០ ឆ្នាំនេះ*

*៤២២.១.១១ ឆ្នាំមុន*

៤២២.១.២ ប្រាក់ដុល្លារ

*៤២២.១.២០ ឆ្នាំនេះ*

*៤២២.១.២១ ឆ្នាំមុន*

៤២២.២ នៅរតនាគារខេត្ត-ក្រុង

៤២២.២០ ឆ្នាំនេះ

៤២២.២១ ឆ្នាំមុន

## ៤៤ រដ្ឋ និងសមូហភាពសាធារណៈផ្សេងៗ

៤៤១ ប្រាក់បញ្ញើមូលធនអាណត្តិប្រៃសណីយ៍

៤៤១.១ នៅរតនាគារកណ្តាល

៤៤១.២ នៅរតនាគារខេត្ត-ក្រុង

៤៤២ ប្រាក់បញ្ញើថវិកាខេត្ត-ក្រុង

៤៤២.០១ ប្រាក់បញ្ញើថវិកាខេត្ត-ក្រុង

៤៤២.០២ ប្រាក់បញ្ញើថវិការាជធានីភ្នំពេញ អគ្គិសនី

៤៤២.០៣ ប្រាក់បញ្ញើថវិការាជធានីភ្នំពេញ រដ្ឋាករទឹក

៤៤៣ ប្រាក់បញ្ញើថវិកាឃុំ សង្កាត់

## ៤៥ ប្រាក់បញ្ញើមូលធននៅរតនាគារ

៤៥០ ប្រាក់បញ្ញើរបស់ក្រុមហ៊ុនឯកជន

៤៥០.១ នៅរតនាគារកណ្តាល

៤៥០.១០ ឆ្នាំនេះ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

*៤៥០.១០.៥* *បង់ប្រាក់*

*៤៥០.១០.៩* *អាណត្តិ*

៤៥០.១១ ឆ្នាំមុន

*៤៥០.១១.៥* *បង់ប្រាក់*

*៤៥០.១១.៩* *អាណត្តិ*

៤៥០.២ នៅរតនាគារកណ្តាល

៤៥០.២០ ឆ្នាំនេះ

*៤៥០.២០.៥* *បង់ប្រាក់*

*៤៥០.២០.៩* *អាណត្តិ*

៤៥០.២១ ឆ្នាំមុន

*៤៥០.២១.៥* *បង់ប្រាក់*

*៤៥០.២១.៩* *អាណត្តិ*

៤៥១ ប្រាក់បញ្ញើរបស់គ្រឹះស្ថានសេដ្ឋកិច្ចស្វយ័ត

៤៥១.១ នៅរតនាគារកណ្តាល

៤៥១.១០ ឆ្នាំនេះ

៤៥១.១១ ឆ្នាំមុន

៤៥១.២ នៅរតនាគារខេត្ត-ក្រុង

៤៥១.២០ ឆ្នាំនេះ

៤៥១.២១ ឆ្នាំមុន

៤៥២ ប្រាក់បញ្ញើរបស់សហគ្រាសចំរុះ

៤៥៣ ប្រាក់បញ្ញើមូលនិធិរបស់អង្គការជាតិ អន្តរជាតិ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

៤៥៨ គណនីទំនាក់ទំនង

៤៥៨. ១ ទំនាក់ទំនងរវាងរតនាគារកណ្តាល និងរតនាគារខេត្ត-ក្រុង

៤៥៨. ១. ៣ ផ្ទេរសាច់ប្រាក់

៤៥៨. ១. ៤ ផ្ទេរប្រតិបត្តិការផ្សេងៗ

៤៥៨. ១. ៥ ផ្ទេរសមតុល្យ

៤៥៨. ២ ទំនាក់ទំនងរវាង រតនាគារខេត្ត-ក្រុង និងរតនាគារកណ្តាល

៤៥៨. ២. ៣ ផ្ទេរសាច់ប្រាក់

៤៥៨. ២. ៤ ផ្ទេរប្រតិបត្តិការផ្សេងៗ

៤៥៨. ២. ៥ ផ្ទេរសមតុល្យ

## ៤៦ ឥណទាយិក ឥណទាយីផ្សេងៗ

៤៦០ វិសមភាពបេឡាត្រូវដោះស្រាយ

៤៦០. ១ វិសមភាពបេឡា ឥណទាយិក

៤៦០. ២ វិសមភាពបេឡា ឥណទាយី

៤៦១ ឱនភាពគណនេយ្យត្រូវដោះស្រាយ

៤៦១. ១ នៅរតនាគារកណ្តាល

៤៦១. ២ នៅរតនាគារខេត្ត-ក្រុង

៤៦២ ប្រាក់តំកល់ និងធានាលើទីផ្សារសាធារណៈ

៤៦២. ១ នៅរតនាគារកណ្តាល

៤៦២. ១. ១ ប្រាក់រៀល

៤៦២. ១. ២ ប្រាក់ដុល្លារ

៤៦២. ២ នៅរតនាគារខេត្ត-ក្រុង



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

៤៦៣ ឥណទាយិកផ្សេងៗ

៤៦៣.១មូលនិធិថែទាំផ្លូវ

៤៦៣.២មូលនិធិសងការខូតខាត

៤៦៤ មូលនិធិឃុំ-សង្កាត់

៤៦៥ ឥណទាយីផ្សេងៗ

៤៦៥.១ អតិរេកពីការបង់ប្រាក់លើស

៤៦៧ ប្រាក់បញ្ញើរបស់ក្រសួង-មន្ទីរ

៤៦៧.១ ប្រាក់បញ្ញើរបស់ក្រសួង

៤៦៧.១០ ឆ្នាំនេះ

៤៦៧.១១ ឆ្នាំមុន

៤៦៧.២ ប្រាក់បញ្ញើរបស់អង្គភាពចំណុះក្រសួង

៤៦៧.២០ ឆ្នាំនេះ

៤៦៧.២១ ឆ្នាំមុន

៤៦៧.៣ប្រាក់បញ្ញើរបស់មន្ទីរ

៤៦៧.២០ ឆ្នាំនេះ

៤៦៧.២១ ឆ្នាំមុន

៤៦៧.៤ ប្រាក់បញ្ញើរបស់អង្គភាពចំណុះមន្ទីរ

៤៦៧.៤០ ឆ្នាំនេះ

៤៦៧.៤១ ឆ្នាំមុន

៤៦៨ ផលត្រូវទទួល និងបន្ទុកត្រូវសង

៤៦៨.១ បន្ទុកត្រូវសងទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

៦១៨. ២ បន្ទុកត្រូវសងលើធនធានថៃទាំផ្លូវ

៦១៨. ៣ បន្ទុកត្រូវសងលើការខូចខាត

## ៤៧ គណនីចំលង ឬគណនីរងចាំ

៤៧០ ចំណូលត្រូវនិយ័តភាព

៤៧០. ១ កម្រៃរូមរតនាគារ

៤៧០. ២ កម្រៃអត្ថប្រយោជន៍រតនាគារ

៤៧០. ៣សាច់ប្រាក់បានទទួលពីរតនាគារខេត្ត-ក្រុង រង់ចាំនិយ័ត្តកម្ម

៤៧០. ៤ ចំណេញពីអត្រាប្តូរប្រាក់រង់ចាំការដោះស្រាយ

៤៧០. ៨ ចំណូលផ្សេងៗ និងបង្វែររង់ចាំដោះស្រាយ

៤៧១ ចំណូលបណ្តោះអាសន្ន (គយ និងពន្ធ)

៤៧១. ១ នៅរតនាគារកណ្តាល

៤៧១. ២ នៅរតនាគារខេត្ត-ក្រុង

៤៧២ ចំណាយរង់ចាំនិយ័តភាព

៤៧២. ១ ចំណាយមុនការធ្វើអាណត្តិកិច្ច (ការប្រាក់ ប្រាក់ដើម)

៤៧២. ២ សាច់ប្រាក់បានផ្ទេរទៅរតនាគារខេត្ត- ក្រុងរង់ចាំធ្វើនិយ័តភាព

៤៧២. ៤ ខាតពីអត្រាប្តូរប្រាក់រង់ចាំការដោះស្រាយ

៤៧២. ៨ ចំណាយផ្សេងៗរង់ចាំដោះស្រាយ

៤៧៣ ចំណាយជាបណ្តោះអាសន្ន (បុរេប្រទានសាច់ប្រាក់) សំរាប់ដំណើរការ

៤៧៣. ១ នៅរតនាគារកណ្តាល

៤៧៣. ១. ១ ប្រាក់បៀវត្ស

*៤៧៣. ១. ១០ ឆ្នាំនេះ*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

*៤៧៣.១.១១* *ឆ្នាំមុន*

៤៧៣.១.២ ប្រាក់ដុល្លារ

*៤៧៣.១.២០* *ឆ្នាំនេះ*

*៤៧៣.១.២១* *ឆ្នាំមុន*

៤៧៣.២ នៅរតនាគារខេត្ត-ក្រុង

៤៧៣.២.១ រតនាគារខេត្ត-ក្រុង

*៤៧៣.២.១០* *ឆ្នាំនេះ*

*៤៧៣.២.១១* *ឆ្នាំមុន*

៤៧៣.២.២ មន្ទីរនានា

*៤៧៣.២.២០* *ឆ្នាំនេះ*

*៤៧៣.២.២១* *ឆ្នាំមុន*

៤៧៤ ចំណូលបានទទួលពុំទាន់មានសាលាកប័ត្រ

៤៧៤.១ នៅរតនាគារកណ្តាល

៤៧៤.១.១ ប្រាក់រៀល

៤៧៤.១.២ ប្រាក់ដុល្លារ

៤៧៤.២ នៅរតនាគារខេត្ត-ក្រុង

៤៧៥ ចំណូលបណ្តោះអាសន្នរបស់គណនេយ្យកររដ្ឋបាលហិរញ្ញវត្ថុ

៤៧៥.៣ អង្គភាពគយ និងរដ្ឋាករ

៤៧៥.៤ អង្គភាពពន្ធដារ

៤៧៧ រជ្ជទេយ្យករចំណូល

៤៧៧.១ នៅរតនាគារកណ្តាល

៤៧៧.២ នៅរតនាគារខេត្ត-ក្រុង



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

៤៧៨ ចំណាយបណ្តោះអាសន្ន (បុរេប្រទានសាច់ប្រាក់) សំរាប់វិនិយោគ

៤៧៨.១ រតនាគារកណ្តាល

៤៧៨.១.១ ប្រាក់រៀល

*៤៧៨.១.១០ ឆ្នាំនេះ*

*៤៧៨.១.១១ ឆ្នាំមុន*

៤៧៨.១.២ ប្រាក់ដុល្លារ

*៤៧៨.១.២០ ឆ្នាំនេះ*

*៤៧៨.១.២១ ឆ្នាំមុន*

៤៨២ ចំណូលត្រូវប្រមូលបានកត់ត្រាទុកមុន

៤៨២.១ ចំណូលគយ និងរដ្ឋាករ

៤៨២.២ ចំណូលពន្ធដារ

៤៨២.៣ចំណូលមិនមែនសារពើពន្ធ

៤៨៦ បន្ទុកបានពិនិត្យកត់ត្រាមុន

៤៨៦.១ នៅរតនាគារកណ្តាល

៤៨៦.២ នៅរតនាគារខេត្ត- ក្រុង

៤៨៧ ផលបានពិនិត្យកត់ត្រាមុន

៤៨៧.១ នៅរតនាគារកណ្តាល

៤៨៧.២ នៅរតនាគារខេត្ត- ក្រុង

## គណនីលេខ ៥ គណនីហិរញ្ញវត្ថុ

### ៥១ ធនាគារ

៥១០ គណនីចរន្តនៅធនាគារជាតិនៃកម្ពុជា និងនៅសាខា

៥១០.១ របស់រតនាគារកណ្តាល



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

៥១០.១១ គណនីចរន្ត

៥១០.១២ បណ្ណរតនាគារ

៥១០.២ របស់រតនាគារខេត្ត-ក្រុង

៥១០.២.០១ ចរិការដ្ឋ និងខេត្ត-ក្រុង

៥១០.២.០២ ចរិកាឃុំ សង្កាត់

៥១១ មូលប្បទានបត្រ ធ្វើបេឡានិច្ច័យ

៥១១.១ នៅរតនាគារកណ្តាល និងខេត្ត-ក្រុង

៥១១.៣នៅអង្គភាពគយ និងរដ្ឋាករ

៥១១.៤ នៅអង្គភាពពន្ធដារ

៥១២ មូលប្បទានបត្រ បានបោះផ្សាយ

៥១៣ ប្រាក់រូបិយប័ណ្ណនៅធនាគារជាតិនៃកម្ពុជា

៥១៤ ប្រាក់បញ្ញើជំនួយជាប្រាក់រៀលនៅធនាគារជាតិនៃកម្ពុជា

៥១៤.១ ប្រាក់បញ្ញើជំនួយជប៉ុន នៅធនាគារជាតិនៃកម្ពុជា

៥១៤.២ ប្រាក់បញ្ញើជំនួយអាឡឺម៉ង់ នៅធនាគារជាតិនៃកម្ពុជា

៥១៤.៣ប្រាក់បញ្ញើជំនួយបារាំង នៅធនាគារជាតិនៃកម្ពុជា

៥១៤.៤ ប្រាក់បញ្ញើកំចីបន្តពីធនាគារអភិវឌ្ឍន៍អាស៊ី

៥១៤.៥ ប្រាក់បញ្ញើកំចីបន្តពីធនាគារពិភពលោក

៥១៤.៦ ហិរញ្ញប្បទានពីសហគមន៍អ៊ឺរ៉ុបលើកំណែទម្រង់អប់រំ

៥១៦ ប្រាក់បញ្ញើមូលនិធីនៅធនាគារ (ក្រៅរតនាគារ)

## ៥៣ បេឡាសាច់ប្រាក់

៥៣២ បេឡានៅរតនាគារកណ្តាល

៥៣២.១បេឡានៅរតនាគារកណ្តាល


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

៥៣២. ២ បេឡានៅរតនាគារខេត្ត- ក្រុង

៥៣២. ៣ បេឡានៅអង្គភាពគយ និងរដ្ឋាករ

៥៣២. ៤បេឡានៅអង្គភាពពន្ធដារ

## ៥៤ វជ្ជទេយ្យបុរេប្រទាន

៥៣៤ វជ្ជទេយ្យករបុរេប្រទាន

៥៣៤. ១នៅរតនាគារកណ្តាល

៥៣៤. ២នៅរតនាគារខេត្ត- ក្រុង

៥៤៤ វជ្ជទេយ្យករបុរេប្រទាន ថវិកាកម្មវិធី

៥៤៤. ១ នៅរតនាគារកណ្តាល

៥៤៤. ២ នៅរតនាគារខេត្ត- ក្រុង

## ថ្នាក់លេខ ៦ គណនីចំណាយ

## ៦០ ការទិញ

៦០១ សម្ភារៈ ផ្គត់ផ្គង់ ថែទាំ

៦០១១ សម្ភារៈផ្គត់ផ្គង់សំអាត និងអនាម័យ

៦០១២ សម្ភារៈផ្គត់ផ្គង់សំរាប់ថែទាំអាគារ និងប្រាសាទ

៦០១៣ សម្ភារៈផ្គត់ផ្គង់សំរាប់ថែទាំផ្លូវថ្នល់ ស្ពាន លូ

៦០១៤ សម្ភារៈផ្គត់ផ្គង់សំរាប់ថែទាំ សម្ភារៈ ឧបករណ៍

៦០១៥ ប្រេងឥន្ធនៈ និងប្រេងរំអិល

៦០១៨ ផ្សេងៗ

៦០២ សម្ភារៈផ្គត់ផ្គង់ផ្នែករដ្ឋបាល

៦០២១ សម្ភារៈការិយាល័យ និងការបោះពុម្ព

៦០២២ សៀវភៅមើល និងឯកសារ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

៦០២៨ ផ្សេងៗ

៦០៣ ស្បៀងអាហារ និងផលិតកម្មកសិកម្ម

៦០៣.១ ស្បៀង

៦០៣.២ ចំណីសត្វ

៦០៣.៣ ពូជ និងកូនរុក្ខជាតិ

៦០៣.៤ ផលិតផលការពារសុខុមាលភាពរុក្ខជាតិ និងជី

៦០៣.៥ ពូជសត្វ ឱសថ និងវត្ថុធាតុសំរាប់បសុពេទ្យ

៦០៣.៨ ផ្សេងៗ

៦០៤ សំលៀកបំពាក់ និងការតុបតែង

៦០៤.១ ឯកសណ្ឋាន

៦០៤.២ សំលៀកបំពាក់ការពារសុវត្ថិភាព

៦០៤.៣ មេដាយ (គ្រឿងឥស្សរិយយស)

៦០៤.៨ ផ្សេងៗ

៦០៥ សម្ភារៈតូចតាច សង្ហារឹម និងសម្ភារៈបរិក្ខារ

៦០៥.១ សម្ភារៈ និងបរិក្ខារ បច្ចេកទេស

៦០៥.២ សង្ហារឹម

៦០៥.៣ សំភារៈប្រើប្រាស់

៦០៥.៤ សំភារៈ និងឧបករណ៍ដឹកជញ្ជូន

៦០៥.៨ ផ្សេងៗ

៦០៦ ថាមពល និងទឹក

៦០៦.១ អគ្គិសនី

៦០៦.២ ទឹក



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

៦០៦.៨ ផ្សេងៗ

៦០៧ សម្ភារៈបរិក្ខារថែទាំសុខភាព

៦០៨ សម្ភារៈផ្គត់ផ្គង់

## ៦១ សេវាក្រៅ

៦១១ កិច្ចសន្យានៃការផ្តល់សេវាជាមួយសហគ្រាស

៦១២ ការជួលមធ្យោបាយដឹកជញ្ជូន

៦១៣ ថ្លៃឈ្នួល និងបន្ទុក (អសង្ហារឹម)

៦១៤ សោហ៊ុយបណ្តុះបណ្តាលបុគ្គលិក ក្នុង និងក្រៅ

៦១៥ ការថែទាំ និងជួសជុល

៦១៥.១ ការថែទាំដីធ្លី ព្រៃឈើ

៦១៥.២ ការថែទាំ ជួសជុល អាគារ និងប្រាសាទ

៦១៥.៣ ការថែទាំ និងជួសជុល ផ្លូវ ផ្លូវលំ ស្ពាន និងលូ

៦១៥.៤ ការថែទាំបណ្តាញផ្សេងៗ

៦១៥.៥ ការថែទាំដែននេសាទ

៦១៥.៦ ការថែទាំ និងជួសជុលមធ្យោបាយដឹកជញ្ជូន

៦១៥.៧ ការថែទាំ និងជួសជុលសម្ភារៈ ឧបករណ៍ការិយាល័យ សម្ភារៈព័ត៌មានវិទ្យា និងទូរគមនាគមន៍

៦១៥.៨ ការថែទាំ និងជួសជុលសម្ភារៈ ឧបករណ៍បច្ចេកទេស

៦១៦ សោហ៊ុយធានារ៉ាប់រង

៦១៧ សោហ៊ុយសិក្សា ពិសោធន៍ សោហ៊ុយនៃការប្រើប្រាស់សេវា និងសោហ៊ុយនៃការប្រើប្រាស់សិទ្ធិ

៦១៧.១ សោហ៊ុយសិក្សា ពិសោធន៍

៦១៧.២ សោហ៊ុយនៃការប្រើប្រាស់សេវា



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

៦១៧. ៣សោហ៊ុយនៃការប្រើប្រាស់សិទ្ធិ

៦១៧.៤ សំណង់ផ្នែកស៊ីវិល

៦១៨ សោហ៊ុយដឹកជញ្ជូន

៦១៨.១ សម្ភារៈ និង ទំនិញ

## ៦២ សេវាខាងក្រៅផ្សេងៗ

៦២១ បុគ្គលិកខាងក្រៅ

៦២១.១ ភ្នាក់ងារជាតិជាប់កិច្ចសន្យា

៦២១.២ ភ្នាក់ងារបរទេសជាប់កិច្ចសន្យា

៦២១. ៣បុគ្គលិក សម្ពហភាពសាធារណៈផ្សេងៗ

៦២២ ទំនាក់ទំនងសាធារណៈ និងផ្សព្វផ្សាយ

៦២២.១ សោហ៊ុយទទួលភ្ញៀវជាតិ

៦២២.២ សោហ៊ុយទទួលភ្ញៀវបរទេស

៦២២. ៣ប្រជុំ សិក្ខាសាលា និងសន្និសីទ

៦២២.៤ សោហ៊ុយពិធីបុណ្យ

៦២២.៥ ចំណាយសំរាប់វត្ថុអនុស្សាវរីយ៍ ក្នុងប្រទេស និងក្រៅប្រទេស

៦២២.៦ សោហ៊ុយសំរាប់ការតាំងពិពណ៌នៅក្នុង និងក្រៅប្រទេស

៦២២.៧ ការឃោសនា និងផ្សព្វផ្សាយព័ត៌មានសាធារណៈ

៦២៣ សោហ៊ុយជាវព័ត៌មាន និងឯកសារ

៦២៤ ចំណាយទូទាត់សោហ៊ុយក្នុងប្រទេស

៦២៤.១ សោហ៊ុយដឹកជញ្ជូន

៦២៤.២ សោហ៊ុយបេសកកម្ម

៦២៤. ៣សោហ៊ុយស្នាក់នៅ

៦២៥ ចំណាយទូទាត់សោហ៊ុយក្រៅប្រទេស

៦២៥.១ សោហ៊ុយដឹកជញ្ជូន

៦២៥.២ សោហ៊ុយបេសកកម្ម

៦២៥.៣ សោហ៊ុយស្នាក់នៅ

៦២៦ សោហ៊ុយប្រៃសណីយ៍ និងទូរគមនាគមន៍

៦២៦.១ សោហ៊ុយប្រៃសណីយ៍

៦២៦.២ សោហ៊ុយទូរគមនាគមន៍

៦២៧ សោហ៊ុយធនាគារ

៦២៨ សោហ៊ុយផ្សេងៗ

## ៦៣ ពន្ធ និងអាករ

៦៣១ លតាប័ត្រ

៦៣២ បន្ទុកពន្ធគយលើការនាំចូលទំនិញ និងសម្ភារៈ

៦៣៣ បន្ទុកពន្ធប្រថាប់ត្រា

៦៣៤ បន្ទុកពន្ធលើផលទុននៃដីធ្លី ផ្ទះសម្បែង

## ៦៤ បន្ទុកបុគ្គលិក

៦៤១ លាភការ និងប្រាក់បំណាច់ នៃអំណាចសាធារណៈ

៦៤១.១ ខុទ្ទកាល័យព្រះបរមរាជវាំង

៦៤១.២ ប្រាក់បំណាច់ប្រធាន អនុប្រធាន និងសមាជិករបស់ស្ថាប័នកំពូល

៦៤១.៣ ប្រាក់បំណាច់នាយករដ្ឋមន្ត្រី និង ឧបនាយករដ្ឋមន្ត្រី

៦៤១.៤ ប្រាក់បំណាច់រដ្ឋមន្ត្រី- រដ្ឋលេខាធិការ និង អនុរដ្ឋលេខាធិការ

៦៤១.៥ ប្រាក់បំណាច់អគ្គទូត

៦៤១.៦ លាភការទីប្រឹក្សា

៦៤១.៧ លាភការ បេសកជន

៦៤១.៨ លាភការ អ្នកជំនួយការ

៦៤១.៩ ការសង និងការបង្វិលវិញ

៦៤២ លាភការ និងប្រាក់បំណាច់បុគ្គលិកក្របខ័ណ្ឌអចិន្ត្រៃយ៍

៦៤២.១ បៀវត្សមូលដ្ឋាន

៦៤២.២ ប្រាក់បំណាច់មុខងារ

៦៤២. ៣ ប្រាក់បំណាច់ម៉ោងបន្ថែម

៦៤២.៤ ប្រាក់កម្រៃគរុកោសល្យ

៦៤២.៥ ប្រាក់បំប៉នជីវភាពពិសេស

៦៤២.៦ ប្រាក់បំណាច់តំបន់

៦៤២.៧ ប្រាក់បំណាច់ទទួលខុសត្រូវ

៦៤២.៨ ប្រាក់បំណាច់ការងារធ្ងន់ និង ប៉ះពាល់សុខភាព

៦៤២.៩ ការសង និង ការបង្វិលវិញ

៦៤៣ រង្វាន់ និងប្រាក់បំណាច់ផ្សេងៗទៀត

៦៤៣.១ កន្សោមអាទិភាព

៦៤៣.២ ប្រាក់បំណាច់សម្រាប់ប្រឡង- ប្រឡងប្រជែង

៦៤៣. ៣ រង្វាន់

៦៤៣.៤ ប្រាក់បំណាច់បុគ្គលិកក្រសួងផ្សេងៗ

៦៤៣.៥ ប្រាក់បំណាច់គ្រូបង្គោលក្រសួងផ្សេងៗ

៦៤៣.៦ អាហារសម្រាប់បុគ្គលិករដ្ឋ

៦៤៣.៨ ផ្សេងៗ

៦៤៣.៩ ការសង និង ការបង្វិលវិញ



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

៦៤៤ លាភការ និងប្រាក់បំណាច់ បុគ្គលិកមិនមែនក្របខ័ណ្ឌ

៦៤៤.១ បៀវត្សមូលដ្ឋានបុគ្គលិកជាប់កិច្ចសន្យា

៦៤៤.២ លាភការផ្សេងៗទៀត បុគ្គលិកជាប់កិច្ចសន្យា

៦៤៤.៣ បៀវត្សមូលដ្ឋាន បុគ្គលិកអណ្តែត

៦៤៤.៤ លាភការផ្សេងៗទៀត បុគ្គលិកអណ្តែត

៦៤៤.៩ ការសង និង ការបង្វិលវិញ

៦៤៥ ប្រាក់វិភាជន៍សង្គម

៦៤៥.១ ប្រាក់បំណាច់ជាលក្ខណៈគ្រួសារ

៦៤៥.២ មន្ត្រីមានជម្ងឺ និង ឧបត្ថម្ភអ្នកសម្រាលកូន

៦៤៥.៣ មរណៈភាព

៦៤៥.៤ ឧបត្ថម្ភនិវត្តជន

៦៤៥.៥ ឧបត្ថម្ភដល់អ្នកសុំឈប់ពីការងារ

៦៤៥.៦ គ្រោះថ្នាក់ក្នុងការងារ និង ទព្វលភាព

៦៤៥.៧ ឧបត្ថម្ភ ដល់កូនកំព្រារបស់មន្ត្រីរាជការ

៦៤៥.៨ ផ្សេងៗ

៦៤៥.៩ ការសង និងការបង្វិលវិញ

## ៦៥ ឧបត្ថម្ភកធន និង ជំនួយសង្គម

៦៥១ ឧបត្ថម្ភកធនដល់រដ្ឋបាលដែនដី

៦៥១.១ ឧបត្ថម្ភកធនដល់ខេត្ត- ក្រុង

៦៥១.២ ឧបត្ថម្ភកធនដល់ ស្រុក

៦៥១.៣ ឧបត្ថម្ភកធនដល់ ឃុំ សង្កាត់

៦៥២ ឧបត្ថម្ភកធនដល់អង្គការសាធារណៈ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

៦៥៣ ឧបត្ថម្ភកធនដល់គ្រឹះស្ថានសាធារណៈមានលក្ខណៈរដ្ឋបាល

៦៥៤ ការចូលរួមក្នុងការអនុវត្តគម្រោង

៦៥៤.១ ចំណាយចរន្ត ក្នុងការអនុវត្តគម្រោង

៦៥៤.២ ចំណាយជាមូលធន ក្នុងការអនុវត្តគម្រោងវិនិយោគ

៦៥៤.៩ និយ័តកម្មចំណាយវិនិយោគ

៦៥៥ ឧបត្ថម្ភកធនដល់សហគ្រាសសាធារណៈ និងសហគ្រាសឯកជន

៦៥៥.១ ឧបត្ថម្ភកធនដល់សហគ្រាសសាធារណៈ

៦៥៥.២ ឧបត្ថម្ភកធនដល់សហគ្រាសឯកជន

៦៥៦ វិភាគទានដល់អង្គការអន្តរជាតិនានា

៦៥៦.១ អង្គការសហប្រជាជាតិ

៦៥៦.២ ធនាគារពិភពលោក

៦៥៦. ៣ ធនាគារអភិវឌ្ឍន៍អាស៊ី

៦៥៦.៤ សហព័ន្ធអន្តរជាតិខាងកីឡាផ្សេងៗ

៦៥៦.៥ អង្គការអាស៊ាន

៦៥៦.៦ អង្គការអន្តរជាតិផ្សេងៗទៀត

៦៥៧ ជំនួយសង្គម និងប្រាក់វិភាជន៍

៦៥៧.១ ជំនួយដល់ប្រជាជនសម្រាកពេទ្យ និងចំណាយដំណើរការរបស់មណ្ឌលសុខភាព

៦៥៧.២ ឱសថ

៦៥៧. ៣ អាហារ និងសម្ភារៈ (ស្បៀងបម្រុងរដ្ឋ)

៦៥៧.៤ ជួយជនរងគ្រោះ ដោយគ្រោះធម្មជាតិ

៦៥៧.៥ អាហារូបករណ៍សម្រាប់ការសិក្សា និងស្រាវជ្រាវក្នុងប្រទេស

៦៥៧.៦ អាហារូបករណ៍សម្រាប់ការសិក្សា និងស្រាវជ្រាវក្រៅប្រទេស

៦៥៧.៧ សំណងខូចខាតដោយឧប្បទ្ទវហេតុសាធារណៈ

៦៥៧.៨ ផ្សេងៗ

៦៥៨ ឧបត្ថម្ភដល់អង្គភាពដែលមានលក្ខណៈសង្គម និងវប្បធម៌

៦៥៨.១ ឧបត្ថម្ភ សហគមន៍

៦៥៨.២ ឧបត្ថម្ភ មណ្ឌលកុមារកំព្រា

៦៥៨.៣ ឧបត្ថម្ភ ដំណើរលំហែ និង សិក្សា

៦៥៨.៤ ឧបត្ថម្ភ កាកបាទក្រហម

៦៥៨.៥ ឧបត្ថម្ភ សហគមន៍កីឡា និង វប្បធម៌

៦៥៨.៦ ឧបត្ថម្ភ មណ្ឌលស្តារលទ្ធភាពពលកម្ម នីតិសម្បទា និងបណ្តុះបណ្តាលអភិវឌ្ឍន៍

៦៥៨.៧ ចំណាយសង្គមកិច្ចរបស់ព្រះមហាក្សត្រ

## ៦៦ បន្ទុកហិរញ្ញវត្ថុ

៦៦១ ការប្រាក់នៃបំណុលក្នុងប្រទេស

៦៦១.១ ធនាគារជាតិនៃកម្ពុជា

៦៦១.២ ធនាគារពាណិជ្ជ

៦៦១.៣ ប័ណ្ណរតនាគារ

៦៦១.៤ សញ្ញាប័ណ្ណ

៦៦១.៨ ផ្សេងៗ

៦៦២ ការប្រាក់នៃបំណុលក្រៅប្រទេស

៦៦២.១ ពហុភាគី

៦៦២.២ ទ្វេភាគី

៦៦៦ ខាតពីការប្តូរប្រាក់

៦៦៨ បន្ទុកហិរញ្ញវត្ថុផ្សេងៗទៀត



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

## ៦៧ បន្ទុកពិសេស

៦៧១ ឥណទេយ្យដែលទទួលស្គាល់តែទារមិនបាន

៦៧៥ តម្លៃគណនេយ្យនៃចំណែកសកម្មបានលក់ (តម្លៃទៅសល់)

## ៦៨ ទាយជ្ជទានអោយដល់រំលស់អចលវត្ថុ

៦៨១ ទាយជ្ជទានអោយដល់រំលស់អចលកម្មអរូបី

៦៨២ ទាយជ្ជទានអោយដល់រំលស់អចលកម្មរូបី

## ថ្នាក់លេខ ៧ គណនី ចំណូល

## ៧០ ចំណូលសារពើពន្ធក្នុងប្រទេស

៧០០ ពន្ធលើផលទុន ប្រាក់ចំណេញ និង កម្រៃទុន (រូបវន្តបុគ្គល)

៧០០.១ ពន្ធលើប្រាក់បៀវត្ស

៧០០.២ ពន្ធលើផលទុននៃដីធ្លី ផ្ទះសម្បែង

៧០០.៣ ពន្ធលើផលចំណេញពីការលក់អចលនៈទ្រព្យ

៧០១ ពន្ធលើផលទុន ប្រាក់ចំណេញ និង កម្រៃទុន (នីតិបុគ្គល)

៧០១.១ ពន្ធលើប្រាក់ចំណេញរបស់សហគ្រាសសាធារណៈ

៧០១.២ ពន្ធលើប្រាក់ចំណេញរបស់សហគ្រាសឯកជន

៧០១.៣ ពន្ធលើផលទុននៃដីធ្លី ផ្ទះសម្បែង

៧០១.៤ ពន្ធលើផលចំណេញពីការលក់អចលនៈទ្រព្យ

៧០២ ពន្ធទូទៅលើទ្រព្យសម្បត្តិ និង សេវា

៧០៣ ពន្ធលើទ្រព្យសម្បត្តិបានកំណត់

៧០៤ អាករលើសេវាដែលបានកំណត់

៧០៥ អាករលើការប្រើប្រាស់ទ្រព្យសម្បត្តិ ឬ ការអនុវត្តសកម្មភាព

៧០៨ ចំណូលសារពើពន្ធផ្សេងៗទៀត

៧០៩ ការសង និង ការបង្វិលវិញ

## ៧១ ចំណូលពន្ធ លើពាណិជ្ជកម្មក្រៅប្រទេស

៧១០ ពន្ធ និង អាករលើការនាំចូល

៧១០.១ ពន្ធគយលើការនាំចូល

៧១០.២ កម្រៃយកមុនពីការងារគយក្នុងការនាំចូល

៧១០.៣ ពន្ធគយលើផលិតផលតេលសិលា

៧១០.៤ អាករបន្ថែមលើផលិតផលតេលសិលាសម្រាប់ថែទាំផ្លូវថ្នល់

៧១០.៥ ផលនៃការលក់ផ្នែកគយ

៧១០.៦ ពិន័យផ្សេងៗ លើការនាំចូល

៧១១ ពន្ធ និង អាករលើការនាំចេញ

៧១១.១ អាករលើការនាំចេញឈើ

៧១១.២ អាករលើការនាំចេញកៅស៊ូ

៧១១.៣ អាករលើការនាំចេញផលិតផលតេលសិលា

៧១១.៤ អាករលើការនាំចេញផលិតផលកសិផលផ្សេងៗ

៧១១.៥ កម្រៃគ្រប់គ្រង និង ទិដ្ឋាការនាំចេញ

៧១១.៦ ពិន័យផ្សេងៗលើការនាំចេញ

៧១១.៨ ពន្ធ និង អាករលើការនាំចេញផ្សេងៗ

## ៧២ ផលទុននៃទ្រព្យសម្បត្តិរដ្ឋ

៧២០ ផលនៃសម្បទាន និងការជួលដីធ្លី

៧២០.១ សម្បទាននេសាទ

៧២០.២ សម្បទានព្រៃឈើ

៧២០.៣ សម្បទានពីប្រេងកាត

៧២០.៤ សម្បទានរ៉ែ

៧២០.៥ ការជួលដីទំនេរ

៧២០.៨ ផលនៃការជួលដីធ្លីផ្សេងៗ

៧២១ ផលទុនពីសហគ្រាសសាធារណៈ

៧២១.១ ចំនួនលើសនៃទុនចល័ត

៧២១.២ ប្រាក់ចំណេញរបស់សហគ្រាសសាធារណៈ

៧២១.៣ ការបង់ប្រាក់រំលស់

៧២១.៨ ផលទុនផ្សេងៗពីសហគ្រាសសាធារណៈ

## ៧៣ ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និង សេវា

៧៣០ ផលទុនសហគ្រាសសាធារណៈ រដ្ឋបាល និងសេវាដំណើរការរកចំណេញ

៧៣០.១ ផលទុនរបស់អាកាសចរណ៍ស៊ីវិល

៧៣០.២ ផលទុននៃសកម្មភាពភាយន្ត

៧៣០.៣ ផលទុននៃសកម្មភាពទេសចរណ៍

៧៣០.៤ ផលទុននៃសកម្មភាពវប្បធម៌

៧៣០.៥ ផលទុនពីប្រៃសណីយ៍ និង ទូរគមនាគមន៍

៧៣០.៦ ផលទុនពីវិទ្យុ និងទូរទស្សន៍

៧៣០.៧ ផលទុននៃសេវាផ្គត់ផ្គង់ទឹក

៧៣០.៨ ផលទុនផ្សេងៗទៀត

៧៣១ រដ្ឋបាល និង សេវា (មិនរកចំណេញ)

៧៣១.១ ការលក់សម្ភារៈបរិក្ខា- សម្ភារៈខូចខាត- សម្ភារៈសិក្សា

៧៣១.២ លក់ឯកសារ- លតាបត្រ- និងលិខិតបោះពុម្ពផ្សេងៗ

៧៣១.៣ ផលនៃការដឹកជញ្ជូនទំនិញ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

៧៣១.៤ ផលនៃប្រតិបត្តិការអន្តរាគមន៍ដើម្បីថែទាំកិច្ចដំណើរការ

៧៣១.៥ កម្រៃនៃការថែទាំ

៧៣១.៦ ផលបានពីការលក់ទ្រព្យសម្បត្តិកំទេចកំទី សត្វពាហនៈ

៧៣១.៨ ផលពីរដ្ឋបាល និងសេវាផ្សេងៗទៀត

៧៣២ ផលពីការគ្រប់គ្រងរដ្ឋបាល

៧៣២.១ អាករស្ថានទូត (ចំណូលពីលិខិតឆ្លងដែន និង ទិដ្ឋាការ)

៧៣២.២ ផលពីការចុះបញ្ជីគណបក្សនយោបាយ

៧៣២.៣ ផលលើការបង្កើតសហគ្រាស

៧៣២.៤ ផលពីការបង់សិទ្ធិប្រឡង

៧៣២.៥ ផលពីការលក់ស្លាកលេខ

៧៣២.៦ ចំណូលពីប្រដាប់ក្តី

៧៣២.៧ សេវាស៊ុរិយោដី និង សេវាសំណង់

៧៣២.៨ ផលពីការត្រួតពិនិត្យគុណភាពផលិតផល និងការគោរពបទដ្ឋាន

៧៣៣ ការជួលទ្រព្យសម្បត្តិអចល័ត

៧៣៣.១ ការជួលសហគ្រាសសាធារណៈនៅថ្នាក់រដ្ឋបាលកណ្តាល

៧៣៣.២ ការជួលសហគ្រាសសាធារណៈនៅខេត្ត- ក្រុង (មន្ទីរជំនាញ)

៧៣៣.៣ ការជួលសម្ភារៈ និង មធ្យោបាយដឹកជញ្ជូន

៧៣៣.២ ការជួលអចលនៈវត្ថុ (អសង្ហារឹម)

៧៣៣.២ ចំណូលពីការប្រើប្រាស់សេវាបង្ហែរ ដោយម្ចាស់កសិដ្ឋាន

## ៧៤ ផលពីការផាកពិន័យ និងការដាក់ទណ្ឌកម្ម

៧៤១ ផលពីការផាកពិន័យ និង ការដាក់ទណ្ឌកម្ម

## ៧៥ ការឧបត្ថម្ភ អំណោយ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

៧៥១ ឧបត្ថម្ភកធនពីទ្វេភាគី

៧៥២ ឧបត្ថម្ភកធនពីពហុភាគី

៧៥៣ ជំនួយផ្សេងៗទៀត

## ៧៦ ផលហិរញ្ញវត្ថុ

៧៦១ ការប្រាក់នៃការអោយខ្ចី

៧៦២ អន្តរការីយកម្មនៃទីផ្សារមូលប័ត្រ

៧៦៣ ភតិសន្យា

៧៦៤ អន្តរការីយកម្មនៃទីផ្សារអចលវត្ថុ

៧៦៥ អន្តរការីយកម្មនៃទីផ្សារធានារ៉ាប់រង

៧៦៦ ចំណេញពីការប្តូរប្រាក់

៧៦៨ ផលហិរញ្ញវត្ថុផ្សេងទៀត

## ៧៧ ផលផ្សេងៗ និង ផលពិសេស

៧៧១ ផលផ្សេងៗ និងកិច្ចប្រតិបត្តិការគ្រប់គ្រង

៧៧១.១ ចំណូលពីការបង់អតិរេករបស់ថវិកាខេត្ត- ក្រុង

៧៧១.២ កម្រៃរតនាគារ

៧៧១.៣ ចំណូលពីអតិរេករបស់ថវិការដ្ឋ

៧៧២ ផលនៃឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ

៧៧៥ ផលពីការលក់អចលនវត្ថុ

៧៧៧ ចំណែកនៃឧបត្ថម្ភកធន វិនិយោគផ្ទេរទៅគណនីលទ្ធផល

៧៧៨ ផលផ្សេងៗទៀត



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ៧៨ ការខារនៃវដ្ដនេយ្យ

៧៨១ ទៅរតនាគារជាតិ

៧៨២ ទៅរតនាគារខេត្ត- ក្រុង



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ឧបសម្ព័ន្ធទី ៣

# ច្បាប់

# ស្តីពី

# ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

**ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ** នេះ មានគោលដៅកំណត់គោលការណ៍ជាមូលដ្ឋាន សម្រាប់គ្រប់គ្រងប្រព័ន្ធហិរញ្ញវត្ថុសាធារណៈទាំងមូល និងសម្រាប់រៀបចំច្បាប់ហិរញ្ញវត្ថុ ជាពិសេស សម្រាប់ជំហានទីមួយៗ នៃដំណើរការរៀបចំអនុម័ត និងអនុវត្តថវិកា ការត្រួតពិនិត្យលទ្ធផលថវិកា ការកំណត់មុខងារ ការទទួលខុសត្រូវ ព្រមទាំងកម្មវិបាកលើកំហុសឆ្គង ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់ក្រសួង- ស្ថាប័ន អង្គភាពសាធារណៈ ប្រហាក់ប្រហែលគ្រឹះស្ថានសាធារណៈ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ។

**មាត្រា ២.-**

ច្បាប់នេះ មានគោលបំណងគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដោយគោរពគោលការណ៍ បូរណភាព អាជ្ញាភាព ឯកត្តភាព សមាគតភាព សកលភាព សង្គតិភាព គណនេយ្យភាព តម្លាភាព ស្ថិរភាព ភាពគ្រប់ជ្រុងជ្រោយ និង សមិទ្ធកម្ម ។ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនេះ គ្របដណ្តប់ទាំងហិរញ្ញវត្ថុសាធារណៈជាតិ ទាំងទំនាក់ទំនង និង អន្តរសកម្មរវាងហិរញ្ញវត្ថុសាធារណៈជាតិ ហិរញ្ញវត្ថុសាធារណៈអន្តរជាតិ ហិរញ្ញវត្ថុឯកជនជាតិ និងហិរញ្ញវត្ថុ ឯកជនអន្តរជាតិ ហើយត្រូវធានាការគោរពគោលការណ៍



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ថវិកា គណនេយ្យភាពហិរញ្ញវត្ថុ ភាពផ្សាភ្ជាប់គ្នារវាងថវិកា និងគោលនយោបាយ និងគណនេយ្យភាព ចំពោះសមិទ្ធកម្ម ។

**មាត្រា ៣.-**

ច្បាប់នេះ មានវិសាលភាពជាច្បាប់គោល ដែលត្រូវយកធ្វើជាមូលដ្ឋាន និងត្រូវគោរពអនុវត្តតាម សម្រាប់គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៤.-**

សម្រាប់ប្រើប្រាស់នៅក្នុងច្បាប់នេះ វាក្យស័ព្ទខាងក្រោមមានន័យដូចតទៅ:

**ច្បាប់ហិរញ្ញវត្ថុ** សំដៅដល់ច្បាប់ដែលគ្រោងចំណូល និងចំណាយប្រចាំឆ្នាំរបស់រដ្ឋ បទប្បញ្ញត្តិពាក់ព័ន្ធទៅនឹងវិស័យហិរញ្ញវត្ថុ និងការទូទាត់ផ្សេងៗដែលត្រូវបានប្រើប្រាស់សម្រាប់ការអនុវត្តមុខងារ កម្មវិធី និងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដោយអនុលោមទៅតាមបទប្បញ្ញត្តិនៃរដ្ឋធម្មនុញ្ញ និង ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងបទប្បញ្ញត្តិស្តីពីវិស័យហិរញ្ញវត្ថុដែលច្បាប់កំណត់ ។

**ច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ** គ្រោង និងអនុញ្ញាតសម្រាប់ឆ្នាំនីមួយៗនូវប្រភពធនធាន និងបន្ទុករបស់រដ្ឋ ។

**ច្បាប់កែតម្រូវ** សំដៅដល់ច្បាប់កែតម្រូវនៃច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ។

**ច្បាប់ទូទាត់ថវិកា** សំដៅដល់ច្បាប់ត្រួតពិនិត្យ និងវាយតម្លៃលទ្ធផលនៃការអនុវត្តច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ។

**ក្រសួង ស្ថាប័ន ឬ អង្គភាពសាធារណៈប្រហាក់ប្រហែល** សំដៅដល់ក្រសួង ស្ថាប័ន ឬ អង្គភាព ដែលទទួលហិរញ្ញប្បទានទាំងស្រុង ឬ មួយផ្នែកនៃថវិកាជាតិ ឬ/និង ដែលគ្រប់គ្រងទ្រព្យសកម្ម និងបំណុលរបស់រដ្ឋ ឬ/និង គណនេយ្យដែលច្បាប់បង្កើត ព្រមទាំងគ្រប់គ្រងចាត់ចែងសកម្មភាពទាំងឡាយណាដែលនាំឱ្យរដ្ឋជាប់កាតព្វកិច្ចហិរញ្ញវត្ថុ ឬ បំណុលផ្សេងៗ ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

**រយៈពេលមធ្យម** សំដៅដល់រយៈពេលដែលមិនតិចជាង ៣ ឆ្នាំ និងមិនលើសពី ៥ ឆ្នាំ ។

**របៀបវារៈគោលនយោបាយ** សំដៅដល់យុទ្ធសាស្ត្រសម្រាប់សម្រេចចក្ខុវិស័យរបស់រាជរដ្ឋាភិបាល ដែលឆ្លុះបញ្ចាំងនៅក្នុងផែនការរដ្ឋ ដែលរួមមានគោលនយោបាយជាតិ គោលនយោបាយតាមវិស័យ និង តាមអនុវិស័យ ។

**កម្មវិធី** សំដៅដល់ក្រុមនៃអនុកម្មវិធី ឬ/និងក្រុមនៃចង្កោមសកម្មភាព ដែលមានលក្ខណៈឯករាជ្យ តែមានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធ ហើយត្រូវបានរៀបចំឡើង ដើម្បីរួមចំណែកសម្រេចបាននូវគោលបំណងគោលនយោបាយរួមមួយ និងមានបញ្ជាក់ពីសកម្មភាពដែលត្រូវអនុវត្តលទ្ធផលក្នុងឆ្នាំ លទ្ធផលចុងក្រោយព្រមទាំងសូចនាករ ដែលជាមូលដ្ឋានសម្រាប់ការត្រួតពិនិត្យ និងវាយតម្លៃលទ្ធផលសម្រេចបានពីការអនុវត្តកម្មវិធី ។ កម្មវិធី អាចត្រូវបានបែងចែកជាអនុកម្មវិធី ។

**ភាពគ្រប់ជ្រុងជ្រោយនៃថវិកា** សំដៅដល់ថវិកាពេញលេញដែលឆ្លុះបញ្ចាំងគ្រប់ប្រភពចំណូល និងគ្រប់មុខ សញ្ញាចំណាយ ។

**តម្លាភាព** សំដៅដល់រាល់ច្បាប់បទប្បញ្ញត្តិ គោលការណ៍ នីតិវិធី និង ការអនុវត្តទាំងឡាយត្រូវផ្សព្វផ្សាយ ដោយទូលាយសម្រាប់ក្រសួង ស្ថាប័ន ឬ អង្គភាពសាធារណៈ និងសាធារណជន ។

**គណនេយ្យភាព** សំដៅដល់ការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័ន ឬ អង្គភាពសាធារណៈប្រហាក់ប្រហែល រដ្ឋបាលថ្នាក់ក្រោមជាតិ និងបុគ្គល ចំពោះមុខងារ និងភារកិច្ចដែលបានទទួលអនុវត្តតាមរយៈប្រព័ន្ធរបាយការណ៍ ។

**សង្គតិភាព** សំដៅដល់គ្រប់ក្រសួង ស្ថាប័ន ឬ អង្គភាពសាធារណៈ ប្រហាក់ប្រហែល និងរដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់ របស់ព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តគោលការណ៍តែមួយ ដោយប្រទាក់ក្រឡាគ្នា ។

**សកលភាពនៃថវិកា** សំដៅដល់គ្រប់ប្រភេទចំណូលទាំងអស់ អាចប្រើប្រាស់សម្រាប់រាល់មុខចំណាយដោយគ្មានលក្ខខណ្ឌ ។

**សមាគតភាពនៃថវិកា** សំដៅដល់គ្រប់ប្រភេទចំណូលទាំងអស់ និងគ្រប់មុខសញ្ញាចំណាយទាំងអស់ ត្រូវបង់ និងទូទាត់តាមរយៈប្រព័ន្ធគណនីទោលរបស់រតនាគារជាតិ ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

**បូរណភាព** សំដៅដល់ហិរញ្ញវត្ថុសាធារណៈមានប្រព័ន្ធតែមួយ ដែលមានលក្ខណៈពេញលេញគ្រប់ជ្រុងជ្រោយគ្មានការប្រទាំងប្រទើសទាំងផ្នែកគោលនយោបាយ ទាំងក្របខ័ណ្ឌច្បាប់ និងស្ថាប័ន ហើយដែលមិនអាចរំលោភបំពានបាន ។

**រដ្ឋបាលថ្នាក់ជាតិ** សំដៅដល់ក្រសួង ស្ថាប័ន អង្គភាពសាធារណៈ ប្រហាក់ប្រហែល និងមន្ទីរជំនាញក្រោមឱវាទ ។

**រដ្ឋបាលថ្នាក់ក្រោមជាតិ** សំដៅដល់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ដែលស្ថិតក្រោមដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សានីមួយៗ ។

**ថវិកា** សំដៅដល់សំណុំនៃគណនី ដែលពិពណ៌នាសម្រាប់ឆ្នាំនីមួយៗ អំពីធនធានអចិន្ត្រៃយ៍ និងបន្ទុកអចិន្ត្រៃយ៍ទាំងអស់របស់រដ្ឋ ឬ របស់ស្ថាប័ន ឬ របស់អង្គភាពណាមួយ ។

**ថវិកាជាតិ ឬ ថវិការដ្ឋ** សំដៅដល់គម្រោងតុល្យភាពនៃធនធានអចិន្ត្រៃយ៍ និងបន្ទុកអចិន្ត្រៃយ៍ទាំងអស់របស់រដ្ឋ ។ ថវិកាជាតិ ឬ ថវិការដ្ឋ រួមមានថវិកាថ្នាក់ជាតិ និងថវិកាថ្នាក់ក្រោមជាតិ ។ ថវិកាថ្នាក់ជាតិ គឺជាថវិការបស់រដ្ឋបាលថ្នាក់ជាតិ ។ ថវិកាថ្នាក់ក្រោមជាតិ គឺជាថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ។

**អចលកម្មហិរញ្ញវត្ថុ** សំដៅដល់ការវិនិយោគលើមូលបត្រ ឬ មូលបត្រ ដែលបានមកពីការចូលរួមទុនជាមួយសហគ្រាស ឬ ក្រុមហ៊ុន ។ អចលកម្មហិរញ្ញវត្ថុនេះ ជាទ្រព្យសកម្មហិរញ្ញវត្ថុថេរមិនចរន្ត ។ ទ្រព្យសកម្មហិរញ្ញវត្ថុ ដែលជាអចលកម្មហិរញ្ញវត្ថុ រួមមានមូលបត្រគ្រប់ប្រភេទទាំងអស់ វិញ្ញាបនបត្រផ្ញើប្រាក់ ប័ណ្ណសន្យារ៉ាប់រង ផលប័ត្រពាណិជ្ជកម្ម ប័ណ្ណសងតាមបញ្ជា រូបិយណត្តិ និងមូលប្បទានបត្រជាដើម ។

**ផលហិរញ្ញវត្ថុ** សំដៅដល់ផលហិរញ្ញវត្ថុទាំងអស់ ដែលបានមកដោយការយកអតិរេកសាច់ប្រាក់បណ្ដោះអាសន្នទៅវិនិយោគលើមូលបត្រអាចជួញដូរបាន និងក្នុងរយៈពេលខ្លី ។ ផលហិរញ្ញវត្ថុនេះមានជាអាទិ៍អត្រាការ ប្រាក់លើបំណុលប្រាក់ចំណេញ ដែលបានមកពីការវិនិយោគក្នុងរយៈពេលមួយយប់លើប័ណ្ណរតនាគារបរទេស ផលដែលបានមកពីការធានាអោយមានសវិធានធន និង កម្រៃជទៃទៀតដែលបានមកពីប្រតិបត្តិការហិរញ្ញវត្ថុ ។



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

**មាត្រា ៥.-**

ថវិកាត្រូវមានគោលការណ៍គន្លឹះ ១១ យ៉ាងដែលត្រូវអនុវត្តជាចំខាតគឺៈ

១. ភាពជាអាជ្ញា ។

២. ការិយបរិច្ឆេទមានកាលកំណត់មួយឆ្នាំ ។

៣. ភាពគ្រប់ជ្រុងជ្រោយ ។

៤. ឯកត្តភាព ។

៥. សកលភាព ។

៦. វិសេសភាព ។

៧. តុល្យភាព ។

៨. គណនេយ្យភាព ។

៩. តម្លាភាព ។

១០. ស្ថិរភាព ។

១១. សមិទ្ធកម្ម ។

**មាត្រា ៦.-**

រដ្ឋបាលថ្នាក់ជាតិ គ្រឹះស្ថានសាធារណៈ រដ្ឋបាលថ្នាក់ក្រោមជាតិ បុគ្គលដែលជាមន្ត្រីសាធារណៈ និង ប្រតិបត្តិករនៅក្នុងប្រព័ន្ធហិរញ្ញវត្ថុសាធារណៈទាំងមូល ត្រូវប្រកាន់ខ្ជាប់នូវមូលដ្ឋាននៃគោលការណ៍ បូរណភាព សមាគតភាព សង្គតិភាព គណនេយ្យភាព តម្លាភាព និងភាពគ្រប់ជ្រុងជ្រោយ ព្រមទាំង វិសាលភាពក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈទាំងមូល និងគោលការណ៍គន្លឹះទាំង ១១ យ៉ាងនៃថវិកា។

**មាត្រា ៧.-**



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ដើម្បីធានាការអនុវត្តច្បាប់នេះ និងបទប្បញ្ញត្តិច្បាប់ពាក់ព័ន្ធផ្សេងទៀតប្រកបដោយប្រសិទ្ធភាព ត្រូវចេញ អនុក្រឹត្យ សេចក្ដីសម្រេច បទបញ្ជា និង សារាចរណែនាំដោយរាជរដ្ឋាភិបាល ព្រមទាំងប្រកាស និងសារាចរណែនាំ ផ្សេងៗទៀត ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ៨.-**

ច្បាប់ដែលមានលក្ខណៈជាច្បាប់ហិរញ្ញវត្ថុរួមមានៈ

*១.* ច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ។

*២.* ច្បាប់កែតម្រូវ ។

*៣.* ច្បាប់ទូទាត់ថវិកា ។

**មាត្រា ៩.-**

ច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ គ្រោង និងអនុញ្ញាតសម្រាប់ឆ្នាំនីមួយៗនូវប្រភពធនធាន និង បន្ទុកដែលត្រូវចំណាយសរុបរបស់រដ្ឋ ដើម្បីបម្រើឱ្យរបៀបវារៈគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និង សង្គមដោយគិតគូរដល់ការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច សមតាហិរញ្ញវត្ថុ និង រូបិយវត្ថុជាសារវ័ន្ត ពិសេសតាមរយៈការធានាឱ្យបាននូវតុល្យភាពថវិកា ។

**មាត្រា ១០.-**

ក្រៅពីអ្វីដែលមានចែងក្នុងច្បាប់នេះ របបហិរញ្ញវត្ថុ និង ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ជាកម្មវត្ថុនៃច្បាប់ដោយឡែក ។

**មាត្រា ១១.-**

ការិយបរិច្ឆេទនៃឆ្នាំថវិកាចាប់ផ្ដើមនៅថ្ងៃទី ០១ ខែ មករា ហើយបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ជំពូកទី ២

# ចែនាសម្ព័ន្ធថវិកា និងសិទ្ធិអំណាច

## ផ្នែកទី ១

## ចែនាសម្ព័ន្ធថវិកា

**មាត្រា ១២.** -

ថវិកាត្រូវរៀបចំទៅតាមចំណាត់ថ្នាក់រដ្ឋបាលដែលផ្អែកលើរចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាល ចំណាត់ថ្នាក់សេដ្ឋកិច្ចដែលផ្អែកទៅលើប្រភេទចំណាយ ចំណាត់ថ្នាក់មុខងារដែលផ្អែកទៅលើគោលបំណង និងចំណាត់ថ្នាក់តាមកម្មវិធី ។

**មាត្រា ១៣.** -

ធនធានអចិន្ត្រៃយ៍របស់រដ្ឋរួមមានចំណូលចរន្ត និងចំណូលមូលធន ។

ចំណូលចរន្តត្រូវបានបែងចែកជា ២ ក្រុម និង ៣ ប្រភេទគឺ៖

- ក្រុមទី ១៖ ចំណូលពិត
  - ប្រភេទទី ១៖ ចំណូលសារពើពន្ធ
  - ប្រភេទទី ២៖ ចំណូលមិនមែនសារពើពន្ធ
- ក្រុមទី ២៖ ចំណូលតាមដីកា
  - ប្រភេទទី ៣៖ ចំណូលតាមដីកា

ចំណូលមូលធនត្រូវបានបែងចែកជា ២ ក្រុម និង ៣ ប្រភេទគឺ៖

- ក្រុមទី ១៖ ចំណូលពិត



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

- ប្រភេទទី ១: ចំណូលពីប្រភពផ្ទាល់

- ប្រភេទទី ២: ចំណូលពីប្រភពខាងក្រៅ

▪ ក្រុមទី ២: ចំណូលតាមដីកា

- ប្រភេទទី ៣: ចំណូលតាមដីកា

ប្រភេទចំណូលនីមួយៗត្រូវបានធ្វើចំណាត់ថ្នាក់ជាជំពូកគណនី អនុគណនី និងជាយថាហេតុអាចលំអិតជាងនេះទៀត ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ១៤.** -

គណនីថវិការួមមាន ថវិការដ្ឋ ថវិកាឧបសម្ព័ន្ធ ថវិកាគ្រឹះស្ថានសាធារណៈរដ្ឋបាល និងគណនីពិសេសរតនាគារជាតិ ។ គណនីថវិកាផ្សេងៗទៀត អាចបង្កើតបានក្នុងច្បាប់ហិរញ្ញវត្ថុ ។

ថវិកាឧបសម្ព័ន្ធអនុវត្តចំពោះអង្គភាពរដ្ឋ ដែលមានលក្ខណៈឧស្សាហកម្ម និងពាណិជ្ជកម្ម ដែលមិនមែនជានីតិបុគ្គល ។ ថវិកាឧបសម្ព័ន្ធត្រូវបង្កើត ឬ លុបចោលដោយច្បាប់ហិរញ្ញវត្ថុ ។ កិច្ចប្រតិបត្តិការនៃថវិកាឧបសម្ព័ន្ធត្រូវប្រព្រឹត្តទៅក្នុងលក្ខខណ្ឌ និងតាមវិធានដូចគ្នានឹងកិច្ចប្រតិបត្តិការថវិការដ្ឋដែរ ។

គ្រឹះស្ថានសាធារណៈរដ្ឋបាលត្រូវមានថវិកាស្វយ័ត ។ ប្រភពធនធានជាប្រចាំរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលរួមមានចំណូលផ្ទាល់ និងជាយថាហេតុ មានការឧបត្ថម្ភតុល្យភាពដោយថវិការដ្ឋ ។ រីឯចំណាយជាប្រចាំ របស់គ្រឹះស្ថានសាធារណៈរដ្ឋបាលត្រូវគោរពតាមវិធាននៃចំណាត់ថ្នាក់ និងការគ្រប់គ្រងដូចចំណាយជាប្រចាំ របស់ថវិការដ្ឋដែរ ។

ការរៀបចំ និងការប្រព្រឹត្តទៅនៃថវិកាឧបសម្ព័ន្ធ និងថវិកាគ្រឹះស្ថានសាធារណៈរដ្ឋបាលត្រូវកំណត់ដោយអនុក្រឹត្យរបស់រាជរដ្ឋាភិបាល ។

**មាត្រា ១៥.** -

ចំណូលសារពើពន្ធរួមមានចំណូលបានមកពីពន្ធ និងអាករក្នុងប្រទេស និងពន្ធ និងអាករលើពាណិជ្ជកម្មក្រៅប្រទេស និងចំណូលសារពើពន្ធដទៃទៀត ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ចំណូលមិនមែនសារពើពន្ធរួមមានចំណូលបានមកពីការចាត់ចែង ការធ្វើអាជីវកម្ម និងការលក់ទ្រព្យសម្បត្តិរដ្ឋ ផលបានមកពីសម្បទានកម្រៃបានមកពីសេវាសាធារណៈ ផលពីការពិន័យ និងការដាក់ទណ្ឌកម្ម ការឧបត្ថម្ភអំណោយផលហិរញ្ញវត្ថុផលផ្សេងៗ និងផលពិសេស និងចំណូលមិនមែនសារពើពន្ធដទៃទៀត ។

ចំណូលមូលធនរួមមានចំណូលបានមកពីអចលកម្មហិរញ្ញវត្ថុ ហិរញ្ញប្បទានឥតសំណងសម្រាប់វិនិយោគ ការខ្ចី និងចំណូលមូលធនផ្សេងទៀត ។

**មាត្រា ១៦.-**

ពន្ធអាករ និងចំណូលសារពើពន្ធផ្សេងៗត្រូវកំណត់ដោយច្បាប់ និងត្រូវប្រមូល និងត្រួតពិនិត្យដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។ អត្រាពន្ធអាករមូលដ្ឋានជាប់ពន្ធ ការលើកលែងពន្ធ និងវិវាទដែលទាក់ទងនឹងការកំណត់ការប្រមូល និងការត្រួតពិនិត្យពន្ធ ត្រូវកំណត់នៅក្នុងក្របខ័ណ្ឌ និងតាមបែបបទដែលមានចែងនៅក្នុងច្បាប់ដែលទាក់ទងដល់ប្រភេទពន្ធ និងអាករនីមួយៗ ។

គ្មានបទប្បញ្ញត្តិណាមួយ ទោះជាប្រភេទណាក៏ដោយគ្មានអនុសញ្ញាអន្តរជាតិណាមួយ ដែលអាចធ្វើឱ្យមានការប្រែប្រួលនាំមកនូវការបាត់ចំណូលនោះឡើយ ។ ករណីខាងលើអាចប្រព្រឹត្តទៅបានលុះត្រាតែអនុវត្តតាមទម្រង់ច្បាប់ និងបទបញ្ញាដូចគ្នា ក្រោយពីមានយោបល់ឯកភាពពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ការប្រមូលចំណូលមិនមែនសារពើពន្ធ ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

**មាត្រា ១៧.-**

ទ្រព្យសម្បត្តិរដ្ឋ ដែលរួមមានទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ និងទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ត្រូវចាត់ចែង និងគ្រប់គ្រងយ៉ាងត្រឹមត្រូវទៅតាមបទប្បញ្ញត្តិនៃច្បាប់ និងបទបញ្ញាជាធរមាន ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាសេនាធិការរបស់រាជរដ្ឋាភិបាល ក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋលើការលក់ការជួលការផ្ទេរ និងការចាត់ចែងដទៃទៀតលើទ្រព្យសម្បត្តិរដ្ឋ ការផ្តល់សម្បទានផ្សេងៗរបស់រដ្ឋព្រមទាំងការធ្វើបញ្ជីសារពើភណ្ឌ ។ រាល់ការចុះកិច្ចសន្យាលើការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ និងផ្តល់សម្បទានផ្សេងៗ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

របស់រដ្ឋ ដែលមានការពាក់ព័ន្ធនឹងហិរញ្ញវត្ថុសាធារណៈ ត្រូវស្ថិតក្រោមការត្រួតពិនិត្យ និង ការឯកភាពរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។ ក្រោមបទប្បញ្ញត្តិនៃមាត្រា ១៩ នៃច្បាប់នេះ ចំណូលទាំងអស់ដែលបានពីការចាត់ចែង និងគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ត្រូវបង់ចូលគណនីទោលរបស់រតនាគារជាតិនៃថវិការដ្ឋ ដោយមិនអាចដកចំណូលនេះ ទៅកាត់កងដោយត្រង់ជាមួយចំណាយឡើយ ។

**មាត្រា ១៨. -**

សេវាបង់ថ្លៃរបស់រដ្ឋ គឺជាសេវាដែលផ្តល់ដោយអង្គភាពសេវាសាធារណៈរបស់រដ្ឋទៅឱ្យឯកជន និងអង្គការតតិយ ។ កម្រៃសេវារបស់រដ្ឋត្រូវស្ថិតនៅក្រោមអានុភាពនៃតារាងតម្លៃដែលកំណត់ដោយរាជរដ្ឋាភិបាល តាមសំណើរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងតាមយោបល់របស់ក្រសួង និងស្ថាប័នដែលពាក់ព័ន្ធ ។

ចំពោះកម្រៃសេវាសាធារណៈរបស់រដ្ឋ ដែលមានលក្ខណៈតូចតាចមានជាអាទិ៍កម្រៃពីការអនុញ្ញាតរដ្ឋបាល ទម្រង់ការរដ្ឋបាល ប័ណ្ណចូលទស្សនារមណីយដ្ឋាន សារមន្ទីរ វិក័យប័ត្រពិន័យ ត្រូវកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួង ឬ ប្រធានស្ថាប័ន ដែលមានការពាក់ព័ន្ធ ។

**មាត្រា ១៩. -**

ចំណូលត្រូវកត់ត្រាចូលទាំងស្រុង ហើយមិនត្រូវយកទៅកាត់កងដោយត្រង់ជាមួយចំណាយឡើយ។ ការបង្កើនដោយអាណាប័កន្ទូវទឹកប្រាក់នៃឥណទានដែលបានអនុម័ត ដោយសំអាងលើប្រាក់ចំណូលពិសេសណាមួយ ត្រូវបានហាមឃាត់ដាច់ខាត ។

**មាត្រា ២០. -**

ចំណូលទាំងមូល ត្រូវវិភាជន៍សម្រាប់រាល់មុខសញ្ញាចំណាយទាំងអស់ ។ ប៉ុន្តែចំណូលខ្លះ អាចត្រូវវិភាជន៍ សម្រាប់តែមុខសញ្ញាចំណាយជាក់ស្តែងណាមួយក្នុងទម្រង់ និងក្រោមលក្ខខណ្ឌដែលត្រូវកំណត់ដោយច្បាប់ ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

**មាត្រា ២១.-**

បន្ទុកអចិន្ត្រៃយ៍របស់រដ្ឋរួមមានចំណាយចរន្ត និងចំណាយមូលធន ។ បន្ទុកនេះ ត្រូវបានចែកជាក្រុម និង ប្រភេទ ។

**មាត្រា ២២.-**

ចំណាយចរន្តនៃថវិកាត្រូវបានបែងចែកជា ២ ក្រុម និង ៦ ប្រភេទគឺៈ

- ក្រុមទី ១ៈ ចំណាយពិត
  - ប្រភេទទី ១ៈ មធ្យោបាយសេវា
  - ប្រភេទទី ២ៈ បន្ទុកហិរញ្ញវត្ថុ
  - ប្រភេទទី ៣ៈ អន្តរាគមន៍សាធារណៈ
  - ប្រភេទទី ៤ៈ ចំណាយផ្សេងៗ
- ក្រុមទី ២ៈ ចំណាយតាមដីកា និងចំណាយមិនបានគ្រោងទុក
  - ប្រភេទទី ៥ៈ ចំណាយតាមដីកា
  - ប្រភេទទី ៦ៈ ចំណាយមិនបានគ្រោងទុក

ប្រភេទចំណាយនីមួយៗត្រូវបានធ្វើចំណាត់ថ្នាក់ជាជំពូកគណនី អនុគណនី និងជាយថាហេតុ អាចលំអិតជាងនេះទៀត ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ២៣.-**

ចំណាយមូលធននៃថវិកា គឺសម្រាប់ការអនុវត្តកម្មវិធី ការអនុវត្តគម្រោងវិនិយោគ ការចូលរួមភាគកម្ម និងការទូទាត់បំណុល ។

ចំណាយមូលធនត្រូវបានបែងចែកជា ២ ក្រុម និង ៣ ប្រភេទគឺៈ


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

▪ ក្រុមទី ១: ចំណាយពិត

- ប្រភេទទី ១: ការទូទាត់ប្រាក់ខ្ចី និងបំណុលប្រហាក់ប្រហែល

- ប្រភេទទី ២: អចលកម្ម

▪ ក្រុមទី ២: ចំណាយតាមដីកា

- ប្រភេទទី ៣: ចំណាយតាមដីកា

ប្រភេទចំណាយនីមួយៗ ត្រូវធ្វើចំណាត់ថ្នាក់ជាជំពូកគណនី អនុគណនី និងជាយថាហេតុអាចលំអិតជាងនេះទៀត ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ឥណទានវិនិយោគដោយហិរញ្ញប្បទានក្រៅប្រទេស គឺជាឥណទានមានលក្ខណៈប៉ាន់ស្មាន ហើយពុំអាចធ្វើជាកម្មវត្ថុនៃនិយ័តភាពទៅប្រភេទចំណាយណាមួយផ្សេងទៀតបានឡើយ ។

**មាត្រា ២៤.-**

ច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ វិភាជន៍ឥណទានទៅតាមក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈប្រហាក់ប្រហែល ដោយឆ្លុះបញ្ចាំងឱ្យឃើញផងដែរនូវថវិកាឧបសម្ព័ន្ធ និងថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ទៅតាមប្រភេទចំណាយចរន្ត និងចំណាយមូលធន ។ ក្រសួង ស្ថាប័ន ឬ អង្គភាពសាធារណៈប្រហាក់ប្រហែលទាំងនោះ ប្រមូលផ្ដុំឥណទានទាំងអស់សម្រាប់បម្រើការងាររបស់ខ្លួននៅរដ្ឋបាលថ្នាក់ជាតិ ។

ច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ត្រូវវិភាជន៍ឥណទានជាកញ្ចប់ដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ។

**មាត្រា ២៥.-**

ឥណទានថវិកា ដែលបានអនុម័តដោយច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ត្រូវបានបែងចែកលំអិតនៅក្នុងផ្ទៃក្នុងប្រភេទនីមួយៗទៅតាមលក្ខណៈ និងគោលដៅនៃឥណទានថវិកា ។ ឥណទានទាំងនេះអាចធ្វើជាកម្មវត្ថុសម្រាប់ការរៀបចំថវិកាតាមកម្មវិធី និងការប្រមូលផ្ដុំតាមវិស័យផងដែរ ។ ការរៀបចំថវិកាតាមកម្មវិធី ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ចំណាយចរន្តនៃប្រភេទ ២ «បន្ទុកហិរញ្ញវត្ថុ» និង ប្រភេទ ៦ «ចំណាយមិនបានគ្រោងទុក» មិនត្រូវបានបែងចែកឱ្យទៅក្រសួង ស្ថាប័ន ឬ អង្គភាពសាធារណៈ ប្រហាក់ប្រហែលណាមួយឡើយ ។ ឥណទាននេះ ទុកសម្រាប់សងការប្រាក់នៃប្រាក់ខ្ចី និងបន្ទុកហិរញ្ញវត្ថុផ្សេងៗព្រមទាំងឥណទានត្រៀមបម្រុងសម្រាប់ចំណាយផ្សេងៗ លើមុខសញ្ញាដែលកើតឡើងជាយថាហេតុ ។ ឥណទានត្រៀមបម្រុងត្រូវបានអនុញ្ញាតសម្រាប់ការចំណាយទាំងឡាយណា ដែលការបែងចែកមិនអាចត្រូវបានកំណត់ជាក់លាក់នៅពេលដែលឥណទាននោះ ត្រូវបានអនុម័ត ។ ការបែងចែកឥណទានត្រៀមបម្រុងទាំងនេះ តាមក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈប្រហាក់ប្រហែលនីមួយៗ ត្រូវធ្វើឡើងដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

ប្រភេទ ១ នៃចំណាយមូលធន គឺសម្រាប់ការទូទាត់ប្រាក់ខ្ចីនៅក្នុងប្រទេស និងពីក្រៅប្រទេស និងទូទាត់បំណុលប្រហាក់ប្រហែល ។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គឺជាអាណាប័កចំណាយលើការប្រាក់នៃការខ្ចី ចំណាយផ្សេងៗចំណាយសំណង និងចំណាយបង្វិលសងវិញ ព្រមទាំងចំណាយទូទាត់ប្រាក់ខ្ចីនៅក្នុងប្រទេស និង ពីក្រៅប្រទេស និងទូទាត់បំណុលប្រហាក់ប្រហែល ។

**មាត្រា ២៦.-**

ឥណទានថវិកាមានពីរប្រភេទគឺ កំហិតកំណត់ និង ប៉ាន់ប្រមាណ ។ ឥណទានកំហិតកំណត់ គឺត្រូវបានផ្តល់ជាការសន្យា និងការអនុញ្ញាតត្រឹមកម្រិតខ្ពស់បំផុតមួយដែលចំណាយប្រភេទនេះ ត្រូវបានកំណត់ជាមុន ។ ចំណាយបែបនេះ អាចបង្កើនបានតែតាមរយៈច្បាប់កែតម្រូវនៃច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំតែមួយប៉ុណ្ណោះ ។ ឥណទានប៉ាន់ប្រមាណគឺត្រូវ បានអនុញ្ញាតសម្រាប់ចំណាយចាំបាច់ និងក្នុងករណីដែលការគ្រោងមិនគ្រប់គ្រាន់នៅក្នុងដំណាក់កាលបន្ទាប់ពីការអនុម័តថវិកា ។ ចំណាយនៃឥណទានប្រភេទនេះ អាចនឹងត្រូវបានប្រើប្រាស់លើសពីឥណទានដែលបានគ្រោងនៅ ក្នុងជំពូកថវិកាពាក់ព័ន្ធ ។ ឥណទានប្រភេទនេះ កើតមានលើបំណុលសាធារណៈ បៀវត្សរ៍ប្រាក់បំណាច់របស់ បុគ្គលិក វិភាគទានសមាជិកភាពចំពោះស្ថាប័នអន្តរជាតិ ឬ អន្តររដ្ឋាភិបាល និងចំណាយផ្សេងទៀត ដែលត្រូវកំណត់នៅក្នុងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

**មាត្រា ២៧.-**

ឥណទានចំណាយចរន្ត ត្រូវបែងចែកជាឥណទានសម្រាប់សកម្មភាពការងារ ដែលបានអនុម័ត និង ឥណទានសម្រាប់វិធានការថ្មី ។

ឥណទានសម្រាប់សកម្មភាពការងារដែលបានអនុម័តរួមមាន ឥណទានដែលបានកំណត់នៅក្នុង ថវិកាចំណាយចរន្តនៃឆ្នាំមុន ដកទាយជ្ជទាន និងឥណទានសម្រាប់សកម្មភាពការងារ ដែលនឹងមិនកើត ឡើងវិញនៅក្នុងឆ្នាំគ្រោងថវិកា បូកបន្ថែមឥណទានសម្រាប់ការកែតម្រូវតាមស្ថានភាពជាក់ស្តែង ។

ឥណទានសម្រាប់សកម្មភាពការងារដែលបានអនុម័តត្រូវស្ថិតក្នុងកម្រិតអប្បបរមាចាំបាច់ ដែល ត្រូវការសម្រាប់ដំណើរការសកម្មភាពការងារនៅក្នុងលក្ខខណ្ឌនៃឆ្នាំមុន ។

ការកែតម្រូវតាមស្ថានភាពជាក់ស្តែងត្រូវគិតអំពីផលប៉ះពាល់ដែលបានកើតឡើងនៅក្នុងឆ្នាំមុន ព្រមទាំងការ វិវត្តនៃបន្ទុកសាធារណៈខ្លះទៀត ដែលអាចកើតឡើងដោយសារវិធានការ ដែលបានអនុម័ត នៅក្នុងឆ្នាំមុន ។

វិធានការថ្មី គឺទាក់ទងទៅនឹងការសម្រេចទាំងឡាយណា ដែលនាំឱ្យមានផលប៉ះពាល់ហិរញ្ញវត្ថុ បន្ថែមទៀតទៅលើថវិកា ។

**មាត្រា ២៨.-**

ឥណទានចំណាយមូលធន គឺជាឥណទានវិនិយោគដែលត្រូវបែងចែកជាឥណទានភ្ជាប់សន្យា និង ឥណទានទូទាត់ ។ ឥណទានវិនិយោគកំណត់លើកម្មវិធី ឬ គម្រោងការទាំងឡាយដែលរដ្ឋបានផ្តួចផ្តើម នៅក្នុងឆ្នាំ និង គណនាតម្រូវការចំណាយសរុប ។ ឥណទានវិនិយោគគ្រោងមូលនិធិភ្ជាប់សន្យាសម្រាប់ ប្រតិបត្តិការទាំងស្រុងនៃ គម្រោងការ ដោយមិនតម្រូវឱ្យមានការវិនិយោគបន្ថែមសម្រាប់បញ្ចប់នោះទេ ។ ទោះជាយ៉ាងនោះក្តី ឥណទានវិនិយោគអនុញ្ញាតឱ្យរាជរដ្ឋាភិបាល ធ្វើការសន្យាត្រឹមតែក្នុងរង្វង់នៃ ឥណទានភ្ជាប់សន្យា ដែលបានអនុម័តនៅក្នុងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំតែប៉ុណ្ណោះ ។

ឥណទានភ្ជាប់សន្យាត្រូវដាក់នៅក្រោមអាណាប័ក សម្រាប់ចំណាយចាំបាច់ក្នុងការអនុវត្តកិច្ច វិនិយោគ ដែលបានកំណត់នៅក្នុងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ។ ឥណទានទូទាត់ ត្រូវប្រើប្រាស់សម្រាប់ចេញ បញ្ជាចំណាយដែលជាបន្ទុករបស់រដ្ឋ នៅក្នុងកម្រិតនៃឥណទានភ្ជាប់សន្យា ។

**មាត្រា ២៩.-**

ឥណទានភ្ជាប់សន្យាអាចមានតម្លៃគ្មានកំណត់ពេល ។ ឥណទាននេះ ត្រូវបានយោងពីមួយឆ្នាំទៅមួយឆ្នាំ រហូតដល់ការលុបបំបាត់ជាយថាហេតុ ។ ឥណទានទូទាត់ ដែលមិនបានប្រើនៅពេលបិទការគ្រប់គ្រង (បញ្ចប់ឆ្នាំ) ត្រូវបានលុបចោល និងអាចអនុញ្ញាតឥណទានថ្មីសម្រាប់ឆ្នាំបន្ទាប់ ។

**មាត្រា ៣០.-**

គ្មានវិធានការជាបទប្បញ្ញត្តិ បទបញ្ជា ឬ រដ្ឋបាលណាមួយអាចត្រូវបានអនុម័ត ទទួលស្គាល់ ឬសម្រេចបានទេ ប្រសិនបើតម្រូវការចំណាយនៃបន្ទុកថ្មីដែលនឹងកើតឡើងនោះ មិនត្រូវបានវាយតម្លៃព្យាករណ៍ និង អនុញ្ញាតមុនពេលគ្រោង និងកំណត់ថវិកា ។ ការបង្កើត និងការប្តូរមុខរបរ ក៏ដូចជាការប្រឡងជ្រើសរើស អាចកើតមានតែពីតារាងមុខរបរដែលបានកំណត់ដោយរដ្ឋបាល ឬ អង្គភាព និងបានគ្រោងនៅក្នុងថវិកា ។ ការតម្លើងឋានៈ ការផ្តល់បុព្វលាភថ្មី ឬ ការបង្កើនលាភការមិនអាចសម្រេចបានទេបើប្រសិនណាវិធានការទាំងនេះ មិនបានបំពេញដោយឥណទានគ្រប់គ្រាន់ជាមុននៅក្នុងថវិការដ្ឋ ។

**មាត្រា ៣១.-**

គណនីពិសេសរបស់រតនាគារជាតិ គឺជាគណនីដែលបានបើកក្នុងលេខនារបស់រតនាគារជាតិទុកសម្រាប់ៈ

១- ចុះកិច្ចបញ្ជីការចំណូលដោយឡែកជាហិរញ្ញប្បទានជាក់លាក់ ដល់កិច្ចប្រតិបត្តិការសេវាសាធារណៈទាំងឡាយ ដែលហៅថាគណនីចាត់ចែងពិសេស ។

២- បង្ហាញចំណាយមានលក្ខណៈបណ្តោះអាសន្នរបស់រដ្ឋ ដែលហៅថាគណនីបុរេប្រទាន ។

៣- កត់ត្រាប្រតិបត្តិការទាំងអស់ មានលក្ខណៈឧស្សាហកម្ម ឬ ពាណិជ្ជកម្មដែលបានធ្វើដោយរដ្ឋជាលក្ខណៈ បន្ទាប់បន្សំដែលហៅថាគណនីពាណិជ្ជកម្ម ។

គណនីពិសេសរបស់រតនាគារជាតិ ត្រូវបានបង្កើត ឬ លុបចោលដោយច្បាប់ហិរញ្ញវត្ថុ ក្រោមលក្ខខណ្ឌនៃ បទប្បញ្ញត្តិនៃច្បាប់នេះ ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

**មាត្រា ៣២.-**

ចំណូល និងចំណាយទាំងអស់នៃគណនីពិសេសរបស់រតនាគារជាតិត្រូវបានគ្រោង និងអនុញ្ញាត ក្នុងលក្ខខណ្ឌ ដូចគ្នាទៅនឹងប្រតិបត្តិការទូទៅនៃថវិការដ្ឋដែរ ។

**មាត្រា ៣៣.-**

ប្រតិបត្តិការចំណាយ ដែលអាចកត់ត្រាក្នុងគណនីពិសេសរបស់រតនាគារជាតិ ត្រូវប្រព្រឹត្តទៅ ដូចជាថវិការដ្ឋដែរ ក្រោមលក្ខខណ្ឌនៃចំណុចដោយឡែកដូចតទៅៈ

១- ចំណាយសរុបដែលបានសន្យា ឬ បានចេញអាណត្តិទៅឱ្យគណនីពិសេសរបស់រតនាគារជាតិ មិនអាចលើសពីធនធានសរុបរបស់គណនីនេះទេ ។

២- ក្នុងពេលគ្រប់គ្រង ប្រសិនបើចំណូលនៃគណនីពិសេសរបស់រតនាគារជាតិ បានស្តែងឡើងខ្ពស់ ជាងចំណាយប៉ាន់ប្រមាណដែលបានគ្រោងទុក នោះឥណទាននៃគណនីនេះ អាចត្រូវបានតម្លើង ដោយប្រកាសរបស់រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងកម្រិតនៃចំណូលដែលលើសនោះ ។

៣- សមតុល្យឥណទាយីនៃគណនីពិសេសរបស់រតនាគារជាតិ អាចយោងពីមួយឆ្នាំទៅមួយឆ្នាំ លើកលែងតែ មានបទប្បញ្ញត្តិផ្ទុយដែលមានចែងក្នុងច្បាប់ហិរញ្ញវត្ថុ ។

៤- ហាមកត់ត្រាក្នុងគណនីពិសេសរបស់រតនាគារជាតិនូវចំណាយណា ដែលមិនចូលក្នុងក្របខ័ណ្ឌ នៃកម្មវត្ថុរបស់គណនីនេះ មានជាអាទិ៍ប្រាក់បៀវត្សរ៍ ឬ ប្រាក់បំណាច់ ។

## ផ្នែកទី ២

## សិទ្ធិអំណាច និងការទទួលខុសត្រូវ

**មាត្រា ៣៤.-**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានភារកិច្ចទទួលខុសត្រូវក្នុងការគ្រប់គ្រងចំណូល ចំណាយ ការខ្ចី ការឱ្យខ្ចី និងការធានារបស់រដ្ឋ ដែលត្រូវបានអនុញ្ញាតដោយច្បាប់ ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

**មាត្រា ៣៥.-**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាសេនាធិការរបស់រាជរដ្ឋាភិបាល ក្នុងការរៀបចំការអនុវត្ត ការតាមដាន និងការគ្រប់គ្រងក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ រយៈពេលមធ្យម និងរយៈពេលវែងរបស់ព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៣៦.-**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវរាយការណ៍ជូនរដ្ឋសភា និងព្រឹទ្ធសភា អំពីគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល ព្រមទាំងអំពីស្ថានភាពសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសាធារណៈនាពេលបច្ចុប្បន្ន និងព្យាករណ៍សម្រាប់រយៈពេលមធ្យម ។

**មាត្រា ៣៧.-**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានភារកិច្ចដឹកនាំការរក្សាវិន័យហិរញ្ញវត្ថុសាធារណៈ ការរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុ ការរៀបចំក្របខ័ណ្ឌចំណាយរយៈពេលមធ្យម ការគោរពច្បាប់ហិរញ្ញវត្ថុ ព្រមទាំងធានាការត្រួតពិនិត្យជាប្រចាំលើការគ្រប់គ្រងថវិកា ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានភារកិច្ចផ្តល់របាយការណ៍អំពីស្ថានភាពម៉ាក្រូសេដ្ឋកិច្ច និងស្ថានភាពហិរញ្ញវត្ថុសាធារណៈជូនរដ្ឋសភា និងព្រឹទ្ធសភា ពីរដងក្នុង ០១ ឆ្នាំ គឺនៅពេលពិភាក្សាអនុម័តសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ និងនៅពាក់កណ្តាលឆ្នាំ ។

**មាត្រា ៣៧.-**

រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ មានភារកិច្ចទទួលខុសត្រូវក្នុងការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ការគ្រប់គ្រងថវិកា និងការត្រួតពិនិត្យការអនុវត្តថវិការបស់ខ្លួន ជាពិសេស ត្រូវមានគណនេយ្យភាពចំពោះការកំណត់ និងលទ្ធផលនៃការអនុវត្តគោលនយោបាយនៅក្នុងវិស័យរបស់ខ្លួន ដែលស្របទៅនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាល ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ជំពូកទី ៣

# ការរៀបចំថវិកា

## ផ្នែកទី ១

## ក្របខ័ណ្ឌនៃការរៀបចំថវិកា

**មាត្រា ៣៨.-**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ តាមប្រតិទិនដូចខាងក្រោមនេះ ÷

**១- ការរៀបចំផែនការយុទ្ធសាស្រ្តថវិកា (ពីខែមីនា ដល់ ខែ ឧសភា)**

នៅសប្តាហ៍ទីមួយនៃខែមីនា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រៀបចំក្របខ័ណ្ឌគោល-នយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម ដែលមានសង្គតិភាពទៅនឹងក្របខ័ណ្ឌគោលនយោបាយជាតិសម្រាប់ការអភិវឌ្ឍ ដើម្បីដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ និងសម្រេច ។

នៅសប្តាហ៍ទីមួយនៃខែមេសា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវចេញសារាចរណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្រ្តថវិកា ដោយផ្អែកលើក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម ដែលបានកំណត់ដោយរាជរដ្ឋាភិបាល ។

រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័ន ប្រធានអង្គភាពសាធារណៈ ប្រហាក់ប្រហែល និងអភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវរៀបចំផែនការយុទ្ធសាស្រ្តថវិកាសម្រាប់ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយផ្អែកលើសារាចរណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្រ្តថវិកា ចក្ខុវិស័យ គោលបំណង គោលដៅនៃកម្មវិធី និងផែនការសកម្មភាពជាអាទិភាពរបស់ក្រសួង ស្ថាប័ន អង្គភាពសាធារណៈ ប្រហាក់ ប្រហែល និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលបម្រើឱ្យគោលនយោបាយអាទិភាពរបស់វិស័យ និងគោលនយោបាយជាតិសម្រាប់ការអភិវឌ្ឍ ។

ផែនការយុទ្ធសាស្ត្រថវិកាទាំងនេះ ត្រូវផ្ញើមករដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ យ៉ាងយឺតបំផុតត្រឹមថ្ងៃទី ១៥ ខែ ឧសភា ។

**២- ការរៀបចំគម្រោងថវិកា (ពីខែមិថុនា ដល់ ខែកញ្ញា)**

នៅសប្តាហ៍ទីមួយនៃខែមិថុនា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រៀបចំសេចក្តីព្រាងសារាចរណែនាំស្តីពីបច្ចេកទេសនៃការរៀបចំគំរោងថវិកា ដោយបញ្ជាក់ជូននូវទម្រង់បែបបទ និង នីតិវិធីនៃការរៀបចំគម្រោងថវិកា ព្រមទាំងធ្វើកំណត់បង្ហាញ និងឯកសារពាក់ព័ន្ធដែលត្រូវភ្ជាប់មកជាមួយ ដើម្បីដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ និង សម្រេច ហើយផ្ញើជូនក្រសួង ស្ថាប័ន អង្គភាពសាធារណៈ ប្រហាក់ប្រហែល និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីរៀបចំគម្រោងចំណូលចំណាយថវិកាលម្អិតរបស់ខ្លួន ។

រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័ន ប្រធានអង្គភាពសាធារណៈ ប្រហាក់ប្រហែល និងអភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវរៀបចំនូវគម្រោងចំណូល ចំណាយថវិកាលម្អិតរបស់ខ្លួន សម្រាប់រដ្ឋបាលថ្នាក់ជាតិ និង រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយផ្អែកលើមូលដ្ឋានសារាចរណែនាំស្តីពីបច្ចេកទេសនៃការរៀបចំគម្រោងថវិកា និង អាទិភាពនៃគោលនយោបាយរបស់ខ្លួន ។ គម្រោងថវិកាទាំងនេះត្រូវផ្ញើមករដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ យ៉ាងយឺតបំផុតត្រឹមថ្ងៃទី ១៥ ខែ កក្កដា ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ធ្វើការប្រមូលផ្តុំបូកសរុបនូវគម្រោងចំណូល ចំណាយថវិការបស់ក្រសួង ស្ថាប័ន អង្គភាពសាធារណៈ ប្រហាក់ប្រហែលខេត្ត និងរាជធានីដែលបានស្នើឡើង ។

នៅក្នុងអំឡុងខែសីហាទាំងមូល ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អញ្ជើញរដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័ន និង ប្រធានអង្គភាពសាធារណៈ ប្រហាក់ប្រហែលព្រមទាំងអភិបាលគ្រប់ខេត្ត និងរាជធានី មកពិភាក្សា ការពារគម្រោងថវិការបស់ខ្លួន ដើម្បីសម្របសម្រួលនូវគម្រោងចំណូលចំណាយថវិកាទាំងនោះ ឱ្យបានសមស្រប តាមបទប្បញ្ញត្តិនៃការណែនាំដោយមានការកាត់បន្ថយចំណាយណាដែលមិនចាំបាច់ និងបង្កើនចំណូលឱ្យបានសមស្រប ។

នៅក្នុងអំឡុងខែកញ្ញាទាំងមូល ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ធ្វើការបូកសរុបចំណូល ចំណាយរដ្ឋទាំងមូល ដើម្បីតុល្យភាពថវិកាឡើងវិញ រួចរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុ និងធ្វើកំណត់បង្ហាញនៃសេចក្តីព្រាងច្បាប់នេះ ។

***៣- ការអនុម័តថវិកា (ពីខែតុលា ដល់ ខែធ្នូ)***



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

នៅសប្តាហ៍ទីមួយនៃខែតុលា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បញ្ជូនសេចក្តីព្រាងច្បាប់នេះ ដើម្បីដាក់ជូន គណៈរដ្ឋមន្ត្រីពិនិត្យសម្រេច រួចដាក់ជូនរដ្ឋសភានៅសប្តាហ៍ទីមួយនៃខែវិច្ឆិកា ដើម្បីពិនិត្យអនុម័ត និង ដាក់ជូន ព្រឹទ្ធសភា នៅសប្តាហ៍ទីមួយនៃខែធ្នូ ដើម្បីឱ្យសេចក្តីព្រាងច្បាប់នេះ ត្រូវបានអនុម័តជាស្ថាពរមុនថ្ងៃទី ២៥ ខែ ធ្នូ ។

## ផ្នែកទី ២

## ដំណើរការនៃការរៀបចំថវិកា

**មាត្រា ៣៩**

ការរៀបចំថវិកា ត្រូវគោរពបទប្បញ្ញត្តិដែលមានចែងនៅក្នុងមាត្រា ១ មាត្រា ២ និង មាត្រា ៦ នៃច្បាប់នេះ ។

**មាត្រា ៤០.-**

ការគ្រោងចំណូលចរន្ត ត្រូវឈរលើមូលដ្ឋាននៃប្រភពធនធានដែលបានមកពីចំណូលសារពើពន្ធ និងចំណូល មិនមែនសារពើពន្ធ ។

១- រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវគ្រោងដោយផ្ទាល់នូវចំណូលសារពើពន្ធ និង មិនមែនសារពើពន្ធ ដែលជាកម្មវត្ថុនៃការប្រមូលនៅក្រោមសមត្ថកិច្ចរបស់ខ្លួន និងគ្រោងចំណូលសារពើពន្ធ និងមិនមែនសារពើពន្ធ បានមកពីសហគ្រាសសាធារណៈ ។

២- រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័ន ប្រធានអង្គភាពសាធារណៈ ប្រហាក់ប្រហែល និង អភិបាលគ្រប់ខេត្ត និងរាជធានី ដែលមានចំណែកក្នុងការគ្រប់គ្រងចំណូលក្រោមសមត្ថកិច្ចរបស់ខ្លួន ត្រូវផ្ញើមករដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នូវបញ្ជីរាយគ្រប់មុខចំណូល និងបញ្ជីប៉ាន់ស្មានចំណូលទាំងអស់ ដើម្បីកត់ត្រាក្នុងគម្រោងចំណូលនៃថវិកាឱ្យបានពេញលេញ និងត្រឹមត្រូវ ។ ចំណូលទាំងនេះ ជាចំណែកមិនអាចបំបែកបាននៃចំណូលសរុបនៃថវិការដ្ឋ ។

**មាត្រា ៤១.-**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវគ្រោងចំណូលមូលធន ដោយឈរលើមូលដ្ឋាននៃប្រភពធនធាន បានមកពី៖

១- ចំណូលបានមកពីអចលកម្មហិរញ្ញវត្ថុ ។

២- ការសងបំណុល និង សងបុរេប្រទានដោយសហគ្រាសសាធារណៈ ដែលត្រូវកត់ត្រាឱ្យបានត្រឹមត្រូវ ក្នុងតារាងវិលស់ ។

៣- រាល់ប្រភពចំណូលពីការខ្ចីក្នុងប្រទេស ដោយមានការសម្រេចយល់ព្រមពី រាជរដ្ឋាភិបាល ដែលរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវវាយតម្លៃ និងវិភាគលើស្ថានការណ៍សេដ្ឋកិច្ច និងថវិតនៃការខ្ចីដោយសហការជាមួយទេសាភិបាល ធនាគារជាតិនៃកម្ពុជា ។

៤- ហិរញ្ញប្បទានក្រៅប្រទេស ក្រោមរូបភាពជាហិរញ្ញប្បទានឥតសំណងសម្រាប់វិនិយោគ ឬ ការខ្ចី ដែលត្រូវកត់ត្រាក្នុងគម្រោងចំណូល ទៅតាមលក្ខខណ្ឌដែលបានកំណត់ក្នុងកិច្ចព្រមព្រៀង ។ ធនធានសម្រាប់ទ្រទ្រង់ថវិកា និងសម្រាប់គម្រោងត្រូវវាយតម្លៃទៅតាមលំហូរមូលនិធិ និងវឌ្ឍនភាពនៃការអនុវត្តគម្រោង ។ មូលនិធិបដិភាគ ក្រោមរូបភាពជាទំនិញត្រូវគ្រោងជាចំណូលនៃថវិការដ្ឋនូវចំនួនទឹកប្រាក់ ដែលរំពឹងទុកតាមកម្មវិធីនៃការនាំចូលទំនិញទាំងនោះ ។

៥- ចំណូលមូលធនផ្សេងទៀត ។

**មាត្រា ៤២.-**

គម្រោងចំណាយចរន្ត និងចំណាយមូលធនត្រូវរៀបចំឡើងដោយរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ សម្រាប់គ្រប់សេវា និងសកម្មភាពទាំងមូល ។

**មាត្រា ៤៣.-**

ការគ្រោងនៃតម្រូវការថវិកា ត្រូវផ្អែកលើគោលការណ៍ច្បាប់ និងគោលបំណងនៃគោលនយោបាយ កម្មវិធីសកម្មភាព និងលទ្ធផលរំពឹងទុកដោយហ្មត់ចត់ និងច្បាស់លាស់ ។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវបង្កើតនិយាម និងឯកតារង្វាស់សម្រាប់រាល់សកម្មភាពការងារ ដែលមានលក្ខណៈផ្សេងៗគ្នា


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ព្រមទាំងសម្រាប់ទ្រព្យ និង សេវា ដោយសហការជាមួយក្រសួង ស្ថាប័ន អង្គភាពសាធារណៈ ប្រហាក់ប្រហែលពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ។

**មាត្រា ៤៤.-**

ចំណាយមូលធនត្រូវផ្អែកលើកម្មវិធី ឬ គម្រោងដោយឡែកៗដែលមានការយល់ព្រមជាមុន និងដែលត្រូវបានរៀបចំឡើងសំដៅសម្រេចឱ្យបាននូវគោលបំណង ដែលបានកំណត់ក្នុងរបៀបវារៈគោលនយោបាយរបស់រាជរដ្ឋាភិបាល ។ កម្មវិធី ឬ គម្រោងទាំងអស់នោះ គឺជាមូលដ្ឋានសម្រាប់វាយតម្លៃចំណាយមូលធនសរុបរបស់កម្មវិធី និងគម្រោង និងសម្រាប់កំណត់រយៈពេលនៃការសន្យា និងការទូទាត់សម្រាប់ដំណាក់កាលនីមួយៗក្នុងឆ្នាំ ។

**មាត្រា ៤៥.-**

ដើម្បីគោរពតាមប្រតិទិននៃមាត្រា ៣៩ នៃច្បាប់នេះ ក្នុងការរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានសិទ្ធិក្នុងការគ្រោងចំណូល ចំណាយរបស់រដ្ឋបាលថ្នាក់ជាតិ និង រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលមិនបានលើកគម្រោងចំណូល ចំណាយរបស់ខ្លួនតាមកាលកំណត់ដោយផ្អែកលើលទ្ធផលនៃឆ្នាំកំពុងអនុវត្ត ។

**មាត្រា ៤៦.-**

សេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ដែលត្រូវដាក់ជូនរដ្ឋសភា និងព្រឹទ្ធសភា ត្រូវភ្ជាប់មកជាមួយនូវៈ

១- របាយការណ៍វិភាគពីនិន្នាការ និងការវិវត្តរួមនៃស្ថានភាពសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈបច្ចុប្បន្ន និង ការវិភាគលើចរិតលក្ខណៈនៃថវិកាថ្មី ព្រមទាំងបញ្ជាក់អំពីការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច សមតាហិរញ្ញវត្ថុ និង រូបិយវត្ថុជាសារវ័ន្ត ពិសេសតុល្យភាពថវិកា ។

២- របាយការណ៍ទាំងឡាយ ដែលទាក់ទងទៅនឹងនិន្នាការចំណាយចរន្តដោយវិភាគ និងបង្ហាញពីស្ថានភាពឥណទានពាក់ព័ន្ធនឹងការអនុម័តឆ្នាំមុនទៅនឹងតម្រូវការ និងវិធានការថ្មី ដែលមានសារសំខាន់ចាំបាច់សម្រាប់ការគ្រប់គ្រងថ្មី ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

៣- កម្រងកម្មវិធី និងគម្រោងចំណាយមូលធន ដែលរំលេចនូវឥណទានវិនិយោគ ឥណទានភ្ជាប់សន្យា និង ឥណទានទូទាត់សម្រាប់កម្មវិធី និង គម្រោងក្នុងឆ្នាំ ការគ្រោងបម្រុង ឥណទានដែលមានប្រភេទដូចគ្នា ចាំបាច់សម្រាប់បន្តកម្មវិធី និងគម្រោងទាំងនេះ និងការវិភាគកម្មវិធី និងគម្រោងថ្មី ព្រមទាំងតម្រូវការឥណទានសម្រាប់កម្មវិធី និងគម្រោងថ្មីទាំងនេះ ដោយកំណត់តាមប្រតិទិនប្រើប្រាស់ដែលបានគ្រោងទុក ។

៤- ឯកសារពាក់ព័ន្ធផ្សេងៗទៀត ដែលចាំបាច់សម្រាប់ជាព័ត៌មាន និងសម្រាប់ការត្រួតពិនិត្យរបស់រដ្ឋសភា និងព្រឹទ្ធសភា ។

**មាត្រា ៤៧.-**

សេចក្ដីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ចែកចេញជាពីរផ្នែកៈ

ផ្នែកទី ១ សេចក្ដីព្រាងច្បាប់អនុញ្ញាតឱ្យប្រមូលគ្រប់ធនធានសាធារណៈ និងកំណត់ធនធានទាំងនោះ ជាទឹកប្រាក់សរុប ។ សេចក្ដីព្រាងច្បាប់ត្រូវកំណត់ទិសដៅ និង មធ្យោបាយអនុវត្តចំពោះចំណាយមូលធន ។ សេចក្ដីព្រាងច្បាប់បានកំណត់នូវឥណទានត្រូវផ្ដល់ខ្ពស់បំផុត ដែលជាគុណប្រយោជន៍ដល់ថវិការដ្ឋ និងគណនីពិសេសរបស់រតនាគារជាតិ ។ សេចក្ដីព្រាងច្បាប់រួមមានបទប្បញ្ញត្តិទាំងឡាយ ដែលទាក់ទងដល់ចំណូលសារពើពន្ធចំណូល មិនមែនសារពើពន្ធ ចំណូលមូលធន និងទាក់ទងដល់គ្រប់បទប្បញ្ញត្តិហិរញ្ញវត្ថុផ្សេងៗទៀត ។

ផ្នែកទី ២ រួមមានតារាងបែងចែកជាក្រុមប្រភេទជំពូកគណនី និង អនុគណនី ដែលទាក់ទងដល់ចំណូលនៃថវិការដ្ឋ ។ សេចក្ដីព្រាងច្បាប់មានគម្រោងចំណាយចរន្តរបស់ថវិការដ្ឋ បែងចែកទៅតាមក្រសួង ស្ថាប័ន និង អង្គភាពសាធារណៈ ប្រហាក់ប្រហែល ហើយបែងចែកទៅតាមប្រភេទចំណាយដែលត្រូវអនុម័ត ។ សេចក្ដីព្រាងច្បាប់មានគម្រោងចំណាយមូលធនបែងចែកទៅតាមក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈប្រហាក់ប្រហែល និងជាជំពូកដែលចែកចេញជាឥណទានភ្ជាប់សន្យា និងឥណទានទូទាត់ ។ សេចក្ដីព្រាងច្បាប់ត្រូវកំណត់បញ្ជីគណនី ពិសេសរបស់រតនាគារជាតិ ដែលមានលក្ខណៈរដ្ឋបាល និងកំណត់គណនីពិសេសនីមួយៗនូវចំនួនទឹកប្រាក់ចំណូល និងចំនួនទឹកប្រាក់ចំណាយ ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

**មាត្រា ៤៧.-**

ច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ត្រូវអនុម័តដោយរដ្ឋសភា និងពិនិត្យដោយព្រឹទ្ធសភា និងត្រូវប្រកាសឱ្យប្រើដោយព្រះរាជក្រម ហើយត្រូវបោះផ្សាយឱ្យអនុវត្តជាច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៤៨.-**

ប្រសិនបើសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ មិនត្រូវបានអនុម័តមុនថ្ងៃទី ០១ ខែ មករា នៃឆ្នាំការិយបរិច្ឆេទ ទេនោះ ថវិកាឆ្នាំមុនត្រូវបានបន្តដោយស្របច្បាប់ក្នុងលក្ខខណ្ឌដូចខាងក្រោម៖

១- ចំណូលសារពើពន្ធ ចំណូលមិនមែនសារពើពន្ធ និងចំណូលគ្រប់ប្រភេទផ្សេងទៀត ត្រូវបានអនុញ្ញាត និង បន្តឱ្យប្រមូលក្នុងលក្ខខណ្ឌ និងតាមបែបបទដែលបានកំណត់ក្នុងច្បាប់ហិរញ្ញវត្ថុពីមុន និងក្នុងក្របខ័ណ្ឌច្បាប់ ព្រមទាំងបទបញ្ញាដែលមានជាធរមាន ។

២- ចំណាយចរន្តក្រៅពីបន្ទុកបំណុលសាធារណៈ នៅតែបន្តអនុវត្តតាមក្របខ័ណ្ឌនៃថវិកាឆ្នាំមុន ដោយគិតតាមវិធីមួយភាគដប់ពីរជាបណ្តោះអាសន្នក្នុងខែនីមួយៗរហូតដល់ថវិកាថ្មីត្រូវបានអនុម័ត ។

៣- ចំណាយមូលធននៃថវិកាក្រៅពីរំលស់បំណុលសាធារណៈ នៅតែបន្តអនុវត្តតាមក្របខ័ណ្ឌនៃថវិកាឆ្នាំមុន ក្នុងក្របខ័ណ្ឌឥណទានទូទាត់ដែលនៅទំនេរ ហើយអាចលើសពីនេះ ប្រសិនបើចាំបាច់ដោយមិនឱ្យការទូទាត់នោះ លើសពីកំរិតឥណទានភ្ជាប់សន្យាដែលបានអនុម័តក្នុងថវិកាឆ្នាំមុន ។

៤- ចំណាយទាំងឡាយ ដែលជាកាតព្វកិច្ចទាក់ទងទៅនឹងសមាជិកភាពរបស់កម្ពុជា ក្នុងស្ថាប័នអន្តរជាតិ និង អន្តររដ្ឋាភិបាល និងកាតព្វកិច្ចទាក់ទងទៅនឹងបន្ទុកបំណុលសាធារណៈ រួមមានការរំលស់ប្រាក់ដើម ការបង់ការប្រាក់ កម្រៃសេវា និង/ ឬ ការបង់ពិន័យជាយថាហេតុ ត្រូវបានរ៉ាប់រងជាបន្តមិនឱ្យដាច់តាមកិច្ចព្រមព្រៀងជាធរមាន ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ផ្នែកទី ៣

# សិទ្ធិអំណាច និងការទទួលខុសត្រូវ

**មាត្រា ៤៩.-**

ច្បាប់ហិរញ្ញវត្ថុ ត្រូវអនុម័តក្នុងលក្ខខណ្ឌដូចគ្នានឹងច្បាប់ដទៃទៀតដែរ លើកលែងតែករណីពិសេស ដូចខាង ក្រោម៖

គម្រោងចំណូល ត្រូវអនុម័តសរុបជាកញ្ចប់ទាំងសម្រាប់ចំណូលចរន្តទាំងសម្រាប់ ចំណូលមូលធន

គម្រោងចំណាយ ត្រូវអនុម័តជាសរុបទាំងប្រភេទចំណាយចរន្ត ទាំងប្រភេទចំណាយមូលធន លើបញ្ជី ក្រសួង ស្ថាប័ន ឬ អង្គភាពសាធារណៈ ប្រហាក់ប្រហែល

ចំពោះគណនីពិសេសរបស់រតនាគារជាតិ ត្រូវអនុម័តសរុបជាកញ្ចប់លើបញ្ជីនៃគណនីទាំងអស់ដែល មាន

បទប្បញ្ញត្តិទាំងអស់នៃច្បាប់ហិរញ្ញវត្ថុជាកម្មវត្ថុនៃការអនុម័តចុងក្រោយបង្អស់ ។

**មាត្រា ៥០.-**

គ្មានវិសោធនកម្មណាមួយ លើសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុ អាចត្រូវបានអនុញ្ញាតអោយធ្វើនោះទេ ប្រសិនបើវិសោធនកម្មនោះ ធ្វើអោយប៉ះពាល់ដល់តុល្យភាពនៃគម្រោងថវិកាដែលបានស្នើឡើង ។ វិសោធនកម្មប្រភេទនេះ អាចធ្វើទៅបានតែក្នុងលក្ខខណ្ឌដូចខាងក្រោម៖

សំណើចំណាយថ្មី ត្រូវបានប៉ះប៉ូវដោយការលុបចេញ ឬ បន្ថយចំណាយណាមួយផ្សេងទៀត ដើម្បីរក្សា តុល្យភាពថវិកា

សំណើចំណាយថ្មី ត្រូវបានធ្វើឡើងដោយមានភ្ជាប់ជាមួយនូវសំណើសន្សំសំចៃលើប្រភេទចំណាយណាមួយដែលបានស្នើឡើងរួចហើយ ដើម្បីរក្សាតុល្យភាពថវិកា

សំណើចំណាយថ្មី ត្រូវបានធ្វើឡើងដោយមានភ្ជាប់ជាមួយនូវសំណើបង្កើតមុខចំណូលថ្មី ឬ បង្កើនចំណូល ដើម្បីរក្សាតុល្យភាពថវិកា



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

វិសោធនកម្មដែលធ្វើឡើងផ្ទុយនឹងបទប្បញ្ញត្តិខាងលើនៃមាត្រានេះ នឹងត្រូវបានបដិសេធ ហើយទុកជាមោឃៈ ។

**មាត្រា ៥១.-**

ការបែងចែកឥណទានជាជំពូក ត្រូវធ្វើឡើងដោយអនុក្រឹត្យ ។ អនុក្រឹត្យបែងចែកនេះ មិនអាចនាំឱ្យមានការ ប្រែប្រួលឥណទាន ដែលត្រូវបានកំណត់ដោយច្បាប់ ។

**មាត្រា ៥២.-**

ការបែងចែកឥណទានលម្អិតនៅក្នុងជំពូកជាគណនី និងអនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ជំពូកទី ៤

## ការអនុវត្តថវិកា

### ផ្នែកទី ១

### ក្របខ័ណ្ឌនៃការអនុវត្តថវិកា

**មាត្រា ៥៣.-**

ការផ្ទេរឥណទានពីក្រសួង ស្ថាប័ន ឬ អង្គភាពសាធារណៈប្រហាក់ប្រហែលមួយទៅមួយទៀត ត្រូវកំណត់ ដោយច្បាប់ហិរញ្ញវត្ថុ ។ ប៉ុន្តែការផ្ទេរឥណទានពីក្រសួងមួយ ពីស្ថាប័ន ឬ ពីអង្គភាពសាធារណៈ ប្រហាក់ប្រហែល មួយទៅមួយទៀត ដោយភាពចាំបាច់នៃការងារពង្រឹងរចនាសម្ព័ន្ធ ឬ រដ្ឋបាលរបស់រាជរដ្ឋាភិបាល អាចប្រព្រឹត្តទៅបានដោយអនុក្រឹត្យ ក្នុងករណីការផ្ទេរឥណទាននេះ មិនកែប្រែមុខចំណាយ និងការបែងចែកឥណទានតាមជំពូក នីមួយៗទេ ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

**មាត្រា ៥៤.-**

ការបង្វែរឥណទានពីជំពូកមួយទៅជំពូកមួយ នៅផ្ទៃក្នុងថវិការបស់ក្រសួង ស្ថាប័ន ឬ អង្គភាពសាធារណៈ ប្រហាក់ប្រហែលត្រូវធ្វើឡើងដោយអនុក្រឹត្យ ក្នុងករណីមិនកែប្រែឥណទានចំណាយមូលធនសម្រាប់វិនិយោគទៅ ជាឥណទានចំណាយចរន្តសម្រាប់ដំណើរការ ។

**មាត្រា ៥៥.-**

ការបង្វែរឥណទានពីគណនីមួយទៅគណនីមួយ ឬ ពីអនុគណនីមួយទៅអនុគណនីមួយនៅក្នុងជំពូកតែមួយ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ៥៦**

អនុក្រឹត្យដែលធ្វើឡើងតាមសំណើរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចបែងចែកឥណទានថវិកា ដែលកត់ត្រានៅក្នុងចំណាយមិនបានគ្រោងទុកក្រោមរូបភាពនៃឥណទានបន្ថែម ជាគុណប្រយោជន៍ដល់ជំពូកផ្សេងៗរបស់ក្រសួង ស្ថាប័ន ឬ អង្គភាពសាធារណៈ ប្រហាក់ប្រហែលនានា ។

**មាត្រា ៥៩.-**

ឥណទានដែលលែងមានមុខសញ្ញាប្រើប្រាស់ នៅក្នុងការិយបរិច្ឆេទនៃឆ្នាំថវិកា អាចត្រូវបានលុបចោលដោយ ប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រោយពីបានទទួលព័ត៌មានពីរដ្ឋបាលថ្នាក់ជាតិ ឬ រដ្ឋបាលថ្នាក់ក្រោមជាតិ ។

**មាត្រា ៦០.-**

នៅពេលដែលការវិវត្តនៃចំណូល និងចំណាយស្តែងចេញឱ្យឃើញនូវការបាត់តុល្យភាពថវិការដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចចេញជាប្រកាស ដើម្បីបង្កកមួយចំណែក ឬ ទាំងស្រុងនៃប្រភេទឥណទានមួយចំនួន ដែលបានអនុម័តនៅក្នុងច្បាប់ហិរញ្ញវត្ថុ ។ ក្នុងករណីដែលការបាត់តុល្យភាពនេះ មានលក្ខណៈធ្ងន់ធ្ងររាជរដ្ឋាភិបាល អាចធ្វើនីតិវិធីតាមអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រី



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយលុបចោល មួយចំណែក ឬ ទាំងស្រុងនៃប្រភេទឥណទានមួយចំនួនដែលបានអនុម័តក្នុងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ។

**មាត្រា ៥៩.-**

ក្នុងករណីដែលមានគ្រោះធម្មជាតិ ឬ ភាពចាំបាច់ជាបន្ទាន់ដល់ផលប្រយោជន៍ជាតិ ដោយផ្អែកលើរបាយការណ៍របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រាជរដ្ឋាភិបាលអាចចេញអនុក្រឹត្យបន្ថែមឥណទាន ដើម្បីប្រើប្រាស់ ។ ឥណទាននេះ ត្រូវអនុម័តដោយច្បាប់កែតំរូវនៃច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ដែលរាជរដ្ឋាភិបាលត្រូវសុំការយល់ព្រមពីរដ្ឋសភា និងព្រឹទ្ធសភាភ្លាម នៅពេលដែលស្ថានការណ៍ពិសេសទាំងនេះត្រូវបានចប់សព្វគ្រប់ ។

ដោយបដិបញ្ញត្តិនៃកថាខណ្ឌខាងលើនៃច្បាប់នេះ បើច្បាប់កែតម្រូវនៃច្បាប់ហិរញ្ញវត្ថុនេះ ពុំអាចធ្វើទៅកើត ក្នុងត្រីមាសទី ៤ នៃការិយបរិច្ឆេទនៃច្បាប់ហិរញ្ញវត្ថុ ប្រចាំឆ្នាំសម្រាប់ការគ្រប់គ្រងឆ្នាំនីមួយៗឥណទានទាំងនេះ ជាកម្មវត្ថុនៃនិយ័តភាវូបនីយកម្មក្នុងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំបន្ទាប់ ។

**មាត្រា ៦០.-**

ការកែប្រែផ្សេងៗទៀត លើច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំអាចធ្វើទៅបាននៅក្នុងអំឡុងពេលនៃឆ្នាំថវិកាតាមរយៈច្បាប់កែតម្រូវនៃច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ដែលត្រូវដាក់ជូនរដ្ឋសភា និងព្រឹទ្ធសភាអនុម័តដូចការអនុម័តច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំដែរ ។

## ផ្នែកទី ២

## ដំណើរការនៃការអនុវត្តថវិកា

**មាត្រា ៦១.-**

ការអនុវត្តកិច្ចប្រតិបត្តិការហិរញ្ញវត្ថុរបស់រដ្ឋ និងគណនីពិសេសរបស់រតនាគារជាតិ ជាភារកិច្ចរបស់អាណាប័ក និងគណនេយ្យករសាធារណៈ ។ អាណាប័ក និងគណនេយ្យករសាធារណៈមានមុខងារវិសមិតភាពនឹងគ្នា ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

រដ្ឋមន្ត្រី ប្រធានស្ថាប័ន និងប្រធានអង្គភាពសាធារណៈ ប្រហាក់ប្រហែលជាអាណាប័កដើមខ្សែនៃថវិការបស់ខ្លួនទាំងនៅរដ្ឋបាលថ្នាក់ជាតិ និងទាំងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ តាមខ្សែបណ្តោយដែលស្ថិតក្រោមឱវាទ ។ អាណាប័កដើមខ្សែជាអ្នកបញ្ជាចំណូល និងបញ្ជាចំណាយថវិកាតាមផ្នែករៀងៗខ្លួន ។

រដ្ឋមន្ត្រី ប្រធានស្ថាប័ន និង ប្រធានអង្គភាពសាធារណៈ ប្រហាក់ប្រហែល ដែលជាអាណាប័កដើមខ្សែនៃថវិការបស់ខ្លួន អាចប្រគល់សិទ្ធិជូនអភិបាលរដ្ឋបាលថ្នាក់ក្រោមជាតិ ជាអាណាប័កផ្ទេរសិទ្ធិសម្រាប់កិច្ចប្រតិបត្តិការហិរញ្ញវត្ថុនៃថវិកាក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។ រដ្ឋមន្ត្រី ប្រធានស្ថាប័ន និងប្រធានអង្គភាពសាធារណៈ ប្រហាក់ប្រហែល ដែលជាអាណាប័កដើមខ្សែនៃថវិការបស់ខ្លួនអាចប្រគល់សិទ្ធិជូនប្រធានអង្គភាពក្រោមឱវាទប្រធានមន្ទីរ ជំនាញខេត្ត និងរាជធានី ជាអាណាប័កផ្ទេរសិទ្ធិសម្រាប់កិច្ចប្រតិបត្តិការហិរញ្ញវត្ថុនៃថវិកា បន្ទាប់ពីមានការយល់ព្រមជាមុនពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ក្នុងករណីអាណាប័កដើមខ្សែ ឬ អាណាប័កតាមការប្រទានសិទ្ធិអវត្តមាន ឬ មានធុរៈអាចជ្រើសតាំងប្រភេទមន្ត្រីរាជការ ដើម្បីផ្ទេរសិទ្ធិ ឬ ជំនួសខ្លួនដោយផ្អែកលើបទបញ្ជាគណនេយ្យសាធារណៈ ។ ការផ្ទេរសិទ្ធិ ឬ ការចុះហត្ថលេខា ត្រូវធ្វើឡើងដោយប្រកាស បន្ទាប់ពីមានការយល់ព្រមជាមុន ពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

**មាត្រា ៦២.-**

ចំណាយលើថវិការដ្ឋ និង លើគណនីពិសេសរបស់រតនាគារជាតិ ជាកម្មវត្ថុនៃការឆ្លងទិដ្ឋាការពីមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលបានទទួលការតែងតាំងពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។ គោលបំណង និងហេតុផលជាក់ស្តែងនៃការត្រួតពិនិត្យនេះព្រមទាំងវិធីសាស្ត្រនៃកិច្ចប្រតិបត្តិការ ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

**មាត្រា ៦៣.-**

ចំណាយថវិការដ្ឋ រួមទាំងថវិកាថ្នាក់ជាតិ និងថវិកាថ្នាក់ក្រោមជាតិ និងថវិកាគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងគណនីពិសេសរបស់រតនាគារជាតិ ក្នុងការទិញ ការជួសជុល ការសាងសង់


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

និងការជួលសេវា ត្រូវអនុវត្តតាមវិធីសាស្ត្រ និង នីតិវិធីលទ្ធកម្មសាធារណៈ ដែលត្រូវបានកំណត់ដោយច្បាប់ និង បទប្បញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈ ។

## ផ្នែកទី ៣

## សិទ្ធិអំណាច និង ការទទួលខុសត្រូវ

**មាត្រា ៦៤.-**

រដ្ឋមន្ត្រី ប្រធានស្ថាប័ន និងប្រធានអង្គភាពសាធារណៈ ប្រហាក់ប្រហែលព្រមទាំងអភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ មានកាតព្វកិច្ចទទួលខុសត្រូវចំពោះការអនុវត្តថវិការបស់ខ្លួន ។ ចំពោះការប្រមូលចំណូល និង ការអនុវត្តចំណាយត្រូវគោរពទៅតាមព្រំដែននៃសិទ្ធិអំណាចរបស់ខ្លួនដែលច្បាប់បានកំណត់ ។

**មាត្រា ៦៥.-**

ស្ថិតក្រោមកម្រិតកំណត់នៃច្បាប់ហិរញ្ញវត្ថុ និងក្រោមអំណាចរបស់នាយករដ្ឋមន្ត្រី មានតែរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមួយគត់ ដែលមានសិទ្ធិក្នុងការខ្ចីប្រាក់ពីគេ ការបោះផ្សាយមូលបត្ររដ្ឋ ការទទួលហិរញ្ញប្បទានឥតសំណង ការវិនិយោគលើអចលកម្មហិរញ្ញវត្ថុ ការធានា និងការសន្យាផ្នែកហិរញ្ញវត្ថុនានា និងមានសិទ្ធិ ក្នុងការឱ្យប្រាក់គេខ្ចីទាំងក្នុង និងក្រៅប្រទេស ។ គ្មានរដ្ឋមន្ត្រីដទៃណាទៀត ប្រធានស្ថាប័ន ប្រធានអង្គភាពសាធារណៈប្រហាក់ប្រហែល ប្រធានសហគ្រាសសាធារណៈ អភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ឬ មន្ត្រីសាធារណៈណាមួយ មានសិទ្ធិក្នុងការខ្ចីប្រាក់ពីគេ ឬ ឱ្យប្រាក់គេខ្ចី ឬ ចេញជាលិខិតធានា ឬ ក៏ធ្វើទង្វើណាផ្សេងៗ ទៀតដោយផ្ទាល់ ឬ ដោយប្រយោល ដែលអាចនាំឱ្យកើតមាននូវបំណុល ឬ បន្ទុកហិរញ្ញវត្ថុផ្សេងទៀត ដោយផ្ទាល់ ឬ ដោយប្រយោលដល់ព្រះរាជាណាចក្រកម្ពុជាបានទេ ។

**មាត្រា ៦៦.-**



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ស្ថិតក្រោមកម្រិតកំណត់នៃច្បាប់ហិរញ្ញវត្ថុ និងក្រោមអំណាចរបស់នាយករដ្ឋមន្ត្រី មានតែរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតែមួយគត់ ដែលមានសិទ្ធិរៀបចំកម្មវិធីដោះស្រាយបំណុលដែលរដ្ឋជំពាក់គេ ឬ បំណុល ដែលគេជំពាក់រដ្ឋ ។ ការរៀបចំកម្មវិធីដោះស្រាយបំណុលត្រូវកំណត់ដោយច្បាប់ហិរញ្ញវត្ថុ ។

**មាត្រា ៦៧.-**

លក្ខខណ្ឌផ្នែកហិរញ្ញវត្ថុ និងទំហំទឹកប្រាក់នៃការខ្ចីប្រាក់ពីគេ នៃការឱ្យប្រាក់គេខ្ចីនៃការបោះផ្សាយមូលបត្ររដ្ឋ នៃការធានា និងនៃការសន្យាផ្នែកហិរញ្ញវត្ថុនានាត្រូវកំណត់ដោយច្បាប់ហិរញ្ញវត្ថុ ។

**មាត្រា ៦៨.-**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានភារកិច្ចគ្រប់គ្រងលទ្ធកម្មសាធារណៈ និងណែនាំក្នុងការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ ។ ក្រសួង ស្ថាប័ន អង្គភាព សាធារណៈប្រហាក់ប្រហែល ស្ថាប័នថ្នាក់ក្រោមជាតិ គ្រឹះស្ថានសាធារណៈ និងសហគ្រាសសាធារណៈ ត្រូវគោរពតាមច្បាប់ អនុក្រឹត្យ ប្រកាស និងសេចក្តីណែនាំទាំងឡាយ ស្តីពីលទ្ធកម្មសាធារណៈ ។

## ជំពូកទី ៥

## គណនេយ្យ និង ការត្រួតពិនិត្យលទ្ធផល

### ផ្នែកទី ១

### ក្របខ័ណ្ឌគណនេយ្យ និង ការទូទាត់ថវិកា

**មាត្រា ៦៩.-**

គោរពតាមគោលការណ៍គណនេយ្យភាព រដ្ឋមន្ត្រី ប្រធានស្ថាប័ន ប្រធាន អង្គភាពសាធារណៈប្រហាក់ប្រហែល និងអភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ មានភារកិច្ចរៀបចំ និងផ្តល់ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នូវរបាយការណ៍ស្តីពីការអនុវត្តថវិកា របាយការណ៍ស្តីពីការអនុវត្តគម្រោង


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ដែលពាក់ព័ន្ធនឹងការខ្ចីប្រាក់គេ ការបោះផ្សាយមូលបត្ររដ្ឋ ការធានា និង ការសន្យានានាផ្នែកហិរញ្ញវត្ថុ ការទទួលហិរញ្ញប្បទានឥតសំណង និង ដែលពាក់ព័ន្ធនឹងចំណូលមានប្រភពមកពីការវិនិយោគលើអចលកម្មហិរញ្ញវត្ថុ និងព័ត៌មានចាំបាច់ផ្សេងៗទៀត តាមតម្រូវការរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានកាតព្វកិច្ចកំណត់កាលបរិច្ឆេទនៃការផ្តល់ និង គំរូនៃរបាយការណ៍ ដូចមានចែងក្នុងវាក្យខណ្ឌខាងលើនៃមាត្រានេះ ដើម្បីជូនរដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័ន ប្រធានគ្រប់អង្គភាពសាធារណៈប្រហាក់ប្រហែល និងអភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិអនុវត្ត ។

**មាត្រា ៧០.-**

រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័ន ប្រធានគ្រប់អង្គភាពសាធារណៈ ប្រហាក់ប្រហែល ប្រធានសហគ្រាសសាធារណៈ និងអភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ មានកាតព្វកិច្ចទទួលខុសត្រូវក្នុងការរៀបចំក្របខ័ណ្ឌ និង គ្រប់គ្រងកិច្ចប្រតិបត្តិការ ការត្រួតពិនិត្យផ្ទៃក្នុងរបស់ខ្លួន ដើម្បីធានាភាពត្រឹមត្រូវ និងស្របតាមបទដ្ឋាន បទប្បញ្ញត្តិ និងសេចក្តីណែនាំរបស់រាជរដ្ឋាភិបាល ។

ដោយឡែក រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានកាតព្វកិច្ចទទួលខុសត្រូវក្នុងការណែនាំអំពីការរៀបចំក្របខ័ណ្ឌកិច្ចប្រតិបត្តិការត្រួតពិនិត្យផ្ទៃក្នុងរបស់ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល សហគ្រាសសាធារណៈ និងរដ្ឋបាលថ្នាក់ក្រោមជាតិ និងមានភារកិច្ចធ្វើអធិការកិច្ចហិរញ្ញវត្ថុនៅតាមក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល សហគ្រាសសាធារណៈ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ។

**មាត្រា ៧១.-**

កិច្ចប្រតិបត្តិការហិរញ្ញវត្ថុ និងគណនេយ្យសាធារណៈ ទាំងរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវប្រមូលផ្តុំនៅរតនាគារជាតិ និងអនុវត្តដោយគណនេយ្យករសាធារណៈ ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

**មាត្រា ៧២.-**

ប្រព័ន្ធគណនេយ្យសាធារណៈ ត្រូវមានសង្គតិភាពទៅនឹងនិយាមគណនេយ្យអន្តរជាតិ ដែលមានការទទួលស្គាល់ជាទូទៅ ហើយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវចេញប្រកាសកំណត់ប្រព័ន្ធគណនេយ្យនេះ ។

**មាត្រា ៧៣.-**

បទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ ត្រូវកំណត់គ្រប់លក្ខខណ្ឌដែលធ្វើឱ្យប្រតិបត្តិការគណនេយ្យ និង ហិរញ្ញវត្ថុ អាចកត់ត្រាវិភាគ និងគ្រប់គ្រងការអនុវត្តច្បាប់ហិរញ្ញវត្ថុ ប្រកបដោយគណនេយ្យភាព ភាពស័ក្តិសិទ្ធិ និង ប្រសិទ្ធភាព ។

**មាត្រា ៧៤.-**

ការទូទាត់ថវិកា គឺជាកម្មវត្ថុនៃច្បាប់ ។

**មាត្រា ៧៥.-**

សេចក្តីព្រាងច្បាប់ទូទាត់ថវិកា ពិនិត្យកត់ត្រានូវចំនួនទឹកប្រាក់ជាស្ថាពរនៃចំណូលដែលបានបង់ចូលក្នុងគណនីទោលរបស់រតនាគារជាតិ និងអាណាប័ណ្ណចំណាយដែលបានប្រព្រឹត្តទៅក្នុងការិយបរិច្ឆេទនៃឆ្នាំថវិកា ។ សេចក្តីព្រាងច្បាប់នេះ ទុកជាមោឃៈនូវឥណទានដែលមិនបានប្រើប្រាស់ ហើយលើកឡើងឱ្យឃើញនូវលទ្ធផលហិរញ្ញវត្ថុពិតនៃឆ្នាំ ដោយធ្វើការកត់ត្រាទៅក្នុង «គណនីលទ្ធផល» របស់រតនាគារជាតិ ។

**មាត្រា ៧៦.-**

សេចក្តីព្រាងច្បាប់ទូទាត់ថវិកា ត្រូវរៀបចំដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទៅតាមមាតិកាថវិកា នីមួយៗដោយផ្អែកលើទិន្នន័យចំណូល ចំណាយដែលរាយការណ៍ដោយគណនេយ្យករសាធារណៈ ក្រោយពីបានធ្វើការផ្ទៀងផ្ទាត់ត្រឹមត្រូវជាមួយអាណាប័កពាក់ព័ន្ធ ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

**មាត្រា ៧៧.-**

ក្របខ័ណ្ឌ និង កិច្ចដំណើរការនៃសវនកម្មផ្ទៃក្រៅ ត្រូវអនុវត្តតាមច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៧៨.-**

ប្រតិបត្តិការដែលបង្ហាញនៅក្នុងសេចក្តីព្រាងច្បាប់ទូទាត់ថវិកា ត្រូវឆ្លុះបញ្ចាំងនូវវិធានគណនេយ្យសាធារណៈ តាមលំនាំដូចខាងក្រោម៖

១- ចំពោះចំណូលៈ ការគ្រោងទុកដើមគ្រា ព្រមទាំងការកែប្រែ និងចំណូលជាក់ស្តែង ដែលបែងចែកតាមក្រុម ប្រភេទ ជំពូក គណនី និងអនុគណនី ។

២- ចំពោះចំណាយៈ ការគ្រោងទុកដើមគ្រា ការអនុញ្ញាតថ្មី និងចំណាយជាក់ស្តែងនៅតាមក្រសួង ស្ថាប័ន ឬ អង្គភាពសាធារណៈប្រហាក់ប្រហែល និង រដ្ឋបាលថ្នាក់ក្រោមជាតិ ទៅតាមមាតិកាថវិកា ។

៣- ការប្រៀបធៀបទឹកប្រាក់សរុបនៃការគ្រោងទុកនៃចំណូល និងចំណាយ និងការកែប្រែដែលបានធ្វើ ប្រសិនបើមានជាមួយនឹងលទ្ធផលចុងក្រោយនៃថវិការបស់រដ្ឋបាលសាធារណៈនីមួយៗ ។

ប្រតិបត្តិការដែលបង្ហាញនៅក្នុងសេចក្តីព្រាងច្បាប់ទូទាត់ថវិកា ទាំងថវិការដ្ឋ និងទាំងគណនីពិសេសរបស់រតនាគារជាតិ ត្រូវបង្ហាញជាលម្អិតនូវឥណទានដែលបានអនុម័តដើមឆ្នាំ និងឥណទានកែតម្រូវទៅតាមមាតិកាថវិកា ។

**មាត្រា ៧៩.-**

សេចក្តីព្រាងច្បាប់ទូទាត់ថវិកា ដែលត្រូវដាក់ជូនរដ្ឋសភាសុំការអនុម័ត និងព្រឹទ្ធសភាសុំការពិនិត្យត្រូវភ្ជាប់ ជាមួយនូវៈ

១- របាយការណ៍វិភាគស្តីពីលទ្ធផលនៃការប្រមូលចំណូល និងស្ថានភាពនៃការអនុវត្តចំណាយថវិកា ។


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

២- របាយការណ៍ស្តីពីស្ថានភាពទូទៅនៃសេដ្ឋកិច្ច និង ហិរញ្ញវត្ថុនៅក្នុងឆ្នាំអនុវត្ត និងស្តីពីស្ថានភាពនៃការសម្រេចបាននូវតុល្យភាពម៉ាក្រូសេដ្ឋកិច្ច ។

៣- តារាងតុល្យការរបស់រាជរដ្ឋាភិបាល ។

ក្រោយពីបានប្រកាសឱ្យប្រើច្បាប់ទូទាត់ថវិកា ត្រូវបោះផ្សាយដូចគ្នានឹងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំដែរ ។

## ផ្នែកទី ២

## សិទ្ធិអំណាច និង ការទទួលខុសត្រូវ

**មាត្រា ៨០.-**

គណនេយ្យករសាធារណៈទទួលបន្ទុកប្រមូលចំណូល ទូទាត់ចំណាយរក្សាទុកដាក់មូលនិធិ មូលបត្រ ផលិតផល និងសម្ភារៈដែលជាកម្មសិទ្ធិរបស់ស្ថាប័នសាធារណៈ ។ មានតែគណនេយ្យករសាធារណៈមួយគត់ ដែលមានសិទ្ធិអំណាចក្នុងការអនុវត្តប្រតិបត្តិការទាំងឡាយ និងដោះស្រាយបញ្ហាមូលនិធិពាក់ព័ន្ធដទៃទៀត ជាមួយចំណូលនិង ចំណាយ ។

ក្នុងសមត្ថកិច្ចនេះ គណនេយ្យករសាធារណៈ មានការទទួលខុសត្រូវជាលក្ខណៈបុគ្គល និងជាប្រាក់កាស ។

**មាត្រា ៨១.-**

គណនេយ្យករសាធារណៈ ត្រូវបានតែងតាំងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ គណនេយ្យករសាធារណៈមានអំណាចពិសេសរបស់ខ្លួន ។ មុនចូលកាន់តំណែងគណនេយ្យករសាធារណៈត្រូវតែធ្វើសច្ចាប្រណិធានជាផ្លូវការ តាមបែបបទត្រឹមត្រូវនៅចំពោះមុខអាជ្ញាធរមានសមត្ថកិច្ច ។ អាណាប័កដើមខ្សែ និងអាណាប័ក ផ្ទេរសិទ្ធិព្រមទាំងគណនេយ្យករសាធារណៈដទៃទៀត ត្រូវទទួលស្គាល់គណនេយ្យករសាធារណៈ ដែលបានទទួលការតែងតាំងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

**មាត្រា ៨២.-**

រាល់ការអនុវត្តចំណូល និងចំណាយនៃថវិការដ្ឋ ត្រូវធ្វើឡើងទៅតាមបទប្បញ្ញត្តិ និងសេចក្តីណែនាំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ រាល់ការកត់ត្រាចំណូល និងចំណាយរបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវគោរពទៅតាមប្លង់គណនេយ្យ និងមាតិកាថវិកា ហើយរាល់របាយការណ៍គណនេយ្យ និង ហិរញ្ញវត្ថុ ត្រូវមានតម្លាភាព និងផ្សព្វផ្សាយជាសាធារណៈ ។

រាល់ប្រតិបត្តិការហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានសិទ្ធិចាត់តាំងមន្ត្រីក្រោមឱវាទ ចុះធ្វើអធិការកិច្ចលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តាមក្រសួង ស្ថាប័ន ឬ អង្គភាពសាធារណៈប្រហាក់ប្រហែល សហគ្រាសសាធារណៈ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលបានអនុវត្តប្រតិបត្តិការថវិការដ្ឋ ដើម្បីធានាការប្រមូលបាននូវព័ត៌មាន និងទិន្នន័យច្បាស់លាស់សម្រាប់ការរៀបចំទូទាត់ថវិកាប្រចាំឆ្នាំ ។

## ជំពូកទី ៦

## ទោសប្បញ្ញត្តិ

**មាត្រា ៨៣.-**

មន្ត្រីសាធារណៈគ្រប់ប្រភេទ និងគ្រប់ឋានៈ ដែលបានរកឃើញថាមិនបានគោរពតាមបទប្បញ្ញត្តិនៃច្បាប់នេះ ក្នុងការអនុវត្តមុខងារ និងភារកិច្ចរបស់ខ្លួន ដែលរដ្ឋបានប្រគល់ជូននឹងត្រូវទទួលទណ្ឌកម្មខាងវិន័យទៅតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ដែលមានជាធរមាន ដោយមិនទាន់គិតដល់ទោសព្រហ្មទណ្ឌ និងការទទួលខុសត្រូវផ្នែករដ្ឋប្បវេណីផ្សេងទៀត ។ ក្នុងករណីកំហុសរបស់មន្ត្រីសាធារណៈនោះ បានធ្វើអោយមានការបាត់បង់ប្រាក់កាស ឬ ខូចខាតទ្រព្យសម្បត្តិសាធារណៈនោះតម្លៃនៃការបាត់បង់ ឬ ការខូចខាត រួមទាំងការប្រាក់លើតម្លៃបាត់បង់ ឬ ខូចខាត នេះ នឹងក្លាយជាបំណុលចំពោះមន្ត្រីសាធារណៈនោះ ដែលត្រូវសង និងបង់ចូលថវិការដ្ឋវិញ ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

**មាត្រា ៨៤.-**

មន្ត្រីសាធារណៈដែលបញ្ជាក់នៅក្នុងមាត្រា ៨៥ នៃច្បាប់នេះ រួមបញ្ចូលទាំងមន្ត្រីសាធារណៈដែលកំពុងបម្រើការងារ និងមន្ត្រីសាធារណៈដែលធ្លាប់បានបម្រើការងារ ។

## ជំពូកទី ៧

## អន្តរប្បញ្ញត្តិ

**មាត្រា ៨៥.-**

បទប្បញ្ញត្តិច្បាប់ពាក់ព័ន្ធផ្សេងទៀត ដែលផ្អែកលើមូលដ្ឋានច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ០១ នស ចុះថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ ១៩៩៣ ព្រមទាំងអនុក្រឹត្យ សេចក្តីសម្រេច បទបញ្ជា សារាចរណែនាំរបស់រាជរដ្ឋាភិបាល និង ប្រកាស សារាចរណែនាំផ្សេងៗរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលជាបទដ្ឋានគតិយុត្តគាំទ្រសម្រាប់ការអនុវត្តច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុខាងលើ មានសុពលភាពអនុវត្តរហូតដល់ មានបទប្បញ្ញត្តិច្បាប់ អនុក្រឹត្យ សេចក្តីសម្រេច បទបញ្ជា សារាចរណែនាំរបស់រាជរដ្ឋាភិបាល និងប្រកាស សារាចរណែនាំផ្សេងៗរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មកជំនួសថ្មីតាមស្មារតីនៃច្បាប់នេះ ។

## ជំពូកទី ៨

## អវសានប្បញ្ញត្តិ

**មាត្រា ៨៦.-**

ច្បាប់នេះ ត្រូវមានអាទិភាព ប្រសិនបើមានបទប្បញ្ញត្តិនៃច្បាប់ផ្សេងទៀតមិនស្របគ្នានឹងបទ-ប្បញ្ញត្តិទាំងឡាយនៃច្បាប់នេះ ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

**មាត្រា ៨៧.-**

ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈនេះ ត្រូវជំនួសច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសឱ្យប្រើដោយ ព្រះរាជក្រមលេខ ០១ នស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ និងបទប្បញ្ញត្តិទាំងឡាយដែលជាវិសោធនកម្មនៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ។

**មាត្រា ៨៨.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៨៩.-**

ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨

**ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

ពរល.០៨០៥.៥៣៣

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

បានជម្រាបជូនសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

**ហត្ថលេខា**

**គាត ឈន់**



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia



## បណ្ឌិត ហង់ ជួន ណារ៉ុន

បណ្ឌិត **ហង់ ជួន ណារ៉ុន** បច្ចុប្បន្នជាអនុប្រធានប្រចាំការនៃឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ (ក. ប. ស.) និងជាអគ្គលេខាធិការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

បណ្ឌិត **ហង់ ជួន ណារ៉ុន** បានសិក្សាសេដ្ឋកិច្ចអន្តរជាតិនៅ **សកលវិទ្យាល័យរដ្ឋគៀវ** (Kiev State University) នៅសាធារណៈរដ្ឋអ៊ុយក្រែន និង នៅ **វិទ្យាស្ថានរដ្ឋទំនាក់ទំនងអន្តរជាតិនៃទីក្រុងមូស្គូ** (Moscow State Institute of International Relations)(MGIMO) ពីឆ្នាំ ១៩៨២ ដល់ឆ្នាំ ១៩៩១ ។ បន្ទាប់ពីបានទទួលសញ្ញាប័ត្រអនុបណ្ឌិត និង បណ្ឌិតផ្នែកសេដ្ឋកិច្ចអន្តរជាតិនៅ **វិទ្យាស្ថានរដ្ឋទំនាក់ទំនងអន្តរជាតិនៃទីក្រុងមូស្គូ** លោកបានធ្វើការក្នុងបេសកកម្មការទូត និង នៅស្ថាប័នស្រាវជ្រាវ ជាអ្នកវិភាគសេដ្ឋកិច្ច និងនយោបាយ ។ លោកធ្លាប់ធ្វើជាទីប្រឹក្សារបស់ធនាគារពិភពលោកប្រចាំក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។ នៅឆ្នាំ ២០០៤ លោកបានចូលរៀនក្នុងកម្មវិធីប្រតិបត្តិនៅសាលា **កេណេឌី** (JF Kennedy School) របស់រដ្ឋាភិបាលនៃសកលវិទ្យាល័យ **ហាវ៉ាដ** (Harvard University) និង នៅឆ្នាំ ២០០៨ បានទៅធ្វើកម្មសិក្សានៅ **សាលារដ្ឋបាលជាតិ** នៅទីក្រុងប៉ារីស ។ នៅឆ្នាំ ២០០៧ លោកបានទទួលសញ្ញាប័ត្រជាន់ខ្ពស់ផ្នែកធានារ៉ាប់រងពី **វិទ្យាស្ថានធានារ៉ាប់រងម៉ាឡេស៊ី** និង នៅឆ្នាំ ២០០៨ សញ្ញាប័ត្រជាន់ខ្ពស់ផ្នែកធានារ៉ាប់រងពី **វិទ្យាស្ថានធានារ៉ាប់រង** (CII) នៃចក្រភពអង់គ្លេស ។ គាត់ជាសមាជិកនៃវិទ្យាស្ថានធានារ៉ាប់រងចក្រភពអង់គ្លេស (CII) និង ក៏ជាសមាជិកនៃវិទ្យាស្ថានធានារ៉ាប់រងម៉ាឡេស៊ី (AMII) ផងដែរ ។

បណ្ឌិត **ហង់ ជួន ណារ៉ុន**ធ្លាប់កាន់តំណែងជាច្រើននៅក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដូចជា អ្នកសម្របសម្រួលស្រាវជ្រាវនៃក្រុមទីប្រឹក្សាសេដ្ឋកិច្ច និង ជាអនុប្រធាននាយកដ្ឋានទី១ នៃនាយកដ្ឋានថវិកា និងហិរញ្ញកិច្ច ។ បន្ទាប់មកលោកត្រូវបានតែងតាំងជាអគ្គលេខាធិការរង ទទួលបន្ទុកគោលនយោបាយ រួមមាន គោលនយោបាយហិរញ្ញវត្ថុ និង ហិរញ្ញវត្ថុសាធារណៈ អាស៊ាន ឧស្សាហកម្មហិរញ្ញវត្ថុ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ការវិភាគគោលនយោបាយ ក៏ដូចជាទទួលបន្ទុកខាងចរចាជាមួយ មូលនិធិរូបិយវត្ថុអន្តរជាតិ និង ធនាគារពិភពលោក ។ លោកជាអ្នកនិពន្ធឯកសារ គោលនយោបាយរបស់រដ្ឋាភិបាល និង សៀវភៅស្តីពីសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈកម្ពុជា ។

បណ្ឌិត **ហង់ ជួន ណារ៉ុន** សមាជិក និងប្រធានក្រុមប្រឹក្សាភិបាលនៃសហគ្រាសរបស់រដ្ឋមួយចំនួន ដូចជា **ក្រុមហ៊ុនជាតិធានារ៉ាប់រងបន្តកម្ពុជា ទូរគមនាគមន៍កម្ពុជា** និង **អគ្គិសនីកម្ពុជា** (EDC) ក៏ដូចជាវិទ្យាស្ថានស្រាវជ្រាវ និងអង្គការក្រៅរដ្ឋាភិបាល (NGO) ដូចជា **វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា** (CDRI) **វិទ្យាស្ថានគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍** (CBNRMLI) និង **យុវតារាកម្ពុជា** (Youth Star Cambodia) ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia



## ប៉ាទ្រីក ហ្វ៊ីលបែ - ជីវ៉ាល់ឡុង

លោក **ប៉ាទ្រីក ហ្វ៊ីលបែ - ជីវ៉ាល់ឡុង** ធ្លាប់ធ្វើការជាទីប្រឹក្សាអមក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា ពីខែ ឧសភា ឆ្នាំ ២០០៥ ដល់ ខែ មិនា ឆ្នាំ ២០០៧ ។ លោកមានសញ្ជាតិបារាំង ហើយធ្លាប់បានបំពេញការងារជាទីប្រឹក្សា នៅក្នុងប្រទេសជាច្រើននៅទ្វីបអាហ្វ្រិក ។

លោក **ប៉ាទ្រីក ហ្វ៊ីលបែ - ជីវ៉ាល់ឡុង** ទទួលបរិញ្ញាបត្រផ្នែកវិស្វករ (ម៉េកានិច) ពីវិទ្យាស្ថានជាន់ខ្ពស់ខាងផ្នែកម៉េកានិចនៃទីក្រុងប៉ារីស នៅក្នុងឆ្នាំ ១៩៧០ ។ នៅក្នុងឆ្នាំ ១៩៧៧ លោកបានទទួលសញ្ញាបត្រថ្នាក់អនុបណ្ឌិតខាងផ្នែកគ្រប់គ្រង ពីវិទ្យាស្ថានបារាំងខាងផ្នែកគ្រប់គ្រង ។

លោកធ្លាប់បំពេញភារកិច្ចជាទីប្រឹក្សារបស់រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ ទាំងនៅប្រទេសបារាំង ទាំងនៅអាហ្វ្រិច ។ លោកក៏ធ្លាប់ផ្តល់ទីប្រឹក្សាដល់គណប្រតិភូនៃក្រុមប្រឹក្សាអឺរ៉ុបផងដែរ ។

លោក **ប៉ាទ្រីក ហ្វ៊ីលបែ - ជីវ៉ាល់ឡុង** មានឯកទេសខាងផ្នែកចាត់តាំង និង គ្រប់គ្រងផ្នែកសាធារណៈ និង ផ្នែកឯកជន ។ គាត់មានជំនាញខាងផ្នែកអង្កេតស្ថាប័ន សវនកម្មស្ថាប័ន វិមជ្ឈការ ហិរញ្ញវត្ថុសាធារណៈ និង នីតិសាធារណៈ ព័តិមានវិទ្យា ការគ្រប់គ្រងគម្រោង ក្របខ័ណ្ឌគតិយុត្តិ យុទ្ធសាស្ត្រអភិវឌ្ឍន៍ និង សមាហរណកម្មក្នុងតំបន់ ។

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា

Phone: (855)23 722 664 Fax: (855) 23 427 798

**ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ**

២០៨ អា មហាវិថីព្រះនរោត្តម ខ័ណ្ឌចំការមន រាជធានីភ្នំពេញ

Phone: (855)23 726 449 Fax: (855) 23 726 447


9 789996 350504

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia